ការរៀបចំស្ថាប័នដើម្បី

# ប្រឆាំងអំពើពុករលួយ

## ការសិក្សាបែបប្រៀបធៀប



កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

# ការរៀបចំស្ថាប័នដើម្បី ប្រឆាំងអំពើពុករលួយ

## ការសិក្សាបែបប្រៀបធៀប

រូបភាពក្របក្រៅដោយ : ជីវ៉ាថាម ង៉ាមសុក និង ប្រាចា ជូមពូ

រចនាប្លង់ដោយ : Keen Publishing (Thailand) Co., Ltd.

រក្សាសិទ្ធិ © ២០០៥

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី)
ក្រុមអនុវត្តន៍អភិបាលកិច្ចបែបលទ្ធិប្រជាធិបតេយ្យ
មជ្ឈមណ្ឌលប្រចាំតំបន់របស់អង្គការយូអិនឌីភី នៅទីក្រុងបាងកក
http://regionalcentrebangkok.undp.or.th
UN Service Building
Rajdamnern Nok Avenue
ទីក្រុងបាងកក ១០២០០ ប្រទេសថៃ

ISBN: ៩៧៤-៩៣៦៣២-៣-x

# មាតិកា


**បុព្វកថា** iv

**ផ្នែកទី ១ : ទិដ្ឋភាពទូទៅ និង អនុសាសន៍គោលនយោបាយ**

ពាក្យបំព្រួញ ២
១. សេចក្តីផ្តើម ៣
១.១ សារៈសំខាន់នៃអង្គភាពប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាព ៤
១.២ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងអំពើពុករលួយ និងការរៀបចំស្ថាប័នដើម្បីប្រឆាំងអំពើពុករលួយ ៥
២. ភ្នាក់ងារ ឬគណៈកម្មការពិសេសដើម្បីប្រឆាំងអំពើពុករលួយ ៧
២.១ ឯករាជភាពរបស់ភ្នាក់ងារប្រឆាំងអំពើពុករលួយ ៧
២.២ អាណត្តិការងារ ៩
២.៣ សង្ខេបៈ គុណសម្បត្តិ និងគុណវិបត្តិនៃអង្គភាពឯករាជ្យប្រឆាំងអំពើពុករលួយ ១៣
៣. ស្ថាប័នផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ ១៧
៣.១ ព្រះរាជអាជ្ញា ១៨
៣.២ អគ្គសវនករ ១៩
៣.៣ ទីភ្នាក់ងារកំណែទម្រង់សេវាសាធារណៈ ឬគណៈកម្មការសេវាសាធារណៈ ២០
៣.៤ មន្ត្រីការពារប្រជាពលរដ្ឋ (Ombudsman) ២២
៣.៥ តុលាការ ២៣
៤. បណ្តាប្រទេសដែលមិនមានទីភ្នាក់ងារពិសេសប្រឆាំងអំពើពុករលួយ ២៥
៥. ការសម្របសម្រួល ២៧
៦. សេចក្តីសន្និដ្ឋាន ២៩
គន្ថនិទ្ទេស ៣២

**ផ្នែកទី ២ : សេចក្តីពណ៌នាសង្ខេបរបស់ប្រទេសនីមួយៗ**

ប្រទេសអូស្ត្រាលី (រដ្ឋញូសៅវែល) ៣៥
ប្រទេសបូតស្វាណា ៤៧
ប្រទេសប៊ុលហ្គារី ៥៣
ក្រុងហុងកុង S.A.R. ៦០
ប្រទេសឥណ្ឌូនេស៊ី ៦៧
ប្រទេសឡាតវៀ ៧៣
ប្រទេសលីទុយអានី ៨១
ប្រទេសម៉ាឡេស៊ី ៨៩
ប្រទេសនីហ្សេរីយ៉ា ៩៦
សាធារណរដ្ឋកូរ៉េ ១០៤
ប្រទេសសិង្ហបុរី ១១២
ប្រទេសអាហ្វ្រិកខាងត្បូង ១១៨
រាជាណាចក្រថៃ ១២៦
សាធារណរដ្ឋរួមតង់ហ្សានី ១៣៧

# បុព្វកថា

ជាការពិតណាស់ អំពើពុករលួយមានផលប៉ះពាល់អវិជ្ជមានមកលើការអភិវឌ្ឍ។ អំពើពុករលួយឆ្លុះបញ្ចាំងឱ្យឃើញនូវកង្វះខាតនៃលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងអភិបាលកិច្ច ដែលជះឥទ្ធិពលអវិជ្ជមានទៅលើភាពក្រីក្រ និងសន្តិសុខមនុស្សជាតិ។ អំពើពុករលួយបង្កគ្រោះថ្នាក់ដល់ស្ថេរភាពនៃស្ថាប័នប្រជាធិបតេយ្យ រើសអើងក្នុងការផ្តល់សេវារបស់រដ្ឋាភិបាល ដែលជាកត្តានាំឱ្យរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋជាពិសេសគឺសិទ្ធិជនក្រីក្រ។ ទន្ទឹមនឹងនេះ អំពើពុករលួយក៏ជាឧបសគ្គយ៉ាងធំចំពោះការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ផងដែរ។ អាស្រ័យហេតុនេះ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអឹនឌីភី) ចាត់ទុកសកម្មភាពរបស់ខ្លួនក្នុងវិស័យប្រឆាំងអំពើពុករលួយនេះថាជាសកម្មភាពដ៏មានសារៈសំខាន់ចំពោះការពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យ ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និងការការពារសិទ្ធិមនុស្ស។ នេះក៏ជាការអនុវត្តតាមការឯកភាពគ្នាជាឯកច្ឆ័ន្ទ និងដ៏ទូលំទូលាយនៅក្នុងសហគមន៍អន្តរជាតិ ដែលថា អភិបាលកិច្ចល្អមានសារៈសំខាន់យ៉ាងចាំបាច់ក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្រ។ ការកាត់បន្ថយអំពើពុករលួយក៏នឹងបង្កើនប្រសិទ្ធភាពនៃជំនួយនៅក្នុងប្រទេសដៃគូទាំងឡាយរបស់អង្គការយូអឹនឌីភី។

ចាប់តាំងពីឆ្នាំ ១៩៩៧ មកអង្គការយូអឹនឌីភីបានរួមការងារនៅក្នុងកម្មវិធីគណនេយ្យភាព តម្លាភាព និងសុចរិតភាព (ATI) ដែលជាផ្នែកមួយនៃអន្តរាគមន៍របស់យើងដើម្បីពង្រឹងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ នៅក្នុងឆ្នាំកន្លងមកអន្តរាគមន៍របស់អង្គការយូអឹនឌីភីនៅក្នុងវិស័យ ATI និងការប្រឆាំងអំពើពុករលួយបានប្រែក្លាយពីគោលការណ៍គាំទ្រការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ មកជាការផ្តល់យោបល់ជូនប្រទេសជាដៃគូ តាមវិធីសាស្ត្រទូលំទូលាយ ដោយផ្អែកលើមេរៀនពីមុនៗ និងឧបករណ៍គោលនយោបាយដែលកសាងផ្ទៃក្នុង។

ការវិវត្តសំខាន់នៅពេលថ្មីៗនេះ គឺការចូលជាធរមាននៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) នៅក្នុងឆ្នាំ ២០០៥។ ក្នុងនាមជាភ្នាក់ងាររបស់អ.ស.ប. ដែលឈានមុខគេលើវិស័យអភិបាលកិច្ច អង្គការយូអឹនឌីភីនឹងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀននិងឧក្រិដ្ឋកម្ម (UNODC) ព្រមទាំងអង្គការជាតិទ្វេភាគី និងអង្គការអន្តរជាតិទាំងអស់ដើម្បីជួយកសាងសមត្ថភាពក្នុងការគាំទ្រដល់ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ UNCAC។ កាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចរបស់រដ្ឋជាភាគីចំពោះអនុសញ្ញានេះគឺត្រូវរៀបចំស្ថាប័នចាំបាច់ផ្សេងៗដើម្បីទប់ស្កាត់និងប្រឆាំងអំពើពុករលួយ។ ការសិក្សាប្រៀបធៀបស្តីអំពីការរៀបចំស្ថាប័នដើម្បីប្រឆាំងអំពើពុករលួយនេះ បានធ្វើការសិក្សាលើប្រទេសចំនួន ១៤ និងមានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីជម្រើសផ្សេងៗដែលមាននៅក្នុងវិស័យនេះ ព្រមទាំងពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិនៃជម្រើសទាំងនោះ។

គោលគំនិតនៃការសិក្សាប្រៀបធៀបនេះ គឺជាលទ្ធផលនៃសំណើរដែលផ្តួចផ្តើមដោយក្រុមការងារសភាស្តីពីការប្រឆាំងអំពើពុករលួយរបស់រដ្ឋប្រេក្កត ហូរាល់ (Great Hural) នៅប្រទេសម៉ុងហ្គោលីដើម្បីផ្តល់ឱ្យពួកគេនូវជម្រើសផ្សេងៗសម្រាប់រៀបចំក្របខ័ណ្ឌនៃស្ថាប័នបែបណាមួយដែលនឹងគាំទ្រដល់ការអនុវត្តកម្មវិធីជាតិប្រឆាំងអំពើពុករលួយនៅពេលអនាគត។ ការសិក្សានេះផ្តល់នូវទិដ្ឋភាពដ៏មានសារៈប្រយោជន៍មួយស្តីអំពីគំរូផ្សេងៗគ្នាដែលត្រូវបានគេប្រើប្រាស់នៅក្នុងប្រទេសនានា ដើម្បីផ្តល់នូវបញ្ជីជម្រើស និងដំណោះស្រាយសម្រាប់ប្រទេសផ្សេងទៀតនៅក្នុង និងក្រៅតំបន់ ដោយផ្អែកលើការយល់ដឹងយ៉ាងហ្មត់ចត់អំពីស្ថានភាពនយោបាយ សង្គម និងសេដ្ឋកិច្ចក្នុងប្រទេស។ ការសិក្សានេះជាការសិក្សានាំមុខ ហើយបានបំពេញបន្ថែមទៅលើការសិក្សាមួយផ្សេងទៀត ស្តីពីច្បាប់ប្រឆាំងអំពើពុករលួយដែលការិយាល័យគោលនយោបាយអភិវឌ្ឍន៍ (BDP) កំពុងធ្វើនៅពេលនេះ នៅក្នុងប្រទេសដែលគេបានជ្រើសរើសមួយចំនួន។

ការសិក្សាប្រៀបធៀបអំពីការរៀបចំស្ថាប័នប្រឆាំងអំពើពុករលួយ គឺជាលទ្ធផលនៃការផ្តួចផ្តើមរួមគ្នាមួយ រវាងមជ្ឈមណ្ឌលតំបន់របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅទីក្រុងបាងកក អង្គការយូអឹនឌីភីនៅម៉ុងហ្គោលី និងក្រុមអភិបាលកិច្ចក្នុងប្រទេសរបស់ការិយាល័យគោលនយោបាយអភិវឌ្ឍន៍ (BDP)។ ឯកសារនេះត្រូវបានរៀបចំដោយលោកប៉ែត្រិក ខឺលឿស (Patrick Keuleers) (ទីប្រឹក្សាថ្នាក់តំបន់ទទួលបន្ទុក

កំណែទម្រង់រដ្ឋបាលសាធារណៈ និងការប្រឆាំងអំពើពុករលួយ ក្រុមអនុវត្តន៍អភិបាលកិច្ចតាមបែបលទ្ធិប្រជាធិបតេយ្យ (RCB) និងលោក នីល តាសែល (Nils Taxell) (មន្ត្រីស្រាវជ្រាវក្រុមអនុវត្តន៍អភិបាលកិច្ចតាមបែបលទ្ធិប្រជាធិបតេយ្យ (RCB)។ រាល់ការផ្តល់គំនិតយោបល់ចំពោះឯកសារនេះ ត្រូវបានផ្តល់ជូនដោយលោកស្រី ប៉ូលីន តាមេស៊ីស (Pauline Tamesis) (ទីប្រឹក្សាប្រឆាំងអំពើពុករលួយ BDP ញូវយ៉ក) លោក តូរ៉ូដ ល្ខាក់វ៉ាចាវ (Turod Lkhagvajav) (អ្នកជំនាញផ្នែកកម្មវិធីរបស់អង្គការយូអ៊ីនឌីភីប្រចាំប្រទេសម៉ុងហ្គោលី) និង លោក រីរតនា សុវណ្ណរក្ស (Ryratana Suwanraks) (ប្រធានក្រុមអភិបាលកិច្ចរបស់អង្គការយូអ៊ីនឌីភីប្រចាំប្រទេសថៃ)។

យើងសូមសម្តែងការដឹងគុណចំពោះសហការីទាំងអស់របស់អង្គការយូអ៊ីនឌីភីដែលបានរួមចំណែកក្នុងការស្រាវជ្រាវ និងការសរសេរឯកសារផ្តល់ចំណេះដឹងនេះ ដែលយើងសង្ឃឹមថានឹងពិតជាមានសារៈប្រយោជន៍ចំពោះប្រតិបត្តិការប្រឆាំងអំពើពុករលួយទាំងអស់។

**អេលីហ្សាបែត ហ្វុង**
អ្នកគ្រប់គ្រងប្រចាំតំបន់
មជ្ឈមណ្ឌលប្រចាំតំបន់ នៅក្រុងបាងកក

**ប្រានីធា ម៉េតា**
តំណាងប្រចាំប្រទេស
យូអ៊ីនឌីភីម៉ុងហ្គោលី

ផ្នែកទី ១

# និដ្ឋភាពទូទៅ និង អនុសាសន៍គោលនយោបាយ

# ពាក្យបំព្រួញ

| | |
|---|---|
| ACA | ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ |
| ATI | គណនេយ្យភាព តម្លាភាព និង សុចរិតភាព |
| BAI | ក្រុមប្រឹក្សាភិបាលសវនកម្ម និងអធិការកិច្ច |
| BDP | ការិយាល័យគោលនយោបាយអភិវឌ្ឍន៍ |
| CPCB | ការិយាល័យបង្ការ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ |
| CPIB | ការិយាល័យបង្ការ និងស៊ើបអង្កេតអំពើពុករលួយ |
| DCEC | នាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មអំពើពុករលួយ និងសេដ្ឋកិច្ច |
| ICAC | គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ |
| KICAC | គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយរបស់កូរ៉េ |
| KPK | គណៈកម្មការលុបបំបាត់អំពើពុករលួយ |
| MDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| NCCC | គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ |
| PCB | ការិយាល័យទប់ស្កាត់អំពើពុករលួយ |
| PJC | គណៈកម្មាធិការចំរុះសភាស្តីពី ICAC |
| PSAC | អង្គភាពប្រឆាំងអំពើពុករលួយសាធារណៈ |
| RCB | មជ្ឈមណ្ឌលប្រចាំតំបន់ នៅក្រុងបាងកក |
| SIS | សេវាស៊ើបអង្កេតពិសេស |
| UNCAC | អនុសញ្ញាសហប្រជាជាតិ ប្រឆាំងអំពើពុករលួយ |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNODC | ការិយាល័យសហប្រជាជាតិ ប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម |

# សេចក្តីផ្តើម

# ១

ដូចបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០០៥ (ផ្អែកលើនិន្នាការបច្ចុប្បន្ន) ប្រទេសក្រីក្រភាគច្រើននឹងមិនអាចសម្រេចបានតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ស្ទើរតែទាំងអស់ ហើយភាពក្រីក្រដ៏ធ្ងន់ធ្ងរបំផុតនឹងមិនអាចកាត់បន្ថយបានពាក់កណ្តាលឡើយនៅឆ្នាំ ២០១៥ នៅក្នុងតំបន់ណាក៏ដោយលើកលែងតែអាស៊ីបូព៌ា។ មានមូលហេតុជាច្រើនចំពោះហេតុការណ៍ជាក់ស្តែងទាំងនេះ។ ហេតុការណ៍ជាក់ស្តែងមួយគឺ អំពើពុករលួយយ៉ាងសុសសាយ មានផលប៉ះពាល់ជាដុំកំភួន និងជាច្រើនកន្លែងទៅលើកំណើនសមធម៌ និងភាពក្រីក្រ។ អំពើពុករលួយធ្វើឱ្យសង្គមបែកបាក់ និងធ្វើឱ្យខូចប្រព័ន្ធសេដ្ឋកិច្ច។ វាបង្កឱ្យមានការរើសអើងអំពើអយុត្តិធម៌ និងការមិនគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ វាបណ្តាលនូវគ្រោះថ្នាក់ដល់ស្ថេរភាពនៃស្ថាប័នប្រជាធិបតេយ្យរើសអើងក្នុងការផ្តល់សេវារបស់រដ្ឋាភិបាល ដែលជាកត្តានៃការរំលោភសិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសគឺសិទ្ធិរបស់អ្នកក្រីក្រ។ ទីណាមានអំពើពុករលួយទីនោះតែងមានការគំរាមកំហែងដល់សិទ្ធិ និងសេរីភាពជាមូលដ្ឋាន ហើយកិច្ចសន្យាសង្គមនិងសេដ្ឋកិច្ចមានភាពមិនអាចទស្សន៍ទាយបាន។ ហេតុនេះ អំពើពុករលួយនៅតែជាឧបសគ្គចម្បងមួយមិនឱ្យសម្រេចបាននូវការអភិវឌ្ឍដោយចិរភាពសម្រាប់ជួយដល់អ្នកក្រីក្រក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ ការប្រឆាំងដ៏គ្រប់ជ្រុងជ្រោយមួយទៅលើអំពើពុករលួយ នៅតែជាការប្រឈមមុខមួយសម្រាប់ប្រទេសជាច្រើន ទាំងប្រទេសកំពុងអភិវឌ្ឍន៍ក៏ដូចជាប្រទេសអភិវឌ្ឍន៍ដែរ។

នៅទសវត្សរ៍ឆ្នាំ ១៩៩០ ការផ្តោតលើអភិបាលកិច្ចល្អ និងការកើនឡើងនូវលទ្ធិប្រជាធិបតេយ្យ និងការផ្តល់អំណាចដល់សង្គមស៊ីវិល ដែលកើតចេញមកពីលទ្ធិប្រជាធិបតេយ្យនេះ បានបង្កើតឱ្យមានសេចក្តីសង្ឃឹមចង់ឱ្យមានសង្គមមួយ ដែលកាន់តែបើកចំហរ និងមានតម្លាភាព ដែលនៅក្នុងនោះការប្រព្រឹត្តិអំពើពុករលួយនឹងមិនអាចអត់អោនបានទៀតឡើយ។ តាំងពីពេលនោះមក មានលេចឡើងនូវនិន្នាការប្រកបដោយក្តីសង្ឃឹមជាច្រើន ដែលជាលទ្ធផលនៃជោគជ័យក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹង ដែលរៀបចំឡើងដោយអង្គការសង្គមស៊ីវិលអន្តរជាតិ ដោយមានអង្គការ Transparency International ជាអ្នកដើរតួនាំមុខ។ ប្រព័ន្ធសារព័ត៌មានដែលកាន់តែសកម្ម បានជួយបើកចំហរនូវអំពើពុករលួយ។

ប៉ុន្តែ ទោះបីជាមានច្បាប់ថ្មីៗ និងការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ និងសុចរិតភាពកាន់តែច្រើនឡើងក៏ដោយ យើងនៅតែមានការខកចិត្តចំពោះលទ្ធផលជាទូទៅដដែល ព្រោះសេចក្តីប្រាថ្នារបស់យើងមានច្រើនជាងសមិទ្ធផលជាក់ស្តែងដែលសម្រេចបាន ហើយលទ្ធផលជារូបីយ៍នៅតែមានកម្រិតតិចតួចនៅឡើយ។ ចរន្តនៃវិមជ្ឈការ បច្ចុប្បន្ននាំឱ្យមានកង្វល់កាន់តែច្រើនថែមទៀត ដោយខ្លាចក្រែងអំពើពុករលួយរីករាលដាលទៅដល់រដ្ឋបាលមូលដ្ឋាន។

អំពើពុករលួយ ត្រូវបានចាត់ទុកថាជាបរាជ័យរបស់ស្ថាប័នជាពិសេសគឺស្ថាប័នទទួលបន្ទុកស៊ើបអង្កេត ប្តឹងចោទ និងអនុវត្តច្បាប់។ នៅពេលនេះ មានការផ្តោតអារម្មណ៍ជាច្រើនទៅលើការអនុវត្តអនុសញ្ញា អ.ស.ប. ប្រឆាំងអំពើពុករលួយ ដែលត្រូវបានចុះហត្ថលេខាកាលពីខែ ធ្នូ ឆ្នាំ ២០០៣ ដោយប្រទេសចំនួន ៩៥ និងបានចូលជាធរមាននៅឆ្នាំ ២០០៥ ក្រោយពីមានការផ្តល់សច្ចាប័នលើកទី ៣០ ចំពោះសន្ធិសញ្ញានេះ។ អនុសញ្ញានេះ ផ្តល់នូវក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់ទប់ទល់ជាមួយអំពើពុករលួយក្នុងស្រុកនិងអន្តរជាតិ ក្នុងវិស័យសាធារណៈ និងវិស័យឯកជន។ អនុសញ្ញានេះក៏ជំរុញឱ្យមានការ

ផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវបទពិសោធពាក់ព័ន្ធ និងចំណេះដឹងជំនាញ និងជំរុញការពិភាក្សាលើបញ្ហាដែលជាកង្វល់រួមគ្នា និងការអនុវត្តប្រកបដោយជោគជ័យ ក្នុងការបង្ការ និងប្រឆាំងអំពើពុករលួយ។

ចំពោះរឿងនេះ បញ្ហាដ៏សំខាន់មួយគឺត្រូវសម្រេចលើការរៀបចំស្ថាប័នសម្រាប់ប្រឆាំងអំពើពុករលួយ ពោលគឺជម្រើសដែលពាក់ព័ន្ធនឹងប្រភេទនៃទីភ្នាក់ងារឬគណៈកម្មការ/គណៈកម្មាធិការដែលចាំបាច់ត្រូវបង្កើតឡើង ឬត្រូវពង្រឹងបន្ថែម ដើម្បីធានានូវការប្រឆាំងអំពើពុករលួយប្រកបដោយជោគជ័យ ព្រមទាំងសេចក្តីសម្រេចដែលពាក់ព័ន្ធអំពីបញ្ហាច្បាប់គោលនយោបាយ ធនធាន និងបញ្ហាផ្សេងៗទៀត ដែលចាំបាច់ត្រូវលើកយកមកពិចារណា។

ការស្រាវជ្រាវប្រៀបធៀបស្តីអំពីការរៀបចំស្ថាប័នដើម្បីប្រឆាំងអំពើពុករលួយនេះ បានផ្តើមចេញមកពីការងារដំបូងរបស់យូអឹនឌីភីនៅប្រទេសម៉ុងហ្គោលី និងតាមសំណើរបស់ក្រុមការងារនៃសភាម៉ុងហ្គោលី ស្តីពីការប្រឆាំងអំពើពុករលួយ ដែលបានស្នើមកការិយាល័យយូអឹនឌីភីប្រចាំប្រទេសក្នុងក្រុងអ៊ូឡានបាតា (Ulaanbaatar) ដើម្បីធ្វើការសិក្សាប្រៀបធៀបស៊ីជម្រៅមួយ។ ដោយសារនៅក្នុងប្រទេសមួយចំនួនដែលយូអឹនឌីភីបានជាប់ពាក់ព័ន្ធ ឬកំពុងចូលពាក់ព័ន្ធក្នុងការងារប្រឆាំងអំពើពុករលួយនោះ មានបញ្ហាមជ្ឈភាពស្ថាប័ន កិច្ចការនេះត្រូវបានសម្រេចឱ្យមជ្ឈមណ្ឌលប្រចាំតំបន់នៅក្រុងបាងកក ដើរតួនាទីឈានមុខក្នុងការសិក្សានេះ ដោយសហការជាមួយយូអឹនឌីភីម៉ុងហ្គោលី និងទីប្រឹក្សាប្រឆាំងអំពើពុករលួយនៅក្នុងក្រុមអភិបាលកិច្ចតាមលទ្ធិប្រជាធិបតេយ្យប្រចាំការិយាល័យគោលនយោបាយអភិវឌ្ឍន៍របស់យូអឹនឌីភី។

ឯកសារនេះមានពីរផ្នែក។ ផ្នែកទីមួយនិយាយពីទិដ្ឋភាពទូទៅ និងការវិភាគលើការរៀបចំស្ថាប័ននានាសម្រាប់ប្រឆាំងអំពើពុករលួយ មេរៀនដែលទទួលបាន និងលក្ខខណ្ឌសម្រាប់ជោគជ័យ។ ផ្នែកទីពីរ ពិពណ៌នាសង្ខេបអំពីប្រទេសចំនួន ១៤ ដែលរៀបរាប់ពីយន្តការស្ថាប័នសម្រាប់ប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសនីមួយៗ។ ប្រទេសទាំងនេះត្រូវបានជ្រើសរើសក្នុងគោលបំណងផ្តល់ឱ្យបានគ្រប់ទិដ្ឋភាពនៃការរៀបចំស្ថាប័ននានាដែលមានស្រាប់សម្រាប់ប្រឆាំងអំពើពុករលួយ ដែលមានសព្វថ្ងៃនេះ។ ប្រទេសមួយចំនួនក៏ត្រូវបានជ្រើសរើសដែរ ដោយហេតុថាប្រទេសទាំងនេះត្រូវបានគេដឹងយ៉ាងទូលំទូលាយថា បានទទួលជោគជ័យក្នុងការប្រឆាំងអំពើពុករលួយ។

## ១.១. សារៈសំខាន់នៃអង្គភាពប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាព

ទោះបីជាមានការយកចិត្តទុកដាក់កាន់តែច្រើនទៅលើការប្រឆាំងអំពើពុករលួយក៏ដោយក៏ការខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយជាច្រើនបានទទួលបរាជ័យ ដោយសារមូលហេតុច្រើនប្រភេទ។ មូលហេតុមួយក្នុងចំណោមមូលហេតុទាំងនោះគឺ វិសមភាពយ៉ាងជាក់ស្តែងរវាងការផ្តល់អាទិភាពទៅលើគោលដៅដែលមើលឃើញក្នុងរយៈពេលខ្លី ដែលដោះស្រាយទៅលើរោគសញ្ញា ជាជាងឫសគល់នៃអំពើពុករលួយ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ កាន់តែលំបាករួមទាំងពេលវេលា និងកំណែទម្រង់ប្រព័ន្ធដែលត្រូវប្រើប្រាស់ធនធានច្រើន (UNDP, ២០០៤:៦)។ ការគិតគូរដ៏ត្រឹមត្រូវមួយ តាមរយៈយុទ្ធសាស្ត្រកំណែទម្រង់ប្រឆាំងអំពើពុករលួយ ទាមទារឱ្យមាននូវចក្ខុវិស័យរយៈពេលយូរ និងការយល់ដឹងច្បាស់លាស់ ដែលអាចនាំឱ្យមានការកែប្រែដល់ឫសគល់យ៉ាងឆាប់បំផុតនៅជំនាន់ក្រោយ មិនមែននៅជំនាន់នេះឡើយ[១]។

ធាតុសំខាន់មួយនៃយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ គឺត្រូវជ្រើសយកគំរូស្ថាប័នសម្រាប់ប្រឆាំងអំពើពុករលួយ ព្រមទាំងគោលនយោបាយ ហើយនិងការខិតខំកសាងសមត្ថភាព ដែលនឹងអនុញ្ញាតឱ្យស្ថាប័នទាំងនេះបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។

ការសម្រេចថា តើត្រូវបង្កើតស្ថាប័នដោយឡែកមួយ ដូចជាភ្នាក់ងារប្រឆាំងអំពើពុករលួយ (ACA) ដើម្បីដោះស្រាយតែបញ្ហាអំពើពុករលួយសុទ្ធសាធ ឬមួយត្រូវកែប្រែ ឬក៏ទទួលយកស្ថាប័នដែលមានស្រាប់ ឬក៏ត្រូវសម្រេចយកការរួមផ្សំនូវភាគខ្លះនៃរូបមន្តទាំងពីរនេះ គឺនៅតែជាបញ្ហាសម្រាប់ពិភាក្សាគ្នានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ ជម្រើសមួយក្នុងចំណោមជម្រើសទាំងនេះ នាំមកនូវកត្តាច្បាប់ គោលនយោបាយ ធនធាន និងកត្តាផ្សេងៗទៀត ដែលចាំបាច់ត្រូវថ្លឹងថ្លែងដោយប្រុងប្រយ័ត្ន។ ដូចគ្នានេះដែរ ទោះបីមិនមានសារៈសំខាន់ជាងក៏ដោយ ក៏ត្រូវធានាឱ្យមាននូវវិធានប្រតិបត្តិច្បាស់លាស់ ដែលនឹងជួយណែនាំដល់អន្តរកម្ម និងកិច្ចសហប្រតិបត្តិការ

[១] សិង្ហបុរីចំណាយពេលអស់ ១៥ឆ្នាំ ដើម្បីបង្កើតបាន CPIB ជាភ្នាក់ងារឯករាជ្យ ដោយចាប់ផ្តើពីឆ្នាំ ១៩៥២ ដែលស្ថិតនៅក្រៅពីសមត្ថកិច្ចរបស់ប៉ូលីស។ ហុងកុងចំណាយពេល ២៦ឆ្នាំ សម្រាប់ការបង្កើត ICAC ដោយចាប់ផ្តើមនៅឆ្នាំ ១៩៧៤ (គម្រោងស្រាវជ្រាវអំពើពុករលួយ និងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ ១៩៩៩)។

រវាងស្ថាប័ននានា ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយគ្រប់រូបភាព។

ទោះបីជាអ្នកខ្លះលើកឡើងថាគ្រាន់តែចម្លងតាមគំរូជោគជ័យនៃការប្រឆាំងអំពើពុករលួយរបស់ហុងកុង ឬសិង្ហបុរី ជាការគ្រប់គ្រាន់ហើយក៏ដោយ ការពិតគឺគ្មានដំណោះស្រាយណាមួយដែលសមស្របសម្រាប់រាល់ការប្រឆាំងអំពើពុករលួយនោះទេ។ ទោះបីជាមាន "ការប្រយុទ្ធប្រឆាំងល្អៗបំផុត" ហើយអាចនឹងផ្តល់ជាគោលការណ៍ណែនាំដែលមានសារៈប្រយោជន៍ក៏ដោយ ក៏មិនអាចយកទៅអនុវត្តចំពោះបរិបទរបស់ប្រទេសណាមួយជាស្វ័យប្រវត្តិបានដែរ[២]។

## ១.២. អនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយនិងការរៀបចំស្ថាប័នប្រយុទ្ធប្រឆាំងអំពើពុករលួយ

ដូចមានចែងនៅក្នុង UNCAC:

*រដ្ឋជាភាគីនីមួយៗត្រូវធានាឱ្យមាននូវអង្គភាព**ទប់ស្កាត់**អំពើពុករលួយមួយឬច្រើនតាមការចាំបាច់។ រដ្ឋជាភាគីនីមួយៗត្រូវផ្តល់ឱ្យអង្គភាពទាំងនេះនូវឯករាជភាពតាមការចាំបាច់ដែលស្របជាមួយនឹងគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធគតិយុត្តិរបស់ខ្លួន ដើម្បីឱ្យអង្គភាពនេះអាចបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងចាកផុតពីឥទ្ធិពលមិនសមរម្យណាមួយ។ គួរតែផ្តល់ជូននូវធនធានសម្ភារៈចាំបាច់នានា និងបុគ្គលិកជំនាញ ព្រមទាំងការបណ្តុះបណ្តាល ដែលបុគ្គលិកនេះអាចត្រូវការ ដើម្បីបំពេញមុខងាររបស់ពួកគេ ( មាត្រា ៦)។*

បន្ថែមទៅលើមាត្រាទាំងឡាយដែលផ្តោតលើការទប់ស្កាត់ មាត្រា ៣៦ នៃអនុសញ្ញាចែងថា :

*ស្របតាមគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធគតិយុត្តិរបស់ខ្លួន រដ្ឋជាភាគីនីមួយៗត្រូវធានាឱ្យមាននូវអង្គភាពមួយឬច្រើន ឬបុគ្គលទាំងឡាយដែលមានជំនាញក្នុង**ការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមរយៈការអនុវត្តច្បាប់**។ អង្គភាព ឬបុគ្គលទាំងនេះ ត្រូវទទួលបាននូវឯករាជភាពតាមការចាំបាច់ដែលស្របតាមគោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធគតិយុត្តិរបស់រដ្ឋជាភាគី ដើម្បីអាចបំពេញមុខងាររបស់ពួកគេប្រកបដោយប្រសិទ្ធភាព និងដោយគ្មានឥទ្ធិពលមិនសមស្របណាមួយ។ បុគ្គល ឬបុគ្គលិកនៃអង្គភាពនេះ គួរទទួលបានការបណ្តុះបណ្តាលនិងធនធានសមស្រប ដើម្បីបំពេញភារកិច្ចរបស់ពួកគេ។*

អាស្រ័យហេតុនេះ UNCAC ទាមទារឱ្យមានការបង្កើតឡើងនូវស្ថាប័នបែបនេះ (លើកលែងតែមានអត្ថិភាពក្នុងទម្រង់ណាមួយ) នៅក្នុងវិស័យជាក់លាក់ពីរគឺ :

(១) អង្គភាពទប់ស្កាត់អំពើពុករលួយ
(២) អង្គភាពដែលមានជំនាញខាងការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមរយៈការអនុវត្តច្បាប់។

ប៉ុន្តែ នៅក្នុងដំណាក់កាលដែលកំពុងគិតគូរពីការរៀបចំ រដ្ឋជាភាគីអាចបង្កើត ឬប្រើប្រាស់អង្គភាពដដែល ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃបញ្ញត្តិទាំងពីរ។

ហេតុដូច្នេះ រដ្ឋជាភាគីនៃអនុសញ្ញានេះ ត្រូវសម្រេចថាតើត្រូវបង្កើតអង្គភាពថ្មីៗ ឬត្រូវកែទម្រង់/កែលម្អអង្គភាពដែលមានស្រាប់ហើយនិងត្រូវសម្រេចថា តើត្រូវផ្តល់ការទទួលខុសត្រូវចំពោះអង្គការតែមួយគត់ ឬត្រូវបែងចែកភារកិច្ចរវាងស្ថាប័នទប់ស្កាត់ និងស្ថាប័នអនុវត្តន៏ច្បាប់ផ្សេងៗ។ ទន្ទឹមនឹងនេះ រដ្ឋជាភាគីចាំបាច់ត្រូវសម្រេចទៅលើអាណត្តិការងារ និងអំណាចរបស់ស្ថាប័នទាំងនេះ កម្រិតនៃស្វ័យភាពរបស់ស្ថាប័នទាំងនេះ ធនធានដែលស្ថាប័នទាំងនេះត្រូវមាននិងវិធានប្រតិបត្តិដែលនឹងជួយឱ្យមានអន្តរកម្ម និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងនោះ។ ជំពូកបន្តទៅទៀត ផ្តល់នូវទិដ្ឋភាពទូទៅមួយនៃគំរូខុសៗគ្នា ដែលត្រូវបានគេប្រើនៅក្នុងប្រទេសនានា ហើយនិងពិនិត្យមើលទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃគំរូខុសៗគ្នាទាំងនោះ។

[២] ការសិក្សាមួយអំពីកត្តាដែលប៉ះពាល់ដល់ការប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសក្រោយរបបកុំម្មុយនីស នៅក្នុងអឺរ៉ុបខាងកើត បានបង្ហាញឱ្យឃើញថា "ការប្រតិបត្តិល្អៗ" ត្រូវបានចាត់ទុកថាមានសារៈប្រយោជន៍ ប៉ុន្តែមានការលំបាកក្នុងការផ្ទេរទៅក្នុងបរិការណ៍ផ្សេងទៀត។ ហេតុនេះ ការប្រើប្រាស់គំរូដែលមានស្រាប់ ទាមទារនូវការប្រុងប្រយ័ត្ន និងការអភិវឌ្ឍនូវការការពារគ្រប់គ្រាន់ដែលរៀបចំឡើងនៅក្នុងស្រុក "ដើម្បីដោះស្រាយឱ្យចំបញ្ហា" (Anusiewicz, ២០០៣)។

# ភ្នាក់ងារ ឬ គណៈកម្មការ ពិសេសប្រឆាំងអំពើពុករលួយ

# ២

ប្រទេសជាច្រើនបានជ្រើសរើសយក ឬកំពុងពិចារណាបង្កើត គណៈកម្មការ ឬទីភ្នាក់ងារឯករាជ្យ ឱ្យទទួលភារកិច្ចទាំងអស់ក្នុងការ ប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ការ បង្កើតស្ថាប័នបែបនេះមិនមែនជាឱសថទិព្វសម្រាប់ព្យាបាលអំពើពុក រលួយដ៏ធ្ងន់ធ្ងរគ្រប់យ៉ាងបានឡើយ។ ជាក់ស្តែង ឧទាហរណ៍នៃ គណៈកម្មការ ឬទីភ្នាក់ងារឯករាជ្យប្រឆាំងអំពើពុករលួយដែលទទួល បានជោគជ័យមានតិចតួចណាស់។ ប្រវត្តិនៃភាពជោគជ័យបំផុត គឺ ប្រវត្តិនៃគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយរបស់ហុងកុង (ICAC), ការិយាល័យស៊ើបអង្កេតអំពើពុករលួយរបស់ប្រទេស សិង្ហបុរី (CPIB), នាយកដ្ឋានសម្រាប់បទល្មើសសេដ្ឋកិច្ច និងអំពើពុក រលួយរបស់ប្រទេសបូតស្វាណា (DCEC) និង គណៈកម្មការឯករាជ្យ ប្រឆាំងអំពើពុករលួយរបស់ញូសៅវែល (New South Wale) (ICAC)។ ប៉ុន្តែ ដូចដែលបានលើកឡើង គំរូទាំងនេះមិនអាចចម្លង យកមកប្រើបានដោយងាយៗនោះទេ ដោយសារតែស្ថានភាពខុសៗ ពីគ្នា ដែលគំរូទាំងនេះត្រូវដំណើរការតាម (និងប្រវត្តិដោយឡែកពីគ្នា នៃការបង្កើតគំរូទាំងនេះ និងការវិវត្តរបស់វា)។ ការបង្កើត ACA គួរ ផ្អែកលើការវិភាគលើប្រព័ន្ធនៃបរិការណ៍ក្នុងស្រុក(ប្រព័ន្ធនយោបាយ) និងតម្រូវការជាក់ស្តែង ព្រមទាំងអាទិភាពរបស់ប្រទេស។

## ២.១. ឯករាជភាពរបស់ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ

ឯករាជភាពរបស់ ACA ត្រូវចាត់ទុកថាជាសេចក្តីត្រូវការ ចាំបាច់សម្រាប់ប្រសិទ្ធភាពរបស់ ACA ដោយហេតុថា វានឹងអនុញ្ញាត ឱ្យស្ថាប័ននេះធ្វើសកម្មភាពដោយសេរី ចាកផុតពីឥទ្ធិពលរបស់បុគ្គល ឬភាគីមានអំណាច និងអាចធ្វើការស៊ើបអង្កេតអំពើពុករលួយ ដែល គេសង្ស័យនៅក្នុងគ្រប់វិស័យទាំងអស់ និងនៅគ្រប់កម្រិតទាំងអស់នៃ សង្គម (Kpundel និង Levy ២០០៤)។ ការធ្វើវិសោធនកម្មរដ្ឋ ធម្មនុញ្ញ ដែលផ្តល់ឯករាជភាពដល់ ACA គឺមានសារៈប្រយោជន៍ ប៉ុន្តែក៏នៅតែមិនទាន់គ្រប់គ្រាន់ដែរ។ ប៉ុន្តែ តើស្ថាប័នដែលកំពុងមាន បច្ចុប្បន្ននេះ ពិតជាឯករាជ្យមែនឬទេ? តថភាពបានបង្ហាញឱ្យឃើញ នូវកម្រិតស្វ័យភាពខុសៗគ្នា ហើយសូម្បីតែទីភ្នាក់ងារ ឬគណៈកម្មការ ដែលមានជោគជ័យបំផុតមួយចំនួន ក៏មិនឯករាជពេញលេញពីអ្នក ដែលមានអំណាចដែរ[៣]។ ឧទាហរណ៍ DCEC នៅប្រទេសបូតស្វាណា ត្រូវរាយការណ៍ជូនប្រធានាធិបតី ហើយនាយក និងបុគ្គលិកស្ថិតនៅ ក្រោមច្បាប់មន្ត្រីសាធារណៈ។CPIB របស់ប្រទេសសិង្ហបុរី មានទីតាំង ស្ថិតនៅក្នុងការិយាល័យនាយករដ្ឋមន្ត្រី ហើយនាយករបស់ CPIB ទទួល ខុសត្រូវផ្ទាល់ចំពោះនាយករដ្ឋមន្ត្រី។ ICAC របស់ហុងកុង រាយការណ៍ ជូនប្រមុខស្ថាប័នប្រតិបត្តិ។ បើដូច្នេះ តើអ្វីខ្លះដែលធ្វើឱ្យ ស្ថាប័ន ទាំងនេះមានប្រសិទ្ធភាពជាងស្ថាប័នផ្សេងៗទៀត? មួយផ្នែក នៃចម្លើយស្ថិតនៅលើការរៀបចំប្រព័ន្ធសមស្របសម្រាប់ត្រួតពិនិត្យ ទៅវិញទៅមក និងកត្តាដែលស្ថាប័នទាំងនេះស្ថិតនៅក្រោមការពិនិត្យ ពិច័យជានិច្ចកាល តាមរយៈយន្តការត្រួតពិនិត្យផ្សេងៗ ដែលធានា ឱ្យស្ថាប័នទាំងនេះ ដំណើរការបានដោយមិនលំអៀង។ ឧទាហរណ៍ សកម្មភាពនៃ ICAC របស់ហុងកុង ត្រូវបានត្រួតពិនិត្យដោយ គណៈកម្មាធិការឯករាជ្យ ៤ រួមទាំងតំណាងមកពីសង្គមស៊ីវិល ព្រមទាំងគណៈកម្មាធិការឯករាជ្យ ICAC សម្រាប់ទទួលពាក្យបណ្តឹង ដែលមានភារកិច្ចទទួលពាក្យបណ្តឹង តាមដានពិនិត្យ និងពិនិត្យសារ ឡើងវិញលើពាក្យបណ្តឹងប្រឆាំងនឹងគណៈកម្មការនេះ ។

[៣] ជំបូង ឯករាជភាពរបស់វាគឺចាកផុតពីប៉ូលីស និងក្នុងកម្រិតស្រាលបន្តិចពីរដ្ឋាភិបាល

វិធីមួយផ្សេងទៀតដើម្បីលើកកម្ពស់ស្វ័យភាពរបស់ ACA គឺត្រូវធានាថាការជ្រើសរើស និងការតែងតាំងផ្នែកប្រតិបត្តិរបស់ ACA គឺជាការទទួលខុសត្រូវរួមដោយស្ថាប័នមួយចំនួន[៤]។ សន្តិសុខក្នុងមុខតំណែងសម្រាប់មន្ត្រីជាន់ខ្ពស់របស់ទីភ្នាក់ងារនេះ និងអភ័យឯកសិទ្ធិរួចផុតពីបណ្តឹងរដ្ឋប្បវេណី ក៏មានសារៈសំខាន់ដែរ។ គណៈកម្មការលុបបំបាត់អំពើពុករលួយរបស់ប្រទេសឥណ្ឌូនេស៊ី ត្រូវបានតែងតាំងដោយសភាតាមបញ្ជីឈ្មោះបេក្ខជនដែលផ្តល់ជូនដោយប្រធានាធិបតី[៥]។ បញ្ជីឈ្មោះបេក្ខជនត្រូវបានរៀបចំដោយគណៈកម្មាធិការជ្រើសរើសមួយ ដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ នៅក្នុងប្រទេសផ្សេងៗទៀត ប្រធាន ACA ត្រូវបានតែងតាំងដោយប្រធានាធិបតី (ប្រទេសតង់ហ្សានី) អភិបាលរដ្ឋ ( រដ្ឋញូសៅវែល) ឬដោយប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី ដោយមានការឯកភាព ឬតាមសំណើរបស់សភា (ប្រទេសលីទុយអានី និងប្រទេសនីហ្សេរីយ៉ា) ឬដោយសភា តាមសំណើរបស់គណៈរដ្ឋមន្ត្រី (ប្រទេសឡាតវៀ) ឬដោយព្រះមហាក្សត្រ តាមសំណើរបស់នាយករដ្ឋមន្ត្រី (ប្រទេសម៉ាឡេស៊ី)។ នៅសាធារណរដ្ឋកូរ៉េ ប្រធានាធិបតីតែងតាំងប្រធាន និងសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយរបស់កូរ៉េ (KICAC)។ លើសពីនេះទៅទៀត សភា និងប្រធានតុលាការកំពូលស្នើសមាជិក ៣រូបរៀងៗខ្លួន។

ដើម្បីចៀសវាងការជ្រៀតជ្រែកពីសំណាក់ក្រុមអ្នកគ្រប់គ្រងស្ថាប័ន ACA នេះ ប្រទេសមួយចំនួនបានបង្កើតខ្សែបន្ទាត់រាយការណ៍ជាច្រើន ឬបានប្តូរខ្សែបន្ទាត់រាយការណ៍ទៅតំណាងរាស្ត្រវិញ។

ក៏ប៉ុន្តែ ការកើនឡើងនូវឯករាជភាពក៏ទាមទារឱ្យមានការត្រួតពិនិត្យទៅវិញទៅមកនៅក្នុងស្ថាប័ននោះដែរ ដើម្បីធានាកុំឱ្យមានការរំលោភលើស្វ័យភាព។ ដូចដែលបានរៀបរាប់ខាងលើ ICAC របស់ហុងកុងមានគណៈកម្មាធិការផ្តល់យោបល់ ៤ (គណៈកម្មាធិការផ្តល់យោបល់លើការទប់ស្កាត់អំពើពុករលួយ គណៈកម្មាធិការផ្តល់យោបល់ដល់ប្រជាជនលើទំនាក់ទំនងជាមួយសហគមន៍ គណៈកម្មាធិ-ការពិនិត្យសារឡើងវិញលើកិច្ចប្រតិបត្តិការ និងគណៈកម្មាធិការផ្តល់យោបល់លើការទប់ស្កាត់អំពើពុករលួយ)។ ដោយមានសមាជិកដែលត្រូវបានតែងតាំងពិសេសអំពីសហគមន៍ទាំងមូលនោះ គណៈកម្មាធិការទាំងនេះ ជួបប្រជុំជាទៀងទាត់ ដើម្បីពិនិត្យសារឡើងវិញនូវសកម្មភាពរបស់ ICAC។ ICAC នៅញូសៅវែល ទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ តាមរយៈគណៈកម្មាធិការចំរុះពហុសភា (PJC) ដែលសង្កេតការណ៍លើរាល់សកម្មភាពទាំងអស់របស់ ICAC តាមរយៈគណៈកម្មាធិការពិនិត្យសារឡើងវិញលើកិច្ចប្រតិបត្តិការ[៦] ដែលមានរួមបញ្ចូលទាំងសមាជិករបស់សាធារណជនទូទៅ និងទីភ្នាក់ងារផ្សេងៗរបស់រដ្ឋាភិបាល ហើយនិងមានកាតព្វកិច្ចត្រូវរាយការណ៍ជាទៀងទាត់ ជូនសាធារណជន និងរាយការណ៍ប្រចាំឆ្នាំអំពីការស៊ើបអង្កេតធំៗ។ PJC រាយការណ៍ជូនសភាទាំងពីរ អំពីកិច្ចការទាំងអស់ដែលទាក់ទងនឹង ICAC ដែលតាមមតិរបស់ PJC គួរតែជម្រាបជូនទៅសភា។ ការិយាល័យទប់ស្កាត់អំពើពុករលួយ (PCB) របស់ប្រទេសតង់ហ្សានី ក៏មានគណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃដែលគ្រប់គ្រងលើដំណើរការរបស់ខ្លួន ប៉ុន្តែ សមាសភាពរបស់គណៈកម្មាធិការ លំបាកនឹងធានានូវការពិនិត្យពិច័យដោយឯករាជ្យណាស់ (គណៈកម្មាធិការនេះ ដឹកនាំដោយអគ្គលេខាធិការប្រចាំទីស្តីការប្រធានាធិបតី ហើយមានសមាសភាពជាអគ្គនាយក PCB និងអគ្គនាយកនៃប្រព័ន្ធចារកម្ម និងសន្តិសុខប្រទេសតង់ហ្សានី និងលេខាធិការផ្ទាល់របស់ប្រធានាធិបតី )។

ការពង្រីកប្រព័ន្ធរាយការណ៍របស់ ACA ក៏ជាវិធីបង្កើនការត្រួតពិនិត្យ ដោយឱ្យ ACA ទទួលខុសត្រូវចំពោះអាជ្ញាធរលើសពីមួយ។ នៅប្រទេសឥណ្ឌូនេស៊ី KPK ត្រូវបានចាត់ទុកថាជាភ្នាក់ងារឯករាជ្យរបស់រដ្ឋ ដែលរាយការណ៍អំពីសកម្មភាពរបស់ខ្លួន ជូនប្រធានាធិបតី សភាជាតិ និងសវនកររបស់រដ្ឋ។ ភ្នាក់ងារស៊ើបអង្កេតពិសេសរបស់ប្រទេសលីទុយអានី (SIS) ទទួលខុសត្រូវចំពោះប្រធានាធិបតី និងសភា។ វាមានកាតព្វកិច្ចត្រូវរាយការណ៍ យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ជាលាយលក្ខណ៍អក្សរជូនប្រធានាធិបតី និងប្រធានសភា Seimas។ គណៈកម្មការប្រឆាំងអំពើពុករលួយរបស់ប្រទេសថៃ (NCCC) រាយការណ៍ជូនព្រឹទ្ធសភា។ ប៉ុន្តែ របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនក៏ត្រូវដាក់ជូនសភាជាន់ទាប និងគណៈរដ្ឋមន្ត្រីផងដែរ។

---

[៤] ជំនឿទុកចិត្តរបស់សាធារណជនមកលើគណៈកម្មការ ឬភ្នាក់ងារ នឹងពឹងផ្អែកមួយផ្នែកធំនៅលើថា តើសាធារណជនយល់ថាសមាជិករបស់ស្ថាប័នមានសេចក្តីថ្លៃថ្នូរ មានសមត្ថភាព និងតំណាងឱ្យផលប្រយោជន៍ពាក់ព័ន្ធនៅក្នុងសង្គម។

[៥] ជាការចាំបាច់ដែលមនុស្សម្នាក់នៅថ្នាក់កំពូល ដែលមានអំណាច និងដែលទទួលខុសត្រូវចំពោះអំពើរបស់អង្គភាពនេះ។ បទពិសោធនៅកន្លែងផ្សេងៗបង្ហាញថា អង្គភាពមួយដែលដំណើរការដោយផ្អែកលើដំណើរការធ្វើសេចក្តីសម្រេចចិត្តសមូហភាព មានការលំបាកក្នុងការបំពេញការងាររភ្លាមៗ និងដាច់ខាត។

[៦] ICAC ត្រូវពិគ្រោះយោបល់ជាមួយ ORC មុននឹងសម្រេចថា តើត្រូវបញ្ឈប់ ឬមិនត្រូវចាប់ផ្តើមការស៊ើបអង្កេត ឬពាក្យបណ្តឹង ឬត្រូវបញ្ឈប់ការស៊ើប អង្កេតដែលកំពុងដំណើរការ។

ប្រទេសផ្សេងៗទៀតបានសម្រេចផ្លាស់ប្តូរខ្សែរបន្ទាត់រាយការណ៍ពីស្ថាប័នដែលគ្រប់គ្រងដោយមនុស្សម្នាក់ ដូចជាប្រធានាធិបតី ឬនាយករដ្ឋមន្ត្រី ទៅជូនតំណាងអង្គភាពនីតិកម្មរបស់ប្រជាជនដែលអនុញ្ញាតឱ្យភាគីផ្សេងៗនៅក្នុងសភាអាចពិនិត្យពិច័យទៅលើរាល់សកម្មភាពរបស់ ACA ។ ថ្មីៗនេះ វិសោធនកម្មច្បាប់នៅប្រទេសយូហ្គាន់ដា និង ហ្សាំប៊ៀ បានតម្រូវឱ្យអធិការ និងគណៈកម្មការប្រឆាំងអំពើពុករលួយរាយការណ៍ជូនសភា ជាជាងជូនប្រមុខរដ្ឋ។

## ២.២. អាណត្តិការងារ

អាណត្តិការងាររបស់អង្គភាពពិសេសប្រឆាំងអំពើពុករលួយនឹងអាស្រ័យលើកត្តាមួយចំនួន ជាពិសេស គឺអាណត្តិរបស់អង្គភាពពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងវិស័យដូចជា ការលើកគោលនយោបាយ ការកែប្រែច្បាប់ ការអនុវត្តច្បាប់ និងការដាក់បណ្តឹងអាជ្ញាអត្ថិភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយផ្ទៃក្នុង (ដូចជា អង្គភាពស៊ើបអង្កេតពិសេសនៅក្នុងកងកម្លាំងប៉ូលីស) ហើយនិងថាតើអាណត្តិនេះមានបំណងដោះស្រាយអំពើពុករលួយគ្រប់កម្រិតទាំងអស់របស់រដ្ឋាភិបាលដែរឬអត់ (ថ្នាក់កណ្តាល តំបន់ និងខេត្ត-ក្រុង ឬមូលដ្ឋាន) (UNODC, ២០០៤:៩២) ។

នៅក្នុងកម្រិតទីទៃៗពីគ្នា មុខការគន្លឹះទាំង ៥ ខាងក្រោមនេះអាចជាកិច្ចការសម្រាប់អង្គភាពពិសេសប្រឆាំងអំពើពុករលួយមួយ :

១. ការស៊ើបអង្កេត
២. ការធ្វើបណ្តឹងអាជ្ញា (ការរៀបចំបែបបទដើម្បីចោទពីបទល្មើសព្រហ្មទណ្ឌ)
៣. ការអប់រំ និងការលើកកម្ពស់ការយល់ដឹង
៤. ការទប់ស្កាត់ និង
៥. ការសម្របសម្រួល

ACA ភាគច្រើនប្រើប្រាស់យុទ្ធសាស្ត្របីរួមគ្នាគឺ**ការទប់ស្កាត់ ការស៊ើបអង្កេត និងការអប់រំ** (ប្រទេសបូតស្វាណា ឥណ្ឌូនេស៊ី ហុងកុង ឡាតវៀ លីទុយអានី រដ្ឋញូសៅវែល និងប្រទេសថៃ) ។

មុខងារស៊ើបអង្កេតគឺជាចំណុចស្នូលសម្រាប់អាណត្តិការងារនៃ ACA ជាច្រើន ដែលត្រូវបានសិក្សានៅក្នុងឯកសារសង្ខេបនៃប្រទេសនីមួយៗ។ ក៏ប៉ុន្តែ រាល់ទីភ្នាក់ងារទាំងអស់ មិនមែនសុទ្ធតែត្រូវមានអាណត្តិការងារសម្រាប់ធ្វើការស៊ើបអង្កេតលើករណីចោទប្រកាន់ពីបទពុករលួយទេ ដូចជាករណីនៃ KICAC ក្នុងពេលបច្ចុប្បន្ននេះជាដើម ។ ចំពោះអង្គភាពប្រឆាំងអំពើពុករលួយដែលមានមុខនាទីស៊ើបអង្កេតនេះ គឺមានលក្ខណៈខុសគ្នាត្រង់ប្រការដែលថា ពេលណាត្រូវចាប់ផ្តើមធ្វើការស៊ើបអង្កេតលើករណីចោទប្រកាន់ពីបទពុករលួយ ឬលើការសង្ស័យពីបទពុករលួយឡើយ។ តាមគោលគំនិត គឺថា ACA អាចផ្តើមការស៊ើបអង្កេតលើពាក្យបណ្តឹងដែលខ្លួនបានទទួល រួមទាំងអាចបើកការស៊ើបអង្កេតតាមចិត្តរបស់ខ្លួន ដោយមិនចាំបាច់មានពាក្យបណ្តឹង។ ក្នុងករណីខ្លះ ការស៊ើបអង្កេតក៏អាចធ្វើឡើងតាមសំណើរបស់ស្ថាប័នផ្សេងដែរ (ឧទាហរណ៍ៈ ដោយសភា ក្នុងករណី ICAC របស់ញូសៅវែល) ។

តាមធម្មតា ត្រូវមានរចនាសម្ព័ន្ធមួយនៅក្នុង ACA សម្រាប់វិភាគថា តើត្រូវធ្វើការស៊ើបអង្កេតឬក៏មិនធ្វើ ដោយផ្អែកលើរបាយការណ៍ដែលទទួលបាន។ ក៏ប៉ុន្តែ ក្នុងករណីខ្លះ ACA ត្រូវតែស៊ើបអង្កេតលើរាល់របាយការណ៍ដែលខ្លួនបានទទួល (ឧទាហរណ៍ ICAC របស់ហុងកុង)។ ដោយហេតុថា របាយការណ៍ពីសាធារណជនភាគច្រើន គឺជាប្រភពព័ត៌មានសំខាន់នោះ ACA ជាច្រើន បានដាក់ឱ្យដំណើរការនូវយន្តការមួយ ដើម្បីធានាឱ្យប្រជាជនអាចរាយការណ៍បាន និងសម្រួលដល់ការធ្វើរបាយការណ៍។ នៅហុងកុង ICAC បានបង្កើតការិយាល័យស្រុកប្រចាំតំបន់ (ព្រោះគេបានរកឃើញថា នៅក្នុងទីតាំងដែលមិនសូវផ្លូវការ បុគ្គលម្នាក់ៗមានអារម្មណ៍ស្ងប់ស្ងួលជាង) ហើយ KICAC នៅសាធារណរដ្ឋកូរ៉េ បានបង្កើតនូវ**មជ្ឈមណ្ឌលរាយការណ៍អំពីអំពើពុករលួយ**មួយ ។ ផ្ទុយទៅវិញ នីតិវិធីដ៏ស្មុគស្មាញសម្រាប់ដាក់ពាក្យប្តឹងជាមួយគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធរបស់ប្រទេសនីហ្សេរីយ៉ា ត្រូវបានគេយល់ឃើញថាជាមូលហេតុដែលនាំឱ្យគណៈកម្មការទទួលបានពាក្យបណ្តឹងតិចតួច ។

ការភ័យខ្លាចអំពីការសងសឹកលើការរាយការណ៍អំពើពុករលួយ គឺជាការខ្លាចរអារយ៉ាងធ្ងន់ធ្ងរ ចំពោះការចូលរួមរបស់សាធារណជន ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងបន្ទុចបង្អាក់សក្តានុពលសម្រាប់ជោគជ័យ។ ហេតុនេះ ការបើកលទ្ធភាពឱ្យរាយការណ៍ជាអនាមិក និងការការពារសាក្សី ត្រូវបានមើលឃើញថាជាធាតុសំខាន់នៃយុទ្ធសាស្ត្រជោគជ័យ ដើម្បីប្រឆាំងអំពើពុក រលួយ។ ភាគច្រើន ប៉ុន្តែមិនមែនទាំងអស់ទេ ទីភ្នាក់ងារប្រឆាំងអំពើ ពុករលួយ ACA (ដូចជា NCCC នៅប្រទេសថៃ) ពិតជាទទួលយករបាយការណ៍អនាមិក។

ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA ជាច្រើន (ដូចជា ICAC នៅហុងកុង KICAC នៅសាធារណរដ្ឋកូរ៉េ និង KPK នៅឥណ្ឌូនេស៊ី) មានអាណត្តិការងារច្បាស់លាស់ សម្រាប់ធានាដល់ការការពារសាក្សី និងអ្នកបង្ហើបឱ្យដឹង (គឺអ្នករាយការណ៍អំពីអំពើពុករលួយ)។ នៅកន្លែងណា ដែលគេឃើញថាការការពារសាក្សីបានទទួលជោគជ័យ នោះវាក៏នាំឱ្យធ្លាក់ចុះនូវចំនួនរបាយការណ៍អនាមិកអំពីអំពើពុករលួយ។ មន្ត្រី និងបុគ្គលិករបស់ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA ផ្សេងៗ នៅក្នុងឯកសារដកស្រង់នេះ មានកម្រិតអំណាចស៊ើបអង្កេតខុសៗគ្នា។ អំណាចទាំងនេះ រួមមាន ការឆែកឆេរខ្លួនបុគ្គល និងឆែកឆេរទីតាំងផ្ទះសម្បែង ការចាប់ខ្លួន និង/ឃុំខ្លួន អំណាចស្នើឱ្យបុគ្គលឬស្ថាប័នផ្តល់ព័ត៌មាន អំណាចស្នើសុំមើលសៀវភៅធនាគារ ដាក់ចេញនូវវិធានការឃ្លាំមើល ឧទាហរណ៍ ដូចជា ការថតសំលេងសន្ទនាគ្នា និងរឹបអូសទ្រព្យសម្បត្តិជាដើម។ ជាញឹកញយ អំណាចនៃការស៊ើបអង្កេតទាំងនេះ តម្រូវឱ្យមន្ត្រីស៊ើបអង្កេត ស្នើសុំការឯកភាពជាលាយល័ក្ខណ៍អក្សរជាមុនពីព្រះរាជអាជ្ញា (ឧទាហរណ៍ ម៉ាឡេស៊ី និងសិង្ហបុរី) ឬពីចៅក្រម/តុលាការ (ឧ. ប្រទេសថៃ) និងករណីខ្លះពីប្រធានអង្គភាពប្រឆាំងអំពើពុករលួយ (នីហ្សេរីយ៉ា តង់ហ្សានី)។

ផ្នែកដ៏សំខាន់មួយនៃមុខងារស៊ើបអង្កេត គឺការតាមដានត្រួតពិនិត្យ**ការប្រកាសទ្រព្យសកម្ម និងអកម្ម** (ហើយនិងពិនិត្យជីវភាព) របស់មន្ត្រីជាន់ខ្ពស់ ព្រោះវាអាចមានឥទ្ធិពលខ្លាំងដែរ ក្នុងការទប់ស្កាត់អំពើពុករលួយ។ ដោយឡែក NCCC នៅប្រទេសថៃ មានអាណត្តិការងារទូលំទូលាយ និងយ៉ាងច្បាស់លាស់ក្នុងវិស័យនេះ[៧]។ នេះគឺជាករណីនៃការិយាល័យបង្ការ និងប្រឆាំងអំពើពុករលួយ នៅប្រទេសឡាត់វៀ[៨] (CPCB) ដែលមានភារកិច្ចតាមដានត្រួតពិនិត្យនូវការប្រតិបត្តិតាមច្បាប់ស្តីពីការទប់ស្កាត់ទំនាស់ផលប្រយោជន៏ នៅក្នុងសកម្មភាពរបស់មន្ត្រីសាធារណៈ។ កាលណាមានតម្រូវការឱ្យរក្សាការសម្ងាត់ សមត្ថភាពក្នុងការស៊ើបអង្កេតលើការប្រកាសនូវទ្រព្យសម្បត្តិ ច្រើនតែមានការលំបាក ដោយហេតុថា វាមិនអាចឱ្យមានការងារ បន្ថែមពីខាងក្រៅ ចំពោះអ្នកស៊ើបអង្កេតពីក្រៅស្ថាប័នឡើយ (នេះគឺ ជាករណីនៅប្រទេសបូតស្វាណា)។ ប៉ុន្តែ ទីភ្នាក់ងារផ្សេងៗទៀតក៏ អាចចូលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតការប្រកាសទ្រព្យសម្បត្តិនេះ ផងដែរ។ នៅប្រទេសប៊ុលហ្គារី ការិយាល័យសវនកម្មជាតិកាន់កាប់ បញ្ជីប្រកាសទ្រព្យរបស់មន្ត្រីជាន់ខ្ពស់។ នៅប្រទេសលីទុយអានី មន្ត្រីជាន់ខ្ពស់ត្រូវធ្វើការប្រកាសទ្រព្យរបស់ខ្លួន ជូនគណៈកម្មការក្រមសីលធមិរបស់មន្ត្រី ដែលមានភារកិច្ចវិភាគការប្រកាសទាំងនេះ។ នៅប្រទេសហ្វីលីពីន មន្ត្រីសាធារណៈ តម្រូវឱ្យធ្វើសេចក្តីប្រកាស ភ្ជាប់ដោយពាក្យសម្បថអំពីទ្រព្យសកម្ម និងអកម្មរបស់ខ្លួនជារៀងរាល់ឆ្នាំ[៩] ហើយការត្រួតពិនិត្យជីវភាព អាចត្រូវបានធ្វើឡើងដោយការិយាល័យ ទទួលពាក្យបណ្តឹង ឬដោយគណៈកម្មការប្រឆាំងអំពើពុករលួយរបស់ ប្រធានាធិបតី។ នៅប្រទេសលីទុយអានី ការទទួលខុសត្រូវស្ថិតនៅលើ ប្រធានគណៈកម្មការក្រមសីលធមិមន្ត្រី ដែលវិភាគលើការប្រកាសទ្រព្យ ហើយនិងធានាថា អ្នកកាន់តំណែងសាធារណៈប្រាកដជាធ្វើសេចក្តីសម្រេចដើម្បីតែប្រយោជន៏សាធារណៈ ដោយមិនលំអៀងក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងទប់ស្កាត់នូវការកើតឡើង និងការរាលដាលនៃអំពើពុករលួយនៅក្នុងសេវាសាធារណៈ។ នៅប្រទេសតង់ហ្សានី គឺលេខាធិការដ្ឋាននៃក្រមសីលធមិមេដឹកនាំសាធារណៈ ដែលដឹកនាំដោយស្នងការក្រមសីលធមិ (តែងតាំងដោយ ប្រធានាធិបតី) ដែលមានភារកិច្ចទទួលសេចក្តីប្រកាសទ្រព្យសម្បត្តិ។

ក្នុងគ្រប់ករណីទាំងអស់ ទំនាក់ទំនងរវាងទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA និងអង្គភាពទទួលបន្ទុកតាមដានត្រួតពិនិត្យការប្រកាសទ្រព្យ និងត្រួតពិនិត្យសំណុំឯកសារពន្ធចំណូល មានសារៈសំខាន់យ៉ាងខ្លាំង ។ បន្ទុកនៃភស្តុតាងត្រូវបានបន្ថយកាន់តែច្រើនឡើងៗ។ ទោះបីជាទ្រឹស្តីតាមប្រពៃណី ប្រកាន់យកគោលការណ៏នៃ "ការសន្មត់ថាគ្មានទោស" រហូតទាល់តែព្រះរាជអាជ្ញាអាចបង្ហាញនូវ

---

[៧] បុគ្គលដែលកាន់តំណែងនយោបាយ ព្រមទាំងមន្ត្រីរដ្ឋាភិបាលដែលមានឋានន្តរស័ក្តិខ្ពស់ (ថ្នាក់កណ្តាល និងមូលដ្ឋាន) ត្រូវដាក់ជូនទៅ NCCC នូវគណនេយ្យទ្រព្យសកម្ម និងអកម្មរបស់ខ្លួន ព្រមទាំងរបស់ប្រពន្ធរបស់ខ្លួន និងកូន (ក្នុងបន្ទុក) (រៀងរាល់ ៣ឆ្នាំម្តង ព្រមទាំងនៅពេលចូលកាន់តំណែង ចាកចេញពីតំណែង មួយឆ្នាំក្រោយពីចាកចេញពីតំណែង)។ NCCC មានភារកិច្ចកំណត់នូវប្រភេទមុខតំណែង ដែលតម្រូវឱ្យធ្វើអធិការកិច្ចលើទ្រព្យសកម្ម និងត្រូវហាមឃាត់តាមវិធាន និងនីតិវិធីពាក់ព័ន្ធ។ NCCC អាចធ្វើអធិការកិច្ចរាល់ករណីណាក៏ដោយ ដែលមានមូលហេតុត្រឹមត្រូវដើម្បីសង្ស័យមន្ត្រីរដ្ឋាភិបាលណាម្នាក់ (ទោះបីជាបុគ្គលនោះមិនមែនជាមន្ត្រីជាន់ខ្ពស់ក៏ដោយ) ហើយបញ្ជាឱ្យមន្ត្រីរដ្ឋាភិបាលរូបនោះ ដាក់ជូននូវការប្រកាសបែបនេះ។

[៨] CBCB នៅឡាតវៀ ក៏តាមដានត្រួតពិនិត្យនូវការអនុវត្តរបស់អង្គភាពនយោបាយ អំពីបទប្បញ្ញត្តិរបស់គណៈបក្សដែលផ្តល់ហិរញ្ញប្បទាន។

[៩] ការស៊ើបអង្កេត/ការត្រួតពិនិត្យអំពីជីវភាព នឹងធ្វើទៅលើមន្ត្រីទាំងអស់របស់រដ្ឋាភិបាល ប៉ុន្តែជាដំបូងវានឹងផ្តោតទៅលើមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ (ទោះជាត្រូវបានជាប់ឆ្នោត ឬតែងតាំងក៏ដោយ) ព្រមទាំងទៅលើមន្ត្រីទាំងអស់របស់ភ្នាក់ងារក្រោយពីរាយការណ៍ថាមានជាប់ពាក់ព័ន្ធអំពើពុករលួយខ្លាំងបំផុតគឺ : ការិយាល័យចំណូលផ្ទៃក្នុងការិយាល័យគយ និងនាយកដ្ឋានសាធារណៈការ និងផ្លូវ Highway។

អំពើខុសច្បាប់ក៏ដោយក៏នៅពេលនេះ ច្បាប់ប្រឆាំងអំពើពុករលួយកាន់តែសន្មត់ថា គឺជាការមានបានដោយខុសច្បាប់ ដរាបណាជនជាប់ចោទមិនអាចពន្យល់ឱ្យបានសមរម្យ អំពីជីវភាពមិនធម្មតារបស់ខ្លួនទេនោះ។ ការប្រកាសទ្រព្យគួរត្រូវធ្វើឡើងដោយមន្ត្រីរាជការទាំងអស់ឬតែមន្ត្រីមួយចំនួន គឺនៅតែជាបញ្ហាដែលត្រូវ ពិភាក្សាគ្នានៅឡើយ[១០]។ ដើម្បីជៀសវាងនូវការប្រកាសច្រើនពេក និងការចំណាយច្រើនលើសលប់សម្រាប់ការស៊ើបអង្កេត[១១] ការមានវិធីជ្រើសរើសមួយគឺអាចនឹងមានភាពសមស្របជាង។ បើជំនាញ និងសមត្ថភាពមានកម្រិត គេបានស្នើឱ្យផ្តោតគោលដៅតែទៅលើក្រុមមន្ត្រីសាធារណៈសំខាន់ៗខ្លះប៉ុណ្ណោះ (ឧទាហរណ៍ៈ មន្ត្រីនយោបាយដែលជាប់ឆ្នោត ឬតែងតាំង មន្ត្រីសាធារណៈថ្នាក់ខ្ពស់) ព្រមទាំងអ្នកដែលបម្រើការនៅក្នុងវិស័យការងារ ដែលងាយនឹងប្រព្រឹត្តអំពើពុករលួយខ្លាំងៗ (ឧ. មន្ត្រីលទ្ធកម្ម និងមន្ត្រីគយ និងពន្ធដារ)។

ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA មិនមែនសុទ្ធតែមាន **អាណត្តិការងារ ដើម្បីធ្វើបណ្តឹងអាជ្ញា** (គឺរៀបចំបែបបទប្តឹងចោទពីបទល្មើសព្រហ្មទណ្ឌ) ដែលតាមធម្មតា គឺជាកិច្ចការមួយស្ថិតនៅក្នុងភារកិច្ចរបស់តុលាការ[១២]។ បន្ទាប់ពីការស៊ើបអង្កេតរបស់ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA[១៣] ឬភ្នាក់ងារអនុវត្តន៍ច្បាប់ណាមួយ (ឧ. ប៉ូលីស) ប្រសិនបើមានហេតុផលអាចឱ្យធ្វើបណ្តឹងអាជ្ញាបាន បញ្ហានេះត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញា ដើម្បីនាំរៀបចំសំណុំបែបបទដាក់ទៅតុលាការ។ ផ្អែកលើភស្តុតាងជាក់ស្តែង ដែលបានផ្តល់ជូន តុលាការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីសម្រេចថា តើត្រូវផ្តើមដំណើរការព្រហ្មទណ្ឌដែរឬអត់។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានបែបបទគួរឱ្យចាប់អារម្មណ៍មួយចំនួនផងដែរ។ នៅប្រទេសបូតស្វាណា អគ្គមេធាវី មានអំណាចតាមរដ្ឋធម្មនុញ្ញ និងតាមច្បាប់ព្រហ្មទណ្ឌក្នុងការដឹកនាំរាល់ការចោទប្រកាន់ព្រហ្មទណ្ឌទាំងអស់ រួមទាំងការចោទប្រកាន់លើគ្រប់ករណីដែលពាក់ព័ន្ធនឹងអំពើពុករលួយ។ ប៉ុន្តែដោយទំហំការងាររបស់អគ្គមេធាវីធ្ងន់ធ្ងរពេក នាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មអំពើពុករលួយ និងសេដ្ឋកិច្ច DCEC ក៏ផ្តើមធ្វើការចោទប្រកាន់ដោយខ្លួនឯងកាន់តែច្រើនឡើងៗ។ នៅប្រទេសលីទុយអានី ការិយាល័យស៊ើបអង្កេតរបស់ SIS រាយការណ៍ផ្ទាល់ទៅអគ្គរដ្ឋអាជ្ញា ហើយពួកគេមិនអាចស្ថិតក្រោមឥទ្ធិពលរបស់ប្រធានការិយាល័យ SIS ឡើយ។ នៅប្រទេសលីទុយអានី ប៉ូលីសមានកាតព្វកិច្ចទូទៅក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្មណាក៏ដោយ ដែលបានដាក់ស្នើមកគេ ដោយរួមទាំងករណីអំពើពុករលួយផងដែរ ប៉ុន្តែ ករណីអំពើពុករលួយជាធម្មតា តែងតែដាក់ជូនទៅ SIS ឬព្រះរាជាអាជ្ញា។ នៅប្រទេសតង់ហ្សានី ជាធម្មតា ការធ្វើបណ្តឹងអាជ្ញា គឺជាអាណត្តិការងាររបស់នាយកការិយាល័យអយ្យការសាធារណៈ។ ក៏ប៉ុន្តែ ការិយាល័យបង្ការអំពើពុករលួយ PCB ក៏អាចធ្វើបណ្តឹងអាជ្ញាលើករណីនេះដោយខ្លួនឯងបាន ក្រោយពីមានការឯកភាពពីនាយកការិយាល័យអយ្យការសាធារណៈ ដែលនៅក្នុងករណីនេះគឺជាផ្នែកច្បាប់ និងការចោទប្រកាន់នៅក្នុង PCB ដែលទទួលបន្ទុកធ្វើបណ្តឹងអាជ្ញាលើបទល្មើសនៃអំពើពុករលួយ។ ដើម្បីធ្វើការងារនេះ ផ្នែកនេះត្រូវសហការជិតស្និទ្ធជាមួយប៉ូលីស និងការិយាល័យអយ្យការសាធារណៈ។

តែទោះជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ឆន្ទានុសិទ្ធិនេះក៏ងាយនឹងនាំឱ្យប្រព្រឹត្តអំពើពុករលួយដែរ។ មានស្ថានភាពមួយចំនួនដែល ACA គួរមានអាទិភាពក្នុងការស៊ើបអង្កេត និងគួរតែត្រូវបានផ្តល់អំណាចឱ្យអាចធ្វើសកម្មភាពដោយខ្លួនឯង ដូចជាព្រះរាជអាជ្ញាមួយរូប ដែលស្ថិតក្រោមការត្រួតពិនិត្យសមស្របតាមផ្លូវតុលាការ។ នៅប្រទេសថៃ គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ NCCC ដើរតួនាទីជាព្រះរាជអាជ្ញា ក្នុងគ្រប់ករណីទាំងអស់ដែលត្រូវបានដាក់ជូនតុលាការធម្មនុញ្ញ (ការប្រកាសទ្រព្យសម្បត្តិ)។ NCCC នេះក៏អាចដើរតួនាទីជាព្រះរាជអាជ្ញាបានដែរ នៅពេលដែលជនជាប់ចោទជាអគ្គព្រះរាជអាជ្ញាខ្លួនឯង។ ជាចុងក្រោយ នៅពេលដែលអគ្គព្រះរាជអាជ្ញា ចាត់ទុកថារបាយការណ៍របស់ NCCC មិនគ្រប់គ្រាន់ ហើយមិនមានការសំអាងសមស្របដើម្បីធ្វើបណ្តឹងអាជ្ញា ហើយក៏មិនអាចឯកភាពគ្នាបានទេនោះ NCCC អាចសម្រេចដើរតួដោយខ្លួនឯងជាព្រះរាជអាជ្ញានៅក្នុងរឿងនេះ។ នៅប្រទេសឥណ្ឌូនេស៊ី គណៈកម្មការ

[១០] ជាឧទាហរណ៍ ដូចជានៅប្រទេសសិង្ហបូរី មន្ត្រីរដ្ឋការទាំងអស់ត្រូវប្រកាសអំពីការមិនមានជាប់ជំពាក់បំណុល និងទ្រព្យសម្បត្តិ ព្រមទាំងការវិនិយោគនានា ខណៈពេលដែលទទួលបានការតែងតាំង និងជាបន្តបន្ទាប់មកទៀត ត្រូវធ្វើការប្រកាសរៀងរាល់មួយឆ្នាំម្តង។

[១១] នៅប្រទេសហ្វីលីពីន គេបានប៉ាន់ស្មានថា ការចំណាយសម្រាប់ការស្រាវជ្រាវលើរឿងក្តីមួយ ប្រហែល ២.000ដុល្លារ។ នៅឆ្នាំ ២00៤ ពេលវេលាជាមធ្យមសម្រាប់ការស៊ើបអង្កេតទៅលើរឿងក្តីមួយ មានរយៈពេលប្រហែល ៣ខែ ថែមទាំងរយៈពេល ១0ខែទៀត សម្រាប់ដំណើរការនៅការិយាល័យទទួលពាក្យបណ្តឹង (កាត់បន្ថយពីពេលមុន ដែលចំណាយពេល ២ឆ្នាំ ជាមធ្យម)។

[១២] នៅហុងកុង អំណាចធ្វើការចោទប្រកាន់បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត ត្រូវបានផ្តល់ជូនរដ្ឋមន្ត្រីយុត្តិធម៌ ដែលនេះធានាថាគ្មានករណីណាទាល់តែសោះដែលត្រូវបានបញ្ជូនទៅកាន់តុលាការ តែដោយសារការកាត់សេចក្តីរបស់ ICAC នោះទេ។

[១៣] KICAC របស់សាធារណរដ្ឋកូរ៉េ ត្រូវបានផ្តល់អាណត្តិដើម្បីធ្វើការស៊ើបអង្កេត។ CPIB របស់សិង្ហបុរីអាចធ្វើការស៊ើបអង្កេតបានតែនៅពេលណាមានការឯកភាពពីព្រះរាជអាជ្ញាប៉ុណ្ណោះ។

លុបបំបាត់អំពើពុករលួយ KPK មានអំណាចចោទប្រកាន់ ឬធ្វើបណ្តឹងអាជ្ញាលើរឿងអំពើពុករលួយណាមួយ ដែលប៉ូលីស ឬការិយាល័យអយ្យការកំពុងចាត់ការ (ដែលបន្ទាប់មក ប៉ូលីស ឬការិយាល័យអយ្យការត្រូវប្រគល់រាល់លិខិតស្នាមទាំងអស់ទៅឱ្យ KPK)។ ប្រការបែបនេះកើតឡើងនៅពេលណាដែលប៉ូលីស ឬការិយាល័យអយ្យការមិនអាចចាត់ការលើរឿងណាមួយបានទាន់ពេលវេលា និងមិនអាចឆ្លើយតបតាមតម្រូវការបាន[១៤]។ នៅប្រទេសឡាតវៀ ការិយាល័យបង្ការ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ CPCB មានអំណាចទាញយកករណី ពីស្ថាប័នស៊ើបអង្កេតផ្សេងៗមកចាត់ការ បើករណីទាំងឡាយនោះ ស្ថិតនៅក្នុងអាណត្តិការងាររបស់ខ្លួន។ នេះក៏ដូចគ្នានៅតង់ហ្សានីដែរ គឺអគ្គនាយកការិយាល័យទប់ស្កាត់អំពើពុករលួយ PCB អាចចាត់ចែង ការស៊ើបអង្កេត ឬធ្វើបណ្តឹងអាជ្ញាជាជំនួសប៉ូលីសលើបទល្មើសពាក់ព័ន្ធ នឹងអំពើពុករលួយទាំងឡាយណា ដែលប៉ូលីសបានផ្តើម។

នៅក្នុងបណ្តាប្រទេសទាំងឡាយណា ដែលសេវាកម្មរបស់ប៉ូលីស និងរបស់អយ្យការត្រូវបានចាត់ទុកថាពុករលួយខ្លាំង វិធានការទាំងនេះមានសារៈសំខាន់ណាស់។ នៅពេលណាដែលមន្ត្រីជាន់ខ្ពស់ជាប់ពាក់ព័ន្ធក្នុងសកម្មភាពពុករលួយ ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA អាចជាអង្គភាពតែមួយគត់ ដែលមានឯករាជភាពគ្រប់គ្រាន់ ក្នុងការនាំយករឿងនោះទៅតុលាការ។ ប៉ុន្តែ នៅទីណាដែលសេវាកម្ម ផ្នែកអយ្យការមានដំណើរការត្រឹមត្រូវហើយនោះ គេមិនចាំបាច់ឱ្យ មានអំណាចធ្វើបណ្តឹងអាជ្ញានៅដោយឡែកឡើយ (UNODC, ២004:៩២)។

ករណីពិសេសមួយពាក់ព័ន្ធនឹងការដកមន្ត្រីជាន់ខ្ពស់ចេញពីតំណែង។ តាមធម្មតា ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA មិនអាចធ្វើបណ្តឹងចោទប្រកាន់ប្រធានាធិបតីកំពុងកាន់តំណែង ឬមន្ត្រីជាន់ខ្ពស់ផ្សេងទៀតឡើយ ដោយហេតុថា ពួកគេតែងមានអភ័យឯកសិទ្ធិតាមច្បាប់រដ្ឋធម្មនុញ្ញ។ ហេតុដូច្នេះ ជាគោលការណ៍ ដំណើរការដកតំណែង គឺជាភារកិច្ចរបស់អង្គនីតិបញ្ញត្តិជាតិ។ តែទោះជាយ៉ាងដូចនេះក៏ដោយ ច្បាប់អាចអនុញ្ញាតឱ្យ ACA ផ្តល់របាយការណ៍ជូនប្រធានរដ្ឋសភា នៅពេលណាដែលមានហេតុផលសមស្របអាចជឿបានថា ប្រធានាធិបតី ឬមន្ត្រីជាន់ខ្ពស់ណាម្នាក់ បានប្រព្រឹត្តបទល្មើស ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ការពិត ដែលអាចយកជាការបាននៅក្នុងតុលាការ (Pope, ១៩៩៩)។ បន្ទាប់ពីនោះមក តាមធម្មតា គឺជាការទទួលខុសត្រូវរបស់អង្គនីតិបញ្ញត្តិ ក្នុងដំណើរការដកតំណែង ដោយអនុលោមតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ។

កម្មវិធីប្រឆាំងអំពើពុករលួយជាច្រើនត្រូវបានចាត់ទុកថាជាឧបករណ៍របស់រដ្ឋ ដែលផ្តោតជាពិសេសទៅលើមន្ត្រីរាជការស៊ីវិល និង ឬស្ថាប័ននិយ័តកម្មពាក់ព័ន្ធផ្សេងៗទៀត។ បទពិសោធហុងកុងបានបង្ហាញឱ្យឃើញថា **មុខងារអប់រំ និងលើកកម្ពស់ការយល់ដឹង** មានសារៈសំខាន់នៅក្នុងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយនីមួយៗ។ តម្លាភាព គឺជាការចាំបាច់ សម្រាប់បង្កើតនូវជំនឿទុកចិត្តក្នុងកម្រិតអប្បបរមា ដើម្បីទប់ស្កាត់ និងជាវិធានការឆ្ពោះទៅរកជោគជ័យ។ ICAC របស់ហុងកុង ត្រូវបានកត់សម្គាល់អំពីកម្មវិធីប្លែកពីគេ ក្នុងការគ្របដណ្តប់ដល់សាធារណជន។ កម្មវិធីនេះបានប្រើប្រាស់សេចក្តីប្រកាសព័ត៌មាន ការផ្សព្វផ្សាយព័ត៌មានសាធារណៈ បទសម្ភាសន៍ ឯកសារ ផ្ទាំងរូបភាព ក្រដាសព័ត៌មាន កិច្ចប្រជុំ ការនិយាយជាសាធារណៈ និងបានធ្វើការជាមួយសាលារៀន និង សាកលវិទ្យាល័យ ដើម្បីបញ្ជូនសារអំពីការប្រឆាំងអំពើពុករលួយ ទៅដល់សាធារណជន។ កម្មវិធីនេះឧបត្ថម្ភគាំទ្រដល់កម្មវិធីកីឡា វប្បធម៌ និងនាទីកំសាន្តផ្សេងៗ ដែលផ្តោតលើយុវជន និងដែលសង្កត់ធ្ងន់លើប្រធានបទប្រឆាំងអំពើពុករលួយ។ នៅឆ្នាំ ១៩៩៥ កម្មវិធីនេះបានដឹកនាំកិច្ចខិតខំប្រឹងប្រែងសហប្រតិបត្តិការមួយជាមួយសភាពាណិជ្ជកម្មធំៗ ចំនួន ៦ ក្នុងការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សីលធម៌ហុងកុង ដើម្បីលើកកម្ពស់សីលធម៌នៅក្នុងក្រុមហ៊ុន ។ ទន្ទឹមនឹងនេះ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ICAC នៅរដ្ឋញូសៅវែល ក៏មានអាណត្តិការងារទូលំទូលាយនៅក្នុងវិស័យនេះដែរ[១៥]។ ICAC របស់រដ្ឋញូសៅវែល បើកសវនាការសាធារណៈដើម្បីបង្ហាញអំពីអំពើពុករលួយ។ សវនាការទាំងនេះ ក៏ជួយបង្កើនទំនុកចិត្តពីសាធារណជនទៅលើសុចរិតភាពនៃការស៊ើបអង្កេត។ នៅពេលនេះ ប្រទេសម៉ាឡេស៊ី ក៏ផ្តោតកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយកម្មវិធីប្រឆាំងអំពើ

---

[១៤] មាត្រា ៩ នៃច្បាប់ស្តីពី KPK ចែងថា KPK ត្រូវដើរតួនាទីចោទប្រកាន់ ឬកាត់ទោស ប្រសិនបើ : របាយការណ៍មួយរបស់សមាជិកម្នាក់នៃសាធារណជនទូទៅអំពីពើពុករលួយ មិនត្រូវបានអើពើ។ ការចាត់ការលើករណីពុករលួយបានបន្តក្នុងរយៈពេលយូរពេក ឬត្រូវបានពន្យារពេលដោយគ្មានហេតុផលយកជាការបាន។ ការដោះស្រាយករណីពុករលួយត្រូវបានប្រើល្បិចដើម្បីការពារជនជាប់ចោទ។ ការដោះស្រាយករណីពុករលួយ អាស្រ័យទៅតាមអំពើពុករលួយ។ មានអន្តរាគមន៍ពីផ្នែកនីតិប្រតិបត្តិ នីតិបញ្ញត្តិ និង តុលាការនៅក្នុងរឿងក្តី ឬកាលៈទេសៈណាមួយផ្សេងទៀតដែលប៉ូលីស ឬការិយាល័យអយ្យការមិនអាចចាត់ការលើរឿងក្តី ឱ្យបានទាន់ពេលវេលា និងឆ្លើយតបទៅតាមសេចក្តីត្រូវការបាន។

[១៥] នៅពេលនេះ ស្ទើរតែមួយនៅក្នុងរបាយការណ៍ ១០ អំពីអំពើពុករលួយនៅក្នុងវិស័យឯកជន ត្រូវបានធ្វើឡើងដោយអ្នកចាត់ចែងជាន់ខ្ពស់នៃអាជីវកម្ម (ICAC website – Hong Kong)។

ពុករលួយ ទៅដល់គ្រួសារដែលជាស្នូលដ៏សំខាន់នៅក្នុងសង្គម។ ការផ្តោតលើសង្គមគ្រួសារក៏បានបើកឱកាសឱ្យមានការចូលរួមផងដែរពីសំណាក់យុវជនដែលជាអ្នកដឹកនាំជំនាន់ក្រោយ។ នៅក្នុងក្របខ័ណ្ឌនៃផែនការសុចរិតភាពរបស់ប្រទេសម៉ាឡេស៊ី ដែលផ្អែកលើលទ្ធផលនៃការអង្កេតថ្នាក់ជាតិ កាលពីខែមករា ឆ្នាំ ២០០៣ ស្តីអំពីសាធារណមតិចំពោះអំពើពុករលួយ រដ្ឋាភិបាលបានបង្កើតវិទ្យាស្ថានសុចរិតភាពម៉ាឡេស៊ី ដែលតាមរយៈនោះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីអំពើពុករលួយ និងសេចក្តីត្រូវការឱ្យមានតម្លាភាពនៅក្នុងសេវាសាធារណៈ (ADB/ OECD, ២០០៤:៥៥)។

ក្រៅពីវិធានការអប់រំទូទៅ ACA គួរស្ថិតក្នុងតួនាទីកសាងធ្វើសំណើ និងអនុវត្ត**វិធានការទប់ស្កាត់**តាមការចាំបាច់និង/ឬសហការជិតស្និទ្ធជាមួយភ្នាក់ងារផ្សេងៗទៀត ដែលមានអាណត្តិការងារបែបនេះ។ ICAC របស់ហុងកុងមានអាណត្តិការងារទូលំទូលាយ ក្នុងវិស័យនេះ[១៦]។ វិធានការទប់ស្កាត់នេះ គឺដើម្បីពិនិត្យពិច័យលើការប្រតិបត្តិ និងពិនិត្យលើនីតិវិធីរបស់ក្រសួងនានារបស់រដ្ឋាភិបាល និងអង្គភាពសាធារណៈ ដើម្បីសម្រួលដល់ការបើកកកាយអំពើពុករលួយ និងធានានូវការកែប្រែវិធីសាស្ត្រ/នីតិវិធីការងារ ដែលនាំទៅរកការប្រព្រឹត្តិអំពើពុករលួយ។ លើសពីនេះទៅទៀតត្រូវណែនាំផ្តល់យោបល់ និងជួយដល់បុគ្គលណាម្នាក់ តាមសំណើរបស់បុគ្គលនោះ អំពីរបៀបដែលអាចលុបបំបាត់អំពើពុករលួយបាន និងផ្តល់មតិជូនប្រធានស្ថាប័នរដ្ឋ ឬអង្គភាពសាធារណៈ អំពីការផ្លាស់ប្តូរការអនុវត្ត ឬនីតិវិធី ដែលស៊ីគ្នាទៅនឹងការបំពេញភារកិច្ចដ៏មានប្រសិទ្ធភាព ដែលលោកស្នងការយល់ឃើញថាមានការចាំបាច់ ដើម្បីកាត់បន្ថយលទ្ធភាពដែលអាចប្រព្រឹត្តអំពើពុករលួយ។ នាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មអំពើពុករលួយ និងសេដ្ឋកិច្ច DCEC របស់ប្រទេសបូតស្វាណា ការិយាល័យបង្ការ និងស៊ើបអង្កេតអំពើពុករលួយ CPIB របស់សិង្ហបុរី និងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ICAC របស់ញូវសៅវែលមានអាណត្តិការងារប្រហាក់ប្រហែលគ្នា។ គណៈកម្មការលុបបំបាត់អំពើពុករលួយ KPK របស់ឥណ្ឌូនេស៊ីក៏មានអាណត្តិការងារទូលំទូលាយ ដើម្បីតាមឃ្លាំមើលអភិបាលកិច្ចរបស់រដ្ឋដែរ។ វាអាចធ្វើការពិនិត្យសារឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នរដ្ឋទាំងអស់ ហើយប្រសិនបើមិនអនុវត្តតាមអនុសាសន៍របស់ KPK ទេនោះ KPK ត្រូវរាយការណ៍បញ្ហានេះជូន ប្រធានាធិបតី សភា ហើយនិងសវនកររបស់រដ្ឋ។ ការិយាល័យ ទប់ស្កាត់អំពើពុករលួយ PCB របស់ប្រទេសតង់ហ្សានី (ការិយាល័យ ស្រាវជ្រាវ ត្រួតពិនិត្យ និងស្ថិតិ) ស្រាវជ្រាវលើគោលនយោបាយ ផ្សេងៗ ច្បាប់ បទបញ្ញត្តិ និងកិច្ចប្រតិបត្តិការរបស់ស្ថាប័នផ្សេងៗ ដើម្បីស្វែងរកកង្វះខាតដែលនាំទៅដល់អំពើពុករលួយ។ វាក៏ស្រាវជ្រាវលើវិធីសាស្ត្រក្នុងការប្រឆាំងអំពើពុករលួយ ដែលអនុវត្តនៅប្រទេសផ្សេងៗផងដែរ។

ផ្នែកមួយនៃវិធានការបង្ការទាំងនេះ គឺសមត្ថភាពក្នុងការយកមេរៀនដែលបានរៀនសូត្រ មកពិចារណា និងប្រើប្រាស់មេរៀនទាំងនេះ ដើម្បីលើកសំណើកែតម្រូវច្បាប់ បទបញ្ញត្តិ និងនីតិវិធីផ្សេងៗ។ នៅក្នុងប្រទេសខ្លះ ACA អាចធ្វើអនុសាសន៍បែបនេះជាសាធារណៈ ជូនទៅអង្គនីតិបញ្ញត្តិ និងអង្គនីតិប្រតិបត្តិ តាមការចាំបាច់។ ការិយាល័យបង្ការ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ CPCB នៅប្រទេសឡាតវៀ និងសេវាស៊ើបអង្កេតពិសេស SIS នៅប្រទេសលីទុយអានី មានសិទ្ធិវិភាគច្បាប់ និងលើកសំណើ ដើម្បីពិនិត្យសារឡើងវិញ។ SIS មានអំណាចធ្វើសេចក្តីស្នើច្បាប់ដាក់ជូនប្រធានាធិបតី និងសភា។

វិស័យពាក់ព័ន្ធមួយទៀតគឺសមត្ថភាព**ស្រាវជ្រាវ**ទៅលើបញ្ហាពាក់ព័ន្ធនឹងអំពើពុករលួយ ព្រមទាំង**ការគ្រប់គ្រងចំណេះដឹង**។ សមត្ថភាពក្នុងការស្រាវជ្រាវអំពីគំនិតសាធារណៈព្រមទាំងនិន្នាការ និងលក្ខណៈនៃអំពើពុករលួយ មានសារៈសំខាន់ក្នុងការកសាងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ប្រឆាំងអំពើពុករលួយ។ នៅក្នុងការវិភាគរបស់ខ្លួន គណៈកម្មការអឺរ៉ុបបានរកឃើញថា កង្វះខាតសមត្ថភាពស្រាវជ្រាវនៅប្រទេសឡាតវៀ និងលីទុយអានី គឺជាការគួរឱ្យព្រួយបារម្ភ ហើយគេបានផ្តល់អនុសាសន៍ឱ្យកសាងសមត្ថភាពនៅក្នុងវិស័យនេះ។ នៅរដ្ឋញូវសៅវែលវិញ គេបានសន្និដ្ឋានថា សមត្ថភាពនៃការស្រាវជ្រាវដ៏មានប្រសិទ្ធភាព និងសក្តិសិទ្ធបំផុត គឺស្ថិតនៅក្នុង ACA តែម្តង។ នៅក្នុងប្រទេសមួយចំនួន ក្នុងចំណោមប្រទេសដែលសិក្សាខាងក្រោម ACA ពិតជាមានមុខងារស្រាវជ្រាវនេះ។ ប៉ុន្តែនៅក្នុងប្រទេសជាច្រើនទៀត តួនាទីនេះក៏ត្រូវបានអនុវត្តដោយស្ថាប័នផ្សេងៗទៀត ព្រមទាំងសង្គមស៊ីវិលផងដែរ។

## ២.៣. សង្ខេប : គុណសម្បត្តិ និងគុណវិបត្តិនៃអង្គភាពឯករាជ្យប្រឆាំងអំពើពុករលួយ

[១៦] ការបង្ការ (ការអប់រំ និងលើកកម្ពស់ការយល់ដឹងរបស់សហគមន៍) គឺជាសកម្មភាពស្នូលនៃគំរូហុងកុង ដែលជួនកាលត្រូវបានជូនព័ត៌មានដោយអ្នកស៊ើបអង្កេតដែលធ្វើការលើផ្នែកអនុវត្តន៍ច្បាប់។ នេះអនុញ្ញាតឱ្យគណៈកម្មការកសាងនូវយុទ្ធសាស្ត្រ ដែលរលូន និងប្រទាក់ក្រឡាគ្នា ជាមួយលទ្ធផលដែលមនុស្សភាគច្រើនចង់បានយ៉ាងខ្លាំង។ អ្នកដែលព្យាយាមចម្លងតាមគំរូនេះភាគច្រើនបានទទួលបរាជ័យ ព្រោះគេមានការខ្វះខាតទាំងយុទ្ធវិធីដែលរលូន និងធនធានចាំបាច់ដើម្បីអនុវត្ត។

ដោយហេតុថាអំពើពុករលួយកាន់តែជឿនលឿន ភ្នាក់ងារអនុវត្តច្បាប់ធម្មតា កាន់តែមិនអាចរកឃើញ និងមិនអាចប្តឹងចោទលើករណីអំពើពុករលួយដ៏ស្មុគស្មាញបានឡើយ។ បទពិសោធរបស់ CPIB នៅសិង្ហបុរី DCAC នៅបូតស្វាណា ICAC នៅរដ្ឋញូសៅវែល និង ICACនៅហុងកុង បង្ហាញឱ្យឃើញនូវប្រសិទ្ធភាពនៃគណៈកម្មការ ឬទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ដែលអនុវត្តគោលនយោបាយ និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយតែឯង។ បទពិសោធទាំងនេះបង្ហាញឱ្យឃើញថា ACA ចាំបាច់ត្រូវតែនៅដោយឡែកពីប៉ូលីសជាពិសេសនៅពេលដែលគេយល់ថា ប៉ូលីសពុករលួយ។

ប្រទេសកាន់តែច្រើននៅអាស៊ីបានជ្រើសយកទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ដែលមានលក្ខណៈប្រមូលផ្តុំ។ ហុងកុង ម៉ាឡេស៊ី ណេប៉ាល់ និងសិង្ហបុរី បានធ្វើតាមគំរូនេះអស់ជាច្រើនសតវត្សរ៍មកហើយ។ ឥណ្ឌូនេស៊ី គៀរហ្ស៊ីតង់ សាធារណរដ្ឋកូរ៉េ និងប៉ាគីស្ថាន ទើបតែបានបង្កើតគំរូនេះថ្មីៗប៉ុណ្ណោះ ហើយប្រទេសកម្ពុជា និងម៉ុងហ្គោលី បានដំណើរការឆ្ពោះទៅបង្កើតស្ថាប័នបែបនេះ។ នៅបង់ក្លាដែស ច្បាប់ស្តីពីការបង្កើតគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ត្រូវបានអនុម័តកាលពីឆ្នាំ ២០០៤ ប៉ុន្តែ គណៈកម្មការនេះនៅមិនទាន់បានបង្កើតនៅឡើយ (ADB/OECD, ២០០៤)។

ករណីទាំងឡាយដែលបានជោគជ័យក៏បានសង្កត់ធ្ងន់ដែរទៅលើសារៈសំខាន់នៃការប្តេជ្ញាផ្នែកនយោបាយយ៉ាងម៉ឺងម៉ាត់ និងភាពជាអ្នកដឹកនាំ។ នៅទីណាដែលមានជោគជ័យ ACA បានទទួលនូវការគាំទ្រកម្រិតខ្ពស់ពីសាធារណជន និងពីផ្នែកនយោបាយ មានធនធានគ្រប់គ្រាន់ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការស្រាវជ្រាវ និងបានអនុម័តយកវិធីសាស្ត្រស៊ើបអង្កេតយ៉ាងម៉ឺងម៉ាត់ និងកម្មវិធីប្រកបដោយភាពច្នៃប្រឌិតអំពីការបង្ការ និងការអប់រំដល់សាធារណជន។ តម្រូវការឱ្យមានគណៈកម្មាធិការពិសេស ដែលមានភារកិច្ចតាមដានត្រួតពិនិត្យរាល់សកម្មភាពរបស់ខ្លួន ក៏បានបង្ហាញឱ្យឃើញថាមានសារៈសំខាន់មិនអាចខ្វះបាន។

ផ្ទុយទៅវិញ ការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ទៅលើការបង្ការ និងការអប់រំ ភាពទន់ខ្សោយក្នុងការអនុវត្តច្បាប់ ការខ្វះធនធាន ខ្វះឆន្ទៈនយោបាយ ខ្វះឯករាជភាព និងការមានអន្តរាគមន៍ផ្នែកនយោបាយ[១៧] និងការមានច្បាប់មិនគ្រប់គ្រាន់ ត្រូវបានចាត់ទុកថាជាមូលហេតុនៃការបរាជ័យភាគច្រើន[១៨]។ ទន្ទឹមនឹងនេះ មានបញ្ហានៃការដែលត្រូវចំណាយទៅលើការបង្កើតស្ថាប័នថ្មីៗនេះ និងបញ្ហាសមត្ថភាពទន់ខ្សោយរបស់រដ្ឋ ដែលតំណាងឱ្យការពិតនៃប្រទេសភាគច្រើន ដែលមានការអភិវឌ្ឍតិចតួចជាងគេបំផុតនៅក្នុងតំបន់។ ការបង្ការគឺជាការប្រសើរជាងការធ្វើបណ្តឹងចោទប្រកាន់ ហើយទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA ដ៏មានប្រសិទ្ធភាព ដែលមានភារកិច្ចស៊ើបអង្កេត និងតាមដានត្រួតពិនិត្យ/សម្របសម្រួល និងមានអំណាចគ្រប់គ្រាន់ និងឯករាជ្យពីអ្នកនយោបាយ ត្រូវបានគេចាត់ទុកថាជាការល្អប្រសើរបំផុតសម្រាប់បំពេញភារកិច្ចនោះ (Pope, ១៩៩៩)។ អត្ថបទស្ថិតក្នុងរង្វង់ខាងក្រោមនេះជម្រាបជូនអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការមានអង្គភាពឯករាជ្យប្រឆាំងអំពើពុករលួយ (សង្ខេបពី UNODC, ២០០៤)។

### គុណសម្បត្តិ និងគុណវិបត្តិនៃការមានអង្គភាពឯករាជ្យប្រឆាំងអំពើពុករលួយ

**គុណសម្បត្តិៈ**

- ផ្តល់នូវសញ្ញាមួយដែលថា រដ្ឋាភិបាលខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយយ៉ាងម៉ឺងម៉ាត់
- អាចសម្រេចបាននូវឯកទេសនីយកម្ម និងជំនាញកម្រិតខ្ពស់
- អាចកសាងស្វ័យភាពកម្រិតខ្ពស់ ដើម្បីញែកស្ថាប័ននេះឱ្យដាច់ចេញពីអំពើពុករលួយ និងឥទ្ធិពលមិនសមរម្យផ្សេងៗ ទៀត
- ស្ថាប័ននេះនឹងនៅដាច់ដោយឡែកពីទីភ្នាក់ងារ និងនាយកដ្ឋានទាំងឡាយ ដែលខ្លួននឹងទទួលខុសត្រូវស៊ើបអង្កេត។
- ស្ថាប័នថ្មីស្រឡាងមួយមាន "ការចាប់ផ្តើមដោយបរិសុទ្ធ" ដែលប្រាសចាកពីអំពើពុករលួយ និងបញ្ហាផ្សេងៗទៀតដែលអាចមាននៅក្នុងស្ថាប័នដែលមានស្រាប់។

[១៧] ឧទាហរណ៍នៅពេលស្ថិតនៅក្រោមការិយាល័យប្រធានាធិបតី ភ្នាក់ងារនេះនឹងមិនស្ថិតនៅក្នុងស្ថានភាពមួយនៃការដោះស្រាយអំពើពុករលួយធ្ងន់ធ្ងរដែលពាក់ព័ន្ធនឹងតួអង្គទាំងឡាយដែលជិតស្និទ្ធជាមួយប្រធានាធិបតី (Pope, ១៩៩៩)។ នេះក៏ត្រូវបានគេលើកឡើងដូចគ្នានៅប្រទេសតង់ហ្សានីផងដែរ។

[១៨] ដកស្រង់មកពី Bertrand de Speville (២០០០)។

- មានជំនឿទុកចិត្តយ៉ាងខ្លាំងពីសាធារណជនទូទៅ
- វានឹងអាចទទួលបាននូវការការពារសន្តិសុខដ៏ប្រសើរ
- វានឹងមានគណនេយ្យភាពក្នុងវិស័យនយោបាយ និងចំពោះមុខច្បាប់ និងចំពោះវិស័យសាធារណៈកាន់តែល្អជាងមុន
- វានឹងមានភាពកាន់តែច្បាស់លាស់ ក្នុងការវាយតម្លៃវឌ្ឍនភាព ជោគជ័យ និងបរាជ័យរបស់ខ្លួន
- នឹងមានវិធានការកាន់តែលឿនប្រឆាំងអំពើពុករលួយ។ ធនធានសម្រាប់ភារកិច្ចជាក់លាក់នឹងត្រូវបានប្រើប្រាស់ ហើយមន្ត្រីទាំងអស់នឹងមិនអាស្រ័យទៅតាមអាទិភាពដែលមានការប្រកួតប្រជែងនៅក្នុងការអនុវត្តច្បាប់ទូទៅ សវនកម្ម និងទីភ្នាក់ងារប្រហាក់ប្រហែលគ្នានោះទេ។ ហើយ
- វាបញ្ចូលនូវការការពារមួយបន្ថែមទៀតប្រឆាំងនឹងអំពើពុករលួយ ពោលគឺ វានឹងស្ថិតនៅក្នុងស្ថានភាពមួយដើម្បីតាមដានត្រួតពិនិត្យទៅលើសហគមន៍អនុវត្តន៏ច្បាប់ធម្មតា ហើយផ្ទុយទៅវិញ ប្រសិនបើទីភ្នាក់ងារខ្លួនឯងនេះពុករលួយ នោះសហគមន៍នឹងតាមដានត្រួតពិនិត្យទៅលើទីភ្នាក់ងារនេះវិញ។

**គុណវិបត្តិៈ**

- ចំណាយរដ្ឋបាលកាន់តែខ្ពស់
- ភាពនៅដាច់ដោយឡែក របាំង និងការប្រកួតប្រជែងរវាងស្ថាប័ននឹងស្ថាប័ន និងអង្គភាពនិងស្ថាប័នទាំងអស់ ដែលខ្លួននឹងត្រូវសហប្រតិបត្តិការជាមួយ ដូចជាមន្ត្រីអនុវត្តន៏ច្បាប់ មន្ត្រីអយ្យការ សវនករ និងអធិការ។
- បើកលទ្ធភាពឱ្យមានការកាត់បន្ថយឋានៈរបស់រចនាសម្ព័ន្ធដែលមានស្រាប់ ដែលនៅដោយឡែកពីស្ថាប័នថ្មីនេះ
- អាចបង្កើតសម្ពាធនយោបាយប្រកួតប្រជែងគ្នា ពីក្រុមទាំងឡាយដែលស្វែងរកអាទិភាពប្រហាក់ប្រហែលគ្នា សម្រាប់គំនិតផ្តួចផ្តើមដទៃទៀតដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម
- ក៏អាចទទួលរងគ្រោះចំពោះការប៉ុនប៉ងដកចេញ ឬកាត់បន្ថយនូវប្រសិទ្ធភាពរបស់ខ្លួន ដោយការផ្តល់មូលនិធិមិនគ្រប់គ្រាន់ ឬរចនាសម្ព័ន្ធរាយការណ៏មិនគ្រប់គ្រាន់។

# ស្ថាប័នផ្សេងទៀតដែលពាក់ព័ន្ធនៅក្នុងការប្រឆាំងអំពើពុករលួយ

# ៣

ការសន្និដ្ឋានទូទៅមួយដែលលេចចេញពីពណ៌នាសង្ខេបនៃប្រទេសនីមួយៗ គឺថា ស្ថាប័នតែមួយគត់មិនអាចយកជ័យជំនះនៅក្នុងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយបានឡើយ។ សូម្បីតែនៅក្នុងប្រទេសទាំងឡាយដែលទីភ្នាក់ងារ ឬអង្គភាពដែលមានធនធានគ្រប់គ្រាន់ ហើយត្រូវបានបង្កើតឡើងតាមច្បាប់គំរូក៏ដោយ ក៏ពួកគេនៅតែពឹងផ្អែកលើការទំនាក់ទំនង និងប្រសិទ្ធភាពរបស់ស្ថាប័នផ្សេងទៀត។ ផ្នែកនេះ នឹងពិនិត្យមើលលើទិដ្ឋភាពទូទៅនៃស្ថាប័នមួយចំនួនសម្រាប់គ្រប់គ្រងបន្ថែម (ឧ. ព្រះរាជអាជ្ញា អ្នកការពារប្រជាពលរដ្ឋ សវនករ និង តុលាការ)[១៩] ដែលដើរតួនាទី (ឬមានសក្តានុពលក្នុងការដើរតួនាទី) សំខាន់នៅក្នុងការប្រឆាំងអំពើពុករលួយ។ អត្ថបទនៅក្នុងប្រអប់ខាងក្រោមនេះ (ដកស្រង់មកពីកំណត់សម្គាល់អំពីការអនុវត្តរបស់យូអ៊ីនឌីភី ស្តីពីការប្រឆាំងអំពើពុករលួយ) ផ្តល់នូវទិដ្ឋភាពទូទៅនៃប្រភេទផ្សេងៗគ្នានៃកំណែទម្រង់ស្ថាប័ន ដែលចាំបាច់ត្រូវពិចារណាដើម្បីពង្រឹងនូវការអនុវត្តលើគំនិតផ្តើមប្រឆាំងអំពើពុករលួយ។

### កំណែទម្រង់ស្ថាប័នដែលត្រូវពិចារណាដើម្បីពង្រឹងនូវការអនុវត្តលើគំនិតផ្តើមប្រឆាំងអំពើពុករលួយ

- បង្កើតឱ្យមាន**អ្នកស៊ើបអង្កេតឯករាជ្យ ព្រះរាជអាជ្ញា និងអ្នកកាត់សេចក្តី** ដែលធានានូវការអនុវត្ត "ស្មើភាព" ចំពោះច្បាប់ និង បទបញ្ញត្តិ។
- ពង្រឹងសមត្ថភាព និងសុចរិតភាពរបស់**ប៉ូលីស ក្នុងនាមជាភ្នាក់ងារស៊ើបអង្កេតជួរមុខ**ចំពោះបទល្មើសឧក្រិដ្ឋ។
- ពង្រឹង និងធានានូវ**ឯករាជភាព និងគណនេយ្យភាពរបស់ប្រព័ន្ធតុលាការ**។
- ផ្តល់**អំណាចពេញលេញ ក្នុងការស៊ើបអង្កេត និងធ្វើបណ្តឹងអាជ្ញា** ដែលស្របតាមវិធានសិទ្ធិមនុស្សអន្តរជាតិ។
- បញ្ចូលយន្តការតម្លាភាពទៅក្នុងកំណែទម្រង់នៃវិធានការអនុវត្ត ដោយ**លុបបំបាត់បុព្វសិទ្ធិ** ដែលគ្មានទំនាក់ទំនងទៅនឹងសេចក្តីត្រូវការរបស់សាធារណជន ហើយដែលមន្ត្រីសាធារណៈជាន់ខ្ពស់ចូលចិត្តចង់បាន ដោយសារតែមុខតំណែងរបស់ពួកគេ។
- កសាង**យន្តការដ៏មានប្រសិទ្ធភាពសម្រាប់ទទួលពាក្យបណ្តឹង និងនីតិវិធីសម្រាប់ប្តឹងទាស់** ទោះជាដោយមន្ត្រីរាជការផ្ទៃក្នុង ឬដោយសាធារណជនក៏ដោយ។
- កសាងយន្តការដើម្បី**ការពារអ្នកបង្ហើបឱ្យដឹង** (អំពីអំពើពុករលួយ)៖ ជំរុញឱ្យមានការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍច្បាប់ និងការប្រតិបត្តិ ដែលធានាថា ប្រជាពលរដ្ឋដែលមានស្មារតីទទួលខុសត្រូវ អាចរាយការណ៍អំពីអំពើពុករលួយ ដោយមិនខ្លាចការសងសឹក និង**ធានាផ្តល់អំណាចឱ្យសារព័ត៌មានដើរតួនាទីសំខាន់** ក្នុងការដាក់ឱ្យបុគ្គល និងស្ថាប័នទទួលខុសត្រូវ។
- **ដោះស្រាយជាមួយវិស័យពិសេសៗដែលគេដឹងថាកំពុងសាបព្រោះអំពើពុករលួយ** (ឧ. នៅប្រទេសហ្ស៊ីរកហ្ស៊ីស្ថា ការប្រឆាំងអំពើពុករលួយបានចាប់ផ្តើមនៅក្នុងក្រសួងអប់រំ ដែលត្រូវបានចាត់ទុកថាជាប្រព័ន្ធមួយដែលមានអំពើពុករលួយខ្លាំងបំផុត)។

---

[១៩] បើទោះបីជាកម្លាំងប៉ូលីសក៏មានតួនាទីសំខាន់ក្នុងការប្រឆាំងអំពើពុករលួយក៏ដោយ ស្ថាប័ននេះក៏នឹងមិនសិក្សាដាច់ដោយឡែកដែរ ហើយនៅពេលណាចាំបាច់ វានឹងត្រូវបានពិភាក្សាដោយពាក់ព័ន្ធទៅនឹងស្ថាប័នផ្សេងៗទៀតដែលបានសិក្សា។

- ចំពោះ**អំពើពុករលួយដែលអាចនឹងកើតមានឡើង** ត្រូវដាក់វិធានការខ្លាំងៗដែលធ្វើឱ្យញញើត ដូចជាទណ្ឌកម្មរដ្ឋប្បវេណី ការធ្វើបញ្ជីខ្មៅនៃក្រុមហ៊ុនពុករលួយ បែបបទបត្យាប័ន និងបទបញ្ញត្តិច្បាប់ផ្សេងៗទៀត ដែលអាចឱ្យមានការឃាត់ចាប់ និងរឹបអូសនូវផលនៃអំពើពុករលួយទាំងនៅក្នុង ឬក្រៅប្រទេស។
- **ពង្រឹងក្រសួងដែលទទួលខុសត្រូវចំពោះកំណែទម្រង់មន្ត្រីរាជការ និងបង្កើតទំនាក់ទំនងឱ្យបានជិតស្និទ្ធរវាងក្រសួងនេះ នឹងទីភ្នាក់ងារប្រឆាំងអំពើពុករលួយផ្សេងទៀត** (អនុវត្តក្រមសីលធម៌ បង្កើនការត្រួតពិនិត្យ ការអនុវត្តសំដៅរកលទ្ធផល សូចនាករប្រតិបត្តិការដែលអាចវាស់វែងបានដោយផ្អែកលើការគ្រប់គ្រង ការផ្តល់អំណាចដល់សាធារណជន តាមរយៈធម្មនុញ្ញរបស់ពលរដ្ឋ ប្រព័ន្ធដោះស្រាយបណ្តឹងសាធារណៈដែលអាចជឿទុកចិត្តបាន លទ្ធភាពទទួលបានព័ត៌មាន)។

## ៣.១ ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដើរតួនាទីសំខាន់នៅក្នុងដំណើរការនាំយកសកម្មភាពពុករលួយទៅតុលាការ ដោយឈានចេញពីការស៊ើបអង្កេតមកជាការដាក់បណ្តឹងអាជ្ញា (គឺរៀបចំបែបបទដើម្បីប្តឹងចោទ)។ ប្រទេសនីមួយៗត្រូវមានច្បាប់ដែលធានាឱ្យមានឯករាជភាពផ្នែកនយោបាយ មិនត្រឹមតែសម្រាប់ ACA ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងសម្រាប់តុលាការ និងការិយាល័យអយ្យការសាធារណៈផងដែរ។ ទំនាក់ទំនងរវាងអង្គភាពប្រឆាំងអំពើពុករលួយ និងព្រះរាជអាជ្ញាមានពណ៌នានៅក្នុងសេចក្តីពណ៌នាសង្ខេបនៃប្រទេសមួយៗ។

ទំនាក់ទំនងរវាង ACA និងការិយាល័យអយ្យការសាធារណៈគឺជាទំនាក់ទំនងដ៏សំខាន់។ ជាគោលការណ៍ ទោះនៅក្នុងប្រទេសដែលអនុវត្តតាមប្រព័ន្ធច្បាប់ស៊ីវិល ឬ Common Law ក្តី ក៏គ្មានក្របខ័ណ្ឌណាដែលដាក់បង្ខំថា ត្រូវឱ្យអ្នកណារក្សាទុកនូវអំណាចស៊ើបអង្កេត និងអំណាចធ្វើបណ្តឹងអាជ្ញាឡើយ (លើកលែងតែមានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ)។ នៅពេលណាដែលរដ្ឋធម្មនុញ្ញចែងថា ព្រះរាជអាជ្ញាជាអ្នកគ្រប់គ្រងតែម្នាក់គត់ចំពោះរាល់ការធ្វើបណ្តឹងអាជ្ញា គាត់ត្រូវមានអំណាចធ្វើអន្តរាគមន៍នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌទាំងអស់ ដែលផ្តើមដោយបុគ្គល ឬអាជ្ញាធរណាមួយ។ ប៉ុន្តែ បញ្ហានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺថា តើព្រះរាជអាជ្ញាមានឯករាជភាពពេញលេញក្នុងការសម្រេចយករឿងក្តីទៅតុលាការដែរឬអត់។ ជាញឹកញយ ភាពទន់ខ្សោយរបស់យន្តការប្រឆាំងអំពើពុករលួយ កាន់តែមើលឃើញច្បាស់នៅត្រង់ចំណុចសំខាន់រវាងការស៊ើបអង្កេត (ដោយ ACA ឬអង្គភាពប្រហាក់ប្រហែលគ្នា) និងការធ្វើបណ្តឹងអាជ្ញាដោយស្ថាប័នតុលាការ ហើយនិងដំណើរការរបស់តុលាការ។

ហើយក៏មានឧទាហរណ៍ពីបណ្តាប្រទេសដែលបានសម្រេចមិនបង្កើតភ្នាក់ងារពិសេសប្រឆាំងអំពើពុករលួយដែរ ផ្ទុយទៅវិញ គេបង្កើតអង្គភាពពិសេសប្រឆាំងអំពើពុករលួយនៅក្រោមព្រះរាជអាជ្ញាសាធារណៈ។ នេះគឺជាករណីនៅប្រទេសម៉ុងហ្គោលី[២០] នៅពេលនេះ (អង្គភាពស៊ើបអង្កេតពិសេស) នៅប្រទេសនីការ៉ាហ្គា (អង្គភាពស៊ើបអង្កេត និងផ្តល់ដំបូន្មាន) នៅប្រទេសម៉ូហ្សាំប៊ិក (អង្គភាពកណ្តាលប្រឆាំងអំពើពុករលួយ) និងនៅកូឡុំប៊ូ។ នៅកូឡុំប៊ូ ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩១ ផ្តល់នូវអំណាចស៊ើបអង្កេតយ៉ាងធំទៅដល់អគ្គមេធាវី[២១]។ ដូចគ្នានេះដែរ នៅក្នុងប្រទេសតាជីគីស្ថាន អគ្គព្រះរាជអាជ្ញាទទួលបន្ទុកអនុវត្តច្បាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ។ នៅប្រទេសម៉ូហ្សាំប៊ិក ច្បាប់ប្រឆាំងអំពើពុករលួយថ្មី (២០០១) កំណត់អំពីរចនាសម្ព័ន្ធដែល "អយ្យការសាធារណៈ និងប៉ូលីសស៊ើបអង្កេតរឿងព្រហ្មទណ្ឌ ទទួលបន្ទុកទប់ស្កាត់ និងប្រឆាំងឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់"។ អង្គភាពនេះនឹងមានព្រះរាជអាជ្ញា ដែលមានការបណ្តុះបណ្តាលពិសេស និងប៉ូលីស ដើម្បីធ្វើការនៅក្នុងវិស័យពុក

[២០] នៅពេលនេះមានភាគច្រើននៅក្នុងសភា ដែលធ្វើការលើការប្រឆាំងអំពើពុករលួយ ដែលគាំទ្រដល់ការបង្កើត ACA ឯករាជ្យ និងការកែប្រែសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវបានបញ្ចប់។ សេចក្តីព្រាងច្បាប់ផ្តល់ឱ្យអង្គភាពប្រឆាំងអំពើពុករលួយ នូវអាណត្តិមួយដើម្បីស៊ើបអង្កេត ការចោទប្រកាន់ពីបទពុករលួយ បង្ការអំពើពុករលួយ អប់រំ និងកៀងគរសាធារណជន។ ការចោទប្រកាន់ និងការកាត់ទោសបទល្មើសទាំងឡាយគឺទុកឱ្យបរិធានរដ្ឋផ្សេងទៀត។ តែទោះជាយ៉ាងណាក៏ដោយគេនៅចាំមើលថា តើនឹងមានការគាំទ្រនយោបាយគ្រប់គ្រាន់នៅក្នុងសភា និងក្នុងរដ្ឋាភិបាល ទៅលើជម្រើស ACA ដែរឬអត់។

[២១] មន្ត្រីនេះត្រូវបានតែងតាំងសម្រាប់អាណត្តិ ៤ឆ្នាំ ដោយតុលាការកំពូល និងមិនអាចបណ្តេញចេញ ឬតែងតាំងម្តងទៀតឡើយ។ ប្រតិបត្តិការដោយមានស្វ័យភាពរដ្ឋបាល និងថវិកា ការិយាល័យនេះស៊ើបអង្កេត និងចោទប្រកាន់ បញ្ជូនមកតុលាការ ដឹកនាំ និងសម្របសម្រួលមុខងាររបស់ប៉ូលីសយុត្តិធម៌ និងការពារជនរងគ្រោះ សាក្សី និងជនផ្សេងៗទៀតដែលពាក់ព័ន្ធនៅក្នុងដំណើរការក្តី។

រលួយ។ អង្គភាពនេះធ្វើការនៅក្រោមការិយាល័យអគ្គមេធាវី[២២]។ ប្រទេសជប៉ុន បានបង្កើតនាយកដ្ឋានជំនាញស៊ើបអង្កេតនៅក្នុងការិយាល័យអយ្យការ នៅក្នុងទីក្រុងធំៗ។

ប៉ុន្តែ នៅប្រទេសទាំងឡាយណាដែលមានអំពើពុករលួយនៅគ្រប់ទិសទីនោះ គេមានការមិនទុកចិត្តជាខ្លាំងទៅលើអង្គភាពប្រឆាំងអំពើពុករលួយនៅក្នុងការិយាល័យអយ្យការ។ បន្ថែមទៅលើការអនុវត្តដែលកំពុងតែមានបញ្ហា គេនៅតែចាំមើលថា តើព្រះរាជអាជ្ញាអាចមានសមត្ថភាព និងមានអំណាចសីលធម៌ ដើម្បីចាត់វិធានការទប់ស្កាត់ ដូចជា ការសម្របសម្រួលជាមួយសង្គមស៊ីវិល ហើយនិងអង្គការយុវជន និងទំនាក់ទំនងជាញឹកញាប់ជាមួយប្រព័ន្ធសារព័ត៌មាន និងប្រព័ន្ធអប់រំ ដែរឬទេ។

នៅទីណាដែលមានអង្គភាពពិសេសប្រឆាំងអំពើពុករលួយ អង្គភាពនោះដោយអនុលោមតាមល័ក្ខខ័ណ្ឌមួយចំនួន គួរតែមានអំណាច និងសមត្ថភាព ក្នុងការធ្វើបណ្តឹងអាជ្ញាដោយឯករាជ្យពីអគ្គមេធាវី។ ឧទាហរណ៍បែបនេះ បានផ្តល់ជូននៅក្នុងផ្នែកមុនៗនៃរបាយការណ៍នេះ (ឧ. ប្រទេសឥណ្ឌូនេស៊ី នីហ្សេរីយ៉ា និងថៃ)។ ប៉ុន្តែ ទោះជា ACA មានទំនាក់ទំនងបែបណាជាមួយនឹងព្រះរាជអាជ្ញាក៏ដោយ ACA នេះគួរតែត្រូវបានផ្តល់សិទ្ធិជាមន្ត្រីអនុវត្តន៏ច្បាប់ ដែលអាចមើលឯកសាររដ្ឋ និងឯកសាររបស់មន្ត្រីរាជការ បានដោយពេញលេញ។

## ៣.២ អគ្គសវនករ

អនុសញ្ញា អ.ស.ប. ប្រឆាំងអំពើពុករលួយ UNCAC ចាត់ទុកសេចក្តីត្រូវការសវនកម្មថាជាអង្គធាតុនៃការទប់ស្កាត់អំពើពុករលួយ ទាំងនៅក្នុងវិស័យសាធារណៈ (មាត្រា ៩) និងវិស័យឯកជន (មាត្រា ១២) ប៉ុន្តែ ធាតុជាក់លាក់របស់អនុសញ្ញា ដូចជា ល័ក្ខខ័ណ្ឌថែរក្សាសុចរិតភាពរបស់សៀវភៅ កំណត់ត្រា និងឯកសារហិរញ្ញវត្ថុផ្សេងទៀត បានបង្ហាញច្បាស់ថា អនុសញ្ញាក៏បានគិតគូរផងដែរទៅលើមុខងារក្នុងការធ្វើឱ្យគេខ្លាចអំពើពុករលួយ មុខងារក្នុងការស្វែងរកការស៊ើបអង្កេត និងការធ្វើបណ្តឹងអាជ្ញា(UNODC, ២០០៤:១០០)។

ស្ថាប័នសវនកម្មដើរតួនាទីយ៉ាងសំខាន់ ដោយហេតុថា វាជួយជំរុញឱ្យមានការគ្រប់គ្រងហិរញ្ញវត្ថុល្អត្រឹមត្រូវ និងរដ្ឋបាលមានគណនេយ្យភាព និងតម្លាភាព ដែលនឹងរួមចំណែកដល់ការទប់ស្កាត់ និងតាមរកការប្រព្រឹត្តអំពើពុករលួយ។ ឯករាជភាពពេញលេញនៃស្ថាប័នសវនកម្មលើផ្នែកបុគ្គលិក និងថវិកា មានអំណាចច្បាប់ទូលំទូលាយ និងអំណាចស៊ើបអង្កេតគ្រប់គ្រាន់ រួមទាំងការកោះហៅសាក្សី និងការរឹបអូសឯកសារ គឺមានសារៈសំខាន់ដល់ដំណើរការត្រឹមត្រូវនៃស្ថាប័នបែបនេះ (ADB/OECD, ២០០៤:១៧)។

តួនាទីរបស់ការិយាល័យសវនកម្ម ក្នុងការប្រឆាំងអំពើពុករលួយ មិនត្រូវមើលស្រាលឡើយ។ ការធ្វើសវនកម្មទៀងទាត់អាចទប់ស្កាត់អំពើពុករលួយ និងឧក្រិដ្ឋកម្មសេដ្ឋកិច្ច ដោយធ្វើឱ្យអំពើទាំងនេះកាន់តែមានហានិភ័យ ដែលជាហេតុអាចកាត់បន្ថយឱកាសសម្រាប់ប្រព្រឹត្តអំពើពុករលួយ។ សវនកម្មគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ព្រោះវាផ្ទៀងផ្ទាត់ព័ត៌មាន និងការវិភាគចង្អុលបង្ហាញនូវភាពទន់ខ្សោយ ប្រាប់អំពីការប្រព្រឹត្តិខុសឆ្គង ឬបញ្ហាផ្សេងទៀត ដែលអ្នកខាងក្នុងមិនអាច ឬមិនចង់ចង្អុលបង្ហាញ។ ការកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងរចនាសម្ព័ន្ធ និងនីតិវិធីរដ្ឋបាល ការរាយការណ៍អំពីសកម្មភាពរបស់ពួកគេ ដែលអាចនឹងបង្កើនសំពាធនយោបាយ ឱ្យខិតខំរកដំណោះស្រាយចំពោះបញ្ហាដែលគេបានចង្អុលបង្ហាញ។

ប៉ុន្តែ នៅមានភាពខុសគ្នាសំខាន់ៗជាច្រើន ដោយអាស្រ័យទៅលើអាជ្ញាធរដែលមានអំណាចតែងតាំង និងខ្សែបន្ទាត់ដែលត្រូវរាយការណ៍ ។ ប្រការនេះ អាចជាផ្នែកនីតិប្រតិបត្តិ (ក្នុងករណីនេះ គឺជាមុខងារផ្ទៃក្នុង និងការត្រួតពិនិត្យខ្លួនឯងរបស់ស្ថាប័នរដ្ឋាភិបាល) ឬផ្នែកនីតិប្រតិបត្តិ (ក្នុងករណីនេះ វាគឺជាផ្នែកនៃដំណើរការមួយនៃ "ការទទួលខុសត្រូវខ្សែទទឹង" ឬការត្រួតពិនិត្យ) ឬទាំងពីរ។ មុខងារត្រួតពិនិត្យរបស់អគ្គសវនករ តែងតែត្រូវបានរំខានជាញឹកញយផងដែរ ដោយសារតែភាពទន់ខ្សោយរបស់គណៈកម្មាធិការត្រួតពិនិត្យសភា។ ការដែលសភាមិនអើពើចំពោះរបាយការណ៍ដែលដាក់ជូនមកពួកគេនោះ គឺមិនមែនជារឿងមិនធម្មតាទេ។ ឋានៈរបស់អគ្គសវនករនៅក្នុងប្រទេសអាស៊ីខាងត្បូងភាគច្រើន គឺស្ថិតក្រោមការធានារបស់រដ្ឋធម្មនុញ្ញ។ ប៉ុន្តែ មានករណីជាច្រើនដែលឯករាជភាពរបស់អគ្គសវនករ ត្រូវបានសម្របសម្រួល ដោយហេតុថា តាមការអនុវត្តជាក់ស្តែង តំណែងនេះស្ថិតនៅក្រោមក្រសួងហិរញ្ញវត្ថុ (ឧ. ប្រទេសបង់ក្លាដែស)។

[២២] មានទស្សនៈចម្រុះអំពីសេចក្តីសម្រេចរបស់ម៉ូហ្សាំប៊ិក ដើម្បីពង្រីកការិយាល័យអគ្គមេធាវី ជាយន្តការសំខាន់សម្រាប់ប្រឆាំងអំពើពុករលួយ ជំនួសឱ្យការបង្កើតនូវទម្រង់នៃគណៈកម្មការប្រឆាំងអំពើពុករលួយ។ មានបញ្ហាធ្ងន់ធ្ងរពាក់ព័ន្ធនឹងសមត្ថភាពរបស់អង្គភាព សម្រាប់មុខងារគ្រប់គ្រង និងសម្របសម្រួល និងការយល់ដឹងរបស់ពលរដ្ឋ។

ក្រុមប្រឹក្សាភិបាលសវនកម្ម និងអធិការកិច្ច (BAI) នៅសាធារណរដ្ឋកូរ៉េ មានអាណត្តិការងារទូលំទូលាយ រួមទាំងការស៊ើបអង្កេតពាក់ព័ន្ធនឹងការប្រើប្រាស់មូលនិធិសាធារណៈ[២៣]។ មុនពេលបង្កើតគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយរបស់ប្រទេសកូរ៉េ KICAC គណៈកម្មការសម្រាប់ទប់ស្កាត់អំពើពុករលួយ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់យោបល់ឱ្យ BAI លើការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ការិយាល័យសវនកម្មរបស់រដ្ឋញូសៅវែល ក៏ផ្តល់យោបល់ដល់សភា រដ្ឋាភិបាល និងទីភ្នាក់ងារវិស័យសាធារណៈ លើដំណើរការនៃវិស័យសាធារណៈផងដែរ។

ករណីនៅប្រទេសប៊ុលហ្គារី គឺជាករណីដែលគួរឱ្យចាប់អារម្មណ៍ ដោយសារតែតួនាទីដែលផ្តល់ជូនសវនករនៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ការិយាល័យសវនកម្មជាតិនៃប្រទេសប៊ុលហ្គារី មានប្រធានមួយរូប និងសមាជិក ១០រូបទៀត ដែលត្រូវបោះឆ្នោតជ្រើសរើសដោយសភាសម្រាប់អាណត្តិ ៩ឆ្នាំ។ សវនករនៅប្រទេសប៊ុលហ្គារី មិនគ្រាន់តែកាន់កាប់បញ្ជីប្រកាសទ្រព្យសម្បត្តិដែលត្រូវបានដាក់ជូនដោយមន្ត្រីជាន់ខ្ពស់សាធារណៈប៉ុណ្ណោះទេ សវនករក៏ធ្វើសវនកម្មលើសកម្មភាពហិរញ្ញវត្ថុរបស់គណបក្សនយោបាយផងដែរ។ តែទោះជាយ៉ាងនេះក៏ដោយ សវនករមិនមានតួនាទីអនុវត្តច្បាប់ទេ។ ប្រសិនបើគេរកឃើញអំពើព្រហ្មទណ្ឌ គេមានកាតព្វកិច្ចដាក់ជូនទៅរដ្ឋអាជ្ញាសាធារណៈ។

ជាធម្មតា សវនកររាយការណ៍ជូនសភាជាតិ។ ដូចបានរៀបរាប់ខាងលើ មានឧទាហរណ៍ដែលបញ្ជាក់ថា សភាខកខានមិនបានចាត់ការតាមអនុសាសន៍ ដែលបានលើកឡើងនៅក្នុងរបាយការណ៍ (ឧ. ប្រទេសបូតស្វាណា និងប៊ុលហ្គារី)។ នៅប្រទេសជាច្រើន របាយការណ៍ប្រចាំឆ្នាំរបស់ ACA ត្រូវបានចែករំលែកជាមួយសវនករ។ នៅប្រទេសឥណ្ឌូនេស៊ី KPK ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនជូនក្រុមប្រឹក្សាភិបាលសវនករ ហើយក្រុមប្រឹក្សាភិបាលសវនករនេះក៏ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ KPK វិញដែរ។ អាស្រ័យហេតុនេះ វាមានសារៈសំខាន់ដូចគ្នា ក្នុងការធានាថា ACA អាចពិនិត្យមើលរបាយការណ៍សវនកម្ម។ ដោយសារតែមានច្បាប់រក្សាការសម្ងាត់ដែលគេនៅតែអនុវត្ត នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន របាយការណ៍អាចបញ្ជូនទៅជូនតែមន្ត្រីជាន់ខ្ពស់ប៉ុណ្ណោះ ដើម្បីបង្ការការបើកចំហរទូលំទូលាយនូវព័ត៌មានរសើប។ បទពិសោធពីបណ្តាប្រទេសជាច្រើនដែលបានទទួលជោគជ័យ បង្ហាញឱ្យឃើញនូវទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាង ACA និងអគ្គសវនករ ព្រមទាំងការិយាល័យអ្នកការពារប្រជាពលរដ្ឋ (សូមមើលខាងក្រោម)។

ការពិនិត្យឡើងវិញទៅលើការចោទប្រកាន់ពីអំពើពុករលួយត្រូវបានធ្វើឡើងដោយអគ្គអធិការផងដែរ នៅក្នុងប្រទេសយូហ្គាន់ដា។ នៅក្នុងករណីជាច្រើន ការិយាល័យសវនកម្មទាំងនេះដំណើរការដូចជាការិយាល័យអ្នកការពារពលរដ្ឋ ដែលទទួលចុះបញ្ជីពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ លើបញ្ហាពុករលួយ។ នៅក្នុងករណីផ្សេងៗទៀត (ឧ. ប្រទេសបូលីវៀ) គេទំនាក់ទំនងការងារក្នុងសកម្មភាពប្រឆាំងអំពើពុករលួយជាមួយទីភ្នាក់ងារទាំងអស់។ ទីភ្នាក់ងារផ្សេងទៀតនៅតែមានអំណាចស៊ើបអង្កេត និងអំណាចធ្វើបណ្តឹងអាជ្ញា (ឧ. តុលាការរបស់ប្រទេសប៉េរូ សម្រាប់សីលធម៌សាធារណៈ និងរដ្ឋអាជ្ញាសាធារណៈរបស់ប្រទេសអ៊ុយរ៉ាហ្គាយ)។

## ៣.៣ ភ្នាក់ងារកំណែទម្រង់សេវាសាធារណៈ ឬគណៈកម្មការសេវាសាធារណៈ

កំណែទម្រង់សេវាសាធារណៈគឺជាការចាំបាច់សម្រាប់យុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយគ្រប់ប្រភេទ។ ACA គួរសហការជិតស្និទ្ធជាមួយស្ថាប័នទាំងនេះ ដោយហេតុថាកំណែទម្រង់សេវាសាធារណៈ គឺជាធាតុសំខាន់នៃវិធានការបង្ការអំពើពុករលួយ។

វប្បធម៌ផ្ទៃក្នុងរបស់ស្ថាប័នមិនអាចត្រូវបានត្រួតពិនិត្យពីខាងក្រៅបានឡើយ ព្រោះតែហេតុនេះហើយបានជាចាំបាច់ត្រូវឱ្យអ្នកគ្រប់គ្រងវិស័យសាធារណៈខ្លួនឯង ទទួលខុសត្រូវចំពោះសុចរិតភាពនៅកន្លែងការងាររបស់ពួកគេ។ គឺជាសារៈសំខាន់ក្នុងការតាមដានត្រួតពិនិត្យលើការឆ្លើយតបរបស់អ្នកគ្រប់គ្រង ចំពោះវិធានការទប់ស្កាត់ និងអនុសាសន៍ ដែលធ្វើឡើងដោយអង្គភាពប្រឆាំងអំពើពុករលួយ និងសវនកម្មផ្សេងៗ។

ហេតុផលសំខាន់មួយនៃជោគជ័យរបស់ប្រទេសសិង្ហបុរីក្នុងការប្រឆាំងអំពើពុករលួយ គឺកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់ឱកាសសម្រាប់ប្រព្រឹត្តអំពើពុករលួយ តាមរយៈការផ្តោតជានិច្ចលើការធ្វើឱ្យមានប្រសិទ្ធភាពនូវនីតិវិធីរដ្ឋបាលដែលស្មុគស្មាញ កាត់បន្ថយការិយាល័យធិបតេយ្យ និងអនុម័តកំណែទម្រង់លទ្ធកម្ម។ គោលនយោបាយដឹកនាំជាគំរូនៅក្នុងសេវាសាធារណៈរបស់ប្រទេសសិង្ហបុរី គឺជាកត្តាម៉ឺងម៉ាត់មួយនៅក្នុងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយរបស់ខ្លួន។ ជាធម្មតា ប្រាក់ឈ្នួលខ្ពស់នៅក្នុងសេវា

[២៣] BAI នៅសារណរដ្ឋកូរ៉េ រាយការណ៍ជូនប្រធានាធិបតី សភា និងរដ្ឋាភិបាល។

សាធារណៈ ត្រូវបានចាត់ទុកថាជាកត្តារួមចំណែកមួយសំខាន់តទល់នឹងអំពើពុករលួយកម្រិតទាបនៅសិង្ហបុរី ប៉ុន្តែត្រូវចាំថា កម្រិតប្រាក់ឈ្នួលខ្ពស់ទាំងនេះគឺជាលទ្ធផលសំខាន់មួយបានមកពីគោលនយោបាយប្រឆាំងអំពើពុករលួយ មិនមែនគ្រាន់តែជាកត្តាសម្រាប់ពន្យល់ពីជោគជ័យរបស់ពួកគេទេ[២៤] ។ អ្វីដែលជាគន្លឹះនៅក្នុងករណីប្រទេសសិង្ហបុរី គឺថា ភារកិច្ចទប់ស្កាត់អំពើពុករលួយស្ថិតនៅក្នុងនាយកដ្ឋានទាំងអស់។ លេខាធិការអចិន្ត្រៃយ៍នៅក្នុងក្រសួងនីមួយៗទទួលខុសត្រូវក្នុងការធានាថា នាយកដ្ឋាននីមួយៗមានគណៈកម្មាធិការមួយដែលមានភារកិច្ចពិនិត្យសើរើឡើងវិញនូវវិធានការប្រឆាំងអំពើពុករលួយ ព្រមទាំងធានាឱ្យមានការចាត់វិធានការគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ ការប្រព្រឹត្តិអំពើពុករលួយ។ នេះក៏រួមមានការដាក់ឱ្យដំណើរការនូវគោលនយោបាយម៉ឺងម៉ាត់ប្រឆាំងនឹងទំនាស់ផលប្រយោជន៍។

នៅអាហ្វ្រិកខាងត្បូងអាណត្តិកិច្ចការប្រឆាំងអំពើពុករលួយត្រូវបានបែងចែកក្នុងចំណោមប៉ូលីស រដ្ឋអាជ្ញា អគ្គសវនករ សេវាប្រមូលចំណូលអាហ្វ្រិកខាងត្បូង និងគណៈកម្មការសេវាសាធារណៈ (ក្នុងចំណោមសេវាផ្សេងៗទៀត) ។ ជាមុខងារសំខាន់របស់ខ្លួន ពួកគេត្រូវពង្រឹងសុចរិតភាពរបស់មន្ត្រី ការគ្រប់គ្រងហិរញ្ញវត្ថុ និងគុណភាពរដ្ឋបាលនៅក្នុងសេវាសាធារណៈ។ ក្នុងករណីដែលគ្មានទីភ្នាក់ងារពិសេសប្រឆាំងអំពើពុករលួយ អាហ្វ្រិកខាងត្បូងពឹងផ្អែកយ៉ាងខ្លាំងលើមុខងារសាធារណៈ និងអ្នកគ្រប់គ្រងវិស័យសាធារណៈ ដើម្បីរក្សានូវវប្បធម៌សុចរិតភាពនៅក្នុងរដ្ឋាភិបាល។ នៅក្នុងនាយកដ្ឋានសេវាសាធារណៈ និងរដ្ឋបាល អង្គភាពប្រឆាំងអំពើពុករលួយនៅក្នុងសេវាសាធាណៈ (PSAC) ក៏មានមុខងារសម្របសម្រួល និងទទួលបន្ទុកកសាង និងអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយនៅក្នុងសេវាសាធារណៈផងដែរ។ អង្គភាព PSAC ក៏ផ្តល់នូវដំបូន្មាន និងការគាំទ្រដល់វិស័យសាធារណៈលើគោលនយោបាយ និងច្បាប់ប្រឆាំងអំពើពុករលួយ ព្រមទាំងកោះប្រជុំគណៈកម្មាធិការសម្របសម្រួលប្រឆាំងអំពើពុករលួយ។ ប៉ុន្តែ អង្គភាពនេះមិនធ្វើការស៊ើបអង្កេតអំពើពុករលួយណាមួយដោយខ្លួនឯងទេ។ លើសពីនេះទៅទៀត ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ រដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីសម្រេចថា រាល់នាយកដ្ឋាន និងស្ថាប័នទាំងអស់នៅក្នុងមុខងារសាធារណៈត្រូវតែមានសមត្ថភាពអប្បបរមាមួយ ដើម្បីធ្វើការវិភាគអំពីហានិភ័យ អនុវត្តផែនការប្រឆាំងអំពើក្លែងបន្លំ ស៊ើបអង្កេតលើការចោទប្រកាន់ពីបទពុករលួយ ចាត់ចែងដំណឹងស្តីពីរឿងពុករលួយ និងលើកកម្ពស់អាកប្បកិរិយាប្រកបដោយសីលធម៌ក្នុងចំណោមមន្ត្រីទាំងអស់របស់ពួកគេ។ តែទោះជាយ៉ាងនេះក្តី ទីភ្នាក់ងារជាច្រើនហាក់ដូចជាមិនមានដាក់ចេញនូវគោលនយោបាយ និងនីតិវិធី ដើម្បីអនុវត្តតាមកាតព្វកិច្ចទាំងនេះឡើយ។

នៅប្រទេសថៃ គណៈកម្មការមុខងារសាធារណៈ ព្រមទាំងគណៈកម្មការអភិវឌ្ឍន៍វិស័យសាធារណៈ ដើរតួនាទីយ៉ាងសំខាន់។ គណៈកម្មការមុខងារសាធារណៈដើរតួនាទីជាទីភ្នាក់ងារស្នូលក្នុងការការពារប្រព័ន្ធ ដែលផ្អែកលើគុណសម្បត្តិល្អ និងជំរុញឱ្យមានការគ្រប់គ្រងដែលសំដៅទៅរកលទ្ធផលតម្លាភាព និងគណនេយ្យភាពនៅក្នុងសេវាសាធារណៈ។ គណៈកម្មការអភិវឌ្ឍន៍វិស័យសាធារណៈតាមដានត្រួតពិនិត្យនូវការអនុវត្តក្រឹត្យស្តីពីវិធាន និងនីតិវិធីសម្រាប់រដ្ឋបាលសាធារណៈល្អ ។ ទន្ទឹមនឹងនេះ ប្រការសំខាន់មួយទៀតគឺថា ពលរដ្ឋនៅប្រទេសថៃអាចដាក់ពាក្យប្តឹងទៅការិយាល័យគណៈកម្មការព័ត៌មាននៃមន្ត្រីរាជការ ក្នុងករណីណាដែលទីភ្នាក់ងារសាធារណៈណាមួយមិនព្រមផ្តល់ព័ត៌មាន ។

*ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ* នៅប្រទេសលីទុយអានីចែងថា គ្រប់ទីភ្នាក់ងារថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង អាចបង្កើតអង្គភាពផ្ទៃក្នុងមួយ សម្រាប់ទប់ស្កាត់អំពើពុករលួយនៅក្នុងអាណត្តិការងាររបស់ពួកគេរៀងៗខ្លួន។

គណៈកម្មការសេវាសាធារណៈនៅប្រទេសហ្វីជី បានបង្កើតអង្គភាពពិសេសមួយ ដែលមិនត្រឹមតែដើម្បីស្រាវជ្រាវអំពីរបាយការណ៍នៃអំពើពុករលួយប៉ុណ្ណោះទេ ថែមទាំងធ្វើការស៊ើបអង្កេតនៅពេលមានការសង្ស័យថាមានសកម្មភាពពុករលួយផងដែរ។ ច្បាប់ស្តីពីក្រមសីលធម៌ នឹងត្រូវលើកយកមកពិភាក្សានៅក្នុងសភាជាន់ទាប ដែលនឹងអនុវត្តចំពោះអ្នកកាន់តំណែងជាន់ខ្ពស់ទាំងអស់ រួមទាំងប្រធានាធិបតី អនុប្រធានាធិបតី រដ្ឋមន្ត្រី សមាជិកសភា ប្រមុខនីតិប្រតិបត្តិ និងអ្នកទាំងអស់ដែលត្រូវបានតែងតាំងតាមលក្ខន្តិកៈ ឬតំណែងប្រតិបត្តិ នៅក្នុងអាជ្ញាធរតាមលក្ខន្តិកៈ។ ច្បាប់នេះនឹងទាមទារឱ្យមានសុចរិតភាពតាមស្តង់ដាពិតប្រាកដ។

[២៤] នៅឆ្នាំ ១៩៥៩ នៅពេលដាក់ចេញនូវយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ GNP សម្រាប់មនុស្សម្នាក់នៅសិង្ហបុរី ប្រហែលជា ៤៤៣ដុល្លារ។ ៣០ឆ្នាំក្រោយមកតួលេខបានកើនឡើងជាង ១១% ជារៀងរាល់ឆ្នាំ ជាពិសេសអាស្រ័យ ដោយការសម្រេចបានក្នុងការប្រមូលចំណូល និងផលិតភាពដែលទទួលបានមកពីគោលនយោបាយប្រឆាំងអំពើពុករលួយ ពីគោលនយោបាយអភិវឌ្ឍន៍សំដៅឱ្យមានកំណើនលឿន រួមទាំង ការវិនិយោគលើការអភិវឌ្ឍធនធានមនុស្ស។ នៅត្រឹមឆ្នាំ ១៩៩៤ ប្រាក់ឈ្នួលក្នុងវិស័យសាធារណៈ មានលំដាប់ថ្នាក់ស្ថិតនៅក្នុងចំណោមប្រទេសដែលមានកម្រិតខ្ពស់បំផុតនៅក្នុងពិភពលោក ដែលមានកម្រិតជិតស្មើនឹងកម្រិតប្រាក់ឈ្នួលវិស័យឯកជន។

នៅទីណាដែលមាន ACA ជាធម្មតាវាមានអនុសាសន៍អំពីរបៀបដែលត្រូវកែលម្អការគ្រប់គ្រងសាធារណៈ ដើម្បីកាត់បន្ថយឱកាសពុករលួយ ទុកជាផ្នែកមួយនៃអាណត្តិទប់ស្កាត់អំពើពុករលួយរបស់ខ្លួន។ នៅក្នុងប្រទេសមួយចំនួន អនុសាសន៍របស់ ACA ទៅទីភ្នាក់ងាររដ្ឋាភិបាល គឺត្រូវតែអនុវត្តតាម។ នៅក្នុងប្រទេសផ្សេងទៀត ច្បាប់មិនបានតម្រូវឱ្យទីភ្នាក់ងារសាធារណៈអនុវត្តតាមអនុសាសន៍របស់ ACA ឡើយ។ ក្នុងករណីទាំងនោះ ACA គួរតែត្រូវបានអនុញ្ញាតឱ្យផ្តល់អនុសាសន៍នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ជូនរដ្ឋសភា រដ្ឋាភិបាល និងសវនកម្ម ដែលដាក់ឱ្យនាយកដ្ឋានទាំងអស់ទទួលខុសត្រូវ ប្រសិនបើនាយកដ្ឋានទាំងនោះមិនមានការកែលម្អទេ។

## ៣.៤ មន្ត្រីការពារប្រជាពលរដ្ឋ (Ombudsman)

សារៈសំខាន់នៃមន្ត្រីការពារប្រជាពលរដ្ឋ ស្ថិតនៅត្រង់ថា ក្នុងនាមជាស្ថាប័នឯករាជ្យ វាត្រូវបានចាត់ទុកថាជាឧបករណ៍បន្ថែមសម្រាប់ទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ ដែលគ្របដណ្តប់លើវិស័យនៃសកម្មភាពនានា ខុសអំពីសកម្មភាពរបស់ស្ថាប័នដែលមានស្រាប់ គឺថាមន្ត្រីការពារប្រជាពលរដ្ឋ ការពារមិនឱ្យមានការរំលោភបំពានពីរដ្ឋបាលសាធារណៈមកលើប្រជាពលរដ្ឋ។ សំខាន់ជាងនេះទៅទៀត មន្ត្រីការពារប្រជាពលរដ្ឋ គួរតែឯករាជ[២៥] ពីសាខាផ្សេងៗទៀតរបស់រដ្ឋាភិបាល/រដ្ឋបាល ប៉ុន្តែ គួរសហការជាមួយស្ថាប័នស្វយ័តផ្សេងៗទៀត ដូចជា តុលាការ និងអង្គភាពសវនកម្ម (World Bank, ១៩៩៩)។

ជាទូទៅ អាណត្តិការងាររបស់មន្ត្រីការពារប្រជាពលរដ្ឋ គ្របដណ្តប់លើសពីករណីពុករលួយទៅទៀត ហើយរួមបញ្ចូលទាំងហេតុការណ៍នៃការគ្រប់គ្រងមិនល្អ ដែលនាំទៅរកអសមត្ថភាព ភាពលំអៀង កំហុស ឬការព្រងើយកន្តើយផ្សេងទៀត ដែលមិនចាំបាច់តែជាអំពើពុករលួយនោះទេ។ នៅប្រទេសបូតស្វាណា អាណត្តិការងារចម្បងនៃមន្ត្រីការពារប្រជាពលរដ្ឋ គឺស៊ើបអង្កេតលើពាក្យបណ្តឹងដែលទទួលបានពីសាធារណជន ពាក់ព័ន្ធនឹងអំពើអយុត្តិធម៌ ឬការគ្រប់គ្រងមិនល្អនៅក្នុងសេវាសាធារណៈ[២៦]។ នេះអាចជាសារៈប្រយោជន៍មួយ ដោយហេតុថា នៅក្នុងករណីជាច្រើន អ្នកដាក់ពាក្យបណ្តឹងនឹងមិនដឹង ឬមិនសង្ស័យអំពីអត្ថិភាពនៃអំពើពុករលួយឡើយ។ ផ្ទុយទៅវិញ មន្ត្រីការពារប្រជាពលរដ្ឋ នឹងកំណត់ថា តើមានអំពើពុករលួយឬអត់ ហើយប្រសិនបើចាំបាច់ គាត់នឹងបញ្ជូនរឿងនេះទៅ ACA ឬ រដ្ឋអាជ្ញា ដើម្បីចាត់វិធានការបន្ថែមទៀត។ នៅប្រទេសផ្សេងៗទៀត មន្ត្រីការពារប្រជាពលរដ្ឋ អាចធ្វើការស៊ើបអង្កេតដោយផ្ទាល់ ទៅលើពាក្យបណ្តឹងពីអំពើពុករលួយ។ នៅសាធារណរដ្ឋកូរ៉េ ច្បាប់មិនផ្តល់អំណាចឱ្យមន្ត្រីការពារប្រជាពលរដ្ឋស៊ើបអង្កេត តាមគំនិតផ្តួចផ្តើមរបស់ខ្លួនទេ ហើយអនុសាសន៍របស់ខ្លួនក៏មិនតម្រូវឱ្យគេអនុវត្តតាមឡើយ។ ចំណុចខ្លាំងរបស់វាស្ថិតនៅលើការផ្សព្វផ្សាយរបាយការណ៍របស់ខ្លួន។ នៅរដ្ឋញូសៅវែល មន្ត្រីការពារប្រជាពលរដ្ឋក៏តាមដានត្រួតពិនិត្យរាល់សកម្មភាពរបស់គណៈកម្មការសុចរិតភាពផ្នែកប៉ូលីសផងដែរ[២៧] ដែលត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់ ស្វែងរក និងស៊ើបអង្កេតលើការប្រព្រឹត្តិខុសធ្ងន់ធ្ងរ នៅក្នុងផ្នែកប៉ូលីស។ មន្ត្រីការពារប្រជាពលរដ្ឋក៏មានអំណាចពិនិត្យសារឡើងវិញនូវច្បាប់ដែលមានជាធរមានផងដែរ។

នៅក្នុងប្រទេសមួយចំនួន ការិយាល័យមន្ត្រីការពារប្រជាពលរដ្ឋ មានដំណើរការ ដូចជា អង្គភាពប្រឆាំងអំពើពុករលួយដែរ (ប្រទេសប៉ាពួញូហ្គីណេ និងអ៊ូហ្គាន់ដា)។ ប្រទេសឡាតវៀ គ្មានមន្ត្រីការពារប្រជាពលរដ្ឋទេ ប៉ុន្តែ មុខងារនេះត្រូវបានអនុវត្តដោយការិយាល័យរដ្ឋសម្រាប់ការពារសិទ្ធិមនុស្សវិញ (ការបង្កើតមន្ត្រីការពារប្រជាពលរដ្ឋ កំពុងត្រូវបានពិចារណា)។ អ្នកខ្លះទៀតអាចនឹងលើកមតិថា មានការខុសគ្នាច្បាស់ណាស់រវាងតួនាទីទាំងពីរនេះ គឺថា: មន្ត្រីការពារប្រជាពលរដ្ឋមានវត្តមាននៅទីនោះ ដើម្បីលើកកម្ពស់យុត្តិធម៌រដ្ឋបាល ហើយថា កិច្ចការនេះអាចសម្រេចបានតាមរយៈការទុកចិត្តរបស់ការិយាធិបតេយ្យ។ ទីភ្នាក់ងារ ឬគណៈកម្មការដែលមានភារកិច្ចស៊ើបអង្កេត និងធ្វើបណ្តឹងអាជ្ញាលើមន្ត្រីសាធារណៈ គឺហាក់ដូចជាត្រូវគេខ្លាច ជាជាងគេទុកចិត្ត (Pope, ១៩៩៨)។

នៅប៉ាពួញូហ្គីណេ ហ្វីលីពីន និងឡាតវៀ មន្ត្រីការពារប្រជាពលរដ្ឋមានអាណត្តិការងារប្រហាក់ប្រហែលទៅនឹងអាណត្តិ

[២៥] នៅប្រទេសលីទុយអានី មន្ត្រីការិយាល័យដោះស្រាយពាក្យបណ្តឹង អាចត្រូវដកហូតបានតែតាមរយៈសំលេងឆ្នោតភាគច្រើននៅក្នុងសភាតែប៉ុណ្ណោះ។

[២៦] ប្រសិនបើមិនអនុវត្តតាមអនុសាសន៍របស់ការិយាល័យដោះស្រាយពាក្យបណ្តឹងទេ ការិយាល័យមានកាតព្វកិច្ចធ្វើរបាយការណ៍ពិសេសជូនទៅសភា។

[២៧] ICAC មិនអាចស៊ើបអង្កេត ឬដោះស្រាយបញ្ហាដែលពាក់ព័ន្ធជាមួយអំពើរបស់មន្ត្រីប៉ូលីសបានឡើយ សូម្បីតែនេះពាក់ព័ន្ធនឹងការប្រព្រឹត្តិរបស់មន្ត្រីសាធារណៈដែលមិនមែនចេញមកពីប៉ូលីសក៏ដោយ។ ICAC មិនបានទទួលជោគជ័យក្នុងការប្រឆាំងអំពើពុករលួយ និងការប្រព្រឹត្តិខុសនៅក្នុងកងកម្លាំងប៉ូលីសរបស់ New South Wale ដែលជាហេតុផលថាហេតុអ្វីបានជាគណៈកម្មការសុចរិតភាពប៉ូលីស ត្រូវបានបង្កើតឡើង។ តែទោះបីជាយ៉ាងណាក៏ដោយ អំពើពុករលួយនៅក្នុងជួរប៉ូលីស ហាក់ដូចជានៅតែជាបញ្ហាធ្ងន់ធ្ងរដដែល។

ការងាររបស់ ACA ដែរ។ មន្ត្រីការពារប្រជាពលរដ្ឋរបស់ប្រទេសហ្វីលីពីន មានបំពាក់ទៅដោយមធ្យោបាយស៊ើបអង្កេតផងដែរ។ ប្រទេសឥណ្ឌាបានបង្កើតស្ថាប័នត្រួតពិនិត្យបែបវិមជ្ឈការដែលទទួលខុសត្រូវក្នុងការទប់ស្កាត់ និងស៊ើបអង្កេតករណីពុករលួយ (ADB/OECD, ២០០៤:៤១)។

នៅប្រទេសស្រីលង្កា មន្ត្រីការពារប្រជាពលរដ្ឋ ដែលត្រូវបានស្គាល់ថាជាស្នងការសភាសម្រាប់រដ្ឋបាល ត្រូវបានបង្កើតឡើងដើម្បីស៊ើបអង្កេតពាក្យបណ្ដឹងប្រឆាំងនឹងនាយកដ្ឋានរដ្ឋ គណៈអភិបាលសាជីវកម្ម អាជ្ញាធររដ្ឋាភិបាល និងស្ថាប័នរដ្ឋបាលមូលដ្ឋានផ្សេងៗទៀត។ មន្ត្រីនេះក៏ពិនិត្យលើការរំលោភសិទ្ធិជាមូលដ្ឋាន ការគ្រប់គ្រងមិនល្អទៅលើសាធារណជនទូទៅ ការខកខានមិនឱ្យសាធារណជនទទួលបាននូវព័ត៌មាន និងអំពើរំលោភផ្នែករដ្ឋបាល។ ការធ្វេសប្រហែស និងការមិនបំពេញតាមកាតព្វកិច្ច គឺជាប្រភពនៃពាក្យបណ្ដឹងភាគច្រើន។

## ៣.៥ តុលាការ

សមត្ថកិច្ច វិជ្ជាជីវៈ និងសុចរិតភាពរបស់ចៅក្រម មានសារៈសំខាន់ចំពោះជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ។ សារៈសំខាន់តែមួយគត់នៃស្ថាប័នតុលាការ ត្រូវបានទទួលស្គាល់នៅក្នុង UNCAC ដែលកំណត់នៅក្នុងមាត្រាជាក់លាក់មួយ (មាត្រា ១១) ចំពោះបញ្ហានៅក្នុងវិស័យនេះ។ មាត្រានេះស្នើសុំឱ្យមានវិធានការសម្រាប់ពង្រឹងសុចរិតភាព និងទប់ស្កាត់ឱកាសសម្រាប់អំពើពុករលួយផ្នែកតុលាការខ្លួនឯង ដែលត្រូវធ្វើឡើងដោយមិនឱ្យខូចខាតដល់ឯករាជភាពរបស់តុលាការ។ មាត្រា ១១ ក៏ស្នើសុំឱ្យមានវិធានការប្រហាក់ប្រហែលគ្នា ចំពោះព្រះរាជអាជ្ញា នៅក្នុងប្រព័ន្ធទាំងឡាយដែលពួកគេទទួលបាននូវកម្រិតនៃឯករាជភាពប្រហាក់ប្រហែលគ្នា។

ប៉ុន្តែ ដូចមានលើកឡើងនៅក្នុងបទពិណនាសង្ខេបអំពីប្រទេសនីមួយៗ ភាគច្រើន តុលាការគឺជាផ្នែកមួយដែលខ្សោយបំផុតក្នុងការរៀបចំស្ថាប័នដាក់ឱ្យដំណើរការដើម្បីប្រឆាំងអំពើពុករលួយ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការទុកចិត្តក្នុងប្រព័ន្ធសុចរិតភាពជាតិទាំងមូល។ នៅប្រទេសបូតស្វាណា មានពេលខ្លះ ការកាត់ក្ដីត្រូវបានពន្យារពេល ដែលធ្វើឱ្យប៉ះពាល់ដល់អត្រានៃការដាក់ទោសចំពោះករណីដែលនាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មអំពើពុករលួយ និងសេដ្ឋកិច្ច DCEC បានដាក់ជូនតុលាការ ។ ករណីទាំងឡាយនោះក៏ត្រូវបានពន្យារពេលនៅក្នុងការិយាល័យព្រះរាជអាជ្ញាផងដែរ ដែលជំរុញឱ្យ DCEC កសាងសមត្ថភាពផ្ទាល់ខ្លួន ដើម្បីធ្វើបណ្ដឹងអាជ្ញាលើករណីពុករលួយ (សូមមើលខាងលើ)។

ក្រៅពីចំណុចដែលថា តុលាការខ្លួនឯងត្រូវបានគេយល់ថាមានភាពពុករលួយខ្លាំង នៅប៊ុលហ្គារី កង្វល់បន្ថែមទៀតគឺការខ្វះចៅក្រមព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ដែលមានជំនាញនៅក្នុងបទល្មើសនៃអំពើពុករលួយ។

ប្រសិនបើប្រព័ន្ធតុលាការខ្សោយ និងមិនអាចទស្សន៍ទាយបាន កិច្ចខិតខំប្រឹងប្រែងដើម្បីផ្ដល់ការដោះស្រាយតាមផ្លូវតុលាការនឹងមិនសូវមានប្រសិទ្ធភាពឡើយ។ អាស្រ័យហេតុនេះ ប្រទេសខ្លះបានបង្កើតតុលាការពិសេស ដើម្បីកាត់សេចក្ដីរឿងពុករលួយ។ ឧទាហរណ៍ ប្រទេសឥណ្ឌូនេស៊ី មានតុលាការសម្រាប់អំពើពុករលួយមួយដែលមានអាណត្តិការងារវាយតម្លៃ និងសម្រេចលើករណីព្រហ្មទណ្ឌពុករលួយ ដែលរួមទាំងករណីទាំងឡាយ ដែលបានប្រព្រឹត្តនៅក្រៅយុត្តាធិការរបស់ឥណ្ឌូនេស៊ី (ប្រសិនបើចារីមានសញ្ជាតិឥណ្ឌូនេស៊ី)។

ទោះជាមាន ឬគ្មានតុលាការពិសេសដើម្បីកាត់សេចក្ដីរឿងពុករលួយក៏ដោយ ផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ គឺគួរពង្រឹងសុចរិតភាពរបស់តុលាការ ធានាឱ្យមានការអភិវឌ្ឍវិជ្ជាជីវៈសមស្របសម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ និងគួរបង្កើតរចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់គណនេយ្យភាព។

បើទោះបីជាកំណែទម្រង់នៃស្ថាប័នផ្សេងៗ ដូចជា វិជ្ជាជីវៈច្បាប់ សេវាកម្មអយ្យការ និងទីភ្នាក់ងារអនុវត្តន៍ច្បាប់ មានសារៈសំខាន់ដែរក៏ដោយ គឺនៅថ្នាក់តុលាការទេដែលអំពើពុករលួយបង្កនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជាកន្លែងដែលកំណែទម្រង់មានសក្ដានុពលធំធេង ដើម្បីធ្វើឱ្យមានស្ថានភាពប្រសើរឡើងវិញ (UNODC, ២០០៤:៥១)។

# ៤

# ប្រទេសដែលគ្មានទីភ្នាក់ងារពិសេសប្រឆាំងអំពើពុករលួយ

គ្រប់ប្រទេសមិនមែនសុទ្ធតែជ្រើសយកទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA ពិសេសនោះទេ។ ប្រទេសប៊ុលហ្គារី និងអាហ្វ្រិកខាងត្បូង គឺជាឧទាហរណ៍នៃប្រទេសពីរ ដែលបានសម្រេចមិនបង្កើតអង្គភាពបែបនេះ ប៉ុន្តែ បែរជាទៅពង្រឹងស្ថាប័នដែលមានស្រាប់ទៅវិញ។ ពួកគេបានបង្កើតស្ថាប័នជំនួសវិញ ដើម្បីធានាឱ្យមានសមត្ថកិច្ចជំនាញក្នុងការស្វែងរក និងស៊ើបអង្កេតអំពើពុករលួយ។

នៅប្រទេសប៊ុលហ្គារី តួនាទីសំខាន់មួយត្រូវបានបំពេញដោយការិយាល័យប៉ូលីសជាតិ ការិយាល័យសន្តិសុខជាតិ ការិយាល័យជាតិប្រឆាំងឧក្រិដ្ឋកម្ម ទីភ្នាក់ងារចារកម្មហិរញ្ញវត្ថុ និងទីភ្នាក់ងារត្រួតពិនិត្យហិរញ្ញវត្ថុ។ មន្ត្រីការពារប្រជាពលរដ្ឋ និងការិយាល័យសវនកម្មជាតិ ក៏ដើរតួនាទីគន្លឹះក្នុងការទប់ស្កាត់អំពើពុករលួយផងដែរ។

រដ្ឋាភិបាលប្រទេសអាហ្វ្រិកខាងត្បូង ក៏បានសម្រេចចិត្តរក្សាទុកនូវរចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់ប្រឆាំងអំពើពុករលួយ និងបានសម្រេចយកនូវការកែលម្អបន្ថែមចំពោះទីភ្នាក់ងារដែលមានស្រាប់។ ប៉ុន្តែ គណៈកម្មាធិការសម្របសម្រួលមួយ ដើម្បីប្រឆាំងអំពើពុករលួយត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការងាររបស់ទីភ្នាក់ងារផ្សេងៗ។ អាស្រ័យហេតុនេះ អាណត្តិកិច្ចការប្រឆាំងអំពើពុករលួយ ត្រូវបានបែងចែករវាងប៉ូលីស ព្រះរាជអាជ្ញា អគ្គសវនករការិយាល័យពន្ធដារអាហ្វ្រិកខាងត្បូង និងគណៈកម្មាធិការសេវាសាធារណៈ។ តួនាទីគន្លឹះស្ថិតនៅជាមួយទីភ្នាក់ងារអយ្យការជាតិ។ នាយកដ្ឋានបណ្តឹងផ្ទៃក្នុង ស៊ើបអង្កេតលើការចោទប្រកាន់អំពីការប្រព្រឹត្តិមិនត្រឹមត្រូវនៅក្នុងកម្លាំងប៉ូលីស។

ស្ថាប័នដែលផ្តោតលើការប្រឆាំងអំពើពុករលួយ ទំនងជានឹងត្រូវបង្កើតឡើងនៅទីណាដែលអំពើពុករលួយរីកសុសសាយ ឬគេយល់ថារីកសុសសាយ ដោយសារស្ថាប័នដែលមានស្រាប់មិនអាចយកមកប្រើ ដើម្បីកសាង និងអនុវត្តកំណែទម្រង់ចាំបាច់ ឬក្នុងករណីណាដែលស្ថាប័នមានស្រាប់ខ្លួនឯងត្រូវបានគេចាត់ទុកថាពុករលួយ។ ប្រសិនបើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលបង្កើតឡើងនេះ អាចដោះស្រាយបញ្ហាពុករលួយបាន នោះការបង្កើតទីភ្នាក់ងារជំនាញមួយនឹងមានគុណវិបត្តិច្រើនជាងគុណសម្បត្តិ។ គុណសម្បត្តិជាច្រើន ដូចជា ឯកទេសកម្មជំនាញ និងសូម្បីតែកម្រិតចាំបាច់នៃស្វ័យភាពក៏ដោយ ក៏អាចសម្រេចបានតាមការបង្កើតអង្គភាពដែលតម្រូវឱ្យបំពេញកិច្ចនោះ នៅក្នុងទីភ្នាក់ងារអនុវត្តន៍ច្បាប់ដែលមានស្រាប់។ ជាលទ្ធផល ការធ្វើបែបនេះមានគុណវិបត្តិតិចតួចនៅក្នុងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ជាមួយករណីអនុវត្តច្បាប់ផ្សេងៗទៀត (UNODC, ២០០៤)។ តែទោះជាយ៉ាងដូច្នេះក៏ដោយ ដូចមាននៅក្នុងករណីសិក្សានៅក្នុងប្រទេសទាំងឡាយ ដែលមិនទាន់បានបង្កើត ACA ហើយពឹងផ្អែកលើស្ថាប័នដែលមានស្រាប់វិញនោះ ការសម្របសម្រួលហាក់ដូចជាបញ្ហាចម្បងមួយ ដែលទាមទារឱ្យមានដំណោះស្រាយពិសេសផ្នែកស្ថាប័ន។

# ការសម្របសម្រួល ៥

ដោយស្ថាប័ននានាដែលពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ តែងតែមានតួនាទីបំពេញបន្ថែម ជោគជ័យរបស់ ACA ភាគច្រើន ពឹងផ្អែកលើកិច្ចសហប្រតិបត្តិការ និងការប្រាស្រ័យទាក់ទងល្អ ហើយ និងដំណើរការត្រឹមត្រូវរបស់ភ្នាក់ងារអនុវត្តន៍ច្បាប់ផ្សេងៗទៀត ជាពិសេសគឺប៉ូលីស ព្រះរាជអាជ្ញាសាធារណៈ និងតុលាការ។ ដោយ មិនគិតអំពីការរៀបចំស្ថាប័ន ដែលប្រទេសមួយបានជ្រើសរើសយក គឺកិច្ចសហការដ៏មានប្រសិទ្ធភាពរបស់តួអង្គដែលពាក់ព័ន្ធទេ ដែល កំណត់ថា តើការប្រឆាំងអំពើពុករលួយនឹងបានទទួលជោគជ័យដែរឬ ទេ។ ហេតុនេះ ការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការរវាង ភ្នាក់ងារអនុវត្តន៍ច្បាប់ដែលមានស្រាប់ គឺជាអាទិភាពសម្រាប់ប្រទេស ជាច្រើននៅតំបន់អាស៊ី។ នៅប្រទេសហ្វីលីពីន ការផ្លាស់ប្តូរព័ត៌មាន ផ្លូវការ ត្រូវបានដាក់ឱ្យមានក្នុងប្រព័ន្ធរវាងទីភ្នាក់ងារអនុវត្តន៍ច្បាប់ ដែលពាក់ព័ន្ធ ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការរបស់ពួកគេ និង ការបង្កើតឡើងនូវអង្គភាពពិគ្រោះយោបល់អន្តរស្ថាប័ន និងក្រុម ការងារពិសេស និង/ឬអង្គការដែលមានកម្មវិធីបណ្តុះបណ្តាលរួមគ្នា ត្រូវបានអនុវត្ត។ ប្រទេសប៉ាពួញូហ្គីណេ កំពុងបង្កើតឡើងនូវសម្ព័ន្ធ ភាពប្រឆាំងអំពើពុករលួយ ដែលប្រមូលផ្តុំ និងសម្របសម្រួលធនធាន នៃទីភ្នាក់ងារអនុវត្តន៍ច្បាប់ផ្សេងៗគ្នា។ សាធារណរដ្ឋកូរ៉េ កំពុងដំណើរ ការនូវអង្គភាពសម្របសម្រួលគោលនយោបាយប្រឆាំងអំពើពុករលួយ ដែលរួមមានទីភ្នាក់ងារ ១០ ពាក់ព័ន្ធ ដូចជាក្រសួងនានា និងអង្គភាព ត្រួតពិនិត្យ (ADB/OECD, ២០០៤:៤១-៤២)។

ឧទាហរណ៍នៃយន្តការ ដែលត្រូវបានបង្កើតឡើងនៅក្នុង ប្រទេសទាំងឡាយ ដែលគ្មាន ACA រួមមាន គណៈកម្មការសម្រាប់ សម្របសម្រួលសកម្មភាពប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើង នៅប្រទេសប៊ុលហ្គារី ក្នុងឆ្នាំ ២០០២។ វាគឺជាគណៈកម្មការអន្តរ ក្រសួង ដែលមានតំណាងមកពីក្រសួងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងការិយាល័យសវនកម្ម។ មុខងារសំខាន់របស់ គណៈកម្មការនេះគឺត្រូវសម្របសម្រួល និងត្រួតពិនិត្យការអនុវត្ត យុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ និងវិភាគអំពីប្រសិទ្ធភាពនៃកិច្ច ខិតខំប្រឹងប្រែង ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ គណៈកម្មការ នេះមិនមានអំណាចស៊ើបអង្កេតដោយផ្ទាល់ខ្លួនទេ ហើយក៏មិនត្រូវបាន អនុញ្ញាតឱ្យធ្វើអន្តរាគមន៍នៅក្នុងករណីពុករលួយទៀតផង។ លើសពី នេះទៀត គណៈកម្មការសភាមួយ ក៏ត្រូវបានបង្កើតឡើង ដើម្បីកំណត់ អំពីគម្លាតនៅក្នុងការអនុវត្តច្បាប់ និងស្នើឡើងនូវការធ្វើវិសោធនកម្ម ច្បាប់ជាធរមាន។ អនុវត្តតាមអនុសាសន៍របស់យុទ្ធសាស្ត្រប្រឆាំង អំពើពុករលួយនៃសេវាសាធារណៈ អាហ្វ្រិកខាងត្បូងបានបង្កើតឡើង នូវគណៈកម្មាធិការសម្របសម្រួលប្រឆាំងអំពើពុករលួយ ដែលមាន ភ្នាក់ងារទាំងឡាយ ដែលមានមុខងារប្រឆាំងអំពើពុករលួយ រួមទាំង នាយកដ្ឋានថ្នាក់ជាតិ និងថ្នាក់ខេត្តផងដែរ។ បើទោះបីជាមានគណៈ កម្មាធិការនេះក៏ដោយ ក៏ការសម្របសម្រួលនៅតែជាបញ្ហាចោទនៅ ឡើយ ព្រោះតែអាណត្តិនីតិបញ្ញត្តិជាន់គ្នា។

ប៉ុន្តែការសម្របសម្រួលមិនត្រឹមតែជាបញ្ហានៅក្នុងប្រទេស ដែលមិនមាន ACA ប៉ុណ្ណោះទេ។ ការបង្កើតស្ថាប័នច្រើនពេក ដែលជា ជាញឹកញាប់មានអាណត្តិការងារផ្ទុយគ្នា គឺជាបញ្ហាដែលតែងកើត ឡើងនៅក្នុងប្រទេសជាច្រើន។ ការសម្របសម្រួលត្រូវតែមានជា ចាំបាច់ហើយ ដូចបានលើកឡើងខាងលើអាណត្តិការងារច្បាស់លាស់ មួយចាំបាច់ត្រូវតែផ្តល់ជូនស្ថាប័នដែលទទួលភារៈនេះ។

នៅឥណ្ឌូនេស៊ី KPK ត្រូវបានផ្តល់ភារកិច្ចសម្របសម្រួល និងគ្រប់គ្រងស្ថាប័នទាំងអស់ ដែលពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងអំពើពុករលួយ។ KPK អាចស្នើសុំឱ្យប៉ូលីស ឬអយ្យការធ្វើការស៊ើបអង្កេតបន្ថែមទៀតលើករណីណាមួយ ប្រសិនបើគេមិនអាចរកភស្តុតាងបានគ្រប់គ្រាន់។ ប៉ូលីស និងអយ្យការ អាចធ្វើការដាក់ពិរុទ្ធចំពោះករណីពុករលួយ ប៉ុន្តែពួកគេត្រូវជូនព័ត៌មានទៅ KPK ក្នុងរយៈពេល ១៤ ថ្ងៃ។ KPK មានភារកិច្ចត្រូវសម្របសម្រួលសកម្មភាពរបស់ពួកគេ។ KPK ក៏មានអំណាចយកដំណើរការដាក់ពិរុទ្ធមកអនុវត្តវិញ ជំនួសប៉ូលីស ឬអយ្យការ។

CPCB របស់ប្រទេសឡាតវៀ ក៏មានអាណត្តិការងារច្បាស់លាស់ ដើម្បីសម្របសម្រួលការអនុវត្តវិធានការប្រឆាំងអំពើពុករលួយ នៅក្នុងស្ថាប័ននៃរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋានដែរ។ អង្គភាពផ្សេងទៀត ដែលមានអាណត្តិស៊ើបអង្កេត តម្រូវឱ្យជួយការិយាល័យនេះ ក្នុងការស៊ើបអង្កេតរបស់ខ្លួន។ តែទោះជាយ៉ាងនេះក៏ដោយ តាមការអនុវត្តជាក់ស្តែង បញ្ហាជាច្រើននៅតែមាន ជាពិសេសដោយសារតែការកើនឡើងនូវភ្នាក់ងារអនុវត្តច្បាប់ (ប៉ូលីសហិរញ្ញវត្ថុ ប៉ូលីសសន្តិសុខ ប៉ូលីសរដ្ឋ និងរដ្ឋអាជ្ញា)។ ហេតុដូច្នេះហើយ បានជាក្រុមប្រឹក្សាសភាដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម និងអំពើពុករលួយត្រូវបានបង្កើតឡើង និងដឹកនាំដោយនាយករដ្ឋមន្ត្រី និងមានភារកិច្ចសម្របសម្រួល និងគ្រប់គ្រងរាល់សកម្មភាពរបស់អាជ្ញាធររដ្ឋ នៅក្នុងវិស័យទប់ស្កាត់ឧក្រិដ្ឋកម្ម និងអំពើពុករលួយ។

នៅប្រទេសលីទុយអានី គឺរដ្ឋអាជ្ញាទេ ដែលមានភារកិច្ចបែងចែករឿងក្តីព្រហ្មទណ្ឌ ដោយសំអាងលើសមត្ថកិច្ចជាក់លាក់របស់អង្គភាពអនុវត្តន៍ច្បាប់ផ្សេងៗ។ ជាធម្មតា SIS មានភារកិច្ចដោះស្រាយករណីពុករលួយ ប៉ុន្តែប៉ូលីសក៏មានកាតព្វកិច្ចទូទៅដើម្បីធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មណាមួយដែលខ្លួនបានទទួល រួមទាំងអំពើពុករលួយផងដែរ។ អាស្រ័យហេតុនេះ កង្វះខាតការសម្របសម្រួលបានបង្ខំឱ្យរដ្ឋាភិបាលបកស្រាយឱ្យច្បាស់លាស់នូវភារកិច្ចសម្រាប់បែងចែករឿងក្តីពុករលួយ។

ប្រទេសថៃហាក់ដូចជាកំពុងតែប្រឈមមុខនឹងបញ្ហានៃការសម្របសម្រួល។ ប្រទេសថៃបានបង្កើតឡើងនូវបណ្តាញស្ថាប័នស្មុគស្មាញមួយនៃអង្គការជាច្រើនដែលពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ ដើម្បីអាចដោះស្រាយអំពើពុករលួយបានពីទិដ្ឋភាពផ្សេងៗគ្នា។ ប៉ុន្តែ ជាមួយនឹងការកើនឡើងនូវចំនួនទីភ្នាក់ងារដែលពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងអំពើពុករលួយ ក៏មានការកើនឡើងនូវហានិភ័យនៃការជាន់ភារកិច្ចគ្នា និងការធ្វើច្រំដែលៗ ដែលជាហេតុតម្រូវឱ្យមានយន្តការសម្របសម្រួលនានាដែលមានប្រសិទ្ធភាព។

នៅពេលធ្វើសេចក្តីសម្រេចលើចំនួនស្ថាប័នដែលត្រូវពាក់ព័ន្ធនឹងសកម្មភាពប្រឆាំងអំពើពុករលួយ និងសម្រេចលើការបែងចែកភារកិច្ចពាក់ព័ន្ធនោះ ការប្រឈមមុខ គឺថាត្រូវអនុញ្ញាតឱ្យមានភារកិច្ចស្ទួនគ្នា ឬ ភារកិច្ចបញ្ច្រាសគ្នាត្រឹមតែគ្រប់ល្មមសម្រាប់លាតត្រដាងអំពើពុករលួយតែប៉ុណ្ណោះបានហើយ ប្រសិនបើកិច្ចការដំបូងគេរបស់ ACA មិនបានសម្រេចជោគជ័យទេនោះ (UNODC, ២០០៤)។ ប៉ុន្តែមិនគួរមានភារកិច្ចស្ទួនគ្នាច្រើនពេកទេ ព្រោះវាធ្វើឱ្យលំហូរព័ត៌មានសម្ងាត់ចុះថយ ឬធ្វើឱ្យឱកាសស៊ើបអង្កេត និងឱកាសធ្វើបណ្តឹងអាជ្ញារបស់អាជ្ញាធរបឋមត្រូវបានសាបសូន្យ ។ ឧទាហរណ៍ នៅប្រទេសហ្សាំបៀ ប៉ូលីស គណៈកម្មការប្រឆាំងអំពើពុករលួយ និងគណៈកម្មការបោះឆ្នោត ម្នាក់ៗសុទ្ធតែបានបដិសេធថា ការអនុវត្តច្បាប់បោះឆ្នោតមិនមែនជាភារកិច្ចរបស់ពួកគេទេ ដែលជាហេតុនាំទៅដល់កង្វះខាតទាំងស្រុង នូវការអនុវត្តច្បាប់បោះឆ្នោត និងបទបញ្ញត្តិពាក់ព័ន្ធ (Tamesis, ២០០៤:៦)។

ដើម្បីដោះស្រាយបញ្ហានេះ ACA ឬ ទីភ្នាក់ងារផ្សេងមួយទៀត អាចទទួលខុសត្រូវសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ទោះជាតាមរបៀបទូលំទូលាយ ឬនៅតែក្នុងវិស័យមួយចំនួនក្តី (ឧ. រដ្ឋអាជ្ញាអាចទទួលខុសត្រូវ សម្របសម្រួលរាល់ការស៊ើបអង្កេតទាំងអស់)។

នៅទីណាដែលការសម្របសម្រួលនៅតែជាបញ្ហា គេគួរតែបង្កើតគណៈកម្មាធិការ ឬ គណៈកម្មការពិសេសមួយ។ សមាជិករបស់គណៈកម្មាធិការ/គណៈកម្មការនេះ អាចរួមបញ្ចូលទាំងតំណាងមកពីអង្គនីតិប្រតិបត្តិ តុលាការ នីតិបញ្ញត្តិ មន្ត្រីរាជការនៅក្នុងនាយកដ្ឋានសំខាន់ៗ ដូចជា នាយកដ្ឋានគយ នាយកដ្ឋានលទ្ធកម្ម និងនាយកដ្ឋានប្រមូលចំណូល ព្រមទាំងមន្ត្រីអនុវត្តន៍ច្បាប់ និងមន្ត្រីមកពីរដ្ឋបាលមូលដ្ឋាន។ គេក៏អាចរួមបញ្ចូលសមាជិកមកពីក្រៅរដ្ឋាភិបាលផងដែរ (ឧ. តំណាងក្រុមសាសនា អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ថ្នាក់ដឹកនាំមុខជំនួញ សារព័ត៌មាន និង សហគមន៍បណ្ឌិតសភា)។

# សេចក្តីសន្និដ្ឋាន ៦

គ្មានសង្គមណាដែលចាកផុតពីអំពើពុករលួយទាំងស្រុងនោះឡើយ។ តែទោះជាយ៉ាងណាក៏ដោយ បើមានវិធានការសមស្របផ្នែកស្ថាប័ន និងផ្នែកនីតិកម្ម អំពើពុករលួយអាចនឹងកំណត់នៅក្នុងកម្រិតមួយដែលអាចទទួលយកបាន។ UNCAC អញ្ជើញប្រទេសទាំងអស់ឱ្យចែករំលែកបទពិសោធ និងបច្ចេកទេសរបស់ពួកគេ ជាមួយនឹងអ្នកបំពេញវិជ្ជាជីវៈដូចគ្នា និងអ្នកធ្វើគោលនយោបាយ ដើម្បីទទួលបានផលប្រយោជន៍ពីគ្នាទៅវិញទៅមក ជាថ្នាក់អន្តរជាតិ ទាំងការប្រតិបត្តិល្អ និងការប្រតិបត្តិអាក្រក់ផង។ ក្នុងនាមជាអ្នកជួយសម្រួលផ្នែកចំណេះដឹង UNDP ដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនេះ។ UNCAC ដែលបានចូលជាធរមាននៅឆ្នាំ ២០០៥ ក្រោយពីទទួលបានលិខិតូបករណ៍ផ្តល់សច្ចាប័នទី ៣០ បានផ្តល់នូវការណែនាំយ៉ាងម៉ឺងម៉ាត់លើបញ្ហាពុករលួយថាជានិយាមអន្តរជាតិ ហើយប្រទេសទាំងអស់ដែលបានផ្តល់សច្ចាប័នរួចហើយ មានកាតព្វកិច្ចត្រូវអនុវត្តតាមខ្លឹមសារនៃអនុសញ្ញានេះ។ តែទោះជាយ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ មានតែប្រទេសអាហ្វ្រិកបាហ្សាន់ ចិន កៀហ្ស៊ីស្ថង់ ម៉ុងហ្គោលី ស្រីលង្កា និងទៀម៉េនីស្តង់ គឺជាប្រទេសមកពីអាស៊ី ដែលបានក្លាយជាភាគីនៃអនុសញ្ញានេះ។

ការសិក្សាប្រៀបធៀបនេះ បានវិភាគអំពីការរៀបចំស្ថាប័នសម្រាប់ប្រឆាំងអំពើពុករលួយនៅក្នុងបណ្តាប្រទេសជាច្រើន។ ការសិក្សាបានផ្តល់នូវមេរៀនជាច្រើន ដែលត្រូវយកមកពិចារណានៅពេលកសាងកំណែទម្រង់នៃការរៀបចំស្ថាប័ន ដែលនៅក្នុងនោះមានបទបញ្ញត្តិជាច្រើននៅក្នុងអនុសញ្ញា អ.ស.ប. ប្រឆាំងអំពើពុករលួយ UNCAC។

គេបានលើកឡើងជាច្រើនដងហើយថា ការបង្កើតទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ACA គឺមិនមែនជាឱសថទិព្វសម្រាប់ដោះស្រាយរាល់បញ្ហាពុករលួយនោះទេ។ ប្រសិនបើគេយល់ថា ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមានស្រាប់ អាចប្រយុទ្ធប្រឆាំងអំពើពុករលួយបាននោះ គឺការបង្កើត ACA ប្រហែលជាមានតម្លៃតែបន្តិចបន្តួចប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើត្រូវការបង្កើត ACA នោះគឺមានចំណុចមួយចំនួនដែលត្រូវតែយកមកគិតពិចារណា (សូមមើល UNDP, ២០០៤):

- ACA ត្រូវតែ**ឯករាជ្យ** (ទាំងផ្នែកនយោបាយ និងផ្នែកប្រតិបត្តិការ) ពីឥទ្ធិពលខាងក្រៅ ដើម្បីអាចឱ្យវាធ្វើបណ្តឹងអាជ្ញាលើអំពើពុករលួយបាននៅគ្រប់កម្រិតទាំងអស់ (នេះអាចសម្រេចបានតាមរយៈឯករាជភាពដែលមានការធានាតាមរដ្ឋធម្មនុញ្ញ ឬ តាមរយៈការបង្កើតឱ្យបានគ្រប់គ្រាន់នូវយន្តការគណនេយ្យភាព/យន្តការគ្រប់គ្រង)។

- ACA (ព្រមទាំងទីភ្នាក់ងារដទៃទៀតដែលពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ) ចាំបាច់ត្រូវប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននៃ**ក្របខ័ណ្ឌច្បាប់ទូលំទូលាយ និងរឹងមាំ**[២៨]។

- ACA ត្រូវតែមានការគាំទ្រនយោបាយរឹងមាំនៅកម្រិតខ្ពស់បំផុតរបស់រដ្ឋាភិបាល។

[២៨] បើគ្មានច្បាប់ដែលអាចអនុវត្តបាន និងប្រសិទ្ធភាពទេ ភ្នាក់ងារមួយមិនអាចដំណើរការបានឡើយ។ នៅហុងកុង អាជ្ញាធរទាំងអស់ទទួលស្គាល់នូវតម្លៃនៃក្របខ័ណ្ឌច្បាប់ ដែលនៅក្នុងនោះ ICAC គួរដំណើរការ។ ដូចគ្នានេះដែរ CPIB របស់សិង្ហបុរី និង ICAC របស់ញូសៅវែល ក៏មានការគាំទ្រពីច្បាប់ដែលអាចអនុវត្តបាន និងរឹងមាំផងដែរ។

- ACA ត្រូវមាន**ធនធានហិរញ្ញវត្ថុ**[២៩] **ធនធានមនុស្ស**[៣០] និង បច្ចេកទេសគ្រប់គ្រាន់ និងសមត្ថភាពរៀបចំអង្គការ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយប្រកប ដោយ ប្រសិទ្ធភាព។ វាត្រូវតែដំណើរការដោយបង្ហាញនូវភាព ជាអ្នកនាំគំរូ ដែលត្រូវមានសុចរិតភាពខ្ពស់បំផុត។

- ACAត្រូវមានអំណាចស៊ើបអង្កេតគ្រប់គ្រាន់ ឧទាហរណ៍ ការសាកសួរសាក្សី មើលឯកសារនានាជាដើម ព្រមទាំង លទ្ធភាពធ្វើបណ្ដឹងអាជ្ញា នៅពេលណា និងទីណាដែល ចាំបាច់

- ACA ត្រូវមានយុទ្ធសាស្ត្ររលូន និងគ្រប់ជ្រុងជ្រោយ សម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ ហើយនិងផ្ដោត លើការទប់ស្កាត់ ការស៊ើបអង្កេត និងការលើកកម្ពស់ការ យល់ដឹង។ (ជាការចាំបាច់គួរផ្ដោតការយកចិត្តទុកដាក់ ចំពោះធាតុទាំងបីនេះ។ ហើយនៅក្នុងប្រទេសមួយចំនួន ស្ថាប័នដែលបានផ្ដោតតែលើការស៊ើបអង្កេត និងការ អនុវត្តច្បាប់នោះ មានជោគជ័យតិចជាងស្ថាប័ន ដែល បានអនុម័តយកយុទ្ធវិធីគ្រប់ជ្រុងជ្រោយ) និង

- ACA ត្រូវតែមាន**ការគាំទ្រពីសង្គមទាំងមូល** ដើម្បីទទួល បានជោគជ័យ(ដែលបញ្ជាក់បន្ថែមទៀតអំពីសារៈសំខាន់ នៃការលើកកម្ពស់ការយល់ដឹង)។

នៅគ្រប់ប្រទេសដែលគេបានធ្វើការសិក្សាសង្ខេបទាំងនេះ សក្ខីភាពបង្ហាញឱ្យឃើញច្បាស់ថា កិច្ចខិតខំប្រឹងប្រែងណាមួយដើម្បី ប្រយុទ្ធប្រឆាំងអំពើពុករលួយឱ្យមានប្រសិទ្ធភាព គឺត្រូវតែមានយុទ្ធវិធី មួយដែលមាន**លក្ខណៈជាប្រព័ន្ធគ្រប់ជ្រុងជ្រោយ និងយូរអង្វែង**។ នេះ មានន័យថា ស្ថាប័នទាំងឡាយដែលទទួលភារកិច្ចប្រយុទ្ធប្រឆាំងអំពើ ពុករលួយត្រូវតែឱ្យមានពេលវេលាគ្រប់គ្រាន់បន្ថែមទៅលើធនធាន ដើម្បីឱ្យបានជោគជ័យ។ នេះក៏គាំទ្រដល់ជំហរដែលថា បន្ថែមទៅលើ ការធ្វើឱ្យមនុស្សញញើតមិនហ៊ានប្រព្រឹត្តអំពើពុករលួយ ស្ថាប័នដែល ទទួលភារកិច្ចប្រយុទ្ធប្រឆាំងអំពើពុករលួយក៏ត្រូវធ្វើការលើកកម្ពស់ ការយល់ដឹងអំពីអំពើពុករលួយ និងតាមរយៈសកម្មភាពទប់ស្កាត់ គឺត្រូវធ្វើកិច្ចការសម្រាប់លុបបំបាត់ចោលឱ្យអស់នូវឱកាសប្រព្រឹត្ត អំពើពុករលួយ។

លើសពីនេះទៅទៀត គ្មានស្ថាប័នណានឹងអាចទទួល ជោគជ័យក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដោយគ្មានក្របខ័ណ្ឌ **អភិបាលកិច្ចមួយដែលមានអំណាច** ព្រមទាំង**ប្រព័ន្ធសុចរិតភាពមួយ** ដែលមានដំណើរការ និងមានភាពរលូនឡើយ។ ដូចដែលបានពិភាក្សា នៅខាងលើ ក្របខ័ណ្ឌនេះរួមមាន តុលាការ ប៉ូលីស ស្ថាប័នសវនកម្ម មន្ត្រីការពារប្រជាពលរដ្ឋជាដើម...។ **សារៈសំខាន់ជាពិសេសនោះ គឺ ទំនាក់ទំនងរវាងស្ថាប័នដែលទទួលភារកិច្ចប្រយុទ្ធប្រឆាំងអំពើពុក រលួយ និងស្ថាប័នដែលទទួលភារកិច្ចប្ដឹងចោទប្រកាន់ និងស្ថាប័ន តុលាការ**។ ស្ថាប័នទាំងនេះមានសារៈសំខាន់សម្រាប់នាំយកករណី ពុករលួយទៅតុលាការ ដើម្បីកាត់សេចក្ដី។ អាស្រ័យហេតុនេះ ប្រសិនបើមិនយកចិត្តទុកដាក់ទៅដល់ការពង្រឹងសមត្ថភាពរបស់ព្រះ រាជអាជ្ញា និងតុលាការទេ កិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំង អំពើពុករលួយទំនងជានឹងត្រូវទទួលបរាជ័យ។

ត្រូវតែគិតដោយយកចិត្តទុកដាក់បំផុត អំពីតួនាទីរបស់**ស្ថាប័ន សវនកម្ម** ព្រមទាំង**មន្ត្រីការពារប្រជាពលរដ្ឋ** ព្រោះថាស្ថាប័នទាំងនេះ មានតួនាទីបំពេញបន្ថែមសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីបំពេញមុខងារផ្សេងៗ ដែលស្ថាប័នដែលមានភារកិច្ចបឋមក្នុង ការប្រឆាំងអំពើពុករលួយមិនអាចធ្វើបាន។

ទោះបីជាប្រទេសណាមួយសម្រេចយកការបង្កើតនូវស្ថាប័ន កំពូល (ដូចជា ACA) ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ឬ សម្រេច ប្រើប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងស្ថាប័នដែលមានស្រាប់ក៏ដោយ ការសំខាន់គឺថា វាត្រូវមាន**បណ្ដាញ និងយន្តការសម្រាប់ធានានូវកិច្ច សហប្រតិបត្តិការ និងការសម្របសម្រួល**រវាងស្ថាប័នផ្សេងៗ ដែល ពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីឱ្យស្ថាប័ន ទាំងនោះមានប្រសិទ្ធភាព។

---

[២៩] ឧទាហរណ៍ ថវិកាសម្រាប់ ICAC របស់ហុងកុង មានចំនួន ៩៤លានដុល្លារ នៅក្នុងឆ្នាំ ២០០២/៩០លានដុល្លារ ក្នុងឆ្នាំ ២០០១។ ICAC របស់ញូសៅវែល ដំណើរការដោយមានថវិកាប្រចាំឆ្នាំចំនួនប្រហែល ៨,៧លានដុល្លារ។ ការិយាល័យស៊ើបអង្កេតអំពើពុករលួយរបស់សិង្ហបុរី មិនមានផ្សាយពីចំនួនថវិការបស់ខ្លួនឡើយ តែត្រូវបានរាយការណ៍ថាមានចំនួនប្រមាណ ៤,៣លានដុល្លារ នៅឆ្នាំ ១៩៨៦។ អធិការដ្ឋានប្រឆាំងឧក្រិដ្ឋកម្មសេដ្ឋកិច្ចនិងអំពើពុករលួយរបស់ប្រទេស បូតស្វាណា មានថវិកាចំនួន ២,៤លានដុល្លារ។

[៣០] ICAC របស់ហុងកុង មានបុគ្គលិកចំនួន ១.៣០០នាក់ សម្រាប់ប្រជាជនសរុបចំនួន ៦.៨លាននាក់។ NCCC របស់ប្រទេសថៃ មានបុគ្គលិកប្រមាណ ៥០០នាក់ សម្រាប់ប្រជាជនសរុបចំនួន ៦៥លាននាក់។ ថៃពន្យល់ពីការលំបាកដែល NCCC ជួបប្រទះនៅក្នុងការបំពេញអាណត្តិរបស់ខ្លួន។

ប៉ុន្តែ ទោះជាប្រទេសនីមួយៗសម្រេចរៀបចំស្ថាប័នយ៉ាងដូចម្តេចក៏ដោយ គេត្រូវសង្កត់ធ្ងន់ថា **អ្វីដែលល្អនៅក្នុងទ្រឹស្តីអាចមិនសូវល្អទេនៅក្នុងការអនុវត្តជាក់ស្តែង**។ ដូចបានលើកឡើងខាងលើ ស្ថាប័នទាំងអស់ត្រូវតែមានការគាំទ្រពេញលេញផ្នែកនយោបាយ ព្រមទាំងបំពាក់ទៅដោយអំណាច និងធនធានគ្រប់គ្រាន់។ ប៉ុន្តែស្ថាប័នទាំងនោះក៏ត្រូវតែមានការគាំទ្រដោយ**ក្របខ័ណ្ឌនីតិកម្ម**សមស្របផងដែរ។ ទន្ទឹមនឹងនេះ នៅក្នុងប្រទេសមួយចំនួនដែលបានសិក្សានៅក្នុងឯកសារនេះ កត្តាសំខាន់មួយនៅក្នុងជោគជ័យនៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺជា**គំរូដែលបានធ្វើឡើងដោយថ្នាក់ដឹកនាំ**របស់ប្រទេសនោះ។ នៅទីណាដែលគេយល់ឃើញថា ថ្នាក់ដឹកនាំនយោបាយមិនពុករលួយ ហើយអំពើពុករលួយមិនត្រូវបានចំណោមសមាជិករដ្ឋាភិបាលទទួលយកទេនោះ កិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយនឹងទទួលបានជោគជ័យកាន់តែច្រើន។

# គន្ថនិទ្ទេស (កម្រងឯកសារពាក់ព័ន្ធផ្សេងៗ)


- ADB/OECD ខែ វិច្ឆិកា ឆ្នាំ ២០០៤: គោលនយោបាយប្រឆាំងអំពើពុករលួយនៅអាស៊ី និងប៉ាស៊ីហ្វិក-ក្របខ័ណ្ឌច្បាប់ និងស្ថាប័ន *http://www1.oecd.org/daf/ASIAcom/pdf/ac-policies-asiapacific-str.pdf*

- Anusiewicz, T. ២០០៣: ប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងរដ្ឋដែលចេញពីរបបកុម្មុយនីស្ត: ឥឡូវតើយើងនៅទីណា? តើយើង ត្រូវចេញដំណើរពីទីនេះទៅទីណា?

- គម្រោងស្រាវជ្រាវយុទ្ធសាស្ត្រអំពើពុករលួយ និងប្រឆាំងអំពើពុករលួយ (ឧបត្ថម្ភដោយ DfiD UK) ឆ្នាំ ១៩៩៩: តើទីភ្នាក់ងារឯករាជ្យប្រឆាំងអំពើពុករលួយ គឺជាដំណោះស្រាយមានប្រសិទ្ធភាពចំពោះបញ្ហាពុករលួយដែរឬទេ? ឯកសារឧទ្ទេសនាមនៅក្នុងសន្និសីទអន្តរជាតិលើកទី ៩ ស្តីពីការប្រឆាំងអំពើពុករលួយ ខែ តុលា ឆ្នាំ ១៩៩៩
- Bertrand de Speville, B., ខែ មេសា ឆ្នាំ ២០០០: ហេតុអ្វីបានជាទីភ្នាក់ងារប្រឆាំងអំពើពុករលួយបរាជ័យ?

- Kpundeh, S. and Levy, B. (eds.), ២០០៤: កសាងសមត្ថភាពរដ្ឋនៅអាហ្វ្រិក : វិធីសាស្ត្រថ្មីៗ មេរៀនដែលលេចឡើង

- Pope, ១៩៩៩ : ឯកសារការងារ: តម្រូវការ និងតួនាទីរបស់ទីភ្នាក់ងារឯករាជ្យប្រឆាំងអំពើពុករលួយ

- Tamesis, P., ២០០៤: កំណែទម្រង់ជាតិប្រឆាំងអំពើពុករលួយ : ជំនះការប្រឈមមុខក្នុងការផ្តល់សេវាមេរៀនពីប្រទេសជុំវិញពិភពលោក

- UNDP, ខែ កុម្ភៈ ឆ្នាំ ២០០៤ : កំណត់សម្គាល់អំពីការអនុវត្តការប្រឆាំងអំពើពុករលួយ *http://www.undp.org/governance/docs/AC%20-%20PN%20-20English.pdf*

- UNODC កម្មវិធីពិភពលោកប្រឆាំងអំពើពុករលួយ ឧបករណ៍ប្រឆាំងអំពើពុករលួយរបស់អ.ស.ប. បោះពុម្ពលើកទី៣ ទីក្រុង Vienna, ខែ កញ្ញា ឆ្នាំ ២០០៤ *http://www.unodc.org/unodc/en/corruption_toolkit.html*

- World Bank, ខែ មេសា ឆ្នាំ ១៩៩៩ : ការប្រើប្រាស់មន្ត្រីការពារប្រជាពលរដ្ឋ ដើម្បីគ្រប់គ្រងមន្ត្រីសាធារណៈ កំណត់សម្គាល់ PREM លេខ១៩ *http://www1.worldbank.org/prem/PREMNotes/premnote19.pdf*

ផ្នែកទី ២

# ការពណ៌នាសង្ខេប របស់ប្រទេសនីមួយៗ

# ប្រទេសអូស្ត្រាលី (រដ្ឋញ៉ូសៅវែល)



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- នាយកដ្ឋានអគ្គមេធាវីនៃរដ្ឋញ៉ូសៅវែល *www.lowlink.nsw.gov.au/agd*
- ការិយាល័យសវនកម្មនៃរដ្ឋញ៉ូសៅវែល *www.audit.nsw.gov.au*
- គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) *www.icac.nsw.gov.au*
- មន្ត្រីការពារប្រជាពលរដ្ឋ រដ្ឋញ៉ូសៅវែល *www.nswombudsman..nsw.gov.au*
- រតនាគារនៃរដ្ឋញ៉ូសៅវែល *www.treasury..nsw.gov.au/index.htm*
- ការិយាល័យនាយកព្រះរាជអាជ្ញាសាធារណៈ *www.odpp.nsw.gov.au*
- គណៈកម្មាធិការពិនិត្យសារឡើងវិញលើការប្រតិបត្តិ (ORC) *www.icac.nsw.gov.au/go/the-icac/what-is-the-icac/independence/-accountability/the-operations-review-committee-(orc)*
- គណៈកម្មាធិការសភារួមស្តីពី ICAC (PJC) *www.parliament.nsw.gov.au/prod/parliment/committee.nsf/0/A0A166D9395ADD4D4A2563E000050563*
- គណៈកម្មាធិការសភារួមនៃការិយាល័យការពារប្រជាពលរដ្ឋ និងគណៈកម្មការប៉ូលីសសច្ចធមិ *www.parliament.nsw.gov.au/prod/parliment/committee.nsf/0/847F90F3F57A066A4A2563E000050573*
- គណៈកម្មការប៉ូលីសសច្ចធមិ (PIC) *www.pic.nsw.gov.au*
- តុលាការកំពូល *www.lawlink.nsw.gov.au/sc*

## បទបញ្ញត្តិចម្បង

- ច្បាប់ស្តីពីនាយកព្រះរាជអាជ្ញាសាធារណៈ (DPP) ឆ្នាំ ១៩៨៦ *http://www.austlii.edu.au/au/legis/nsw/consol_act/doppa1986343*
- ច្បាប់ស្តីពីគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ឆ្នាំ ១៩៨៨ *http://www.austlii.edu.au/au/legis/nsw/consol_act/icaca1988442*
- ច្បាប់ស្តីពីអ្នកការពារប្រជាពលរដ្ឋ ឆ្នាំ ១៩៧៤ *http://www.austlii.edu.au/au/legis/nsw/consol_act/oa1974114*
- ច្បាប់ស្តីពីគណៈកម្មាការប៉ូលីសសច្ចធមិ (PIC) ឆ្នាំ ១៩៩៦ *http://www.austlii.edu.au/au/legis/nsw/consol_act/pica1996312*
- ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ និងសវនកម្ម (PFA) ឆ្នាំ ១៩៨៣ *http://www.austlii.edu.au/au/legis/nsw/consol_act/pfaaa1983189/#pfaaa*

## សាវតា

ក្នុងឆ្នាំ ១៩៨៨ រដ្ឋាភិបាលថ្មីមួយត្រូវបានគេបោះឆ្នោតជ្រើសរើសនៅក្នុងរដ្ឋញ៉ូសៅវែល ដែលបានសន្យាថានឹងបង្កើតគណៈកម្មការដោះស្រាយបញ្ហាពុករលួយ ដោយមានការគាំទ្រផងដែរពីគណបក្សប្រឆាំង ។ ដូច្នេះ ចាំបាច់ត្រូវចងក្រងបទបញ្ញត្តិមួយ ហើយជាលទ្ធផល **ច្បាប់ស្តីអំពីគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ** ត្រូវបានអនុម័តដោយសភាទាំងពីរក្នុងឆ្នាំ ១៩៨៨។ ស្នងការមួយរូបត្រូវបានតែងតាំងក្នុងឆ្នាំ ១៩៨៨ ហើយគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ចាប់ផ្តើមប្រតិបត្តិការកាលពីដើមឆ្នាំ ១៩៨៩ ជាមួយនឹងការចាប់ផ្តើមច្បាប់ស្តីអំពីគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ICAC ឆ្នាំ ១៩៩៧។ ការសម្រេចឱ្យបង្កើត ICAC គឺដោយសារមានបញ្ហាអាស្រូវដ៏ធ្ងន់ធ្ងរ និងកំពុងបន្តមាននៅក្នុងផ្នែកសាធារណៈ ហើយបានរាលដាលចូលទៅដល់សៃវៀននយោបាយផងដែរ ដែលបណ្តាលឱ្យសាធារណជនមានការព្រួយបារម្ភពាសពេញទិសទី (O'Keefe, ២០០២:២-៣)។ គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ ICAC បានអនុម័តយកវិធីសាស្ត្រ ៣មុខព្រួញ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ស្រដៀងគ្នាទៅនឹងវិធីសាស្ត្រដែលបានអនុម័តដោយគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយនៅទីក្រុងហុងកុង S.A.R. ដែលគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) របស់រដ្ឋញ៉ូសៅវែលយកជាគំរូ ។ ប្រការនេះ បង្ហាញពីយុទ្ធសាស្ត្រដែលផ្តោតទៅលើការ**ស៊ើបអង្កេត ការទប់ស្កាត់** ព្រមទាំង**ការអប់រំ**។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ICAC ជាមួយគណៈកម្មការប្រឆាំងនឹងអំពើពុករលួយនៃប្រទេសសឹង្ហបុរី ហើយនិងហុងកុង S.A.R. ត្រូវបានមជ្ឈដ្ឋានអន្តរជាតិ មើលឃើញថាជាគំរូសម្រាប់បង្កើតស្ថាប័នប្រឆាំងអំពើពុករលួយ ហើយគំរូនេះត្រូវបានគេកំពុងអនុម័តតាម ដូចជានៅប្រទេសកូរ៉េខាងត្បូងជាដើម ឬកំពុងត្រូវបានពិចារណាដោយប្រទេសផ្សេងទៀត ។ ប៉ុន្តែ ចំណាយដ៏ខ្ពស់ផ្នែកសេដ្ឋកិច្ច និងនយោបាយក្នុងការបង្កើតគណៈកម្មការឯករាជ្យបែបនេះ បានបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការអនុវត្ត (អង្គការតម្លាភាពអន្តរជាតិ ២០០១:១៤)។

ទោះបីជាគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ត្រូវបានចាត់ទុកជាឧទាហរណ៍សម្រាប់ឱ្យអ្នកដទៃអនុវត្តតាមក៏ដោយ ក៏នៅក្នុងឆ្នាំ ១៩៩៦ គណៈកម្មការភូមិន្ទ ដែលធ្វើការស៊ើបអង្កេតទៅលើកងកម្លាំងប៉ូលីសនៃរដ្ឋញ៉ូសៅវែល បានរកឃើញថា មានអំពើពុករលួយពាសពេញនៅក្នុងកងកម្លាំងប៉ូលីសនេះ។ គណៈកម្មការភូមិន្ទបានរកឃើញថា គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) មិនត្រូវបានបំពាក់ឧបករណ៍គ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងកងកម្លាំងប៉ូលីសទេ ហើយបានផ្តល់អនុសាសន៍ឱ្យបង្កើតស្ថាប័នឯករាជ្យមួយសម្រាប់ដោះស្រាយតែចំពោះការប្រព្រឹត្តិខុសឆ្គងនៅក្នុងកងកម្លាំងប៉ូលីស។ ប្រការនេះ បាននាំទៅរកការអនុម័តច្បាប់ស្តីអំពីប៉ូលីសសច្ចធម៌ក្នុងឆ្នាំ ១៩៩៦ បន្ទាប់មកទៀត ទើបនាំឱ្យមានការបង្កើតគណៈកម្មការប៉ូលីសសច្ចធម៌ (PIC) ក្នុងឆ្នាំ ១៩៩៧ (Wood ២០០៤)។

មិនមានសមមូលទៅនឹងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) នៅថ្នាក់ជាតិនៃប្រទេសអូស្ត្រាលីទេ។ ទីភ្នាក់ងារស្រដៀងគ្នានេះប្រាកដជាមាននៅថ្នាក់រដ្ឋ ឧទាហរណ៍ គណៈកម្មការប្រឆាំងឧក្រិដ្ឋកម្ម និងការប្រព្រឹត្តិខុសនៅឃ្វីន្សលែន និងគណៈកម្មការប្រឆាំងអំពើពុករលួយនៅភាគខាងលិចអូស្ត្រាលី។ ប្រការនេះត្រូវបានមតិមួយចំនួនគិតថា នៅក្នុងការរៀបចំនេះ គេពិតជាមិនបានគិតគូរដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅថ្នាក់ជាតិសោះទេ (Doig និង McIvor, ២០០៤:១៦)។

ប្រទេសអូស្ត្រាលីជាប់ចំណាត់ថ្នាក់លេខ ៩ ក្នុងចំណោមប្រទេសចំនួន ១៥៩ ក្នុងសន្ទស្សន៍ ស្តីអំពីទស្សនៈអំពីអំពើពុករលួយប្រចាំឆ្នាំ ២០០៥ របស់អង្គការ**តម្លាភាពអន្តរជាតិ** ។ ទោះបីជាប្រការនេះបង្ហាញថា ប្រជាជនអូស្ត្រាលីយល់ឃើញថា មានអំពើពុករលួយតិចតួចនៅក្នុងប្រទេសរបស់ខ្លួនក៏ដោយ រូបភាពពិតគឺមានលក្ខណៈខុសគ្នានៅថ្នាក់រដ្ឋ។ ក្នុងឆ្នាំ២០០៣ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC)ដែលបានធ្វើការអង្កេតទៅលើអកប្បកិរិយារបស់សហគមន៍ចំពោះអំពើពុករលួយ និងចំពោះគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) បានរកឃើញថា ៨២ភាគរយ យល់ឃើញថា អំពើពុករលួយគឺជាបញ្ហានៅក្នុងរដ្ឋញ៉ូសៅវែល ហើយ ៤២ភាគរយ ជឿជាក់ថាពួកគេ និងគ្រួសាររបស់ខ្លួនបានទទួលរងនូវផលប៉ះពាល់តាមបែបផ្សេងៗនៃអំពើពុករលួយ។ អំពើពុករលួយត្រូវបានគេយល់ឃើញថា បានប៉ះពាល់ដល់សហគមន៍ទាំងមូលដោយសារសេវាទន់ខ្សោយ និង/ឬថាមនុស្ស/ប្រជាជនត្រូវបង់លុយបន្ថែមសម្រាប់សេវាកម្ម ។ ឧទាហរណ៍នៃអំពើពុករលួយដែលអ្នកឆ្លើយតបបានផ្តល់ឱ្យ គឺភាគច្រើនប្រព្រឹត្តដោយរដ្ឋអំណាចមូលដ្ឋាន ប៉ូលីស និងក្រសួងផ្សេងទៀត ឬនៅក្នុងឱកាសរកការងារធ្វើ ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ** (ICAC) គឺជាគណៈកម្មការអចិន្ត្រៃយ៍ស៊ើបអង្កេត ដែលផ្តោតជាពិសេសទៅលើការស៊ើបអង្កេត និងការទប់ស្កាត់រាល់អំពើពុករលួយក្នុងផ្នែកសាធារណៈ។ គណៈកម្មការនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៨៩ ដោយយោងតាមគុណតម្លៃអនុផ្នែក ៤ (១) នៃច្បាប់ ICAC។ ច្បាប់ ICAC បានកំណត់និយមន័យទៅលើពាក្យ**ពុករលួយ** កំណត់តួនាទីការងាររបស់ ICAC ពិពណ៌នាពីការទទួលខុសត្រូវលើកិច្ចការដែលសភាបញ្ជូនមកឱ្យរៀបចំ និងកំណត់តួនាទីរបស់**គណៈកម្មការសភារួមស្តីពី ICAC (PJC)** និង**គណៈកម្មការពិនិត្យលើការប្រតិបត្តិ** (ORC) ព្រមទាំងបង្កើតបទបញ្ញត្តិសម្រាប់កិច្ចការដែលសភាបញ្ជូនមកឱ្យ និងកិច្ចការរាយការណ៍ជូនទៅសភាវិញ។ បន្ថែមទៅលើច្បាប់ ICAC អភិបាលរដ្ឋប្រហែលជាត្រូវបង្កើតបទបញ្ជាដែលស្របជាមួយបទបញ្ញត្តិនេះ ដែលពាក់ព័ន្ធទៅលើវិស័យផ្សេងៗ ដូចជា ការតែងតាំងល័ក្ខខ័ណ្ឌការងារ វិន័យ ក្រមសីលធម៌ និងការបញ្ឈប់បុគ្គលិកពីការងាររបស់ ICAC ។ល។ (ICAC Act, section ១១៧) ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ប្រតិបត្តិការដោយឯករាជ្យដាច់ពីសភាញូសៅវែល រដ្ឋាភិបាល និងតុលាការ ហើយច្បាប់ស្តីពីគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ក៏បានផ្តល់ឱ្យនូវសិទ្ធិអំណាច និងសេរីភាពសំខាន់ៗដល់ ICAC ដើម្បីអនុវត្ត តួនាទីជាគោលការណ៍របស់ខ្លួន។ ជាលទ្ធផល "**មានក្របខ័ណ្ឌអភិបាលកិច្ចដ៏ទូលំទូលាយ** (ទាំងខាងក្នុង និងខាងក្រៅ) **ដើម្បីធានាថា ICAC មានតម្លាភាព និងមានការទទួលខុសត្រូវ**" (ICAC ២០០៤:៥១)។ ក្របខ័ណ្ឌការងារនេះនឹងត្រូវបានពិភាក្សានៅខាងក្រោម ព្រមទាំងស្ថិតនៅក្រោមចំណងជើងការរៀបចំប្រតិបត្តិការ។ ដោយយោងទៅតាមផ្នែក ៧៦ នៃច្បាប់ ICAC គណៈកម្មការនេះត្រូវដាក់ជូនទៅការិយាល័យប្រធានសភានីមួយៗនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីប្រតិបត្តិការរបស់ខ្លួន។ គណៈកម្មការនេះត្រូវទទួលខុសត្រូវចំពោះ**រតនាគារញូសៅវែល**ពាក់ព័ន្ធទៅនឹងការផ្តល់មូលនិធិ និងចំណាយ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ដឹកនាំដោយស្នងការមួយរូប ដែលតែងតាំងដោយអភិបាល (ច្បាប់ ICAC, ផ្នែក ៥) បន្ទាប់ពីបានត្រូវគេបញ្ជូនទៅកាន់ PJC (ច្បាប់ ICAC, អនុផ្នែក ៥A [១]) ជាមួយគ្នានឹងជំនួយការម្នាក់របស់ស្នងការ ដែលត្រូវបានតែងតាំងដោយអភិបាល ដោយមានការឯកភាពរបស់ស្នងការ (ច្បាប់ ICAC, ផ្នែក៦)។ អាណត្តិមុខងាររបស់ស្នងការមានរយៈពេល ៥ឆ្នាំ និងមិនបន្តថ្មីឡើងវិញទេ (ច្បាប់ ICAC, កាលវិភាគ ១, អនុផ្នែក ៤) ហើយស្នងការរូបនេះអាចត្រូវដកហូតពីតំណែងបានតែតាមការសម្រេចរបស់សភាប៉ុណ្ណោះ (ច្បាប់ ICAC, កាលវិភាគ ១, ផ្នែក ៦ [៣])។ យោងទៅតាមអនុផ្នែក ១០៤ (១) នៃច្បាប់ ICAC ស្នងការអាចជួលបុគ្គលិកតាមការចាំបាច់ ដើម្បីអនុវត្តតួនាទីការងាររបស់ខ្លួន។ គ្រប់សមាជិកទាំងអស់នៃ ICAC ស្ថិតនៅក្រោមការគ្រប់គ្រង និងការដឹកនាំរបស់ស្នងការ (ច្បាប់ ICAC, អនុផ្នែក ១០៤ [៧])។ យោងតាមអនុផ្នែក ១០៧ [១-២] នៃច្បាប់ ICAC ស្នងការ ព្រមទាំងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) អាចបែងចែកតួនាទីណាមួយរបស់ខ្លួនឱ្យទៅជំនួយការរបស់ស្នងការ ឬឱ្យទៅមន្ត្រីនៃគណៈកម្មការ លើកលែងតែមានចែងនៅក្នុងអនុផ្នែក ១០៧ [៤-៥] ។

រចនាសម្ព័ន្ធស្ថាប័ននៃ ICAC មានអង្គភាពប្រតិបត្តិការ ១ និងសាខាចំនួន ៥ ដែលមានឈ្មោះដូចខាងក្រោមនេះ:

- **ផ្នែកវាយតម្លៃ** ទទួលរបាយការណ៍ និងពាក្យបណ្តឹងទាំងអស់ ចុះបញ្ជីបញ្ហានីមួយៗ និងធ្វើការសាកសួរបន្ថែមតាមចាំបាច់។ បន្ទាប់មកទៀត រាល់បញ្ហាទាំងអស់ត្រូវបានរាយការណ៍ទៅ**គណៈកម្មការវាយតម្លៃ**ដែលជាគណៈកម្មការពិនិត្យផ្ទៃក្នុង ដែលមានភារកិច្ចត្រូវកំណត់ថា តើត្រូវធ្វើយ៉ាងដូចម្តេចចំពោះបញ្ហានីមួយៗដែលទទួលបាន ។
- **ផ្នែកសាខាសេវារួម** ផ្តល់សេវា និងដំណោះស្រាយ ដែលទាក់ទងទៅនឹងបញ្ហាអាជីវកម្មរបស់អតិថិជន ព្រមទាំងផ្តល់យោបល់ណែនាំបន្ថែមទៅលើគោលនយោបាយជាយុទ្ធសាស្ត្រក្នុងវិស័យធ្វើផែនការអាជីវកម្ម ធនធានមនុស្ស ការអភិវឌ្ឍ ការសិក្សា ការអភិវឌ្ឍបុគ្គលិក ការចាត់ចែងហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យ លទ្ធកម្ម និងសេវាការិយាល័យ ហើយនិងការគ្រប់គ្រងព័ត៌មាន និងបច្ចេកវិទ្យា ។

- **ផ្នែកទប់ស្កាត់អំពើពុករលួយ ការអប់រំ និងការស្រាវជ្រាវ** ផ្តល់ឱវាទ ការអប់រំ ធនធានបណ្តុះបណ្តាល និងការណែនាំដល់ទីភ្នាក់ងារសាធារណៈ ព្រមទាំងអប់រំដល់មន្ត្រីរាជការ និងសហគមន៍ជាទូទៅ អំពីអំពើពុករលួយ និងរបៀបរាយការណ៍ពីអំពើពុករលួយ ។
- **ផ្នែកច្បាប់** ហើយនិង
- **ផ្នែកប្រតិបត្តិការយុទ្ធសាស្ត្រ** មានការទទួលខុសត្រូវសំខាន់ក្នុងការស៊ើបអង្កេតរបស់ ICAC ។ ផ្នែកនេះមានអង្គភាព ២ គឺអង្គភាពស៊ើបអង្កេត និងអង្គភាពវាយតម្លៃលើហានិភ័យនៃយុទ្ធសាស្ត្រ ដែលចែកចេញជា ៣ ផ្នែកតូចៗគឺ ការតាមឃ្លាំមើល ការគ្រប់គ្រងផលិតផល និងការស៊ើបការសម្ងាត់ ។

ការសម្របសម្រួលផ្ទៃក្នុងព្រមទាំងអភិបាលកិច្ចនៅក្នុងគណៈកម្មការត្រូវស្ថិតនៅក្នុងបន្ទុករបស់ក្រុមគ្រប់គ្រង ចំនួន ២ៈ

- **ក្រុមគ្រប់គ្រងផ្នែកទប់ស្កាត់** ពិនិត្យជារួមទៅលើការទប់ស្កាត់អំពើពុករលួយ ការអប់រំ និង ការស្រាវជ្រាវរបស់គណៈកម្មការ និងធានាថា ការងារទាំងនោះត្រូវមានការសម្របសម្រួលល្អជាមួយសកម្មភាពផ្សេងទៀតរបស់គណៈកម្មការ ។
- **ក្រុមគ្រប់គ្រងផ្នែកស៊ើបអង្កេត** ផ្តល់ទិសដៅ ផ្តល់ដំបូន្មាន និងការពិនិត្យលើការស៊ើបអង្កេតដែលធ្វើឡើងដោយផ្នែកប្រតិបត្តិការយុទ្ធសាស្ត្រ ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) បានអនុម័តយុទ្ធសាស្ត្រមួយឆ្ពោះទៅរកការប្រយុទ្ធប្រឆាំងអំពើពុករលួយស្រដៀងគ្នាទៅនឹងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយនៅទីក្រុងហុងកុង S.A.R. ដែលផ្តោតទៅលើការស៊ើបអង្កេត ការទប់ស្កាត់ និងការអប់រំ ។ ផ្នែក ១៣ នៃច្បាប់ ICAC ចែងថា ភារកិច្ចចម្បងរបស់គណៈកម្មការនេះ មានៈ

- ក្នុងវិស័យស៊ើបអង្កេត (អនុផ្នែក ១ [a-c])
  - ដើម្បីស៊ើបអង្កេតការចោទប្រកាន់ ឬការប្តឹងណាមួយ ឬបញ្ហាផ្សេងទៀតដែលគណៈកម្មការយល់ថា ចំណុចខាងក្រោមនេះអាចកើតឡើងរួចហើយ អាចនឹងកំពុងកើតឡើង ឬប្រហែលជាអាចនឹងកើតឡើងនូវៈ
    - ការប្រព្រឹត្តអំពើពុករលួយ ឬ
    - ការប្រព្រឹត្តដែលអនុញ្ញាតឱ្យកើតមាន ជំរុញឱ្យកើតមាន ឬ បណ្តាលឱ្យកើតមានការប្រព្រឹត្តអំពើពុករលួយ
    - ការប្រព្រឹត្តដែលទាក់ទងទៅនឹងការប្រព្រឹត្តអំពើពុករលួយ
  - ដើម្បីស៊ើបអង្កេតបញ្ហានានាដែលសភាទាំងពីរបានបញ្ជូនមកគណៈកម្មការ
  - ដើម្បីទំនាក់ទំនងជាមួយអាជ្ញាធរសមស្រប ស្តីពីលទ្ធផលនៃការស៊ើបអង្កេត

ដូចមានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីគណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) ការប្រព្រឹត្តអំពើពុករលួយ គឺជាការប្រព្រឹត្តទាំងឡាយណា ដែលធ្វើដោយនរណាម្នាក់ ទោះជាមន្ត្រីរាជការ ឬមិនមែនជាមន្ត្រីរាជការ ដែលបង្កផលប៉ះពាល់អាក្រក់ ឬអាចប៉ះពាល់ដល់ការបំពេញតួនាទីជាផ្លូវការនៅក្នុងរដ្ឋញ៉ូសៅវែល (ផ្នែក ៨) ។ តែទោះជាយ៉ាងនេះក៏ដោយ ចំពោះការប្រព្រឹត្តដែលត្រូវគេចាត់ទុកថាជាអំពើពុករលួយ គឺត្រូវមានប្រភេទមួយដែលបង្កឱ្យមាន ឬដែលពាក់ព័ន្ធជាមួយបទល្មើសព្រហ្មទណ្ឌ ឬបទល្មើសដែលត្រូវដាក់វិន័យ ឬត្រូវមានមូលហេតុសមស្របសម្រាប់បណ្តេញមន្ត្រីសាធារណៈចេញពីការងារ ។ ចំពោះរដ្ឋមន្ត្រី ឬសមាជិកសភាវិញនោះ គឺត្រូវតែមានការរំលោភធ្ងន់ធ្ងរទៅលើក្រមសីលធម៌ ឬមានការពាក់ព័ន្ធនឹងការរំលោភច្បាប់ (បទបញ្ញត្តិ ICAC ផ្នែក៩) ។ គួរកត់សម្គាល់ផងដែរថា ICAC អាចស៊ើបអង្កេតលើអំពើពុករលួយដែលគេសង្ស័យថាមាននៅក្នុងផ្នែកឯកជន ដែលវាទាក់ទងទៅនឹងឬប៉ះពាល់ទៅដល់សេវាសាធារណៈតែប៉ុណ្ណោះ ។

- ក្នុងវិស័យទប់ស្កាត់ (អនុផ្នែក ១ឱ្យដ-ងឌ) មុខងារចម្បងរបស់គណៈកម្មការគឺៈ
  - ពិនិត្យលើច្បាប់គ្រប់គ្រងអាជ្ញាធរសាធារណៈ និងមន្ត្រីសាធារណៈ ការអនុវត្ត និងនីតិវិធីអនុវត្តរបស់អាជ្ញាធរសាធារណៈ និងមន្ត្រីសាធារណៈ ដើម្បីជួយសម្រួលដល់ការស្វះស្វែងរកឱ្យឃើញនូវការប្រព្រឹត្តអំពើពុករលួយ និងដើម្បីធានាកុំឱ្យបាត់នូវការត្រួតពិនិត្យលើរបៀបធ្វើការ ឬ នីតិវិធីការងារ ដែលគណៈកម្មការយល់ថា វាអាចនាំទៅរកការប្រព្រឹត្តអំពើពុករលួយ ។

- ណែនាំ ផ្ដល់យោបល់ និងជួយដល់អាជ្ញាធរ ឬមន្ត្រីសាធារណៈ ឬអ្នកដទៃ (តាមសំណើរបស់អាជ្ញាធរ ឬមន្ត្រីសាធារណៈ ឬអ្នកដទៃ) នូវរបៀបដែលត្រូវធ្វើក្នុងការលុបបំបាត់ការប្រព្រឹត្តអំពើពុករលួយ ។
- ណែនាំដល់អាជ្ញាធរ ឬមន្ត្រីសាធារណៈ អំពីការផ្លាស់ប្ដូរការអនុវត្ត ឬការផ្លាស់ប្ដូរនីតិវិធី សម្រាប់ធ្វើឱ្យការងារមានប្រសិទ្ធភាព ដែលគណៈកម្មការគិតថា ចាំបាច់ត្រូវកាត់បន្ថយនូវឱកាសដែលអាចនាំឱ្យកើតមានការប្រព្រឹត្តអំពើពុករលួយ ។
- សហការជាមួយអាជ្ញាធរ និងមន្ត្រីសាធារណៈ ក្នុងការពិនិត្យលើច្បាប់ ការអនុវត្ត និងនីតិវិធី ក្នុងគោលបំណងដើម្បីកាត់បន្ថយឱកាសដែលនាំឱ្យកើតមានការប្រព្រឹត្តអំពើពុករលួយ ។

- នៅក្នុងវិស័យអប់រំ (អនុផ្នែក ១ [h-k]) មុខងារចម្បងរបស់គណៈកម្មការគឺ:
  - អប់រំ និងណែនាំដល់អាជ្ញាធរ និងមន្ត្រីសាធារណៈ និងសហគមន៍ស្ដីពីយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងនឹងការប្រព្រឹត្តអំពើពុករលួយ ។
  - អប់រំ និងចែកចាយព័ត៌មានដល់សាធារណជន ស្ដីពីផលអាក្រក់នៃការប្រព្រឹត្តអំពើពុករលួយ និងស្ដីពីសារៈសំខាន់នៃការថែរក្សាសច្ចធម៌នៅក្នុងផ្នែករដ្ឋបាលសាធារណៈ ។
  - ចុះបញ្ជី និងជំរុញឱ្យមានការគាំទ្រពីសាធារណជន ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រព្រឹត្តអំពើពុករលួយ
  - បង្កើត រៀបចំ គ្រប់គ្រង ចូលរួម និងអនុវត្តកម្មវិធីអប់រំ ឬ កម្មវិធីណែនាំក្នុងវិស័យប្រយុទ្ធប្រឆាំងនឹងការប្រព្រឹត្តអំពើពុករលួយនេះ ដូចដែលបានពិពណ៌នានៅក្នុងសេចក្ដីអំណះអំណាង ដែលសភាទាំងពីរបានដាក់ឱ្យគណៈកម្មការ ។

លើសពីនេះទៀត យោងទៅតាមអនុផ្នែក ១៣ (២) គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ត្រូវធ្វើការស៊ើបអង្កេតដើម្បីកំណត់ថា:

- តើការប្រព្រឹត្តិអំពើពុករលួយបានកើតឡើង កំពុងកើតឡើង ឬនឹងកើតឡើងដែរឬទេ ។
- តើច្បាប់គ្រប់គ្រងអាជ្ញាធរ និងមន្ត្រីសាធារណៈត្រូវផ្លាស់ប្ដូរដែរឬទេ ដើម្បីកាត់បន្ថយនូវឱកាស ដែលនាំឱ្យកើតមានការប្រព្រឹត្តអំពើពុករលួយ ។
- តើមានវិធីសាស្ត្រការងារណាមួយ ការអនុវត្តណាមួយ ឬនីតិវិធីណាមួយរបស់អាជ្ញាធរ និង មន្ត្រីសាធារណៈណាមួយបានអនុញ្ញាត ឬអាចអនុញ្ញាត ជំរុញឱ្យកើតមាន ឬជាមូលហេតុបង្កឱ្យកើតមានការប្រព្រឹត្តិអំពើពុករលួយដែរឬទេ ។

បន្ថែមទៅលើចំណុចនេះ មុខងារសំខាន់របស់ ICAC ក៏រួមបញ្ចូលផងដែរ នូវអំណាចធ្វើរបាយការណ៍ និងលើកយោបល់ដោយឈរលើមូលដ្ឋាននៃលទ្ធផលដែលទទួលបានពីការស៊ើបអង្កេតរបស់ខ្លួន ស្ដីអំពីការប្រព្រឹត្តិណាមួយ និងស្ដីពីកាលៈទេសៈ ឬព្រឹត្តិការណ៍នានា ដែលការស៊ើបអង្កេតនោះមានការចាប់អារម្មណ៍ទៅលើ ។ ប្រការនេះអាចធ្វើបាន ទោះបីជាការរកឃើញឬមតិយោបល់ទាក់ទងទៅនឹងការប្រព្រឹត្តិអំពើពុករលួយ ហើយនិងអំណាចនៃការផ្ដល់អនុសាសន៍សម្រាប់ចាត់វិធានការការស៊ើបអង្កេតរបស់ខ្លួន ដែល ICAC បានលើកឡើងត្រូវបានគេទទួលយកឬមិនយកក៏ដោយ (ច្បាប់ ICAC អនុផ្នែក ១៣ [3]) ។

ដូចដែលបានលើកឡើងខាងលើ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) អាចធ្វើការស៊ើបអង្កេតតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនឯងផង តាមពាក្យបណ្ដឹងផង តាមរបាយការណ៍ដែលគេបានដាក់ជូនផង ព្រមទាំងតាមសេចក្ដីអំណះអំណាងដែលបានដាក់ជូនគណៈកម្មការផង ។ យោងតាមចំណុច អនុផ្នែក ១០ នៃច្បាប់ ICAC "ជនណាក៏មានសិទ្ធិដាក់ពាក្យបណ្ដឹងទៅគណៈកម្មការ អំពីបញ្ហាដែលពាក់ព័ន្ធ ឬដែលអាចពាក់ព័ន្ធនឹងការប្រព្រឹត្តិអំពើពុករលួយ" ។ ការស៊ើបអង្កេតតាមពាក្យបណ្ដឹង ឬមិនស៊ើបអង្កេត ឬការបញ្ឈប់ការស៊ើបអង្កេត គឺជាសិទ្ធិសម្រេចរបស់គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) (ច្បាប់ ICAC អនុផ្នែក១០ [2-3]) ។ ប៉ុន្តែ គណៈកម្មការនេះត្រូវតែពិគ្រោះយោបល់ជាមួយគណៈកម្មការពិនិត្យលើការប្រតិបត្តិ (ORC) មុននឹងសម្រេចថា តើត្រូវផ្អាកឬមិនត្រូវផ្អាក ត្រូវចាប់ផ្ដើម ឬមិនត្រូវចាប់ផ្ដើមធ្វើការស៊ើបអង្កេតលើពាក្យបណ្ដឹងណាមួយ ឬលើរបាយការណ៍ណាមួយ (ច្បាប់ ICAC អនុផ្នែក ២០ [4]) ។ មន្ត្រីសំខាន់ៗនៃអាជ្ញាធរសាធារណៈត្រូវបានច្បាប់ ICAC តម្រូវឱ្យរាយការណ៍ជូនគណៈកម្មការ នូវរាល់ការប្រព្រឹត្តិនានា ដែលគេសង្ស័យថាមានពាក់ព័ន្ធនឹងអំពើពុករលួយ

(អនុផ្នែក២)។ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) អាចណែនាំដល់អាជ្ញាធរសមស្រប ឱ្យចាត់វិធានការការពារសាក្សី និងអ្នកដែលជួយដល់ ICAC (ច្បាប់ ICAC ផ្នែក៥០) ។

សារៈសំខាន់នៃការស៊ើបអង្កេត គឺត្រូវឈរលើមូលដ្ឋាននៃការមិនសន្មត់ថាមានកំហុស ដូចដែលមានចែងនៅក្នុងពាក្យបណ្តឹង ឬក្នុងរបាយការណ៍ដែលទទួលបានឡើយ។ ការបង្ហាញថា ការប្រព្រឹត្តិអំពើពុករលួយបានកើតឡើង គឺជាតួនាទីរបស់ ICAC (ច្បាប់ ICAC ២០០៨:៣០) ។ ដូច្នេះ ក្រោមច្បាប់ ICAC គណៈកម្មការនេះបានទទួលនូវសិទ្ធិអំណាចខ្លាំងក្លា លើសពីបទបញ្ញត្តិដែលបានផ្តល់ដល់មន្ត្រីប៉ូលីសក្នុងការស៊ើបអង្កេត។ សិទ្ធិអំណាចទាំងនេះរួមមានៈ អំណាចទាមទារឱ្យអាជ្ញាធរសាធារណៈ និងមន្ត្រីផ្តល់ព័ត៌មាន ឬបង្កើតឯកសារ (ច្បាប់ ICAC ផ្នែក ២១ និង ផ្នែក ២២) អំណាចចូលក្នុងការិយាល័យសាធារណៈនានា ដោយមានការអនុញ្ញាតជាលាយល័ក្ខអក្សរពីស្នងការ (ច្បាប់ ICAC ផ្នែក ២៣) ព្រមទាំងមានដីកាឆែកឆេរ មានសិទ្ធិចូលក្នុងគេហដ្ឋាន មានសិទ្ធិឆែកឆេរ និងធ្វើអធិការកិច្ច ថតចម្លង និងរឹបអូសឯកសារ ឬភស្តុតាងផ្សេងទៀត (ច្បាប់ ICAC ផ្នែក ៤១ និង ៤៧) ។ ដីកាឆែកឆេរអាចចេញដោយចៅក្រម ឬដោយស្នងការ (ទោះជាស្នងការកំរប្រើប្រាស់អំណាចនេះក៏ដោយ) (ច្បាប់ ICAC  អនុផ្នែក ៤០ [1-2]) ។ អ្នកស៊ើបអង្កេតរបស់ ICAC ក៏អាចទទួលបានដីកាដែលអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍សម្រាប់ស្តាប់ និងសម្រាប់ចាប់សម្លេងសន្ទនាតាមទូរស័ព្ទ។ យោងតាមបទបញ្ញត្តិឆ្នាំ ១៩៨៤ ស្តីពីការប្រើប្រាស់ឧបករណ៍ស្តាប់ការប្រើប្រាស់គ្រឿងស្តាប់នេះ ត្រូវតែមានការអនុញ្ញាត និងការផ្តល់ឱ្យដោយចៅក្រមតុលាការកំពូល។ យោងទៅតាមបទបញ្ញត្តិឆ្នាំ ១៩៧៩ ស្តីពីការចាប់សម្លេងសន្ទនាតាមទូរស័ព្ទ ការចាប់សម្លេងទូរស័ព្ទនេះត្រូវមានការអនុញ្ញាត ឬផ្តល់ឱ្យដោយសមាជិកម្នាក់នៃតុលាការឧទ្ធរណ៍រដ្ឋបាល។ ដើម្បីធានាឱ្យមានការគោរពតាមសេចក្តីតម្រូវទាំងនេះ មន្ត្រីការពារប្រជាពលរដ្ឋ (**Ombudsman**) ធ្វើអធិការកិច្ចលើកំណត់ត្រាការងាររបស់ ICAC ស្តីពីការចាប់សម្លេងទូរស័ព្ទ និងត្រួតពិនិត្យលើប្រតិបត្តិការផង។ ICAC ក៏ត្រូវរាយការណ៍ពីការប្រើប្រាស់គ្រឿងស្តាប់សម្លេងរបស់ខ្លួនជូន **នាយកដ្ឋានអគ្គមេធាវី**ផងដែរ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ក៏មានគោលនយោបាយអនុម័តផ្ទៃក្នុងផងដែរ មុននឹងដាក់ពាក្យសុំដីកាប្រភេទណាមួយ ។ ដោយស្របជាមួយនឹងគោលនយោបាយនេះ អ្នកស៊ើបអង្កេតរបស់ ICAC ត្រូវដាក់ពាក្យសុំនេះ ទៅនាយកដ្ឋានច្បាប់ដើម្បីពិនិត្យ។ បន្ទាប់មកទៀត ពាក្យសុំនេះត្រូវដាក់ជូនទៅនាយកប្រតិបត្តិនៃផ្នែកប្រតិបត្តិការយុទ្ធសាស្ត្រ មុននឹងដាក់ជូនទៅអាជ្ញាធរសមស្រប ។

ដើម្បីធ្វើការស៊ើបអង្កេតអ្វីមួយ គណៈកម្មការនេះអាចបើកសវនាការ ដែលដឹកនាំដោយស្នងការ ឬជំនួយការស្នងការ តាមការសម្រេចរបស់ស្នងការ (ច្បាប់ ICAC អនុផ្នែក ៣០ [1-2]) ។ សវនាការអាចធ្វើជាសាធារណៈ ជាឯកជន ឬរួមគ្នាទាំង ២ (ច្បាប់ ICAC អនុផ្នែក ៣១ [1]) ។ សវនាការសាធារណៈត្រូវបានគេយល់ឃើញថាជាឧបករណ៍សំខាន់ក្នុងការបង្ហាញជូនសាធារណជនអំពីអំពើពុករលួយ និងអាចប្រើសម្រាប់បង្កើនការទុកចិត្តពីសាធារណជន ទៅលើសុចរិតភាពនៃការស៊ើបអង្កេត។ ក្នុងការធ្វើសវនាការ គណៈកម្មការនេះមានសិទ្ធិកោះហៅសាក្សី (ច្បាប់ ICAC អនុផ្នែក ៣៥ [1]) ។ ប្រសិនបើសាក្សីដែលត្រូវបានកោះហៅ មិនបានចូលមកទេនោះគណៈកម្មការអាចចេញដីកាចាប់ខ្លួនសាក្សីបាន ( បទបញ្ញត្តិ ICAC អនុផ្នែក ៣៦ [1]) ។

គណៈកម្មការនេះបានអនុម័ត**ក្រមសីលធម៌របស់ ICAC** ដែលដាក់ចេញនូវគោលការណ៍ដែលថា បុគ្គលិក ICAC ត្រូវបានគេរំពឹងថានឹងទ្រទ្រង់ ហើយនិងប្រព្រឹត្តតាមការប្រតិបត្តិជាក់លាក់ក្នុងវិស័យនានា ដែលចាត់ទុកថាជាស្នូលនៃមុខងាររបស់ ICAC។ ពាក្យបណ្តឹងអំពីការប្រព្រឹត្តិរបស់បុគ្គលិក ICAC ត្រូវបានយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ និងត្រូវបានស៊ើបអង្កេតដោយសមាជិកមួយរូបពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់ ICAC។ ការស៊ើបអង្កេត និងចំណាត់ដែលស្នើឡើង នឹងត្រូវពិនិត្យដោយស្នងការ។ ក្នុងករណីណាដែលធ្ងន់ធ្ងរមែនទែន អ្នកស៊ើបអង្កេតមកពីខាងក្រៅ ICAC អាចត្រូវអញ្ជើញឱ្យមកធ្វើការស៊ើបអង្កេតបាន ប៉ុន្តែត្រូវរាយការណ៍ជូន**គណៈកម្មការពិនិត្យលើការប្រតិបត្តិ (ORC)** ។

ដើម្បីលើកកម្ពស់តម្លាភាព កិច្ចការរដ្ឋបាល ការស្រាវជ្រាវ និងការអប់រំរបស់ ICAC ត្រូវគ្របដណ្តប់ដោយច្បាប់ស្តីពី*សេរីភាពនៃព័ត៌មាន*។

## ការរៀបចំកិច្ចប្រតិបត្តិការ

ដូចដែលបានលើកឡើងខាងលើ ក្របខ័ណ្ឌការងារត្រូវបានបង្កើតឡើងដើម្បីធានាឱ្យមានការទទួលខុសត្រូវរបស់ ICAC ជូនចំពោះសាធារណជននៃរដ្ឋញូសៅវែលព្រមទាំងរក្សាតម្លាភាពរបស់ខ្លួន។ ប្រការនេះមានសារៈសំខាន់ ជាពិសេសណាស់ បើគិតទៅដល់អំណាចដ៏ទូលំទូលាយ ដែលច្បាប់ ICAC បានផ្តល់ឱ្យគណៈកម្មការនេះ។ បន្ថែមទៅលើស្ថាប័នដែលបានរៀបរាប់ខាងលើនេះ មានស្ថាប័នត្រួតពិនិត្យសំខាន់ ២ ទៀត គឺ: **គណៈកម្មការពិនិត្យលើការប្រតិបត្តិ (ORC)** និង **គណៈកម្មការសភារួមស្តីពី ICAC (PJC)** ។

គណៈកម្មការពិនិត្យលើការប្រតិបត្តិ (ORC) ត្រូវបានបង្កើតឡើងក្រោមផ្នែក ៥៨ នៃច្បាប់ ICAC ដើម្បីផ្តល់យន្តការមួយដែលអាចធានាថា ICAC អាចដោះស្រាយដោយសមស្របចំពោះពាក្យបណ្តឹងដែលទទួលបានពីសាធារណជន។ តួនាទីរបស់ ORC គឺ: ផ្តល់ការណែនាំដល់ស្នងការ ថាតើ ICAC ត្រូវស៊ើបអង្កេតពាក្យបណ្តឹងក្រោមច្បាប់ ICAC ដែរឬទេ ត្រូវផ្អាកការស៊ើបអង្កេតលើពាក្យបណ្តឹងនោះ និងត្រូវផ្តល់ការណែនាំដល់ស្នងការស្តីពីបញ្ហាផ្សេងៗ ដែលជួនកាល ស្នងការលើកយកមកស្នើសុំយោបល់ពី ORC (ច្បាប់ ICAC អនុផ្នែក ៥៩ [1])។ ដោយអនុលោមតាមអនុផ្នែក ៦០ (១) នៃច្បាប់ ICAC គណៈកម្មការពិនិត្យលើការប្រតិបត្តិ (ORC) ត្រូវមានសមាជិក ៨ រូបគឺ ស្នងការមួយរូបជាប្រធាន ជំនួយការស្នងការមួយរូប ដែលបានស្នើឡើងដោយស្នងការ ស្នងការប៉ូលីសមួយរូបដែលត្រូវបានតែងតាំងដោយអភិបាលរដ្ឋ តាមអនុសាសន៍របស់អគ្គមេធាវី ដោយមានការសម្របសម្រួលជាមួយស្នងការ និងមនុស្ស ៤នាក់ទៀត ដែលតែងតាំងដោយអភិបាល តាមអនុសាសន៍របស់រដ្ឋមន្ត្រី ដោយមានការសម្របសម្រួលជាមួយស្នងការដើម្បីតំណាងឱ្យទស្សនៈរបស់សហគមន៍ ។

ផ្នែក ៦៣ នៃច្បាប់ ICAC ចែងពីការបង្កើតគណៈកម្មការសភារួម **(PJC)** ។ តួនាទីរបស់ PJC ដូចដែលបានចែងក្នុងអនុផ្នែក ៦៤ (១) នៃច្បាប់ ICAC គឺ:

- សង្កេតការ និងពិនិត្យលើគណៈកម្មការ ក្នុងការអនុវត្តមុខងាររបស់ខ្លួន។
- រាយការណ៍ជូនសភាទាំងពីរ ដោយមានជូនយោបល់សមស្របអំពីបញ្ហាដែលទាក់ទងនឹង ICAC ឬ ទាក់ទងទៅនឹងការបំពេញមុខងាររបស់ខ្លួនដែលខ្លួនយល់ឃើញថាសភាគួរតែយកចិត្តទុកដាក់។
- ពិនិត្យសាកសួរលើរបាយការណ៍ប្រចាំឆ្នាំនីមួយៗ និងពិនិត្យលើរបាយការណ៍ផ្សេងទៀតរបស់គណៈកម្មការ ហើយរាយការណ៍ជូនសភាទាំងពីរនូវរាល់បញ្ហាដែលកើតមាននៅក្នុង ឬដែលបានលេចចេញពីរបាយការណ៍ទាំងនោះ (ជាទូទៅការពិនិត្យសាកសួរនេះធ្វើឡើងជាបែបសវនាការនៅចំពោះមុខ PJC)។
- ពិនិត្យទៅលើនិន្នាការ និងការផ្លាស់ប្តូរក្នុងការប្រព្រឹត្តិអំពើពុករលួយព្រមទាំងការអនុវត្ត និងវិធីសាស្ត្រ ដែលទាក់ទងទៅនឹងការប្រព្រឹត្តិអំពើពុករលួយ ហើយនិងរាយការណ៍ជូនសភាទាំងពីរនូវការផ្លាស់ប្តូរនានាដែល PJC គិតថាជាការចាំបាច់សម្រាប់ការងារវចនាសម្ព័ន្ធ និងនីតិវិធីរបស់គណៈកម្មការ។
- សួរសំណួរណាដែលសភាទាំងពីរបានលើកឡើងទាក់ទងនឹងការងាររបស់គណៈកម្មការ ហើយរាយការណ៍ជូនសភាទាំងពីរវិញស្តីពីសំណួរនោះ។

ដូចដែលបានលើកឡើងខាងលើ គណៈកម្មការសភារួម (PJC) ក៏មានសិទ្ធិអំណាចបោះឆ្នោតបដិសេធសំណើតែងតាំងស្នងការសម្រាប់ ICAC ដែរ (ច្បាប់ ICAC, ផ្នែក ៦៤A)។ ទោះបីជាយ៉ាងនេះក៏ដោយ គណៈកម្មការសភារួម (PJC) អាចនឹងមិនធ្វើការស៊ើបអង្កេតទៅលើបញ្ហាណាមួយដែលទាក់ទងនឹងការប្រព្រឹត្តិរបស់ ICAC ឬពិចារណាឡើងវិញលើសេចក្តីសម្រេចដើម្បីស៊ើបអង្កេត ឬមិនស៊ើបអង្កេត ឬបញ្ឈប់ការស៊ើបអង្កេតលើពាក្យបណ្តឹងណាមួយ ឬពិចារណាឡើងវិញលើការរកឃើញ អនុសាសន៍ ការប្តេជ្ញា ឬ ការសម្រេចផ្សេងទៀតរបស់ ICAC ទាក់ទងទៅនឹងការស៊ើបអង្កេត ឬពាក្យបណ្តឹងណាមួយ (ច្បាប់ ICAC អនុផ្នែក ៦៤ [2])។ ដោយអនុលោមតាមអនុផ្នែក ៦៥(១) នៃច្បាប់ ICAC គណៈកម្មការសភារួម (PJC) ត្រូវមានសមាជិក ១១រូប គឺ ៣រូបជាសមាជិកក្រុមប្រឹក្សានីតិបញ្ញត្តិ ហើយត្រូវតែងតាំងដោយក្រុមប្រឹក្សានីតិបញ្ញត្តិ ៨រូបទៀត ជាសមាជិកសភានីតិបញ្ញត្តិ ហើយត្រូវតែងតាំងដោយសភានីតិបញ្ញត្តិ។ ប្រធាន និងអនុប្រធានរបស់ PJC ត្រូវគេជ្រើសរើសដោយបោះឆ្នោតក្នុងចំណោមសមាជិក PJC (ច្បាប់ ICAC អនុផ្នែក ៦៧ [1])។

**តុលាការកំពូល**មានដែនសមត្ថកិច្ចក្នុងវិស័យ**រដ្ឋធម្មនុញ្ញ** និងវិស័យច្បាប់ សម្រាប់គ្រប់គ្រងទៅលើដំណើរការនៃការជំនុំជំរះផ្នែករដ្ឋបាល ដូចជាកិច្ចការរបស់គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ ICACជាដើម ដើម្បីធានាថាICACនេះ ពិតជាធ្វើការដោយគោរពតាមច្បាប់ ។

ដោយអនុលោមតាមអនុផ្នែក ១៦[១] នៃច្បាប់ ICAC នៅពេលធ្វើការស៊ើបអង្កេត គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ត្រូវតែសហការឱ្យបានច្រើនជាមួយ**ទីភ្នាក់ងារអនុវត្តន៍ច្បាប់** ព្រមទាំងទីភ្នាក់ងារផ្សេងទៀត ដូចជា **អគ្គសវនករ** និង**មន្ត្រីការពារប្រជាពលរដ្ឋ** (Ombudsman) ។ កិច្ចសហការនេះ រួមទាំងការតែងតាំងសមាជិកនៃកម្លាំងប៉ូលីសទៅក្នុង ICAC ដោយអនុលោមតាមបទបញ្ញត្តិនៃអនុផ្នែក ១០៤[៥] នៃច្បាប់ ICAC ។ មុននឹងឬបន្ទាប់ពីធ្វើការស៊ើបអង្កេតបញ្ហាណាមួយ ICAC ក៏អាចបញ្ជូនបញ្ហាស៊ើបអង្កេតនេះឬសកម្មភាពផ្សេងទៀតទៅឱ្យ "ជនណាឬស្ថាប័នណា ដែលគណៈកម្មការយល់ថាសមស្របតាមកាលៈទេសៈ" (ច្បាប់ ICAC អនុផ្នែក ៥៣[១]) ។

តួនាទីរបស់ ICAC គឺត្រូវប្រមូលភស្តុតាង ដែលបើកផ្លូវឱ្យនាំខ្លួនជនណាម្នាក់យកទៅកាត់ទោសពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងច្បាប់របស់រដ្ឋ NSW និងបញ្ជូនភស្តុតាងទាំងនេះទៅជូន**នាយកអយ្យការសាធារណៈ** ។ ពេលណាមានភស្តុតាងគ្រប់គ្រាន់ហើយ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) នឹងផ្តល់អនុសាសន៍ជូននាយកអយ្យការសាធារណៈ សុំឱ្យពិចារណាដល់ការរៀបចំសំណុំរឿង ដើម្បីប្តឹងចោទពីបទព្រហ្មទណ្ឌលើជនណាម្នាក់ ឬផ្តល់អនុសាសន៍ដល់អាជ្ញាធរត្រួតពិនិត្យ (ប្រធានស្ថាប័ន) សុំឱ្យចាត់វិធានការដាក់វិន័យលើមន្ត្រីណាម្នាក់ ។ បន្ទាប់មក នាយកអយ្យការសាធារណៈ ឬប្រធានស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធ ត្រូវពិចារណាថាតើការកាត់ទោស ឬវិធានការដាក់វិន័យមានលក្ខណៈសមស្របដែរទេ ។

នាយកអយ្យការសាធារណៈ ដែលបានតែងតាំងដោយអភិបាលរដ្ឋ (តាមច្បាប់ DPP, អនុផ្នែក ៤[១]) តាមការឯកភាពពីគណៈកម្មការសភារួម PJC ដែលទទួលបន្ទុកផ្នែកការិយាល័យការពារប្រជាពលរដ្ឋ (Ombudsman) និងទទួលបន្ទុកផ្នែកគណៈកម្មការប៉ូលីសសច្ចធម៌ (តាមបទបញ្ញត្តិ DPP, អនុផ្នែក ៤A[1]) – គឺជាប្រធាននៃ**ការិយាល័យនាយកអយ្យការសាធារណៈ (ODPP)** ។ ឯករាជភាពរបស់នាយក ត្រូវបានចែងនៅក្នុងច្បាប់ DPP ដែលចែងថា ទោះជានាយកទទួលខុសត្រូវចំពោះអគ្គមេធាវី ក្នុងការបំពេញមុខងាររបស់នាយកក្រោមបញ្ញត្តិច្បាប់នេះក្តី នាយកមានឯករាជភាពក្នុងកិច្ចការដែលទាក់ទងទៅនឹងការរៀបចំដំណើរការ មានឯករាជភាពក្នុងការបង្កើតបែបបទសម្រាប់ដាក់ឱ្យដំណើរការ និងឯករាជ្យក្នុងការអនុវត្តដំណើរការ (អនុផ្នែក ៤[៣]) ។ អនុលោមតាមអនុផ្នែក ៧[១] នៃច្បាប់ DPP, នាយកមានភារកិច្ចបង្កើតបែបបទនៃបណ្តឹងអាជ្ញា និងធ្វើបណ្តឹងអាជ្ញាលើបទល្មើសដែលអាចចោទប្រកាន់បានក្រោមច្បាប់រដ្ឋញូសៅវែលទៅតុលាការកំពូល និងតុលាការថ្នាក់ស្រុក ។ នេះបានន័យថា គឺនាយកដែលជាអ្នកសម្រេចថា តើត្រូវធ្វើឬមិនត្រូវធ្វើបណ្តឹងអាជ្ញា ។ នៅក្នុងការិយាល័យនាយកអយ្យការសាធារណៈ ODPP អង្គភាពពិសេសមួយត្រូវបានបង្កើតឡើង គឺ**ក្រុម៦** ដែលធ្វើបណ្តឹងអាជ្ញាលើមន្ត្រីប៉ូលីស និងធ្វើបណ្តឹងអាជ្ញាលើបញ្ហាដែលគណៈកម្មការប៉ូលីសសច្ចធម៌ PIC និងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) បានលើកឡើងជូនការិយាល័យនាយកអយ្យការសាធារណៈ ODPP ព្រមទាំងធ្វើបណ្តឹងអាជ្ញាលើបញ្ហាសំខាន់ៗផ្សេងទៀត ។

យោងទៅតាមអនុផ្នែក ១២៩[1] នៃច្បាប់ស្តីពីគណៈកម្មការប៉ូលីសសច្ចធម៌ PIC គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) មិនអាចស៊ើបអង្កេត ឬដោះស្រាយចំពោះបញ្ហាទាក់ទងនឹងការប្រព្រឹត្តិរបស់មន្ត្រីប៉ូលីសទេ ប្រសិនបើបញ្ហានោះមិនមានការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិរបស់មន្ត្រីសាធារណៈដែលមិនមែនជាមន្ត្រីប៉ូលីស ។ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ត្រូវបញ្ជូនពាក្យបណ្តឹងទាំងអស់ដែលខ្លួនបានទទួល ទៅជូនការិយាល័យការពារពលរដ្ឋ (Ombudsman) ទោះជារឿងនេះមានឬមិនការចូលរួមពីមន្ត្រីសាធារណៈផ្សេងទៀតក៏ដោយ ។ ក៏ប៉ុន្តែ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) អាចបញ្ជូនពាក្យបណ្តឹងទាំងនេះទៅ គណៈកម្មការប៉ូលីសសច្ចធម៌ PIC ប្រសិនបើ ICAC យល់ថា ពាក្យបណ្តឹងទាំងនេះទាក់ទងទៅនឹងការប្រព្រឹត្តិមិនត្រឹមត្រូវដ៏ធ្ងន់ធ្ងររបស់មន្ត្រីប៉ូលីស ។ ដោយអនុលោមតាមផ្នែកនេះ ពាក្យបណ្តឹងណាដែលបានបញ្ជូនដល់ការិយាល័យការពារពលរដ្ឋ (Ombudsman) ត្រូវបញ្ជូនទៅឱ្យគណៈកម្មការ ប៉ូលីសសច្ចធម៌ PIC ប្រសិនបើ Ombudsman យល់ថា ពាក្យបណ្តឹងឬបញ្ហានេះមានការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិមិនត្រឹមត្រូវដ៏ធ្ងន់ធ្ងររបស់មន្ត្រីប៉ូលីស (ច្បាប់ PIC ផ្នែក ១២៨) ។

**គណៈកម្មការប៉ូលីសសច្ចធម៌ (PIC)** គឺជាទីភ្នាក់ងារឯករាជ្យដែលបានបង្កើតឡើងដោយគុណតម្លៃនៃអនុផ្នែក ៦(១) នៃច្បាប់ PIC។ គណៈកម្មការនេះដឹកនាំដោយស្នងការ ១រូប ដែលតែងតាំងដោយអភិបាលរដ្ឋ (ច្បាប់ PIC, អនុផ្នែក ៧[1])។ គណៈកម្មការនេះមិនអាចតែងតាំងបុគ្គលិកណាម្នាក់ដែលកំពុងបម្រើការ ឬធ្លាប់បានបម្រើការក្នុងកងកម្លាំងប៉ូលីសញ៉ូសៅវ៉ែលទេ។ **គណៈកម្មការសភារួម (PJC)** ដែលទទួលបន្ទុកការិយាល័យ Ombudsman និង**គណៈកម្មការប៉ូលីសសច្ចធម៌** សង្កេតការ និង ពិនិត្យសារឡើងវិញលើការបំពេញភារកិច្ចរបស់**គណៈកម្មការប៉ូលីសសច្ចធម៌** PIC (ច្បាប់ PIC, ផ្នែក ៩៥)។ គណៈកម្មការប៉ូលីសសច្ចធម៌ PIC នេះត្រូវរាយការណ៍ពីកិច្ចប្រតិបត្តិការរបស់ខ្លួនជារៀងរាល់ឆ្នាំទៅជូនសភាជាតិ (ច្បាប់ PIC, អនុផ្នែក ៩៥[១])។ យោងតាមអនុផ្នែក ១៣[១] នៃច្បាប់ PIC មុខងារសំខាន់ៗរបស់គណៈកម្មការនេះ គឺ:

- ទប់ស្កាត់ការប្រព្រឹត្តិខុសដ៏ធ្ងន់ធ្ងររបស់ប៉ូលីស និងការប្រព្រឹត្តិមិនត្រឹមត្រូវឯទៀតរបស់ប៉ូលីស។
- រុករក ឬស៊ើបអង្កេត ឬចាត់ចែងទីភ្នាក់ងារដទៃទៀត ក្នុងការរុករក ឬស៊ើបអង្កេតចំពោះការប្រព្រឹត្តិខុសដ៏ធ្ងន់ធ្ងររបស់ប៉ូលីស និង
- រុករក ឬស៊ើបអង្កេត ឬពិនិត្យទៅលើភ្នាក់ងារផ្សេងទៀត ក្នុងការរុករក ឬស៊ើបអង្កេតចំពោះការប្រព្រឹត្តិមិនត្រឹមត្រូវផ្សេងទៀតរបស់ប៉ូលីស ដែលគណៈកម្មការប៉ូលីសសច្ចធម៌ PIC យល់ថាសមស្រប។

គណៈកម្មការប៉ូលីសសច្ចធម៌ PIC មានអំណាចទូលំទូលាយស្រដៀងគ្នាទៅនឹង ICAC ដែរ ក្នុងការស៊ើបអង្កេតការប្រព្រឹត្តិមិនត្រឹមត្រូវ ឬអំពើពុករលួយរបស់ប៉ូលីស ។

**ការិយាល័យសវនកម្មញ៉ូសៅវ៉ែល**ដែលបង្កើតឡើងដោយគុណតម្លៃនៃផ្នែក ៣៣A[១] នៃច្បាប់ PFA ដឹកនាំដោយ**អគ្គសវនករ** ដែលត្រូវបានតែងតាំងដោយអភិបាលរដ្ឋ ក្នុងអាណត្តិមួយដែលមិនអាចបន្តថ្មីបាន សម្រាប់រយៈពេល ៧ឆ្នាំ (ច្បាប់ PFA, អនុផ្នែក ២៨[១]) តាមការឯកភាពរបស់**គណៈកម្មាធិការគណនេយ្យសាធារណៈ** (PFA Act អនុផ្នែក ២៨A[១]) ។ ការិយាល័យសវនកម្មផ្តល់ឱវាទជូនសភា រដ្ឋាភិបាល និងទីភ្នាក់ងារសាធារណៈអំពីការបំពេញការងារក្នុងវិស័យសាធារណៈ។ តាមបញ្ញត្តិច្បាប់របស់ PFA និងតាមច្បាប់រដ្ឋញ៉ូសៅវ៉ែល ការិយាល័យសវនកម្មនេះត្រូវធ្វើសវនកម្មផងដែរ ហើយអាចនឹងធ្វើសវនកម្មទៅលើគ្រប់សកម្មភាពទាំងអស់របស់អាជ្ញាធរសាធារណៈពាក់ព័ន្ធនឹងប្រសិទ្ធភាពសេដ្ឋកិច្ច និងការប្រតិបត្តិតាមច្បាប់ដែលពាក់ព័ន្ធ។ ចំពោះភារកិច្ចបែបនេះ ការិយាល័យសវនកម្មក៏ត្រូវពិនិត្យឡើងវិញផងដែរ លើឯកសារហិរញ្ញវត្ថុនានារបស់គណៈកម្មការ ICAC ដែលមាននៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន។ គណៈកម្មការ ICAC ក៏ត្រូវសហការជាមួយការិយាល័យសវនកម្ម ដើម្បីផ្តល់ឱ្យគណៈកម្មការនេះ នូវមុខងារសវនកម្មផ្ទៃក្នុង។

**ការិយាល័យការពារប្រជាពលរដ្ឋ (Ombudsman)** ត្រូវបានបង្កើតឡើងក្នុងពេលមានការតែងតាំង Ombudsman ទីមួយនៅក្នុងឆ្នាំ ១៩៧៥ ដោយអនុលោមតាមអនុផ្នែក ៦[១] នៃច្បាប់ស្តីពី Ombudsman ដែលចែងថា អភិបាលរដ្ឋអាចតែងតាំង Ombudsman ម្នាក់ តាមអនុសាសន៍របស់រដ្ឋមន្ត្រីបន្ទាប់ពីមានការអនុម័ត យល់ព្រមរបស់គណៈកម្មការសភារួម PJC ដែលទទួលបន្ទុកការិយាល័យ Ombudsman និងគណៈកម្មការ ប៉ូលីសសច្ចធម៌ (ច្បាប់ Ombudsman, ផ្នែក ៣១BA)។ គណៈកម្មាធិការសភារួម PJC ក៏ឃ្លាំមើល និងពិនិត្យឡើងវិញផង ដែរលើ Ombudsman ក្នុងការអនុវត្តមុខងាររបស់ខ្លួន (ច្បាប់ Ombudsman ផ្នែក ៣១B)។ យោងតាមផ្នែក ៣៣ នៃច្បាប់ Ombudsman, Ombudsman ត្រូវដាក់ជូនប្រធានសភានីមួយៗ នូវរបាយការណ៍ប្រចាំឆ្នាំស្តីពីកិច្ចប្រតិបត្តិការរបស់ខ្លួន ។ តួនាទីចម្បងរបស់ Ombudsman គឺដើរតួជាស្ថាប័នពិនិត្យឯករាជ្យមួយ។ ក្នុងន័យនេះ Ombudsman មានតួនាទីត្រូវអនុវត្ត:

- ការពិនិត្យឡើងវិញផ្នែករដ្ឋបាល ដោយរួមទាំងដោះស្រាយពាក្យបណ្តឹងអំពីការប្រព្រឹត្តិផ្នែករដ្ឋបាលរបស់ទីភ្នាក់ងារសាធារណៈ និងមន្ត្រីសាធារណៈ ហើយនិងការប្រព្រឹត្តិរបស់ស្ថាប័នសមមូល និងមនុស្សនានា។
- ការពិនិត្យឡើងវិញលើការប្រតិបត្តិតាមច្បាប់ ដែលរួមមាន:
    - ពិនិត្យឡើងវិញលើការគោរពច្បាប់ និងតាមដានការអនុវត្តល្អ ឧ. ការគោរពតាមនីតិវិធីសមធម៌ និងការអនុវត្តល្អ ក្នុងការស៊ើបអង្កេត ការប្រើប្រាស់អំណាចប៉ូលីស ត្រួតពិនិត្យប្រតិបត្តិការ សវនកម្មលើឯកសារចាប់សម្លេងទូរគមនាគមន៍។

- ពិនិត្យឡើងវិញលើការចាត់ចែង និងការឆ្លើយតបចំពោះការចោទប្រកាន់ និងពាក្យបណ្ដឹង
- ពិនិត្យឡើងវិញលើស្តង់ដារនៃការផ្តល់សេវាកម្ម

- ពិនិត្យឡើងវិញលើនីតិបញ្ញត្តិ គឺថាពិនិត្យលើការអនុវត្តបទបញ្ញត្តិមួយចំនួន ដែលពង្រីកអំណាចឱ្យប៉ូលីស និងបុគ្គលិកមន្ទីរឃុំឃាំង ។

មន្ត្រីការពារប្រជាពលរដ្ឋ Ombudsman អាចផ្តួចផ្តើមការស៊ើបអង្កេតលើករណីផ្សេងៗ ទោះជាមានពាក្យបណ្តឹង ឬមិនមានក៏ដោយ (ច្បាប់ Ombudsman អនុផ្នែក ១៣[១]) ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ គួរកត់សម្គាល់ថា Ombudsman មិនមានអំណាចបង្ខំឱ្យគេគោរព តាមអនុសាសន៍ដែលខ្លួនលើកឡើងឡើយ ។

## មេរៀនដែលទទួលបាន

ស្ថានភាពចម្បងមួយក្នុងចំណោមស្ថានភាពរបស់ ICAC គឺអត្ថិភាពនៃក្របខ័ណ្ឌការងារដ៏ទូលំទូលាយទាំងខាងក្នុង និងខាងក្រៅ សម្រាប់ធានាការទទួលខុសត្រូវ និងតម្លាភាពរបស់គណៈកម្មការ ។ វិធានការទាំងនេះសំខាន់ណាស់សម្រាប់ឱ្យសាធារណជនយល់ឃើញថា គណៈកម្មការពិតជាអញ្ចឹងមែន ពោលគឺមានការទទួលខុសត្រូវ និងមានតម្លាភាព ។ ប្រការនេះមានសារៈសំខាន់ពិសេសណាស់ ពីព្រោះដូចមានចែងនៅក្នុងរបាយការណ៍ពីមុនមួយរបស់គណៈកម្មការ ICAC គឺថា ជោគជ័យជាច្រើនរបស់គណៈកម្មការ ICAC គឺជាលទ្ធផលនៃការជួយ និងការផ្តល់ព័ត៌មានពីសំណាក់សាធារណជន ហើយក៏មានចែងដែរថាគណៈកម្មការ ICAC មិនអាចបំពេញការងារខ្លួនដោយមិនមានជំនួយ ឬការគាំទ្រពីសាធារណៈជននោះទេ (ICAC ១៩៩១:១៧-១៨) ។

វិធីសាស្ត្រ ៣ មុខព្រួញសម្រាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះសម្រាប់ជោគជ័យរបស់គណៈកម្មការ ICAC ក្នុងការដោះស្រាយបញ្ហានៃអំពើពុករលួយនៅក្នុងវិស័យសាធារណៈ ។ មេរៀនមួយដែលគណៈកម្មការរៀនសូត្រទទួលបានគឺថា ការយកចិត្តទុកដាក់ទៅលើប្រព័ន្ធ និងវប្បធម៌រៀបចំស្ថាប័ន មានប្រសិទ្ធភាពជាងការផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហានីមួយៗដោយឡែកពីគ្នា ។ ការស៊ើបអង្កេតតែលើបទចោទប្រកាន់នីមួយៗដោយឡែកៗពីគ្នាមិនគ្រប់គ្រាន់ទេ ។ ការទប់ស្កាត់បានបង្ហាញជាក់ច្បាស់ថាជាផ្នែកសំខាន់មួយក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយដោយសង្កត់ធ្ងន់បន្ថែមទៅលើសារៈសំខាន់នៃការយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរជាប្រព័ន្ធ និងជាស្ថាប័ន (Gorta ១៩៩៩) ។

ផ្នែកមួយនៃជោគជ័យរបស់គណៈកម្មការ ICAC គឺកិច្ចសហការជាមួយទីភ្នាក់ងារផ្សេងៗទៀត ។ ទោះជាមានធនធានច្រើនយ៉ាងណាក៏ដោយក៏គ្មានទីភ្នាក់ងារណាមួយអាចដោះស្រាយបញ្ហាអំពើពុករលួយដោយប្រសិទ្ធភាពតែឯកឯងបានឡើយ ។ ដើម្បីធានាឱ្យវិស័យសាធារណៈមួយរួចផុតអំពីអំពើពុករលួយ ត្រូវតែមានការទទួលខុសត្រូវរួមគ្នា ។ លើសពីនេះទៀត វប្បធម៌ក្នុងស្ថាប័នមិនអាចគ្រប់គ្រងបានពីខាងក្រៅនោះទេ ហើយវាបានបង្ហាញឱ្យឃើញច្បាស់ថា អ្នកគ្រប់គ្រងវិស័យសាធារណៈចាំបាច់ត្រូវទទួលខុសត្រូវដោយខ្លួនឯង ចំពោះវិស័យសច្ចធម៌នៅកន្លែងធ្វើការរបស់ខ្លួន ។ ទាក់ទងទៅនឹងបញ្ហានេះ សារៈសំខាន់គឺការតាមឃ្លាំមើលលទ្ធផល ។ គេបានរកឃើញថា ការវាស់ស្ទង់លើការចាត់ចែងវិធានការទប់ស្កាត់ គឺមានសារៈសំខាន់ណាស់ ហើយគេក៏បានរកឃើញដែរថា ប្រសិនបើមានការតាមដានឃ្លាំមើល នោះវិធានការ ហើយនិងអនុសាសន៍នានាទំនងជាត្រូវបានអនុវត្តច្រើន (Gorta ១៩៩៩) ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) បានយល់ឃើញតាំងតែពីតំណាក់កាលដំបូងថា ជាចាំបាច់ត្រូវមានទិន្នន័យសមស្រប ដើម្បីអនុវត្តការវិភាគ និងការវាយតម្លៃលើហានិភ័យ ។ អតីតស្នងការរបស់ ICAC ម្នាក់មានមតិថា ការដាក់សមត្ថភាពស្រាវជ្រាវឱ្យសមស្រប ឱ្យមានប្រសិទ្ធភាព និងមានភាពស័ក្តិសិទ្ធិបំផុត គឺត្រូវដាក់នៅក្នុងទីភ្នាក់ងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះតែម្តង ។ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ក៏ត្រូវពង្រីកនូវសមត្ថភាពស្រាវជ្រាវរបស់ខ្លួនឱ្យទូលំទូលាយឡើង ។ ផ្នែកស្រាវជ្រាវនេះបានផ្តល់ឱ្យ ICAC នូវទិន្នន័យដ៏មានតម្លៃ ដែលត្រូវបានគេមើលឃើញថាបានជួយមួយផ្នែកធំក្នុងការបែងចែកធនធានទៅតំបន់នៃការស៊ើបអង្កេតសកម្ម ព្រមទាំងណែនាំដល់ការបែងចែកធនធានចំពោះវិធានការទប់ស្កាត់អំពើពុករលួយ (O'Keefe ២០០២:៩) ។

គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ក៏បានធ្វើការអង្កេតមួយទៅលើទស្សនៈរបស់និយោជិកក្នុងវិស័យសាធារណៈ ព្រោះគណៈកម្មាការនេះចាត់ទុកថា អកប្បកិរិយាចំពោះអំពើពុករលួយរបស់និយោជិក ឬនៅកន្លែងធ្វើការ មានភាពលេចធ្លោក្នុងការគ្រប់គ្រងឥរិយាបទជាជាងការកំណត់និយមន័យជាផ្លូវការ ហើយនិយោជិកស្ថិតនៅក្នុងជំហរល្អបំផុតក្នុងការសង្កេត និងឆ្លើយតបចំពោះសក្ដានុពលនៃការប្រព្រឹត្តិអំពើពុករលួយ ដែលអាចកើតឡើងនៅកន្លែងធ្វើការរបស់ខ្លួន។ ដូច្នេះ សារៈសំខាន់គឺត្រូវជំរុញការយល់ដឹងជាទូទៅ អំពីប្រការដែលនាំឱ្យមានឥរិយាបទប្រព្រឹត្តអំពើពុករលួយ (Gorta ១៩៩៩) ។

សិទ្ធិអំណាចរបស់ ICAC ក្នុងការបើកសវនាការជាសាធារណៈ ត្រូវបានអ្នកខ្លះមើលឃើញថាជាមធ្យោបាយប្រកបដោយប្រសិទ្ធភាពក្នុងការដាក់បង្ហាញនូវលំដាប់នៃការប្រព្រឹត្តិមិនត្រឹមត្រូវ ហើយគំនិតនៃការបើកសវនាការបែបនេះ គឺដើម្បីធ្វើឱ្យពួកអ្នកពាក់ព័ន្ធក្នុងសវនាការនេះមានការអៀនខ្មាស់ ដើម្បីឱ្យគេផ្លាស់ប្ដូររបៀបរស់នៅរបស់ពួកគេ។ វាក៏ជាឱកាសមួយដើម្បីលើកឡើង និងបង្ហាញនូវវិស័យនានាដែលត្រូវផ្លាស់ប្ដូរនីតិវិធី គោលនយោបាយ និងច្បាប់បញ្ញត្តិ ។ វាក៏ជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពសម្រាប់ជូនដំណឹងដល់សាធារណជន អំពីអ្វីដែលបានកើតឡើងពិតប្រាកដ ។ ក្នុងពេលសវនាការ គណកម្មការ ICAC អាចកោះហៅសាក្សីឱ្យចូលមកផ្ដល់ភស្តុតាង។ ប៉ុន្តែ ភស្តុតាងដែលសាក្សីផ្ដល់ជូន មិនអាចយកជាការបាននៅក្នុងតុលាការទេ ។ នេះជាទិដ្ឋភាពនៃសវនាការដែលត្រូវបានទទួលការរិះគន់យ៉ាងខ្លាំង ព្រោះបុគ្គលម្នាក់ៗពេលត្រូវបាននាំទៅកាន់តុលាការក្រោមបទចោទប្រកាន់អំពីអំពើពុករលួយ បាននិយាយអះអាងថា គេមិនបានទទួលការកាត់ក្ដីប្រកបដោយយុត្តិធមិទេ។ មានការជជែកវែកញែកថា យន្តការនេះអាចសមស្របសម្រាប់ប្រទេសដែលមានអំពើពុករលួយខ្លាំង ព្រោះវាជាឧបករណ៍ដែលអាចកំណត់បង្ហាញនូវវិស័យនានាដែលត្រូវកែទម្រង់ ទោះជាយន្តការនេះមានការអនុញ្ញាតឱ្យជនជាប់ចោទរួចខ្លួនក៏ដោយ (Hakes Drielsma ៥៥) ។

ទោះបីជាមតិសាធារណៈមានការជឿជាក់កាន់តែច្រើនឡើងថា អ្នកដែលបានរាយការណ៍ពីអំពើពុករលួយ នឹងមិនទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានក៏ដោយ ក៏នៅក្នុងការអង្កេតរបស់ ICAC មានអ្នកឆ្លើយតបចំនួន ៦០ភាគរយ ជឿថា អ្នកដែលបានរាយការណ៍ពីអំពើពុករលួយ ច្រើនតែត្រូវបានទទួលរងការឈឺចាប់ដោយសារការរាយការណ៍នោះ។ ទាក់ទងនឹងចំណុចនេះ អង្គការតម្លាភាពអន្តរជាតិ បានសង្កត់ធ្ងន់ថាក្របខ័ណ្ឌការងារផ្នែកច្បាប់នឹងត្រូវពង្រឹងបន្ថែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការទុកចិត្តពីសំណាក់សាធារណៈ (២០០៤:១៥៦) ។

ទោះបីជាគណកម្មការ ICAC ត្រូវបានគេមើលឃើញយ៉ាងទូលំទូលាយថា មានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងផ្នែកសាធារណៈក៏ដោយក៏នៅឆ្នាំ ១៩៩៦ គណៈកម្មការភូមិន្ទទទួលបន្ទុកកងកម្លាំងប៉ូលីសនៃរដ្ឋញូសៅវែលបានរកឃើញថា គណៈកម្មការ ICAC មិនទទួលបានជោគជ័យក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ឬការប្រព្រឹត្តិខុសរបស់កងកម្លាំងប៉ូលីស NSW ទេ។ ប្រការនេះ ត្រូវបានពន្យល់ខ្លះៗ នៅក្នុងផ្នែកនៃអាណត្តិការងាររបស់ ICAC ដែលចែងអំពីទីភ្នាក់ងារសាធារណៈ និងមន្ត្រីសាធារណៈទាំងអស់ រួមជាមួយនឹងការលើកឡើងអំពីកង្វះខាតបុគ្គលិក និងធនធានមានកម្រិត ។ កត្តាដែលកាន់តែស្មុគស្មាញថែមទៀត គឺការដែល ICAC ត្រូវពឹងផ្អែកទៅលើអ្នកស៊ើបអង្កេត ដែលខ្ចីពីកងកម្លាំងប៉ូលីស NSW ដែលអ្នកនោះក្រោយមកនឹងត្រូវវិលទៅកាន់កងកម្លាំងប៉ូលីសវិញ ព្រមទាំងការខ្វះនាយកដ្ឋានមួយច្បាស់លាស់នៅក្នុងគណៈកម្មការ ICAC ដែលមានសមត្ថកិច្ចដោះស្រាយបញ្ហានៃអំពើពុករលួយរបស់ប៉ូលីស។ គណៈកម្មការភូមិន្ទក៏បានរកឃើញដែរថា គណៈកម្មការ ICAC បានសង្កត់ធ្ងន់លើសកម្មភាពទប់ស្កាត់អំពើពុករលួយ និងការអប់រំ ច្រើនជាងតួនាទីស៊ើបអង្កេតរបស់ខ្លួន។ ការរកឃើញបានបណ្ដាលឱ្យគណៈកម្មការភូមិន្ទផ្ដល់អនុសាសន៍ឱ្យបង្កើតគណៈកម្មការប៉ូលីសសច្ចធមិឯករាជ្យ ដែលជាអនុសាសន៍មួយត្រូវបានអនុវត្តនៅក្នុងឆ្នាំ ១៩៩៧ (Wood ២០០៤) ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ យោងតាមរបាយការណ៍ស្ដីពីអំពើពុករលួយក្នុងពិភពលោកឆ្នាំ ២០០៣ របស់អង្គការតម្លាភាពអន្តរជាតិ អំពើពុករលួយនៅក្នុងកងកម្លាំងប៉ូលីសរដ្ឋញូសៅវែលនៅតែជាបញ្ហាដដែល (២០០៤:១១៧) ។

## ប្រភព


- Doig. A. and McIvor, S., ២០០៤, ប្រព័ន្ធសច្ចធមិជាតិ, របាយការណ៍សិក្សាអំពីប្រទេសរបស់ Transparency Internationalt, អូស្ត្រាលី២០០៤
  *http://transparency .org/activities/not_integ_systems/country_studies.htm/#austr*

- Gorta, A., ១៩៩៩ ប្រកាន់យកវិធីសាស្ត្រគួរឱ្យទុកចិត្តដើម្បីកាត់បន្ថយអំពើពុករលួយ ការបង្ហាញសម្រាប់វិទ្យាស្ថានសិក្សាអំពីឧក្រិដ្ឋកម្មអូស្ត្រាលី *http://www.aic.gov.au/conferences/occasionl/gorta.pdf*
- Hakes Drielsma, C., យុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយដ៏ជោគជ័យនៅទូទាំងពិភពលោក *http://www.loksatta.org/coruption %20chris%20report.pdf*
- ICAC, ១៩៩១ ពីរឆ្នាំដំបូងរបស់ព្យួរប្ជាសំខាន់ៗចំនួន ១៩ *http://www.icac.nsw.gov.au/files/pdf/pub2_2q.pdf*
- ICAC, ១៩៩៧ ប្រវត្តិសាស្ត្ររបស់ ICAC, *http://www.icac.nsw.gov.au/files/pdf/pub2_16q.pdf*
- ICAC, ២០០៣ អាកប្បកិរិយារបស់សហគមន៍ចំពោះអំពើពុករលួយនិង ICAC, *http://www.icac.nsw.gov.au/files/pdf/pub2_27r1.pdf*
- ICAC, ២០០៤ របាយការណ៍ប្រចាំឆ្នាំ ២០០៣-២០០៤ *http://www.icac.nsw.gov.au/files/pdf/ICAC_Annual_Report_03_043.pdf*
- O'Keefe, ២០០២ ជំរុញភាពស្អាតស្អំ និងការប្រឆាំងអំពើពុករលួយក្នុងសេវាសាធារណៈ ទស្សនៈវិស័យមួយដែលផ្អែកលើបទពិសោធជាស្ទួងការរបស់ ICAC, *http://www.oecd.org/dataoecd/44/11/2408954.pdf*
- Transparency International, ២០០១ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០១ *http://www.globalcorruptionreport.org/gcr2001.html*
- Transparency International, ២០០៣ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០៣ *http://www.globalcorruptionreport.org/gcr2003.html*
- Transparency International, ២០០៤ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០៤ *http://www.globalcorruptionreport.org/download.html*
- Wood, J., ២០០៤ គណៈកម្មការរ៉ូយ៉ាល់ស្តីពីភាពវិវឌ្ឍន៍ កងកម្លាំងប៉ូលីសញូវសៅវែល *www.isrcl.org/Papers/2004/Wood.pdf*


ព័ត៌មានក៏ត្រូវបានប្រមូលពីវេបសាយនៃស្ថាប័ននានាដែលបានរាយនាមខាងលើ ។

# ប្រទេសបូតស្វាណា



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- សភាអគ្គមេធាវី *www.gov.bw/government/attorney_generals_chambres.html*
- អគ្គនាយកដ្ឋានស្តីពីអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (DCEC) *www.gov.bw/government/directorate_on_corruption_and_economic_crime.html*
- ការិយាល័យអគ្គសវនករ (OAG) *www.gov.bw/government/office_of_auditor_general.html*
- ការិយាល័យ Ombudsman (មន្ត្រីការពារប្រជាពលរដ្ឋ) *www.gov.bw/government/ministry_of_state_president.html/#ombudsman*

## បទបញ្ញត្តិចម្បង

- ច្បាប់ស្តីពីអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (លេខ ១៣) ឆ្នាំ ១៩៩៤ (Act No.១៣)

## សារំតា

មិនមានគេដឹងច្បាស់តែសោះ ថាមានអំពើពុករលួយនៅក្នុងឆាកនយោបាយនៃប្រទេសបូតស្វាណា រហូតទាល់តែដល់ដើមទសវត្សរ៍ ១៩៩០ ហើយផ្នែកសេវាសាធារណៈបានអះអាងខ្លួនឯងថាមិនមានអំពើពុករលួយទេ ។ ប៉ុន្តែ នៅដើមទសវត្សរ៍ ១៩៩០ គេឃើញមានករណីជាច្រើនទាក់ទងទៅនឹងអំពើពុករលួយជាន់ខ្ពស់ ដែលគណៈកម្មការប្រធានាធិបតីបានរកឃើញជាបន្តបន្ទាប់គ្នាចំនួនបីដង (Frimpong ២០០១:១១) ។ ការរកឃើញនេះ បានធ្វើឱ្យរដ្ឋាភិបាលក្នុងឆ្នាំ ១៩៩៤ បង្កើតនូវអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (DCEC) នៅក្នុងការិយាល័យប្រធានាធិបតី ដោយអនុលោមតាមគុណតម្លៃនៃផ្នែក ៣(១) នៃច្បាប់លេខ ១៣។ ការសម្រេចបង្កើតអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC នេះជាលទ្ធផលនៃការពិនិត្យឡើងវិញរបស់រដ្ឋាភិបាលលើវិធីសាស្ត្រផ្សេងៗដែលបានអនុវត្តឆ្ពោះទៅរកការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅទូទាំងពិភពលោក។ គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយនៅទីក្រុងហុងកុង និងវិធីសាស្ត្រ ៣មុខព្រួញ[១] ស្តីពីអំពើពុករលួយត្រូវបានមើលឃើញថាជាប្រយោជន៍ពិសេស ហើយអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC ក៏បានអនុម័តលើវិធីសាស្ត្រស្រដៀងគ្នានេះដែរ ដោយផ្តោតទៅលើការស៊ើបអង្កេត ការទប់ស្កាត់ និងការអប់រំសាធារណជន ។

តាំងពីចាប់កំណើតមក អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC បានទទួលរបាយការណ៍កាន់តែច្រើនឡើង ស្តីពីការសង្ស័យថាមានអំពើពុករលួយ ឬការចោទប្រកាន់ថាមានអំពើពុករលួយ។ ក្នុងឆ្នាំ ២០០១ DCEC បានទទួលរបាយការណ៍ ស្តីពីអំពើពុករលួយចំនួន ១.៨៤១ ករណី ដែលកើនឡើង ២៤.៨ភាគរយពីឆ្នាំមុន ហើយចំនួននៃការស៊ើបអង្កេតដែលកើតឡើងពីរបាយការណ៍ទាំងនេះ

[១] សម្រាប់ព័ត៌មានបន្ថែមស្តីពី ICAC និងការរៀបចំស្ថាប័នឱ្យមាននៅនឹងកន្លែងដើម្បីប្រឆាំងនឹងអំពើពុករលួយនៅក្រុងហុងកុង សូមមើលព័ត៌មានសង្ខេបស្តីពីក្រុង Hong Kong S.A.R ។

កើនឡើងចំនួន ៦ភាគរយច្រើនជាងឆ្នាំមុន (DCEC ២០០២:១៨)។ ដើម្បីដោះស្រាយចំពោះបន្ទុកការងារដ៏ធ្ងន់ធ្ងរនេះ DCEC បានបង្កើតប្រព័ន្ធ មួយសម្រាប់គ្រប់គ្រងសំណុំរឿង ដែលជាលទ្ធផលនៅឆ្នាំ ២០០១ សំណុំរឿងសម្រាប់មន្ត្រីទទួលបន្ទុកម្នាក់ៗ ថយចុះពី ១៣ ទៅចំនួនមធ្យម ៧ (DCEC ២០០២:១៣) ។ នៅចុងឆ្នាំ ២០០១ DCEC បានបញ្ចប់រឿងចំនួន ៤២ករណី[២] និងមិនទាន់បានបញ្ចប់ចំនួន ៥២ករណី ដែលបង្ហាញថា មានការកើនឡើងនូវករណីដែលបានបញ្ចប់នៅក្នុងឆ្នាំនីមួយៗ (DCEC ២០០២:១៦)។ ករណីចំនួន ៦៣ ត្រូវបានបញ្ជូនបន្តទៅដល់សភា អគ្គមេធាវី ។

ការវិវឌ្ឍជាវិជ្ជមានបន្ថែមមួយទៀតគឺថា នៅក្នុងឆ្នាំ ២០០១ សភាជាតិបានអនុម័តបញ្ញត្តិច្បាប់ ដែលទាមទារឱ្យសមាជិកសភាបង្ហាញពីទ្រព្យសម្បត្តិដែលខ្លួនមាន ទោះជាការចុះបញ្ជីត្រូវធ្វើជាសម្ងាត់ក៏ដោយ (តម្លាភាពអន្តរជាតិ ២០០៣:២៥៣) ។

ប្រទេសបូតស្វាណាធ្លាប់មានកម្រិតនៃអំពើពុករលួយតិចតួច គឺជាប់ក្នុងលំដាប់ថ្នាក់លេខ ៣២ ក្នុងចំណោមប្រទេសចំនួន ១៥៩ នៅក្នុង*សន្ទស្សន៍ការយល់ឃើញអំពើពុករលួយ* ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិ។ ទោះបីជាថាមិនមែនអត់អំពើពុករលួយទាំងស្រុងក៏ដោយក៏ប្រទេសបូតស្វាណានៅតែជាប់ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅអាហ្វ្រិកខាងត្បូងដែលថា រឿងអាស្រូវស្ដីពីអំពើពុករលួយមានតិចតួចណាស់ ហើយជាទូទៅ រដ្ឋាភិបាលត្រូវបានគេយល់ឃើញថា មានការទទួលខុសត្រូវ និងមានតម្លាភាព (អង្គការតម្លាភាពអន្តរជាតិ ២០០១:៥៧)។ ឧប្បត្តិហេតុនៃអំពើពុករលួយក្នុងកម្រិតខ្ពស់ជាប្រព័ន្ធ ដែលជាដើមហេតុជំរុញឱ្យរដ្ឋាភិបាលបង្កើតអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC ហាក់ដូចជាបានរលត់រលាយបាត់ទៅហើយ។ ប៉ុន្តែ នៅមានការចោទប្រកាន់មួយចំនួន ដែលលើកឡើងថា DCEC គឺមិនបានដេញចាប់ "ត្រីធំ" ទេ ។ ករណីដែលត្រូវបាន DCEC ស៊ើបអង្កេតឥឡូវនេះ គឺសុទ្ធសឹងតែជាអំពើពុករលួយកម្រិតទាប ហើយជនជាប់សង្ស័យក៏សុទ្ធតែជាមន្ត្រីរាជការថ្នាក់ទាប (Frimpong ២០០១:១៤-១៥)។ ហើយទោះបីជាតុលាការបានដាក់ទោសចំពោះករណីនៃអំពើពុករលួយមួយចំនួនក៏ដោយក៏ DCEC បានសម្ដែងក្ដីបារម្ភថាការដាក់ទោសចំពោះបទឧក្រិដ្ឋទាំងនេះមានលក្ខណ:ធូរស្រាលពេក (DCEC ២០០២:១៧)។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច** (DCEC) ត្រូវបានបង្កើតឡើងក្នុងខែ កញ្ញា ឆ្នាំ ១៩៩៤ ដោយអនុលោមតាមគុណតម្លៃផ្នែក ៣(១) នៃច្បាប់លេខ ១៣ ដែលបានអនុម័តកាលពីមួយខែមុន។ បន្ថែមលើនេះទៀត ច្បាប់លេខ ១៣ នេះក៏បានចែងពីតួនាទីរបស់ DCEC សិទ្ធិអំណាច និងភារកិច្ចរបស់នាយក DCEC និងនីតិវិធីដែលត្រូវគោរពតាម ក្នុងការដោះស្រាយបញ្ហាពុករលួយ។ ជាស្ថាប័ន DCEC ត្រូវបានចាត់ទុកថាជាអគ្គនាយកដ្ឋានស្វយ័ត ស្ថិតនៅក្រោមការិយាល័យប្រធានាធិបតី ហើយត្រូវរាយការណ៍ដោយផ្ទាល់ជូនប្រធានាធិបតី ។

អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (DCEC) ត្រូវដឹកនាំដោយនាយក ១រូប និងនាយករង ១រូប។ នាយកទទួលខុសត្រូវដឹកនាំ និងដំណើរការរដ្ឋបាលនៃ DCEC (ផ្នែក ៤[២]) នៃច្បាប់លេខ ១៣។ ប្រធានាធិបតីតែងតាំងនាយក "តាមល័ក្ខខ័ណ្ឌដែលយល់ឃើញថាសមស្រប" (ផ្នែក ៤[១] នៃច្បាប់លេខ ១៣)។ ដោយអនុលោមតាមគុណតម្លៃនៃផ្នែក ៣(២) នៃច្បាប់លេខ ១៣ DCEC ត្រូវបានតែងតាំងជាការិយាល័យសាធារណៈមួយ ដូច្នេះ នាយក និងបុគ្គលិកនៃ DCEC ត្រូវស្ថិតនៅក្រោមច្បាប់នៃលក្ខន្តិកៈសេវាសាធារណៈ។ ដូច្នេះ នាយកមិនមានសន្តិសុខក្នុងការកាន់មុខតំណែងទេ ហើយត្រូវទទួលខុសត្រូវជាផ្លូវការ និងដោយផ្ទាល់ចំពោះប្រធានាធិបតី ។

អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (DCEC) មានសាខាចំនួន ៧ គឺ ផ្នែកកាត់ទោស ផ្នែកស៊ើបអង្កេត ផ្នែកវិភាគព័ត៌មានសម្ងាត់ ផ្នែកទប់ស្កាត់អំពើពុករលួយ ផ្នែកអប់រំសាធារណៈ ផ្នែករដ្ឋបាល និងធនធានមនុស្ស និងផ្នែកប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងបណ្ដុះបណ្ដាល ។

ផ្នែកទី៦ នៃច្បាប់នេះចែងថា អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច មានមុខងារទូលំទូលាយដូចខាងក្រោម:

- ទទួល និង ស៊ើបអង្កេតរាល់ពាក្យបណ្ដឹងចោទប្រកាន់អំពើពុករលួយនៅក្នុងស្ថាប័នរដ្ឋ។
- ស៊ើបអង្កេតករណីចោទប្រកាន់ ឬសង្ស័យថាមានបទល្មើស តាមបញ្ញត្តិច្បាប់លេខ ១៣ ឬការចោទប្រកាន់ផ្សេងទៀត ដែលបានបង្ហាញក្នុងពេលធ្វើការស៊ើបអង្កេតនេះ។
- ស៊ើបអង្កេតករណីចោទប្រកាន់ ឬសង្ស័យថាមានការរំលោភទៅលើបញ្ញត្តិនានារបស់ច្បាប់សារពើពន្ធនិងច្បាប់ស្ដីពីចំណូលពន្ធដារ។
- ស៊ើបអង្កេតការប្រព្រឹត្តិរបស់ជនណាម្នាក់ ដែលតាមគំនិតរបស់នាយក DCEC អាចពាក់ព័ន្ធ ឬ បង្កឱ្យមានអំពើពុករលួយ ។
- ជួយដល់ទីភ្នាក់ងារអនុវត្តន៍ច្បាប់របស់រដ្ឋាភិបាល ក្នុងការស៊ើបអង្កេតករណីចោទប្រកាន់ទាក់ទងនឹងការមិនស្មោះត្រង់ ឬការលួចប្រាក់ចំណូលសាធារណៈ។
- ពិនិត្យមើលការអនុវត្ត និងនីតិវិធីនៃស្ថាប័នសាធារណៈ ដើម្បីសម្រួលដល់ការស្វែងរកឱ្យឃើញនូវការប្រព្រឹត្តិអំពើពុករលួយ និង ដើម្បីធានាឱ្យបាននូវការពិនិត្យសារឡើងវិញលើរបៀបរបបធ្វើការងារ ឬនីតិវិធីធ្វើការងារ ដែលអាចនាំឱ្យមានការប្រព្រឹត្តិអំពើពុករលួយ។
- ផ្ដល់ឱវាទដល់ប្រធានស្ថាប័នសាធារណៈពីការផ្លាស់ប្ដូររបៀបរបបធ្វើការ ឬនីតិវិធីធ្វើការងារ ដើម្បីកាត់បន្ថយឱកាសដែលអាចប្រព្រឹត្តអំពើពុករលួយបាន។
- អប់រំដល់សាធារណជនអំពីលទ្ធផលអាក្រក់នៃអំពើពុករលួយ។ ហើយនិង
- ចុះបញ្ជី និងជំរុញឱ្យសាធារណជនឱ្យគាំទ្រក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

ដើម្បីបំពេញភារកិច្ចនេះ ផ្នែក ៧(១) នៃច្បាប់លេខ ១៣ បានអនុញ្ញាតឱ្យនាយកអាចផ្ទេរសិទ្ធិឱ្យមន្ត្រីណាមួយនៃ DCEC ឱ្យសួរដេញដោល និងស៊ើបអង្កេតចំពោះបទល្មើសដែលត្រូវគេចោទប្រកាន់ ឬគេសង្ស័យ ដូចមានចែងនៅក្នុងផ្នែក៤ នៃច្បាប់លេខ១៣។ មន្ត្រីក៏មានសិទ្ធិស្នើសុំពីបុគ្គលម្នាក់ៗ ព្រមទាំងពីធនាគារ ឬពីស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតនូវព័ត៌មានដែលទាក់ទងទៅនឹងករណីសង្ស័យពីអំពើពុករលួយ (ផ្នែក៧ និង ៨ នៃច្បាប់លេខ ១៣)។ នាយកក៏អាចស្នើសុំឱ្យចៅក្រមដកហូតឯកសារធ្វើដំណើររបស់ជនណាម្នាក់ដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តអំពើពុករលួយ (ផ្នែក១៦ ច្បាប់លេខ១៣)។ មន្ត្រីដែលបានចាត់តាំងដោយនាយក DCEC អាចឃាត់ខ្លួនបុគ្គលណាមួយបាន ប្រសិនបើបុគ្គលនោះបានប្រព្រឹត្ត ឬរៀបនឹងប្រព្រឹត្តបទល្មើសដែលចែងនៅក្រោមច្បាប់លេខ ១៣ (ផ្នែក ១០)។

គួរកត់ចំណាំផងដែរថា យោងតាមគុណតម្លៃនៃផ្នែក ៣៤ នៃច្បាប់លេខ ១៣ អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច អាចស៊ើបអង្កេតលើបុគ្គលណាម្នាក់ដែលមានជីវភាពរស់នៅមិនស្របទៅនឹងប្រាក់ចំណូលរបស់ខ្លួន ឬដែលមានធនធាន ឬទ្រព្យសម្បត្តិដែលមិនសមាមាត្រទៅនឹងប្រភពប្រាក់ចំណូល ឬធនធានបច្ចុប្បន្នរបស់ខ្លួន។ បុគ្គលម្នាក់នឹងត្រូវបានចាត់ទុកថាមានទោសពីបទប្រព្រឹត្តអំពើពុករលួយ ប្រសិនបើបុគ្គលនោះមិនអាចពន្យល់ឱ្យបានសមហេតុផល អំពីរបៀបដែលខ្លួនបានទទួលទ្រព្យ ឬធនធានទាំងនេះ។ ផ្នែក ៣៩ នៃច្បាប់លេខ ១៣ បានចែងថា បន្ទាប់ពីការស៊ើបអង្កេត ប្រសិនបើអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC មានមូលហេតុសមស្របអាចសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្តអំពើពុករលួយ ដូចដែលបានចែងនៅក្នុងវគ្គ ៤ នៃច្បាប់លេខ១៣ នោះ នាយក DCEC ត្រូវបញ្ជូនបញ្ហានេះទៅជូនអគ្គមេធាវី ដើម្បីធ្វើសេចក្ដីសម្រេច។ បើមិនមានការយល់ព្រមជាលាយល័ក្ខអក្សរពីអគ្គមេធាវីទេ ការដាក់បណ្ដឹងអាជ្ញាលើករណីបទល្មើសណាមួយមិនអាចធ្វើឡើងបានឡើយ (សូមមើលផ្នែកខាងក្រោម ស្ដីពីទំនាក់ទំនងរវាង DCEC និងសភាអគ្គមេធាវី) ។

ក្នុងការបំពេញការងាររបស់ខ្លួន អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC បានធ្វើការយ៉ាងមានប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនអំពីវត្តមាន និងតួនាទីរបស់ខ្លួន ព្រមទាំងធ្វើការអប់រំដល់សាធារណជនទូទៅពីជម្ងឺនៃអំពើពុករលួយ។ សកម្មភាពក្នុងវិស័យនេះ ក៏បានដាក់បញ្ចូលនូវការចុះទស្សនាភូមិនានានៅតាមតំបន់ជនបទ ដើម្បីណែនាំដល់ប្រជាជនមូលដ្ឋានពីសិទ្ធិរបស់ពួកគេ និងដើម្បីធានាថាគ្រូបង្រៀន និងបុគ្គលិកសាធារណៈមិនស៊ីសំណូកទេក្នុងការផ្ដល់សេវាដែលរដ្ឋាភិបាលបានឧបត្ថម្ភ

មូលនិធិ ហើយថាប្រជាជនមានសិទ្ធិទទួលសេវានោះដោយសេរី ។ អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC ក៏បានចេញផ្សាយនូវសារព័ត៌មានជាប្រចាំ ដើម្បីជូនដំណឹងដល់សាធារណជនពីនិន្នាការដែលបានលើកឡើងដល់ប្រជាជន និងពីលទ្ធផលនៃនិន្នាការទាំងនេះ ។

## ការរៀបចំកិច្ចប្រតិបត្តិការ

ដូចបានកត់ចំណាំខាងលើ អគ្គមេធាវីគឺជាអ្នកដែលសម្រេចថាតើត្រូវឬមិនត្រូវផ្តួចផ្តើមធ្វើការប្តឹងចោទទៅលើករណីសង្ស័យពីអំពើពុករលួយ ។ អគ្គមេធាវី គឺជា**ប្រធាននៃសភាអគ្គមេធាវី** ដែលបង្កើតបានជានាយកដ្ឋានក្រៅក្រសួងមួយ ។ អគ្គមេធាវីមានអាណត្តិការងារក្រោមរដ្ឋធម្មនុញ្ញ និងក្រោមបញ្ញត្តិច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងភស្តុតាង ដើម្បីដឹកនាំគ្រប់ការធ្វើបណ្តឹងអាជ្ញាផ្នែកព្រហ្មទណ្ឌ រួមទាំងការដាក់បណ្តឹងអាជ្ញាលើករណីដែលទាក់ទងនឹងអំពើពុករលួយផង ។ គ្រប់ករណីទាំងអស់នឹងត្រូវបានធ្វើបណ្តឹងអាជ្ញានៅក្នុងប្រព័ន្ធតុលាការទូទៅ ។ ទោះបីជាយ៉ាងណាក៏ដោយ ប៉ូលីស និង DCEC មានសិទ្ធិអំណាចធ្វើបណ្តឹងអាជ្ញាជំនួសឱ្យអគ្គមេធាវី ឬតាងនាមឱ្យអគ្គមេធាវី ។ ដូច្នេះ អគ្គមេធាវីអាចណែនាំដល់ DCEC ឱ្យធ្វើបណ្តឹងអាជ្ញា បន្ទាប់ពីសម្រេចថាត្រូវធ្វើ ។ ប៉ុន្តែ ទោះបីជាកាលពីដំបូង ផ្នែកបណ្តឹងអាជ្ញារបស់ DCEC ត្រូវធ្វើការក្នុងនាមជាទំនាក់ទំនងមួយរវាងអ្នកស៊ើបអង្កេតរបស់ DCEC នឹងអគ្គមេធាវីក៏ដោយ ឥឡូវនេះវាមានលក្ខណៈចាំបាច់កាន់តែច្រើនឡើង ហើយសម្រាប់ឱ្យ DCEC ធ្វើបណ្តឹងអាជ្ញាដោយខ្លួនឯង ដោយសារតែទំហំការងារធ្ងន់ធ្ងររបស់សភាអគ្គមេធាវី ។ ប្រការនេះ ក៏ទាមទារឱ្យ DCEC មានបុគ្គលិកដែលមានសមត្ថភាពដើម្បីបំពេញមុខងារបន្ថែមរបស់ខ្លួន ។

**ការិយាល័យអគ្គសវនករ** (OAG) ត្រូវបានបង្កើតឡើងដោយគុណតម្លៃនៃផ្នែក ១២៤ នៃរដ្ឋធម្មនុញ្ញ ដែលចែងថាត្រូវមានអគ្គសវនករម្នាក់ ។ ក្នុងការបំពេញមុខងាររបស់ខ្លួន អគ្គសវនករមិនគោរពតាមការណែនាំ ឬស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បុគ្គល ឬអាជ្ញាធរណាមួយឡើយ ។ ទោះបីជាអគ្គសវនករត្រូវបានតែងតាំងដោយប្រធានាធិបតីក៏ដោយ ក៏ឯករាជភាពរបស់គាត់ត្រូវបានធានាសុវត្ថិភាព ដោយសារការដកហូតគាត់ចេញពីការិយាល័យមិនស្ថិតនៅក្នុងអំណាចនីតិប្រតិបត្តិ ។ ការិយាល័យនេះ នឹងមានការផ្លាស់ប្តូរតែនៅពេលណាដែលអគ្គសវនករមានអាយុដល់ ៦០ឆ្នាំ ។ អគ្គសវនករធ្វើសវនកម្មលើគណនីសាធារណៈរបស់ប្រទេសបូតស្វាណា និងរបស់មន្ត្រីទាំងអស់ តុលាការ និងអាជ្ញាធរនៃរដ្ឋាភិបាល ព្រមទាំងគណនីនៃអង្គការធំៗរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ។ អគ្គសវនករត្រូវបញ្ជូនរបាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដែលនឹងត្រូវរៀបចំបែបបទបញ្ជូនទៅរដ្ឋសភា ។ ការិយាល័យអគ្គសវនករ (OAG) អនុវត្តតួនាទីរបស់អគ្គសវនករក្នុងនាមអគ្គសវនករ ។ ដូច្នេះ វាក្លាយជាស្ថាប័នសវនកម្មកំពូលរបស់ប្រទេសបូតស្វាណា ។ គោលដៅចម្បងរបស់អគ្គសវនករ ហើយនិងការិយាល័យអគ្គសវនករ OAG គឺដើម្បីធ្វើឱ្យរីកចម្រើនដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេស តាមរយៈការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុ និងការទទួលខុសត្រូវចំពោះមូលនិធិសាធារណៈ និងសម្បត្តិជាតិ ។

**ការិយាល័យ Ombudsman** ត្រូវបានបង្កើតឡើងដោយ **បញ្ញត្តិច្បាប់ស្តីពី Ombudsman** ឆ្នាំ ១៩៩៥ ហើយ Ombudsman ទី១ ដែលបានតែងតាំង គឺនៅឆ្នាំ ១៩៩៧ ។ Ombudsman ត្រូវបានតែងតាំងដោយប្រធានាធិបតី ។ ការិយាល័យ Ombudsman គឺជាស្ថាប័នក្រៅក្រសួងមួយក្រោមការិយាល័យប្រធានាធិបតី ។ ក្នុងការបំពេញមុខងាររបស់ខ្លួន Ombudsman មិនត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬក្រោមការណែនាំរបស់បុគ្គល ឬអាជ្ញាធរណាមួយទេ ។ បន្ថែមលើនេះទៀត ដំណើរការរបស់ Ombudsman មិនត្រូវបានតុលាការ ច្បាប់ណាមួយសួរដេញដោលទេ ។ អាណត្តិការងារចម្បងរបស់ Ombudsman គឺស៊ើបអង្កេតពាក្យបណ្តឹងពីភាពអយុត្តិធម៌ ឬរដ្ឋបាលមិនល្អនៅក្នុងសេវាសាធារណៈដែលទទួលបានពីសាធារណជន ។ ប្រសិនបើពាក្យបណ្តឹងទាំងនោះត្រូវបានរកឃើញថាមានសុពលភាព Ombudsman នឹងផ្តល់អនុសាសន៍អំពីបញ្ហានេះជូនដល់អាជ្ញាធរមានសមត្ថកិច្ច ។ ប្រសិនបើអនុសាសន៍មិនត្រូវបានអនុវត្តតាមទេនោះ Ombudsman មានកាតព្វកិច្ចត្រូវធ្វើរបាយការណ៍ពិសេសជូនរដ្ឋសភា ។

## មេរៀនដែលទទួលបាន

អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច (DCEC) ដែលមានលក្ខណៈខុសប្លែកពីស្ថាប័នស្រដៀងគ្នាផ្សេងទៀត នៅក្នុងប្រទេសអាហ្វ្រិក គឺដោយសារវាមិនគ្រាន់តែអនុវត្តតាមវិធីសាស្ត្រ ៣មុខព្រួញរបស់ក្រុងហុងកុង S.A.R ដែលមានការស៊ើបអង្កេត ការទប់ស្កាត់ និងការអប់រំតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ទទួលបាននូវជោគជ័យក្នុងការបំពេញបន្ថែមទៅឱ្យស្ថាប័នផ្សេងៗទៀត នៅក្នុងប្រទេសដែលគេបានបង្កើតឡើងដើម្បីកែលំអអភិបាលកិច្ច និងជំរុញការទទួលខុសត្រូវ និងតម្លាភាព។ មានមូលហេតុជាច្រើនចំពោះប្រការនេះ មូលហេតុទាំងនោះរួមមានលក្ខន្តិកៈរបស់ DCEC ដែលបានបញ្ជាក់ថា វាជាទីភ្នាក់ងារឯករាជ្យ ដែលអនុវត្តកម្មវិធីចុះដល់សហគមន៍ ផ្នែកឯកជន និងផ្នែកសាធារណៈផ្សព្វផ្សាយពីការខាតបង់ដែលបណ្តាលមកពីអំពើពុករលួយ ហើយនិងមូលហេតុមួយទៀតគឺ ស្ថាប័នសំខាន់ៗផ្សេងទៀត ដែលរួមគ្នាបង្កើតបានជាប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ បានដំណើរការយ៉ាងល្អ និងមូលហេតុមួយទៀតគឺ រចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធលើកទឹកចិត្តនៅក្នុងប្រទេសបូតស្វាណា ជួយរួមចំណែកក្នុងតួនាទីសំខាន់ ដែលទីភ្នាក់ងារនេះត្រូវអនុវត្តក្នុងការបំពេញបន្ថែមដល់ស្ថាប័នសំខាន់ៗ។ លើសពីនេះទៀត អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC មានថវិកាសម្រាប់ប្រតិបត្តិ (២,៤ លានដុល្លារអាមេរិកសម្រាប់ឆ្នាំ ២០០១-២០០២ ប្រៀបធៀបនឹងឆ្នាំមុនមាន ២,២ លានដុល្លារ)។

ក៏ប៉ុន្តែ នៅមានកត្តាមួយចំនួនដែលរួមចំណែកបង្កបញ្ហាដល់ប្រសិទ្ធភាពរបស់អគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC។ ទោះបីជាប្រព័ន្ធតុលាការត្រូវបានចាត់ទុកថាមានឯករាជ្យពេញលេញ និងមានសេរីភាពក្នុងការបំពេញភារកិច្ចដោយមិនមានការភ័យខ្លាច ឬមិនមានការនិយម ហើយបានបំពេញការងាររបស់ខ្លួនក្នុងការកាត់ទោស និងដាក់ទណ្ឌកម្មជនល្មើសពីបទពុករលួយក៏ដោយក៏ជាច្រើនលើកច្រើនគ្រា ការកាត់ក្តីត្រូវបានពន្យារពេល ដែលអាចប៉ះពាល់ដល់អត្រាដាក់ទោសចំពោះករណីដែល DCEC បានលើកឡើងជូនតុលាការ (Frimpong ២០០១:១៧)។ ករណីទាំងនេះត្រូវបានពន្យារពេលនៅក្នុងសភាអគ្គមេធាវី ដែលជាការបង្កបញ្ហាថែមទៀត។ ដូចបានលើកឡើងខាងលើ ប្រការនេះបានជំរុញ DCEC ឱ្យបង្កើតធនធាន និងសមត្ថភាពផ្ទាល់ខ្លួន ដើម្បីរៀបចំបណ្តឹងអាជ្ញាលើករណីពាក់ព័ន្ធនឹងអំពើពុករលួយ (Frimpong ២០០១:១៨)។ នៅក្នុងករណីទាំង ២នេះ ចំណុចខ្វះខាត គឺអាចបណ្តាលមកពីការខ្វះបុគ្គលិក និងខ្វះធនធាន។ យ៉ាងណាមិញ ប្រការនេះមានផលប៉ះពាល់ជាអវិជ្ជមានដល់ការយល់ឃើញរបស់សាធារណជន អំពីកិច្ចខិតខំដែលបានធ្វើក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ DCEC ក៏នឹងត្រូវបង្កើនបុគ្គលិកផងដែរ ដើម្បីឆ្លើយតបទៅនឹងទំហំការងារដែលកំពុងកើនឡើង (Frimpong ២០០១:២៣)។ ដូចដែលបានលើកឡើងខាងលើ មានការចោទប្រកាន់ថា DCEC កំពុងតាមចាប់ករណីនៃអំពើពុករលួយកម្រិតទាប ហើយធ្វើមិនដឹងមិនឮចំពោះ "ត្រីធំ" (Frimpong ២០០១:១៤)។

ការដាក់ DCECនៅក្នុងការិយាល័យប្រធានាធិបតី បានបង្កឱ្យមានសំនួរមួយសួរថាតើ DCEC មានឯករាជ្យពេញលេញ ឬមិនពេញលេញក្នុងការអនុវត្តអាណត្តិការងាររបស់ខ្លួន។ ប្រការនេះអាចដោះស្រាយបាន ដោយទាមទារឱ្យ DCEC ធ្វើរបាយការណ៍ដាក់ជូនរដ្ឋសភាជាតិ ជាជាងជូនប្រធានាធិបតីដូចពេលឥឡូវនេះ។ បញ្ហាមួយទៀតដែលបានលើកឡើងគឺថា នាយក DCEC មិនមានការធានាសន្តិសុខក្នុងការកាន់មុខតំណែងទេ (Frimpong ២០០១:៦)។ រីឯការិយាល័យ Ombudsman ដែលជាសេវាសាធារណៈមួយដូចអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC ដែរ - ការិយាល័យ Ombudsman នេះបានអះអាងថា ខ្លួនមិនមានឯករាជភាពគ្រប់គ្រាន់ដើម្បីបំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពទេ ហើយមានការអំពាវនាវឱ្យធ្វើវិសោធនកម្មលើបទបញ្ញត្តិផងដែរ (Frimpong ២០០១:៥)។

ផ្ទុយអំពីអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC និងការិយាល័យ Ombudsman, អគ្គសវនករមានឯករាជ្យ និងមានសន្តិសុខក្នុងមុខតំណែង។ មានមតិយល់ឃើញថា អគ្គសវនករធ្វើការងារយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព ក្នុងការរាយការណ៍ និងបើកកកាយករណីនៃអំពើពុករលួយ និងការប្រើប្រាស់មិនត្រឹមត្រូវនូវមូលនិធិសាធារណៈ។ ប៉ុន្តែ មានការអះអាងថា រដ្ឋសភាមិនបានធ្វើការងារខ្លួន ចំពោះអនុសាសន៍ដែលមាននៅក្នុងរបាយការណ៍ទាំងនេះទេ (Frimpong ២០០១:១២-១៣)។

ការពិភាក្សាមួយដែលបានធ្វើឡើងនៅក្នុងអគ្គនាយកដ្ឋានប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច DCEC គឺថា តើត្រូវអនុម័ត ឬមិនត្រូវអនុម័តលើប្រព័ន្ធ "កំណត់គោលដៅប្រតិបត្តិ" ដែលអាចនាំឱ្យ DCEC ផ្តោតលើការស៊ើបអង្កេតក្រុមគោលដៅជាក់លាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ គេបានសម្រេចថា DCEC ចាំបាច់ត្រូវបន្តធ្វើការស៊ើបអង្កេតតទៅទៀត ចំពោះរបាយការណ៍ជាក់លាក់ណាដែលខ្លួនទទួលបាន ។ បើមិនដូច្នោះទេ DCEC ត្រូវតែផ្តល់អាទិភាពដល់ការស៊ើបអង្កេតអំពើពុករលួយ ដែលប៉ះពាល់ដល់ប្រជាជនក្រីក្រ ។

## ប្រភព


- DCEC ២០០២ របាយការណ៍ប្រចាំឆ្នាំ ២០០១ *http://www.gov.bw/government /doc/Annual _Report_2001.doc*
- Frimpong, Kwame, របាយការណ៍សិក្សារបស់ប្រទេសអំពីប្រព័ន្ធសច្ចធម៌ជាតិ បូតស្វាណា ២០០១ *http://www.transparency.org/activities/nat_integ_systems/dnld/botswana.pdf*
- Kpundeh, S. and Levy, B. (eds.), ២០០៤ៈ កសាងសមត្ថភាពរដ្ឋនៅអាហ្វ្រិកវិធីសាស្ត្រថ្មី – មេរៀនដែលបានកើតឡើង
- Transparency International ២០០១ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០១ *http://www.globalcorruptionreport.org/gcr2001.htm#download*
- Transparency International ២០០៣ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០៣ *http://www.globalcorruptionreport.org/gcr2003.htm*


ព័ត៌មានក៏ត្រូវបានប្រមូលពីវេបសាយនៃស្ថាប័ននានាដែលបានរាយនាមខាងលើ ។

# ប្រទេសប៊ុលហ្គារី



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- គណៈកម្មការសម្របសម្រួលសកម្មភាពប្រឆាំងអំពើពុករលួយ
- ទីភ្នាក់ងារស៊ើបអង្កេតហិរញ្ញវត្ថុ (FIA) *www.fia.minfin.bg/index_en.php?main=1*
- ប្រព័ន្ធតុលាការ (រួមមាន តុលាការ សេវាអយ្យការសាធារណៈ និងសេវាស៊ើបអង្កេតថ្នាក់ជាតិ)
- ក្រសួងមហាផ្ទៃ (ជាពិសេស សេវាប៉ូលីសថ្នាក់ជាតិ [NSP] សេវាសន្តិសុខថ្នាក់ជាតិ [NSS] និងសេវាថ្នាក់ជាតិដើម្បីប្រឆាំងឧក្រិដ្ឋកម្ម ជាប្រព័ន្ធ [NSCOC])
- ការិយាល័យសវនកម្មជាតិ (NAO) *www.bulnao.government.bg/en*
- Ombudsman: មន្ត្រីការពារប្រជាពលរដ្ឋ
- គណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភា
- ទីភ្នាក់ងារត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈផ្ទៃក្នុង (PIFCA) *www.advfk.minfin.bg/en*

## បទបញ្ញត្តិចម្បង

- បទបញ្ញត្តិប្រព័ន្ធយុត្តិធម៌ (JS) (State Gazette No. ៥៩, ១៩៩៤ រហូតដល់វិសោធនកម្មលេខ ៧៤ ឆ្នាំ ២០០២) *http://www.legislationonline.org/view.php?document=59751*
- ច្បាប់ស្តីពី Ombudsman (State Gazette No. ៤៨ ថ្ងៃ ២៣ ខែ ឧសភា ឆ្នាំ ២០០៣ *http://www.anticorruption.bg/ombudsman//eng/lefframe_eng.htm*
- បទបញ្ញត្តិការិយាល័យសវនកម្មជាតិ (NAO) (State Gazette No. ១០៩ ថ្ងៃ១៨ ខែធ្នូ ឆ្នាំ ២០០១ រហូតដល់វិសោធនកម្ម លេខ ៣៨ ថ្ងៃ ១១ ខែឧសភា ឆ្នាំ ២០០៤) *http://www.bulnao.government.bg/en/pages.html/?catID=50*
- បទបញ្ញត្តិត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈផ្ទៃក្នុង (១ មករា ២០០១) *http://www.advfk.minfin.bg/pdf_doc/Public_Internal_%20Financial_Control_Act.pdf*

## សាវតា

អំពើពុករលួយនៅប្រទេសប៊ុលហ្គារី គឺជាបញ្ហាសំខាន់ និងត្រូវបានគេមើលឃើញថារីករាលដាលនៅក្នុងផ្នែកភាគច្រើននៃក្រុមមន្ត្រីសាធារណៈ (GRECO ២០០២:៣)។ អាជ្ញាធរគយ ការងារដែលទាក់ទងនឹងប្រព័ន្ធយុត្តិធម៌ ប៉ូលីស និងវិស័យសុខាភិបាល ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុងក្រុមដែលមានអំពើពុករលួយជាងគេបំផុត (EC ២០០៣:១៩)។ ចាប់តាំងពីការបោះឆ្នោតឆ្នាំ ១៩៩៧ បញ្ហាអំពើពុករលួយ និងការទប់ស្កាត់អំពើពុករលួយ បានក្លាយជាបញ្ហានយោបាយដ៏សំខាន់សម្រាប់រដ្ឋាភិបាល ព្រមទាំងសម្រាប់សង្គមស៊ីវិលដែលធ្វើការយ៉ាងសកម្ម ដើម្បី

ដាក់បញ្ហាអំពើពុករលួយនៅក្នុងរបៀបវារៈទី១ នៅថ្នាក់ជាតិ។ ទាក់ទងនឹងចំណុចនេះ ច្បាប់មួយចំនួនដែលពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវបានអនុម័ត។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ក៏ការកែទម្រង់មួយចំនួននៅតែមិនទាន់មានប្រសិទ្ធភាព ហើយមានការខ្វះខាតការសម្របសម្រួលទៅលើកិច្ចខិតខំប្រយុទ្ធប្រឆាំងអំពើពុករលួយ (OSI ២០០២:៨២)។

មូលហេតុដ៏សំខាន់មួយដែលបណ្ដាលឱ្យកើនឡើងនូវការផ្ដោតការយកចិត្តទុកដាក់ទៅលើអំពើពុករលួយ និងវិធានការប្រឆាំងអំពើពុករលួយ គឺប្រទេសប៊ុលហ្គារីត្រូវរៀបចំខ្លួនចូលជាសមាជិកសហគមន៍អឺរ៉ុប (EU)។ នៅក្នុងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើពុករលួយថ្នាក់ជាតិ រដ្ឋាភិបាលបានលើកឡើងថា ការអនុម័តយកយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើពុករលួយនេះ គឺជាតម្រូវការចាំបាច់សម្រាប់ធានាដល់សមាជិកភាពនៅក្នុង EU (២០០១:១)។ ការអនុម័តលើយុទ្ធសាស្ត្រថ្នាក់ជាតិរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០០១ បង្ហាញពីកិច្ចព្យាយាមដំបូងក្នុងការដាក់កិច្ចខិតខំប្រឆាំងអំពើពុករលួយនៅក្នុងក្របខ័ណ្ឌការងារជាប្រព័ន្ធ (OSI ២០០២:៩១)។ យុទ្ធសាស្ត្រនេះ ក៏បានសង្កត់ធ្ងន់ផងដែរទៅលើវិធានការទប់ស្កាត់ក្នុងការប្រឆាំងអំពើពុករលួយ ។

ជំហានបន្ទាប់មួយទៀត គឺការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល និងពង្រឹងរចនាសម្ព័ន្ធស្ថាប័ន ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ហើយនិងសម្របសម្រួល ព្រមទាំងត្រួតពិនិត្យលើការអនុវត្តផែនការយុទ្ធសាស្ត្រថ្នាក់ជាតិនេះ។ គណៈកម្មការអចិន្ត្រៃយ៍សភាស្ដីពីអំពើពុករលួយ ក៏ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០២។ ការកែទម្រង់មួយចំនួនផ្សេងទៀត ដូចដែលមានពិភាក្សានៅក្នុងផ្នែកស្ដីពីមេរៀនដែលទទួលបានខាងក្រោម គួរតែអាចជួយបង្កើនប្រសិទ្ធិភាពនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយ ហើយនិងអាចជួយរកដំណោះស្រាយចំពោះចំណុចខ្សោយដែលមាននៅក្នុងប្រព័ន្ធសច្ចធម៌ជាតិ។ ការតែងតាំង Ombudsman នៅពេលខាងមុខ ក៏អាចជួយឱ្យរីកចម្រើនថែមទៀតក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

ទោះបីជារដ្ឋាភិបាលប្រទេសប៊ុលហ្គារី មានការរីកចម្រើនក្នុងការដោះស្រាយបញ្ហាអំពើពុករលួយក៏ដោយ ក៏គេបានលើកឡើងក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការអឺរ៉ុបឆ្នាំ ២០០៣ ស្ដីពីវិវឌ្ឍនភាពរបស់ប្រទេសប៊ុលហ្គារី ដើម្បីចូលជាសមាជិកថា "អំពើពុករលួយនៅតែជាបញ្ហា ហើយប្រទេសប៊ុលហ្គារីត្រូវរក្សាកិច្ចខិតខំដើម្បីអនុវត្តវិធានការដែលពាក់ព័ន្ធបញ្ហានេះ" (២០០៣:១២១)។ របាយការណ៍នេះក៏បានលើកឡើងថែមទៀតថា ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ប្រទេសប៊ុលហ្គារី "បានធ្វើឱ្យមានការរីកចម្រើនក្នុងការចងក្រងក្របខ័ណ្ឌច្បាប់ច្រើនជាងការអនុវត្តច្បាប់" (GRECO ២០០២:២១)។ ប្រទេសប៊ុលហ្គារីមានចំណាត់ថ្នាក់លេខ ៥៥ ក្នុងចំណោមប្រទេស ១៥៩ លើសន្ទស្សន៍នៃការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០០៥។ ការប៉ាន់ប្រមាណពីអំពើពុករលួយក្នុងឆ្នាំ ២០០៣ ដែលបានអនុវត្តដោយក្រុមចំរុះ ២០០០[១] បានរកឃើញថា មិនមានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់ទេ ចំពោះកម្រិតនៃអំពើពុករលួយនៅក្នុងប្រទេសកាលពីឆ្នាំមុន ហើយថាអំពើពុករលួយនៅតែត្រូវបានគេមើលឃើញថាជាបញ្ហាដ៏ធំធេងនៅក្នុងសង្គម។ មានការសន្និដ្ឋានបន្ថែមទៀតថា "រហូតមកទល់ពេលនេះ គេបានប្រើអស់លទ្ធភាពហើយ ក្នុងការអនុវត្តវិធានការប្រឆាំងអំពើពុករលួយ ប៉ុន្តែនៅតែមិនឃើញមានសញ្ញានៃការរីកចម្រើនសោះ" (Coalition ២០០០, ២០០៤:៥)។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

មិនមានទីភ្នាក់ងារជំនាញសម្រាប់ដោះស្រាយបញ្ហាអំពើពុករលួយតែមួយផ្នែកប៉ុណ្ណោះទេ។ ផ្ទុយទៅវិញ មានអង្គភាព មានផ្នែក មាននាយកដ្ឋាន និងមានទីភ្នាក់ងារមួយចំនួន ត្រូវបានគេបង្កើតឡើងនៅតាមក្រសួងនានានៅក្នុងប្រព័ន្ធយុត្តិធម៌ និងនៅក្នុងស្ថាប័នប៉ូលីស ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។

[១] សម្ព័ន្ធភាព ២០០០ គឺជាគំនិតផ្តួចផ្តើមមួយដែលបានចាប់ផ្តើមនៅខែ មេសា ឆ្នាំ ១៩៩៨ ដោយមានគោលបំណងប្រយុទ្ធនឹងអំពើពុករលួយនៅក្នុងសង្គមនៃប្រទេសប៊ុលហ្គារី តាមរយៈកិច្ចសហប្រតិបត្តិការគ្នានៅក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋាភិបាល។ សម្រាប់ព័ត៌មានបន្ថែម សូមមើល *http://www.csd.bg/en/c2000*។

មុខងារជាច្រើនរបស់ប៉ូលីស ត្រូវបានអនុវត្តក្រោមការណែនាំដោយផ្ទាល់ពី**ក្រសួងមហាផ្ទៃ**។ ក្រសួងមហាផ្ទៃត្រូវដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ជាមួយអនុរដ្ឋមន្ត្រីជាច្រើន និងអគ្គលេខាធិការ ដែលជាមន្ត្រីស៊ីវិលមានឋានៈខ្ពស់បំផុតនៅក្នុងក្រសួង។ អគ្គលេខាធិការត្រូវបានតែងតាំង និងដកចេញដោយប្រធានាធិបតី តាមសំណើររបស់រដ្ឋាភិបាល។

ទោះបីជាសេវាទាំងអស់ដែលនៅក្រោមក្រសួងមហាផ្ទៃ មានការរួមចំណែកក្នុងកម្រិតមួយចំនួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយក៏ដោយ ក៏ស្ថាប័នដែលដើរតួនាទីសំខាន់បំផុតក្នុងវិស័យនេះ គឺ**សេវាប៉ូលីសថ្នាក់ជាតិ [NSP] សេវាសន្តិសុខថ្នាក់ជាតិ [NSS]** និង**សេវាថ្នាក់ជាតិប្រឆាំងឧក្រិដ្ឋកម្មជាប្រព័ន្ធ [NSCOC]**។ នៅក្នុងគ្រប់នាយកដ្ឋានប៉ូលីសថ្នាក់តំបន់ និងថ្នាក់ខេត្ត មានអង្គភាពជំនាញសម្រាប់ដោះស្រាយបទឧក្រិដ្ឋផ្នែកសេដ្ឋកិច្ច រួមទាំងអំពើពុករលួយផងដែរ។ នៅថ្នាក់ក្រសួងមហាផ្ទៃ ស្ថាប័នសេវាប៉ូលីសថ្នាក់ជាតិ NSP មានអង្គភាពចំនួន ៥ នៅក្នុងនាយកដ្ឋានប៉ូលីសសេដ្ឋកិច្ច ដែលដោះស្រាយរឿងបទល្មើសដែលទាក់ទងតែនឹងអំពើពុករលួយ (GRECO ២០០៤:៥)។ ស្ថាប័នសេវាសន្តិសុខថ្នាក់ជាតិ NSS មានភារកិច្ចប្រឆាំង និងទប់ស្កាត់បទល្មើសព្រហ្មទណ្ឌប្រឆាំងសន្តិសុខជាតិ រួមទាំងបទល្មើសពុករលួយដែលមានការពាក់ព័ន្ធជាមួយសេវាបរទេស ឬអង្គការបរទេស (GRECO ២០០២:១០)។ នៅក្នុងស្ថាប័ន សេវាថ្នាក់ជាតិប្រឆាំងឧក្រិដ្ឋកម្មជាប្រព័ន្ធ NSCOC មាននាយកដ្ឋានប្រឆាំងអំពើពុករលួយ ដែលការប្រយុទ្ធប្រឆាំងអំពើពុករលួយស្ថិតនៅក្នុងចំណោមនៃភារកិច្ចជាអាទិភាពរបស់ខ្លួន។ សកម្មភាពរបស់នាយកដ្ឋាននេះ រួមមានការរុករកអំពើពុករលួយនៅក្នុងវិស័យឯកជន និងវិស័យសាធារណៈ ព្រមទាំងនៅក្នុងក្រសួងមហាផ្ទៃខ្លួនឯងផងដែរ (GRECO ២០០៤:៥)។

នៅក្នុង**ក្រសួងហិរញ្ញវត្ថុ** មាន**ទីភ្នាក់ងារស៊ើបអង្កេតហិរញ្ញវត្ថុ (FIA)**[២] និង**ទីភ្នាក់ងារត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈផ្ទៃក្នុង (PIFCA)** ដែលបំពេញការងារទាក់ទងទៅនឹងប្រព័ន្ធសច្ចធម៌ជាតិ។

ទីភ្នាក់ងារស៊ើបអង្កេតហិរញ្ញវត្ថុ គឺជារដ្ឋបាលឯករាជ្យថ្នាក់ជាតិ ដឹកនាំដោយនាយក ១រូប។ មុខងារចម្បងរបស់ទីភ្នាក់ងារនេះ គឺទទួលផែទាំ ពិនិត្យ វិភាគ និងបង្ហាញដល់ស្ថាប័នអនុវត្តនីច្បាប់ដែលពាក់ព័ន្ធ នូវព័ត៌មានដែលទាក់ទងទៅនឹងការលាងលុយកខ្វក់។[៣]

សកម្មភាពរបស់ទីភ្នាក់ងារត្រួតពិនិត្យហិរញ្ញវត្ថុសាធារណៈផ្ទៃក្នុង PIFCA ត្រូវបានកំណត់ដោយបញ្ញត្តិច្បាប់របស់ PIFC ហើយទីភ្នាក់នេះ ដឹកនាំដោយនាយក ១រូប ដែលបានតែងតាំង (និងដកចេញ) ដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុ ដោយមានការយល់ស្របពីនាយករដ្ឋមន្ត្រី (មាត្រា ៦ និង៧)។ ក្រៅពីការតែងតាំងនាយករង ដែលនាយកត្រូវការការអនុម័តពីរដ្ឋមន្ត្រីហិរញ្ញវត្ថុ នាយកទទួលខុសត្រូវក្នុងការគ្រប់គ្រងបុគ្គលិកនៅក្នុង PIFCA (មាត្រា ៧) ព្រមទាំងគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពរបស់ទីភ្នាក់ងារ (មាត្រា ៩[១] ច្បាប់ PIFC)។ គោលដៅទូទៅរបស់ PIFCA ដូចមានចែងនៅក្នុងមាត្រា ២(២) នៃច្បាប់ PIFC គឺការទប់ស្កាត់ ការរុករក និងស្តារឡើងវិញនូវការខូចខាតដែលមាននៅក្នុងប្រទេស។ មុខងារចម្បងរបស់ PIFCA រួមមាន ការធ្វើផែនការ ការគ្រប់គ្រង និងការអនុវត្តគោលនយោបាយចំរុះមួយនៅក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុផ្ទៃក្នុង ការបង្កើតយន្តការប៉ាន់ប្រមាណលើហានិភ័យ និងការផ្តល់សេចក្តីណែនាំ និងអនុសាសន៍លើការបង្កើតប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុ និងពិនិត្យលើការអនុវត្តឱ្យបានត្រឹមត្រូវ ព្រមទាំងតាមមើលលើការចំណាយធនធានហិរញ្ញវត្ថុក្រោមកម្មវិធី និងមូលនិធិសហភាពអឺរ៉ុប។

លើសពីនេះទៀត **Ombudsman** ឯករាជ្យ និង**ការិយាល័យសវនកម្មជាតិ (NAO)** ដើរតួនាទី ឬត្រូវគេរំពឹងថាជាអ្នកដើរតួនាទីទប់ស្កាត់អំពើពុករលួយ។

Ombudsman ម្នាក់ត្រូវបានជ្រើសរើសដោយរដ្ឋសភា ក្នុងខែមេសា ឆ្នាំ ២០០៥ ដោយអនុលោមតាមច្បាប់ឆ្នាំ ២០០៣ ស្តីពី Ombudsman[៤]។Ombudsman ម្នាក់ ត្រូវគេជ្រើសរើសសម្រាប់រយៈពេល ៥ឆ្នាំ (មាត្រា ៨)។ ច្បាប់ចែងអំពីឋានៈ ស្ថាប័ន និងសកម្មភាព

[២] FIA ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៣ ជំនួសឱ្យការិយាល័យស៊ើបអង្កេតហិរញ្ញវត្ថុលើកមុន (FIA ២០០៤:៣)

[៣] FIA ក៏មានភារកិច្ចទប់ស្កាត់សកម្មភាពហិរញ្ញវត្ថុរបស់ភេរវជន

[៤] ការជ្រើសរើស Ombudsman ត្រូវបានជ្រើសរើសដោយការព្យាយាម ២ដង និងបរាជ័យពីមុន ដោយរដ្ឋសភាជាតិធ្វើការបោះឆ្នោត (CSD ២០០៤)

របស់ Ombudsman ។ មាត្រា ៣ នៃច្បាប់នេះ ចែងថា Ombudsman ត្រូវជាបុគ្គលឯករាជ្យ និងត្រូវធ្វើអន្តរាគមន៍តាមមធ្យោបាយ ដែលច្បាប់បានផ្តល់ឱ្យនៅពេលណាដែលសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋត្រូវបានរំលោភបំពានដោយអំពើ ឬដោយការមិនបំពេញសកម្មភាពពីសំណាក់អាជ្ញាធររដ្ឋ ឬអាជ្ញាធរក្រុង ឬផ្នែករដ្ឋបាលរបស់អាជ្ញាធរនោះ ព្រមទាំងដោយបុគ្គលនីមួយៗនៅក្នុងសេវាសាធារណៈ (មាត្រា ២ និង ៣ [១]) ។ អាជ្ញាធររដ្ឋ ឬអាជ្ញាធរក្រុង ឬផ្នែករដ្ឋបាលរបស់អាជ្ញាធរនោះ ឬនីតិបុគ្គល ព្រមទាំងប្រជាពលរដ្ឋទូទៅ មានកាតព្វកិច្ចត្រូវជូនដំណឹងដល់ Ombudsman នូវព័ត៌មានដែលពួកគេទទួលបានជាផ្លូវការ ហើយនិងមានកាតព្វកិច្ចត្រូវជួយដល់ Ombudsman ក្នុងកិច្ចការដែលទាក់ទងទៅនឹងពាក្យបណ្តឹងដែលគេបានទទួល (មាត្រា ៧) ។ Ombudsman ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនដល់រដ្ឋសភា (មាត្រា ២២) ។ អ្នកសម្របសម្រួលសាធារណៈក៏ត្រូវបានតែងតាំងនៅក្នុងក្រុងមួយចំនួននៃប្រទេសប៊ុលហ្គារីដែរ (CSD ២០០៤) ។

ការិយាល័យសវនកម្មជាតិ (NAO) ដែលត្រូវបានបង្កើតឡើងតាមគុណតម្លៃនៃមាត្រា ៩១ នៃរដ្ឋធម្មនុញ្ញ មានប្រធាន ១រូប និងសមាជិក ១០រូប ដែលត្រូវបានជ្រើសតាំង (និងដកចេញ) សម្រាប់អាណត្តិការងារ ៩ឆ្នាំ ដោយរដ្ឋសភា (មាត្រា ១ [២] ច្បាប់ NAO) ។ សិទ្ធិអំណាច រចនាសម្ព័ន្ធអង្គការ និងសកម្មភាពរបស់ NAO បានចែងច្បាស់នៅក្នុងបទ ច្បាប់ NAO (មាត្រា ១ [២]) ។ ដូចមានចែងនៅក្នុងមាត្រា ២ នៃច្បាប់ NAO, NAO មានឯករាជភាព ដោយមានការទទួលខុសត្រូវចំពោះរដ្ឋសភា និងមានថវិកាផ្ទាល់ខ្លួន (មាត្រា ៣ នៃច្បាប់ NAO) ។ ប្រធានការិយាល័យសវនកម្មជាតិ NAO ទទួលខុសត្រូវគ្រប់គ្រងបុគ្គលិករបស់ NAO (មាត្រា ១៥ នៃច្បាប់ NAO) ។ ការិយាល័យសវនកម្មជាតិ NAO មាននាយកដ្ឋានអនុវត្តមួយចំនួន រួមជាមួយនិងការិយាល័យតំបន់នានាដែលត្រូវបានបង្កើតឡើងតាមមូលដ្ឋានភូមិសាស្ត្រ (មាត្រា ១៦ នៃច្បាប់ NAO) ។

ការិយាល័យសវនកម្មជាតិ (NAO) គឺជាស្ថាប័នរដ្ឋសម្រាប់ធ្វើសវនកម្មពីខាងក្រៅទៅលើថវិកាជាតិ និងមូលនិធិសាធារណៈផ្សេងទៀត ហើយនិងសកម្មភាពឯទៀតៗ ដូចមានចែងនៅក្នុងបញ្ញត្តិច្បាប់នេះ ។ ភារៈកិច្ចចម្បងរបស់វា គឺដើម្បីចូលរួមចំណែកដល់ការគ្រប់គ្រងថវិកាជាតិ និងមូលនិធិសាធារណៈផ្សេងទៀត ហើយត្រូវផ្តល់ជូនទៅរដ្ឋសភានូវព័ត៌មានដែលអាចទុកចិត្តបាន ស្តីពីការប្រើប្រាស់មូលនិធិទាំងនេះ (មាត្រា ១ [២] និងមាត្រា ៤ នៃច្បាប់ NAO) ព្រមទាំងធ្វើសវនកម្មលើសកម្មភាពហិរញ្ញវត្ថុរបស់គណបក្សនយោបាយនានា (OSI ២០០២:១០០) ។ ថែមពីលើនេះទៀត ការិយាល័យសវនកម្មជាតិ NAO កាន់បញ្ជីប្រកាសទ្រព្យសម្បត្តិ ដែលមន្ត្រីសាធារណៈទាំងអស់ដែលកាន់តួនាទីធំៗបានដាក់ជូន (OSI ២០០២:៩៩)[៥] ។ ការិយាល័យសវនកម្មជាតិ NAO បានទទួលនូវសិទ្ធិអំណាចមួយចំនួន ដើម្បីបំពេញភារកិច្ចរបស់ខ្លួន (មាត្រា ៣១ [១] នៃច្បាប់ NAO) ។ NAO អាចផ្តល់អនុសាសន៍ ដើម្បីកែលម្អការគ្រប់គ្រងថវិកា និង/ឬមូលនិធិសាធារណៈផ្សេងទៀត ហើយស្ថាប័នដែលត្រូវបានគេធ្វើសវនកម្មនេះ ត្រូវតែអនុវត្តតាមអនុសាសន៍ទាំងនេះ (មាត្រា ៤១ [១] និងមាត្រា ៤២ [១] នៃច្បាប់ NAO) ។ ប្រសិនបើអនុសាសន៍ទាំងនេះមិនត្រូវបានអនុវត្តតាមទេនោះ NAO ត្រូវបញ្ជូនរបាយការណ៍ដោយមានអនុសាសន៍ទាំងនេះ ទៅជូនស្ថាប័នជាន់ខ្ពស់ដែលពាក់ព័ន្ធ (មាត្រា ៤២ [២] នៃច្បាប់ NAO) ។ ទោះបីជាយ៉ាងណាក៏ដោយ ការិយាល័យសវនកម្មជាតិ NAO មិនបំពេញតួនាទីជាអ្នកអនុវត្តច្បាប់ទេ ។ ប្រសិនបើ NAO រកឃើញថាមានអំពើល្មើសព្រហ្មទណ្ឌ NAO មានកាតព្វកិច្ចត្រូវដាក់ជូននូវសក្ខីភាពទាំងនេះទៅសេវាផ្នែកអយ្យការសាធារណៈ ឬទៅកាន់ស្ថាប័នជាន់ខ្ពស់ដែលទទួលខុសត្រូវក្នុងការដាក់វិន័យផ្នែករដ្ឋបាល ឬទណ្ឌកម្មផ្សេងៗទៀត (GRECO ២០០២:១៦ និង OSI ២០០២:១០១) ។

**ប្រព័ន្ធយុត្តិធម៌** ក៏មានតួនាទីសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយដែរ ។ ប្រព័ន្ធយុត្តិធម៌មាន **តុលាការ ការិយាល័យព្រះរាជអាជ្ញា** និងសេវាស៊ើបអង្កេតដែលមុខងារ និងរចនាសម្ព័ន្ធនៃស្ថាប័នទាំងនេះនឹងមានចែងនៅក្នុងអត្ថបទខាងក្រោម ស្តីពីការរៀបចំកិច្ចប្រតិបត្តិការ ។ ប្រព័ន្ធយុត្តិធម៌ស្ថិតនៅក្រោមការគ្រប់គ្រងរបស់**ក្រសួងយុត្តិធម៌** និង**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** (SJC) ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម SJC កំណត់ពីសមាសភាព និងអនុវត្តការរៀបចំប្រព័ន្ធយុត្តិធម៌ ។ ក្រុមប្រឹក្សានេះមានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន[៦] និងមានសមាជិក ២៥នាក់ គឺប្រធានតុលាការកំពូល ប្រធានតុលាការរដ្ឋបាលកំពូល និងអគ្គព្រះរាជអាជ្ញាជាសមាជិកជាប់

[៥] កាតព្វកិច្ចនេះ ដើរតាមការណែនាំពីបទបញ្ញត្តិស្តីពីការបង្ហាញទ្រព្យសម្បត្តិរបស់បុគ្គលដែលមានតួនាទីធំនៅក្នុងប្រទេស ។ មន្ត្រីធំៗ រួមទាំង សមាជិករដ្ឋសភាជាតិ ប្រធានាធិបតី អនុប្រធានាធិបតី រដ្ឋមន្ត្រី ។ល ។ (OSI, ២០០១:៩៩)

[៦] រដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ មិនមានសិទ្ធិបោះឆ្នោតទេ

តួនាទី រួមជាមួយសមាជិកចំនួន ១១នាក់ ដែលបានជ្រើសរើសដោយរដ្ឋសភា និងសមាជិកចំនួន ១១ រូបទៀតជ្រើសរើសដោយប្រព័ន្ធយុត្តិធម៌ (មាត្រា ១៦-១៧-២៦ [១] នៃច្បាប់ JS)។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម SJC ជាអ្នកស្នើទៅប្រធានាធិបតី ដើម្បីតែងតាំង ឬដកចេញនូវប្រធានតុលាការការកំពូល និងប្រធានតុលាការរដ្ឋបាលកំពូល ព្រមទាំងអគ្គព្រះរាជអាជ្ញា។ ប្រសិនបើសំណើអ្វីមួយត្រូវបានលើកឡើងជូនប្រធានាធិបតីជាច្រើនដង ប្រធានាធិបតីត្រូវតែធ្វើតាមសំណើរនោះ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម SJC ក៏ជាអ្នកតែងតាំង តម្លើងឋានៈ ទំលាក់ឋានៈ និងដកចេញ ព្រមទាំងគ្រប់គ្រងលើករណីដាក់វិន័យចំពោះចៅក្រម ព្រះរាជអជ្ញា និងអ្នកស៊ើបអង្កេតនៅក្នុងប្រព័ន្ធតុលាការ (មាត្រា ២៧ នៃច្បាប់ JS)។

## ការរៀបចំកិច្ចប្រតិបត្តិការ

ដើម្បីសម្របសម្រួល និងពង្រឹងរចនាសម្ព័ន្ធស្ថាប័នសម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ **គណៈកម្មការសម្របសម្រួលសកម្មភាពប្រឆាំងអំពើពុករលួយ**ត្រូវបានបង្កើតឡើងនៅក្នុងខែកុម្ភៈ ឆ្នាំ ២០០២។ នេះជាគណៈកម្មការអន្តរក្រសួង ដោយមានតំណាងមកពីក្រសួងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ហើយនិងការិយាល័យសវនកម្មជាតិ NAO និងមកពីស្ថាប័នផ្សេងទៀត។ គណៈកម្មការនេះដឹកនាំដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន រួមជាមួយនឹងអនុប្រធាន ២រូប និងមានការជួយគាំទ្រការងារដោយលេខាធិការដ្ឋានមួយដែលត្រូវដឹកនាំដោយលេខាធិការ។ មុខងារចម្បងរបស់គណៈកម្មការនេះគឺដើម្បីសម្របសម្រួល និងត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ និងការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រនេះ ដែលជារួមមាន ការកំណត់ការទទួលខុសត្រូវរបស់នាយកដ្ឋាននានាទាក់ទងនឹងបញ្ហានេះ។ គណៈកម្មការនេះ ក៏មានភារកិច្ចរាយការណ៍អំពីការអនុវត្តយុទ្ធសាស្ត្រជាតិ តាមរយៈផែនការសកម្មភាព និងធ្វើសំណើ ដើម្បីធ្វើឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាព។ លើសពីនេះទៀត គណៈកម្មការនេះក៏មានភារកិច្ចវិភាគលើប្រសិទ្ធភាពទូទៅនៃកិច្ចខិតខំប្រយុទ្ធប្រឆាំងអំពើពុករលួយ និងរៀបចំវិធានការដើម្បីបង្កើនប្រសិទ្ធភាពនៃវិធានការប្រឆាំងអំពើពុករលួយ។ ប៉ុន្តែគណៈកម្មការនេះមិនមានសិទ្ធិអំណាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងទេ ហើយនិងមិនអាចធ្វើអន្តរាគមន៍ទៅលើករណីនៃអំពើពុករលួយណាមួយឡើយ (EC ២០០៣:GRECO ២០០៤:៣ TI ២០០៤:១៦៧)។

បន្ថែមលើនេះទៀត **គណៈកម្មការសភាអចិន្ត្រៃយ៍** ដែលមានសមាជិក ២៤នាក់ ត្រូវបានបង្កើតឡើងដោយរដ្ឋសភាក្នុងខែតុលា ឆ្នាំ ២០០២ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ភារកិច្ចចម្បងរបស់គណៈកម្មការនេះគឺ ត្រូវធ្វើឱ្យច្បាប់ជាតិស្របជាមួយលំនាំបែបបទ (Acquis) និងការអនុវត្តរបស់សហគមន៍អឺរ៉ុប EU, ត្រូវតាមពិនិត្យមើលការអនុវត្តច្បាប់ និងត្រូវបំពេញបន្ថែមទៅលើច្បាប់ទាំងនោះ ប្រសិនបើមានចំណុចខ្សោយកើតឡើង (EC, ២០០៣:២០)។ គណៈកម្មការនេះក៏មានភារកិច្ចស្នើធ្វើវិសោធនកម្ម និងតាមពិនិត្យមើលការអនុវត្តច្បាប់ដែលមានស្រាប់ ព្រមទាំងកំណត់ការខ្វះចន្លោះនានានៅក្នុងការអនុវត្តច្បាប់។ គណៈកម្មការនេះមិនមានសិទ្ធិអំណាចស៊ើបអង្កេតទេ (TI ២០០៤:១៦៧)។[៧]

**ប្រព័ន្ធយុត្តិធម៌**មានភារកិច្ចធ្វើការស៊ើបអង្កេត ធ្វើបណ្តឹងអាជ្ញា និងវិនិច្ឆ័យទោសចំពោះករណីនៃអំពើពុកលួយ (GRECO ២០០២:៧)។ ឯករាជភាពនៃអង្គចៅក្រម ត្រូវបានចែងនៅក្នុងមាត្រា ១១៧ នៃរដ្ឋធម្មនុញ្ញ ព្រមទាំងមាត្រា ១៣ និង ១៤ នៃច្បាប់ JS។ មិនមានតុលាការជំនាញសម្រាប់ដោះស្រាយចំពោះករណីនៃអំពើពុករលួយទេ (GRECO ២០០២:១៥)។ **ការិយាល័យព្រះរាជអាជ្ញា**ដំណើរការតាមបែបខ្សែបណ្តោយ និងបែបមជ្ឈការ ដោយព្រះរាជអាជ្ញាម្នាក់ៗស្ថិតនៅក្រោមចំណុះនាយព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាទាំងអស់ ស្ថិតនៅក្រោមចំណុះអគ្គព្រះរាជអាជ្ញា ដែលជាប្រធានការិយាល័យព្រះរាជអាជ្ញា (មាត្រា ១១១ និង ១១២ ច្បាប់ JS)។ **សេវាស៊ើបអង្កេត** មានសេវាស៊ើបអង្កេតថ្នាក់ជាតិ និង**សេវាស៊ើបអង្កេតថ្នាក់ស្រុក**ដែលដឹកនាំដោយនាយកនានា (មាត្រា ១២២ និង ១២៣ ច្បាប់ JS)។ អ្នកស៊ើបអង្កេតធ្វើការស៊ើបអង្កេតបឋម លើករណីព្រហ្មទណ្ឌដូចដែលបានចែងនៅក្នុងច្បាប់ (មាត្រា ១២១ [១] ច្បាប់ JS)។

[៧] ព័ត៌មានស្តីពីគណៈកម្មការនេះ អាចយកបានពី http://www.anticorruption.org

កិច្ចសហប្រតិបត្តិការរវាងប៉ូលីស សេវាអយ្យការ និងសេវាស៊ើបអង្កេត ត្រូវបានបែងចែកនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងនៅក្នុងសេចក្តីណែនាំស្តីពីសកម្មភាព និងការសម្របសម្រួលរវាងអាជ្ញាធរដំណើរការដំបូង (GRECO ២០០២:១៤ និង GRECO ២០០៤:៦)។ ប៉ុន្តែមិនមានបទបញ្ញត្តិពិសេសណាសម្រាប់ការស៊ើបអង្កេត និងការធ្វើបណ្តឹងអាជ្ញាចំពោះករណីនៃអំពើពុករលួយ ដែលត្រូវដោះស្រាយក្នុងរបៀបដូចគ្នាទៅនឹងបទល្មើសផ្សេងទៀតទេ។ ករណីនៃអំពើពុករលួយ ត្រូវបានស៊ើបអង្កេតជាធម្មតា ដោយសេវាស៊ើបអង្កេតថ្នាក់ស្រុក ទោះបីជាការស៊ើបអង្កេតត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សេវាអយ្យការក៏ដោយ។ សេវាអយ្យការត្រួតពិនិត្យលើភាពស្របច្បាប់នៃការស៊ើបអង្កេតមុនពេលកាត់ក្តី ព្រមទាំងនាំករណីទៅដាក់តុលាការ (GRECO ២០០២:១៤)។

## មេរៀនដែលទទួលបាន

នៅប្រទេសប៊ុលហ្គារី ក្តីបារម្ភចម្បងគេគឺការខ្វះការសម្របសម្រួលលើកិច្ចខិតខំប្រឆាំងអំពើពុករលួយ។ ផ្នែកខ្លះនៃការសម្របសម្រួលនេះត្រូវបានដោះស្រាយដោយការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់សម្របសម្រួលសកម្មភាពប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងគណៈកម្មការសភាអចិន្ត្រៃយ៍ស្តីពីអំពើពុករលួយ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅក្នុងរបាយការណ៍របស់ខ្លួនជូនដល់រដ្ឋាភិបាល ស្តីពីការអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយថ្នាក់ជាតិ គណៈកម្មការអន្តរក្រសួងបានលើកឡើងថា ការរៀបចំរដ្ឋបាលនៃរចនាសម្ព័ន្ធឯកទេសសម្រាប់ប្រឆាំងអំពើពុករលួយគួរតែពង្រឹងបន្ថែមទៀត[៨]។

ប្រធានាធិបតីបានស្នើឡើងនូវលទ្ធភាពបង្កើតរចនាសម្ព័ន្ធឯករាជ្យថ្មីមួយ ឬសេវាសម្រាប់ប្រឆាំងអំពើពុករលួយ ដើម្បីបង្កើនទំនុកចិត្តពីសាធារណៈ ព្រមទាំងផ្តល់នូវប្រសិទ្ធភាពឱ្យកាន់តែល្អប្រសើរជាងនេះ ក្នុងការតាមដានអំពើពុករលួយរបស់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល និងអ្នកនយោបាយ[៩] - នេះជាអ្វីដែលយុទ្ធសាស្ត្រថ្នាក់ជាតិបច្ចុប្បន្ន មិនបានយល់ឃើញថាអាចដោះស្រាយបានគ្រប់ជ្រុងជ្រោយ (OSI ២០០២:៨២)។ ក៏ប៉ុន្តែ រដ្ឋាភិបាលហាក់បីដូចជាបានជ្រើសយកការពង្រឹងសមត្ថភាពប្រឆាំងអំពើពុករលួយនៅក្នុងស្ថាប័នដែលមានស្រាប់ជាជំនួសវិញ។ ការតែងតាំង Ombudsman ក៏អាចរួមចំណែកដល់ការទប់ស្កាត់អំពើពុករលួយផងដែរ។ បន្ថែមលើនេះទៀត តួនាទីរបស់ការិយាល័យសវនកម្មជាតិ NAO ក្នុងការប្រយុទ្ធប្រឆាំងទៅអំពើពុករលួយត្រូវបានពង្រឹងបន្ថែម ដោយផ្អែកទៅតាមវិធីសាស្ត្រទប់ស្កាត់ តម្លាភាពនៃការងារសវនកម្ម និងការចេញផ្សាយនូវលទ្ធផលនៃការធ្វើសវនកម្ម (EC ២០០៣:១១៤)។ ទោះបីជាយ៉ាងនេះក៏ដោយ គេបានអះអាងថា របាយការណ៍ និងអនុសាសន៍របស់ការិយាល័យសវនកម្មជាតិ NAO ត្រូវបានគេធ្វើព្រងើយកន្តើយជាខ្លាំង (OSI ២០០២:១០១)។

ការអនុម័តយុទ្ធសាស្ត្រជាតិ គឺជាវិធានការមួយសម្រាប់ដោះស្រាយការខ្វះកម្មវិធីសម្របសម្រួល និងទូលំទូលាយមួយ ដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ។ កង្វះយុទ្ធសាស្ត្របែបនេះត្រូវបានមើលឃើញថាជាបញ្ហារាំងស្ទះដ៏ធ្ងន់ធ្ងរចំពោះការដោះស្រាយបញ្ហាអំពើពុករលួយឱ្យមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រជាតិក៏បានសង្កត់ធ្ងន់ទៅលើការទប់ស្កាត់អំពើពុករលួយ ផ្ទុយពីកិច្ចខិតខំលើកមុនដែលបានផ្តោតជាពិសេសទៅលើការបង្ក្រាបអំពើពុករលួយ។ រីឯយុទ្ធសាស្ត្រថ្នាក់ជាតិ ក៏មិនឃើញមានដាក់បញ្ចូលនូវសមាសភាពសំខាន់ៗនៃការអប់រំពីអំពើពុករលួយ ឬពីការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុង GRECO ២០០២ ក្នុងរបាយការណ៍វាយតម្លៃស្តីពីប្រទេសប៊ុលហ្គារី (២០០២:១៩) ទេ។

ប្រទេសប៊ុលហ្គារីក៏បានបង្កើតប្រព័ន្ធព័ត៌មានរួមមួយសម្រាប់ប្រឆាំងនឹងបទឧក្រិដ្ឋ និងបង្កើតក្រុមប្រឹក្សាអង្កេតលើបទឧក្រិដ្ឋ ដើម្បីដោះស្រាយចំពោះកង្វល់ដែលទាក់ទងនឹងកង្វះព័ត៌មានទូទៅស្តីពីអំពើពុករលួយ ព្រមទាំងកង្វល់ទាក់ទងនឹងការស្រាវជ្រាវមិនបានគ្រប់គ្រាន់ស្តីពីអំពើពុករលួយ - ដែលប្រការទាំង ២ នេះមានលក្ខណៈចាំបាច់ដើម្បីបង្កើត និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការនានាដើម្បីទប់ស្កាត់ និងប្រឆាំងនឹងអំពើពុករលួយ (GRECO ២០០២:១៧-១៨ និង GRECO ២០០៤:២-៣)។

---

[៨] ដូចក្នុងការដកស្រង់ពី EU ២០០៣:១៩

[៩] សូមមើលបន្ថែមទៀតលើការបង្កើតស្ថាប័នប្រឆាំងអំពើពុករលួយថ្មីមួយនៅប្រទេសប៊ុលហ្គារីៈ តួនាទីរបស់ប្រធានាធិបតី និងការជជែកជាសាធារណៈ *http://www.csd.bg/news/acagensy_strenograma.doc*

ការព្រួយបារម្ភមួយទៀត ទាក់ទងនឹងសមត្ថភាពរបស់ប្រទេសប៊ុលហ្គារី ក្នុងការប្រឆាំងអំពើពុករលួយឱ្យមានប្រសិទ្ធភាព គឺដំណើរការនៃប្រព័ន្ធយុត្តិធម៌។ ឧបសគ្គមួយគឺកង្វះចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ដែលមានជំនាញក្នុងករណីអំពើពុករលួយ ព្រមជាមួយនិងកង្វះខាតជាទូទៅនូវធនធានមនុស្ស និងមូលនិធិនៅក្នុងប្រព័ន្ធយុត្តិធម៌។ លើសពីនេះទៀត ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានគេចាត់ទុកថាយឺតយ៉ាវ បណ្តាលឱ្យមានករណីនៃអំពីពុករលួយតិចតួចត្រូវបានវិនិច្ឆ័យទោស។ ថ្វីបើគេយល់ឃើញថា ប្រការនេះកើតឡើងដោយសារខ្វះធនធានគេបានសង្កត់ធ្ងន់ថា ការបង្កើនជំនាញស្តីពីអំពើពុករលួយក្នុងចំណោមមន្ត្រីអាជ្ញាធរស៊ើបអង្កេត នឹងអាចធ្វើឱ្យប្រសើរឡើងដល់ការស៊ើបអង្កេត និងដល់ការវិនិច្ឆ័យទោសករណីអំពើពុករលួយ។ នៅក្នុងរបាយការណ៍វាយតម្លៃស្តីពីប្រទេសប៊ុលហ្គារី ក្នុង GRECO ២០០២ គេបានផ្តល់អនុសាសន៍បន្ថែមទៀត ដោយស្នើឱ្យមាននាយកដ្ឋានជំនាញប្រឆាំងអំពើពុករលួយនៅក្នុងសេវាអយ្យការ ព្រមទាំងនៅក្នុងសេវាស៊ើបអង្កេតផងដែរ (២០០២:២០-២១)។ រដ្ឋាភិបាលបានចាត់វិធានការខ្លះលើការបង្កើតនាយកដ្ឋានជំនាញបែបហ្នឹង ព្រមទាំងផ្តល់ការបណ្តុះបណ្តាលបន្ថែមស្តីពីអំពើពុករលួយដល់ចៅក្រម ព្រះរាជអាជ្ញា និងចៅក្រម magistrates (GRECO ២០០៤:៥-៧)។ ឧបសគ្គបន្ថែមមួយទៀត គឺការខ្វះខាតការសម្របសម្រួលរវាងសេវាសេវាអយ្យការ និងសេវាស៊ើបអង្កេត ព្រមទាំងជាមួយស្ថាប័នអនុវត្តច្បាប់ផ្សេងទៀត (GRECO ២០០២:២០)។ ដូចបានលើកឡើងខាងលើ រដ្ឋាភិបាលបានចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួល រវាងស្ថាប័នស៊ើបអង្កេតជាច្រើន តាមរយៈការអនុម័តសេចក្តីណែនាំជាក់លាក់ជាច្រើន (GRECO ២០០៤:៦)។

ទោះបីជាយ៉ាងណាក៏ដោយ គួរកត់ចំណាំថា ប្រព័ន្ធយុត្តិធម៌ខ្លួនឯង ត្រូវបានគេយល់ឃើញថាកំពុងតែមានអំពើពុករលួយ ហើយមានជំហរមួយដែលថា កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ពិតជាមានសារៈសំខាន់ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ និងសម្រាប់ធ្វើឱ្យប្រព័ន្ធយុត្តិធម៌កាន់តែមានប្រសិទ្ធភាពក្នុងការប្រឆាំងនឹងអំពើពុករលួយនៅក្នុងសង្គម[១០]។

## ប្រភព


- Coalition ២០០០, របាយការណ៍ពីការប៉ាន់ប្រមាណអំពើពុករលួយ ២០០៣ *http://www.cds.bg/fileSrc.php?id=357*
- មណ្ឌលសិក្សាអំពីប្រជាធិបតេយ្យ CSD សង្ខេប No.5: ផ្លូវដល់វែងឆ្ងាយនៃការកើតឡើងនូវ Ombudsman: ប្រាំមួយខែក្រោយមក *http://www.cds.bg/artShow.php?id=4283*
- គណៈកម្មការអឺរ៉ុប របាយការណ៍ទៀងទាត់អំពីវិវឌ្ឍនភាពរបស់ប៊ុលហ្គារីចំពោះការចូលជាសមាជិក ២០០៣ *http://auropa.eu.int/comm/enlargement/report_2003/pdf/rr_bg_final.pdf*
- ទីភ្នាក់ងារស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ២០០៤, របាយការណ៍ប្រចាំឆ្នាំរបស់ទីភ្នាក់ងារស៊ើបអង្កេតផ្នែកហិរញ្ញវត្ថុ ២០០៣ *http://www.fia.minfin.bg/docs_en/fia_report2003.pdf*
- GRECO ២០០២ ការវាយតម្លៃលើកទីមួយ, របាយការណ៍អំពីការប្រតិបត្តិតាមរបស់ប៊ុលហ្គារី *http://unpan1.un.org/intradoc/groups/public/documents/untc/unpan009761.pdf*
- GRECO ២០០៤, First Evaluation Round ការវាយតម្លៃលើកទីមួយ របាយការណ៍អំពីការប្រតិបត្តិតាមរបស់ប៊ុលហ្គារី *http://greco.coe.int/evaluations/cylce1/GrecoRC-I(2004)3E-Bulgaria.pdf*
- យុទ្ធសាស្ត្រជាតិប្រឆាំងអំពើពុករលួយ ២០០១ *http://unpan1.un.org/intradoc/groups/public/documents/UNTC/UNPAN016837.pdf*
- វិទ្យាស្ថានសង្គមបើកចំហ ២០០២ ការពិនិត្យតាមដានដំណើរការចូល EU: អំពើពុករលួយ និងគោលនយោបាយប្រឆាំងអំពើពុករលួយ *http://www.eumap.org/reports/2002/corruption*
- Transparency International ២០០៤ របាយការណ៍ពិភពលោកអំពីអំពើពុករលួយ ២០០៤ *http://www.globalcorruption report.org/download.htm*


ព័ត៌មានក៏ត្រូវបានប្រមូលពីវេបសាយនៃស្ថាប័ននានាដែលបានរាយនាមខាងលើ។

[១០] សូមមើលឧទាហរណ៍ CSD ២០០៣ កម្មវិធីប្រឆាំងនឹងអំពើពុករលួយក្នុងប្រព័ន្ធតុលាការ *http://www.csd.bg/artshow.php?id=137*



# ក្រុងហុងកុង

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- នាយកដ្ឋានយុត្តិធម៌ *www.doj.gov.hk*
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ក្រមសីលធម៌ហុងកុង (HKEDC) *www.icac.org.kh/hkedc*
- គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) *www.icac.org.hk/eng/main*
- ការិយាល័យការពារប្រជាពលរដ្ឋ (Ombudsman) *www.ombudsman.gov.hk*

## បទបញ្ញត្តិចម្បង[១]

- ច្បាប់ស្តីពីសវនកម្ម (Cap. ១២២)
- ច្បាប់ស្តីពីការបោះឆ្នោត (អំពើពុករលួយ និងការប្រព្រឹត្តិខុសច្បាប់) (Cap. ៥៥៤)
- ច្បាប់ស្តីពីគណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) (Cap. ២០៤)
- ច្បាប់ស្តីពីការទប់ស្កាត់ការសូកប៉ាន់ (Cap. ២០១)
- ច្បាប់ស្តីពីគណៈកម្មការសេវាសាធារណៈ (Cap. ៩៣)
- ច្បាប់ស្តីពីការិយាល័យការពារប្រជាពលរដ្ឋ (Ombudsman) (OO) (Cap. ៣៩៧)

## សាវតា

ថ្វីបើបច្ចុប្បន្ននេះ យើងហាក់ដូចជានឹកមិនដល់ទាល់តែសោះថា អំពើពុករលួយធ្លាប់បានរីករាលដាលពេញក្រុងហុងកុង ក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ និងដើមទសវត្សរ៍ឆ្នាំ ១៩៧០។ ការសូកប៉ាន់ត្រូវបានចាត់ទុកថាជាអំពើអាក្រក់ដោយខានមិនបានមួយ និងជាមធ្យោបាយមួយ ដែលឱ្យអាចធ្វើអ្វីៗបាន។ នាយកដ្ឋានប៉ូលិសទទួលខុសត្រូវក្នុងការស៊ើបអង្កេតករណីអំពើពុករលួយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិទ្ធភាពរបស់ប៉ូលិសនៅមានកម្រិត ព្រោះមានអង្គការចាត់តាំងពុករលួយនៅគ្រប់ទិសទីក្នុងកងកម្លាំងប៉ូលិស ហើយការស៊ីសំណូកត្រូវបានក្លាយជាស្ថាប័នស្ទើរតែនៅគ្រប់រដ្ឋបាលក្រុងទាំងអស់។ ចំណុចរបត់មួយត្រូវបានសម្រេចជាដំបូងដោយសារតែរឿងអាស្រូវពីអំពើពុករលួយទាក់ទងទៅនឹងមន្ត្រីប៉ូលិសជាន់ខ្ពស់ម្នាក់។ ដោយសារតែសាវតានេះហើយបានជាគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) ត្រូវបានបង្កើតឡើងក្នុងខែកុម្ភៈ ឆ្នាំ១៩៧៤ ដើម្បីឆ្លើយតបទៅនឹងការទាមទាររបស់សាធារណជន ឱ្យចាត់ការលើសកម្មភាពប្រឆាំងនឹងអំពើពុករលួយដ៏ពាសវាលពាសកាលនេះ។ គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) មានភារកិច្ចធំៗ ២ ដើម្បីផ្តាច់ឫសនៃអំពើពុករលួយ និងកសាងឡើងវិញនូវទំនុកចិត្តរបស់សាធារណជនទៅលើរដ្ឋាភិបាល។

---

[១] ច្បាប់ទាំងអស់ អាចរកបានតាមរយៈ *http://www.legislation.gov.kh/eng/index.htm*
សូមមើលច្បាប់ ស្តីពីអង្គការចាត់តាំង និងបទល្មើសកម្រិតធ្ងន់ (ជំពូក ៤៥៥) បើចាប់អារម្មណ៍

ដើម្បីទទួលបានទំនុកចិត្តពីសំណាក់សាធារណជន គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) ត្រូវបានផ្តាច់ចេញពីអាជ្ញាធរស៊ីវិលទាំងអស់ និងទទួលខុសត្រូវដោយផ្ទាល់ចំពោះអភិបាលក្រុងហុងកុង។ ដើម្បីជំរុញឱ្យគណៈកម្មការនេះអាចដោះស្រាយដល់ប្រភពដើមនៃបញ្ហាបាន គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ (ICAC) បានទទួលភារកិច្ចឱ្យអនុវត្តយុទ្ធសាស្ត្រ ៣ មុខព្រួញ ក្នុងការប្រឆាំងអំពើពុករលួយគឺ ការស៊ើបអង្កេត ការទប់ស្កាត់ និងការអប់រំសាធារណជន។ ដើម្បីសម្រេចបាននូវគោលដៅ ដែលបានកំណត់ខាងលើ គណៈកម្មការនេះបានទទួលនូវសិទ្ធិអំណាច ព្រមទាំងធនធានគ្រប់គ្រាន់។សកម្មភាពអនុវត្តច្បាប់ដ៏តឹងរឹងលើរឿងដែលល្បីៗ អាចឱ្យសាធារណជនជឿជាក់ភ្លាមៗថា រដ្ឋាភិបាល និងគណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) កំពុងយកចិត្តទុកដាក់យ៉ាងហ្មត់ចត់លើអំពើពុករលួយ ដោយ ICAC បានខិតខំគ្រប់សកម្មភាពដើម្បីកម្ចាត់អំពើពុករលួយទាំងក្នុងវិស័យសាធារណៈ និងទាំងវិស័យឯកជន។ ដើម្បីជំរុញឱ្យមានវប្បធម៌ស្អាតស្អំ គណៈកម្មការបានចាប់ផ្តើមយុទ្ធនាការអប់រំសាធារណជន ក្នុងគោលបំណងដើម្បីពន្យល់ដល់ប្រជាជនថា អំពើពុករលួយគឺជារឿងអាក្រក់ ព្រមទាំងចុះបញ្ជីគាំទ្ររបស់ប្រជាជន ក្នុងការរាយការណ៍អំពីបុគ្គលពុករលួយនានា។

ក្នុងអំឡុងឆ្នាំ ១៩៧៧ គេយល់ឃើញថា អង្គការចាត់តាំងពុករលួយចម្បងៗត្រូវបានបំបែក។ ជាពិសេស គឺកិច្ចខំប្រឹងប្រែងផ្តាច់ឫសផ្តាច់គល់នៃអំពើពុករលួយនៅក្នុងកងកម្លាំងប៉ូលីស។ បន្ទាប់ពីទទួលបានជោគជ័យ ICAC ឥឡូវនេះមានលទ្ធភាពផ្តោតការយកចិត្តទុកដាក់ទៅលើការដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងវិស័យឯកជន។ ការផ្លាស់ប្តូរលក្ខណៈនៃអំពើពុករលួយ ត្រូវបានមើលឃើញតាមលក្ខណៈនៃរបាយការណ៍ចំនួន ៤.៣១០ច្បាប់ ស្តីពីអំពើពុករលួយដែល ICAC បានទទួលក្នុងឆ្នាំ ២០០៣ – គឺ ៥៧,៤% នៅក្នុងវិស័យឯកជន ២៣,៤% នៅក្នុងនាយកដ្ឋានរដ្ឋាភិបាល ១២,៣% នៅក្នុងប៉ូលីស និង ៦,៩% នៅក្នុងស្ថាប័នសាធារណៈ (ICAC ២០០៣:៣៥)។ ក្នុងឆ្នាំដដែលនេះ មនុស្ស ៤២១នាក់ ត្រូវបាននាំយកមកកាត់ទោសក្នុងរឿងកាត់ក្តីចំនួន ២០៧ ករណី ដោយមានអត្រានៃការជាប់ទោសចំនួន ៨៥% (ICAC ២០០៣:១២-១៣)។ ក្នុងឆ្នាំ ១៩៧៤ អំពើពុករលួយនៅក្នុងវិស័យសាធារណៈ មានចំនួនជាង ៨០% នៃចំនួនរបាយការណ៍ទាំងអស់ដែលគណៈកម្មការបានទទួល។

ការអភិវឌ្ឍថ្មីៗមួយចំនួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ បានរួមបញ្ចូលទាំងការពិនិត្យឡើងវិញលើសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ ICAC សម្រាប់ឆ្នាំ ១៩៩៤ ដែលត្រូវបានពិនិត្យចប់សព្វគ្រប់ក្នុងបរិបទនៃការផ្លាស់ប្តូរនយោបាយ និងបញ្ញត្តិសិទ្ធិមនុស្សរបស់ក្រុងហុងកុងឆ្នាំ ១៩៩៣។ គោលបំណងនៃការពិនិត្យឡើងវិញនេះ គឺដើម្បីធានាថា ICAC នៅតែមានប្រសិទ្ធភាពប្រឆាំងអំពើពុករលួយ ដោយខ្លួនឯងមិនមានពាក់ព័ន្ធនឹងអំពើពុករលួយ។ លទ្ធផលដែលបានពីការពិនិត្យឡើងវិញនេះ គឺការផ្លាស់ប្តូរដែលជារួមមាន ការត្រួតពិនិត្យពីខាងក្រៅកាន់តែច្រើនទៀត លើសិទ្ធិអំណាចស៊ើបអង្កេត ដីកាឆែកឆេរ ជាដើម ដែលឥឡូវនេះជាការទទួលខុសត្រូវរបស់តុលាការ មិនមែនរបស់ ICAC ទៀតទេ។ ក្នុងឆ្នាំ ១៩៩៥ សភាពាណិជ្ជកម្មធំៗចំនួន ៦ រួមជាមួយនឹង ICAC បានជួយបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍ក្រមសីលធម៌ហុងកុង (HKEDC) ដើម្បីលើកកម្ពស់ក្រមសីលធម៌ និងអភិបាលកិច្ចសាជីវកម្ម។ សព្វថ្ងៃនេះ របាយការណ៍ ១ ក្នុងចំណោម ១០ ស្តីពីអំពើពុករលួយនៅក្នុងវិស័យឯកជន ត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រងអាជីវកម្មជាន់ខ្ពស់[២]។

សព្វថ្ងៃនេះ ហុងកុងអាចគ្រប់គ្រងអំពើពុករលួយបាន ដោយប្រទេសហុងកុងបានជាប់ចំណាត់ថ្នាក់លេខ ១៥ ក្នុងចំណោមប្រទេសចំនួន ១៥៩ លើសន្ទស្សន៍ការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០០៥ ។ ខណៈដែលរដ្ឋាភិបាលមិនបានរំពឹងថានឹងអាចលុបបំបាត់អំពើពុករលួយបានទាំងស្រុងទេនោះ ការកែលម្អក្នុងវិស័យសច្ចធម៌កំពង់តែធ្វើឱ្យមានសង្ឃឹម។ ភាពស័ក្តិសិទ្ធិ និងភាពស្មោះត្រង់នៃសេវាសង្គម ត្រូវបានទទួលស្គាល់ដោយសហគមន៍ទូទាំងពិភពលោក ហើយអង្គការចាត់តាំងពុករលួយបានក្លាយទៅជាវត្ថុបុរាណ។ ការផ្លាស់ប្តូរអាកប្បកិរិយារបស់សាធារណជន ពីការទទួលសំណូកជាមធ្យោបាយចាំបាច់ក្នុងជីវិត ទៅជាការចូលរួមយ៉ាងសកម្មក្នុងការជួយនាំយកបុគ្គលពុករលួយទៅឱ្យតុលាការកាត់ទោស គឺសម្រេចបានតាមរយៈយុទ្ធនាការផ្សព្វផ្សាយ និងការទាក់ទងដោយផ្ទាល់ជាមួយសមាជិកនានានៃសហគមន៍។ ការទុកចិត្តលើ ICAC មានកម្រិតខ្ពស់ ដោយមានអ្នកឆ្លើយតបចំនួន ៩៨% សម្តែងការគាំទ្រដល់ការងាររបស់ ICAC។ សមាមាត្ររបស់អ្នកឆ្លើយតបដែលយល់ស្របថា ICAC មានភាពអព្យាក្រិត្យក្នុងការធ្វើការស៊ើបអង្កេតបានឡើងដល់កម្រិតដែលមិនធ្លាប់មានគឺ ៧៤,៦% ក្នុងឆ្នាំ ២០០០ កើនពី ៥៦,៤% ក្នុងឆ្នាំ ១៩៩៤។

---

[២] សម្រាប់ព័ត៌មានបន្ថែម ស្តីពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ក្រមសីលធម៌ហុងកុង សូមមើល *http://www.icac.org.hk/hkedc/eng/main2.asp*

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC)** ត្រូវបានបង្កើតឡើងនៅថ្ងៃ ១៥ កុម្ភៈ ១៩៧៤ ដោយគុណតម្លៃនៃផ្នែក ៣ នៃច្បាប់ ICAC ដែលជាស្ថាប័នចម្បងក្នុងការប្រឆាំងអំពើពុករលួយ ដោយប្រើវិធីសាស្ត្រ ៣ មុខព្រួញ គឺទប់ស្កាត់ ស៊ើបអង្កេត និងអប់រំសាធារណជន។ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (ICAC) មានស្នងការ ១រូប ជាប្រធាន ហើយនិងស្នងការរង ១រូប - ទាំង ២រូបនេះត្រូវបានតែងតាំងដោយប្រធានប្រតិបត្តិ (អនុផ្នែក ៥[៣] និងផ្នែក ៦ ច្បាប់ ICAC) និងមន្ត្រីនានាតាមការតែងតាំង។ ច្បាប់ ICAC ចែងពីធម្មនុញ្ញរបស់គណៈកម្មការ ហើយនិងចែងពីអាណត្តិការងាររបស់ ICAC ទៀតផងដែរ បើច្បាប់ ICAC រួមជាមួយគ្នានឹងច្បាប់ POBO។

ផ្នែក ៦នៃ ច្បាប់ ICAC ចែងថា ស្នងការទទួលខុសត្រូវណែនាំ និងគ្រប់គ្រងរដ្ឋបាលលើ ICAC ដោយគោរពតាមបញ្ជា និងការត្រួតពិនិត្យពីប្រធានប្រតិបត្តិ ។ លើសពីនេះទៀត ច្បាប់ ICAC ចែងថា ស្នងការមិនត្រូវគោរពតាមការណែនាំឬការគ្រប់គ្រងរបស់បុគ្គលណាមួយក្រៅពីប្រធានប្រតិបត្តិទេ។ ស្នងការមានសិទ្ធិអំណាចតែងតាំងមន្ត្រីនៅ ICAC (ផ្នែក ៨ ច្បាប់ ICAC)។ នៅក្នុងផ្នែក ១៧ នៃច្បាប់ ICAC ស្នងការត្រូវផ្ញើរបាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព ICAC ជូនប្រធានប្រតិបត្តិ។ ដោយយោងទៅតាមផ្នែក ៤ នៃច្បាប់ ICAC ការចំណាយរបស់គណៈកម្មការត្រូវទូទាត់ដោយនាយកដ្ឋានចំណូលទូទៅ គឺថា ICAC ទទួលធនធានពីរដ្ឋាភិបាល។ ICAC មានឯករាជភាពផ្នែករចនាសម្ព័ន្ធ បុគ្គលិក ហិរញ្ញវត្ថុ និងសិទ្ធិអំណាច។

ជាអង្គការ គណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយ ICAC មានការិយាល័យស្នងការ និងមាននាយកដ្ឋានបំពេញការងារ ៣ គឺ នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ និងនាយកដ្ឋានទំនាក់ទំនងសហគមន៍ - ដែលទទួលសេវាដោយផ្នែករដ្ឋបាលរបស់ខ្លួន។ ការបែងចែកការងាររវាងនាយកដ្ឋានទាំងនេះ គោរពតាមវិធីសាស្ត្រ ៣ មុខព្រួញរបស់ ICAC ក្នុងការប្រឆាំងនឹងអំពើពុករលួយ គឺការស៊ើបអង្កេត ការទប់ស្កាត់ និងការអប់រំ។

**នាយកដ្ឋានប្រតិបត្តិការ** គឺជាអាវុធសម្រាប់ធ្វើការស្រាវជ្រាវរបស់ ICAC ហើយជានាយកដ្ឋានធំជាងគេ។ កិច្ចប្រតិបត្តិការទាំងនោះរួមមានការស៊ើបអង្កេតលើសេវាអនុវត្តច្បាប់ សេវាសាធារណៈ ធនាគារ វិស័យឯកជន និងការបោះឆ្នោត។ ការក្លែងបន្លំ គឺជាការទទួលខុសត្រូវរបស់ប៉ូលីស ប៉ុន្តែការទទួលកម្រៃជើងសារខុសច្បាប់ គឺត្រូវដោះស្រាយដោយ ICAC។ ក្នុងស្មារតីនេះ ដោយអនុលោមតាមគុណតម្លៃផ្នែក ១០ (A ដល់ G) នៃច្បាប់ ICAC ប្រធាននៃនាយកដ្ឋានប្រតិបត្តិការ អាចផ្តល់សិទ្ធិដល់មន្ត្រីរបស់ខ្លួន ដើម្បីដាក់កំហិតលើចលនារបស់ជនជាប់សង្ស័យ ដើម្បីស៊ើបអង្កេតលើគណនីធានាគារ និងប្រអប់ដាក់លុយសន្សំ ដើម្បីដាក់កំហិតលើការលក់ដូរទ្រព្យធនរបស់ជនជាប់សង្ស័យ និងដើម្បីទាមទារឱ្យជនជាប់សង្ស័យផ្តល់ព័តិមានលម្អិតពីស្ថានភាពហិរញ្ញវត្ថុរបស់ខ្លួន។ ICAC អាចឃាត់ខ្លួន និងឃុំខ្លួន (ដោយមិនចាំបាច់មានដីកា) នៅក្នុងមជ្ឈមណ្ឌលរបស់ខ្លួនក្នុងរយៈពេល ៤៨ ម៉ោង (សម្រាប់បទល្មើសដែលចែងនៅក្នុងច្បាប់ ICAC និង POBO)។ នាយកដ្ឋាននេះក៏អាចប្រមូល និងរក្សាទុកភស្តុតាងសម្រាប់បទល្មើសបែបនេះដែរ។ ជាការម្តងម្កាល មន្ត្រី ICAC ចូលរួមក្នុងសកម្មភាពបង្កប់ផ្ទៃក្នុង។ កាលពីដើម ICAC ត្រូវបានអនុញ្ញាតឱ្យចេញដីកាឆែកឆេរ ប៉ុន្តែឥឡូវនេះ វាក្លាយទៅជាការទទួលខុសត្រូវទោលរបស់តុលាការវិញហើយ។

**នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ** គឺជាអង្គភាពតូចជាងគេបង្អស់នៅក្នុង ICAC ។ តួនាទីរបស់នាយកដ្ឋានគឺ ដើម្បីពិនិត្យលើការអនុវត្ត និងនីតិវិធីរបស់នាយកដ្ឋានរដ្ឋាភិបាល និង ស្ថាប័នសាធារណៈ ចង្អុលបង្ហាញចន្លោះប្រហោងដែលអាចឱ្យប្រព្រឹត្តអំពើពុករលួយបាន និងផ្តល់អនុសាសន៍ធ្វើកំណែទម្រង់វិធីសាស្ត្រការងារ ដើម្បីកាត់បន្ថយសក្តានុពលនៃការប្រព្រឹត្តអំពើពុករលួយ។ ការទប់ស្កាត់ត្រូវបានអះអាងថា អស់ចំណាយតិចជាងការកាត់ទោស។ ការទប់ស្កាត់ មានរួមទាំងការផ្តល់អនុសាសន៍ទៅលើការប្រព្រឹត្តិល្អក្នុងអាជីវកម្ម ដើម្បីកាត់បន្ថយចំណង់ចិត្ត និងហានិភ័យ។ អនុសាសន៍គឺជាការតម្រូវឱ្យមន្ត្រីសាធារណៈអនុវត្តតាម និងជាការណែនាំសម្រាប់អាជីវកម្មឯកជន។ គេបានផ្តោតការយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរប្រព័ន្ធជាជាងផ្លាស់ប្តូរមនុស្ស។ ដើម្បីទិសដៅនេះ អ្នកជំនាញទប់ស្កាត់អំពើពុករលួយត្រូវបានបញ្ជូនទៅនាយកដ្ឋានផ្សេងៗ ដើម្បីពិនិត្យពីនីតិវិធី និងការអនុវត្ត ក្នុងគោលបំណងដកចេញនូវចន្លោះប្រហោងទាំងអស់ ដែលអាចឱ្យប្រព្រឹត្តអំពើពុករលួយបាន។ ជំនួយបច្ចេកទេសក៏ត្រូវបានផ្តល់ជូននៅពេលណាចាំបាច់ដែរ ដើម្បីជួយនាយកដ្ឋានឱ្យបង្កើតក្រុម និងមាគ៌ាណែនាំ ស្តីពីការ

ប្រតិបត្តិរបស់បុគ្គលិក។ នាយកដ្ឋានក៏ចូលរួមតាំងពីតំណាក់កាលដំបូងក្នុងការបង្កើតគោលនយោបាយ និងបទបញ្ញត្តិថ្មីៗ ដើម្បីបិទចោលឱ្យអស់នូវឱកាសប្រព្រឹត្តអំពើពុករលួយ។

**នាយកដ្ឋានទំនាក់ទំនងសហគមន៍** មាន ២ផ្នែក ដែលមួយត្រូវទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងមួយទៀតទំនាក់ទំនងជាមួយសាធារណជន។ នាយកដ្ឋាននេះទទួលខុសត្រូវអប់រំសាធារណជនអំពីឥទ្ធិពលអាក្រក់នៃអំពើពុករលួយ និងដើម្បីកៀងគរការជួយគាំទ្រពីសាធារណជនទៅលើ ICAC។ នាយកដ្ឋាននេះ អនុវត្តកម្មវិធីអប់រំយ៉ាងសកម្មនៅក្នុងសហគមន៍។ រៀងរាល់ឆ្នាំ បុគ្គលិកនាយកដ្ឋានជួបជាមួយអ្នកគ្រប់គ្រងផ្នែកអាជីវកម្ម នាយកសាលា គ្រូបង្រៀន និងសិស្សថ្នាក់មធ្យមសិក្សា និងឧត្តមសិក្សា បុគ្គលិករាជការ និងតំណាងអង្គការនៅក្នុងប្រទេសចិន ដើម្បីអប់រំពួកគេឱ្យយល់ពីការបង់ខាតលើអំពើពុករលួយ បញ្ញត្តិច្បាប់ប្រឆាំងការសូកប៉ាន់ ជាពិសេសករណីដែលពាក់ព័ន្ធលើរឿងពីមុនៗ ទណ្ឌកម្ម និងផលវិបាកនៃអំពើពុករលួយ។ ជោគជ័យនៃកិច្ចខិតខំទាំងនេះពឹងផ្អែកមួយផ្នែកលើករណីជោគជ័យក្នុងតុលាការ និងការផ្សព្វផ្សាយអំពីជោគជ័យទាំងនោះ ដែលនឹងផ្តល់ឱ្យនូវការគំរាមជាក់ស្តែងចេញពីការកាត់ទោស។ សិក្ខាសាលា កម្មវិធីបណ្តុះបណ្តាល និងកម្មវិធីការងារផ្សេងៗទៀតត្រូវបានរៀបចំឡើង ដើម្បីឈានចូលទៅដល់គោលដៅ និងចែកជូននូវកម្រងឯកសារស្តីពីការទប់ស្កាត់។ នាយកដ្ឋាននេះបានបង្កឱ្យមានការបដិវត្តមួយក្នុងចំណោមប្រជាជនទូទៅចំពោះអំពើពុករលួយ។

ឧបករណ៍សំខាន់របស់ ICAC ក្នុងការប្រឆាំងអំពើពុករលួយ មាននៅក្នុងផ្នែក ១០ នៃ POBO – ស្តីអំពីកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលមិនអាចពន្យល់បាន ដែលចែងថា បុគ្គលម្នាក់ៗដែលមានកម្រិតជីវភាពរស់នៅ ឬមានធនធានហិរញ្ញវត្ថុហួសពីកម្រិតនៃប្រាក់ចំណូល និងមិនអាចផ្តល់ការពន្យល់ច្បាស់លាស់បាន ពីរបៀបដែលខ្លួនអាចរក្សាកម្រិតជីវភាពរស់នៅបែបហ្នឹង ឬរបៀបដែលខ្លួនទទួលធនធានហិរញ្ញវត្ថុខុសច្បាប់ត្រូវចាត់ទុកថាជាបទល្មើសមួយ។

ICAC ប្រើប្រព័ន្ធផ្សព្វផ្សាយដើម្បីធ្វើឱ្យមនុស្សញញើត និងដើម្បីធ្វើការអប់រំ។ កម្មវិធីផ្សព្វផ្សាយដើម្បីជាប្រយោជន៍ដល់សាធារណជនត្រូវបានធ្វើឡើងតាមទូរទស្សន៍ និងវិទ្យុ ដោយពន្យល់ពីកិច្ចខិតខំរបស់ ICAC ដោយមានប្រធានបទសំខាន់ ៣ គឺ អំពាវនាវដល់សាធារណជនឱ្យរាយការណ៍ពីអំពើពុករលួយ ព្រមានថា ការប្រព្រឹត្តិអំពើពុករលួយនឹងត្រូវបានរកឃើញ ហើយនិងផលវិបាកធ្ងន់ធ្ងរអាចនឹងកើតមាន និងអង្វរកឱ្យមានភាពស្មោះត្រង់ដើម្បីអត្ថប្រយោជន៍របស់សង្គមជាតិ។ កម្រងឯកសារសម្រាប់អប់រំក៏ត្រូវបានផ្តល់នៅតាមសាលារៀនផងដែរ។

## ការរៀបចំកិច្ចប្រតិបត្តិការ

ICAC គឺជាស្ថាប័នចម្បងដែលទទួលខុសត្រូវប្រឆាំងនឹងអំពើពុករលួយ និងមានសិទ្ធិអំណាចដ៏ទូលំទូលាយ ដើម្បីជំរុញឱ្យគណៈកម្មការនេះបំពេញអាណត្តិការងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព។ ដោយសារតែ ICAC មានសិទ្ធិអំណាចស៊ើបអង្កេតដ៏ទូលំទូលាយនេះហើយ បានជាគេត្រូវបង្កើតឱ្យមានប្រព័ន្ធត្រួតពិនិត្យគ្នាទៅវិញទៅមកមួយ ដើម្បីទប់ស្កាត់កុំឱ្យសិទ្ធិអំណាចទាំងនេះត្រូវបានគេប្រើដោយរំលោភបំពាន។

ដើម្បីធានាសច្ចធម៌របស់គណៈកម្មការនេះ សកម្មភាពរបស់វាត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដោយគណៈកម្មាធិការឯករាជ្យចំនួន ៤ ដែលបង្កើតឡើងដោយប្រជាពលរដ្ឋពីគ្រប់ផ្នែកនៃសហគមន៍ ដែលតែងតាំងដោយប្រធានប្រតិបត្តិ។ គណៈកម្មាធិការទាំងនេះទទួលរបាយការណ៍ និងពាក្យបណ្តឹង ហើយតាមមើលការងាររបស់ ICAC ដើម្បីធានាថា គណៈកម្មការ ICAC នេះមិនរំលោភលើសិទ្ធិអំណាចរបស់ខ្លួន ឬមិនក្លាយជាពុករលួយ។ គណៈកម្មាធិការទាំងនេះ រួមមាន:

- **គណៈកម្មាធិការប្រឹក្សាពីអំពើពុករលួយ** ដែលពិនិត្យលើទិសដៅទូទៅរបស់ ICAC និង ផ្តល់ឱវាទ ស្តីពីបញ្ហានានាដែលទាក់ទងនឹងគោលនយោបាយ។
- **គណៈកម្មាធិការពិនិត្យឡើងវិញលើការប្រតិបត្តិ** ដែលពិនិត្យលើផ្នែកស៊ើបអង្កេតរបស់ ICAC។
- **គណៈកម្មាធិការប្រឹក្សាពីការទប់ស្កាត់អំពើពុករលួយ** ដែលផ្តល់ឱវាទអំពីអាទិភាពសម្រាប់ធ្វើការសិក្សាស្តីពីការទប់ស្កាត់អំពើពុករលួយ និងពិនិត្យមើលរបាយការណ៍នៃការសិក្សាទាំងអស់។

- **គណៈកម្មាធិការប្រជាពលរដ្ឋប្រឹក្សាលើទំនាក់ទំនងសហគមន៍** ដែលផ្តល់ឱវាទដល់ ICAC ស្តីពីយុទ្ធសាស្រ្ត អប់រំដល់សាធារណជន និងចុះបញ្ជីការជួយគាំទ្ររបស់ពួកគេ។

មានយន្តការទទួលខុសត្រូវ ១ ទៀតគឺ **គណៈកម្មាធិការទទួលពាក្យបណ្តឹង ICAC ឯករាជ្យ** - ដឹកនាំដោយសមាជិកក្រុមប្រឹក្សាប្រតិបត្តិ ១រូប ដែលទទួលតាមដាន និងពិនិត្យឡើងវិញលើរាល់ពាក្យបណ្តឹងទាំងអស់ដែលប្តឹងពី ICAC ។

ICAC មិនមានអំណាចធ្វើបណ្តឹងអាជ្ញាលើករណីពុករលួយទេ។ សិទ្ធិអំណាចដើម្បីធ្វើបណ្តឹងអាជ្ញា បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត គឺជាការទទួលខុសត្រូវរបស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ដើម្បីធានាមិនឱ្យមានករណីណាឡើងទៅដល់តុលាការ ដោយសារតែការវិនិច្ឆ័យរបស់ ICAC តែប៉ុណ្ណោះ។ រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ដឹកនាំក្រសួងយុត្តិធម៌ ដែលទទួលខុសត្រូវលើដំណើរការកាត់ទោសបទព្រហ្មទណ្ឌ។ ក្នុងការបំពេញមុខងារនេះ ឯករាជភាពរបស់ក្រសួងនេះត្រូវបានធានាជាដរាប ដោយគុណតម្លៃនៃមាត្រា ៦៣ នៃច្បាប់ជាមូលដ្ឋានដែលចែងថា ក្រសួងយុត្តិធម៌ "ត្រូវត្រួតពិនិត្យបណ្តឹងអាជ្ញាលើបទព្រហ្មទណ្ឌដោយមិនមានការជ្រៀតជ្រែក"។ នៅក្នុងក្រសួងយុត្តិធម៌ នាយកដ្ឋានអយ្យការដែលដឹកនាំដោយប្រធាននាយកដ្ឋានអយ្យការសាធារណៈមានតួនាទីដាក់បណ្តឹងអាជ្ញាសម្រាប់តុលាការកាត់ក្តី និងប្តឹងឧទ្ធរណ៍តាងនាមឱ្យរដ្ឋមានតួនាទីផ្តល់ការណែនាំផ្នែកច្បាប់ដល់ទីភ្នាក់ងារអនុវត្តន៍ច្បាប់ដោយយោងតាមការស៊ើបអង្កេតរបស់ខ្លួន ហើយជាទូទៅ តាងនាមឱ្យរដ្ឋមន្រ្តីក្រសួងយុត្តិធម៌ អនុវត្តការងារតាមឆន្ទានុសិទ្ធិខ្លួន ថាតើត្រូវឬមិនត្រូវធ្វើបណ្តឹងអាជ្ញាដើម្បីកាត់ក្តីករណីព្រហ្មទណ្ឌ។

**ការិយាល័យ Ombudsman** - ដឹកនាំដោយ Ombudsman ដែលត្រូវបានតែងតាំងដោយប្រធានប្រតិបត្តិ (អនុផ្នែក ៣[៣]OO)-មានតួនាទីធានាថាសាធារណជន ត្រូវបានបម្រើដោយរដ្ឋបាលសាធារណៈប្រកបដោយយុត្តិធម៌ និងប្រសិទ្ធភាព ដែលមានការប្តេជ្ញាចិត្តទទួលខុសត្រូវ ប្តេជ្ញាប្រកាន់ចិត្តទូលាយ និងប្តេជ្ញាផ្តល់សេវាកម្មប្រកបដោយគុណភាព។ ប្រការនេះអាចសម្រេចបានតាមរយៈការស៊ើបអង្កេតដោយឯករាជ្យ និងដោយមិនលំអៀង ដើម្បីឆ្លើយតបចំពោះការកើតទុក្ខមិនសុខចិត្ត និងដោះស្រាយបញ្ហាដែលកើតឡើងពីរដ្ឋបាលមិនល្អនៅក្នុងវិស័យសាធារណៈ និងធ្វើឱ្យមានការកែលម្អគុណភាព និងកែលម្អស្តង់ដារនៃរដ្ឋបាលសាធារណៈ ព្រមទាំងលើកកម្ពស់ភាពយុត្តិធម៌នៅក្នុងរដ្ឋបាលនេះ។ មុខងាររបស់ការិយាល័យ Ombudsman គឺដើម្បីធានាថាៈ

- បញ្ហានៃការិយាល័យធិបតេយ្យមិនរំខានដល់សមធម៌ផ្នែករដ្ឋបាល។
- សាធារណជនអាចជួបអាជ្ញាធរសាធារណៈបានជានិច្ច។
- ការរំលោភបំពានក្នុងការប្រើសិទ្ធិអំណាច ត្រូវបានទប់ស្កាត់។
- កំហុសឆ្គងត្រូវបានកែតម្រូវ។
- នៅពេលមន្រ្តីសាធារណៈ ត្រូវបានចោទប្រកាន់ដោយអយុត្តិធម៌ ការពិតត្រូវតែរកឱ្យឃើញ។
- សិទ្ធិមនុស្សត្រូវបានការពារ។ ហើយនិង
- វិស័យសាធារណៈ បន្តកែលម្អគុណភាព និងភាពស័ក្តិសិទ្ធិ។

## មេរៀនដែលទទួលបាន

ជោគជ័យកម្រិតខ្ពស់របស់ ICAC ជាទូទៅ គឺកើតឡើងដោយសារៈ

- ឆន្ទៈនយោបាយដែលបានបង្ហាញឱ្យឃើញ ក្នុងចំណោមប្រការផ្សេងៗទៀត ដោយសារការផ្តល់ឱ្យ ICAC នូវសិទ្ធិអំណាចផ្នែកច្បាប់ និងធនធានគ្រប់គ្រាន់ ។
- ឯករាជភាពរបស់ ICAC។
- សិទ្ធិអំណាចរបស់ស្នងការ ក្នុងការតែងតាំង គ្រប់គ្រង និងដកបុគ្គលិកចេញដោយមិនចាំបាច់ពន្យល់។
- វត្តមាននៃបទបញ្ញត្តិសមស្របប្រឆាំងនឹងអំពើពុករលួយ ដែលត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។

- ការផ្សព្វផ្សាយជាសាធារណៈអំពីការកាត់ទោសអំពើពុករលួយ ។
- ច្បាប់ដែលដាក់កាតព្វកិច្ចឱ្យមន្ត្រីសាធារណៈប្រកាសពីទ្រព្យសម្បត្តិ និងប្រភពមូលនិធិរបស់ខ្លួន នៅពេលដែលត្រូវបានសួរ ។
- វិធីសាស្ត្រទូលំទូលាយក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ តាមរយៈយុទ្ធសាស្ត្រ ៣ មុខព្រួញ គឺស៊ើបអង្កេត ទប់ស្កាត់ និងអប់រំសាធារណជន ។
- ការគាំទ្រពីសាធារណជន ។ ហើយនិង
- នីតិរដ្ឋ ។

បើនិយាយឱ្យចំៗជាងនេះទៀតគឺថា សារៈសំខាន់បំផុតក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺចាំបាច់ត្រូវ**ធ្វើឱ្យមានកិច្ចសហការ និងការទុកចិត្តពីសាធារណជន** ។ ការផ្លាស់ប្តូរអាកប្បកិរិយារបស់សាធារណជនពីការមានអធ្យាស្រ័យទៅជាការមិនអធ្យាស្រ័យដាច់ខាតចំពោះអំពើពុករលួយ គឺជាដំណើរការដ៏យឺតៗ និងប្រកបដោយការឈឺចាប់ ដែលពេលខ្លះមានជោគជ័យ ហើយពេលខ្លះទៀតមិនមានជោគជ័យ ។

**ការកត់សម្គាល់របស់សាធារណជនចំពោះអំពើពុករលួយ**គឺជាការចាំបាច់ ដែលទាមទារឱ្យមានយុទ្ធនាការអប់រំប្រកបដោយនិរន្តរភាពនៅតាមសហគមន៍ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈ ។ ត្រូវធ្វើឱ្យប្រជាជនយល់ច្បាស់ថា អំពើពុករលួយអាចបង្កឱ្យមានផលវិបាកច្រើនប្រសិនបើទុកឱ្យមានតទៅទៀត ។ ត្រូវតែធ្វើឱ្យពួកគេមានជំនឿថា ប្រជាពលរដ្ឋសាមញ្ញគ្រប់រូបស្ថិតនៅក្នុងតួនាទីមួយដើម្បីធ្វើអ្វីមួយអំពីរឿងពុករលួយនេះ សម្រាប់ជាប្រយោជន៍ផ្ទាល់របស់ពួកគេ និងសម្រាប់ជាប្រយោជន៍ដល់សង្គម ។ ត្រូវបង្ហាញពួកគេឱ្យឃើញជាក់ច្បាស់ថា អំពើពុករលួយបង្កឱ្យមានតែបទឧក្រិដ្ឋថែមទៀត ដែលប៉ះពាល់ដល់ការរីកចម្រើន និងប៉ះពាល់ដល់សុខមាលភាពសេដ្ឋកិច្ចរបស់ប្រជាជន ។ ដូច្នេះ ICAC បានចេញសេចក្តីប្រកាសសម្រាប់ទាក់ទាញចំណាប់អារម្មណ៍ពីសាធារណជន ដើម្បីផ្សាយយ៉ាងសកម្មជូនសាធារណជនជ្រាបអំពីវប្បធម៌ស្អាតស្អំ និងសុចរិតភាព ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការបែងចែកធនធានអប់រំមួយចំនួនធំ ឆ្ពោះទៅរកការបង្កើតភាពស្អាតស្អំ និងភាពស្មោះត្រង់ក្នុងចំណោមយុវជន ដើម្បីឱ្យប្រាកដថា មនុស្សជំនាន់ក្រោយយល់ដឹងពីតម្រូវការបន្តកិច្ចខិតខំប្រឆាំងនឹងអំពើពុករលួយ ។

ភាពភ័យខ្លាចការសងសឹកបានបង្អាក់ទឹកចិត្តប្រជាជនមិនឱ្យរាយការណ៍ពីអំពើពុករលួយ ដែលចាំបាច់ត្រូវតែឱ្យមនុស្សរាយការណ៍ជាសម្ងាត់ ព្រមទាំងត្រូវឱ្យមាននីតិការពារសាក្សី ។ ICAC បានខិតខំយ៉ាងពេញសមត្ថភាពក្នុងការធានាមិនឱ្យមានបុគ្គលណាម្នាក់ទទួលរងគ្រោះដោយសាររាយការណ៍ពីអំពើពុករលួយ ។ ដំបូង ICAC មានគោលការណ៍ទូទៅថា ត្រូវតែធ្វើការស៊ើបអង្កេតរាល់របាយការណ៍ចោទប្រកាន់ពីអំពើពុករលួយ ។ ទី២ ICAC បានអនុម័តគោលការណ៍រក្សាការសម្ងាត់ ចំពោះគ្រប់របាយការណ៍ស្តីពីអំពើពុករលួយទាំងអស់ ។ បើមិនទាន់បានផ្តល់ដីកាឆែកឆេរ ឬមិនទាន់ចោទប្រកាន់ ឬចាប់ខ្លួនជនណាម្នាក់ទេ នោះគឺជាបទល្មើសមួយរបស់បុគ្គលិក ICAC ប្រសិនបើបុគ្គលិកនោះនិយាយប្រាប់គេពីឈ្មោះនៃអ្នកដែលត្រូវបានស៊ើបអង្កេត ។ ទី៣ សម្រាប់ករណីដែលមានវេយិទភាពខ្ពស់ (គឺមានភាពរសើបខ្លាំង) ត្រូវមានកម្មវិធីទូលំទូលាយមួយសម្រាប់**ការពារដល់សាក្សី** ហើយបើក្នុងករណីធ្ងន់ធ្ងរបំផុតមែនទែន ជំរុញឱ្យសាក្សីផ្លាស់ប្តូរអត្តសញ្ញាណ និងឱ្យតាំងលំនៅថ្មី ។ បន្តិចម្តងៗប្រការនេះបានបណ្តាលឱ្យមានការរាយការណ៍ពីអំពើពុករលួយដោយអនាមិកកាន់តែតិចឡើងចាប់ពី ៦៥% ក្នុងឆ្នាំ ១៩៧៤ ចុះដល់ ៣០% ក្នុងឆ្នាំ ២000 ។

ICAC ក៏បានដឹងតាំងពីតំណាក់ដំបូងដែលថា **ការសហការជាដៃគូជាមួយប្រព័ន្ធផ្សព្វផ្សាយ**មានលក្ខណៈចាំបាច់ណាស់ ។ ប្រព័ន្ធផ្សព្វផ្សាយគឺជាដៃគូដ៏មានអំណាចមិនអាចផ្តាច់បាន ក្នុងការផ្សព្វផ្សាយសារប្រឆាំងនឹងអំពើពុករលួយ ។

ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមិនបានកាត់បន្ថយនូវតម្រូវការដែលត្រូវ**ជួបប្រជាជនដោយផ្ទាល់ទេ** ។ ការជួបដោយផ្ទាល់គឺត្រូវបានចាត់ទុកថាមានសារៈសំខាន់សម្រាប់ ICAC ព្រោះវាពន្យល់ពីគោលដៅ និងបេសកកម្មរបស់គណៈកម្មការ ហើយទទួលយោបល់កែលម្អលើការងាររបស់ខ្លួន ។ សម្រាប់គោលបំណងនេះ ICAC ប្រើប្រាស់បណ្តាញយុទ្ធសាស្ត្រនៃការិយាល័យស្រុកថ្នាក់តំបន់ ដើម្បីរក្សាការជួបដោយផ្ទាល់ជាមួយសមាជិកនានានៅក្នុងសហគមន៍ ។ ការិយាល័យទាំងនេះមានមុខងារចម្បង ២គឺ ដើរតួជាចំណុចបង្គោលសម្រាប់ទាក់ទងជាមួយអ្នកដឹកនាំសហគមន៍ និងអង្គការដែលមន្ត្រីថ្នាក់តំបន់របស់ ICAC បានរៀបចំសកម្មភាពមួយចំនួនជាមួយគ្នា ក្នុងការផ្សព្វផ្សាយ

នូវសារស្តីពីការប្រឆាំងនឹងអំពើពុករលួយ និងកំពុងអនុវត្តដោយបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលដើម្បីចែកចាយនូវសាររបស់ ICAC ដល់ផ្នែកផ្សេងៗនៅក្នុងសហគមន៍ ។ ការិយាល័យនេះ ក៏បម្រើជាមជ្ឈមណ្ឌលទទួលរបាយការណ៍ដែលសាធារណជនទូទៅអាចដើរចូល និងដាក់ពាក្យបណ្តឹងអំពីអំពើពុករលួយ ។ បទពិសោធន៍បានបង្ហាញថាប្រជាជនមានអារម្មណ៍ងាយស្រួលក្នុងការផ្តល់ព័ត៌មាននៅក្នុងស្ថានភាពមិនសូវជាផ្លូវការបែបនេះ ។

បទពិសោធន៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្រុងហុងកុង បានបង្ហាញថា **ការទប់ស្កាត់អំពើពុករលួយគឺជាសមាសភាពដ៏សំខាន់នៃយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ** ។ ការទប់ស្កាត់ ក៏ត្រូវបានគេចាត់ទុកថាអស់ចំណាយតិចជាងចំណាយលើការអនុវត្ត ។ ទាក់ទងទៅនឹងចំណុចនេះ ICAC ក៏បាននិងកំពុងផ្តល់ជំនួយផងដែរ ដល់វិស័យសាធារណៈ និងវិស័យឯកជនក្នុង**ការអភិវឌ្ឍក្រមសីលធម៌** ។

សក្ខីភាពបានបង្ហាញឱ្យឃើញផងដែរថា **ការចាត់ទុកអំពើពុករលួយថាជាបទឧក្រិដ្ឋកម្រិតខ្ពស់** ដោយសង្កត់ធ្ងន់លើ**ការធានាឱ្យមានការដាក់ទោសករណីនៃអំពើពុករលួយ គឺមានសារៈសំខាន់ណាស់** ។ ការដាក់ទោសបែបនេះត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងត្រូវឱ្យជ្រួតជ្រាបដល់ស្រទាប់មហាជនទូទៅ ។ **ក៏ប៉ុន្តែ ការកាត់ក្តីសម្រាប់បទល្មើសតូចតាចមានចំណាយខ្ពស់** ហើយបទពិសោធរបស់ ICAC បានបង្ហាញថា **ការព្រមានចំពោះរឿងតូចតាច ដែលជនល្មើសយល់ព្រមទទួលដោយពេញលេញ ត្រូវបានមើលឃើញថាជាការចំណាយដែលមានប្រសិទ្ធភាពខ្ពស់** ដោយជនល្មើសដឹងថា ខ្លួននឹងត្រូវបានគេឃ្លាំមើលយ៉ាងជិតស្និទ្ធ បន្ទាប់ពីត្រូវបានព្រមាន ហើយមានតិចតួចណាស់ដែលបានប្រព្រឹត្តបទល្មើសទៀត ។

ចំពោះសិទ្ធិអំណាចស៊ើបអង្កេតដ៏ទូលំទូលាយរបស់ ICAC គឺអាចមានសក្តានុពលនៃការប្រើសិទ្ធិដោយបំពាន ។ ដោយសារហេតុនេះហើយ បានជា**ចាំបាច់ត្រូវតែមានប្រព័ន្ធមួយដ៏មានប្រសិទ្ធភាពក្នុងការពិនិត្យមើលគ្នាទៅវិញទៅមក** ។

## ប្រភព


- ការិយាល័យ អ.ស.ប អំពីឧក្រិដ្ឋកម្មនិងគ្រឿងញៀន កម្មវិធីពិភពលោកប្រឆាំងអំពើពុករលួយ កម្រងឧបករណ៍ប្រឆាំងអំពើពុករលួយរបស់អ.ស.ប្បការបោះពុម្ពផ្សាយទី ៣ ក្រុងវីយែន ខែកញ្ញា ២០០៤ *http://www.unodc.org/unodc/en/corruption_toolkit.html*
- ICAC ២០០៣ របាយការណ៍ប្រចាំឆ្នាំ *http://www.icac.org.hk/eng/0/1/10/16.html*
- Osborne, D., and Lai, A. ឯកសារដែលត្រូវបានបង្ហាញក្នុងអង្គប្រជុំអ្នកជំនាញរបស់អ.ស.ប អំពីការលម្អិតឧបករណ៍ប្រឆាំងអំពើពុករលួយ ក្រុងវីយែន ១៣-១៤ ខែមេសា ២០០១ ។
- Lai, A. ស្នងការ គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ ហុងកុង តំបន់រដ្ឋបាលពិសេសរបស់ប្រទេសចិន
- Quah, J. ការបង្ក្រាបអំពើពុករលួយនៅអាស៊ី ការសិក្សាប្រៀបធៀបអំពីប្រទេសចំនួនប្រាំមួយ Eastern Universities Press, 2003 ។


ព័ត៌មានក៏ត្រូវបានប្រមូលពីវេបសាយនៃស្ថាប័ននានាដែលបានរាយនាមខាងលើ ។

# ប្រទេសឥណ្ឌូនេស៊ី



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- អង្គភាពសវនកម្មនៃសាធារណរដ្ឋឥណ្ឌូនេស៊ី (BPK) *www.bpk.go.id/english/english.htm*
- គណៈកម្មការលុបបំបាត់អំពើពុករលួយ (KPK) *www.kpk.go.index/php?/idunit=6*
- គណៈកម្មការអំប៊ុដស៍មែនជាតិ (KON) *www.ombudsman.or.id*
- ស្ថាប័នអយ្យការសាធារណៈ

## បទបញ្ញត្តិចម្បង

- ច្បាប់លេខ ១៥ ឆ្នាំ ២០០២ ស្តីពីការលុបបំបាត់អំពើលាងលុយកខ្វក់[១]
- ច្បាប់លេខ ២៨ ឆ្នាំ ១៩៩៩ ស្តីពីមន្ត្រីប្រតិបត្តិរបស់រដ្ឋាភិបាលដែលស្អាតស្អំ គ្មានអំពើពុករលួយ គ្មានការឃុបឃិត និងគ្មានបក្សពួកនិយម ។[២]
- ច្បាប់លេខ ៣០ ឆ្នាំ ២០០២ ស្តីពីគណៈកម្មការដើម្បីលុបបំបាត់អំពើពុករលួយ (Law 30/2002) *http://www1.oecd.org/daf/ASIAcom/pdf.indonesia_302002_KPK.pdf*
- ច្បាប់លេខ ៣១ ឆ្នាំ ១៩៩៩ ស្តីពីការលុបបំបាត់អំពើពុករលួយ (Law 31/1999)[៣] *http://www.hamline.edu/apakabard/basisdata/2000/03/13/0022/html*

## សាវតា

ចាប់តាំងពីការដួលរលំរបបស៊ូហាតូក្នុងឆ្នាំ ១៩៩៧ រដ្ឋាភិបាលឥណ្ឌូនេស៊ីបានប្រកាសម្តងហើយម្តងទៀត ពីការប្តេជ្ញារបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ហើយបានអនុម័តវិធានការច្បាប់មួយចំនួនដើម្បីដោះស្រាយបញ្ហានេះ ។ វិធានការទាំងនោះរួមមាន ច្បាប់ស្តីពីរដ្ឋាភិបាលស្អាតស្អំ ច្បាប់ប្រឆាំងអំពើលាងលុយកខ្វក់ និងច្បាប់ប្រឆាំងអំពើពុករលួយ (ដូចមានរាយឈ្មោះខាងលើ) ដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ដើម្បីដាក់បន្ទុកនៃការផ្តល់ភស្តុតាងទៅលើជនជាប់ចោទ ។ ប៉ុន្តែ ថ្វីដ្បិតតែមានការអភិវឌ្ឍច្បាប់គួរឱ្យចាប់អារម្មណ៍នេះក៏ដោយ ចំណុចខ្សោយរបស់ប្រទេសឥណ្ឌូនេស៊ី បានធ្វើឱ្យប្រសិទ្ធភាពនៃវិធានការប្រឆាំងអំពើពុករលួយ មានកម្រិត (Transparency International, ២០០៣:១៤០) ដោយមានការរីកចម្រើនតិចតួចក្នុងការប្រយុទ្ធប្រឆាំងនឹងអ្វីដែលភាសាឥណ្ឌូនេស៊ីហៅថា korupi, kolusi dan nepotisme មានន័យថាអំពើពុករលួយ អំពើឃុបឃិតគ្នា និងបក្សពួកនិយម ។ ផ្នែកធំៗនៃច្បាប់ទាំងនោះ មិនទាន់បានអនុម័តនៅឡើយ ហើយរដ្ឋាភិបាលក៏មិនបានអនុវត្តនូវការតាមដានដែលត្រូវធ្វើជាចាំបាច់ដែរ ។ ជាពិសេស រដ្ឋាភិបាលម្តងហើយម្តងទៀតមិនបានបែងចែកថវិកាគ្រប់គ្រាន់សម្រាប់ស្ថាប័នដែលបង្កើតឡើងដើម្បីអនុវត្ត និងអនុម័តច្បាប់ទាំងនេះឡើយ ។

---

[១] ច្បាប់នេះគ្មានការបកប្រែជាភាសាអង់គ្លេសទេ ។

[២] ច្បាប់នេះគ្មានការបកប្រែជាភាសាអង់គ្លេសទេ ។

[៣] ច្បាប់នេះត្រូវបានកែដោយច្បាប់លេខ ២០ ឆ្នាំ ២០០១ ស្តីពីការកែប្រែច្បាប់លេខ ៣១ ឆ្នាំ ១៩៩៩ ។

ប៉ុន្មានឆ្នាំថ្មីៗនេះ គេសង្កេតឃើញមាននិទានការសំខាន់ៗក្នុងការអភិវឌ្ឍស្ថាប័ន ដោយមានស្ថាប័នចំណុះរដ្ឋមួយចំនួនត្រូវបានបង្កើតឡើង ដែលមានអាណត្តិការងាររួមចំណែកដល់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ស្ថាប័នទាំងនោះរួមមាន គណៈកម្មការសវនកម្មទ្រព្យសម្បត្តិមន្ត្រីសាធារណៈ (KPKPN)[៤] គណៈកម្មាការអំប៊ុដស៍មែនជាតិ គណៈកម្មការច្បាប់ជាតិ និងគណៈកម្មការលុបបំបាត់អំពើលាងលុយកខ្វក់ (ADB, ២០០៤:១) ។ ប៉ុន្តែ កិច្ចប្រឹងប្រែងរបស់ស្ថាប័នទាំងនេះ ត្រូវបានចុះខ្សោយដោយអាណត្តិការងារផ្ទុយគ្នា (Transparency International, ២០០៣:១៤៥) ។ ការវិវឌ្ឍដ៏សំខាន់មួយក្នុងវិស័យនេះ គឺការបង្កើតគណកម្មការលុបបំបាត់អំពើពុករលួយ (KPK) ក្នុងខែធ្នូ ឆ្នាំ ២០០៣ ដែលទទួលបន្ទុកសម្របសម្រួល និងត្រួតពិនិត្យស្ថាប័នទាំងអស់ដែលគេផ្តល់អំណាចឱ្យលុបបំបាត់អំពើពុករលួយ ។ គេមានសង្ឃឹមថា (KPK) នឹងបង្កើតបានជាផ្នែកសំខាន់មួយ ហើយក្លាយទៅជាចំណុចកណ្តាលនៃក្របខណ្ឌស្ថាប័នទូលំទូលាយសម្រាប់ដោះស្រាយបញ្ហាពុករលួយនៅឥណ្ឌូនេស៊ី ។

អំពើពុករលួយនៅតែជាបញ្ហាប្រឈមខ្លាំងនៅឡើយ ប្រទេសឥណ្ឌូណេស៊ីជាប់ចំណាត់ថ្នាក់ទី ១៣៧ ក្នុងចំណោមប្រទេស ១៥៩ លើតារាងសន្ទស្សន៍ការយល់ឃើញពីអំពើពុករលួយរបស់អង្គការតម្លាភាពអន្តរជាតិ Transparency International ២០០៥ ដែលមានផលប៉ះពាល់ដល់សមាមាត្រនៃជីវភាពជនក្រីក្រ ដូចបានរៀបរាប់ក្នុងឯកសារ The Poor Speak Up-ស្តីអំពីអំពើពុករលួយ ១៧ករណី និងផលប៉ះពាល់អវិជ្ជមានមកលើការអភិវឌ្ឍប្រទេសទាំងមូល ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**គណៈកម្មការលុបបំបាត់អំពើពុករលួយ** KPK ត្រូវបានបង្កើតក្នុងខែធ្នូ ឆ្នាំ ២០០៣ តាមគុណតម្លៃនៃមាត្រា ៤៣ នៃច្បាប់លេខ ៣១/១៩៩៩ ។ រចនាសម្ព័ន្ធរបស់អង្គការ អាណត្តិការងារ និងសមត្ថកិច្ចនៃ KPK ត្រូវបានចែងដោយច្បាប់លេខ ៣០/២០០២ ។ មាត្រា ៣ នៃច្បាប់លេខ ៣០/២០០២ ចែងថា "KPK គឺជាទីភ្នាក់ងាររដ្ឋដែលត្រូវបំពេញភារកិច្ច និងអំណាចរបស់ខ្លួនដោយឯករាជ្យ មិនស្ថិតក្រោមឥទ្ធិពលអ្វីទាំងអស់" ។ "KPK ត្រូវសម្រេចលើគោលនយោបាយ និងនីតិវិធី ក្នុងការអនុវត្តភារកិច្ច និងអំណាចរបស់ខ្លួន ។ KPK ក៏ត្រូវទទួលខុសត្រូវចំពោះការគ្រប់គ្រងបុគ្គលិករបស់ខ្លួនដែរ ដែលរួមទាំងការតែងតាំង និងបញ្ចប់កិច្ចសន្យា (មាត្រា ២៥(១) ច្បាប់លេខ ៣០/២០០២) ។ តាមមាត្រា ១៥(គ) នៃច្បាប់លេខ ៣០/២០០២ KPK ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីសកម្មភាពរបស់ខ្លួនដាក់ជូនប្រធានាធិបតី សភា និងអគ្គសវនកររដ្ឋ ។

គណៈកម្មការលុបបំបាត់អំពើពុករលួយ KPK មានសមាសភាព និងដឹកនាំដោយស្នងការ ៥រូប ដែលមាន ១រូបជាប្រធានរបស់ KPK និង ៤រូបទៀតជាអនុប្រធាន ។ ស្នងការទាំងនេះត្រូវបានតែងតាំងជាមន្ត្រីរដ្ឋាភិបាល (មាត្រា ២១ នៃច្បាប់លេខ ៣០/២០០២) ។ ស្នងការត្រូវបានជ្រើសតាំងដោយសភា ចេញពីបញ្ជីដែលស្នើឡើងដោយប្រធានាធិបតី ។ បញ្ជីបេក្ខជនត្រូវបានរៀបចំដោយគណកម្មការជ្រើសរើសដែលតែងតាំងដោយរដ្ឋាភិបាល (មាត្រា ៣០ ច្បាប់លេខ ៣០/២០០២) ។ តំណែងជាស្នងការមានអាណត្តិ ៤ឆ្នាំ ហើយអាចត្រូវបានតែងតាំងសម្រាប់មួយអាណត្តិទៀតបាន (មាត្រា ៣៤ ច្បាប់លេខ ៣០/២០០២) ។ KPK មានអគ្គលេខាធិការមួយរូបជាជំនួយការ ។ អគ្គលេខាធិការត្រូវបានតែងតាំងដោយប្រធានាធិបតី ប៉ុន្តែទទួលខុសត្រូវចំពោះស្នងការរបស់ KPK (មាត្រា ២៧ ច្បាប់លេខ ៣០/ ២០០២) ។

ស្នងការ នឹងត្រូវដកចេញពីតំណែងប្រសិនបើគាត់បំពានបទបញ្ញត្តិនៃច្បាប់លេខ ៣០/២០០២ ។ បើមានការសង្ស័យថា ស្នងការណាម្នាក់បានប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយ ស្នងការនោះនឹងត្រូវដកចេញពីតំណែងជាបណ្តោះអាសន្ន ។ សេចក្តីសម្រេចពាក់ព័ន្ធទៅនឹងប្រការខាងលើនេះត្រូវធ្វើឡើងដោយប្រធានាធិបតី (មាត្រា ៣២ ច្បាប់លេខ ៣០/២០០២) ។

មានក្រុមពិគ្រោះយោបល់មួយ ដែលមានសមាជិកបួនរូប ជ្រើសតាំងដោយ KPK ពីចំណោមបេក្ខជនដែលស្នើឡើងដោយគណៈកម្មការជ្រើសរើស (មាត្រា ២១ (១-ខ) និង ២២ ច្បាប់លេខ ៣០/២០០២) ។ ក្រុមពិគ្រោះយោបល់នេះមានគោលបំណងផ្តល់មតិ និងការណែនាំជូន KPK ក្នុងការអនុវត្តភារកិច្ច និងអំណាចរបស់ KPK (មាត្រា ២៣ ច្បាប់លេខ ៣០/២០០២) ។

[៤] KPKPN ត្រូវបញ្ចូលជាមួយ KPK ក្លាយទៅជាអង្គភាពបង្កាដែលមានមុខងារតាមដានទ្រព្យសម្បត្តិមន្ត្រីសាធារណៈ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ KPK ។

ស្ថាប័ន KPK មាន ៤ផ្នែក: ផ្នែកទប់ស្កាត់ ផ្នែកអយ្យការ ផ្នែកព័ត៌មាននិងទិន្នន័យ និងអង្គភាពត្រួតពិនិត្យផ្ទៃក្នុងនិងបណ្ដឹងសាធារណៈ ។ ផ្នែកនីមួយៗបែងចែកទៅជាអង្គភាព (នាយកដ្ឋាន) តូចៗជាច្រើនទៀត (មាត្រា ២៦ ច្បាប់លេខ ៣០/២០០២) ។

មាត្រា ៦ នៃច្បាប់លេខ ៣០/២០០២ ចែងថា KPK មានភារកិច្ចដូចខាងក្រោម :

- សម្របសម្រួលជាមួយស្ថាប័នដែលមានអាណត្តិការងារលុបបំបាត់អំពើពុករលួយ ។
- ត្រួតពិនិត្យស្ថាប័នដែលមានអាណត្តិការងារលុបបំបាត់អំពើពុករលួយ ។
- ធ្វើការស៊ើបអង្កេត ចោទប្រកាន់ និងធ្វើបណ្ដឹងអាជ្ញាពីបទល្មើសពុករលួយ ។
- ចាត់វិធានការទប់ស្កាត់អំពើពុករលួយ ។ ហើយនិង
- តាមដានការមើលអភិបាលកិច្ចរបស់រដ្ឋ ។

KPK ត្រូវបំពេញភារកិច្ចក្នុងការស៊ើបអង្កត ចោទប្រកាន់ និងធ្វើបណ្ដឹងអាជ្ញាលើករណីពុករលួយ ដែលពាក់ព័ន្ធនឹង "មន្ត្រីអនុវត្តន៍ច្បាប់ មន្ត្រីរដ្ឋាភិបាលឬភាគីឯទៀតដែលមានការពាក់ព័ន្ធជាមួយនឹងអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីអនុវត្តន៍ច្បាប់ មន្ត្រីរដ្ឋាភិបាល" ដែលធ្វើឱ្យសាធារណជនមានការចាប់អារម្មណ៍ ឬធ្វើឱ្យបាត់ថវិការដ្ឋយ៉ាងហោចណាស់ ១.០០០.០០០.០០០ រូពី[៥] (មាត្រា ១១ ច្បាប់លេខ ៣០/២០០២) ។ ក្នុងអាណត្តិការងារនេះ KPK ជាអ្នកតែងតាំងនិងបញ្ជប់ការងាររបស់អ្នកស៊ើបអង្កេត អ្នកចោទប្រកាន់ និងរដ្ឋអាជ្ញា (មាត្រា ៤៣, ៤៥ និង ៥១) ។

មាត្រា ១២ ច្បាប់លេខ ៣០/២០០២ ផ្ដល់ឱ្យ KPK នូវអំណាចទូលំទូលាយក្នុងការបំពេញការងារស៊ើបអង្កេត ការចោទប្រកាន់ និងការធ្វើបណ្ដឹងអាជ្ញា រួមទាំងការបញ្ជាឱ្យស្ថាប័នពាក់ព័ន្ធ ហាមឃាត់ជនសង្ស័យកុំឱ្យធ្វើដំណើរទៅបរទេស ស្នើសុំព័ត៌មានហិរញ្ញវត្ថុពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឯទៀត និងផ្អាកមិនឱ្យជនសង្ស័យ ឬភាគីពាក់ព័ន្ធ ប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន បញ្ជាឱ្យមានការព្យួរតំណែងជនសង្ស័យ ស្នើសុំព័ត៌មានពីទ្រព្យសម្បត្តិ និងរបាយការណ៍បង់ពន្ធដារបស់ជនសង្ស័យ ស្នើសុំជំនួយពីប៉ូលិសអន្តរជាតិឥណ្ឌូនេស៊ី និងស្ថាប័នអនុវត្តន៍ច្បាប់របស់ប្រទេសផ្សេងៗ ដើម្បីឆែកឆេរ ចាប់ខ្លួន និងដកហូតទ្រព្យសម្បត្តិនៅបរទេស និងស្នើសុំជំនួយពីប៉ូលិស ឬស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីចាប់ខ្លួនឃុំខ្លួន វាយឆ្មក់ និងរឹបអូសទ្រព្យក្នុងករណីអំពើពុករលួយ ដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេត ។

ក្នុងការអនុវត្តតួនាទីទប់ស្កាត់របស់ខ្លួន KPK មានអំណាចធ្វើសវនកម្មទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈ និងធ្វើការអប់រំ និងអនុវត្តកម្មវិធីផ្សព្វផ្សាយនានា ដូចជាអនុវត្តកម្មវិធីអប់រំប្រឆាំងអំពើពុករលួយគ្រប់កម្រិតសិក្សា រៀបចំនិងអនុវត្តកម្មវិធីសង្គមប្រឆាំងអំពើពុករលួយ ធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយ ធ្វើកិច្ចសហការទ្វេភាគី និងពហុភាគី ដើម្បីប្រឆាំងអំពើពុករលួយ (មាត្រា ១៣ ច្បាប់លេខ ៣០/២០០២) ។

ក្នុងការបំពេញតួនាទីតាមដានមើលការគ្រប់គ្រងរដ្ឋរបស់ KPK អាចពិនិត្យឡើងវិញនូវប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នទាំងអស់ និងផ្ដល់យោបល់ដល់ស្ថាប័នទាំងនោះ ប្រសិនបើការត្រួតពិនិត្យបង្ហាញឱ្យឃើញថាប្រព័ន្ធទាំងនោះអាចនឹងកើតមានអំពើពុករលួយ ។ ប្រសិនបើស្ថាប័នមិនគោរពតាមឱវាទរបស់ KPK ទេ KPK ត្រូវរាយការណ៍ជូនប្រធានាធិបតី សភាជាតិ និងអគ្គសវនករជាតិ (មាត្រា ១៤ ច្បាប់លេខ ៣០/២០០២) ។

មាត្រា ១៥ ច្បាប់លេខ ៣០/២០០២ ចែងថា KPK ត្រូវតែផ្ដល់កិច្ចការពារដល់សាក្សី ឬអ្នកបង្ហើបការណ៍ ដែលរាយការណ៍ ឬផ្ដល់ព័ត៌មានពីអំពើពុករលួយ ។

[៥] ស្មើនឹង ១០០.០០០ ដុល្លារ ។

ដើម្បីបំពេញភារកិច្ចសម្របសម្រួលការ KPK មានអាណត្តិការងារដូចខាងក្រោមនេះ:

- សម្របសម្រួលការស៊ើបអង្កេត ការចោទប្រកាន់ និងការធ្វើបណ្ដឹងអាជ្ញាប្រឆាំងអំពើពុករលួយ
- អនុវត្តប្រព័ន្ធរាយការណ៍ក្នុងគោលបំណងលុបបំបាត់អំពើពុករលួយ
- ស្នើសុំព័ត៌មានអំពីច្បាប់ពីស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងលុបបំបាត់អំពើពុករលួយ
- រៀបចំសវនាការផ្ដល់មតិ និងកិច្ចប្រជុំសម្ដែងមតិជាមួយស្ថាប័ននានា ដែលមានភារកិច្ចលុបបំបាត់អំពើពុករលួយ និង
- ស្នើសុំព័ត៌មានពីស្ថាប័នពាក់ព័ន្ធ ដែលនិយាយពីការទប់ស្កាត់អំពើពុករលួយ (មាត្រា ៧ ច្បាប់លេខ ៣០/ ២០០២)។

ច្បាប់លេខ ៣០/ ២០០២ បានសង្កត់ធ្ងន់ថា KPK ត្រូវតែមានតម្លាភាព និងបើកចំហជូនសាធារណជន រួមទាំងការតែងតាំងស្នងការ និងតែងតាំងបុគ្គលិកផ្សេងទៀត ព្រមទាំងធ្វើយុទ្ធនាការផ្ដល់ព័ត៌មាន និងលើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណជន អំពីសកម្មភាពរបស់ KPK។ KPK ក៏មានទិសដៅស្វះស្វែងរក និងលើកកម្ពស់យ៉ាងសកម្មនូវការចូលរួមពីសាធារណជនក្នុងសកម្មភាពរបស់ខ្លួន។

## ការរៀបចំកិច្ចប្រតិបត្តិការ

ក្នុងពេលអនុវត្តភារកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យស្ថាប័នរដ្ឋដែលធ្វើសកម្មភាពប្រឆាំងអំពើពុករលួយ មាត្រា ៨ នៃច្បាប់លេខ ៣០/២០០២ ចែងថា KPK មានអំណាចធ្វើការចោទប្រកាន់ ឬធ្វើបណ្ដឹងអាជ្ញា ដែលកំពុងដំណើរការដោយនគរបាល ឬស្ថាប័នរដ្ឋអាជ្ញា ដែលច្បាប់ តម្រូវឱ្យបញ្ជូនជនជាប់សង្ស័យ និងឯកសារពាក់ព័ន្ធទាំងអស់ទៅឱ្យ KPK ប្រសិនបើល័ក្ខខ័ណ្ឌណាមួយដែលចែងក្នុងមាត្រា ៩ ច្បាប់លេខ ៣០/២០០២ មានប្រៀបជាង។[៦]

ទោះបីជា KPK មានភារកិច្ចស៊ើបអង្កេត ចោទប្រកាន់ និងធ្វើបណ្ដឹងអាជ្ញាលើករណីពុករលួយក្ដី ក៏ KPK អាចស្នើសុំឱ្យនគរបាល ឬស្ថាប័នរដ្ឋអាជ្ញាធ្វើការស៊ើបអង្កេតករណីសង្ស័យថាមានអំពើពុករលួយ ប្រសិនបើ KPK មិនអាចប្រមូលភស្តុតាងបានគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ទេនោះ (មាត្រា ៤៤ ច្បាប់លេខ ៣០/២០០២)។ នគរបាលឬស្ថាប័នរដ្ឋអាជ្ញា ក៏អាចអនុវត្តការចោទប្រកាន់ដែលពាក់ព័ន្ធនឹងករណីពុករលួយបានដែរ ប៉ុន្តែត្រូវតែរាយការណ៍ជូន KPK ពីបញ្ហានេះក្នុងរយៈពេល ១៤ថ្ងៃ។ បន្ទាប់ពីនេះ KPK មានភារកិច្ចសម្របសម្រួលដំណើរការចោទប្រកាន់នេះ។ ប្រសិនបើ KPK ផ្ដួចផ្ដើមដំណើរការចោទប្រកាន់ករណីពុករលួយ ឬកំពុងអនុវត្តដំណើរការចោទប្រកាន់ក្នុងពេលជាមួយគ្នានឹងនគរបាល ឬស្ថាប័នរដ្ឋអាជ្ញា នោះនគរបាល ឬស្ថាប័នរដ្ឋអាជ្ញាលែងមានភារកិច្ចបន្តការចោទប្រកាន់តទៅទៀតហើយ (មាត្រា ៥០ ច្បាប់លេខ ៣០/២០០២)។

មាត្រា ៥៣ នៃច្បាប់លេខ ៣០/២០០២ ចែងឱ្យបង្កើត**តុលាការប្រឆាំងអំពើពុករលួយ** នៅក្នុងប្រព័ន្ធតុលាការទូទៅ ប៉ុន្តែមានលក្ខណៈខុសគ្នាពីតុលាការដទៃទៀត។ តុលាការប្រឆាំងអំពើពុករលួយនេះមានភារកិច្ច និងអាណត្តិការងារវាយតម្លៃនិងសម្រេចលើករណីពុករលួយ ដែល KPK បានដាក់ជូន។ តុលាការប្រឆាំងអំពើពុករលួយនេះក៏មានភារកិច្ច និងអាណត្តិការងារវាយតម្លៃនិងសម្រេចលើករណីពុករលួយ ដែលប្រព្រឹត្តនៅក្រៅយុត្តាធិការច្បាប់នៃប្រទេសឥណ្ឌូនេស៊ី ប្រសិនបើចារីមានសញ្ជាតិជាឥណ្ឌូនេស៊ី (មាត្រា ៥៥ ច្បាប់លេខ ៣០/២០០២)។ អង្គជំនុំជំរះមានចៅក្រម ៥រូប គឺចៅក្រមសាលាដំបូង ២រូប[៧] ដែលបានតែងតាំងតាមសេចក្ដីសម្រេចរបស់ប្រធានតុលាការកំពូល និងចៅក្រមចំពោះកិច្ច ៣រូប ដែលតែងតាំងដោយប្រធានាធិបតីដោយមានការពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល (មាត្រា ៥៦ ច្បាប់លេខ ៣០/២០០២)។

---

[៦] មាត្រា ៩ ចែងថា KPK ត្រូវទទួលយកការចោទប្រកាន់ ឬបណ្ដឹងអាជ្ញា ប្រសិនបើៈ មានរបាយការណ៍ពីសាធារណជនថាមានការលាក់កំបាំងអំពើពុករលួយ ដំណើរការក្ដីពុករលួយពន្យារពេលយូរដោយគ្មានមូលហេតុសមស្រប ការប្រគល់រឿងក្ដីពុករលួយមានចែងនៅក្នុងបទបញ្ជាដើម្បីការពារជនជាប់ចោទ ការប្រគល់រឿងក្ដីពុករលួយស្ថិតនៅក្រោមអំណាចច្បាប់ស្ដីពីអំពើពុករលួយ កាលណាមានការជ្រៀតជ្រែកពីស្ថាប័ននីតិប្រតិបត្តិ នីតិបញ្ញត្តិ និងអំណាចតុលាការ ឬកាលៈទេសៈណាផ្សេងទៀត ដែលនគរបាល ឬស្ថាប័នរដ្ឋអាជ្ញាមិនអាចអនុវត្តរឿងក្ដីបានក្នុងលក្ខណៈមានការទទួលខុសត្រូវ និងគ្រប់ជ្រុងជ្រោយបាន។

[៧] អនុលោមតាមមាត្រា ៥៧ នៃច្បាប់លេខ ៣០/២០០២ ដែលតម្រូវឱ្យចៅក្រមចំពោះកិច្ច លាលែងពីមុខតំណែងដែលគេកំពុងបម្រើ។

អនុលោមតាមមាត្រា ៥៨(១) នៃច្បាប់លេខ ៣០/២០០២ តុលាការត្រូវតែវាយតម្លៃ និងសម្រេចលើករណីអំពើពុករលួយដែលបានប្ដឹងក្នុងរយៈពេល ៩០ថ្ងៃយ៉ាងយូរ។ ការវាយតម្លៃរបស់តុលាការត្រូវធ្វើឡើងស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់លេខ ៣១/១៩៩៩ ដូចដែលបានកែប្រែដោយច្បាប់លេខ ២០/២០០១ ស្ដីពីការកែប្រែច្បាប់លេខ ៣១/១៩៩៩ (មាត្រា ៦២/២០០២)។ សេចក្ដីសម្រេចរបស់តុលាការពុករលួយ អាចត្រូវបានគេប្ដឹងឧទ្ធរណ៍ទៅតុលាការជាន់លើ ហើយគេអាចប្ដឹងឧទ្ធរណ៍សេចក្ដីសម្រេចរបស់តុលាការនេះទៅតុលាការកំពូលបាន (មាត្រា ៥៩-៦០ នៃច្បាប់លេខ ៣០/២០០២)។

ស្ថាប័នអយ្យការសាធារណៈ គឺជាស្ថាប័នរដ្ឋាភិបាលដែលអនុវត្តអំណាចរដ្ឋ ជាពិសេស ក្នុងវិស័យធ្វើបណ្ដឹងអាជ្ញា នៅក្នុងអំណាចច្បាប់ និងទីភ្នាក់ងារអនុវត្តន៍យុត្តិធម៌ និងដឹកនាំដោយអគ្គមេធាវី ដែលតែងតាំងដោយ និងទទួលខុសត្រូវចំពោះមុខប្រធានាធិបតី។ ស្ថាប័នអយ្យការសាធារណៈចែកចេញជាការិយាល័យអគ្គមេធាវី ការិយាល័យរដ្ឋអាជ្ញាជាន់ខ្ពស់ និងការិយាល័យរដ្ឋអាជ្ញាសាលាដំបូង ដែលតំណាងឱ្យអង្គភាពតែមួយដែលមិនអាចបំបែកបាន។

**ក្រុមប្រឹក្សាសវនកម្ម** គឺជាស្ថាប័នសវនកម្មកំពូលនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហើយទទួលខុសត្រូវធ្វើសវនកម្មលើភាពទទួលខុសត្រូវនៃហិរញ្ញវត្ថុរដ្ឋ រួមទាំង ការប្រើប្រាស់ថវិការបស់រដ្ឋាភិបាលកណ្ដាល រដ្ឋាភិបាលតំបន់ សហគ្រាសរដ្ឋ និងការប្រើប្រាស់ថវិការបស់សហគ្រាសរដ្ឋាភិបាលតំបន់។ KPK មានភារកិច្ចរាយការណ៍ពីសកម្មភាពរបស់ខ្លួនជូនទៅសវនករជាតិ។ សវនករជាតិ គឺជាស្ថាប័នមួយដែលស្ថិតនៅក្រោមសមត្ថកិច្ចត្រួតពិនិត្យរបស់ KPK ដោយសារតែស្ថាប័នសវនករជាតិនេះមានភារកិច្ចប្រយុទ្ធប្រឆាំងអំពើពុករលួយ។

**គណៈកម្មាការអំប៊ូដស៍មែនជាតិ** គឺជាស្ថាប័នសាធារណៈឯករាជ្យដែលមានទិសដៅថែរក្សាសុចរិតភាព ការទទួលខុសត្រូវ និងការដឹកនាំដ៏ស័ក្ដិសិទ្ធរបស់រដ្ឋ។ ក្នុងការងាររបស់ខ្លួន គណៈកម្មការនេះទទួលពាក្យបណ្ដឹង និងព្យាយាមរុករក និងដោះស្រាយតាមពាក្យបណ្ដឹងដែលសាធារណជនប្ដឹងប្រឆាំងនឹងកំហុសឆ្គងផ្នែករដ្ឋបាលរបស់រដ្ឋាភិបាល ព្រមទាំងព្យាយាមបង្កើតលក្ខខណ្ឌ ដែលនាំទៅដល់ការទ្រទ្រង់រដ្ឋមួយ ដែលត្រូវផ្ដល់សេវាជូនប្រជាពលរដ្ឋ តាមរបៀបដែលគ្មានអំពើពុករលួយ។

## មេរៀនដែលទទួលបាន

បទពិសោធពីមុនរបស់ប្រទេសឥណ្ឌូនេស៊ីគឺថា ក្ដីសង្ឃឹមដ៏ខ្លាំងទៅលើស្ថាប័នដែលបង្កើតឡើង សម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយនោះត្រូវបានអន្តរាយទៅវិញ ដោយសារគ្មានការគាំទ្រពីរដ្ឋាភិបាល និងថវិកាមិនគ្រប់គ្រាន់។ កំណែទម្រង់តុលាការ ដែលជាធាតុផ្សំសំខាន់សម្រាប់ប្រឆាំងអំពើពុករលួយក៏បាននាំឱ្យមានការខកចិត្តដែរ។ កាលពីមុន រដ្ឋាភិបាលមិនទាន់មានយុទ្ធសាស្ត្ររួម ដែលប្រមូលផ្ដុំនូវគំនិតដ៏គួរជាទីទុកចិត្តដែលបានផ្ដួចផ្ដើមរួចមកហើយ សម្រាប់ដោះស្រាយបញ្ហាអំពើពុករលួយនៅឡើយទេ។ ប្រទេសឥណ្ឌូនេស៊ីត្រូវការផែនទីវិថីច្បាស់លាស់មួយសម្រាប់កំណែទម្រង់ និងការប្ដេជ្ញារបស់រដ្ឋាភិបាល ដើម្បីជំរុញ សម្របសម្រួល និងតាមដានកំណែទម្រង់នេះ។ មកទល់នឹងថ្ងៃនេះ ប្រវត្តិនៃគំនិតផ្ដួចផ្ដើមប្រឆាំងអំពើពុករលួយក្នុងសម័យក្រោយរបបស៊ូហាតូ គឺគ្រាន់តែជារឿងនិទានមួយនៃការផ្ដើមគំនិតដ៏ឈ្លាសវៃ ហើយនិងគ្រាន់តែជាការសន្យាមួយថានឹងចងក្រងច្បាប់នានា ប៉ុន្តែមិនត្រូវបានអនុវត្តតាម។ អ្នកសង្កេតការណ៍ខ្លះនិយាយថា ច្បាប់ និងស្ថាប័នពាក់ព័ន្ធនានា ត្រូវបានរៀបចំឡើងដើម្បីឱ្យបរាជ័យ ដោយមានការប្ដេជ្ញាតែសំបកក្រៅថាប្រយុទ្ធប្រឆាំងអំពើពុករលួយ ប៉ុន្តែមានរចនាសម្ព័ន្ធផ្ទៃក្នុង ដែលនាំឱ្យស្ថាប័នទាំងនេះមិនអាចដំណើរការបាន។ ប្រការនេះអាចចាត់ទុកថាជាទម្រង់នៃ "រចនាសម្ព័ន្ធរដ្ឋ" ដែលមានលក្ខណៈស្មុគស្មាញខ្លាំង និងចាំបាច់ត្រូវតែមានឆន្ទៈនយោបាយនៅថ្នាក់កំពូល ដើម្បីឱ្យកិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយមានឱកាសទទួលជោគជ័យ។

គេកំពុងចាំមើលថា តើរដ្ឋាភិបាលរបស់ប្រធានាធិបតី Susilo Bambang Yudhoyono ដែលជាប់ឆ្នោត កាលពីខែកញ្ញា ឆ្នាំ ២០០៤ មានទិសដៅប្រឆាំងអំពើពុករលួយអ្វីខ្លះ។ ប្រធានបទចម្បងមួយក្នុងយុទ្ធនាការឃោសនាដែលនាំឱ្យគាត់ជាប់ឆ្នោតជាប្រធានាធិបតី គឺសារសំខាន់នៃការលុបបំបាត់អំពើពុករលួយ។ គេក៏កំពុងចាំមើលថាការបង្កើត KPK នឹងមានផលប៉ះពាល់អ្វីខ្លះ។ បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់ដើម្បីឱ្យ KPK មានជោគជ័យពេញលេញក្នុងអាណត្តិការងាររបស់ខ្លួន គឺការធ្វើឱ្យច្បាប់ដទៃទៀតមានភាពរលូនជាមួយនឹងច្បាប់លេខ ៣០/២០០២។

បទបញ្ញត្តិនានានៃច្បាប់លេខ ៣០/២០០២ នេះ មិនសូវមានភាពរលូនជាមួយលិខិតបទដ្ឋានគ្រប់គ្រងស្ថាប័នផ្សេងទៀតទេ។ ឧទាហរណ៍មួយក្នុងប្រការនេះគឺថា ទោះបីជាច្បាប់ផ្តល់អំណាចឱ្យ KPK អាចស្នើសុំព័ត៌មានពីស្ថាប័នរដ្ឋក្តី ក៏គ្មានបទបញ្ញត្តិណាដែលតម្រូវឱ្យស្ថាប័ននោះផ្តល់ ឬលាតត្រដាងព័ត៌មានដែលត្រូវបានស្នើសុំឡើយ (ADB: 2004:2) ។

ការបង្កើត KPK បង្ហាញឱ្យឃើញច្បាស់ថា វាមិនត្រឹមតែមានការចាំបាច់ត្រូវពិនិត្យមើលអាណត្តិការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានាឱ្យលិខិតបទដ្ឋានរបស់ស្ថាប័នផ្សេងទៀត ឆ្លុះបញ្ចាំងពីអាណត្តិការងាររបស់ស្ថាប័នប្រឆាំងអំពើពុករលួយផងដែរ ជាពិសេស ប្រសិនបើស្ថាប័ននេះមានតួនាទីត្រូវសម្របសម្រួល។ ក្នុងស្ថានភាពដែលប្រទេសមួយមានស្ថាប័នប្រឆាំងអំពើពុករលួយច្រើន ហើយមានសេចក្តីសម្រេចដើម្បីបង្កើតស្ថាប័នសម្របសម្រួលមួយ បញ្ហានេះត្រូវធ្វើឱ្យក្របខ័ណ្ឌច្បាប់មានភាពរលូន ហើយត្រូវតែធានាមិនទុកឱ្យនៅមានសល់ច្បាប់ណាដែលអង្គភាពពុករលួយអាចយកទៅប្រើដើម្បីជាប្រភពការពារទល់នឹងរដ្ឋបាន។

## ប្រភព


- Transparency International ២០០៣ របាយការណ៍អំពើពុករលួយសកលលោកឆ្នាំ ២០០៣ *http://www.globalcoruuptionreport.org/gcr2003.htm*
- Hardjono Ratih and Teggemann, Stefanie (eds.) ២០០២ The Poor Speak Up – អំពើពុករលួយ ១៧ករណីភាពជាដៃគូដើម្បីកំណែទម្រង់អភិបាលកិច្ច *http://www.kemitraan.or.id/data/pdf/poor%20speak%up.pdf*
- Asian Development Bank ខែឧសភា ឆ្នាំ ២០០៤ TAR: INO ៣៧០២៥ ជំនួយបច្ចេកទេសសម្រាប់ប្រទេសឥណ្ឌូនេស៊ី សម្រាប់ពង្រឹងសមត្ថភាពគណកម្មាការលុបបំបាត់អំពើពុករលួយប្រទេសឥណ្ឌូនេស៊ី *ttp://www.adb.org/Documents/TARs/INO/tar_ino_37025.pdf*


ព័ត៌មានទាំងនេះត្រូវបានប្រមូលចេញពីគេហទំព័ររបស់ស្ថាប័ននានាដែលបានរាយឈ្មោះខាងលើ។



# ប្រទេសឡាតវៀ

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- ការិយាល័យទប់ស្កាត់និងលុបបំបាត់អំពើពុករលួយ (CPCB) *www.knab.gov.lv/en*
- ក្រុមប្រឹក្សាទប់ស្កាត់បទល្មើសនិងអំពើពុករលួយ (CCPC)
- ការិយាល័យសវនកម្មជាតិ (SAO) *www.lrvk.gov.lv/htmls/english/engindex.htm*
- ក្រសួងមហាផ្ទៃ *www.iem.gov.lv/?ing=en&cat=136*
- នគរបាលរដ្ឋ *www.vp.gov.lv/?setl=2&PHPSESSID=10e32a205f1c94ca81fc3748e907be35*
- នគរបាលសន្តិសុខ *www.iem.gov.lv/iem/2nd/?lng=en&cat=136*
- ស្ថាប័នគ្រប់គ្រងចំណូលជាតិ (SRS) *www.vid.gov.lv/lng/Index.htm*

## បទបញ្ញត្តិចម្បង

- ច្បាប់ព្រហ្មទណ្ឌ (១៧ មិថុនា ១៩៩៨ និងវិសោធនកម្មរហូតដល់ ១ មិថុនា ២០០០) *http://www.tm.gov.lv/str/569_the%20Criminal%20Law.htm*
- ច្បាប់ស្តីពីការិយាល័យទប់ស្កាត់និងប្រយុទ្ធប្រឆាំងអំពើពុករលួយ (CCPC) ១៨ មេសា ២០០២ *http://www.knab.gov.lv/uploads/en_htm/EN_bureau.htm*
- ច្បាប់ស្តីពីការទប់ស្កាត់ទំនាស់ផលប្រយោជន៍ក្នុងសកម្មភាពមន្ត្រីសាធារណៈ (PCIAPO) ០៥ មេសា ២០០២ *http://www.knab.gov.lv/uploads/en_htm/EN_amatpersonas.htm*
- ច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញា (PPO) ១ កក្កដា ១៩៩៤ *http://www.humanrights.lv/doc/latlik/prok.htm*
- ច្បាប់ស្តីពីស្ថាប័នគ្រប់គ្រងចំណូលជាតិ (SRS) ២៨ តុលា ១៩៩៣ *http://www.vid.gov.lv/eng/4laws/docs/203-01.pdf*
- ច្បាប់ស្តីពីស្ថាប័នសវនកម្មជាតិ (SAO) ២៩ ឧសភា ២០០២ *www.lrvk.gov.lv/page/php?id=1779*

## សាវតា

សម្ពាធដ៏សំខាន់មួយនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសឡាតវៀ គឺជាលក្ខណៈវិនិច្ឆ័យតឹងរ៉ឹង ដែលតម្រូវឱ្យប្រទេសនេះអនុម័ត ដើម្បីឆ្ពោះទៅរកការចូលជាសមាជិកសហភាពអឺរ៉ុប នៅខែឧសភា ឆ្នាំ ២០០៤។ សហភាពអឺរ៉ុបខ្លួនឯងបានក្លាយទៅជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសឡាតវៀ (Transparency International ២០០៣:១៧៧-១៧៨)។

វិធានការជាច្រើនត្រូវបានគេអនុវត្តក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយ។ ជាមួយនឹងការបង្កើត

ក្រុមប្រឹក្សាទប់ស្កាត់អំពើពុករលួយក្នុងឆ្នាំ ១៩៩៧ រដ្ឋាភិបាលបានចាត់វិធានការទីមួយក្នុងការអភិវឌ្ឍគោលនយោបាយប្រឆាំងអំពើពុករលួយ (OSI, ២០០២:៣០០)។ ក៏ប៉ុន្តែរចនាសម្ព័ន្ធស្ថាប័នដើម្បីប្រឆាំងនឹងទប់ស្កាត់អំពើពុករលួយនៅមិនទាន់រឹងមាំ ហើយគ្មានប្រសិទ្ធភាពក្នុងការសម្របសម្រួល។ ជាទូទៅគេយល់ឃើញថា អំពើពុករលួយគឺជាបាតុភូតអាក្រក់មួយ ដែលប៉ះពាល់ជាអវិជ្ជមានទៅលើសកម្មភាពស្ថាប័នសាធារណៈមួយចំនួន (GRECO, ២០០២:៦)។ ប្រធានាធិបតីបច្ចុប្បន្នបានបង្កើតគណបក្សសម័យថ្មី ក្នុងគំនិតកាត់បន្ថយអំពើពុករលួយក្នុងប្រទេស។ រហូតមកដល់ការបោះឆ្នោតឆ្នាំ ២០០២ ដែលនាំឱ្យគណបក្សសម័យថ្មីនេះទទួលបានសម្លេងគាំទ្រខ្ពស់បំផុត ការកាត់បន្ថយអំពើពុករលួយ គឺជាការសន្យាចម្បងក្នុងយុទ្ធនាការឃោសនាការបោះឆ្នោត (FHI, ២០០៤:១៨)។

រដ្ឋាភិបាលឡាតវៀនៅរក្សាការប្តេជ្ញានេះយ៉ាងរឹងមាំក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយតទៅទៀត ហើយបានចាត់វិធានការសំខាន់ៗមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពគោលនយោបាយប្រឆាំងអំពើពុករលួយ។ វិធានការនេះ រាប់បញ្ចូលទាំងការកែលម្អច្បាប់ ដូចជាការអនុម័តច្បាប់ ស្តីពីការទប់ស្កាត់ទំនាស់ផលប្រយោជន៍ក្នុងសកម្មភាពមន្ត្រីសាធារណៈ PCIAPO ក្នុងឆ្នាំ ២០០២ ព្រមទាំងការជម្រះចោលនូវភាពមិនច្បាស់លាស់ និងការពង្រឹងបញ្ចូលគ្នានូវរចនាសម្ព័ន្ធស្ថាប័ន តាមរយៈការបង្កើតការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ (KNAB) ដែលបានដំណើរការទាំងស្រុងចាប់តាំងពីខែកុម្ភៈ ឆ្នាំ ២០០៣ (EC, ២០០៣:១៤)។ វិធានការសំខាន់ៗផ្សេងទៀត គឺការបង្កើតក្រុមប្រឹក្សាទប់ស្កាត់បទល្មើស និងទប់ស្កាត់អំពើពុករលួយ (CCPC) ក្នុងឆ្នាំ ២០០២ និងថ្មីៗនេះការអនុម័ត យុទ្ធសាស្ត្រជាតិដើម្បីទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ ឆ្នាំ ២០០៤-២០០៨។

ប្រទេសឡាតវៀស្ថិតក្នុងចំណាត់ថ្នាក់ទី ៥១ ក្នុងចំណោមប្រទេស ១៥៩ លើតារាងសន្ទស្សន៍របស់អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០០៥ ស្តីពីការយល់ឃើញពីអំពើពុករលួយ។ ទោះបីជាប្រទេសឡាតវៀបានចាត់វិធានការសំខាន់ៗជាច្រើន ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយក៏ដោយ ក៏នៅក្នុងរបាយការណ៍តាមដានលំអិតរបស់ឡាតវៀស្តីពីការត្រៀមចូលជាសមាជិកសហគមន៍អឺរ៉ុបបានសង្កត់ធ្ងន់ថា ការប្រឆាំងអំពើពុករលួយ "ត្រូវតែនៅជាអាទិភាពខ្ពស់ជាបន្តទៅទៀត"។ ជាពិសេស ត្រូវមានកិច្ចប្រឹងប្រែងបន្ថែម ដើម្បីចងក្រងច្បាប់មូលដ្ឋានឱ្យបានចប់សព្វគ្រប់ និងពង្រឹងការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB(2003:56)។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**ការិយាល័យទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ (CCPC)** ត្រូវបានបង្កើតក្នុងខែតុលា ឆ្នាំ ២០០២ គឺជាស្ថាប័នរដ្ឋ ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គណៈរដ្ឋមន្ត្រី (មាត្រា ២(១) នៃច្បាប់ CPCB)។ ច្បាប់ CPCB ចែងពីនិត្យានុកូលភាព និងគោលដៅរបស់ការិយាល័យនេះ។ CPCB ដឹកនាំដោយប្រធានមួយរូប ដែលតែងតាំងនិងដកហូត ដោយសភា Saeima តាមអនុសាសន៍របស់គណៈរដ្ឋមន្ត្រី (មាត្រា ៤១(១)នៃច្បាប់ CPCB) និងមានអនុប្រធាន២រូប ដែលទទួលខុសត្រូវដោយឡែកពីគ្នា គឺកិច្ចការទប់ស្កាត់អំពើពុករលួយ និងកិច្ចការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

ការិយាល័យទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ (CPCB) ចែកជា ១៦ផ្នែក ដែលមាន ៩ផ្នែកស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន ដែលជាចម្បងបំពេញមុខងារផ្ទៃក្នុង[១]។ ក្នុងចំណោមអង្គភាពផ្សេងទៀត មានអង្គភាពត្រួតពិនិត្យសកម្មភាពមន្ត្រីសាធារណៈ អង្គភាពត្រួតពិនិត្យហិរញ្ញប្បទានរបស់គណបក្សនយោបាយ អង្គភាពវិភាគអំពើពុករលួយនិងវិធីសាស្ត្រវិធានការទប់ទល់ និងអង្គភាពទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ស្ថិតនៅក្រោមការដឹកនាំរបស់អនុប្រធានទទួលបន្ទុកកិច្ចការទប់ស្កាត់អំពើពុករលួយ។ អង្គភាពស៊ើបការណ៍សម្ងាត់ពាក់ព័ន្ធនឹងបទល្មើស អង្គភាពស៊ើបសួរ និងអង្គភាពរដ្ឋបាលផ្នែកចាំឃ្លាំមើល ស្ថិតនៅក្រោមការដឹកនាំរបស់អនុប្រធានទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើពុករលួយ។

---

[១] ទាំងអស់នេះមានផ្នែកច្បាប់ ផ្នែកហិរញ្ញវត្ថុ ផ្នែកបុគ្គលិក ផ្នែករដ្ឋបាល ផ្នែកគ្រប់គ្រងផ្ទៃក្នុង ផ្នែកការពារព័ត៌មានសម្ងាត់ ផ្នែកព័ត៌មានវិទ្យា ផ្នែកសវនកម្មផ្ទៃក្នុង និងមណ្ឌលរបាយការណ៍

សកម្មភាពរបស់ CPCB ផ្តែកលើសសរទ្រូងបី គឺការទប់ស្កាត់អំពើពុករលួយ ការស៊ើបអង្កេតករណីអំពើពុករលួយ និងបង្កើនការយល់ដឹងដល់សាធារណជន។ អនុលោមតាមមាត្រា ៧(១)នៃច្បាប់ CPCB ការិយាល័យនេះមានភារកិច្ចរៀបចំយុទ្ធសាស្ត្រជាតិដើម្បីទប់ស្កាត់ និងប្រឆាំងអំពើពុករលួយឆ្នាំ ២០០៤-២០០៨ ដែលក្រោយមកត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ ២០០៤។ ការិយាល័យទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ CPCB មានអាណត្តិការងារជាក់លាក់ក្នុងការសម្របសម្រួល ការអនុវត្តវិធានការប្រឆាំងអំពើពុករលួយនៅក្នុងស្ថាប័នរដ្ឋ និងស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន ហើយការិយាល័យនេះក៏ទទួលបន្ទុកធានាការសម្របសម្រួលកិច្ចប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងអស់ដែលមានភារកិច្ចប្រយុទ្ធប្រឆាំងអំពើពុករលួយ ស្របតាមយុទ្ធសាស្ត្រជាតិ (មាត្រា ៧(១) នៃច្បាប់ CPCB)។ ពាក់ព័ន្ធនឹងបញ្ហានេះ CPCB ក៏ទទួលខុសត្រូវក្នុងការផ្តល់ជូនក្រុមប្រឹក្សាទប់ស្កាត់អំពើពុករលួយនិងបទល្មើស (CCPC) នូវព័ត៌មាននិងអនុសាសន៍ ស្តីពីបញ្ហាទាក់ទិននឹងអំពើពុករលួយ។ នៅក្នុងផ្នែកដែលមានចំណងជើងថា ការរៀបចំកិច្ចប្រតិបត្តិការ មាននិយាយពិស្តារអំពី CPCB។

អនុលោមតាមមាត្រា ៧ នៃច្បាប់ CPCB មុខងារសំខាន់ៗរបស់ការិយាល័យនេះក្នុងការទប់ស្កាត់អំពើពុករលួយ រួមមានៈ

- កសាងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ។
- ពិនិត្យបណ្តឹងទាំងឡាយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ការិយាល័យ។
- វិភាគសកម្មភាពអនុវត្តការទប់ស្កាត់អំពើពុករលួយក្នុងស្ថាប័នរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ហើយក្នុងករណីរកឃើញអំពើពុករលួយ ដាក់ជូនអនុសាសន៍ទៅក្រសួងនិងស្ថាប័នពាក់ព័ន្ធ។
- កសាងវិធីសាស្ត្រទប់ស្កាត់ និងប្រឆាំងអំពើពុករលួយក្នុងស្ថាប័នរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ព្រមទាំងសម្រាប់វិស័យឯកជនផងដែរ។
- វិភាគ និងរៀបចំសេចក្តីព្រាងច្បាប់ និងស្នើវិសោធនកម្ម និងផ្តល់អនុសាសន៍សម្រាប់សេចក្តីព្រាងច្បាប់។
- ធ្វើការស្ទាបស្ទង់មតិសាធារណជន និងវិភាគលទ្ធផល។
- អប់រំសាធារណជនអំពីទិដ្ឋភាពច្បាប់ និងទិដ្ឋភាពក្រមសីលធម៌ដែលពាក់ព័ន្ធអំពើពុករលួយ។
- ផ្តល់ព័ត៌មានដល់សាធារណជនអំពីការវិវឌ្ឍនៃអំពើពុករលួយក្នុងប្រទេស ករណីពុករលួយដែលរកឃើញ ព្រមទាំងកិច្ចប្រឹងប្រែងក្នុងការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។
- កសាង និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងសាធារណៈ និង
- ដោយអនុលោមតាមសមត្ថកិច្ចរបស់ខ្លួន វាយតម្លៃលើការស៊ើបអង្កេតដែលធ្វើឡើងដោយស្ថាប័នឯទៀតៗ។

ដូចមានចែងក្នុងច្បាប់ CPCB ក្នុងវិស័យប្រយុទ្ធប្រឆាំងអំពើពុករលួយ ការិយាល័យទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ CPCB មានភារកិច្ចធ្វើការចោទប្រកាន់មន្ត្រីសាធារណៈដែលមានការខុសឆ្គងខាងរដ្ឋបាល និងតម្រូវឱ្យដាក់ទណ្ឌកម្មមន្ត្រីសាធារណៈ ក្នុងករណីមានការរំលោភបំពានរដ្ឋបាលក្នុងវិស័យពុករលួយ ដូចមានចែងក្នុងច្បាប់ និងធ្វើការស៊ើបអង្កេត និងដាក់វិធានការប្រតិបត្តិ ដើម្បីស្វែងរកអំពើពុករលួយនៅក្នុងមុខងារសាធារណៈ។ ស្ថាប័នទាំងអស់ផ្សេងទៀតដែលមានភារកិច្ចស៊ើបអង្កេត ត្រូវបានតម្រូវឱ្យជួយការិយាល័យនេះក្នុងការស៊ើបអង្កេត។ ការិយាល័យនេះក៏បំពេញមុខងារតាមដានមើលអង្គការនយោបាយនានា ក្នុងការប្រតិបត្តិតាមបញ្ញត្តិច្បាប់ស្តីពីការផ្តល់មូលនិធិគណបក្ស (មាត្រា ៩ ច្បាប់ CPCB)។

មាត្រា ១០ នៃច្បាប់ CPCB ផ្តល់ជូនមន្ត្រីការិយាល័យនេះ នូវសិទ្ធិ និងអំណាចទូលំទូលាយ ដូចជា :

- ធ្វើការស៊ើបអង្កេតដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។
- ធ្វើប្រតិបត្តិការស៊ើបអង្កេត ដូចដែលច្បាប់អនុញ្ញាត ដើម្បីរើកមុខ និងទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ ក្នុងវិស័យអំពើពុករលួយ និងវិស័យហិរញ្ញប្បទានដល់គណបក្ស។
- រៀបចំការចោទប្រកាន់បទល្មើសរដ្ឋបាល ក្នុងករណីរកឃើញការបំពាន ពិនិត្យករណីបំពានខាងរដ្ឋបាល និងដាក់វិន័យរដ្ឋបាលក្នុងករណីបំពាន ហើយតាមក្រមស្តីពីការរំលោភផ្នែករដ្ឋបាល ការពិនិត្យនេះស្ថិតក្រោមសមត្ថកិច្ចរបស់ការិយាល័យ។
- ទទួលព័ត៌មាន ទទួលឯកសារ និងទទួលព័ត៌មានតាមសំណើរបស់រដ្ឋាភិបាល និងរដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន អង្គការ មន្ត្រី និងបុគ្គល

ផ្សេងទៀត ដោយមិនគិតពីស្ថានភាពលាក់ការសម្ងាត់របស់ពួកគេឡើយ ។

- ទទួលព័ត៌មានពីស្ថាប័នហិរញ្ញវត្ថុដែលចាំបាច់សម្រាប់រឿងក្តីព្រហ្មទណ្ឌ តាមរយៈទីភ្នាក់ងារនៃអគ្គរដ្ឋអាជ្ញា ។
- ចេញដីកាកោះហៅឱ្យទៅ CPCB នូវបុគ្គលដែលជាប់ពាក់ព័ន្ធនឹងការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌ ឬសម្ភារៈពាក់ព័ន្ធ ហើយក្នុងករណីដែលបុគ្គលមិនព្រមបង្ហាញខ្លួនបន្ទាប់ពីទទួលដីកាកោះនេះ ត្រូវប្រើកម្លាំងដើម្បីនាំខ្លួនជនទោះ ហើយនិង
- ប្រើកម្លាំងបើមានការចាំបាច់ ។

តាមការសម្រុះសម្រួលរបស់អគ្គរដ្ឋអាជ្ញា ការិយាល័យ CPCB អាចដាក់ករណីព្រហ្មទណ្ឌ ឬវត្ថុតាងជូនស្ថាប័នសាកសួរផ្សេងទៀតសម្រាប់បន្តដំណើរការស៊ើបសួរ ព្រមទាំងទទួលយកករណីព្រហ្មទណ្ឌ និងឯកសារសាកសួរពីស្ថាប័នស៊ើបអង្កេតឯទៀតៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ការិយាល័យនេះ (មាត្រា ១០(១៧) ច្បាប់ CPCB) ។

ក្រៅពីការងារខាងលើ មាត្រា ៧(៣) នៃច្បាប់ CPCB ចែងថា ការិយាល័យនេះមានភារកិច្ចតាមឃ្លាំមើលការប្រតិបត្តិតាមច្បាប់ស្តីពីការទប់ស្កាត់ទំនាស់ផលប្រយោជន៍ក្នុង*សកម្មភាពមន្ត្រីសាធារណៈ*។ ការងារនេះរាប់ទាំងភារកិច្ចពិនិត្យមើលសេចក្តីប្រកាសរបស់មន្ត្រីសាធារណៈ[២] ដែលបានដាក់ជូន CPCB តាមផ្នែកទី ២៣(៤) នៃច្បាប់ PCIAPO (មាត្រា ៧ (១៦) ច្បាប់ CPCB) ។ វត្ថុបំណងនៃច្បាប់ PCIAPO គឺដើម្បីធានាថា សេចក្តីសម្រេច និងសកម្មភាពដែលអនុវត្តដោយមន្ត្រីសាធារណៈគឺដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងដើម្បីទប់ស្កាត់ឥទ្ធិពលពីខាងក្រៅ ឬផលប្រយោជន៍ហិរញ្ញវត្ថុ។ នៅទីបំផុត ការងារនេះមានគោលបំណងលើកកម្ពស់សេចក្តីទុកចិត្តពីសាធារណជនទៅលើសកម្មភាពរបស់មន្ត្រីសាធារណៈ (ផ្នែកទី ២ ច្បាប់ PCIAPO) ។

## ការរៀបចំកិច្ចប្រតិបត្តិការ

**ក្រុមប្រឹក្សាទប់ស្កាត់បទល្មើសនិងអំពើពុករលួយ (CPCC)** នៃរដ្ឋសភាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ និងដឹកនាំដោយនាយករដ្ឋមន្ត្រីដែលមានតួនាទីត្រួតពិនិត្យកិច្ចប្រឹងប្រែងទប់ស្កាត់អំពើពុករលួយ និងប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មអង្គការចាត់តាំង ។ ដូចនេះ CPCC មានភារកិច្ចសម្របសម្រួល និងត្រួតពិនិត្យសកម្មភាពរដ្ឋអំណាចទាំងអស់ ក្នុងវិស័យទប់ស្កាត់ឧក្រិដ្ឋកម្ម និងទប់ស្កាត់អំពើពុករលួយ (GRECO, 2004a:4) ។ ក្នុងភារកិច្ចនេះ ក្រុមប្រឹក្សាបានដឹកនាំការត្រួតពិនិត្យលើការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB (EC, 2003:15) ។ ក្រៅពីនេះ ក្រុមប្រឹក្សាទប់ស្កាត់បទល្មើស និងអំពើពុករលួយ CPCC នៃរដ្ឋសភា មានភារកិច្ចគាំទ្រការចូលរួមរបស់សង្គមស៊ីវិល ក្នុងគោលនយោបាយប្រឆាំងអំពើពុករលួយ ការលើកកម្ពស់ផែនការទប់ស្កាត់ឧក្រិដ្ឋកម្មអង្គការចាត់តាំង និងទប់ស្កាត់អំពើពុករលួយ និងគាំទ្រការសិក្សាស្រាវជ្រាវពីឧក្រិដ្ឋកម្ម ។ ក្រុមប្រឹក្សា CPCC នេះក៏មានសិទ្ធិលើកសំណើ ដើម្បីកែលម្អសេចក្តីព្រាងច្បាប់ និងការអនុវត្តគោលនយោបាយយុត្តិធម៌ និងគោលនយោបាយកិច្ចការមហាផ្ទៃ ដើម្បីធានានូវកិច្ចសម្របសម្រួលសកម្មភាពនៅក្នុងស្ថាប័ន ដែលប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម និងអំពើពុករលួយ ព្រមទាំងធានានូវកិច្ចសហការរបស់ស្ថាប័នជាតិរបស់ឡាតវៀ ជាមួយស្ថាប័នអន្តរជាតិនានា (GRECO, 2004a:4-5) ។

**ការិយាល័យសវនកម្មរដ្ឋ (SAO)** ត្រូវបានបង្កើតជាស្ថាប័នឯករាជ្យ តាមមាត្រា ៨៧នៃរដ្ឋធម្មនុញ្ញ ដែលស្ថិតនៅតែក្រោមអំណាចច្បាប់មួយ (Subsection 1[2] SAO Law) ។ ការិយាល័យសវនកម្មរដ្ឋ គឺជាស្ថាប័នកំពូល និងដឹកនាំដោយអគ្គសវនករ ដែលតែងតាំងដោយសភា Saeima សម្រាប់អាណត្តិ ៧ឆ្នាំ (Subsection 26[1] SAO Law) និងក្រុមប្រឹក្សាសវនកម្ម ដែលសមាជិកនៃក្រុមប្រឹក្សានេះក៏មានអាណត្តិ ៧ឆ្នាំដែរ ត្រូវបានផ្តល់ការយល់ព្រមដោយសភា Saeima តាមអនុសាសន៍របស់អគ្គសវនករ (Subsection 27[1] SAO Law) ។ ការរៀបចំ និងការទទួលខុសត្រូវរបស់ការិយាល័យសវនកម្មរដ្ឋ មានចែងក្នុងច្បាប់ស្តីពីការិយាល័យសវនកម្មរដ្ឋ។ អនុលោមតាមមាត្រា ២ នៃច្បាប់ស្តីពីការិយាល័យសវនកម្មរដ្ឋ ការិយាល័យនេះមានភារកិច្ចត្រួតពិនិត្យចំណូល និងចំណាយរបស់រដ្ឋ និងប្រភពថវិការដ្ឋាភិបាលមូលដ្ឋាន ការប្រើប្រាស់ធនធានរបស់សហភាពអឺរ៉ុប និងអង្គការ ឬស្ថាប័នអន្តរជាតិឯទៀត ដែលបានដាក់បញ្ចូលក្នុងថវិការដ្ឋ ឬក្នុងថវិការដ្ឋាភិបាលមូលដ្ឋាន និងដាក់វិធានការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងទ្រព្យសម្បត្តិរដ្ឋាភិបាលមូលដ្ឋាន ដើម្បីធានាឱ្យការប្រើធនធាននោះបានស្របច្បាប់ ត្រឹមត្រូវ សន្សំសំចៃ និងមានប្រសិទ្ធភាព។ ប្រសិនបើការិយាល័យសវនកម្មរដ្ឋ រកឃើញភាពមិនប្រក្រតីដែលនាំឱ្យមានការសង្ស័យពីអំពើពុករលួយ ករណីនេះនឹងត្រូវ

[២] ផ្នែកទី ៤ នៃច្បាប់ PCIAPO កំណត់ពីដែនសមត្ថកិច្ចរបស់មន្ត្រីសាធារណៈតាមច្បាប់ ។

រាយការណ៍ផ្ទាល់ទៅស្ថាប័នរដ្ឋអាជ្ញាសាធារណៈ PPO ប្រសិនបើមានភស្តុតាងពីសកម្មភាពឧក្រិដ្ឋ។ បើមិនដូច្នោះទេ ករណីនេះក៏ត្រូវរាយការណ៍ជូនស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ (SRS), (GRECO, 2002:17)។ ការិយាល័យសវនកម្មរដ្ឋត្រូវរាយការណ៍អំពីសកម្មភាពខ្លួនជូនសភា Saeima និងជូនរដ្ឋាភិបាល (Section 3, SAO Law)។

**ស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ (SRS)** គឺជាស្ថាប័នរដ្ឋបាលរបស់រដ្ឋ ដែលធ្វើការក្រោមឱវាទក្រសួងហិរញ្ញវត្ថុ (Article 1, SRS Law) និងដឹកនាំដោយអគ្គនាយកម្នាក់ ដែលតែងតាំងដោយរដ្ឋមន្ត្រីហិរញ្ញវត្ថុ តាមការឯកភាពពីរដ្ឋាភិបាល (Article 4[1], SRS Law)។ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ SRS មានចែងក្នុងច្បាប់ SRS។ ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់ SRS ភារកិច្ចចម្បងរបស់ SRS មានដូចខាងក្រោមនេះ:

- ធានាការប្រមូលពន្ធអាករ ពន្ធគយ និងការទូទាត់ជាកាតព្វកិច្ចឯទៀតៗ ដែលដឹកនាំដោយ SRS នៅក្នុងប្រទេសឡាតវៀ និងនៅតាមព្រំដែន ឧ. ពន្ធគយ។
- អនុវត្តគោលនយោបាយជាតិសម្រាប់គយ និងធានាការការពារព្រំដែនគយ។
- តាមក្របខណ្ឌអំណាចរបស់ខ្លួនដូចកំណត់ក្នុងច្បាប់ ត្រួតពិនិត្យលើការអនុវត្តវិធានការប្រឆាំងអំពើពុករលួយ ព្រមទាំងធានាឱ្យមានការគោរពតាមកំហិតបន្ថែមដែលដាក់ទៅឱ្យមន្ត្រីរដ្ឋការ ដូចដែលមានចែង ដោយច្បាប់ឯទៀតៗ។
- ទប់ស្កាត់ និងតាមរកបទល្មើសក្នុងវិស័យបង់ពន្ធដារ ពន្ធគយ និងការទូទាត់ជាកាតព្វកិច្ចឯទៀតៗ ដែលកំណត់ដោយរដ្ឋ។

នៅក្នុងស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ SRS នគរបាលហិរញ្ញវត្ថុមានអំណាចទូលំទូលាយ ដូចមានចែងក្នុងមាត្រា ១៦ នៃច្បាប់ស្តីពីស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ នៅក្នុងក្របខណ្ឌនៃពន្ធចំណូលរបស់រដ្ឋ។ អនុលោមតាមមាត្រា ១៤ នគរបាលហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោមនេះ :

- ធ្វើការស៊ើបអង្កេត ក្នុងគោលបំណងបើកមុខ និងទប់ស្កាត់បទល្មើសក្នុងក្របខណ្ឌនៃពន្ធចំណូលរបស់រដ្ឋ។
- ធ្វើការស៊ើបអង្កេត ក្នុងគោលបំណងបើកមុខ និងទប់ស្កាត់បទល្មើសក្នុងសកម្មភាពរបស់មន្ត្រី និងនិយោជិតរបស់ស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ និង
- ធ្វើការស៊ើបអង្កេតករណីរត់ពន្ធ និងករណីព្រហ្មទណ្ឌទាក់ទិននឹងបទល្មើសដែលរកឃើញនៅក្នុងក្របខណ្ឌនៃពន្ធចំណូលរបស់រដ្ឋ ព្រមទាំងនៅក្នុងសកម្មភាពរបស់មន្ត្រី និងនិយោជិតរបស់ស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ។

ក្រៅពីការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB នគរបាលហិរញ្ញវត្ថុគ្រាន់តែជាស្ថាប័នអនុវត្តន៍ច្បាប់មួយក្នុងចំណោមស្ថាប័នអនុវត្តន៍ច្បាប់ជាច្រើនដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតអំពើពុករលួយ។ បន្ថែមពីលើនេះទៀតមាន **នគរបាលសន្តិសុខ** ព្រមទាំង **នគរបាលជាតិ** ជាពិសេសគឺ **នាយកដ្ឋាននគរបាលសេដ្ឋកិច្ច (EPD)** របស់នគរបាលជាតិនេះ និង**នាយកដ្ឋានអនុវត្តន៍ច្បាប់ស្តីពីបទឧក្រិដ្ឋអង្គការចាត់តាំង (OCED)** ក៏ចូលរួមក្នុងការស៊ើបអង្កេតដែរ។ នាយកដ្ឋាន EPD មានតួនាទីចម្បងក្នុងការស៊ើបអង្កេតករណីពុករលួយនៅក្នុងវិស័យឯកជន ចំណែកឯនាយកដ្ឋាន OCED មានភារកិច្ចទប់ស្កាត់ និងតាមរកបទល្មើសពុករលួយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង និងបទល្មើសសេដ្ឋកិច្ច (GRECO, 2004a:5)។ ក្នុងការស៊ើបអង្កេតករណីពាក់ព័ន្ធនឹងអំពើពុករលួយ ពួកគេទាំងអស់ធ្វើការជិតស្និទ្ធជាមួយ KNAB ហើយនិងដូចដែលបានបញ្ជាក់ពីខាងលើ ស្ថាប័នទាំងនេះមានភារកិច្ចជួយដល់ការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ (KNAB) ក្នុងការស៊ើបអង្កេត ប្រសិនបើមានសំណើ។ ទាំងនគរបាលសន្តិសុខ ទាំងនគរបាលជាតិ ជាស្ថាប័នរដ្ឋបាលរបស់រដ្ឋដែលចំណុះឱ្យក្រសួងមហាផ្ទៃ។

**ស្ថាប័នអយ្យការសាធារណៈ PPO** គឺជាប្រព័ន្ធឯកភាព និងមជ្ឈការ ដែលមានបីថ្នាក់ គឺការិយាល័យអគ្គរដ្ឋអាជ្ញា ការិយាល័យរដ្ឋអាជ្ញាតុលាការតំបន់ និងការិយាល័យរដ្ឋអាជ្ញាតុលាការស្រុក ព្រមទាំងការិយាល័យរដ្ឋអាជ្ញាជំនាញ (មាត្រា ២២ ច្បាប់ស្តីពីរដ្ឋអាជ្ញា)។ ស្ថាប័នរដ្ឋអាជ្ញាសាធារណៈ PPO ដឹកនាំដោយអគ្គរដ្ឋអាជ្ញា ដែលតែងតាំងដោយសភា Saeima តាមអនុសាសន៍របស់ប្រធានតុលាការកំពូល សម្រាប់អាណត្តិ

៥ឆ្នាំ (មាត្រា ៣៨(១) ច្បាប់ស្តីពីរដ្ឋអាជ្ញា)។ រដ្ឋអាជ្ញាទាំងឡាយត្រូវបានតែងតាំង និងដកហូតពីតំណែងដោយអគ្គរដ្ឋអាជ្ញា តាមនីតិវិធីដែលចែងក្នុងច្បាប់ស្តីពីរដ្ឋអាជ្ញា (មាត្រា ២៣(២) ច្បាប់ស្តីពីរដ្ឋអាជ្ញា)។ មាត្រា ៥ នៃច្បាប់ស្តីពីរដ្ឋអាជ្ញាចែងថា ក្នុងពេលពិចារណារឿងក្តី រដ្ឋអាជ្ញាត្រូវធ្វើសេចក្តីសម្រេចដោយឯករាជ្យ និងអនុលោមតាមច្បាប់។ លើសពីនេះទៀត មាត្រា៦ នៃច្បាប់ស្តីពីរដ្ឋអាជ្ញាចែងថា រដ្ឋអាជ្ញាត្រូវមានឯករាជ្យពីឥទ្ធិពលរបស់ស្ថាប័នឯទៀត ឬមន្ត្រីផ្សេងទៀត។ ដូចមានចែងក្នុងមាត្រា ២ នៃច្បាប់ស្តីពីរដ្ឋអាជ្ញា ស្ថាប័នអយ្យការសាធារណៈ PPO មានភារកិច្ចដូចខាងក្រោមនេះ:

- ត្រួតពិនិត្យសកម្មភាពស្ថាប័នស៊ើបអង្កេត និងសកម្មភាពអនុវត្តរបស់ស្ថាប័នផ្សេងទៀត
- រៀបចំ ចាត់ចែង និងអនុវត្តការស៊ើបអង្កេត មុនពេលកាត់ទោស
- ផ្តួចផ្តើម និងអនុវត្តការចោទបទល្មើសព្រហ្មទណ្ឌក្នុងនាមរដ្ឋ
- ត្រួតពិនិត្យការអនុវត្តទោសឱ្យបានត្រឹមត្រូវ
- ការពារសិទ្ធិ និងការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គល និងរដ្ឋ ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់។
- ដាក់ពាក្យបណ្តឹង ឬដាក់សំអាងជូនតុលាការចំពោះករណីដែលច្បាប់កំណត់ និង
- ចូលរួមក្នុងបណ្តឹងសើរើរបស់តុលាការ នៅពេលដែលច្បាប់តម្រូវ។

នៅក្នុងស្ថាប័នអយ្យការសាធារណៈ PPO នាយកដ្ឋានមួយចំនួនត្រូវបានគេប្រគល់មុខងារពិសេសឱ្យ។ ប៉ុន្តែ ក្នុងចំណោមនាយកដ្ឋានទាំងនេះ គ្មាននាយកដ្ឋានណាមួយទទួលមុខងារចម្បងសម្រាប់តែករណីអំពើពុករលួយទេ (GRECO, 2002:24)។ រឿងក្តីទាំងអស់រួមទាំងករណីអំពើពុករលួយផង ត្រូវបានប្តឹងទៅតុលាការដោយស្ថាប័នអយ្យការសាធារណៈ PPO។

ឯករាជភាពនៃ**ចៅក្រម** និង**តុលាការ** ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ ដែលចែងថា ចៅក្រមត្រូវតែមានឯករាជ្យ ហើយស្ថិតនៅក្រោមអំណាចច្បាប់តែមួយគត់។ រឿងក្តីពុករលួយត្រូវដោះស្រាយដោយតុលាការដូចគ្នា នឹងបណ្តឹងផ្សេងទៀតដែលបានប្តឹងទៅតុលាការដែរ។

ប្រទេសឡាតវៀមិនមានស្ថាប័ន**អំប៊ុដស៍មឹន**ទេ។ ផ្ទុយទៅវិញ មានមុខងារខ្លះដែលតាមប្រពៃណី ត្រូវអនុវត្តដោយអំប៊ុដស៍មឹន ត្រូវបានអនុវត្តដោយស្ថាប័នផ្សេងៗទៀត ដូចជា ការិយាល័យរដ្ឋទទួលបន្ទុកការពារសិទ្ធិមនុស្ស និងស្ថាប័នអយ្យការសាធារណៈ PPO (GRECO, 2004b:9 and 13)។

## មេរៀនដែលទទួលបាន

របាយការណ៍វាយតម្លៃប្រទេសឡាតវៀ GRECO ២០០២ បញ្ជាក់ថា កង្វះការដឹកនាំ និងកង្វះកិច្ចសម្របសម្រួលរវាងស្ថាប័នអនុវត្តកិច្ចការនគរបាលនានា ដែលទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺជាបញ្ហាព្រួយបារម្ភចម្បង និងជាឧបសគ្គដល់កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយផងដែរ។ តាមទស្សនៈនេះ ចាំបាច់ត្រូវមានអនុសាសន៍ថ្នាក់ជាតិមួយ ដើម្បីលើកកម្ពស់ការសម្របសម្រួល ការចែករំលែកបទពិសោធ និងការចរាចរព័ត៌មានក្នុងចំណោមស្ថាប័នទាំងនោះ។ ការងារនេះ ក៏អាចរាប់ទាំងការបង្កើតអង្គភាពមួយសម្រាប់តាមដានការសម្របសម្រួល (២០០២:២១)។ ការបង្កើតការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB និងក្រុមប្រឹក្សាទប់ស្កាត់បទល្មើស និងអំពើពុករលួយនៃរដ្ឋសភា CPCC បានក្លាយទៅជាការដោះស្រាយបញ្ហានេះក្នុងកម្រិតមួយ។ ប៉ុន្តែ ក្នុងវិស័យស៊ើបអង្កេតអំពើពុករលួយ បញ្ហានៅមានលក្ខណៈបែកខ្ញែកពីស្ថាប័នអនុវត្តមួយចំនួនដូចបានរៀបរាប់ខាងលើ (GRECO, 2004a:6)។ របាយការណ៍តាមដានរបស់សហគមន៍អឺរ៉ុប បានកត់សម្គាល់ថា ប្រទេសនេះត្រូវការបង្កើតយន្តការសហការឱ្យមានប្រសិទ្ធភាព រវាងស្ថាប័នប្រឆាំងអំពើពុករលួយ ដូចជាស្ថាប័នសវនកម្ម និងស្ថាប័នគ្រប់គ្រងចំណូលរដ្ឋ (EC, 2003:15)។

ការព្រួយបារម្ភមួយទៀត គឺការគ្មានប្រព័ន្ធស័ក្តិសិទ្ធសម្រាប់ស៊ើបការណ៍លើអំពើពុករលួយដែលមានមុខងារអនុវត្ត រួមទាំងការស្រាវជ្រាវលើវិស័យដែលងាយរងគ្រោះ និងការកសាងយុទ្ធសាស្ត្រអន្តរាគមន៍ជាមុន។ ការព្រួយបារម្ភទាំងនេះត្រូវបានដោះស្រាយ តាមរយៈការបង្កើតនាយកដ្ឋានទទួលបន្ទុកសកម្មភាពស៊ើបអង្កេតពិសេស និងវិភាគ ព្រមទាំងនាយកដ្ឋានវិភាគអំពើពុករលួយ និងបង្កើតវិធីសាស្ត្រទប់ទល់នៅក្នុងការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB (GRECO 2004a:6)។

ការព្រួយបារម្ភផ្សេងទៀត គឺការយល់ឃើញរបស់សាធារណជន ដែលយល់ថាស្ថាប័នតុលាការ និងស្ថាប័នអយ្យការ គ្មានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ បញ្ហានេះគឺមួយផ្នែក ដោយសារភាពខុសគ្នារវាងបទល្មើសដែលមានចុះក្នុងបញ្ជី និងចំនួនបុគ្គលដែលទទួលទោសក្នុងរឿងក្តីពុករលួយ។ ក្រៅពីនេះ មានការកត់សម្គាល់ថា គ្មានអង្គភាពនៅក្នុងស្ថាប័នអយ្យការ ដែលមានមុខជំនាញខាងអំពើពុករលួយ។ ប្រការនេះត្រូវគេចាត់ទុកថាជាបញ្ហាមួយ ពីព្រោះការស៊ើបអង្កេត និងការធ្វើបណ្តឹងអាជ្ញាលើអំពើពុករលួយត្រូវមានការហ្វឹកហ្វឺនពិសេស ជំនាញ និងបទពិសោធន៍។ របាយការណ៍ GRECO បានស្នើឱ្យស្ថាប័នអយ្យការបង្កើតអង្គភាពតែមួយសម្រាប់ដោះស្រាយបញ្ហាអំពើពុករលួយ ដោយមានការទទួលខុសត្រូវបន្ថែមនៃការបណ្តុះបណ្តាល ការគាំទ្រ និងចែករំលែកបទពិសោធជាមួយអង្គភាពដទៃទៀត ដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ការបណ្តុះបណ្តាលទូទៅក៏ជាបញ្ហាចាំបាច់ដែរចំពោះចៅក្រម និងមន្ត្រីនគរបាល (GRECO 2002:24)។ ក្រៅពីនេះក៏មានការសង្កត់ធ្ងន់លើកិច្ចសហការ និងសម្របសម្រួលតួនាទីរបស់ស្ថាប័នអយ្យការ (EC, 2003:15)។ មានចាត់វិធានការដើម្បីពង្រឹងការបណ្តុះបណ្តាលរដ្ឋអាជ្ញា ចៅក្រម និងមន្ត្រីនគរបាល ប៉ុន្តែមិនមានគោរពតាមអនុសាសន៍ ដែលសុំឱ្យបង្កើតអង្គភាពតែមួយក្នុងស្ថាប័នអយ្យការសម្រាប់ដោះស្រាយករណីអំពើពុករលួយទេ (GRECO 2004a:8)។

ដូចបានបញ្ជាក់ខាងលើ ទោះបីមានស្ថាប័នផ្សេងៗបំពេញមុខងារដែលអនុវត្តដោយស្ថាប័នអំប៊ូដស៍មឺនក៏ដោយ ក៏គេយល់ថានៅមិនគ្រប់គ្រាន់ទេ។ សារៈសំខាន់នៃស្ថាប័នអំប៊ូដស៍មឺន ស្ថិតនៅត្រង់ការពិតដែលថា ក្នុងឋានៈជាស្ថាប័នឯករាជ្យមួយ ស្ថាប័ននេះអាចជាឧបករណ៍សំខាន់បន្ថែមមួយសម្រាប់ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើពុករលួយ។ បញ្ហានេះគឺដោយសារតួនាទីរបស់ស្ថាប័នអំប៊ូដស៍មឺនគ្របដណ្តប់លើសកម្មភាពនានាដែលខុសអំពីសកម្មភាពរបស់ស្ថាប័នដែលមានស្រាប់ ព្រោះស្ថាប័នអំប៊ូដស៍មឺន ផ្តោតទៅលើការការពារប្រជាពលរដ្ឋឱ្យរួចផុតពីការបំពានរបស់អំណាចសាធារណៈ។ មានរបាយការណ៍ថា ការរៀបចំបង្កើតស្ថាប័នអំប៊ូដស៍មឺន កំពុងតែត្រូវបានពិចារណា (GRECO 2004b:13)។ មេរៀនសំខាន់មួយដែលទទួលបានពីស្ថាប័នប្រឆាំងអំពើពុករលួយគឺ សារៈសំខាន់នៃការទទួលបាននូវការទុកចិត្តពីសាធារណជនតាមរយៈការបង្ហាញនូវប្រសិទ្ធភាពការងារ និងបញ្ចេញជាលទ្ធផលការងារ។ ដូចដែលរបាយការណ៍ GRECO បានកត់សម្គាល់កង្វះការដាក់ទោសចំពោះករណីអំពើពុករលួយពីមុន នាំឱ្យសាធារណជនបាត់បង់សេចក្តីទុកចិត្តលើកិច្ចប្រឹងប្រែងដែលកំពុងធ្វើ និងបាត់បង់សេចក្តីទុកចិត្តលើស្ថាប័នដែលមានភារកិច្ចទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ (GRECO 2002:26)។ យើងសង្ឃឹមថាបញ្ហានេះនឹងត្រូវដោះស្រាយដោយការិយាល័យប្រឆាំង និងទប់ស្កាត់អំពើពុករលួយថ្នាក់ជាតិ KNAB ដែលបានយកចិត្តទុកដាក់ខ្លាំងលើទំនាក់ទំនងសាធារណៈ និងបង្កើនការយល់ដឹង។ ប៉ុន្តែ របាយការណ៍តាមដានរបស់សហគមន៍អឺរ៉ុប បានកត់សម្គាល់ថា នៅពេលណាដែលការយល់ដឹងជាសាធារណៈស្តីអំពីអំពើពុករលួយ និងតួនាទី និងមុខងាររបស់ KNAB ត្រូវបានកើនឡើងជាទូទៅ ចាំបាច់ត្រូវតែមានកិច្ចប្រឹងប្រែងជាបន្តទៀត ដើម្បីបង្កើនការយល់ដឹងដល់ស្ថាប័នអនុវត្តន៍ច្បាប់ វិស័យអាជីវកម្ម និងសហគមន៍ជាទូទៅ (EC 2003:15)។

## ប្រភព


- គណៈកម្មការអឺរ៉ុប ២០០៣ របាយការណ៍តាមដានទូលំទូលាយអំពីត្រៀមចូលជាសមាជិករបស់ឡាតវៀ
  *http://www.europa.eu.int./comm/enlargement/report_2003.pdf.cmr_lv_final.pdf*
- Freedom House International ២០០៤ ប្រទេសឡាតវៀក្នុងអន្តរកាល ២០០៤
  *http://unpan1.un.org/introduc/groups/public/documents/NISPAcee/UNPAN016580.pdf*
- GRECO ២០០២ ការវាយតម្លៃលើកទីមួយ របាយការណ៍វាយតម្លៃលើប្រទេសឡាតវៀ
  *http://unpan1.un.org/introduc/groups/public/documents/UNTC/UNPAN009754.pdf*

- GRE CO ២០០៤a ការវាយតម្លៃលើកទីមួយ របាយការណ៍អនុលោមភាពប្រទេសឡាតវៀ
  *http://www.greco.coe.int/evaluations/Default.htm*
- GRECO ២០០៤b ការវាយតម្លៃលើកទី២ របាយការណ៍វាយតម្លៃប្រទេសឡាតវៀ
  *http://www.greco.coe.int/evaluations/Default.htm*
- យុទ្ធសាស្ត្រជាតិស្ដីពីការទប់ស្កាត់និងប្រឆាំងអំពើពុករលួយ ២០០៤-២០០៨, ២០០៤
  *http://www.knab.gov.lV/uploads/en_htm/National_Strategy.htm*
- Open Society Institute ២០០២ ការតាមដានដំណើរការចូលជាសមាជិកសហភាពអឺរ៉ុប: គោលនយោបាយប្រឆាំងអំពើពុករលួយ *http://www.eumap.org/reports/2002/corruption*
- Transparency International ២០០៣ របាយការណ៍អំពើពុករលួយសកល ២០០៣
  *http://www.globalcorruptionreport.org/gcr2003.htm*

ព័ត៌មានទាំងនេះត្រូវបានប្រមូលចេញពីគេហទំព័ររបស់ស្ថាប័នានាដែលបានរាយឈ្មោះខាងលើ ។

# ប្រទេសលីទុយអានី



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- គណៈកម្មការក្រមសីលធម៌មន្ត្រីជាន់ខ្ពស់ (COEC) *www.vtek.lt/enver.htm/*
- អង្គភាពត្រួតពិនិត្យរដ្ឋ (SC) （ការិយាល័យសវនកម្មរដ្ឋ） *www.vkontrole.lt/en/about_general.shtm/*
- Seimas Ombudsmen's Office (SOO) ការិយាល័យការពារប្រជាពលរដ្ឋនៃសភា Seimas *www3.lrs/lt/Pls/Inter/www_viewer.viewer.ViewTheme?p_int_tv_id=823&p_kalb_id=2*
- ស្ថាប័នស៊ើបអង្កេតពិសេស (SIS) *www.stt.lt?lang=en*

## បទបញ្ញត្តិចម្បង

- ច្បាប់ស្ដីពីការសម្របសម្រួលផលប្រយោជន៍សាធារណៈ និងឯកជនក្នុងវិស័យសាធារណៈ (APIPPS) *http://www.unpan1.un.org/introduc/groups/public/documents/UNTC/UNPAN017541.pdf*
- ច្បាប់ស្ដីពី Seimas Ombudsmen（ខែធ្នូ ១៩៩៨ No. VIII-950） *http://www3.lrs.lt/cgi-bin/preps2?Condition1=85986&Condition2*
- ច្បាប់ស្ដីពីសេវាស៊ើបអង្កេតពិសេស（២ ឧសភា ២០០២ No. VIII-1649） *http://www.stt.lt/en/files/stt_law.pdf*
- ច្បាប់ស្ដីពីអង្គភាពត្រួតពិនិត្យរដ្ឋ（២ ឧសភា ២០០០ No. I-907） ច្បាប់វិសោធនកម្ម ថ្ងៃទី ១៣ ធ្នូ ឆ្នាំ ២០០១ No. IX-950) *http://www.vkontrole.lt/en/_back_law.shtml* *http://www.vid.gov.lv/eng/4laws/docs/203-01.pdf*
- ច្បាប់ទប់ស្កាត់អំពើពុករលួយ（២៨ ឧសភា ២០០២ No. I-904） *http://www.stt.lt/en/files/prvention.pdf*

## សាវតា

សន្ទុះដ៏សំខាន់នៃការប្រយុទ្ធប្រឆាំងអំពើពុករលួយ នៅក្នុងប្រទេសលីទុយអានី គឺជាលក្ខណៈវិនិច្ឆ័យតឹងរ៉ឹង ដែលតម្រូវឱ្យប្រទេសនេះអនុម័ត ដើម្បីឆ្ពោះទៅរកការចូលជាសមាជិកសហភាពអឺរ៉ុប នៅខែឧសភា ឆ្នាំ ២០០៤ ។ សហភាពអឺរ៉ុបបានក្លាយទៅជាកម្លាំងចលករ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងប្រទេសលីទុយអានី (Transparency International, 2003: 177-178) ។

ចាប់តាំងពីអំឡុងទសវត្សរ៍ឆ្នាំ ១៩៩០ ប្រទេសលីទុយអានីបានបង្កើតនូវអង្គភាពភាគច្រើននៃក្របខណ្ឌច្បាប់ប្រឆាំងអំពើពុករលួយ (OSI, 2002:356) ។ ក្រៅពីនេះ ប្រទេសលីទុយអានីបានបង្កើតស្ថាប័ន និងទីភ្នាក់ងារជាច្រើន ជាពិសេស ក្នុងវិស័យអនុវត្តន៍ច្បាប់ ដើម្បីទប់ស្កាត់ តាមដាន និងប្រឆាំងអំពើពុករលួយ (GRECO, 2002:5) ។ អង្គភាពសំខាន់ជាងគេគឺស្ថាប័នស៊ើបអង្កេតពិសេស (SIS) ដែលបង្កើតក្នុងឆ្នាំ ១៩៩៧ ក្នុងក្រសួងមហាផ្ទៃ (GRECO, 2002:8) ។ ក្នុងឆ្នាំ២០០០ ក្រៅពីការអនុម័តច្បាប់ស្ដីពីស្ថាប័នស៊ើបអង្កេតពិសេស SIS នេះ គេបានពិនិត្យឃើញថា

SIS បានក្លាយទៅជាអ្វីដែលគេចាត់ទុកថាជាអង្គភាពប្រឆាំងអំពើពុករលួយឯករាជ្យពិតប្រាកដតែមួយគត់ ក្នុងប្រទេសជាច្រើនដែលបានចូលជាសមាជិកសហភាពអឺរ៉ុបនាឆ្នាំ ២០០៤ និងប្រទេសដែលកំពុងព្យាយាមចូលជាសមាជិក។

ការអភិវឌ្ឍសំខាន់ពីរទៀតគឺការអនុម័តរបស់សភា Seimas នូវកម្មវិធីជាតិប្រឆាំងអំពើពុករលួយ ក្នុងខែមករា ឆ្នាំ ២០០២ និងការអនុម័តច្បាប់ទប់ស្កាត់អំពើពុករលួយក្នុងខែឧសភា ឆ្នាំ ២០០២។ កម្មវិធីជាតិទូលំទូលាយប្រឆាំងអំពើពុករលួយ កំណត់នូវមធ្យោបាយបីយ៉ាងដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ ដូចជាៈ

- **ការទប់ស្កាត់** ដោយរាប់ទាំងការទប់ស្កាត់អំពើពុករលួយផ្នែកនយោបាយ និងទំនាស់ផលប្រយោជន៍ អំពើពុករលួយក្នុងរដ្ឋបាលក្នុងពន្ធដារ និងក្នុងអាជ្ញាធរគយ ក្នុងវិស័យសុខាភិបាល ក្នុងស្ថាប័នអនុវត្តន៍ច្បាប់ និងក្នុងស្ថាប័នតុលាការ ហើយជំរុញឱ្យមានលទ្ធកម្មសាធារណៈ និងឯកជនភាវូបនីយកម្ម សហប្រតិបត្តិការអន្តរជាតិ និងជំរុញឱ្យមានការចូលរួមរបស់សាធារណជន ក្នុងការទប់ស្កាត់អំពើពុករលួយ។
- **ការស៊ើបអង្កេត** ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការស៊ើបអង្កេត ចាប់ពីបញ្ញត្តិច្បាប់ដាក់កំហិតបុព្វសិទ្ធិ រហូតដល់ការបង្កើនការចែករំលែកព័ត៌មានរវាងស្ថាប័នផ្សេងៗដែលពាក់ព័ន្ធនឹងការស៊ើបអង្កេត និងការធ្វើបណ្តឹងអាជ្ញា។
- **ការអប់រំ** រួមទាំងការបញ្ចូលប្រធានបទស្តីពីការប្រឆាំងអំពើពុករលួយទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា។

ប្រទេសលីទុយអានីស្ថិតក្នុងចំណាត់ថ្នាក់ទី ៤៤ ក្នុងចំណោមប្រទេស ១៥៩ លើតារាងសន្ទស្សន៍របស់អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០០៥ ស្តីពីការយល់ឃើញពីអំពើពុករលួយ។ ថ្វីត្បិតតែប្រទេសលីទុយអានីបានចាត់វិធានការសំខាន់ៗជាច្រើន ដើម្បីដោះស្រាយបញ្ហាអំពើពុករលួយក៏ដោយ ក៏នៅក្នុងរបាយការណ៍តាមដានលម្អិតរបស់លីទុយអានីស្តីពីការត្រៀមចូលជាសមាជិកសហគមន៍អឺរ៉ុបបានសង្កត់ធ្ងន់ថា ការប្រឆាំងអំពើពុករលួយ "ត្រូវតែបន្តទទួលនូវអាទិភាពខ្ពស់" (2003:54)។ នៅក្នុងការកំណត់អំពើពុករលួយដែលធ្វើឡើងដោយអង្គការតម្លាភាពអន្តរជាតិ Transparency International ប្រចាំប្រទេសលីទុយអានីនេះ នាឆ្នាំ ២០០៤ គេបានរកឃើញថា ប្រជាពលរដ្ឋភាគច្រើនយល់ថាអំពើពុករលួយគឺជាការគំរាមកំហែងដល់ប្រទេសជាតិ។ សហភាពអឺរ៉ុបបានសន្និដ្ឋានថា "អំពើពុករលួយនៅតែជាប្រភពនៃការព្រួយបារម្ភនៅឡើយ ជាពិសេសនៅក្នុងស្ថាប័នគយ ស្ថាប័នលទ្ធកម្មសាធារណៈ នគរបាលចរាចរ ហើយនិងវិស័យសុខាភិបាល ព្រមទាំងប្រព័ន្ធតុលាការ (2003:13)។ ទោះបីជាអំពើពុករលួយក្នុងនយោបាយកម្រិតខ្ពស់ជាបញ្ហាតូចតាចក៏ដោយ ក៏អំពើពុករលួយខាងរដ្ឋបាលនៅតែមានកម្រិតខ្ពស់នៅឡើយ (OSI, 2002:351)។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**ការិយាល័យស៊ើបអង្កេតពិសេស SIS** ត្រូវបានបង្កើតដំបូងនៅក្នុងក្រសួងមហាផ្ទៃ នាឆ្នាំ១៩៩៧ ដែលមានមុខងារចម្បង ប្រមូល និងប្រើព័ត៌មានសម្ងាត់ស្តីអំពីបណ្តាញឧក្រិដ្ឋជន និងមន្ត្រីសាធារណៈពុករលួយ បន្ថែមទៅលើការអនុវត្តសកម្មភាពទប់ស្កាត់អំពើពុករលួយ (GRECO, 2002:8)។ បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការិយាល័យស៊ើបអង្កេតពិសេស ក្នុងឆ្នាំ ២០០០ ស្ថាប័ននេះ ដែលកាលនោះទទួលខុសត្រូវចំពោះរដ្ឋាភិបាល ឥឡូវនេះ បានក្លាយជាស្ថាប័នក្រោមច្បាប់រដ្ឋធម្មនុញ្ញ ទទួលខុសត្រូវចំពោះប្រធានាធិបតី និងសភា Seimas (មាត្រា ២(១) នៃច្បាប់ SIS) ដើម្បីបង្កើនឯករាជភាពរបស់ខ្លួន ពង្រឹងប្រសិទ្ធភាពរបស់ខ្លួន និងបង្កើនសមត្ថភាពរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងផ្នែកនីតិប្រតិបត្តិ។ ដូច្នេះ ស្ថាប័ននេះមានកាតព្វកិច្ចធ្វើរបាយការណ៍ពីសកម្មភាពរបស់ខ្លួនជាលាយលក្ខណ៍អក្សរជូនប្រធានាធិបតី និងប្រធានសភា Seimas យ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ (មាត្រា ៨(៧) នៃច្បាប់ SIS)។ ច្បាប់ស្តីពី SIS នេះ ចែងពីវត្ថុបំណង និងមូលដ្ឋានច្បាប់សម្រាប់សកម្មភាពរបស់ SIS ព្រមទាំងភារកិច្ច និងមុខងាររបស់ខ្លួនទៀតផង (មាត្រា ១ នៃច្បាប់ SIS)។

នាយកការិយាល័យស៊ើបអង្កេតពិសេស SIS ត្រូវបានតែងតាំងសម្រាប់អាណត្តិ ៥ឆ្នាំ ដោយប្រធានាធិបតី និងដោយមានការឯកភាពពីសភា Seimas។ បេក្ខជនសម្រាប់តំណែងនាយកការិយាល័យស៊ើបអង្កេតពិសេសនេះ ត្រូវបានស្នើឡើងដោយប្រធានាធិបតី ដាក់ជូនសភា

Seimas ។ ប្រធានាធិបតីអាចដកហូតតំណែងនាយកការិយាល័យស៊ើបអង្កេតពិសេសបាន ដោយសារនិងដោយមានការឯកភាពពីសភា Seimas អនុលោមតាមបទបញ្ញត្តិ មាត្រា ១២ នៃច្បាប់ SIS (មាត្រា ១១(១) នៃច្បាប់ SIS)។ អនុប្រធានទី១ និងអនុប្រធាននៃការិយាល័យស៊ើបអង្កេតពិសេសត្រូវបានតែងតាំង និងដកហូតដោយប្រធានាធិបតី តាមការពិគ្រោះយោបល់ជាមួយប្រធាន SIS (មាត្រា ១១(២) នៃច្បាប់ SIS)។

ការិយាល័យស៊ើបអង្កេតពិសេ SIS ចែកចេញជាផ្នែក និងនាយកដ្ឋានមួយចំនួន ដូចជា នាយកដ្ឋានសកម្មភាពស៊ើបការណ៍ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ និងការិយាល័យមូលដ្ឋាន ៤ ដែលការិយាល័យនីមួយៗមានផ្នែកស៊ើបអង្កេតរៀងៗខ្លួន ព្រមទាំងមាននាយកដ្ឋាន និងមានផ្នែកមួយចំនួនសម្រាប់តែអនុវត្តកិច្ចការផ្ទៃក្នុង។[១]

ការិយាល័យស៊ើបអង្កេតពិសេស SIS ត្រូវបានបង្កើតជាអង្គភាពចម្បងសម្រាប់ប្រឆាំងអំពើពុករលួយ ដែលមានការទទួលខុសត្រូវជាច្រើន ដូចជា ការសម្របសម្រួលកម្មវិធីប្រឆាំងអំពើពុករលួយ ការតាមរក និងទប់ស្កាត់បទល្មើសពុករលួយ ព្រមទាំងការធានានូវវិធានការសម្របសម្រួលនៅក្នុងស្ថាប័នរដ្ឋ និងរវាងស្ថាប័នទាំងនោះ ជាមួយនឹងសង្គម (Open Society Institute, 2002:367) GRECO, 2002:8)។ មុខងារចម្បងរបស់ការិយាល័យស៊ើបអង្កេតពិសេស មានចែងនៅក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការិយាល័យស៊ើបអង្កេតពិសេស គឺ:

- អនុវត្តសកម្មភាពប្រតិបត្តិការ ក្នុងការតាមរកនិងទប់ស្កាត់បទល្មើសទាក់ទិននឹងអំពើពុករលួយ។
- អនុវត្តការសាកសួរ និងស៊ើបអង្កេតបឋមលើបទល្មើសទាក់ទិននឹងអំពើពុករលួយ។
- សហការជាមួយស្ថាប័នអនុវត្តន៍ច្បាប់ឯទៀត ដូចដែលមានចែងក្នុងច្បាប់។
- ប្រមូល រក្សាទុក និងវិភាគព័ត៌មានស្តីអំពីអំពើពុករលួយ និងបាតុភាពសង្គម និងសេដ្ឋកិច្ចដទៃទៀតដែលពាក់ព័ន្ធ និង
- រៀបចំ និងអនុវត្តកម្មវិធីត្រួតពិនិត្យនិងទប់ស្កាត់បទល្មើស ដោយឈរលើមូលដ្ឋាននៃ ព័ត៌មានដែលប្រមូលបាន។

ក្នុងការបំពេញភារកិច្ចដែលប្រគល់ជូនទៅការិយាល័យស៊ើបអង្កេតពិសេស SIS មន្ត្រីរបស់ការិយាល័យនេះទទួលបានអំណាចទូលំទូលាយ រួមទាំងការតាមដានលិខិតឆ្លើយឆ្លង ទំនាក់ទំនងតាមអេឡិចត្រូនិក និងលំនៅដ្ឋាន ការចូលក្នុងទីតាំងនៃសហគ្រាសគ្រប់ប្រភេទ និងការធ្វើអធិការកិច្ចនៅចំណុចព្រំដែន (មាត្រា ១៣ ច្បាប់បង្កើតការិយាល័យស៊ើបអង្កេតពិសេស SIS)។ មាត្រា ១៦(២) នៃច្បាប់បង្កើតការិយាល័យស៊ើបអង្កេតពិសេស ចែងច្បាស់ថា "ស្ថាប័នរដ្ឋនិងទីភ្នាក់ងាររដ្ឋ ឬនិយោជិតនៃស្ថាប័នទាំងនោះ គណបក្សនយោបាយ អង្គការ និងចលនាសាធារណៈ បណ្តាញសារព័ត៌មាន នីតិបុគ្គល ឬរូបវន្តបុគ្គលឯទៀត" ត្រូវបានហាមឃាត់មិនឱ្យជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការ ឬការងារដទៃទៀតរបស់មន្ត្រីនៃការិយាល័យស៊ើបអង្កេតពិសេស។ ការស៊ើបសួរ និងការស៊ើបអង្កេតបឋម ដែលធ្វើឡើងដោយការិយាល័យស៊ើបអង្កេតពិសេស SIS (ដោយនាយកដ្ឋានស៊ើបអង្កេតរបស់ការិយាល័យនេះ) ត្រូវបានត្រួតពិនិត្យ រៀបចំ និងដឹកនាំដោយស្ថាប័នអយ្យការ (Article 22[2], SIS Law)។ ដើម្បីធានាឯករាជភាពរបស់ខ្លួន នាយកដ្ឋានស៊ើបអង្កេតទាំងនេះត្រូវរាយការណ៍ផ្ទាល់ទៅជូនអគ្គរដ្ឋអាជ្ញា ហើយមិនអាចរងឥទ្ធិពលអ្វីពីប្រធានរបស់ SIS ឡើយ (GRECO, 2002:9)។

ក្រៅពីនេះ មាត្រា ១៥ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ចែងថាការិយាល័យស៊ើបអង្កេតពិសេស SIS ត្រូវតែ:

- ចូលរួមក្នុងការកសាង និងអនុវត្តកម្មវិធីជាតិប្រឆាំងអំពើពុករលួយ ដោយរួមជាមួយនឹងទីភ្នាក់ងារនានា នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង។
- ដាក់ជូនប្រធានាធិបតី សភា Seimas និងរដ្ឋាភិបាល នូវសំណើស្តីពីការដាក់ឱ្យអនុវត្ត និងការកែលម្អច្បាប់ថ្មីៗ ដែលចាំបាច់សម្រាប់ការអនុវត្តសកម្មភាពទប់ស្កាត់អំពើពុករលួយ។

[១] មានក្រុមសវនកម្មផ្ទៃក្នុង គណនេយ្យករ នាយកដ្ឋាននីតិកម្ម នាយកដ្ឋានបុគ្គលិកនិងស៊ើបអង្កេតផ្ទៃក្នុង ការិយាល័យបច្ចេកវិទ្យាព័ត៌មាន ការិយាល័យកិច្ចការអង្គការ ការិយាល័យរដ្ឋបាល និងការិយាល័យនីតិវិធីរដ្ឋបាល។ ហើយក៏មានទីប្រឹក្សារបស់ប្រធាន និងមន្ត្រីព័ត៌មាន។

- ចូលរួមជាមួយរដ្ឋាភិបាលក្នុងការអនុវត្តមុខងារសម្របសម្រួលរបស់ខ្លួន ហើយនិងត្រួតពិនិត្យសកម្មភាពទប់ស្កាត់អំពើពុករលួយរបស់ទីភ្នាក់ងារផ្សេងៗ នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ហើយនិង
- រួមជាមួយនឹងទីភ្នាក់ងារនានា នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ដើម្បីអនុវត្តវិធានការទប់ស្កាត់អំពើពុករលួយ។

តាំងពីដើមរៀងមក ការិយាល័យ SIS បានដំណើរការជាស្ថាប័នអនុវត្តន៍ច្បាប់មួយ ដែលផ្តោតជាពិសេសតែលើវិធីសាស្ត្រប្រឆាំងអំពើពុករលួយតាមបែបបង្ក្រាប ឥឡូវនេះ ការិយាល័យ SIS បានបែរមកអនុម័តយកកាន់តែច្រើនឡើងនូវមធ្យោបាយ ៣ មុខព្រួញ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលផ្តោតទៅលើការទប់ស្កាត់ ការស៊ើបអង្កេត និងការអប់រំសាធារណៈ ដោយអនុលោមតាមអាទិភាព ដែលដាក់ចេញដោយ NACP (GRECO, 2002:23-24 and SIS, 2004:3)។ ការអភិវឌ្ឍនេះនឹងមានការពិភាក្សាតទៅទៀតនៅក្នុងផ្នែកដែលនិយាយអំពីមេរៀនដែលទទួលបាន។

## ការរៀបចំកិច្ចប្រតិបត្តិការ

មាត្រា ១២ នៃច្បាប់ទប់ស្កាត់អំពើពុករលួយចែងថា ការអនុវត្តវិធានការទប់ស្កាត់អំពើពុករលួយដូចមានចែងក្នុងច្បាប់ ត្រូវអនុវត្តដោយរដ្ឋាភិបាល **គណៈកម្មាការក្រមសីលធម៌សម្រាប់មន្ត្រីថ្នាក់ដឹកនាំ (COEC) និងទីភ្នាក់ងារនានាថ្នាក់ជាតិនិងថ្នាក់ខេត្ត-ក្រុង**[២] បន្ថែមទៅលើការិយាល័យស៊ើបអង្កេតពិសេស SIS។

ដូចពណ៌នាក្នុងមាត្រា ១៣ នៃច្បាប់ទប់ស្កាត់អំពើពុករលួយ រដ្ឋាភិបាលដើរតួសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយ ដែលក្នុងនោះរដ្ឋាភិបាលមានភារកិច្ចៈ ធានាថាក្រសួងនានាត្រូវតែអនុវត្តវិធានការទប់ស្កាត់អំពើពុករលួយ កសាងកម្មវិធីប្រឆាំងអំពើពុករលួយថ្នាក់ជាតិជាមួយការិយាល័យស៊ើបអង្កេតពិសេស SIS (សម្រាប់ដាក់ជូនទៅ និងអនុម័តដោយសភា Saeimas) និងផ្តល់អនុសាសន៍ជូនសភា Saeimas ដើម្បីដាក់ឱ្យអនុវត្ត និងធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានឯទៀត ដែលចាំបាច់សម្រាប់ទប់ស្កាត់អំពើពុករលួយ។

**គណៈកម្មការក្រមសីលធម៌មន្ត្រីថ្នាក់ដឹកនាំ (COEC)** ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ គឺជាអង្គភាពឯករាជ្យមួយទទួលខុសត្រូវចំពោះសភា Saeimas។ គណៈកម្មាការនេះមានសមាជិក ៥រូប សមាជិក ១រូប តែងតាំងដោយប្រធានាធិបតី ១រូប តែងតាំងដោយប្រធានសភា Saeimas ១រូប តែងតាំងដោយនាយករដ្ឋមន្ត្រី និង ២រូប តែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ប្រធានត្រូវបានតែងតាំងដោយសភា Saeimas។ គណៈកម្មាការនេះមានលេខាធិការដ្ឋានដែលមានសមាជិក ៦រូប ជាជំនួយការ (GECO, 2002:18)។

មុខងារសំខាន់នៃគណៈកម្មការ COEC គឺតាមមើល និងត្រួតពិនិត្យមន្ត្រីរដ្ឋការក្នុងការគោរពច្បាប់ APPIPS ស្តីពីការសម្រួលប្រយោជន៍សាធារណៈ និងប្រយោជន៍ឯកជនក្នុងស្ថាប័នរដ្ឋ ដែលមានគោលបំណងធានាឱ្យ "អ្នកកាន់តំណែងសាធារណៈត្រូវតែធ្វើសេចក្តីសម្រេចដោយផ្អែកតែលើផលប្រយោជន៍សាធារណៈ ធានាអព្យាក្រិតភាពនៃសេចក្តីសម្រេចដែលខ្លួនបានធ្វើ និងទប់ស្កាត់ការកើតឡើង និងការរីកសាយនៃអំពើពុករលួយនៅក្នុងមុខងារសាធារណៈ" (មាត្រា ១ នៃច្បាប់ APPIPS ស្តីពីការសម្រួលប្រយោជន៍សាធារណៈ និងប្រយោជន៍ឯកជនក្នុងស្ថាប័នរដ្ឋរបស់មន្ត្រីរដ្ឋការ)។ មាត្រា ៤ នៃច្បាប់ APPIPS នេះ ក៏បានចែងដែរថា មន្ត្រីជាន់ខ្ពស់ត្រូវតែប្រកាសពីផលប្រយោជន៍ឯកជន (ពោលគឺការប្រកាសពីទ្រព្យសម្បត្តិ និងប្រាក់ចំណូល) ដែលត្រូវដាក់ជូនគណៈកម្មការក្រមសីលធម៌មន្ត្រីថ្នាក់ដឹកនាំ COEC (មាត្រា ៥(៦))។ គណៈកម្មការ COEC វិភាគសេចក្តីប្រកាសទាំងនេះ ហើយអាចផ្តួចផ្តើមធ្វើការស៊ើបអង្កេតលើការគោរពតាមច្បាប់ APPIPS ស្តីពីការសម្រួលប្រយោជន៍សាធារណៈ និងប្រយោជន៍ឯកជនក្នុងស្ថាប័នរដ្ឋរបស់មន្ត្រីរដ្ឋការ ដោយផ្អែកតាមព័ត៌មានដែលទទួលបាន។ ផ្អែកតាមការវិភាគ និងការស៊ើបអង្កេត គណៈកម្មការ COEC អាចផ្តល់អនុសាសន៍ឱ្យចាត់វិធានការផ្សេងៗ ដូចជា ការដាក់ពិន័យ ឬការបណ្តេញចេញពីការងារ។ វិធានការទាំងនេះត្រូវតែដាក់ទៅតុលាការ។ គណៈកម្មការ COEC ក៏អាចបញ្ជូនព័ត៌មានទៅអង្គភាពអនុវត្តន៍ច្បាប់ ដើម្បីធ្វើការស៊ើបអង្កេតបន្ថែម (GECO, 2002:18 and OSI, 2002:364)។

[២] ច្បាប់ទប់ស្កាត់អំពើពុករលួយ ក៏មានចែងពី "អង្គការក្រៅរដ្ឋាភិបាល" ក្នុងមាត្រា ១២។ ប៉ុន្តែមាត្រា ១៦ បានចែងយោងថាជា "ទីភ្នាក់ងារមិនមែនរដ្ឋាភិបាល"។

ក្រៅពីនេះ តាមមាត្រា ១៤ នៃច្បាប់ទប់ស្កាត់អំពើពុករលួយ គណៈកម្មការ COEC មានភារកិច្ចវិភាគបញ្ហាក្រមសីលធម៌ដែលប្រឈមនឹងមន្ត្រីរដ្ឋការ និងផ្តល់អនុសាសន៍ទាក់ទិននឹងកម្មវិធីប្រឆាំងអំពើពុករលួយ និងដាក់ឱ្យអនុវត្ត និងកែលម្អនូវច្បាប់ ព្យាយាមលុបបំបាត់លក្ខខណ្ឌដែលនាំឱ្យមានទំនាស់ផលប្រយោជន៍ឯកជន និងផលប្រយោជន៍សាធារណៈនៅក្នុងក្របខណ្ឌកិច្ចការស៊ីវិល ផ្តល់អនុសាសន៍ជូនសភា Seimas និងទីភ្នាក់ងារឯទៀតៗនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង ទាក់ទិននឹងការអនុវត្តតាមបញ្ញត្តិនានានៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ និងរៀបចំសេចក្តីសង្ខេបនៃការអនុវត្តវិធានច្បាប់ ដែលកំណត់ពីតម្រូវការឱ្យមានក្រមសីលធម៌ស្ថាប័ននៅក្នុងវិស័យផ្សេងៗ ហើយនិងត្រូវចូលរួមក្នុងការរៀបចំសេចក្តីព្រាង និងការតាក់តែងវិធានទាំងនោះឱ្យទៅជាច្បាប់ ។

មាត្រា ១៦ នៃច្បាប់ទប់ស្កាត់អំពើពុករលួយចែងថា ដោយអនុលោមតាមច្បាប់នេះ **ទីភ្នាក់ងាររដ្ឋនិងខេត្ត-ក្រុងទាំងអស់**អាចបង្កើតអង្គភាពផ្ទៃក្នុងសម្រាប់ទប់ស្កាត់អំពើពុករលួយក្នុងវិស័យនៃអាណត្តិការងាររបស់ខ្លួន ហើយត្រូវអនុវត្តគោលនយោបាយជាតិក្នុងវិស័យទប់ស្កាត់អំពើពុករលួយ ។ ត្រូវធានាឱ្យមានការគោរពតាមសេចក្តីតម្រូវរបស់ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ត្រូវកសាង និងអនុម័តកម្មវិធីប្រឆាំងអំពើពុករលួយក្នុងក្របខណ្ឌនៃការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងបង្កើនការយល់ដឹងក្នុងចំណោមបុគ្គលិករបស់ខ្លួនលើបញ្ហាទប់ស្កាត់អំពើពុករលួយ ។

ក្នុងខែតុលា ឆ្នាំ ២០០១ **គណៈកម្មការសភាប្រឆាំងអំពើពុករលួយ Seimas** ត្រូវបានបង្កើតដើម្បីបន្តការងាររបស់គណកម្មាការស៊ើបអង្កេតបទល្មើសសេដ្ឋកិច្ច ។ តួនាទីចម្បងរបស់គណៈកម្មការនេះ គឺតាមមើលស្ថានភាពអំពើពុករលួយក្នុងប្រទេស ស្តាប់របាយការណ៍ និងវិភាគសកម្មភាព និងសេចក្តីសម្រេចរបស់ស្ថាប័នទាំងឡាយ លើវិធានការប្រឆាំងអំពើពុករលួយ ហើយនិងដាក់ជូននូវសេចក្តីស្នើស្តីពីវិធានការប្រឆាំងអំពើពុករលួយ (GECO, 2002:18 and OSI, 2002:369) ។

ក្រៅពីអង្គភាពដែលបញ្ជាក់ខាងលើ **អង្គភាពត្រួតពិនិត្យរដ្ឋ (SC)** ត្រូវបានបង្កើតដោយមាត្រា ១៣៣ នៃច្បាប់រដ្ឋធម្មនុញ្ញ និង**ការិយាល័យអំប៊ុដស៍មែនរបស់សភា Seimas (SOO)** ត្រូវបានបង្កើតដោយមាត្រា ៧៣ នៃច្បាប់រដ្ឋធម្មនុញ្ញ ដែលមានតួនាទីទប់ស្កាត់អំពើពុករលួយ ។

សកម្មភាពនៃអង្គភាពត្រួតពិតនិត្យរដ្ឋ (SC) ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការត្រួតពិនិត្យរដ្ឋ (មាត្រា ១) ។ អង្គភាពត្រួតពិនិត្យរដ្ឋនេះ គឺជាស្ថាប័នសវនកម្មកំពូលរបស់រដ្ឋាភិបាល ហើយទទួលខុសត្រូវចំពោះមុខសភា Seimas (មាត្រា ៥ (១)) ។ អង្គភាពត្រួតពិតនិត្យរដ្ឋដឹកនាំដោយអគ្គសវករ (មាត្រា ៦) ដែលតែងតាំងដោយប្រធានាធិបតី តាមអនុសាសន៍របស់សភា Seimas ។ មុខងារចម្បងរបស់អង្គភាពត្រួតពិនិត្យរដ្ឋ គឺត្រួតពិនិត្យភាពស្របច្បាប់និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងចាត់ចែងថវិការដ្ឋ និងធានាឱ្យការងារសវនកម្មរបស់រដ្ឋាភិបាលស្របទៅតាមស្តង់ដារអន្តរជាតិ (មាត្រា ៤) ។ នៅក្នុងការពិនិត្យ ប្រសិនបើអង្គភាពត្រួតពិនិត្យរដ្ឋ (SC) រកឃើញភាពមិនប្រក្រតី អង្គភាពនេះមានភារកិច្ចស៊ើបអង្កេតមុននឹងបញ្ជូនករណីនេះទៅជូនរដ្ឋអាជ្ញា (GRECO, 2002:20) ។ អង្គភាពត្រួតពិនិត្យរដ្ឋមានឯករាជភាពក្នុងការបំពេញមុខងាររបស់ខ្លួន (មាត្រា៥) ។ ការប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវបានចាត់ទុកថាជាភារកិច្ចសំខាន់របស់អង្គភាពត្រួតពិនិត្យរដ្ឋ ជាពិសេសក្នុងវិស័យស៊ើបរក និងសហការជាមួយអង្គភាពអនុវត្តន៍ច្បាប់នានា (GRECO, 2002:20) ។

គោលការណ៍មូលដ្ឋាននៃច្បាប់ និងសកម្មភាពរបស់អំប៊ុដស៍មែនសភា Seimas និងរចនាសម្ព័ន្ធចាត់តាំង និងអំណាចរបស់ SOO ត្រូវបានកំណត់ដោយច្បាប់ស្តីពីស្ថាប័នអំប៊ុដស៍មែនសភា Seimas (មាត្រា ១) ។ ស្ថាប័នអំប៊ុដស៍មែនសភាគឺជាអង្គភាពរដ្ឋឯករាជ្យ (មាត្រា ១០) ដែលមានសមាជិក ៥រូប ដែលម្នាក់ៗមានភារកិច្ចតាមមើលកិច្ចការនៅក្នុងមុខងារសាធារណៈមួយមុខៗដោយឡែកពីគ្នា ហើយតែងតាំងសម្រាប់អាណត្តិ ៤ឆ្នាំ ចេញពីបេក្ខជនដែលស្នើដោយប្រធានសភា Seimas (មាត្រា ៦) ។ តំណែងអំប៊ុដស៍មែនអាចដកហូតបានតែតាមការបោះឆ្នោតសម្លេងភាគច្រើនពីសភា Seimas (មាត្រា ៧) ។ អំប៊ុដស៍មែនត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំជូនសភា Seimas (មាត្រា ២៥) ។

មុខងារចម្បងរបស់អំប៊ូដស៍មែន (មន្ត្រីការពារប្រជាពលរដ្ឋ) គឺស៊ើបអង្កេតពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងការបំពានអំណាច និងការិយាធិបតេយ្យរបស់ស្ថាប័នរដ្ឋ រដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋបាលមូលដ្ឋាន ព្រមទាំងរបស់ស្ថាប័នយោធា លើកលែងតែច្បាប់ចែងផ្សេងពីនេះ (មាត្រា ៤)។ បន្ទាប់ពីបានស៊ើបអង្កេតហើយ អំប៊ូដស៍មែនអាចផ្តល់អនុសាសន៍ជូនអាជ្ញាធរដែលរងការស៊ើបអង្កេត ព្រមទាំងដាក់ករណីនេះជូនទៅអាជ្ញាធរស៊ើបអង្កេតផ្សេងៗ ប្រសិនបើរកឃើញថាមានភស្តុតាងពីបទល្មើស (មាត្រា ២២) ។ អំប៊ូដស៍មែនក៏មានតួនាទីអប់រំដល់សាធារណជនអំពីសិទ្ធិ និងវិធីប្រើសិទ្ធិទាំងនោះផងដែរ (GRECO, 2002:26)។

**អំណាចតុលាការ** មានឯករាជភាពទាំងក្នុងច្បាប់និងការអនុវត្ត (OSI, 2001:377)។ មិនមាននីតិវិធី ពិសេសសម្រាប់រឿងក្តីដែលទាក់ទិននឹងអំពើពុករលួយទេនៅក្នុងតុលាការ ហើយតុលាការខ្វះជំនាញពិសេសក្នុងរឿងពុករលួយ។ រឿងក្តីពុករលួយត្រូវបានស៊ើបអង្កេតតាមនីតិវិធីធម្មតាសម្រាប់ការស៊ើបអង្កេតមុនជំនុំជម្រះ (GRECO, 2002:15)។

តាមគុណតម្លៃនៃមាត្រា ១១៨ នៃរដ្ឋធម្មនុញ្ញ គឺរដ្ឋអាជ្ញាដែលត្រូវរៀបចំ និងទទួលបន្ទុកការស៊ើបអង្កេតបឋម និងរៀបចំបែបបទដាក់បណ្តឹងចោទលើរឿងក្តីព្រហ្មទណ្ឌក្នុងនាមរដ្ឋ ។ មានការបញ្ជាក់បង្ហាញថា រដ្ឋអាជ្ញាត្រូវមានឯករាជ្យក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ **ស្ថាប័នអយ្យការ**ចែកចេញជាការិយាល័យអគ្គរដ្ឋអាជ្ញា និងការិយាល័យរដ្ឋអាជ្ញាដែនដី និងដឹកនាំដោយអគ្គរដ្ឋអាជ្ញា ដែលតែងតាំងនិងដកហូតដោយប្រធានាធិបតី តាមការឯកភាពរបស់សភា Seimas។ ប្រព័ន្ធអយ្យការគឺមានឋានានុក្រមតឹងរ៉ឹង ហើយអគ្គរដ្ឋអាជ្ញាមានអំណាចទូលំទូលាយក្នុងការធ្វើអន្តរាគមន៍គ្រប់លំដាប់ថ្នាក់ (GRECO, 2002:12-13)។

មាន**នាយកដ្ឋានឧក្រិដ្ឋកម្មអង្គការចាត់តាំង និងស៊ើបអង្កេតអំពើពុករលួយ**មួយ ដែលត្រូវបានបង្កើតនៅក្នុងស្ថាប័នអយ្យការ ហើយមានអង្គភាពបុគ្គលិកដែលមានជំនាញខាងឧក្រិដ្ឋកម្មអង្គការចាត់តាំង និងស៊ើបអង្កេតអំពើពុករលួយ នៅក្នុងការិយាល័យរដ្ឋអាជ្ញាផ្សេងៗ។ រួមគ្នាទាំងអស់ ស្ថាប័នទាំងនោះបង្កើតបានជាប្រព័ន្ធអយ្យការឯកភាព និងមជ្ឈការមួយ សម្រាប់ដោះស្រាយបទល្មើសប្រភេទទាំងនេះ។ នាយកដ្ឋាននេះ មានតួនាទីចាប់ផ្តើម និងធ្វើបណ្តឹងអាជ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្ម អង្គការចាត់តាំង និងបទល្មើសពាក់ព័ន្ធអំពើពុករលួយ ត្រួតពិនិត្យសកម្មភាពសួរចម្លើយ និងអង្គភាពស៊ើបអង្កេតមុនជំនុំជម្រះដោយផ្តោតលើអំពើពុករលួយ ធ្វើការស៊ើបអង្កេតមុនជំនុំជម្រះលើបទល្មើសពុករលួយ គាំទ្រការចោទប្រកាន់របស់រដ្ឋនៅក្នុងតុលាការ ស៊ើបអង្កេតករណីអំពើពុករលួយដែលពាក់ព័ន្ធ និងសម្របសម្រួលសកម្មភាពសួរចម្លើយ និងការស៊ើបអង្កេតមុនជំនុំជម្រះក្នុងករណីបទល្មើសពាក់ព័ន្ធអំពើពុករលួយ។ ស្ថាប័ននេះក៏អាចទទួលយករឿងក្តីពីអគ្គរដ្ឋអាជ្ញាមកធ្វើការបន្តផងដែរ (GRECO, 2002:14)។

**នគរបាល** មានកាតព្វកិច្ចស៊ើបអង្កេតរាល់បទល្មើសដែលបានប្តឹង រាប់ទាំងអំពើពុករលួយផងដែរ។ ប៉ុន្តែ រឿងក្តីពុករលួយ ត្រូវបានបញ្ជូនទៅស្ថាប័នស៊ើបអង្កេតរដ្ឋ ឬ នាយកដ្ឋានឧក្រិដ្ឋកម្មអង្គការចាត់តាំង និងស៊ើបអង្កេតអំពើពុករលួយ (GRECO, 2002:10)។ ស្ថាប័នអនុវត្តន៍ច្បាប់ជាច្រើន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីបង្កើនកិច្ចសហការ និងចែករំលែកព័ត៌មានឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីតាមដាន និងស៊ើបអង្កេតបទល្មើសអំពើពុករលួយ (EC, 2003:14)។ ប៉ុន្តែ គឺរដ្ឋអាជ្ញាដែលមានភារកិច្ចបែងចែករឿងព្រហ្មទណ្ឌ ចំពោះសមត្ថកិច្ចរបស់អង្គភាពអនុវត្តន៍ច្បាប់។ ដូច្នេះ មានតែស្ថាប័នស៊ើបអង្កេតរដ្ឋទេ ដែលមានភារកិច្ចស៊ើបអង្កេតរឿងពុករលួយ (GRECO, 2004:7)។ ក្នុងចំណុចនេះ សកម្មភាពរបស់ស្ថាប័នស៊ើបអង្កេតរដ្ឋត្រូវបានតាមមើលដោយស្ថាប័នអយ្យការ (GRECO, 2002:24)។ គឺរដ្ឋអាជ្ញា ដែលជាអ្នកដាក់បណ្តឹងអាជ្ញាអំពីអំពើពុករលួយទៅតុលាការ (GRECO, 2002:16)។

## មេរៀនដែលទទួលបាន

ដូចដែលបានបញ្ជាក់ក្នុងរបាយការណ៍វាយតម្លៃប្រទេសលីទុយអានី (GRECO, 2002:22) និងរបាយការណ៍លម្អិតរបស់សហភាពអឺរ៉ុបស្តីពីការរៀបចំរបស់ប្រទេសលីទុយអានី ដើម្បីចូលជាសមាជិកសហភាពអឺរ៉ុប (២០០៣:១៣) ប្រទេសលីទុយអានីបានចាត់វិធានការទូលំទូលាយប្រឆាំងអំពើពុករលួយ ជាពិសេសគឺ គោលនយោបាយប្រឆាំងអំពើពុករលួយ រួមទាំងក្របខណ្ឌច្បាប់ និងការបង្កើតស្ថាប័ន គឺកំពុង

ស្ថិតក្នុងដំណើរការល្អ ហើយសមត្ថភាពក្នុងវិស័យប្រឆាំងអំពើពុករលួយត្រូវបានពង្រឹង។ ប៉ុន្តែនៅតែមានការព្រួយបារម្ភជាច្រើន និងនៅមានវិស័យជាច្រើនដែលត្រូវកែលម្អ។ សហគមន៍អឺរ៉ុបបានសន្និដ្ឋានថា "មានការចាំបាច់ក្នុងការពន្លឿនការអនុវត្តនូវកម្មវិធីនៅថ្នាក់ជាតិ និងកម្មវិធីតាមវិស័យ ដោយសង្កត់ធ្ងន់លើថ្នាក់មូលដ្ឋាន ព្រមទាំងធានាឱ្យមានធនធានគ្រប់គ្រាន់" (ទំព័រ ១៣-១៤)។

ការព្រួយបារម្ភមួយគឺ ការខ្វះព័ត៌មានអំពីអំពើពុករលួយ រួមទាំងខ្វះការស្រាវជ្រាវ ព្រមទាំងទិន្នន័យ និងស្ថិតិផ្លូវការ។ មានមតិលើកឡើងថា ទិន្នន័យ និងការស្រាវជ្រាវ ដែលសម្រួលដល់ការវាយតម្លៃស្ថានភាពអំពើពុករលួយ អាចនឹងជួយដល់ការអនុម័ត និងការអនុវត្តវិធានការប្រឆាំងអំពើពុករលួយ (GRECO 2002:22)។ កាន់តែមានការចាប់អារម្មណ៍ខ្លាំងឡើងលើការស្រាវជ្រាវនិងការប្រមូលទិន្នន័យនិងស្ថិតិ។ ឧទាហរណ៍សំខាន់មួយគឺ កិច្ចសហការរវាងស្ថាប័នស៊ើបអង្កេតរដ្ឋ និងអង្គការតម្លាភាពអន្តរជាតិ Transparency International ក្នុងការស្រាវជ្រាវខាងសង្គមលើករណីពុករលួយ (GRECO 2004:2-3)។

ទោះបីជាស្ថាប័នស៊ើបអង្កេតរដ្ឋទទួលបានការកោតសរសើរជាទូទៅក៏ដោយ ក៏មានការព្រួយបារម្ភថា ស្ថាប័ននេះគ្រាន់តែជាស្ថាប័នអនុវត្តន៍ច្បាប់មួយប៉ុណ្ណោះ។ នេះជាការព្រួយបារម្ភដែលទាក់ទង ជាពិសេស ជាមួយតួនាទីសម្របសម្រួលរបស់ស្ថាប័នស៊ើបអង្កេតរដ្ឋ និងកម្មវិធីជាតិប្រឆាំងអំពើពុករលួយ ដោយមានការសង្កត់ធ្ងន់លើការទប់ស្កាត់ និងការអប់រំថែមទៅលើតួនាទីក្នុងការស៊ើបអង្កេត។ របាយការណ៍វាយតម្លៃ GRECO ក៏បានស្នើឱ្យបង្កើតទីភ្នាក់ងារពិសេស ដែលមានការទទួលខុសត្រូវលើកម្មវិធីថ្នាក់ជាតិប្រឆាំងអំពើពុករលួយ។ គេបានចាត់ទុកថាមានការផ្តោតអារម្មណ៍ខ្លាំងពេកទៅលើការអនុវត្ត ហើយត្រូវមានការផ្តោតអារម្មណ៍បន្ថែមទៀតទៅលើការទប់ស្កាត់ និងការអប់រំសាធារណៈទាំងស្ថាប័នស៊ើបអង្កេតរដ្ឋ និងស្ថាប័នផ្សេងទៀតដែលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (CE, 2003:14 and GRECO, 2002:23)។ ទោះបីជាការទទួលខុសត្រូវលើកម្មវិធីជាតិប្រឆាំងអំពើពុករលួយស្ថិតនៅលើស្ថាប័នស៊ើបអង្កេតរដ្ឋក៏ដោយ ក៏ការបង្កើតនាយកដ្ឋានទប់ស្កាត់អំពើពុករលួយរបស់ស្ថាប័ននេះ អាចអនុញ្ញាតឱ្យស្ថាប័ននេះផ្តោតកាន់តែទូលាយទាំងទៅលើការទប់ស្កាត់ ទាំងទៅលើការអប់រំផងដែរ (GRECO, 2004: 3-4)។ អំប៊ូដស៍មីនក៏ដើរតួសំខាន់ក្នុងការអប់រំសាធារណជនផងដែរ (GRECO, 2004:26)។

ការព្រួយបារម្ភខ្លាំងជាងនេះគឺ កង្វះកិច្ចសហការរវាងស្ថាប័នស៊ើបអង្កេតក្នុងរឿងក្តីពុករលួយ ហើយគ្មាននីតិវិធីច្បាស់លាស់សម្រាប់បែងចែកករណីពុករលួយ។ កាលណាការស៊ើបអង្កេតមុនជំនុំជម្រះលើរឿងពុករលួយ ដែលមានជាប់ទាក់ទិនទៅនឹងបទល្មើសផ្សេងទៀត កិច្ចសហការក៏កាន់តែមានការលំបាកខ្លាំង។ លើសពីនេះទៀត គេពិនិត្យឃើញថា ការស៊ើបអង្កេតមុនជំនុំជំរះគ្មានគុណភាព ដែលនាំឱ្យតុលាការត្រូវតែបញ្ជូនសំណុំរឿងទៅឱ្យអ្នកជំនាញពិនិត្យ។ ការងារបែបនេះក៏នាំឱ្យនីតិវិធីតុលាការប្រើពេលវេលាវែងផងដែរ ដែលនាំឱ្យមានការកកស្ទះរឿងក្តីពុករលួយជាច្រើន (GRECO, 2005:24-25)។ គេបានចាត់វិធានការដើម្បីដោះស្រាយកង្វល់ទាំងនេះ តាមរយៈការចាត់តាំងរដ្ឋអាជ្ញាជាអាជ្ញាធរចែករំលែករឿងក្តីព្រហ្មទណ្ឌ និងផ្តល់ការបណ្តុះបណ្តាលជំនាញដល់បុគ្គលិកស៊ើបអង្កេត (GRECO, 2004:6-7)។ ប៉ុន្តែសហគមន៍អឺរ៉ុប នៅតែបញ្ជាក់ថា ត្រូវឱ្យមានកិច្ចប្រឹងប្រែងឱ្យបានខ្លាំង "ដើម្បីបង្កើតបណ្តាញមួយសមស្រប និងស័ក្តិសិទ្ធសម្រាប់ឱ្យមានប្រសិទ្ធភាពក្នុងការ ចែករំលែកព័ត៌មាន" រវាងស្ថាប័នអនុវត្តន៍ច្បាប់នានា (2003: 14)។

## ប្រភព


- គណៈកម្មាការអឺរ៉ុប ២០០៣ របាយការណ៍តាមដានទូលំទូលាយអំពីត្រៀមចូលជាសមាជិករបស់លីទុយអានី
  *http://www.europa.eu.int./comm/enlargement/report_2003.pdf.cmr_lv_final.pdf*
- GRECO ២០០២ ការវាយតម្លៃលើកទី១ របាយការណ៍វាយតម្លៃលើប្រទេសលីទុយអានី
  *http://unpan1.un.org/introduc/groups/public/documents/UNTC/UNPAN009762.pdf*
- GRECO ២០០៤a ការវាយតម្លៃលើកទី១ របាយការណ៍អនុលោមភាពរបស់ប្រទេសលីទុយអានី
  *http://www.greco.coe.int/evaluations/Default.htm*
- កម្មវិធីជាតិប្រឆាំងអំពើពុករលួយនៃសាធារណរដ្ឋលីទុយអានី *http://www.stt.lt/en/files/programme.pdf*

- Open Society Institute, ២០០២ ការតាមដានដំណើរការចូលជាសមាជិកសហភាពអឺរ៉ុប: គោលនយោបាយប្រឆាំងអំពើពុករលួយ *http://www.eumap.org/reports/2002/corruption*
- ស្ថាប័នស៊ើបអង្កេតពិសេស ឆ្នាំ ២០០៤ របាយការណ៍អនុវត្តន៍ប្រចាំឆ្នាំ ២០០៣ *http://www.stt.lt/en/files/report_2003.pdf*
- Transparency International ២០០៣ របាយការណ៍អំពើពុករលួយសកល ២០០៣ *http://www.globalcorruptionreport.org/gcr2003.htm*
- Transparency International ២០០៣ ជំពូកប្រទេសលីទុយអានី ២០០៤ ស្ថានភាពអំពើពុករលួយក្នុងប្រទេសលីទុយអានី ការស្រាវជ្រាវអំពីអាកប្បកិរិយាពលរដ្ឋនិងសហគ្រិនចំពោះអំពើពុករលួយ និងបទពិសោធក្នុងការប្រឈមមុខនឹងករណីពុករលួយ ឆ្នាំ ២០០៤ *http://www.transparency.lt/up/1101479107_MAP_OF_CORR2004_WWW.zip*

ព័ត៌មានទាំងនេះត្រូវបានប្រមូលចេញពីគេហទំព័ររបស់ស្ថាប័ននានាដែលបានរាយឈ្មោះខាងលើ ។

# ប្រទេសម៉ាឡេស៊ី



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសុចរិតភាពថ្នាក់ជាតិ

- ទីភ្នាក់ងារប្រឆាំងអំពើពុករលួយ (ACA) សូមមើលគេហទំព័រ *www.bpr.gov.my/English/acamain.htm/*
- សភារបស់អគ្គព្រះអាជ្ញារបស់ប្រទេសម៉ាឡេស៊ី សូមមើលគេហទំព័រ *www.agc.gov.my/agc/index-eng.htm*
- វិទ្យាស្ថានសុចរិតភាពរបស់ប្រទេសម៉ាឡេស៊ី (IIM)
- នាយកដ្ឋានសវនកម្មជាតិ (NAD) (ការិយាល័យអគ្គសវនករ) សូមមើលគេហទំព័រ *www.audit.gov.my*
- ការិយាល័យទទួលពាក្យបណ្តឹងសាធារណៈ (PBC) សូមមើលគេហទំព័រ *www.bpa.jpam.my/index1.php?lang=E*

## បទបញ្ញត្តិចម្បង

- ច្បាប់ស្តីពីសវនកម្មឆ្នាំ ១៩៥៧
- ច្បាប់ប្រឆាំងអំពើពុករលួយ (ច្បាប់លេខ ៥៧៥/១៩៩៧) សូមមើលគេហទំព័រ *www.bpr.gov.my/English/mainact.htm*

## សាវតា

ច្បាប់ដំបូងដែលបានអនុម័តនៅក្នុងប្រទេសម៉ាឡេស៊ី ដែលមានគោលបំណងប្រយុទ្ធប្រឆាំងអំពើពុករលួយគឺ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ឆ្នាំ១៩៥០។ ក្រោយពីបានទទួលឯករាជ្យក្នុងឆ្នាំ ១៩៥៧ វិធានការមួយក្នុងចំណោមវិធានការជាច្រើនរបស់រាជរដ្ឋាភិបាលគឺការសិក្សាពីអំពើពុករលួយក្នុងប្រទេស។ ក្រោយពីបានបញ្ចប់ការសិក្សានេះ វិធានការមួយចំនួនត្រូវបានគេចាត់ឡើងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយរួមបញ្ចូលទាំងការបង្កើតនូវកងកម្លាំងពិសេសដើម្បីស៊ើបអង្កេតនូវរឿងពាក់ព័ន្ធនឹងអំពើពុករលួយនានា (Kassim Bin Mohamad, 2005:3)។ បន្ទាប់ពីនេះមក មានការអនុម័តច្បាប់ ស្តីពីការទប់ស្កាត់នូវអំពើពុករលួយ ហៅកាត់ថា (PCA) នៅឆ្នាំ១៩៦១ ហើយនិងការបង្កើតទីភ្នាក់ងារប្រឆាំងអំពើរពុករលួយ ហៅកាត់ថា (ACA) ក្នុងឆ្នាំ១៩៦៧។ បន្ទាប់ពីការអនុម័តច្បាប់ស្តីពីការបង្កើតការិយាល័យជាតិសម្រាប់ការស៊ើបអង្កេតក្នុងឆ្នាំ ១៩៧៣មក ទីភ្នាក់ងារប្រឆាំងអំពើពុករលួយត្រូវបានគេប្តូរឈ្មោះទៅជាការិយាល័យជាតិសម្រាប់ការស៊ើបអង្កេត ហៅកាត់ថា (NBI)។ ទោះបីជាការផ្លាស់ប្តូរឈ្មោះនេះមិនមានការប្រែប្រួលជាក់លាក់ណាមួយក្នុងអាណត្តិការងាររបស់ខ្លួនក៏ដោយ ក៏ការផ្លាស់ប្តូរនេះត្រូវបានសាធារណជនយល់ឃើញថា NBI ត្រូវបានគេផ្តល់អាណត្តិការងារច្រើនទូលំទូលាយជាងអាណត្តិរបស់ ACA ដែលធ្លាប់មានពីមុន ហើយតួនាទីរបស់វាក៏បានគ្របដណ្តប់ទៅលើល្បែងស៊ីសង និងការរត់ពន្ធ ព្រមទាំងតួនាទីផ្សេងៗទៀត។ ជាមួយនឹងការអនុម័តច្បាប់ស្តីពីការបង្កើតទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ក្នុងឆ្នាំ ១៩៨២មក ស្ថាប័ននេះក៏ត្រូវបានគេប្តូរឈ្មោះម្តងទៀតទៅជាទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ដែលហៅថា (ACA) ក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹងការងារពិតប្រាកដរបស់ទីភ្នាក់ងារនេះ គឺការងារទប់ស្កាត់អំពើពុករលួយ។

ក្រៅពីទីភ្នាក់ងារប្រឆាំងអំពើពុករលួយ (ACA) ស្ថាប័នផ្សេងៗមួយចំនួនទៀតត្រូវបានគេបង្កើតឡើងក្នុងគោលបំណងដោះស្រាយបញ្ហាអំពើពុករលួយ ពង្រឹងនូវភាពស្មោះត្រង់ ដូចជា ការិយាល័យទទួលពាក្យបណ្តឹងសាធារណៈ (PCB) ដែលបង្កើតឡើងក្នុងឆ្នាំ ១៩៧១ ។ ដើម្បីឱ្យស្របទៅតាមការអភិវឌ្ឍជាតិ និងអន្តរជាតិ ច្បាប់នេះត្រូវបានគេធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៧១ ហើយក៏បាននិរាករណ៍ចេញ និងដាក់ជំនួសដោយច្បាប់ប្រឆាំងអំពើពុករលួយក្នុងឆ្នាំ ១៩៩៧(Kassim Bin Mohamed, 2003) ។ ច្បាប់ប្រឆាំងអំពើពុករលួយ ចែងនូវការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរចំពោះរាល់អំពើពុករលួយ ។ តាមច្បាប់ប្រឆាំងអំពើពុករលួយ ការផ្តល់សំណូកក៏ដូចជាការទទួលសំណូក ត្រូវចាត់ទុកថាជាបទល្មើស ហើយរាល់មន្ត្រីរាជការដែលគេយកសំណូកទៅជូននោះ គឺត្រូវរាយការណ៍ទៅទីភ្នាក់ងារប្រឆាំងអំពើពុករលួយ ឬរាយការណ៍ទៅប៉ូលិស (ផ្នែកទី ១០ និងទី ១៧) ។

ប្រទេសម៉ាឡេស៊ី ស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ ៣៩ ក្នុងចំណោមបណ្តាប្រទេស ១៥៩ លើតារាងសន្ទស្សន៍របស់អង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០០៥ ស្តីពីការយល់ឃើញពីអំពើពុករលួយ ។ ក្នុងការប្រៀបធៀបជាមួយប្រទេសផ្សេងទៀតនៅក្នុងតំបន់អាស៊ី ប្រទេសម៉ាឡេស៊ីមានអំពើពុករលួយក្នុងកម្រិតមួយទាបជាងគេ ប៉ុន្តែ ប្រទេសនេះទទួលស្គាល់ថា អំពើពុករលួយអាចបង្កនូវការគំរាមគំហែងដល់ការអភិវឌ្ឍទៅថ្ងៃអនាគត ។ ដោយយល់ឃើញពីបញ្ហានេះ ដំណាក់កាលជាច្រើនត្រូវបានគេចាត់ឡើងដើម្បីពង្រឹងនូវភាពស្មោះត្រង់នៅក្នុងជួររដ្ឋាភិបាល ទាំងនៅថ្នាក់សហព័ន្ធ និងថ្នាក់ជាតិ ។ ដោយគិតដល់បញ្ហានេះ នៅក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលបានរៀបចំឱ្យមានផែនការសុចរិតភាពជាតិ (NIP) ។ ផែនការសុចរិតភាពជាតិ (NIP) នេះចង្អុលបង្ហាញនូវអាទិភាពដំបូងចំនួន ៥ ក្នុងគោលបំណងដើម្បីជម្រុញនូវភាពស្មោះត្រង់នៅក្នុងសង្គមជាតិទាំងមូល ។ អាទិភាពទាំងនោះមាន:

- កាត់បន្ថយឱ្យបានជាដាច់ខាតនូវអំពើពុករលួយ ការអនុវត្តមិនត្រឹមត្រូវ និងការរំលោភអំណាច ។
- បង្កើនឱ្យភាពស័ក្តិសិទ្ធនៃប្រព័ន្ធចែកចាយជាសាធារណៈ ហើយនិងជំនះឱ្យបាននូវនីតិវិធីស្មុគស្មាញរបស់ការិយាធិបតេយ្យ ។
- ធ្វើឱ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម និងក្រមសីលធម៌មុខជំនួញ ។
- ពង្រឹងស្ថាប័នគ្រួសារ ហើយនិង
- បង្កើនជីវភាពរស់នៅ និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ។

វិទ្យាស្ថានសុចរិតភាពរបស់ប្រទេសម៉ាឡេស៊ី (IIM) ត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ និងសម្របសម្រួលការអនុវត្តផែនការសុចរិតភាពជាតិ (NIP) ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**ទីភ្នាក់ងារប្រយុទ្ធប្រឆាំងអំពើពុករលួយ (ACA)** ចាប់ផ្តើមកិច្ចប្រតិបត្តិការរបស់ខ្លួននៅថ្ងៃទី ១ ខែតុលា ឆ្នាំ១៩៦៧ ។ ACA គឺជាស្ថាប័នដំបូងដែលទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន ដែលបានអនុម័តយកវិធីសាស្ត្រសំខាន់ ៣ មុខព្រួញ គឺស៊ើបអង្កេត ទប់ស្កាត់ និងអប់រំ ។ ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយកំណត់នូវអាណត្តិការងារ និងមុខងាររបស់ ACA ។ ចំពោះដំណើការប្រតិបត្តិ ACA ត្រូវបានគេដាក់ឱ្យស្ថិតនៅក្រោមនាយកដ្ឋានរបស់នាយករដ្ឋមន្ត្រី ។

ទីភ្នាក់ងារប្រយុទ្ធប្រឆាំងអំពើពុករលួយ (ACA) ដឹកនាំដោយអគ្គនាយកម្នាក់ ដែលជ្រើសរើសចេញពីចំណោមសមាជិកមន្ត្រីរដ្ឋាភិបាលតែងតាំងដោយព្រះមហាក្សត្រ (Yang di-Pertuan Agong) តាមយោបល់របស់នាយករដ្ឋមន្ត្រី (កថាភាគ ៣-២ នៃច្បាប់ប្រឆាំងអំពើពុករលួយ) ។ អគ្គនាយកមិនមានសន្តិសុខមុខតំណែងទេ ព្រោះគាត់ត្រូវបំពេញការងារក្រោមព្រះតម្រិះរបស់ព្រះមហាក្សត្រ Yang di-Pertuan Agong តាមការស្នើរសុំរបស់នាយករដ្ឋមន្ត្រី (កថាភាគ ៣-៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ) ។ ពាក់ព័ន្ធនឹងការដាក់វិន័យ អគ្គនាយកគឺហាក់បីដូចជាសមាជិករបស់រដ្ឋាភិបាល (កថាភាគ ៣-៥ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ) ។ យោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អគ្គនាយកទទួលខុសត្រូវចំពោះការដឹកនាំ ការគ្រប់គ្រង និងការត្រួតពិនិត្យនូវរាល់បញ្ហាទាំងអស់ពាក់ព័ន្ធទៅនឹង ACA (កថាភាគ ៣៨-៦) ។ អគ្គនាយកមានជំនួយការដែលជាអគ្គនាយករងចំនួន ២ រូប ។ ACA មានការិយាល័យកណ្តាលមួយ ដែលមាននាយកដ្ឋានចំណុះចំនួន

៩ ព្រមទាំងមានការិយាល័យថ្នាក់រដ្ឋនៅក្នុងរដ្ឋចំនួន ១៤ របស់ប្រទេសម៉ាឡេស៊ី ដែលនៅតាមការិយាល័យនីមួយៗដឹកនាំដោយនាយកការិយាល័យរដ្ឋ។ នៅតាមរដ្ឋទាំងនោះ មានបង្កើតអនុសាខាជាច្រើន ក្នុងគោលបំណងពង្រីកនូវវត្តមានរបស់ ACA នៅតាមតំបន់ដាច់ស្រយាលថែមទៀតនៅក្នុងប្រទេស។ បច្ចុប្បន្ននេះ គេគ្រោងរៀបចំបង្កើតអនុសាខាបន្ថែមទៀត (Kassim Bin Hohamed, 2005:3)។

មុខងារសំខាន់ៗមួយចំនួនរបស់ ACA គឺ:

- ទទួល និងពិចារណានូវរាល់របាយការណ៍ពាក់ព័ន្ធនឹងអំពើពុករលួយ ហើយនិងធ្វើការស៊ើបអង្កេតដោយចំហ ក៏ដូចជាដោយសម្ងាត់លើរបាយការណ៍នានា ដែលគេយល់ថាអាចធ្វើបាន។
- តាមរក និងស៊ើបអង្កេតនូវរាល់បទល្មើសដែលមានការសង្ស័យ ការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើស ឬការឃុបឃិតក្នុងការប្រព្រឹត្តនូវបទល្មើសណាមួយ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។
- ប្រមូលភស្តុតាងដើម្បីបង្ហាញនូវការប្រព្រឹត្តបទល្មើស ការរំលោភអំណាច និង/ឬ ការដាក់វិន័យចំពោះការប្រព្រឹត្តិមិនត្រឹមត្រូវ។
- ធានាថាផលប្រយោជន៍សាធារណៈ និងយុត្តិធម៌ត្រូវបានការពារឱ្យស្របតាមច្បាប់ជាតិ និងបទបញ្ញត្តិដែលពាក់ព័ន្ធ តាមរយៈការផ្តល់ការពិគ្រោះផ្នែកច្បាប់ និងការកាត់ក្តីដ៏យុត្តិធម៌ចំពោះរឿងពាក់ព័ន្ធនឹងអំពើពុករលួយ និងការរំលោភអំណាច។
- ជួយដល់ប្រធានស្ថាប័នរដ្ឋ និងស្ថាប័នឯកជន ក្នុងការអនុវត្តការដាក់វិន័យចំពោះមន្ត្រីដែលបានរំលោភលើច្បាប់ការងារ និងរំលោភក្រមសីលធម៌ការងារ ដូចដែលបានរាយការណ៍នៅក្នុងរបាយការណ៍ដាក់វិន័យរបស់ ACA។
- ពិនិត្យលើការបំពេញការងារ ពិនិត្យលើប្រព័ន្ធ និងនីតិវិធីផ្សេងៗរបស់អង្គភាពរដ្ឋ ដើម្បីជួយសម្រួលដល់ការស្វែងរកបទល្មើសដោយផ្អែកតាមច្បាប់ប្រឆាំងអំពើពុករលួយ ព្រមទាំងធានានូវការពិនិត្យឡើងវិញលើការបំពេញការងារ ប្រព័ន្ធ និងនីតិវិធីទាំងនោះដែលអគ្គនាយកយល់ឃើញថា អាចបង្កឱ្យមានអំពើពុករលួយ។
- ណែនាំដល់ប្រមុខដឹកនាំអង្គភាពរដ្ឋ ក្នុងការកែប្រែការអនុវត្ត កែប្រែប្រព័ន្ធ និងកែប្រែនីតិវិធីផ្សេងៗ ដែលតាមមតិយោបល់របស់អគ្គនាយក វាមានភាពចាំបាច់សម្រាប់កាត់បន្ថយនូវឱកាសនៃការប្រព្រឹត្តិអំពើពុករលួយ។
- ត្រួតពិនិត្យលើការជ្រើសរើស និងលើការអនុម័តយល់ព្រម ចំពោះមន្ត្រីដែលស័ក្តិសមទៅនឹងតំណែងខ្ពស់ៗនៅក្នុងវិស័យសាធារណៈព្រមទាំងនៅក្នុងស្ថាប័នមួយចំនួន ដើម្បីធានាថា មានតែបេក្ខជនដែលមិនធ្លាប់ពាក់ព័ន្ធទៅនឹងអំពើពុករលួយ និងការរំលោភអំណាចប៉ុណ្ណោះទេ ដែលត្រូវបានគេទទួលយក។ ហើយនិង
- អប់រំដល់សាធារណជន ឧទាហរណ៍ដូចជា ធ្វើឱ្យសាធារណជនយល់ដឹងពីផលអាក្រក់នៃអំពើពុករលួយ ព្រមទាំងធ្វើឱ្យការគាំទ្រពីសាធារណជន ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ មានការរីកចម្រើននិងគង់វង្ស។

មន្ត្រីរបស់ ACA គឺត្រូវបានគេផ្តល់នូវអំណាចជាច្រើនទូលំទូលាយដើម្បីបំពេញមុខងាររបស់ខ្លួន។ អនុផ្នែកទី ៧-២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ចែងថា "ចំពោះគោលបំណងនៃច្បាប់នេះ រាល់មន្ត្រីរបស់ទីភ្នាក់ងារមានអំណាច និងអភ័យឯកសិទ្ធិ ដូចគ្នាទៅនឹងអំណាច និងអភ័យឯកសិទ្ធិទាំងអស់របស់មន្ត្រីប៉ូលីស ដែលបានទទួលការតែងតាំងតាមច្បាប់ស្តីពីប៉ូលីសឆ្នាំ ១៩៦៧។" មន្ត្រីជាន់ខ្ពស់របស់ ACA ត្រូវបានគេផ្តល់សិទ្ធិ ដូចគ្នាទៅនឹងសិទ្ធិរបស់អធិការស្រុក ក្នុងការចេញដីកាផ្សេងៗ និងចេញនូវលិខិតបញ្ជាក់នានា (កថាភាគទី ៧-៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។ ពេលណាដែលមន្ត្រីណាម្នាក់របស់ ACA មានហេតុផលដែលអាចជឿបានថា បទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ បានកើតឡើង ឬអាចនឹងកើតឡើងនោះគាត់អាចផ្តើមធ្វើការស៊ើបអង្កេត ហើយដើម្បីធ្វើកិច្ចការនេះ គាត់នឹងអនុវត្តនូវអំណាចទាំងអស់ក្នុងការស៊ើបអង្កេត ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងនូវអំពើពុករលួយ និងក្រមនីតិវិធីព្រហ្មទណ្ឌ (កថាភាគ ២១-៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។ ផ្នែកទី ២២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយចែងថា ក្នុងគោលបំណងដើម្បីធ្វើការស៊ើបអង្កេត មន្ត្រីរបស់ទីភ្នាក់ងារមានអំណាចក្នុងការកោះហៅសាក្សី ដែលគេតម្រូវឱ្យមកបង្ហាញខ្លួន ព្រមទាំងបង្ហាញនូវរាល់ព័ត៌មានចំពោះបញ្ហាដែលគេសួរគាត់ ហើយក៏អាចតម្រូវឱ្យបុគ្គលឯទៀតបង្ហាញ ឬដាក់ជូននូវឯកសារផ្សេងៗជាដើម។ ប៉ុន្តែ សិទ្ធិនេះមិនត្រូវអនុវត្តចំពោះសៀវភៅធនាគារឡើយ។ ប្រសិនបើបុគ្គលណាម្នាក់ប្រព្រឹត្តផ្ទុយទៅនឹងផ្នែកទី ២២ គាត់ត្រូវមានទោសពីបទប្រព្រឹត្តបទល្មើស។ ផ្នែកទី ២៨ នៃច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយក៏បានចែងផងដែរថា:

រាល់បុគ្គលទាំងអស់ ដែលមន្ត្រីរបស់ទីភ្នាក់ងារតម្រូវឱ្យផ្តល់នូវព័ត៌មានចំពោះករណីណាមួយ ដែលវាជាកាតព្វកិច្ចរបស់គាត់ក្នុងការស៊ើបអង្កេត ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ហើយដែលព័ត៌មាននោះស្ថិតនៅក្នុងកណ្តាប់ដៃរបស់បុគ្គលនោះ ជននោះត្រូវជាប់កាតព្វកិច្ចក្នុងការផ្តល់នូវព័ត៌មាននោះ ។

នៅពេលធ្វើការស៊ើបអង្កេត ចលនៈទ្រព្យដែលគិតថាអាចយកមកធ្វើជាភស្តុតាងបានពាក់ព័ន្ធទៅនឹងបទ ល្មើសដូចដែលមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនោះ គឺអាចត្រូវបានរឹបអូសដោយមន្ត្រីរបស់ទីភ្នាក់ងារ ដែលមានឋានៈជាអ្នកស៊ើបអង្កេត ឬឋានៈខ្ពស់ជាងអ្នកស៊ើបអង្កេត (ផ្នែកទី ២៥ នៃច្បាប់ប្រឆាំងអំពើពុករលួយ) ។ មន្ត្រីរបស់ទីភ្នាក់ងារក៏មាន សិទ្ធិផងដែរក្នុងការចាប់ខ្លួនបុគ្គលណាម្នាក់ដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងច្បាប់ប្រឆាំងអំពើពុករលួយ (ផ្នែកទី ៣០ នៃច្បាប់នេះ) ។ អំណាចផ្សេងៗទៀតរបស់មន្ត្រីរបស់ទីភ្នាក់ងារ គឺកំណត់ដោយព្រះរាជអាជ្ញា ដែលនឹងមានចែងបន្ថែមនៅខាងក្រោម ។

ACA បានបង្កើតនូវប្រព័ន្ធទទួលពាក្យបណ្តឹងសាធារណៈ ក្នុងគោលបំណងដើម្បីធានាថាសាធារណជន អាចដាក់ពាក្យបណ្តឹងបានដោយស្រួល ។ ប្រព័ន្ធទាំងនេះ រួមទាំងលេខប្រអប់ប៉ុស្តិ៍ប្រៃសណីយ៍ដែលមិនតម្រូវឱ្យមានការបិទតែម ហើយបណ្តឹងអាចធ្វើដោយអនាមិកបាន ព្រមទាំងលេខទូរស័ព្ទនិយាយដោយឥតគិតថ្លៃប្រចាំការ ២៤ ម៉ោង ។ ក្នុងគោលបំណងដើម្បីធានាថា ប្រជាពលរដ្ឋដឹងនូវប្រព័ន្ធនៃការប្តឹងនេះ មធ្យោបាយទំនាក់ទំនងទាំងនេះ ត្រូវបានចុះផ្សាយនៅក្នុងកាសែតជាតិនានា ដែលជាផ្នែកមួយនៃការអប់រំ និងការជូនដំណឹងជាសាធារណៈរបស់ ACA ដែលរួមបញ្ចូលទាំងការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលអំពាវនាវសុំឱ្យមានការសហប្រតិបត្តិការពីប្រជាពលរដ្ឋ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

## ការរៀបចំកិច្ចប្រតិបត្តិការ

ទោះបីជា ACA មានការទទួលខុសត្រូវទាំងមូល ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏នៅឆ្នាំ ១៩៩៨ នាយករដ្ឋមន្ត្រីបានណែនាំដល់ក្រសួង-មន្ទីរនៃរដ្ឋាភិបាលសហព័ន្ធ ព្រមទាំងរដ្ឋាភិបាលប្រចាំរដ្ឋ នាយកដ្ឋាន និងទីភ្នាក់ងារផ្សេងៗ ឱ្យធ្វើការបង្កើតនូវគណៈកម្មាធិការគ្រប់គ្រងភាពស្មោះត្រង់ ហៅកាត់ថា (IMC) ដើម្បីជួយដល់ការងាររបស់ទីភ្នាក់ងារ ACA ។ មុខងាររបស់ IMC គឺបំពេញការងារដើម្បីឈានទៅរកការទប់ស្កាត់អំពើពុករលួយ ការរំលោភបំពានអំណាច និងការគ្រប់គ្រងមិនត្រឹមត្រូវ តាមរយៈការលើកឡើងនូវបញ្ហាអភិបាលកិច្ចល្អ ។ បន្ថែមលើនេះទៀត គោលបំណងរបស់ IMC គឺដើម្បីដាក់ឱ្យមានជានិច្ចនូវការគ្រប់គ្រងផ្ទៃក្នុងប្រឆាំងនឹងអំពើពុករលួយ ។ ACA រួមជាមួយនឹងអង្គភាពធ្វើផែនការទំនើបភាវូបនីយកម្ម រដ្ឋបាល កម្លាំងពលកម្ម ហៅកាត់ថា (MAMPU) ត្រូវបានគេតែងតាំងឱ្យធ្វើជាសហអ្នកសម្របសម្រួលរបស់គណៈកម្មការជាតិគ្រប់គ្រងភាពស្មោះត្រង់ IMC ។ តាមរយៈយន្តការនេះ ACA ត្រូវបានគេផ្តល់ឱ្យនូវខ្សែបណ្តោយដោយផ្ទាល់ក្នុងការគ្រប់គ្រងទៅលើនាយកនៃនាយកដ្ឋាន និងទីភ្នាក់ងារនានា ដែលអនុញ្ញាតឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធថែមទៀត ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (Kassim Bin Mohamad, 2005:4) ។

រាល់បណ្តឹងអាជ្ញាលើបទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ អាចចាប់ផ្តើមធ្វើដោយព្រះរាជអាជ្ញា ឬដោយមានការយល់ព្រមពី**ព្រះរាជអាជ្ញា** (ផ្នែកទី ៥០ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ) ។ (៣) យោងតាមកថាខ័ណ្ឌទី ៣ នៃមាត្រា ១៤៥ នៃរដ្ឋធម្មនុញ្ញរបស់រដ្ឋសហព័ន្ធ គឺអគ្គមេធាវី ដែលជាអ្នកមានអំណាចក្នុងការសម្រេចថា ចាប់ផ្តើមធ្វើការចោទប្រកាន់ បន្តការចោទប្រកាន់ ឬបញ្ឈប់ការចោទប្រកាន់ ចំពោះបទល្មើសណាមួយជាជាងការដំណើរការនីតិវិធីនៅចំពោះមុខតុលាការ Syariah តុលាការនៅតាមស្រុក ឬតុលាការសឹក ។ **អគ្គមេធាវីក៏ជាប្រធាននៃសភានៃអគ្គមេធាវី**របស់ប្រទេសម៉ាឡេស៊ីផងដែរ ។ អគ្គមេធាវីត្រូវបានតែងតាំងដោយព្រះមហាក្សត្រ Yang di-Pertuan Agong តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី ។ ដើម្បីក្លាយជាអគ្គមេធាវី ជននោះត្រូវតែមានលក្ខណៈសម្បត្តិជាចៅក្រមនៃតុលាការសហព័ន្ធ ។

នៅក្នុងសភានៃអគ្គមេធាវី មាន**ផ្នែកអយ្យការ**ដែលទទួលបន្ទុកអនុវត្តអំណាចរបស់អគ្គមេធាវី ក្នុងតួនាទីជាព្រះរាជអាជ្ញា ដោយអនុលោមតាមផ្នែកទី ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មុខងារបន្ថែមទៀតរបស់ផ្នែកអយ្យការ (គឺផ្នែកទទួលបន្ទុកខាងការចោទប្រកាន់) នេះមាន:

- ធ្វើបណ្តឹងអាជ្ញានៅតុលាការខេត្ត-ក្រុង (សាលាដំបូង) និងតុលាការជាន់ទាបបំផុត(សាលាលហុ)។
- កាត់សេចក្តីរឿងព្រហ្មទណ្ឌ បណ្តឹងឧទ្ធរណ៍ ដាក់ពាក្យសុំ និងពិនិត្យសារឡើងវិញនៅតុលាការកំពូល។
- ធ្វើការប្តឹងទាស់ និងដាក់ពាក្យសុំផ្សេងៗទៅសាលាឧទ្ធរណ៍ និងតុលាការរដ្ឋសហពន្ធ័។
- ផ្តល់យោបល់ និងធ្វើការណែនាំដល់ទីភ្នាក់ងារទទួលបន្ទុកខាងស៊ើបអង្កេត និងចោទប្រកាន់បទល្មើស។
- រៀបចំសំណុំឯកសារស៊ើបអង្កេត និងសម្រេចថាតើត្រូវចាប់ផ្តើមការចោទប្រកាន់ ឬមិនចោទ។

ដោយយោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ព្រះរាជអាជ្ញាត្រូវបានគេផ្តល់ឱ្យបន្ថែមនូវអំណាច ដែលពាក់ព័ន្ធទៅនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីរបស់ ACA ចុះធ្វើអធិការកិច្ចលើសៀវភៅធនាគារ និងប្រមូលនូវសម្ភារៈ និងព័ត៌មានផ្សេងៗពីធនាគារ (ផ្នែកទី ៣១ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។ ព្រះរាជអាជ្ញាក៏អាចអនុញ្ញាតផងដែរដល់រាល់មន្ត្រីរបស់ ACA ឱ្យចូលទៅក្នុងបរិវេណ ឬទីតាំងនានា និងធ្វើការឆែកឆេរបរិវេណ ឬទីតាំងនោះ ព្រមទាំងបុគ្គលគ្រប់រូបដែលមានវត្តមាននៅទីនោះ។ ប្រសិនបើមន្ត្រីរបស់ ACA យល់ឃើញថាវាមិនសមស្របក្នុងការសុំការអនុញ្ញាតពីព្រះរាជអាជ្ញា មន្ត្រី ACA នោះអាចចូលទៅកាន់បរិវេណ ឬទីតាំងនោះ ហើយផ្តើមធ្វើការឆែកឆេរដោយមិនចាំបាច់មានការអនុញ្ញាត (ផ្នែកទី ២៣ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។ នៅក្នុងកាលៈទេសៈខ្លះ នៅពេលដែលព្រះរាជអាជ្ញាយល់ស្របតាមព័ត៌មានដែលបានរាយការណ៍ដោយ ACA ព្រះរាជអាជ្ញាអាចបញ្ជាឱ្យធ្វើការឃាត់ទុក ឬរឹបអូសទ្រព្យសម្បត្តិ (ផ្នែកទី ៣៣ និង ៣៤ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។

ព្រះរាជអាជ្ញាក៏អាចតម្រូវឱ្យបុគ្គលគ្រប់រូបប្រកាសទ្រព្យសម្បត្តិ នៅពេលដែលបុគ្គលនោះត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ប្រសិនបើព្រះរាជអាជ្ញាមានហេតុផលសមស្របអាចជឿបានថា សាច់ញ្ញាតិណាម្នាក់ មិត្តភ័ក្តិ ឬបុគ្គលផ្សេងទៀតអាចជាប្រយោជន៍ក្នុងការស៊ើបអង្កេតរបស់គាត់ គាត់ក៏អាចតម្រូវឱ្យបុគ្គលនោះធ្វើការប្រកាសទ្រព្យសម្បត្តិផងដែរ។ នៅក្នុងករណីនេះ ព្រះរាជអាជ្ញាក៏អាចស្នើរសុំទៅធនាគារ ឱ្យផ្តល់នូវព័ត៌មានស្តីពីទ្រព្យសម្បត្តិរបស់បុគ្គលទាំងនោះ ដូចដែលបានបង្ហាញខាងលើ។ ប្រសិនបើព្រះរាជអាជ្ញាមាននូវហេតុផលសមស្របដែលអាចជឿបានថា រាល់មន្ត្រីណាម្នាក់របស់រដ្ឋាភិបាល ត្រូវបានគេស្នើរសុំឱ្យធ្វើការប្រកាសទ្រព្យសម្បត្តិដែលខ្លួនមាន ចំពោះទ្រព្យដែលមានចំនួនច្រើនលើសពីប្រាក់ចំណូលរបស់គាត់ ហើយដោយធ្វើការពិចារណាទៅលើស្ថានការណ៍ផ្សេងៗទៀតនេះ គាត់អាចស្នើរសុំឱ្យបុគ្គលនោះធ្វើការពន្យល់ថាតើទ្រព្យនោះបានមកដោយរបៀបណា។ ប្រសិនបើមន្ត្រីមិនបានធ្វើការពន្យល់ឱ្យបានច្បាស់លាស់ទេ គាត់នឹងមានកំហុសពីបទល្មើសមួយ ហើយប្រសិនបើតុលាការយល់ឃើញថាមានកំហុស គាត់នឹងត្រូវមានទោសដូចគ្នាទៅនឹងបុគ្គលដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនូវអំពើពុករលួយដែរ។ ការផ្តន្ទាទោសដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរចំពោះបុគ្គលណាដែលមិនបានប្រតិបត្តិតាម នៅក្នុងការងារស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា (ផ្នែកទី ៣២ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។ គួរកត់សម្គាល់ថា ចំពោះករណីទាំងនេះ ការបង្ហាញភស្តុតាងគឺជាបន្ទុករបស់ជនជាប់ចោទ។

**នាយកដ្ឋានសវនកម្មជាតិ (NAD)** ដឹកនាំដោយ**អគ្គសវនករ** ដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ Yang di-Pertuan Agong តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី (មាត្រា ១០៥-១ របស់រដ្ឋធម្មនុញ្ញសហព័ន្ធ)។ ទោះបីជា NAD ស្ថិតនៅក្រោមនាយកដ្ឋាននៃនាយករដ្ឋមន្ត្រីក៏ដោយ តាមរយៈការដឹកនាំរបស់អគ្គសវនករ នាយកដ្ឋានសវនកម្មជាតិ NAD គឺជាស្ថាប័នឯករាជ្យមួយ ហើយនៅក្នុងស្ថាប័នឯករាជ្យនេះ អគ្គសវនករ មានសន្តិសុខមុខតំណែង ហើយត្រូវរាយការណ៍ទៅជូនរដ្ឋសភាតាមរយៈព្រះមហាក្សត្រ Yang di-Pertuan Agong (មាត្រា ១០៥-៣ និង ១០៧-១ នៃរដ្ឋធម្មនុញ្ញសហព័ន្ធ)។ បន្ថែមលើនេះទៀត អគ្គសវនករមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការមុខងារសាធារណៈទេ (មាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញសហព័ន្ធ)។ យោងតាមមាត្រា ១០៦-១ គឺអគ្គសវនករទេ ដែលមានសិទ្ធិធ្វើសវនកម្មលើគណនី និងធ្វើរបាយការណ៍អំពីគណនីរបស់សហព័ន្ធ និងរដ្ឋ។ ដោយផ្អែកតាមផ្នែកទី ៧ នៃច្បាប់ស្តីពីសវនកម្ម ក្នុងការបំពេញការងាររបស់ខ្លួន ដូចដែលមាន

ចែងនៅក្នុងរដ្ឋធម្មនុញ្ញសហព័ន្ធ អគ្គសវនករអាចកោះហៅបុគ្គលគ្រប់រូប ដើម្បីមកពន្យល់ និងផ្តល់ព័ត៌មាន ដែលអគ្គសវនករយល់ថាជាការចាំបាច់ក្នុងការបំពេញមុខងាររបស់ខ្លួន។ អគ្គសវនករអាចពិនិត្យរាល់កំណត់ហេតុទាំងអស់ដែលចាំបាច់សម្រាប់បំពេញមុខងាររបស់ខ្លួន។ ជាងនេះទៅទៀត អគ្គសវនករអាចអនុញ្ញាតឱ្យមន្ត្រីណាម្នាក់ធ្វើការស៊ើបអង្កេត ពិនិត្យ និងធ្វើសវនកម្មក្នុងនាមរបស់គាត់ ហើយរាយការណ៍ពីបញ្ហានេះទៅឱ្យគាត់វិញ ព្រមទាំងអាចប្រគល់អំណាចរបស់គាត់ជាលាយលក្ខណ៍អក្សរទៅឱ្យមន្ត្រីណាម្នាក់ដូចមានចែងនៅក្នុងផ្នែកទី ៧។ គឺតាមរយៈបញ្ញត្តិ នេះហើយដែលមន្ត្រីរបស់ NAD អាចទទួលការផ្ទេរអំណាចពីអគ្គសវនករបាន។ តាមវិធីនេះ NAD មានកាតព្វកិច្ចធានានូវអាទិភាពនៃការទទួលខុសត្រូវនៅក្នុងការគ្រប់គ្រង និងចាត់ចែងមូលនិធិសាធារណៈ តាមរយៈការធ្វើសវនកម្មលើបញ្ជីគណនី និងលើសកម្មភាពរបស់រដ្ឋាភិបាលសហព័ន្ធ រដ្ឋាភិបាលរដ្ឋ អង្គភាពដែលបង្កើតដោយច្បាប់ អាជ្ញាធរមូលដ្ឋាន និងអង្គភាពផ្សេងៗទៀត។ បុគ្គលិករបស់ NAD គឺជាសមាជិកនៃមន្ត្រីរាជការនៃប្រទេសម៉ាឡេស៊ី។ ក្រៅពីតួនាទីដែលមានចែងនៅក្នុងច្បាប់ស្តីពីសវនកម្ម អគ្គសវនករក៏អាចបំពេញតួនាទីនៅតាមទីភ្នាក់ងារសាធារណៈផ្សេងៗទៀត ក្នុងការអភិវឌ្ឍគោលការណ៍អភិបាលកិច្ចសមស្របសម្រាប់ក្របខ័ណ្ឌសាធារណៈ។

**ការិយាល័យទទួលបណ្តឹងសាធារណៈ (PCB)** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៧១ ហើយជាផ្នែកមួយនៅក្នុងនាយកដ្ឋានរបស់នាយករដ្ឋមន្ត្រី។ PCB ដើរតួជាយន្តការមួយ ដែលតាមរយៈយន្តការនេះ សាធារណជនអាចដាក់ពាក្យបណ្តឹងអំពីការបំពេញការងារមិនត្រឹមត្រូវ និងការរំលោភអំណាចនៅក្នុងសេវាសាធារណៈ (គឺនៅក្នុងក្រសួងមន្ទីររបស់រដ្ឋាភិបាល)។ PCB ដឹកនាំដោយអគ្គនាយកមួយរូប ជាមួយគ្នានឹងអគ្គនាយករងមួយរូប។ មាន**គណៈកម្មាធិការអចិន្ត្រៃទទួលពាក្យបណ្តឹងសាធារណៈ (PCPC)** ផងដែរ ដែលមានមុខងារ និងការទទួលខុសត្រូវក្នុងការបង្កើតគោលនយោបាយស្តីពីប្រព័ន្ធគ្រប់គ្រងបណ្តឹងសាធារណៈ ពិនិត្យនិងសម្រេចលើរបាយការណ៍ទទួលបណ្តឹងសាធារណៈ ដែលរៀបចំដោយ PCB ណែនាំដល់ប្រធានអាជ្ញាធរផ្សេងៗដែលជាប់ពាក់ព័ន្ធ ឱ្យចូលរួមក្នុងការប្រជុំរបស់ PCPC ដើម្បីបំភ្លឺអំពីពាក្យបណ្តឹង ឬរឿងផ្សេងៗ ហើយនិងណែនាំអាជ្ញាធរដែលជាប់ពាក់ព័ន្ធឱ្យដោះស្រាយបញ្ហា ដោយផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតលើបណ្តឹង។ PCPC មានអំណាចរដ្ឋបាលក្នុងការស្នើសុំ និងទទួលព័ត៌មាន ពិនិត្យមើលសំណុំឯកសារ និងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត និងស្នើសុំឱ្យមន្ត្រីដែលមានការជាប់ពាក់ព័ន្ធ ធ្វើការពន្យល់។

## មេរៀនដែលទទួលបាន

ការអនុម័តច្បាប់បច្ចុប្បន្ន គឺច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ - កើតចេញមកពីទស្សនៈដែលយល់ថាច្បាប់មុនមានភាពទន់ខ្សោយ ហើយក៏បង្កើតច្បាប់នេះឡើងដើម្បីជំនួសច្បាប់ចាស់។ ជាពិសេស គឺច្បាប់មុននោះត្រូវបានគេយល់ថាមិនមានប្រសិទ្ធភាព ពីព្រោះការផ្តន្ទាទោសបទល្មើសអំពើពុករលួយមានភាពស្រាលពេក។ លើសពីនេះទៀត មន្ត្រីរបស់ ACA មិនមានអំណាចគ្រប់គ្រាន់ដើម្បីបំពេញការងាររបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងវិស័យសាធារណៈឡើយ។ ប្រការនេះរួមបញ្ចូលទាំងករណី ដែលមានលទ្ធភាពតិចតួចក្នុងការរឹបអូសទ្រព្យធន ដែលបានទទួលពីសកម្មភាពពុករលួយ។ បញ្ហានេះមានចែងក្នុងច្បាប់បច្ចុប្បន្ន ព្រមទាំងមានដាក់បញ្ញត្តិនៅក្នុងផ្នែកមួយដែលចែងថាការមានសម្បត្តិទ្រព្យដែលមិនអាចពន្យល់ឱ្យច្បាស់លាស់បាន ត្រូវចាត់ទុកជាបទល្មើសសម្រាប់ការស៊ើបអង្កេត។ (Kassin Bin Mohamed, 2003)

ជោគជ័យរបស់ ACA គឺដោយសារតែមានឆន្ទៈនយោបាយរបស់រដ្ឋាភិបាល រួមជាមួយនឹងការបន្តនូវការពង្រឹងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ហើយពង្រឹងនូវអាណត្តិការងាររបស់ ACA ឱ្យកាន់តែមានប្រសិទ្ធភាព ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ (Kassim Bin Mohamad, 2005:5 and 10)។

ដូចបានពោលខាងលើ រដ្ឋាភិបាលបានទទួលស្គាល់ថាគឺជាការចាំបាច់ក្នុងការជម្រុញឱ្យមានភាពស្មោះត្រង់នៅក្នុងសង្គមជាតិទាំងមូល មិនមែនតែនៅក្នុងវិស័យសាធារណៈតែមួយនោះទេ។ ឆ្លើយតបនឹងគំនិតនេះ រដ្ឋាភិបាលបានអនុម័តនូវផែនការសុចរិតភាពជាតិ (NIP) ដែលដើរតួជាផែនការសកម្មភាពមួយសម្រាប់គ្រប់វិស័យទាំងអស់ ក្នុងការជម្រុញនូវភាពស្មោះត្រង់ និងកសាងនូវសង្គមដ៏ស្អាតស្អំមួយ។ ទិដ្ឋភាពដ៏សំខាន់របស់ NIP គឺថា វាមានមូលដ្ឋានចេញពីគោលការណ៍នៃរដ្ឋធម្មនុញ្ញសហព័ន្ធ ព្រមទាំងគោលនយោបាយណែនាំដទៃទៀត។ ប្រការនេះអាច

ធានាបានថាវាស្របគ្នាជាមួយនឹងអាទិភាព គោលការណ៍ និងកិត្យានុភាពជាតិ។ លើសពីនេះទៀត NIP ដោះស្រាយបញ្ហាអំពើពុករលួយនៅក្នុងវិស័យសាធារណៈ ដ៏ដូចជាក្នុងវិស័យឯកជន និងសំខាន់ជាងនេះទៀតនោះ គឺវាផ្តោតទៅក្នុងគ្រួសារដែលយកយុវជនជាទិសដៅ។ វាផ្ទុយទៅនឹងអ្វីដែលតែងតែកើតឡើងនោះ NIP មិនបានបាត់បង់នូវចក្ខុវិស័យនៃទិសដៅរបស់ខ្លួនក្នុងការជម្រុញនូវភាពស្មោះត្រង់ ការទទួលខុសត្រូវ និងភាពស្មោះត្រង់ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងលើកគុណភាពនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។

ដូចបានលើកឡើងខាងលើ ដើម្បីជម្រុញ និងសម្របសម្រួល ការបំពេញការងាររបស់ NIP ឱ្យកាន់តែមានប្រសិទ្ធភាព វិទ្យាស្ថានសច្ចធម៌របស់ប្រទេសម៉ាឡេស៊ី (IIM) ត្រូវបានបង្កើតឡើង។ IIM ត្រូវបានបង្កើតឡើងដោយសារឃើញច្បាស់ថា ACA ត្រូវប្រឈមមុខនឹងបញ្ហាធំៗជាច្រើន ក្នុងការពង្រឹងកិច្ចការរបស់ខ្លួន ក្នុងការជម្រុញឱ្យសាធារណជនយល់ដឹងអំពីគ្រោះថ្នាក់នៃអំពើពុករលួយ និងការរំលោភអំណាច។ ភាពទន់ខ្សោយរបស់ ACA ក្នុងវិស័យអប់រំ អាចពន្យល់បានថា ទីភ្នាក់ងារ ACA នេះ ផ្តោតជាចម្បងតែទៅលើការស៊ើបអង្កេត និងទប់ស្កាត់អំពើពុករលួយ។ ដូច្នេះ តួនាទីរបស់ IIM គឺដើម្បីជម្រុញផងដែរ នូវការយល់ដឹងអំពីអំពើពុករលួយ និងភាពចាំបាច់នៃតម្លាភាពនៅក្នុងសេវាសាធារណៈ (ADB and OECD, 2004:55)។ ប៉ុន្តែ IIM ដែលជាវិទ្យាស្ថានមួយដែលទើបតែបង្កើតឡើងថ្មី នឹងទាមទារឱ្យមានការបង្កើនសមត្ថភាពព្រមទាំងធនធានបន្ថែមទៀត ដើម្បីឱ្យ IIM អាចបំពេញភារកិច្ចរបស់ខ្លួនដោយមានប្រសិទ្ធភាព។ រីឯ ACA ក៏កំពុងតែផ្តោតអារម្មណ៍កាន់តែច្រើនឡើងទៅលើការទប់ស្កាត់ និងការអប់រំពីអំពើពុករលួយដែរ ពីព្រោះ ACA បានទទួលស្គាល់ថា អំពើពុករលួយមិនអាចកាត់ផ្តាច់បាន និងមិនអាចគ្រប់គ្រងបានតាមរយៈការដាក់ទណ្ឌកម្មតែមួយមុខនោះទេ (Kassim Bin Mohamad, 2005:9)។

## ប្រភព


- Abu Kassim Bin Mohamed ដែលនិយាយអំពីការកាត់ផ្តាច់ឫសគល់នៃអំពើពុករលួយ - ប្រាក់ពិន័យដែលមានចែងនៅក្នុងច្បាប់ប្រឆាំងអំពើពុករលួយរបស់ប្រទេសម៉ាឡេស៊ី ដោយបានបង្ហាញនៅឯសន្និសីទ Interpol និយាយពីភាពជាដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ហៅកាត់ថា ICAC ពីថ្ងៃទី២២-២៤ ខែមករា ឆ្នាំ ២០០៣ នៅទីក្រុងហុងកុងប្រទេសចិន សូមមើលគេហទំព័រ *www.icac.org.hk/conference/Presentation/Day2/Cutting%20off%20th%20lifeline%20Corruption%20 (Mohamed %20-%205 Speech).pdf* ។
- Abu Kassim Bin Mohamed ដែលនិយាយអំពីការទប់ស្កាត់អំពើពុករលួយក្នុងជំនួយ Tsunami: ការអនុវត្តនូវការប្រឆាំងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព និងយន្តការនៃការដោះស្រាយបណ្តឹង បទពិសោធរបស់ប្រទេសម៉ាឡេស៊ី ឯកសារដែលបានបញ្ជូនទៅកិច្ចប្រជុំជំនាញការស្តីពីការទប់ស្កាត់នូវអំពើពុករលួយនៅក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយ Tsunami ៧-៨ ខែមេសា ឆ្នាំ ២០០៥ ទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូណេស៊ី។
- ADBnig OECD គោលនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងអាស៊ី និងប៉ាស៊ីភិក ក្របខ័ណ្ឌ គតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន។
- រដ្ឋាភិបាលរបស់ប្រទេសម៉ាឡេស៊ី និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ខែមេសា ឆ្នាំ ២០០៥ ការអភិវឌ្ឍនូវសមត្ថភាពរបស់វិទ្យាស្ថានសច្ចភាពរបស់ប្រទេសម៉ាឡេស៊ី សម្រាប់អនុវត្តនូវផែនការស្តីពីភាពស្មោះត្រង់របស់ជាតិ (ឯកសារគម្រោង)។


ពត៌មានក៏អាចទទួលបានផងដែរពីវេបសាយរបស់ស្ថាប័នផ្សេងៗដែលបានបង្ហាញខាងលើ។



# ប្រទេសនីហ្សេរីយ៉ា

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- អង្គភាពតាមមើលថវិកា និងស៊ើបតម្លៃ (BMPIU)
- ការិយាល័យក្រមសីលធម៌ (CCB)
- គណៈកម្មការទទួលបន្ទុកខាងបទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហៅកាត់ថា EFCC សូមមើលគេហទំព័រ *www.icpcnigeria.com*
- គណៈកម្មការឯករាជ្យទទួលបន្ទុកបទល្មើសពុករលួយ និងបទល្មើសដែលពាក់ព័ន្ធផ្សេងៗទៀត ហៅកាត់ថា ICPC សូមមើលគេហទំព័រ *www.icpcnigeria.com*

## បទបញ្ញត្តិចម្បង[១]

- ច្បាប់ស្តីពីការប្រព្រឹត្តិអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត ឆ្នាំ២០០០ ហៅកាត់ថា CPRO សូមមើលគេហទំព័រ *www.icpcnigeria.com*
- ច្បាប់ស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុកបទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ ២០០២

## សាវតា

ប្រទេសនីហ្សេរីយ៉ា ស្ថិតនៅក្នុងចំណាត់ថ្នាក់លេខ ១៥២ ក្នុងចំណោមបណ្តាប្រទេស ១៥៩ នៅលើតារាងសន្ទស្សន៍របស់អង្គការតម្លាភាពអន្តរជាតិ ឆ្នាំ ២០០៥ ស្តីពីការយល់ឃើញពីអំពើពុករលួយ ។ ប្រទេសនីហ្សេរីយ៉ា បានក្លាយជាសង្គមមួយ ដែលអំពើពុករលួយបានកើតមានឡើងជាលក្ខណៈស្ថាប័នផង និងជាលក្ខណៈប្រព័ន្ធផង (Agbu, 2004:22) ។ សារៈសំខាន់នៃការដោះស្រាយលើបញ្ហាអំពើពុករលួយដ៏ពាសវាលពាសកាលបែបនេះគឺជាភស្តុតាងជាក់ស្តែង ព្រោះថា អំពើពុករលួយគឺត្រូវបានគេមើលឃើញថាជាកត្តាចម្បងមួយចំពោះភាពក្រីក្រយ៉ាងធ្ងន់ធ្ងររបស់ប្រទេស ហើយក៏ជាកត្តាសំខាន់មួយដែលរួមចំណែកដល់ជីវិតរស់នៅដ៏លំបាក ដែលប្រជាពលរដ្ឋរបស់ខ្លួនបានជួបប្រទះ (Osborne, 2005:3) ។ នៅក្នុងឆ្នាំ ២០០១ ការចុះស្ទង់មតិ ដែលធ្វើឡើងដោយស្ថាប័នរួមគ្នាមួយចំនួន បានបង្ហាញថា ប្រជាពលរដ្ឋនីហ្សេរីយ៉ាបានយល់ឃើញថាអំពើពុករលួយ គឺស្ថិតក្នុងចំណាត់ថ្នាក់លេខពីរ បន្ទាប់ពីភាពឥតការងារធ្វើ ដែលជាឧបសគ្គដល់ការអភិវឌ្ឍ ។ ភាពបន្ទាន់នៃការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ត្រូវបានទទួលស្គាល់ដោយលោកប្រធានាធិបតី Olusegun Obasanjo ដែលនៅក្នុងសន្ទរកថារបស់គាត់នៅពិធីសម្ពោធមួយ បន្ទាប់ពីប្រទេសនីហ្សេរីយ៉ា បានវិលត្រឡប់ទៅកាន់របបប្រជាធិបតេយ្យវិញក្នុងឆ្នាំ ១៩៩៩ បានចង្អុលបង្ហាញថាអំពើពុករលួយជាឧបសគ្គមួយដ៏ធំក្នុងការអភិវឌ្ឍ ហើយបានសន្យាថានឹងចាត់វិធានការប្រឆាំងនឹងបញ្ហានេះ ។ ក្រោយពីលោកប្រធានាធិបតីបានឡើងកាន់តំណែងនៅក្នុងខែមិថុនា ឆ្នាំ២០០៣ គាត់បានចាប់ផ្តើមអនុម័តច្បាប់ស្តីពីការប្រព្រឹត្តអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត (CPRO) (Agbu, 2004:9) ។ ច្បាប់ CPRO បានបង្កើតគណៈកម្មការឯករាជ្យទទួលបន្ទុកបទល្មើសអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត (ICPC) ជាស្ថាប័នកំពូលទទួលបន្ទុកប្រយុទ្ធប្រឆាំងអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត ។

ប៉ុន្តែ ភាពចម្រូងចម្រាស់បានកើតមានចំពោះ ICPC តាំងពីចាប់ផ្តើមដំបូង ដោយសារធម្មនុញ្ញភាពនៃគណៈកម្មការនេះត្រូវគេប្តឹងតវ៉ាទៅតុលាការ។ ពេលដែលរឿងនេះកំពុងស្ថិតនៅឯតុលាការ គណៈកម្មការ ICPC នេះមិនអាចស៊ើបអង្កេត ហើយក៏មិនអាចធ្វើបណ្តឹងចោទលើអំពើដែលជាបទល្មើសពុករលួយបានឡើយ។ ២ ឆ្នាំក្រោយមក ទើបតុលាការបានសម្រេចថា ICPC មានសិទ្ធិធ្វើកិច្ចការទាំងនោះ (Osborne, 2005:10)។ ប៉ុន្តែ នៅមានការពន្យារពេលបន្ថែមទៀត ដោយសារនៅឆ្នាំ២០០៣ ព្រឹទ្ធសភាបានបោះឆ្នោតអនុម័តច្បាប់មួយជាជំនួសច្បាប់ CPRO ដែលធ្វើឱ្យអាណត្តិការងាររបស់ ICPC ចុះខ្សោយ[១]។ ប៉ុន្តែ ច្បាប់ដែលយកមកជំនួសនេះ ត្រូវបានប្រកាសមោឃភាពដោយតុលាការជាន់ខ្ពស់របស់រដ្ឋសហព័ន្ធ (TI, 2004:225)។ លុះត្រាតែដល់ដើមឆ្នាំ ២០០៤ ទើបគណៈកម្មការ ICPC អាចចាប់ដំណើការបានដោយសេរីដូចដែលគេបានគ្រោងទុកពីមុន។ ក្នុងរយៈពេល ៤ ឆ្នាំដំបូង គណៈកម្មការ ICPC បានទទួលរបាយការណ៍តែ ១.២០០ ប៉ុណ្ណោះ។ ចំនួនរបាយការណ៍តិចតួចនេះ បានធ្វើឱ្យនីតិវិធីនៃការរាយការណ៍មានភាពទន់ខ្សោយ (Osborne, 2005:10)។ ហើយចំពោះរបាយការណ៍ដែលបានទទួល គណៈកម្មការអាចធ្វើការស៊ើបអង្កេតបានតែពាក់កណ្តាលប៉ុណ្ណោះ ដោយសារខ្វះថវិកា (Agbu, 2004:10)។ មានទស្សនៈមួយយល់ថា ICPC បានបំពេញការងារទាបជាងអ្វីដែលគេបានរំពឹងទុក (TI, 2004:225) ហើយមិនមានឆន្ទៈព្យាយាម ធ្វើការស៊ើបអង្កេតលើរឿងក្តីពុករលួយធំៗនោះទេ (Agbu, 2004:11)។

ការអនុម័តច្បាប់ CPRO និងការបង្កើតគណៈកម្មការ ICPC គឺគ្រាន់តែជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នរបស់រដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាពុករលួយ។ វិធានការផ្សេងទៀតគឺ រួមបញ្ចូលទាំងការបង្កើតគណៈកម្មការទទួលបន្ទុកបទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (EFCC) និងផ្នែកត្រួតពិនិត្យថវិកា និងចារកម្មតម្លៃ (BMPIU–ត្រូវបានគេស្គាល់ឈ្មោះថាជាការិយាល័យរបៀប) ព្រមទាំងការពង្រីកអាណត្តិការងាររបស់ការិយាល័យខាងក្រមសីលធម៌ (CCB)/ការកែទម្រង់សេវាសាធារណៈ និងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងសុចរិតភាព និងសមត្ថភាពរបស់តុលាការ។ ការផ្តួចផ្តើមគំនិតនេះបង្ហាញប្រាប់ថា រដ្ឋាភិបាលពិតជាមានបំណងប្រយុទ្ធប្រឆាំងអំពើពុករលួយមែន។ ប៉ុន្តែ រហូតមកទល់ពេលនេះ គឺមានភស្តុតាងតិចតួចណាស់ដែលបញ្ជាក់ថា គេបានសម្រេចផលជាដុំកំភួន។ បញ្ហាសំខាន់គឺកង្វះខាតឆន្ទៈនយោបាយជាពិសេសពីសំណាក់ព្រឹទ្ធសភា (Agbu, 2004:11) ព្រមទាំងឧបសគ្គផ្សេងៗទៀតនៅក្នុងសង្គមដែលធ្វើឱ្យពួកគេទទួលបរាជ័យ ក្នុងសង្គ្រាមប្រឆាំងអំពើពុករលួយ។ បញ្ហានេះ ឆ្លុះបញ្ចាំងទៅលើកង្វះឆន្ទៈក្នុងការប្តឹងចោទប្រកាន់បុគ្គលដែលមានតំណែងខ្ពស់ៗ។ ឧបសគ្គផ្សេងទៀតគឺភាពយឺតយ៉ាវខាងនីតិវិធីរបស់តុលាការ (Agbu, 2004:22-33)។ យោងតាម Osborne ការពិតគឺថា ប្រជាជនភាគច្រើនមានទំលាប់រស់នៅក្នុងបែបបទ និងចរិកលក្ខណៈពុករលួយ ហើយមានកិច្ចប្រឹងប្រែងតែបន្តិចបន្តួច ឬក៏ស្ទើរតែគ្មានផងទេ ដើម្បីផ្លាស់ប្តូរបែបបទរស់នៅ និងចរិកលក្ខណៈនោះ (2005:5)។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

គណៈកម្មការឯករាជ្យទទួលបន្ទុកបទល្មើសអំពើពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត (ICPC) គឺជាស្ថាប័នកំពូលសម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ និងបទល្មើសដែលពាក់ព័ន្ធផ្សេងៗទៀត ។ ដោយអនុលោមតាមគុណតម្លៃនៃអនុផ្នែកទី ៣(១) នៃច្បាប់ CPRO គណៈកម្មការនេះត្រូវបានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ ២000 ជាអង្គភាពសាជីវកម្ម។ ឯករាជភាពរបស់គណៈកម្មការ ត្រូវបានធានាដោយអនុផ្នែក ៣(១៤)ដែលចែងថា "ក្នុងការបំពេញមុខងាររបស់ខ្លួន ដូចមានចែងក្នុងច្បាប់ CPRO គណៈកម្មការមិនត្រូវស្ថិតនៅក្រោមការណែនាំ ឬក្រោមការគ្រប់គ្រងរបស់បុគ្គលណាម្នាក់ ឬស្ថាប័នណាមួយឡើយ។" ច្បាប់ក៏បានកំណត់និយមន័យនៃអំពើពុករលួយ ចែងអំពីការផ្តន្ទាទោសបទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ ព្រមទាំងបានកំណត់នូវអាណត្តិការងារ និងមុខងាររបស់គណៈកម្មការឯករាជ្យ ICPC។

យោងទៅតាមអនុផ្នែក ៣(៣) ICPC មានប្រធានមួយរូប និងសមាជិកចំនួន ១២នាក់។ ប្រធាន និងសមាជិកផ្សេងៗទៀតត្រូវតែងតាំងដោយប្រធានាធិបតី តាមការឯកភាពពីព្រឹទ្ធសភា (អនុផ្នែកទី ៣(៦)។ យោងតាមអនុផ្នែក ៣(៨) ប្រធាន ឬសមាជិកផ្សេងៗទៀតរបស់ ICPC អាចនឹងត្រូវដកចេញពីតំណែងដោយប្រធានាធិបតី តាមការអនុម័តយល់ព្រម ២/៣នៃសមាជិកព្រឹទ្ធសភា។ គណៈកម្មការមិនអាចចាប់ផ្តើមបំពេញតួនាទីរបស់ខ្លួនបានឡើយ ទាល់តែសមាជិកទាំងអស់បានប្រកាសនូវទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ខ្លួន។ ប្រធានត្រូវតែជា

[១] គួរកត់សម្គាល់ថា ការកែប្រែមួយចំនួនដែលជម្រុញឱ្យមានការអនុម័តនូវច្បាប់ថ្មីអាចនិងលុបនូវបញ្ញត្តិសំខាន់ៗមួយចំនួន ដែលការធ្វើដូច្នេះធ្វើឱ្យការដឹកនាំរបស់ព្រឹទ្ធសភា និងរដ្ឋសភា ស្ថិតនៅក្នុងការស៊ើបអង្កេតនៅឡើយ។

បុគ្គលដែលធ្លាប់ធ្វើជាចៅក្រម ឬមានលក្ខណៈសម្បត្តិជាចៅក្រមនៃតុលាការជាន់ខ្ពស់។ សមាជិក ១២នាក់ផ្សេងទៀតរបស់គណៈកម្មការនេះ គឺត្រូវតែជាៈ ២នាក់ជាមន្ត្រីប៉ូលីសដែលបានចូលនិវត្តន៍ (ត្រូវមានឋានៈចាប់ពីស្នងការឡើង) ២នាក់ទៀតជាអ្នកធ្វើការក្នុងវិស័យច្បាប់ (ត្រូវមានបទពិសោធន៍ពីមុនមកចំនួន ១០ ឆ្នាំ) ២នាក់ទៀតជាមន្ត្រីរាជការដែលបានចូលនិវត្តន៍ (ដោយមានឋានៈចាប់ពីថ្នាក់នាយកឡើង) ស្ត្រី ២នាក់ និងយុវជនចំនួន ២នាក់ (មានអាយុមិនក្រោម ២១ ឆ្នាំ ឬមិនលើសពី ៣០ឆ្នាំ គិតមកត្រឹមថ្ងៃដែលត្រូវតែងតាំង) (អនុផ្នែក ៣(៣))។ លេខាធិការម្នាក់តែងតាំងដោយប្រធានាធិបតី ដែលទទួលបន្ទុកការងាររដ្ឋបាលទូទៅ និងគ្រប់គ្រងបុគ្គលិករបស់ ICPC តាមការណែនាំរបស់ប្រធានអនុផ្នែក ៤(៦)។ យោងតាមអនុផ្នែក ៣(១២) គណៈកម្មការមានសិទ្ធិតែងតាំង ដកចេញ និងដាក់វិន័យចំពោះបុគ្គលិករបស់ខ្លួន ហើយអាចអនុម័តបទបញ្ជារបស់ខ្លួនសម្រាប់ប្រើប្រាស់។

ក្នុងលក្ខណៈជាស្ថាប័នកំពូលក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ICPC មានភារកិច្ចធ្វើបណ្ដឹងអាជ្ញា (គឺរៀបចំបែបបទប្ដឹងចោទប្រកាន់) និងកំណត់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទល្មើសអំពើពុករលួយ និងបទល្មើសផ្សេងៗទៀតដែលមានការពាក់ព័ន្ធ។ ការទទួលខុសត្រូវចម្បងរបស់គណៈកម្មការ ដូចដែលមានចែងនៅក្នុងផ្នែកទី ៦ នៃច្បាប់ CPRO អាចនឹងត្រូវបែងចែកជាបីផ្នែក ដែលខាងក្រោមៈ

- **ការស៊ើបអង្កេត**
  - ទទួលរបាយការណ៍ ហើយនិងក្នុងករណីសមស្រប ធ្វើការស៊ើបអង្កេត និងប្ដឹងចោទបុគ្គលនោះ ប្រសិនបើមានហេតុផលគ្រប់គ្រាន់សង្ស័យថាបុគ្គលនោះបានឃុបឃិតក្នុងការប្រព្រឹត្តិ ឬបានប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងច្បាប់ CPRO ឬច្បាប់ផ្សេងៗទៀតស្ដីពីអំពើពុករលួយ ឬបទល្មើសដែលពាក់ព័ន្ធ។
- **ទប់ស្កាត់**
  - ពិនិត្យការអនុវត្ត ពិនិត្យប្រព័ន្ធ និងនីតិវិធីរបស់ស្ថាប័នសាធារណៈ ក្នុងគោលបំណងដើម្បីរកឱ្យឃើញ និងដើម្បីធានានូវការពិនិត្យសារឡើងវិញលើការអនុវត្ត ពិនិត្យលើប្រព័ន្ធ និងនីតិវិធីដែលតាមមតិរបស់គណៈកម្មការ វាអាចបណ្ដាលឱ្យមានការប្រព្រឹត្តិអំពើពុករលួយ។
  - ផ្ដល់យោបល់ ណែនាំ និងជួយដល់ស្ថាប័នសាធារណៈអំពីរបៀបដែលត្រូវកាត់បន្ថយ ឬលុបបំបាត់ការបោកបន្លំ និងការប្រព្រឹត្តិអំពើពុករលួយ។ ហើយនិង
  - ណែនាំប្រធានស្ថាប័នសាធារណៈអំពីការអនុវត្ត អំពីប្រព័ន្ធ ឬនីតិវិធីផ្សេងៗ ដែល ICPC ជឿជាក់ថាវាអាចឈានទៅរកការកាត់បន្ថយនូវឱកាសនៃការសូកប៉ាន់ ការប្រព្រឹត្តិអំពើពុករលួយ និងបទល្មើសផ្សេងៗទៀត។
- **ការអប់រំជាសាធារណៈ**
  - អប់រំដល់ប្រជាពលរដ្ឋស្ដីពី (និងការប្រឆាំង) ការសូកប៉ាន់ អំពើពុករលួយ និងបទល្មើសដែលពាក់ព័ន្ធផ្សេងៗទៀត។ ហើយនិង
  - គាំទ្រ និងជម្រុញក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

រចនាសម្ព័ន្ធនៃការប្រព្រឹត្តិទៅរបស់ ICPC មានគណៈកម្មាធិការ ៣ៈ (១) ស៊ើបអង្កេត និងប្ដឹងចោទ (២) ទប់ស្កាត់ និងសិក្សាប្រព័ន្ធ និង (៣) ផ្សព្វផ្សាយ និងអប់រំសាធារណៈ។ គណៈកម្មាធិការទាំងបីនេះ គ្រប់គ្រងលើនាយកដ្ឋានដែលទទួលបន្ទុកតាមផ្នែកនៃកិច្ចការរបស់ខ្លួន។ បន្ថែមលើនេះទៀត មានអង្គភាពពិសេសរបស់ប្រធាន និងក្រុមបេសកកម្មផ្លូវកាត់ (ដែលមានក្រុមអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាថ្នាក់កំពូល) ដែលទាំងអស់គ្នា ទទួលខុសត្រូវចំពោះមុខប្រធាន។ យោងទៅតាមអនុផ្នែកទី ៧(២) ICPC អាចបង្កើតសាខានៅតាមរដ្ឋនីមួយៗ ព្រមទាំងនៅក្នុងដែនដីនៃរដ្ឋសហព័ន្ធ។ ប៉ុន្តែ ការិយាល័យសាខាទាំងនោះ មិនទាន់បានបង្កើតនៅឡើយទេ។

របាយការណ៍ដែល ICPC បានទទួលត្រូវបញ្ជូនទៅនាយកដ្ឋានស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេតបឋម។ ច្បាប់ CPRO ផ្ដល់ឱ្យមន្ត្រីរបស់ ICPC នូវអំណាចទូលំទូលាយក្នុងការស៊ើបអង្កេត ដូចជា ការឆែកឆេរ ការរឹបអូស និងការចាប់ខ្លួនជាដើម។ ប្រធានមានសិទ្ធិណែនាំមន្ត្រី ICPC ឱ្យសុំដីកាពីតុលាការដើម្បីចូលដោយបង្ខំ និងឆែកឆេរក្នុងបរិវេណទីតាំង (ផ្នែកទី ៣៦)។ ក្រោយពីបានទទួលដីកាពីតុលាការ ប្រធានអាចអនុញ្ញាតឱ្យមន្ត្រីរបស់ ICPC ធ្វើការអនុវត្តនូវអំណាចទាំងអស់ក្នុងការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដូចដែលមាន

ចែងនៅក្នុងអនុផ្នែកទី ៤៣(២)។ រាល់បុគ្គលទាំងអស់ ដែលត្រូវបានស្នើរដោយមន្ត្រីរបស់គណៈកម្មការឱ្យផ្តល់ព័ត៌មានលើបញ្ហាពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួន គឺត្រូវតែធ្វើតាមការស្នើសុំនោះ។ ការខកខានក្នុងការផ្តល់ពត៌មានគឺជាបទល្មើសមួយដែលអាចដាក់ទណ្ឌកម្មបាន (ផ្នែកទី ៤០)។ យោងតាមផ្នែកទី ៥ នៃច្បាប់ CPRO នៅពេលធ្វើការស៊ើបអង្កេត ឬចោទប្រកាន់រឿងក្តីបទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយ មន្ត្រីរបស់ ICPC មានអំណាច និងអភ័យឯកសិទ្ធិដូចគ្នាទៅនឹងអំណាច និងអភ័យឯកសិទ្ធិរបស់មន្ត្រីប៉ូលីស ដោយអនុលោមតាមច្បាប់ស្តីពីប៉ូលីស ព្រមទាំងច្បាប់ផ្សេងៗទៀតដែលប្រគល់អំណាចទៅឱ្យប៉ូលីស ឬពង្រឹងអំណាចនិងការពារភ្នាក់ងារអនុវត្តច្បាប់។

បន្ថែមលើនេះទៀត ប្រធានក៏អាចស្នើសុំឱ្យបុគ្គលគ្រប់រូប ព្រមទាំងសាច់ញាត្តិ និងគូកនរបស់បគ្គលនោះ ផ្តល់នូវព័ត៌មានជាលាយលក្ខណ៍អក្សរអំពីចលនទ្រព្យ និងអចលនទ្រព្យ។ ប្រសិនបើប្រធានមានហេតុផលដែលសង្ស័យថាចលនទ្រព្យ ឬអចលនទ្រព្យរបស់បុគ្គលដែលមានការសង្ស័យនេះ ប្រសិនបើគាត់ជាមន្ត្រីរាជការ មានចំនួនច្រើនហួសពីប្រាក់ចំណូលនាពេលបច្ចុប្បន្ន ឬប្រាក់ចំណូលពីអតីតកាល គាត់អាចស្នើសុំឱ្យបុគ្គលម្ចាស់ទ្រព្យធ្វើការពន្យល់បាន។ ប្រសិនបើការពន្យល់មិនមានលក្ខណៈគ្រប់គ្រាន់ទេគឺ បុគ្គលនោះត្រូវបានសន្មត់ថាបានប្រើប្រាស់តំណែងរបស់ខ្លួនដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ដោយអំពើពុករលួយ (ផ្នែកទី ៤៤)។ ប្រធានអាចបញ្ជាឱ្យរឹបអូសនូវទ្រព្យ ដែលបានទទួលដោយដោយការប្រព្រឹត្តបទល្មើស ដូចមានចែងនៅក្នុងច្បាប់ CPRO ព្រមទាំងតាមបញ្ជារបស់តុលាការ ស្នើសុំដកហូតឯកសារធ្វើដំណើរទាំងអស់ពីបុគ្គលដែលស្ថិតនៅក្រោមការស៊ើបអង្កេត (ផ្នែកទី ៤៥ និង ៥០)។ គួរកត់សម្គាល់ផងដែរថា ចៅក្រមរបស់តុលាការជាន់ខ្ពស់អាចណែនាំដល់មេធាវី និងទីប្រឹក្សា ឱ្យបង្ហាញរាល់ព័ត៌មានដែលពួកគេមាន ដែលអាចជាប់ពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរបស់ ICPC តាមពាក្យសុំដែលបានធ្វើឡើងពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ដែលមានចែងនៅក្នុងច្បាប់ CPRO (ផ្នែកទី ៣៩)។

ក្រោយពីបានបញ្ចប់ការស៊ើបអង្កេត មន្ត្រីទទួលបន្ទុកស៊ើបអង្កេតត្រូវរៀបចំរបាយការណ៍បញ្ជូនទៅឱ្យនាយកដ្ឋានអយ្យការ ដើម្បីធ្វើការកំណត់ថា តើមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្កើតសំណុំរឿងឬទេ។ ប្រសិនបើបង្កើតសំណុំរឿងបាន ការចោទប្រកាន់មួយអាចនឹងត្រូវព្រាងឡើង ហើយដាក់ជូនទៅតុលាការ ដែលគេបានកំណត់ (សូមមើលបន្ថែមនូវក្នុងផ្នែកស្តីពីការរៀបចំកិច្ចប្រតិបត្តិការ)។ ចំពោះរបាយការណ៍ណាដែលពាក់ព័ន្ធនឹងបទល្មើសដែលមិនមានចែងនៅក្នុងច្បាប់ CPRO ទេនោះ សំណុំរឿងនឹងត្រូវបញ្ជូនទៅឱ្យស្ថាប័នណាមួយដែលសមស្រប (Raji, 2004)។

ច្បាប់ CPRO ចែងថាមន្ត្រីរាជការដែលត្រូវបានគេប្រគល់ឱ្យ សន្យាថាឱ្យឬផ្តល់ឱ្យនូវសំណូកឬបុគ្គលណាដែលត្រូវបានគេទទូចសុំឱ្យទទួលសំណូកឬបុគ្គលណាដែលមានគេព្យាយាមប្រគល់សំណូកឱ្យ គឺត្រូវតែរាយការណ៍ពីបញ្ហានេះទៅឱ្យមន្ត្រីរបស់គណៈកម្មការ (ឬមន្ត្រីប៉ូលីស)។ ការខកខានមិនបានរាយការណ៍ គឺជាបទល្មើសមួយអាចដាក់ទណ្ឌកម្មបាន ហើយដែលនឹងនាំឱ្យជាប់ពន្ធធនាគាររហូតដល់ ២ឆ្នាំ (ផ្នែកទី ២៣)។

## ការរៀបកិច្ចចំប្រតិបត្តិការ

ទោះបីជា ICPC មានបេសកម្មធ្វើបណ្តឹងអាជ្ញា (ប្តឹងចោទ)អំពីរឿងពុករលួយក៏ដោយ រាល់ការប្តឹងចោទនឹងត្រូវសម្រេចថាអាចចាប់ផ្តើមបាន លុះត្រាតែមានការយល់ព្រមពីអគ្គមេធាវី ដោយអនុលោមតាមអនុផ្នែកទី ៦១ (១) នៃច្បាប់ CPRO។ រឿងក្តីត្រូវបញ្ជូនទៅតុលាការ ឬចៅក្រមដែលត្រូវបានចាត់តាំងដោយប្រធានតុលាការរបស់រដ្ឋ។ ក្រោយពីបានទទួលការចាត់តាំងនេះ ចៅក្រម ឬតុលាការនោះមិនអាចធ្វើការជំនុំជម្រះរឿងក្តីផ្សេងទៀតបានឡើយ (អនុផ្នែកទី ៦១ (៣))។ គួរកត់សម្គាល់ថា យោងតាមផ្នែកទី ១៧៤ នៃរដ្ឋធម្មនុញ្ញ អគ្គមេធាវីមានអំណាចសម្រេចបញ្ឈប់ដំណើរការករណីណាមួយបានគ្រប់ពេលវេលា។ ឧបសគ្គបន្ថែមទៅលើប្រសិទ្ធភាព និងចំណាត់ការជាប្រញ៉ាប់លើករណីពាក់ព័ន្ធទៅនឹងរឿងពុករលួយ គឺថា តុលាការខ្លួនឯងខ្វះសមត្ថភាព ហើយក៏ត្រូវបានគេឃើញថាមានទំនោរទៅរកអំពើពុករលួយផងដែរ។ ICPC កំពុងតែធ្វើការជាមួយការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ដើម្បីពង្រឹងសុចរិតភាព និងពង្រឹងសមត្ថភាពរបស់តុលាការ[២]។

[២] សម្រាប់ព័ត៌មានបន្ថែមសូមមើលគេហទំព័រ *www.unodc.org/unodc/en/corruption_projects_nigeria.html*

ទោះបីជាយ៉ាងណាក៏ដោយ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសនីហ្សេរីយ៉ា គឺមិនមែនជាការទទួលខុសត្រូវតែម្នាក់ឯងទេ។ ជាផ្នែកមួយនៃយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើពុករលួយ ICPC បានព្យាយាមបង្កើតអង្គភាពប្រយុទ្ធប្រឆាំងអំពើពុករលួយជាច្រើននៅតាមបណ្តាក្រសួង នាយកដ្ឋាន និងទីភ្នាក់ងារផ្សេងៗ (Osborne. 2005:20)។ រហូតមកទល់បច្ចុប្បន្ននេះ មានផ្នែកប្រយុទ្ធប្រឆាំងអំពើពុករលួយបែបនេះជាង ១០០ ត្រូវបានបង្កើតឡើង (Agbu, 2004:10)។

ដូចបានកត់សម្គាល់ខាងលើ មានស្ថាប័នផ្សេងៗទៀតដែលដើរតួយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ។ ស្ថាប័នសំខាន់ៗនៅក្នុងចំណោមស្ថាប័នទាំងនោះមានដូចជា **អង្គភាពតាមមើលថវិកានិងស៊ើបតម្លៃ (BMPIUP)** និង**ការិយាល័យក្រមសីលធម៌ (CCB)** និង**គណៈកម្មការទទួលបន្ទុកបទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (EFCC)**។

គណៈកម្មការ EFCC ត្រូវបានបង្កើតឡើងដោយគុណតម្លៃនៃផ្នែកទី១ នៃច្បាប់ស្តីពីការបង្កើតគណៈកម្មការទទួលបន្ទុកបទល្មើសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (EFCC(A)) ដែលមានប្រធាន ១រូប និងសមាជិកចំនួន ១៨រូបផ្សេងទៀត ដោយរួមបញ្ចូលទាំងសមាជិកដែលតំណាងឱ្យក្រសួង ទីភ្នាក់ងារ និងស្ថាប័នផ្សេងៗមួយចំនួន ព្រមទាំងសមាជិកជ្រើសតាំងផងដែរ។ មានអគ្គនាយក ១រូបផងដែរ ដែលត្រូវបានតែងតាំងដោយប្រធានាធិបតី ដែលជាអ្នកដឹកនាំលេខាធិការដ្ឋានរបស់ EFCC (អនុផ្នែកទី ៧-១)។ គណៈកម្មការនេះក៏មានអំណាច តែងតាំង បញ្ឈប់ និងដាក់វិន័យចំពោះបុគ្គលិករបស់ខ្លួន ហើយនិងអាចធ្វើបទបញ្ជាផ្ទៃក្នុងសម្រាប់ប្រើប្រាស់ក្នុងស្ថាប័នរបស់ខ្លួន (ផ្នែកទី ៧ និងទី ៨)។ EFCC មានផ្នែកជាច្រើន រួមបញ្ចូលទាំងផ្នែកស៊ើបអង្កេត ផ្នែកប្រតិបត្តិការ ផ្នែកនីតិកម្ម និងផ្នែកអយ្យការ ផ្នែកស្រាវជ្រាវ ផ្នែកសវនកម្ម ព្រមទាំងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងផ្សព្វផ្សាយ។ EFCC ក៏មានវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវមួយផងដែរ។

ដូចបានបង្ហាញក្នុងផ្នែកទី ២ នៃច្បាប់ស្តីពីការបង្កើត EFCC មុខងាររបស់ EFCC រួមបញ្ចូលទាំងការស៊ើបអង្កេតបទល្មើសខាងហិរញ្ញវត្ថុទាំងអស់ ការសម្របសម្រួល និងការអនុវត្តរាល់ច្បាប់ស្តីពីបទល្មើសសេដ្ឋកិច្ច និងបទល្មើសហិរញ្ញវត្ថុ និងការអនុវត្តមុខនាទី ដែលបានប្រគល់ទៅឱ្យបុគ្គលម្នាក់ឬស្ថាប័នណាមួយ ការអនុម័តវិធានការដើម្បីលុបបំបាត់បទល្មើសសេដ្ឋកិច្ច និងបទល្មើសហិរញ្ញវត្ថុ ការពិនិត្យ និងស៊ើបអង្កេតលើរាល់ករណីដែលបានរាយការណ៍ស្តីពីបទល្មើសសេដ្ឋកិច្ច និងបទល្មើសហិរញ្ញវត្ថុ និងការអនុវត្តនូវយុទ្ធនាការលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ស្តីពីបទល្មើសសេដ្ឋកិច្ច និងបទល្មើសហិរញ្ញវត្ថុ។ គណៈកម្មការក៏មានអំណាចផងដែរ ក្នុងការស្នើសុំឱ្យធ្វើការស៊ើបអង្កេតលើបុគ្គលណាម្នាក់ ថាតើគាត់បានប្រព្រឹត្តបទល្មើសដូចដែលមានចែងនៅក្នុងច្បាប់របស់ EFCC(A) ឬអត់។ បន្ថែមលើនេះទៀត EFCC មានតួនាទីធ្វើបណ្តឹងអាជ្ញា (ឬប្តឹងចោទ)លើជនល្មើស ព្រមទាំងដំណើរការតាមនីតិវិធីនៃបណ្តឹងអាជ្ញានេះ ព្រោះថាវាអាចមានការចាំបាច់ដើម្បីធ្វើការស្វែងរកទ្រព្យសម្បត្តិដែលត្រូវរឹបអូស ដោយអនុលោមតាមច្បាប់ EFCC(A) (អនុផ្នែកទី ១២-២)។ ប៉ុន្តែ គួរចងចាំថា យោងតាមផ្នែកទី ៣៩ នៃច្បាប់ EFCC(A) អគ្គមេធាវីអាចដាក់ចេញវិធាន ឬបទបញ្ញត្តិ ដើម្បីយកទៅប្រើក្នុងការអនុវត្តតាមតួនាទី មុខងារ ឬអំណាចរបស់ EFCC ដែលមានចែងក្នុងច្បាប់។ នៅក្នុងកំឡុងពេលនៃអត្ថិភាពរបស់ខ្លួន EFCC បានក្លាយមកជាស្ថាប័នដែលគេយល់ថាមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ (Agbu, 2004:18) ហើយខុសគ្នាពី ICPC ដោយសារគណៈកម្មការនេះបានធ្វើបណ្តឹងអាជ្ញា (ប្តឹងចោទ)លើរឿងធំៗជាច្រើន។

នៅក្នុងឆ្នាំ ២០០៣ BMPIU[៣] ដែលគេស្គាល់ឈ្មោះថា ការិយាល័យនីតិវិធី ត្រូវបានបង្កើតឡើងនៅក្រោមការិយាល័យនៃលេខាធិការដ្ឋានកណ្តាលរបស់ប្រធានាធិបតី ដោយដំណើរការជាស្ថាប័នឯករាជ្យមួយ។ ផ្នែកនេះត្រូវបានបង្កើតឡើងដើម្បីទប់ទល់ទៅនឹងទស្សនៈដែលថាប្រទេសនីហ្សេរីយ៉ាជាប្រទេសពុករលួយ។ ផ្នែកនេះត្រូវបានគេបង្កើតឡើងឱ្យដើរតួធ្វើជាអ្នកពិនិត្យមើលនូវរាល់កិច្ចសន្យារបស់រដ្ឋាភិបាល ព្រមទាំងការផ្គត់ផ្គង់នូវទំនិញ និងសេវានានា។ មុខងាររបស់ការិយាល័យនីតិវិធីនេះ គឺដើម្បីដាក់កំហិតឱ្យមន្ត្រីរាជការនៃវិស័យសាធារណៈ ប្រតិបត្តិឱ្យបានពេញលេញ តាមការណែនាំ និងតាមនីតិវិធីនានា ដែលបានបង្កើតឡើងសម្រាប់ប្រើប្រាស់ក្នុងការផ្គត់ផ្គង់ទំនិញ។ គួរចងចាំថា នៅក្នុងខែមិនា ឆ្នាំ ២០០៥ ការបង្កើតជាផ្លូវការនូវ BMPIU ត្រូវបានជាប់គាំងនៅរដ្ឋសភាទោះបីជាគេបានរំពឹងថាសេចក្តីព្រាងច្បាប់ថ្មីនឹងត្រូវតែអនុម័តនាពេលឆាប់ៗក៏ដោយ (Osborne, 2005:7)។

[៣] ព័ត៌មានស្តីអំពី BMPIU គឺបានពីគេហទំព័រ *www.nigeriafirst.org/article_841.shtml*

CCB ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានប្រធានមួយរូប (ហើយជានាយកប្រតិបត្តិរបស់ការិយាល័យផងដែរ) និងសមាជិក ៩ រូបផ្សេងទៀត (កថាខ័ណ្ឌទី១ ចំណុចទី៣ ផ្នែកទី១ នៃរដ្ឋធម្មនុញ្ញ) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៨៩ ដោយមានភារកិច្ចបង្កើត និងថែរក្សាការប្រព្រឹត្តិទៅនៃការងាររបស់រដ្ឋាភិបាល និងដើម្បីធានាថា សកម្មភាព និងអត្តចរិករបស់មន្ត្រីរាជការស្របទៅតាមស្តង់ដាមួយដ៏ខ្ពស់បំផុត ខាងសីលធម៌ និងការទទួលខុសត្រូវចំពោះសាធារណៈ។ CCB មានទីស្នាក់ការកណ្តាលរបស់ខ្លួននៅទីក្រុង Abuja ព្រមទាំងការិយាល័យនៅតាមរដ្ឋនីមួយៗ និងនៅទីក្រុងរបស់រដ្ឋសហព័ន្ធ។ CCB មាននាយកដ្ឋានប្រតិបត្តិការចំនួន ៣: (១) ប្រកាសទ្រព្យសម្បត្តិ (២) ស៊ើបអង្កេត និងឃ្លាំមើល និង (៣) សេវាអប់រំ និងផ្តល់យោបល់ និងនាយកដ្ឋានសេវាកម្មដែលមាន: ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ។ នាយកដ្ឋាននីមួយៗដឹកនាំដោយនាយកមួយរូប ។ លេខាធិការរបស់ក្រុមប្រឹក្សាភិបាលដើរតួធ្វើជាប្រធានរដ្ឋបាលរបស់ CCB ។ ការិយាល័យនេះមានការិយាល័យមួយអមជាមួយគឺសាលាជំនុំជម្រះខាងក្រមសីលធម៌ដែលដើរតួជាតុលាការរបស់ CCB ។

អាណត្តិការងាររបស់ CCB ត្រូវបានពង្រីកឡើងនៅពេលដែលវាក្លាយជាអង្គការប្រតិបត្តិរបស់រដ្ឋសហព័ន្ធ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៩។ រដ្ឋធម្មនុញ្ញបានប្រគល់អំណាចឱ្យការិយាល័យនេះក្នុងការទទួលសេចក្តីប្រកាសទ្រព្យសម្បត្តិ ដែលធ្វើដោយមន្ត្រីរាជការតាមការទាមទារដោយអនុលោមតាមក្រមសីលធម៌របស់មន្ត្រីរាជការស៊ីវិល ហៅកាត់ថា (CoC)[៤] ធ្វើការពិនិត្យនូវការប្រកាសធានានូវការគោរពតាម CoC និងទទួលពាក្យបណ្តឹងស្តីពីការមិនគោរពតាម ឬរំលោភលើ CoC (រួមបញ្ចូលទាំងការចោទប្រកាន់លើអំពើពុករលួយ) និងបញ្ជូនបញ្ហានោះទៅឱ្យតុលាការខាងក្រមសីលធម៌ ប្រសិនបើយល់ថាសមស្រប។ ដោយសារតែធនធានមានកម្រិត នៅពេលបច្ចុប្បន្ននេះ CCB តម្រូវឱ្យតែមន្ត្រីរាជការជាន់ខ្ពស់តែប៉ុណ្ណោះទេ ដែលត្រូវប្រកាសទ្រព្យសម្បត្តិ ប៉ុន្តែទិសដៅរបស់ខ្លួនទៅថ្ងៃមុខ គឺនឹងតម្រូវឱ្យមន្ត្រីរាជការទាំងអស់ប្រកាសទ្រព្យសម្បត្តិ(Saba, 2001) ។CCB ក៏មានអំណាចក្នុងការជ្រើសតាំង ជំរុញ បញ្ឈប់ និងដាក់វិន័យចំពោះបុគ្គលិករបស់ខ្លួនដែរ។

## មេរៀនដែលទទួលបាន

ដូចដែលបានគូសបញ្ជាក់ខាងលើ តាមពិត រដ្ឋាភិបាលបានចាត់វិធានការជាច្រើនដើម្បីទប់ទល់នឹងអំពើពុករលួយដ៏រីករាលដាលនៅក្នុងប្រទេសនីហ្សេរីយ៉ា។ ប៉ុន្តែ មានសក្ខីភាពជាក់ស្តែងតិចតួចណាស់ ដែលបញ្ជាក់ថា វិធានការទាំងនោះបានជះឥទ្ធិពលគួរឱ្យកត់សម្គាល់ចំពោះកម្រិតនៃអំពើពុករលួយ។ អ្នកខ្លះហ៊ានសម្តែងមតិថាសង្គ្រាមប្រឆាំងនឹងអំពើពុករលួយ រហូតមកទល់នឹងពេលនេះ បានទទួលបរាជ័យ (Agbu, 2004:24) ។ ទោះបីជាករណីនេះវាពិតឬមិនពិតក៏ដោយ មានកត្តាមួយចំនួនបានរួមចំណែកទៅនឹងការខ្វះលទ្ធផលនេះ ទោះបីជាមានធនធានជាច្រើន រួមទាំងធនធានមនុស្ស និងសម្ភារៈដែលត្រូវបានគេយកមកប្រើក៏ដោយ។

លទ្ធផលមួយនៃកិច្ចប្រឹងប្រែងជាច្រើនរបស់រដ្ឋាភិបាល គឺការបង្កើតឡើងនូវស្ថាប័នជាច្រើន ដែលមានតួនាទីផ្សេងៗពីគ្នាក្នុងការងារប្រឆាំងអំពើពុករលួយ។ ការបង្កើតស្ថាប័នទាំងនេះនាំឱ្យមានការប្រឈមមុខដាក់គ្នា ដោយសារភាពមិនច្បាស់លាស់នៃដែនសមត្ថកិច្ច និងកង្វះកិច្ចសហប្រតិបត្តិការ។ ដើម្បីទប់ស្កាត់បញ្ហានេះមិនឱ្យកើតមានឡើង កិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធគឺជាការចាំបាច់ណាស់ ដើម្បីអនុវត្តឱ្យបាននូវវិធីសាស្ត្រទាំងមូលនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយ (Osborne, 2005:8) ។ មានការផ្តល់យោបល់ថា គួរតែបង្កើតស្ថាប័នចំរុះមួយរវាងស្ថាប័នទាំងនោះ ដោយមានប្រធានរបស់ ICPC ធ្វើជាប្រធាន។ ទោះបីជាយ៉ាងនេះក្តី យោងទៅតាម Osborne មានការជំទាស់មួយចំនួនចំពោះទស្សនៈនៃកិច្ចសហប្រតិបត្តិការរវាងបណ្តាស្ថាប័នទាំងនោះ ព្រោះថា ពួកគេចូលចិត្តសហការគ្នាក្រៅផ្លូវការជាង។ កិច្ចប្រជុំរវាងបុគ្គលដែលពាក់ព័ន្ធទាំងអស់ក៏ត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ផងដែរ ព្រោះថា តាមរយៈការចែករំលែកនូវព័ត៌មាន ពួកគេអាចមានឱកាសធ្វើឱ្យស្ថាប័នទាំងនោះជៀសវាងបាននូវការងារជាន់គ្នា និងជៀសវាងការខាតបង់ធនធាន (2005:15-16) ។

ICPC ដែលត្រូវបានបង្កើតឡើងធ្វើជាស្ថាប័នកំពូលចំពោះកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយ ដូចដែលបានពោលខាងលើនោះ ត្រូវបានគេដឹងថាបានបំពេញមុខងារទាបជាងអ្វីដែលគេបានរំពឹងទុក។ បញ្ហានេះបានបង្កឡើងដោយសារកត្តាជាច្រើន។ ជាការពិតណាស់ ឧបសគ្គមួយដ៏ធំបំផុតនោះគឺ ការជំទាស់ពីព្រឹទ្ធសភា។ ដូចគ្នានេះផងដែរ ច្បាប់ CPRO ហាមឃាត់មិនឱ្យគណៈកម្មការធ្វើការស៊ើបអង្កេតលើ

[៤] ក្រមសីលធម៌របស់មន្ត្រីរាជការស៊ីវិលគឺមានចែងនៅក្នុងមាតិកាទី ១ ផ្នែកទី ១ នៃរដ្ឋធម្មនុញ្ញ។

រឿងពុករលួយទាំងឡាយណាដែលបានកើតឡើងមុនពេលដែលគណៈកម្មការត្រូវបានបង្កើត។ របាយការណ៍មួយចំនួនតូចដែលគណៈកម្មការបានទទួល ផ្នែកខ្លះបានបង្ហាញឱ្យឃើញថាមាននីតិវិធីស្មុគស្មាញ រារាំងទឹកចិត្តសាធារណជនមិនឱ្យធ្វើរបាយការណ៍។ អត្រាដ៏ទាបនៃការស៊ើបអង្កេតលើរបាយការណ៍ដែលបានទទួល គឺបង្កឡើងដោយការខ្វះមូលនិធិ។ តាមពិត ICPC ខ្លួនឯង បានប្រកាសជាច្រើនលើកថា ខ្លួនកំពុងតែត្រូវការជំនួយហិរញ្ញវត្ថុ (Agbu, 2004:10 និង IT, 2004:225)។ បន្ថែមលើនេះទៀត ការងារស៊ើបអង្កេតរបស់ ICPC មានភាពប្រតិសកម្មជាជាងភាពសកម្ម។ ជាងនេះទៀត ការងារស៊ើបអង្កេតរបស់ ICPC មិនបានរកឃើញកំហុសចំពោះរឿងក្តីធំៗនោះទេ។ ICPC ដែលកំពុងតែមានសមត្ថភាពស្តួចស្តើងនៅទូទាំងប្រទេស ត្រូវជួបប្រទះនូវភាពស្មុគស្មាញកាន់តែច្រើនថែមទៀត ជាក់ស្តែង ដោយសារមិនមានកិច្ចខិតខំប្រឹងប្រែងជាលក្ខណៈឯករាជ្យណាមួយពីសំណាក់អាជ្ញាធររដ្ឋខ្លួនឯង ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ (TI, 2004:226)។ ICPC ខ្លួនឯងក៏មិនមានតម្លាភាព ដែលក្នុងន័យនេះ ICPC មិនទាន់បានបោះពុម្ពនូវរបាយការណ៍ ហើយក៏មិនទាន់មានគណនី ដែលបើកឱ្យមានសវនកម្មសាធារណៈបាន (Osborne, 2005:13)។ លើសពីនេះទៀត គណៈកម្មការត្រូវបានគេចោទថាមិនមានឯករាជភាព ហើយត្រូវបានគេសង្កេតឃើញថាគណៈកម្មកានេះត្រូវបានគេយកមកប្រើធ្វើជាឧបករណ៍បម្រើផលប្រយោជន៍នយោបាយ (TI, 2004:225)។

កង្វះឆន្ទៈនយោបាយដូចបានបញ្ជាក់តាមសកម្មភាពមួយចំនួនរបស់ព្រឹទ្ធសភា ដែលបានបង្ហាញខាងលើ ក៏ជាឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើពុករលួយ។ កង្វះឆន្ទៈនយោបាយនេះ នឹងរីករាលដាលទៅដល់អ្នកនយោបាយមួយចំនួនដែលមិនមែនជាសមាជិកព្រឹទ្ធសភា ព្រមទាំងប៉ូលីស (Agbu, 2004:22) ដែលប្រជាពលរដ្ឋចាត់ទុកថាជាស្ថាប័នពុករលួយបំផុតនៅក្នុងប្រទេស។ ការគ្មានគំរូនៃការដឹកនាំល្អពីក្នុងចំណោមវរជនរបស់ប្រទេស គឺជាបញ្ហាមួយ។ មានបណ្តឹងមួយចំនួនបានលើកឡើងថា កង្វះឆន្ទៈនយោបាយនេះបានអនុញ្ញាតឱ្យមន្ត្រីរដ្ឋាភិបាលមួយចំនួនដ៏សែនល្បីៗ ដែលគួរតែត្រូវបានគេស៊ើបអង្កេតពីបទប្រព្រឹត្តអំពើពុករលួយ អាចធ្វើការបញ្ចៀស ឬគេចផុតពីការស៊ើបអង្កេតនេះ (TI, 2005:225)។ តាមពិតទៅ ទោះបីជារយៈពេល ៥ ឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីលោកប្រធានាធិបតី អូបាសានចូ (Obasanjo) បានប្តេជ្ញាថា ចាត់វិធានការប្រឆាំងអំពើពុករលួយក៏ដោយ រហូតមកទល់ពេលនេះមិនទាន់ឃើញមានមន្ត្រីជាន់ខ្ពស់ណាម្នាក់ត្រូវបានផ្តន្ទាទោសដាក់គុកពីបទប្រព្រឹត្តអំពើពុករលួយឡើយ (Agbu, 2004:24)។

ការងារសំខាន់មួយគឺត្រូវជំរុញឱ្យប្រជាជនរបស់ប្រទេសនីហ្សេរីយ៉ា ចូលរួមក្នុងសង្គ្រាមប្រឆាំងអំពើពុករលួយ។ ការសន្យាជាច្រើនដែលមិនបានបំពេញដែលថានឹងបោសសម្អាតនូវផលវិបាកនៃអំពើពុករលួយ ហើយដោយសារមិនដែលមានការចាប់កំហុសចំពោះរឿងធំៗ ហើយនិងរដ្ឋាភិបាល ឬអ្នកនយោបាយសំខាន់ៗមិនបានផ្តល់គំរូល្អក្នុងការដឹកនាំ បានបណ្តាលឱ្យប្រជាពលរដ្ឋមានការលំបាកក្នុងការចូលរួម។ ទោះបីជាអំពើពុករលួយត្រូវបានគេយកចិត្តទុកដាក់តាមរយៈប្រព័ន្ធផ្សព្វផ្សាយក៏ដោយ គេជឿជាក់ថាប្រជាពលរដ្ឋជាច្រើនពិតជានៅតែមិនទាន់បានដឹងពីបញ្ហានេះនៅឡើយ (Osborne, 2005:4)។ ការរាប់បញ្ចូលសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ទៅក្នុងសង្គ្រាមប្រឆាំងអំពើពុករលួយ គឺអាចជាមធ្យោបាយមួយសម្រាប់ទាក់ទាញការគាំទ្រពីប្រជាពលរដ្ឋ ព្រោះថាសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ស្ថិតនៅក្នុងចំណោមបណ្តាស្ថាប័ន ដែលប្រជាពលរដ្ឋទុកចិត្តច្រើនជាងគេនៅក្នុងប្រទេស (agbu, 2004:14)។ឧទាហរណ៍មួយគឺ ក្រសួងហិរញ្ញវត្ថុបានទទួលយកសង្គមស៊ីវិលមួយឱ្យដាក់បណ្តាញទូរស័ព្ទសម្រាប់ឱ្យប្រជាពលរដ្ឋរាយការណ៍ភ្លាមៗតាមទូរស័ព្ទ។ គេជឿជាក់ថា ការធ្វើបែបនេះមានប្រសិទ្ធភាពក្នុងការទទួលបាននូវការទុកចិត្តពីប្រជាពលរដ្ឋ ជាជាងសេវាដែលផ្តល់ដោយរដ្ឋាភិបាល ឬស្ថាប័នណាមួយ ដែលគាំទ្រដោយរដ្ឋាភិបាល (Osborne, 2005:14)។

ស្ថាប័នដែលមានភារកិច្ចលើកកម្ពស់ ឬរក្សាការពារច្បាប់ ដូចជាស្ថាប័នប៉ូលីស និងស្ថាប័នតុលាការ គឺត្រូវបានគេយល់ថាជាស្ថាប័នពីរដែលមានអំពើពុករលួយច្រើនបំផុត។ រាល់កិច្ចប្រឹងប្រែងទប់ទល់នឹងបញ្ហាពុករលួយនៅក្នុងប្រទេស គឺត្រូវដោះស្រាយបញ្ហានេះមុនគេ។ ដូចដែលបានបង្ហាញនៅខាងលើ មានកិច្ចខិតខំប្រឹងប្រែងធ្វើសហប្រតិបត្តការជាមួយប្រទេសផ្តល់ជំនួយ ដើម្បីពង្រឹងសុចរិតភាព និងសមត្ថភាពរបស់ស្ថាប័នតុលាការ។ ប៉ុន្តែ វិធានរបស់តុលាការជាន់ខ្ពស់មិនស្របគ្នាខ្លាំងណាស់ទៅនឹងប្រភេទនៃរឿងដែលស្ថាប័នដូចជា EFCC និង ICPC ប្តឹង។ ក្នុងករណីជាច្រើន វិធានទាំងនេះត្រូវបានគេឆ្លៀតទាញយកប្រយោជន៍ ក្នុងគោលបំណងធ្វើឱ្យជាប់គាំងនូវរឿងក្តីដែលបានដាក់ទៅតុលាការ (Agbu, 2004:16)។ ជាការច្បាស់ណាស់ថា ដើម្បីទទួលបាននូវជោគជ័យលើសង្គ្រាមប្រឆាំងអំពើពុករលួយ ត្រូវពង្រឹងរាល់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនសុចរិតភាពរបស់តុលាការ។

## ប្រភព


- Agbu, Osita, ២០០៤ បូជនីយកិច្ចប្រឆាំងអំពើពុករលួយក្នុងប្រទេសនីហ្សេរីយ៉ា: ការប្រឈមនឹងបញ្ហាក្នុងការផ្តល់សេវាឯកសារដាក់ជូនទៅកិច្ចប្រជុំនៅប្រទេសកេនយ៉ា ស្តីអំពីរដ្ឋាភិបាលប្រឆាំងអំពើពុករលួយថ្មីៗ ដែលសហការរៀបចំដោយរដ្ឋាភិបាលរបស់ប្រទេសកេនយ៉ា, TI-Kenya និងអង្គការតម្លាភាពអន្តរជាតិ ពីថ្ងៃទី ១១-១៣ ខែ តុលា ឆ្នាំ ២០០៤ នៅទីក្រុង Nairobi ប្រទេសកេនយ៉ា ។
- Osbourne, Denis ខែ មិនា ឆ្នាំ ២០០៥ បទសិក្សារបស់ប្រទេសនីហ្សេរីយ៉ា UNDP-PACT (សេចក្តីព្រាងដំបូង) ។
- Raji, Hannuti ២០០៤ គណៈកម្មការឯករាជ្យទទួលបន្ទុកបទល្មើសពុករលួយ និងបទល្មើសពាក់ព័ន្ធផ្សេងៗទៀត - ទស្សនៈទូទៅដោយសង្ខេប សូមមើលគេហទំព័រ *www.icac.org.hk/news/issue 17eng/button2.htm*
- Saba, San ២០០២ ការិយាល័យក្រមសីលធម៌របស់ប្រទេសនីហ្សេរីយ៉ា សូមមើលគេហទំព័រ *www.icac.org.hk/newsl/issue8eng/button2.htm*
- អង្គការតម្លាភាពអន្តរជាតិ ២០០៤ របាយការណ៍ស្តីពីអំពើពុករលួយទូទៅឆ្នាំ២០០៤ សូមមើលគេហទំព័រ *www.globalcorruptionreport.org/gcr2004.htm*


ព័ត៌មានក៏អាចទទួលបានផងដែរពីវេបសាយនៃស្ថាប័នដែលបានបង្ហាញខាងលើ ។



# សាធារណរដ្ឋកូរ៉េ

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច (BAI) *www.bai.go.kr/gamsa/plsql/bai_ehome*
- គណៈកម្មការទប់ស្កាត់អំពើពុករលួយ
- គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ (KICAC) *www.kicac.go.kr*
- គណៈកម្មការការពារពលរដ្ឋកូរ៉េ (Ombudsman) *www.ombudsmam.go.kr/pub_root/english*
- នាយកដ្ឋានអយ្យការ (ក្រសួងយុត្តិធម៌) *www.moj.go.kr*
- ការិយាល័យព្រះរាជអាជ្ញាកំពូលនៃសាធារណរដ្ឋកូរ៉េ (SPO) *http://www.spo.go.kr*

## បទបញ្ញត្តិចម្បង

- ច្បាប់ប្រឆាំងអំពើពុករលួយ (ច្បាប់លេខ ៦៤៩៤ ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០១) *www.kicac.go.kr*
- ច្បាប់ស្តីពីក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច (ឆ្នាំ ១៩៦៣) ច្បាប់ (BAI)
- ក្រឹត្យអនុវត្តន៍ (ក្រឹត្យចេញដោយប្រធានាធិបតី លេខ ១៧៤២០ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ *www.kicac.go.kr*
- ច្បាប់ស្តីពីការិយាល័យព្រះរាជអាជ្ញា (PPO)Act
  *www1.oecd.org/daf/ASIAcom/pdf/korea_public_prosecutors_office_act.pdf*

## សាវតា

ជំហានទីមួយ ក្នុងការអនុវត្តវិធីសាស្ត្ររួមមួយ ស្តីពីការទប់ស្កាត់អំពើពុករលួយនៅកូរ៉េ ត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលស៊ីវិល ដែលកាន់កាប់អំណាចក្នុងឆ្នាំ ១៩៩៣ តាមរយៈការបោះឆ្នោតជ្រើសរើសប្រធានាធិបតី (Cho, ២០០១:៨)។ កិច្ចការនេះរួមមានការបង្កើតប្រព័ន្ធប្រកាសផ្សាយទ្រព្យសម្បត្តិរបស់មន្ត្រីសាធារណៈ ដែលដាក់ជាកាតព្វកិច្ចតម្រូវឱ្យមន្ត្រីសាធារណៈគ្រប់រូបចុះបញ្ជី និងបើកចំហទ្រព្យសម្បត្តិរបស់ខ្លួនឱ្យសាធារណជនបានដឹង ព្រមទាំងការបង្កើតច្បាប់ស្តីពីនីតិវិធីរដ្ឋបាល និងច្បាប់ស្តីពីការប្រាប់ព័ត៌មាន ដោយទីភ្នាក់ងារសាធារណៈ ដែលច្បាប់ទាំងពីរនេះ បានផ្តល់វិភាគទានដល់តម្លាភាពនៃសេវាសាធារណៈដែលចេះតែកើនឡើង។ យ៉ាងណាក៏ដោយ លំនាំដោះស្រាយអំពើពុករលួយនៅតែមិនត្រូវតាមក្បួនខ្នាតនៅឡើយ និងខ្វះភាពទូលំទូលាយ។

ការកែប្រែចម្បងមួយនៅក្នុងទស្សនៈរបស់សាធារណជន និងគោលនយោបាយជាផ្លូវការស្តីពីអំពើពុករលួយបានកើតឡើង ក្រោយពីមានវិបត្តិសេដ្ឋកិច្ចក្នុងឆ្នាំ ១៩៩៧។ គេបានទទួលស្គាល់ថា អំពើពុករលួយគឺជាកត្តាមួយក្នុងចំណោមកត្តាចម្បងនានា ដែលបង្កឱ្យមានភាពធ្ងន់ធ្ងរដល់វិបត្តិសេដ្ឋកិច្ច ដែលធ្វើឱ្យរដ្ឋាភិបាលប្រកាសសង្គ្រាមភ្លាមៗប្រឆាំងអំពើពុករលួយក្នុងឆ្នាំ ១៩៩៨ (KICAC ២០០៣:៣៧)។ នេះក៏ជាលទ្ធផលនៃសម្ពាធដែលចេះតែកើនឡើងទៅលើរដ្ឋាភិបាលផងដែរ សុំឱ្យមានចំណាត់ការប្រឆាំងអំពើពុករលួយ គឺធ្វើឡើងដោយសាធារណជន ដែលមានការ

ធុញថប់ក្នុងការមើលឃើញអំពើពុករលួយក្នុងកម្រិតយ៉ាងខ្ពស់ និងការភ្ញាក់ផ្អើលពីអំពើពុករលួយដែលចេះកើតឡើងវិញ (KICAC ២០០៤:៨១) ។ នៅឆ្នាំ ១៩៩៩ មានបង្កើតគណៈកម្មការប្រធានាធិបតីប្រឆាំងអំពើពុករលួយ (PCAC) ។ យ៉ាងណាក៏ដោយ គណៈកម្មការ PCAC នេះមិនត្រូវបានបំពាក់ឧបករណ៍គ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាអំពើពុករលួយទេ ហើយតួនាទីរបស់គណៈកម្មការមានភាពមិនច្បាស់លាស់ និងមានកម្រិត ដោយបំពេញមុខងារត្រឹមតែជាក្រុមប្រឹក្សាផ្តល់យោបល់ដល់ប្រធានាធិបតីតែប៉ុណ្ណោះ (KICAC ២០០៣:៣៨) ។

ក្នុងឆ្នាំ ២០០១ ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ACA ត្រូវបានអនុម័តដោយបានផ្តល់ឱ្យប្រទេសកូរ៉េ នូវច្បាប់ទូលំទូលាយស្តីពីអំពើពុករលួយជាលើកទីមួយ ។ មុនការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ACA នេះ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងសកម្មភាពទប់ស្កាត់អំពើពុករលួយ ដែលបច្ចុប្បន្ននេះត្រូវបានពង្រីកឱ្យមានការចូលរួមពីសាធារណជនទូទៅ ត្រូវបានកម្រិតត្រឹមតែការិយាល័យព្រះរាជអាជ្ញា នាយកដ្ឋានប៉ូលីស ក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ច BAI និងស្ថាប័នអធិការកិច្ចផ្សេងៗទៀតប៉ុណ្ណោះ ។ ច្បាប់ប្រឆាំងអំពើពុករលួយ ACA បានចែងពីការបង្កើតគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC ផងដែរ ។ គណៈកម្មការ KICAC នេះ ប្រកាន់យកលំនាំធ្វើការមួយដែលមានវិសាលភាពហួសពីការអនុវត្ត ដោយបានផ្តោតទៅលើការទប់ស្កាត់ ការអប់រំ ក៏ដូចជាការលើកស្ទួយការចូលរួមពីសាធារណជនផងដែរ នៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ដូចដែលលោកប្រធាននៃគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC បានកត់សម្គាល់ថា គណៈកម្មការនេះមានការរីកចម្រើនជាដុំកំភួននៅក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ នៅក្នុងឆ្នាំទីមួយ និងទីពីរនៃការបង្កើតគណៈកម្មការនេះ ថ្វីបើគ្មានការរីកចម្រើនគ្រប់គ្រាន់តាមសេចក្តីរំពឹងទុកយ៉ាងខ្ពស់របស់សាធារណជនក៏ដោយ (KICAC ២០០៤) ។

ប្រទេសកូរ៉េត្រូវបានចាត់ថ្នាក់ជាប្រទេសទី ៤០ ក្នុងចំណោមប្រទេសទាំង ១៥៩ នៅក្នុងសន្ទស្សន៍របស់អង្គការតម្លាភាពអន្តរជាតិ ស្តីពីការយល់ឃើញអំពីអំពើពុករលួយឆ្នាំ ២០០៥ ដែលបង្ហាញឱ្យឃើញថា អំពើពុករលួយនៅកូរ៉េមានកម្រិតខ្ពស់ជាងប្រទេសផ្សេងទៀត ដែលមានការអភិវឌ្ឍសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ (KICAC)** ត្រូវបានបង្កើតឡើងក្រោមអធិបតីភាពប្រធានាធិបតី នៅខែមករា ឆ្នាំ ២០០២ តាមមាត្រា ១០ នៃច្បាប់ប្រឆាំងអំពើពុករលួយ ACA ។ ច្បាប់ប្រឆាំងអំពើពុករលួយ ACA រួមគ្នាជាមួយនឹងច្បាប់ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច ED ចែងអំពីអាណត្តិការងារ កិច្ចប្រតិបត្តិការ និងការរៀបចំនៃគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC ។ គណៈកម្មការនេះមានសមាជិក ៩នាក់ រួមទាំងប្រធានម្នាក់ ដែលទទួលខុសត្រូវលើកិច្ចការរបស់គណៈកម្មការ KICAC (មាត្រា៧/១) នៃច្បាប់ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច (ED) និងសមាជិកអចិន្ត្រៃយ៍ ២នាក់ផង ។ ប្រធាន និងសមាជិកអចិន្ត្រៃយ៍ត្រូវតែងតាំងដោយប្រធានាធិបតី ហើយប្រធានាធិបតីតែងតាំងឬចាត់តាំងសមាជិកបីនាក់ផ្សេងទៀត តាមអនុសាសន៍របស់រដ្ឋសភា និងសមាជិកបីនាក់ផ្សេងទៀត តាមអនុសាសន៍របស់ប្រធានតុលាការកំពូល (មាត្រា ១២ នៃច្បាប់ប្រឆាំងអំពើពុករលួយ) ។ ឯករាជភាពរបស់គណៈកម្មការមានចែងនៅមាត្រា ១៥ នៃច្បាប់ប្រឆាំងអំពើពុករលួយ ដែលចែងថា គណៈកម្មការត្រូវបំពេញការងារដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនដោយឯករាជ្យ ។ បន្ថែមលើនេះ គណៈកម្មការត្រូវបានធានារ៉ាប់រងនូវសន្តិសុខមុខតំណែងផងដែរ ។

គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC ត្រូវបានគាំទ្រដោយលេខាធិការដ្ឋានមួយ ដែលមានការិយាល័យមួយ នាយកដ្ឋានពីរ និងផ្នែកចំនួនដប់ប្រាំ ។ លេខាធិការដ្ឋានត្រូវបានដឹកនាំដោយអគ្គលេខាធិការម្នាក់ ដែលតែងតាំងដោយប្រធានគណៈកម្មការពីក្នុងចំណោមសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មការ (មាត្រា ១៩ នៃច្បាប់ប្រឆាំងអំពើពុករលួយ) ។ អាណត្តិការងារ និងការទទួលខុសត្រូវចម្បងរបស់គណៈកម្មាឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ ចែកជាបួនផ្នែក ដូចតទៅនេះ:

- **ការរៀបចំគោលនយោបាយ និងការប៉ាន់ប្រមាណ រួមមានៈ**
  - រៀបចំគោលនយោបាយ និងកម្មវិធីប្រឆាំងអំពើពុករលួយ
  - កំណត់ផែនការអនុវត្តន៍និងផ្តល់អនុសាសន៍ដល់ទីភ្នាក់ងារសាធារណៈឱ្យបង្កើត និងអនុវត្តផែនការទាំងនេះ
  - ធ្វើការស្ទាបស្ទង់រកចំណុចខ្សោយស្តីពីកម្រិតអនុវត្តន៍នៅក្នុងស្ថាប័នសាធារណៈ
  - ធ្វើការស្ទង់មតិជាទៀងទាត់ពីកម្រិតនៃអំពើពុករលួយ មូលហេតុនៃអំពើពុករលួយ វិធីគិត និងឥរិយាបថរបស់មន្ត្រីសាធារណៈ
  - បង្កើត និងប្រកាសផ្សាយនូវការវាយតម្លៃលើគោលនយោបាយប្រឆាំងអំពើពុករលួយ ។

- **ផ្តល់អនុសាសន៍ស្តីពីការធ្វើឱ្យស្ថាប័នរីកចម្រើន (អនុសាសន៍ទាំងនេះមិនជាប់កាតព្វកិច្ចអនុវត្តទេ) រួមមានៈ**
  - បំបាត់ និងកាត់បន្ថយការអនុវត្ត និងនីតិវិធីមិនសមហេតុផល ដែលបណ្តាលឱ្យមានអំពើពុករលួយ
  - ធ្វើឱ្យប្រសើរឡើងគោលការណ៍សម្រាប់លើកស្ទួយតម្លាភាព នៅក្នុងស្តង់ដាររដ្ឋបាល និងនីតិវិធី និង
  - បង្កើតក្រមជាក់លាក់សម្រាប់ទីភ្នាក់ងារសាធារណៈផ្សេងៗ ដើម្បីលើកកម្ពស់សីលធម៌នៅក្នុងផ្នែកសាធារណៈ ។

- **ការគ្រប់គ្រងដល់ការបង្ហើបប្រាប់ពីអំពើពុករលួយ រួមមានៈ**
  - បង្កើតឧបករណ៍សម្រាប់ស្ថាប័ន និងប្រតិបត្តិការឧបករណ៍ទាំងនោះ ដូចជានីតិវិធីសម្រាប់កាន់កាប់របាយការណ៍ស្តីពីអំពើពុករលួយ ការការពារអ្នកបង្ហើបប្រាប់ពីអំពើពុករលួយ និងប្រព័ន្ធលើកទឹកចិត្ត ដើម្បីជំរុញឱ្យមានការចូលរួមជាសាធារណៈនៅក្នុងការប្រយុទ្ធនឹងអំពើពុករលួយ និង
  - ប្រើប្រាស់អំណាចក្នុងការចោទប្រកាន់មន្ត្រីសាធារណៈជាន់ខ្ពស់ដែលពុករលួយ ដាក់ពាក្យបណ្តឹងឱ្យតុលាការកាត់ទោស និងស្នើឱ្យមានការស៊ើបអង្កេតជាថ្មីចំពោះលទ្ធផលដែលមិនគ្រប់គ្រាន់ និងចំពោះវិធានការ ដែលមានការរើសអើងទៅលើអ្នកបង្ហើបប្រាប់ពីអំពើពុករលួយ ។[១]

- **សកម្មភាពអប់រំនិងលើកស្ទួយ រួមមានៈ**
  - លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់ដ៏គ្រោះថ្នាក់នៃអំពើពុករលួយ
  - ពង្រីកកម្មវិធីសិក្សាអំពីការប្រឆាំងអំពើពុករលួយនៅតាមសាលារៀន និងនៅតាមអង្គការសាធារណៈ
  - ធ្វើយុទ្ធនាការ ដោយមានសម្ព័ន្ធភាពជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកែប្រែការគិតរបស់សាធារណជន និង
  - បង្កើនសហប្រតិបត្តិការជាមួយនឹងដៃគូ និងអង្គការអន្តរជាតិ ។

មាត្រា ២៥ នៃច្បាប់ប្រឆាំងអំពើពុករលួយ ចែងថា ជនណាម្នាក់ដែលបានដឹងពីអំពើពុករលួយ អាចរាយការណ៍ពីអំពើបែបនេះដល់គណៈកម្មការ KICAC ។ ដើម្បីសម្រេចបានតាមភារកិច្ចនេះ គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC បានបង្កើតមជ្ឈមណ្ឌលទទួលរបាយការណ៍អំពីអំពើពុករលួយ ដែលមានភារកិច្ចទាំងស្រុងសម្រាប់ទទួលរបាយការណ៍អំពីអំពើពុករលួយ (KICAC ២០០៤:២១) ។ ការទទួលខុសត្រូវជាក់លាក់របស់មជ្ឈមណ្ឌលនេះរួមមានៈ

- ផ្តល់ព័ត៌មានទូទៅ និងផ្តល់យោបល់ ដល់អ្នករាយការណ៍អំពីអំពើពុករលួយ
- ពិនិត្យ និងចាត់ថ្នាក់របាយការណ៍ដែលបានប្រគល់ជូនដោយផ្ទាល់ខ្លួន តាមប្រៃសណីយ៍ ទូរសារ ឬតាមប្រព័ន្ធអ៊ីនធឺណិត (internet)
- វិភាគ និងចាត់ចែងបណ្តឹងតវ៉ាអំពីអំពើពុករលួយ
- បើកបន្ទប់ទទួលរបាយការណ៍ ដែលធ្វើការ ២៤ ម៉ោង
- គ្រប់គ្រងឯកសាររបាយការណ៍/ញត្តិ និងពិនិត្យមើលឯកសារទាំងនេះ ។

[១] អំណាចនៃគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ ក្នុងការចោទប្រកាន់មន្ត្រីសាធារណៈជាន់ខ្ពស់ និងដាក់ពាក្យបណ្តឹងឱ្យតុលាការកាត់សេចក្តី មានពិភាក្សាថែមទៀតនៅក្នុងកិច្ចសម្រួលប្រតិបត្តិការ ។

តាមច្បាប់ប្រឆាំងអំពើពុករលួយ អ្នកបង្ហើបប្រាប់អំពីអំពើពុករលួយត្រូវបានទទួលការការពារដល់ស្ថានភាពរស់នៅ មានន័យថាមិនត្រូវទទួលទណ្ឌកម្មជាបទវិន័យ ឬទទួលការរើសអើងដោយសារតែខ្លួនបានរាយការណ៍ ពីអំពើណាមួយដែលជាប់សង្ស័យថាជាអំពើពុករលួយនោះទេ។ ប្រសិនបើបុគ្គលណាមានអារម្មណ៍ថា ខ្លួនបានទទួលរងការអនុវត្តណាមួយដែលជាការខាតបង់ដល់ខ្លួនដោយសារតែខ្លួនបានរាយការណ៍ បុគ្គលនោះអាចស្នើសុំគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយ KICAC ឱ្យចាត់វិធានការដើម្បីការពារស្ថានភាពរស់នៅរបស់ខ្លួន។ ដោយអាស្រ័យលើការស៊ើបអង្កេតអំពីសំណើនោះ គណៈកម្មការអាចស្នើសុំប្រធាននៃទីភ្នាក់ងារពាក់ព័ន្ធឱ្យចាត់វិធានការធានាស្ថានភាពរបស់និយោជិតនៃទីភ្នាក់ងារ ល្គឹកណាតែមិនមានមូលដ្ឋានសមហេតុផលនឹងធ្វើដូច្នេះ (មាត្រា ៣២)។ អត្តសញ្ញាណនៃអ្នកនិយាយប្រាប់ពីអំពើពុករលួយ មិនអាចប្រកាសផ្សាយជាសាធារណៈបានទេ ហើយគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយអាចចាត់វិធានការដើម្បីធានាសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកនិយាយប្រាប់ពីអំពីអំពើពុករលួយ ប្រសិនបើសាម៉ីជនស្នើសុំឱ្យធ្វើដូច្នេះ។

## ការរៀបកិច្ចចំប្រតិបត្តិការ

មាត្រា ៣ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយចែងថា ទីភ្នាក់ងារសាធារណៈនីមួយៗត្រូវទទួលខុសត្រូវក្នុងការបង្កើតយន្តការសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ រួមទាំងការខិតខំលើកកម្ពស់ការយកចិត្តទុកដាក់របស់និយោជិតរបស់ខ្លួន ក៏ដូចជាសាធារណជនទូទៅ អំពីសារៈសំខាន់នៃការប្រយុទ្ធនឹងអំពើពុករលួយ។ មាត្រា ៦ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយចែងបន្ថែមទៀតថា ពលរដ្ឋម្នាក់ៗត្រូវសហប្រតិបត្តិការយ៉ាងពេញលេញជាមួយនឹងគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ និងកម្មវិធីរបស់ទីភ្នាក់ងារសាធារណៈ។ មន្ត្រីសាធារណៈមានកាតព្វកិច្ចរាយការណ៍ជូនគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ អំពីករណីពុករលួយណាមួយដែលខ្លួនបានដឹង (មាត្រា ២៦ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ)។

ដោយហេតុថាគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ មិនមានអំណាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងនៅពេលដែលបានទទួលរបាយការណ៍ ដែលគណៈកម្មការគិតថាមានភាពចាំបាច់នឹងធ្វើការស៊ើបអង្កេត គណៈកម្មការត្រូវបញ្ជូនរឿងក្តីនោះទៅអាជ្ញាធរមានសមត្ថកិច្ច (មាត្រា ២៩/៣ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ)។ តាមមាត្រា ២២/១ នៃច្បាប់ស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច រឿងក្តីអាចបញ្ជូនទៅ**ក្រុមប្រឹក្សាអធិការកិច្ច និងសវនកម្ម** និងប្រសិនបើមានការសង្ស័យថាមានឧក្រិដ្ឋកម្ម ត្រូវបញ្ជូនទៅទីភ្នាក់ងារស៊ើបអង្កេត។ ប្រសិនបើគ្មានភាពសមស្របនឹងបញ្ជូនរឿងក្តីទៅស្ថាប័នទាំងពីរខាងលើនេះទេ រឿងក្តីនោះអាចបញ្ជូនទៅអង្គការត្រួតមើលសកម្មភាពនៃទីភ្នាក់ងារសាធារណៈពាក់ព័ន្ធ។ ប្រសិនបើរឿងក្តីនោះតម្រូវឱ្យមានការចូលរួមដោយអាជ្ញាធរច្រើន គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយនឹងចាត់តាំងអាជ្ញាធរចម្បងមួយ ដែលនឹងកាន់កាប់រឿងក្តីនោះដោយសហប្រតិបត្តិការជាមួយនឹងអាជ្ញាធរផ្សេងទៀត (មាត្រា ២២/២ នៃការអភិវឌ្ឍសេដ្ឋកិច្ច)។ ក្នុងករណីគណៈកម្មការទទួលរបាយការណ៍ដែលមានការសង្ស័យពីអំពើពុករលួយ ដែលពាក់ព័ន្ធដល់មន្ត្រីសាធារណៈជាន់ខ្ពស់ គណៈកម្មការត្រូវធ្វើការចោទប្រកាន់ដោយផ្ទាល់ទៅអយ្យការ (មាត្រា ២៩/៤ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ)[២]។ នៅពេលទទួលការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវរាយការណ៍អំពីលទ្ធផលនៃការស៊ើបអង្កេតរបស់ខ្លួន ទៅគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ (មាត្រា ២៩/៥ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ)។

**រដ្ឋអាជ្ញា** មានអំណាច និងការទទួលខុសត្រូវតែឯកឯងក្នុងការស៊ើបអង្កេតឧក្រិដ្ឋកម្ម ពោលគឺ ផ្តួចផ្តើមនិងធ្វើសេចក្តីសន្និដ្ឋានអំពីការស៊ើបអង្កេត។ ដូច្នេះ ប៉ូលីសក៏ដូចជាទីភ្នាក់ងារអនុវត្តន៍ច្បាប់ផ្សេងទៀតដែរ ត្រូវបានតម្រូវឱ្យធ្វើការស៊ើបអង្កេតក្រោមទិសដៅ និងការពិនិត្យមើលរបស់រដ្ឋអាជ្ញា។ តាមការអនុវត្ត រដ្ឋអាជ្ញាចាត់ចែងការស៊ើបអង្កេតរបស់ប៉ូលីសចំពោះតែរឿងក្តីណា ដែលគេគិតថាមានសារៈសំខាន់កម្រិតខ្ពស់ប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ដោយហេតុថាមានតែរដ្ឋអាជ្ញាប៉ុណ្ណោះ ដែលអាចធ្វើសេចក្តីសន្និដ្ឋានអំពីការស៊ើបអង្កេតគ្រប់រឿងក្តីទាំងអស់ដែលប៉ូលីសបានស៊ើបអង្កេត ត្រូវបញ្ជូនទៅរដ្ឋអាជ្ញាដើម្បីធ្វើសេចក្តីសម្រេចជាចុងក្រោយ។ ក្នុងករណីដែលមានរឿងដែលទាក់ទិននឹងការខុសឆ្គងធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ចនិងអំពើពុករលួយ រដ្ឋអាជ្ញាផ្តួចផ្តើមធ្វើការស៊ើបអង្កេត។ នៅពេលបញ្ចប់ការស៊ើបអង្កេតនីមួយៗ គឺជាឆន្ទានុសិទ្ធិរបស់

[២] តាមមាត្រា ២៩/៤ នៃច្បាប់ប្រឆាំងនឹងអំពីអំពើពុករលួយ មន្ត្រីសាធារណៈជាន់ខ្ពស់រួមមាន មន្ត្រីសាធារណៈដែលមានឋានន្តរស័ក្តិស្មើនឹងអនុរដ្ឋមន្ត្រី ឬខ្ពស់ជាងនេះ អភិបាលក្រុងពិសេស ឬអភិបាលក្រុង អភិបាលខេត្ត មន្ត្រីប៉ូលីសដែលមានឋានន្តរស័ក្តិស្មើនឹងអគ្គស្នងការ ឬខ្ពស់ជាងនេះ ចៅក្រម ឬព្រះរាជអាជ្ញា មន្ត្រីយោធាដែលមានឋានន្តរស័ក្តិស្មើនឹងឧត្តមសេនីយ និង/ឬសមាជិករដ្ឋសភា។

រដ្ឋអាជ្ញាក្នុងការសម្រេចថាតើត្រូវធ្វើបណ្តឹងអាជ្ញាលើរឿងក្តីនោះ ឬយ៉ាងណា។ នៅក្នុងករណីដែលការស៊ើបអង្កេតបានកើតឡើងដោយការចោទប្រកាន់តាមមាត្រា ២៩/៤ នៃច្បាប់ប្រឆាំងអំពើពុករលួយ ហើយរដ្ឋអាជ្ញាសម្រេចមិនធ្វើបណ្តឹងអាជ្ញា គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងអំពើពុករលួយអាចដាក់ពាក្យសុំការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ ភាពខុសឆ្គងចំពោះការសម្រេចបែបនេះរបស់រដ្ឋអាជ្ញា។ ពាក្យសុំនោះត្រូវដាក់ទៅតុលាការ ដែលមានអមដោយការិយាល័យរដ្ឋអាជ្ញាដែលសាម៉ីរដ្ឋអាជ្ញាធ្វើការ (មាត្រា ៣១/១ នៃច្បាប់ប្រឆាំងនឹងអំពើពុករលួយ)។ រដ្ឋអាជ្ញាក៏មានភារកិច្ចត្រួតមើលការអនុវត្តសាលក្រមផ្តន្ទាទោសផងដែរ។

**ការិយាល័យឧត្តមរដ្ឋអាជ្ញា** ទទួលខុសត្រូវក្នុងការបង្កើត និងអនុវត្តគោលនយោបាយជាមូលដ្ឋាន ស្តីពីមុខងារ និងភារកិច្ចរបស់រដ្ឋអាជ្ញាក៏ដូចជាការត្រួតមើលនិងការគាំទ្រដល់**ការិយាល័យឧត្តមរដ្ឋអាជ្ញា** និង**ការិយាល័យរដ្ឋអាជ្ញាប្រចាំមណ្ឌល**។ ការិយាល័យឧត្តមរដ្ឋអាជ្ញា ស្ថិតនៅក្រោមការដឹកនាំរបស់អគ្គរដ្ឋអាជ្ញា ដែលចាត់ចែងនិងទទួលខុសត្រូវចំពោះសាច់រឿងទាំងអស់ ដែលទាក់ទិននឹងកិច្ចការអយ្យការ។ តាមបែបផែនគឺការិយាល័យរដ្ឋអាជ្ញាប្រចាំមណ្ឌលដែលធ្វើការស៊ើបអង្កេតរឿងព្រហ្មទណ្ឌ ហើយការិយាល័យរដ្ឋអាជ្ញាប្រចាំមណ្ឌលនីមួយៗមាននាយកដ្ឋានស៊ើបអង្កេតពិសេសមួយ ដែលមានតួនាទីសម្រាប់ស៊ើបអង្កេតអំពើពុករលួយនិងរឿងក្តីឧក្រិដ្ឋកម្មផ្នែកសេដ្ឋកិច្ច។

តាមមាត្រា ៨ នៃច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញា គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងឋានៈជាអ្នកត្រួតមើលចម្បងលើមុខងាររបស់អយ្យការដែលចាត់ចែងនិងត្រួតមើលរដ្ឋអាជ្ញា។ យ៉ាងណាក៏ដោយ នៅក្នុងករណីជាក់លាក់នានា លោករដ្ឋមន្ត្រីអាចចាត់ចែង និងត្រួតមើលត្រឹមតែអគ្គរដ្ឋអាជ្ញាប៉ុណ្ណោះ ដែលធ្វើសេចក្តីសម្រេចថាតើត្រូវបញ្ជូនសេចក្តីណែនាំទៅឱ្យរដ្ឋអាជ្ញា ដែលទទួលខុសត្រូវចំពោះរឿងក្តីនោះ ឬយ៉ាងណា។ រដ្ឋអាជ្ញាម្នាក់ៗ ស្ថិតនៅក្រោមបញ្ជារបស់រដ្ឋអាជ្ញាដែលជាមេរបស់ខ្លួនផ្ទាល់ ហើយរដ្ឋអាជ្ញាទាំងអស់ស្ថិតនៅក្រោមបញ្ជាអគ្គរដ្ឋអាជ្ញា។ ឯករាជភាពរបស់រដ្ឋអាជ្ញាត្រូវបានធានាបន្ថែមទៀត ដោយហេតុថា រដ្ឋអាជ្ញាទាំងនេះមិនត្រូវបានបណ្តេញចេញ ឬព្យួរការងារ លើកលែងតែត្រូវបានចោទប្រកាន់ជាផ្លូវការ ហើយតុលាការរកឃើញថាមានកំហុសពីបទឧក្រិដ្ឋធ្ងន់ធ្ងរ (មាត្រា ៣៧ នៃច្បាប់ស្តីពីការិយាល័យព្រះរាជអាជ្ញា)។ រដ្ឋអាជ្ញាត្រូវបានតែងតាំង និងចាត់តាំងដោយប្រធានាធិបតី តាមអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ចំពោះអគ្គរដ្ឋអាជ្ញាវិញ ការតែងតាំងត្រូវធ្វើឡើងដោយមានការយល់ព្រមនៅក្នុងសម័យប្រជុំរបស់រដ្ឋសភា (មាត្រា ៣៤ នៃច្បាប់ស្តីពីការិយាល័យរដ្ឋអាជ្ញា)។

នាយកដ្ឋានអយ្យការ ដែលស្ថិតនៅក្នុងទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រួតមើលការគ្រប់គ្រងបុគ្គលិកមន្ត្រីអយ្យការ។ នាយកដ្ឋាននេះមានអំណាចផងដែរក្នុងការបង្កើត និងធ្វើឱ្យមានភាពប្រសើរឡើងដល់ផែនការរដ្ឋបាលអយ្យការ ធ្វើការប្រមែប្រមូលថវិកាសម្រាប់ការរៀបចំអយ្យការ និងត្រួតមើលការបំបាត់ និងការទប់ស្កាត់ឧក្រិដ្ឋកម្ម ព្រមទាំងអនុវត្តសាលក្រមផងដែរ។

មាត្រា ១០៣ នៃរដ្ឋធម្មនុញ្ញចែងអំពីឯករាជភាពរបស់ចៅក្រម ក្នុងន័យដែលថា ចៅក្រមទាំងនេះត្រូវជម្រះក្តីដោយឯករាជ្យតាមមនសិការរបស់ខ្លួន និងដោយសមស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់។

**ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច** គឺជាស្ថាប័នសវនកម្មនិងអធិការកិច្ចកំពូល។ ក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ច គឺជាអង្គភាពដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលបានបង្កើតឡើងក្រោមអធិបតីភាពប្រធានាធិបតី តាមមាត្រា ៩៧ នៃរដ្ឋធម្មនុញ្ញ។ យ៉ាងណាក៏ដោយ មាត្រា ២ នៃច្បាប់ស្តីពីក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ច ចែងអំពីឯករាជភាពនៃក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ច នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ច ត្រូវបានដឹកនាំដោយក្រុមប្រឹក្សា ដែលមានសមាជិកប្រាំពីរនាក់ រួមទាំងប្រធាន ១រូបផង។ ប្រធានត្រូវបានតែងតាំងដោយប្រធានាធិបតី ដោយមានការយល់ព្រមពីរដ្ឋសភា ហើយសមាជិកផ្សេងទៀតត្រូវបានតែងតាំងដោយប្រធានាធិបតី តាមអនុសាសន៍របស់ប្រធានក្រុមប្រឹក្សា (មាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញ)។ សេចក្តីសម្រេចស្តីពីមុខងារក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចត្រូវធ្វើឡើងជារួមដោយសមាជិកនៃក្រុមប្រឹក្សា។ នៅក្នុងឆ្នាំ ១៩៩៣ **គណៈកម្មការទប់ស្កាត់អំពើពុករលួយ** ត្រូវបានបង្កើតឡើងជាអង្គភាពផ្តល់យោបល់ដល់ប្រធាននៃក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច ដោយផ្តល់យោបល់ និងអនុសាសន៍អំពីការប្រយុទ្ធនឹងអំពើពុករលួយ។

ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចមានអំណាចក្នុងការផ្ទៀងផ្ទាត់មើលគណនីចុងក្រោយរបស់រដ្ឋាភិបាល ធ្វើសវនកម្មលើគណនីរដ្ឋ គណនីរដ្ឋបាលខេត្ត និង គណនីរដ្ឋបាលស្វយ័តមូលដ្ឋានផ្សេងទៀត និងសាជីវកម្មដែលរដ្ឋាភិបាលដាក់ទុនធ្វើវិនិយោគ និងត្រួតមើលលទ្ធផលការងារនៃប្រតិបត្តិការរដ្ឋាភិបាលនិងនិយោជិតរបស់រដ្ឋាភិបាល។ ដើម្បីឱ្យមានភាពប្រសើរឡើងដល់កិច្ចប្រតិបត្តិការរបស់រដ្ឋាភិបាល និងលទ្ធផលការងាររបស់មន្ត្រីសាធារណៈ ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចអាចធ្វើការស៊ើបអង្កេតផងដែរអំពីបញ្ហាដែលមិនទាក់ទិននឹងការប្រើប្រាស់ថវិកាជាតិ។ ពេលធ្វើសវនកម្មនិងអធិការកិច្ចចប់រួចរាល់ហើយ ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចអាចបញ្ជាបុគ្គលដែលត្រូវទទួលខុសត្រូវឱ្យធ្វើការជួសជុលឬសងវិញ ប្រសិនបើមានការខូចខាត ឬការខាតបង់ដល់ទ្រព្យសម្បត្តិរដ្ឋាភិបាល។ ប្រសិនបើការស៊ើបអង្កេតរកឃើញភាពមិនប្រក្រតី ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច អាចស្នើសុំទីភ្នាក់ងារមានសមត្ថកិច្ចឱ្យចាត់វិធានការកែលម្អ និងប្រសិនបើរកឃើញថា បុគ្គលនោះបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរ ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ច អាចស្នើសុំទៅអង្គភាពត្រួតមើលពាក់ព័ន្ធ ឱ្យចាត់វិធានការជាបទវិន័យចំពោះបុគ្គលនោះ។ ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចអាចស្នើសុំទីភ្នាក់ងានានា ឱ្យចាត់វិធានការសម្រាប់ធ្វើឱ្យមានភាពប្រសើរឡើងផងដែរដល់នីតិកម្ម កិច្ចសម្របសម្រួល រចនាសម្ព័ន្ធ និងការអនុវត្តជាក់ស្តែង នៅពេលដែលយល់ថាមានភាពចាំបាច់នឹងធ្វើដូច្នេះ។ បន្ថែមលើនេះទៀត ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចមានអំណាចផងដែរក្នុងការផ្តល់ការគាំទ្រដល់ការបង្កើតសវនកម្មផ្ទៃក្នុង និងមុខងារអធិការកិច្ចនៅក្នុងទីភ្នាក់ងាររដ្ឋាភិបាល។ ក្នុងឆ្នាំនីមួយៗ ក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចរៀបចំរបាយការណ៍សវនកម្ម និងអធិការកិច្ចរបស់ខ្លួន ស្តីពីប្រតិបត្តិការរដ្ឋាភិបាលនៅក្នុងឆ្នាំកន្លងផុតទៅ ដែលត្រូវដាក់ជូនប្រធានាធិបតីនិងរដ្ឋសភា។ អំពីសាជីវកម្មដែលរដ្ឋាភិបាលដាក់ទុនធ្វើវិនិយោគ របាយការណ៍ប្រហាក់ប្រហែលគ្នានេះដែរត្រូវដាក់ជូនរដ្ឋាភិបាល។

**ការិយាល័យការពារពលរដ្ឋកូរ៉េ: Ombudsman of Korea (OK)** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ដើម្បីផ្តល់សុវត្ថិភាពទល់នឹងការអនុវត្តមិនល្អនៅក្នុងរដ្ឋបាល និងការពារសិទ្ធិ និងសារៈប្រយោជន៍របស់ពលរដ្ឋ។ អ្នកការពារពលរដ្ឋកូរ៉េ គឺជាស្ថាប័នរដ្ឋបាលឯករាជ្យ។ ក្រុមប្រឹក្សានៃអ្នកការពារពលរដ្ឋមានសមាជិកដប់នាក់ រួមមានប្រធានម្នាក់ សមាជិកអចិន្ត្រៃយ៍បីនាក់ និងសមាជិកមិនអចិន្ត្រៃយ៍ប្រាំមួយនាក់ ទាំងអស់នេះត្រូវបានតែងតាំងដោយប្រធានាធិបតី។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាត្រូវបានធ្វើឡើងដោយសម្លេងឆ្នោតភាគច្រើន ដោយសមាជិកម្នាក់ៗអាចបោះឆ្នោតបានមួយសម្លេង។ ការិយាល័យអគ្គលេខាធិការ ដែលជាប្រធានរដ្ឋបាលនៃលេខាធិការដ្ឋាន ដែលផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សានៃអ្នកការពារពលរដ្ឋ ត្រូវបានដឹកនាំដោយសមាជិកអចិន្ត្រៃយ៍ម្នាក់។ ការិយាល័យការពារពលរដ្ឋកូរ៉េ មានអំណាចធ្វើការស៊ើបអង្កេតអំពីបណ្តឹងសារទុក្ខដែលសាធារណជនបានដាក់ជូន។ ការិយាល័យការពារពលរដ្ឋកូរ៉េ មិនមានអំណាចចែងនៅក្នុងច្បាប់សម្រាប់ធ្វើការស៊ើបអង្កេតតាមការផ្តួចផ្តើមគំនិតរបស់ខ្លួនទេ។ ការិយាល័យនេះ អាចផ្តល់អនុសាសន៍ស្តីពីវិធានការកែលម្អ នៅពេលដែលការស៊ើបអង្កេតរបស់ខ្លួន បង្ហាញពីនីតិវិធីរដ្ឋបាលមិនត្រឹមត្រូវតាមច្បាប់ឬមិនសមហេតុផល ព្រមទាំងផ្តល់មតិ ឬផ្តល់អនុសាសន៍ សម្រាប់ធ្វើឱ្យប្រព័ន្ធរដ្ឋបាល និងប្រតិបត្តិការរបស់ប្រព័ន្ធនេះមានភាពប្រសើរឡើង។ យ៉ាងណាក៏ដោយ មតិ ឬអនុសាសន៍នៃការិយាល័យការពារពលរដ្ឋកូរ៉េ មិនជាប់កាតព្វកិច្ចអនុវត្តន៍ទេ។ ផ្ទុយទៅវិញការិយាល័យការពារពលរដ្ឋកូរ៉េ មានអំណាចស្នើសុំប្រធានទីភ្នាក់ងាររដ្ឋបាលពាក់ព័ន្ធ ឱ្យជូនដំណឹងដល់ការិយាល័យនេះនូវវិធានការដែលបានចាត់ការជាការឆ្លើយតបទៅនឹងមតិ និងអនុសាសសន៍ ដែលការិយាល័យការពារពលរដ្ឋកូរ៉េបានផ្តល់ដល់ទីភ្នាក់ងារនោះ។ បន្ទាប់មក ការិយាល័យការពារពលរដ្ឋកូរ៉េអាចប្រកាសផ្សាយរបាយការណ៍ទាំងនេះដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសាធារណជនទូទៅ និងរាយការណ៍ដោយផ្ទាល់ជូនប្រធានាធិបតី។ មានកម្រិតខ្លះៗ ចំពោះយុត្តាធិការនៃការិយាល័យការពារពលរដ្ឋកូរ៉េ រួមទាំងការកំហិតថាស្ថាប័ននេះមិនអាចស៊ើបអង្កេតបណ្តឹងសារទុក្ខទល់នឹងក្រុមប្រឹក្សាសវនកម្មនិងអធិការកិច្ចឬករណីដែលស្ថិតនៅក្រោមការស៊ើបអង្កេតរបស់ក្រុមប្រឹក្សាសវនកម្ម និងអធិការកិច្ចបានទេ។

## មេរៀនដែលទទួលបាន

ការបង្កើតគោលការណ៍បច្ចុប្បន្ន សម្រាប់ប្រយុទ្ធនឹងអំពើពុករលួយនៅកូរ៉េ កើតចេញពីបទពិសោធដែលបានទទួលពីការបរាជ័យក្នុងគ្រាអតីតកាល។ រដ្ឋាភិបាលទទួលស្គាល់ថាគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ ត្រូវតែមានភាពទូលំទូលាយ និងត្រូវតាមក្បួនខ្នាត។ គោលនយោបាយពីមុនគឺជាប្រភេទដែលខ្វះលំនាំដោះស្រាយ ដែលមានការគិតគូរឱ្យបានល្អិតល្អន់ និងគ្មានក្បួនខ្នាត (KICAC ២០០៣:៤២)។

កិច្ចប្រឹងប្រែងត្រូវបានតាក់តែងឡើង ជាពិសេស ដើម្បីត្រួតមើលអង្គការជាក់លាក់មួយចំនួន ឬពង្រីកការកាន់មុខតំណែង ពោលគឺ ដោយសារហេតុផលនយោបាយ ជាជាងចំណូលចិត្តពិតប្រាកដក្នុងការចាប់ផ្តើមដោះស្រាយបញ្ហាពុករលួយ (KICAC ២០០៣:៤០) ។

ការអនុម័តច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងការបង្កើតគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ ត្រូវបានមើលឃើញថាជាជំហានដ៏សំខាន់សម្រាប់ជំនះលើកង្វះខាតពីមុន។ គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ បានប្រកាន់យកលំនាំដោះស្រាយប្រហាក់ប្រហែលគ្នាទៅនឹងលំនាំដោះស្រាយដែល គេហៅថា លំនាំដោះស្រាយតាមវិធីសាស្រ្ត ៣មុខសញ្ញា ដែលគណៈកម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយនៅហុងកុងបានអនុម័ត ថ្វីត្បិតតែគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ គ្មានអំណាចស៊ើបអង្កេតក៏ដោយ។ ផ្ទុយទៅវិញ ការប្រកាន់យកលំនាំដោះស្រាយបែបនេះ ផ្តោតទៅលើការចងក្រង និងការវាយតម្លៃគោលនយោបាយ ការរៀបចំស្ថាប័ន ការទទួល និងការចាត់ចែងរបាយការណ៍ ហើយនិងសកម្មភាពអប់រំ និងការជំរុញ។ ដូចបានបញ្ជាក់ពីខាងលើ ថ្វីត្បិតតែគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយបានជោគជ័យ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏មតិសាធារណៈនៅតែយល់ថាមិនទាន់គ្រប់គ្រាន់។ ឧបសគ្គចម្បងមួយចំពោះ KICAC ក្នុងការបំពេញភារកិច្ចរបស់ខ្លួន គឺកង្វះអំណាចស៊ើបអង្កេត (KICAC ២០០៣:៣៩) ។ នៅក្នុងករណីដែលការិយាល័យការពារពលរដ្ឋកូរ៉េ (OK) គ្មានអំណាចសម្រាប់ផ្តួចផ្តើមធ្វើការស៊ើបអង្កេតដោយឯករាជ្យត្រូវបានមើលឃើញថា ជាឧបសគ្គចំពោះការបំពេញភារកិច្ចរបស់ខ្លួនដែរ។

ប្រព័ន្ធសម្រាប់បើកឱ្យមានការបង្ហើបប្រាប់ពីអំពើពុករលួយ ត្រូវបានគេមើលឃើញថាជាឧបករណ៍មួយដែលមានប្រសិទ្ធភាពបំផុតដែលគណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយអាចប្រើប្រាស់បាន ដែលក្នុងនោះ ការផ្តល់រង្វាន់ និងការការពារមានសារៈសំខាន់ជាពិសេស។ យ៉ាងណាក៏ដោយ គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ បានសង្កត់ថា មានតម្រូវការពង្រឹងទិដ្ឋភាពទាំងពីរនេះនៃប្រព័ន្ធ បង្ហើបប្រាប់ពីអំពើពុករលួយ (KICAC ២០០៤:៣៧) ។

អត្ថន័យទូលំទូលាយនៃអំពើពុករលួយ ដែលកំណត់ដោយច្បាប់ប្រឆាំងនឹងអំពើពុករលួយ ACA បានផ្តល់ដល់គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ KICAC នូវក្របខ័ណ្ឌការងារធំធេងផងដែរ។ កាលពីមុន ដែលអត្ថន័យនេះមានរួមបញ្ចូលតែស្ថាប័នមួយចំនួនតូចប៉ុណ្ណោះ បច្ចុប្បន្ននេះ ទស្សនៈស្តីពីអំពើពុករលួយរួមបញ្ចូលមិនគ្រាន់តែមន្ត្រីសាធារណៈប៉ុណ្ណោះទេ ក៏ប៉ុន្តែរួមបញ្ចូលទាំងសារៈប្រយោជន៍សាធារណៈផងដែរ (KICAC ២០០៣:៤០) ។ យ៉ាងណាក៏ដោយ ផ្នែកឯកជនមិនបានរួមបញ្ចូលទៅក្នុងអត្ថន័យនៃអំពើពុករលួយ ដូចដែលច្បាប់ប្រឆាំងនឹងអំពើពុករលួយបានចែងនោះទេ។

គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ KICAC បានទទួលស្គាល់ថា ការទប់ស្កាត់អំពើពុករលួយមានប្រសិទ្ធភាពជាងប្រព័ន្ធត្រួតពិនិត្យអំពើពុករលួយ ដែលអាស្រ័យលើការរើកមុខ និងការផ្តន្ទាទោសមន្ត្រីសាធារណៈ ក្រោយពីការប្រព្រឹត្តិមិនល្អកើតឡើងប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ដើម្បីឱ្យមានវិធានការទប់ស្កាត់ដែលមានប្រសិទ្ធភាព ចាំបាច់ត្រូវមានចំណេះដឹងពិតប្រាកដពីប្រភេទ និងកម្រិតនៃអំពើពុករលួយ។ ដូច្នេះ គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយ បានដៅបញ្ជាក់ពីការប៉ាន់ប្រមាណអំពីអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ ដោយធ្វើការប៉ាន់ប្រមាណអំពីភាពសុចរិតទៀងត្រង់ (KICAC ២០០៤:៤១) ។

ចំពោះរឿងនេះ គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយបញ្ជាក់ផងដែរពីសារៈសំខាន់នៃការអប់រំជាសាធារណៈ មិនគ្រាន់តែលើកកម្ពស់ការយល់ដឹងក្នុងការប្រយុទ្ធទល់នឹងអំពើពុករលួយប៉ុណ្ណោះទេ ក៏ប៉ុន្តែ ជំរុញសាធារណជនឱ្យរាយការណ៍ពីអំពើពុករលួយដែលជាប់សង្ស័យ ក៏ដូចជាលើកកម្ពស់ការយល់ដឹងអំពីកិច្ចការពារ និងការផ្តល់រង្វាន់ដល់អ្នកផ្តល់ព័ត៌មាន តាមប្រព័ន្ធនៃការបង្ហើបប្រាប់ពីអំពើពុករលួយ (KICAC ២០០៤:៥៣ និង KICAC ២០០៣:១៣៩) ។ ការអប់រំជាសាធារណៈ អាចលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីសកម្មភាពរបស់គណៈកម្មការឯករាជ្យកូរ៉េប្រឆាំងនឹងអំពើពុករលួយផងដែរ ក៏ដូចជាឱ្យបានទទួលទំនុកចិត្តពីសាធារណជន។ សារៈសំខាន់នៃការទទួលបានទំនុកចិត្ត និងការគាំទ្រពីសាធារណជន គឺជាមេរៀនដែលបានទទួលពីកិច្ចប្រឹងប្រែងពីមុនក្នុងការប្រយុទ្ធនឹងអំពើពុករលួយដែលទទួលបរាជ័យដោយអន្លើៗ ព្រោះតែខ្វះការគាំទ្រនិងទំនុកចិត្តពីសាធារណជន (Cho, ២០០១:៨) ។ កង្វះកិច្ចសហការពីសាធារណជន និងកង្វះចំណេះដឹងពី

សាធារណជនអំពីសកម្មភាពរបស់ក្រុមប្រឹក្សានៃការិយាល័យការពារពលរដ្ឋកូរ៉េ (OK) ត្រូវបានមើលឃើញថាជាបញ្ហាចំពោះ (OK) ដែលធ្វើឱ្យក្រុមប្រឹក្សាអ្នកការពារពលរដ្ឋផ្តោតការយកចិត្តទុកដាក់ភ្លាមៗទៅលើទំនាក់ទំនងសាធារណៈ និងសកម្មភាពប្រកាសផ្សាយព័ត៌មាន។

នៅប្រទេសកូរ៉េ ការចូលរួមរបស់សង្គមស៊ីវិល ក្នុងទម្រង់ជាអង្គការមិនមែនរដ្ឋាភិបាល និងក្រុមពលរដ្ឋ គឺជាអង្គធាតុដ៏សំខាន់នៅក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ (អង្គការតម្លាភាពអន្តរជាតិ ២០០៣:១៣៧)។ ក្រុមសង្គមស៊ីវិលទាំងនេះសំខាន់ណាស់ក្នុងការជំរុញឱ្យមានរបៀបវារៈស្តីពីអំពើពុករលួយ ហើយនិងហេតុដែលថា ច្បាប់ប្រឆាំងនឹងអំពើពុករលួយត្រូវបានអនុម័ត ទោះជាមានការប្រឆាំងយ៉ាងខ្លាំងពីអ្នកកាន់កាប់អំណាចក៏ដោយ ក៏មួយផ្នែក ដោយសារកិច្ចប្រឹងប្រែងរបស់ក្រុមសង្គមស៊ីវិលទាំងនេះដែរ (KICAC ២០០៣:៣៩)។

## ប្រភព


- Cho, Eun-Kyoung ២០០១ របាយការណ៍ស្រាវជ្រាវរដ្ឋអំពីប្រព័ន្ធជាតិស្តីពីភាពសុចរិតទៀងត្រង់ សាធារណរដ្ឋកូរ៉េ ឆ្នាំ ២០០១ *http://transparency.org/activities/nat_integ_systems/dnld/rep_korea.pdf*
- KICAC ២០០៣ របាយការណ៍ប្រចាំឆ្នាំ របស់ KICAC ឆ្នាំ ២០០២
- KICAC ២០០៤ របាយការណ៍ប្រចាំឆ្នាំ របស់ KICAC ឆ្នាំ ២០០៣ *http://www.kicac.go.kr*
- អង្គការតម្លាភាពអន្តរជាតិ ២០០៣ របាយការណ៍សកលអំពីអំពើពុករលួយ ឆ្នាំ ២០០៣។ *http://www.globalcorruptionreport.org/gcr2003.html*


ព័ត៌មានក៏អាចទទួលបានផងដែរពីវេបសាយនៃស្ថាប័នដែលបានបង្ហាញខាងលើ។



# ប្រទេសសិង្ហបុរី

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- អង្គសភាអគ្គមេធាវីសិង្ហបុរី *http://www.agc.gov.sg/index.html*
- ការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្មពុករលួយ (CPIB) *http://www.cpib.gov.sg*

## បទបញ្ញត្តិច្បាប់[១]

- ច្បាប់ស្តីពីអំពើពុករលួយ ចរាចរគ្រឿងញៀន និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀត (ការរឹបអូសផល) ច្បាប់លេខ២៩ ឆ្នាំ១៩៩២ ធ្វើវិសោធនកម្មរហូតដល់ឆ្នាំ២០០៤ (CBA) ។
- ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ ច្បាប់លេខ ៤/១៨៧១ ធ្វើវិសោធនកម្មរហូតដល់ឆ្នាំ ១៩៩៨ ។
- ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (លេខ ២៤១) បទបញ្ជា លេខ ៣៩/១៩៦០ ធ្វើវិសោធនកម្ម រហូតដល់ឆ្នាំ ២០០២ (POCA) ។

## សាវតា

នៅពេលដែលសិង្ហបុរីបានឯករាជ្យក្នុងឆ្នាំ ១៩៥៩ ប្រទេសនេះបន្តប្រព័ន្ធអភិបាលកិច្ចមួយប្រភេទ ដែលមានអំពើពុករលួយយ៉ាងទូលំទូលាយ ។ អំពើពុករលួយបានក្លាយជារបៀបនៃការរស់នៅ ដោយមានអំពើពុករលួយបែបអង្គការចាត់តាំងយ៉ាងទូលំទូលាយ ហើយការសូកមន្ត្រីសាធារណៈដើម្បីឱ្យបានទទួលសេវា គឺជាការអនុវត្តសាមញ្ញមួយ (Ali ២០០០:៣) ។ អំពើពុករលួយត្រូវតែមើលឃើញថាជាសកម្មភាពដែលមានហានិភ័យទាប/រង្វាន់ខ្ពស់ ហើយកម្រចាប់បានមន្ត្រីពុករលួយណាស់ និងនៅពេលដែលចាប់បាន ក៏មន្ត្រីនោះមិនទទួលការផ្តន្ទាទោសធ្ងន់ធ្ងរដែរ (Quah ១៩៩៩:៨២) ។ រឿងហ្នឹងគឺវាអញ្ចឹង សូម្បីតែនៅពេលដែលការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្ម ពុករលួយ (CPIB) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៥២ ក៏ដោយក្តី ។ ការបរាជ័យដំបូងនៃការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្មពុករលួយ (CPIB) ក្នុងការចាប់ផ្តើមដោះស្រាយបញ្ហាអំពើពុករលួយ គឺដោយសារគោលការណ៍ច្បាប់មិនរឹងមាំ និងដោយហេតុថាពីដំបូងមន្ត្រីនៃការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្មពុករលួយ (CPIB) ត្រូវបានជ្រើសរើសពីកម្លាំងប៉ូលីសសិង្ហបុរី ដែលជាផលវិបាក មន្ត្រីទាំងនេះមិនបានប្តូផ្តាច់ស៊ើបអង្កេតលើការប្រព្រឹត្តិអំពើពុករលួយ ដែលភាគច្រើនពាក់ព័ន្ធនឹងមន្ត្រីប៉ូលីសដែលជាអតីតសហសេវិករបស់ពួកខ្លួននោះទេ ។ ហើយនៅក្នុងការបំពេញការងារជាបណ្តោះអាសន្ន មន្ត្រីប៉ូលីសទាំងនោះមិនបានទទួលកិច្ចការពារ និងសន្តិសុខមុខតំណែងគ្រប់គ្រាន់សម្រាប់ការបំពេញការងារសោះឡើយ ។ ជាលទ្ធផល មន្ត្រីជាច្រើនត្រូវបានទទួលការតែងតាំងថ្មីមុននឹងពួកគេអាចធ្វើការស៊ើបអង្កេតរបស់គេបានចប់សព្វគ្រប់ ។ បន្ថែមលើនេះទៀត សេវាសាធារណៈមានទម្លាប់ប្រព្រឹត្តអំពើពុករលួយ ដោយសារតែមានសមត្ថភាពទន់ទាប ប្រាក់បៀវត្សតិច និងខ្វះភាពសុចរិតទៀងត្រង់ រួមផ្សំនឹងវប្បធម៌ទូទៅដែលគិតថា មន្ត្រីសាធារណៈមានឧត្តមភាពលើពលរដ្ឋ និងការយល់ព្រមទទួលយកជាសាធារណៈនូវប្រព្រឹត្តិកម្មមិនសមស្របពីសំណាក់មន្ត្រីសាធារណៈ (Ali ២០០០:៣-៤) ។ ការគាំទ្រពីក្នុងចំណោមពលរដ្ឋក៏គ្មានដែរ ដោយហេតុថាសាធារណជនមិនទុកចិត្តទៅលើប្រសិទ្ធភាពនៃការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្មពុករលួយ (CPIB) នេះ ។

---

[១] គ្រប់នីតិកម្មទាំងអស់មាននៅ *http://statutes.org.gov.sg.*

នៅពេលដែលគណៈបក្ស People's Action Party ឡើងកាន់អំណាចក្នុងឆ្នាំ ១៩៥៩ រដ្ឋាភិបាលថ្មី បានប្រកាសជាបន្ទាន់ អំពីការកាត់បន្ថយអំពើពុករលួយឱ្យនៅតិចបំផុត និងបានចាត់ទុកអំពើពុករលួយថាជាសកម្មភាពដែលមានហានិភ័យខ្ពស់/រង្វាន់តិច។ ដូច្នេះ នៅក្នុងឆ្នាំ ១៩៦០ យុទ្ធសាស្ត្រទូលំទូលាយប្រឆាំងនឹងអំពើពុករលួយត្រូវបានបង្កើតឡើងតាមរយៈការអនុម័តច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA)។ យុទ្ធសាស្ត្រនេះ មានមូលដ្ឋានលើគោលការណ៍ដែលថា "អំពើពុករលួយបង្កឡើងដោយគ្រឿងលើកទឹកចិត្តផង និងដោយឱកាសប្រព្រឹត្តពុករលួយផង" ដូច្នេះគេតម្រូវថា ត្រូវតែកំចាត់ទាំងគ្រឿងលើកទឹកចិត្ត ទាំងឱកាសប្រព្រឹត្តអំពើពុករលួយនេះចេញ (Quah ១៩៩៩:៨៣)។ ការដឹកនាំល្អធ្វើជាគំរូ និងគោលនយោបាយមិនអត់អោនចំពោះអំពើពុករលួយ គឺជាអង្គធាតុសំខាន់នៃយុទ្ធសាស្ត្រសម្រាប់កែប្រែឥរិយាបថរបស់ពលរដ្ឋ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA បានពង្រីកអំណាចស៊ើបអង្កេតរបស់ការិយាល័យស៊ើបអង្កេតប្រព្រឹត្តិកម្មពុករលួយ (CPIB) ដោយបានផ្តល់ដល់ការិយាល័យនេះ នូវឧបករណ៍ដែលត្រូវការចាំបាច់សម្រាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ ព្រមទាំងបង្កើនការផ្តន្ទាទោសលើការប្រព្រឹត្តិអំពើពុករលួយផងដែរ។ ជាលទ្ធផល វិធានការម៉ឺងម៉ាត់ត្រូវបានដាក់ប្រឆាំងនឹងមន្ត្រីពុករលួយ ដែលបណ្តាលឱ្យមានការគាំទ្រ និងសហប្រតិបត្តិការកាន់តែច្រើនឡើងពីសាធារណជន ហើយនិងជាបណ្តាំច្បាស់លាស់មួយ ដែលប្រាប់ថា ច្បាប់ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង និងថាអំពើពុករលួយ គឺជាសកម្មភាពដែលមានហានិភ័យខ្ពស់/រង្វាន់តិច។

ប្រទេសសិង្ហបុរីត្រូវបានចាត់ថ្នាក់ជាប្រទេសទី៥ ក្នុងចំណោមប្រទេសទាំង ១៥៩ នៅក្នុងសន្ទស្សន៍ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិ ស្តីពីទស្សនៈលើអំពើពុករលួយ។ ដូច្នេះ សិង្ហបុរីត្រូវបានចាត់ថ្នាក់ជាប្រទេសដែលមានអំពើពុករលួយតិចជាងគេបំផុតប្រចាំតំបន់អាស៊ីនៅក្នុងសន្ទស្សន៍នេះ ហើយបច្ចុប្បន្ននេះ សិង្ហបុរីជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអំពើពុករលួយតិចជាងគេនៅក្នុងពិភពលោក។ ក្នុងស្ថានភាពបែបនេះ សិង្ហបុរីបានទទួលការទទួលស្គាល់ទូទាំងពិភពលោក និងការគោរពចំពោះវប្បធម៌នៃភាពសុចរិតទៀងត្រង់របស់ប្រទេសនេះ ដែលជ្រាបចូលទៅក្នុងរដ្ឋបាលសាធារណៈ ក៏ដូចជាផ្នែកឯកជនដែរ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB)** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៥២។ ការិយាល័យនេះគឺជាស្ថាប័នឯករាជ្យមួយ **ដែលស្ថិតនៅក្នុងការិយាល័យនាយករដ្ឋមន្ត្រី (PMO)**។ ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ដឹកនាំដោយនាយកម្នាក់ ដែលតែងតាំងដោយប្រធានាធិបតី តាមអនុសាសន៍របស់គណៈរដ្ឋមន្ត្រី ឬរដ្ឋមន្ត្រីម្នាក់ដែលជាតំណាងស្ថិតនៅក្រោមអំណាចទូទៅនៃគណៈរដ្ឋមន្ត្រី។ ប្រធានាធិបតីអាចបដិសេធ ឬដកហូតការតែងតាំងនាយកនេះ ប្រសិនបើប្រធានាធិបតីមិនឯកភាពតាមអនុសាសន៍ដែលដាក់ជូន (អនុផ្នែក ៣/១ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ)។ នាយកត្រូវទទួលខុសត្រូវផ្ទាល់ចំពោះនាយករដ្ឋមន្ត្រី។ ប្រធានាធិបតីតែងតាំងនាយករងផងដែរ និងនាយកជំនួយការ និងអ្នកស៊ើបអង្កេតពិសេសមួយចំនួនតាមការចាំបាច់ (អនុផ្នែក ៣/២ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA)។ អ្នកទាំងអស់នេះជាមន្ត្រីសាធារណៈ តាមបញ្ញត្តិនៃអនុផ្នែក ៤/១ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA។

ការទទួលខុសត្រូវចម្បងរបស់ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) គឺអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ដូច្នេះ CPIB គឺជាអង្គភាពចម្បងដែលទទួលខុសត្រូវក្នុងការស៊ើបអង្កេត និងទប់ស្កាត់អំពើពុករលួយ។ ក្នុងស្ថានភាពបែបនេះ មុខងារបីប្រភេទនៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) រួមមាន:

- **ទទួលនិងស៊ើបអង្កេតលើបណ្តឹង**ស្តីពីអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន
- **ស៊ើបអង្កេតការអនុវត្តមិនល្អ និងអាកប្បកិរិយាមិនសមស្របរបស់មន្ត្រីសាធារណៈ** និង
- **ពិនិត្យមើលការអនុវត្ត និងនីតិវិធីនៅក្នុងសេវាសាធារណៈ** ដើម្បីកាត់បន្ថយឱកាសប្រព្រឹត្តអំពើពុករលួយឱ្យនៅតិចបំផុត។

រចនាសម្ព័ន្ធនៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ចែកចេញជាបីសាខាដូចតទៅនេះ:

- សាខាស៊ើបអង្កេត ដែលជាសាខាធំជាងគេ មានបួនអង្គភាព ដែលអង្គភាពនីមួយៗដឹកនាំដោយទេសជំនួយការនាយកម្នាក់ ដែលទទួលខុសត្រូវក្នុងការចាត់ចែង និងត្រួតមើលការស៊ើបអង្កេត។
- សាខាគ្រប់គ្រងទិន្នន័យនិងគាំទ្រ ដែលកាន់កាប់ និងចាត់ចែងប្រព័ន្ធព័ត៌មានតាមកុំព្យូទ័រ ដែលអាចបង្កលក្ខណ:ឱ្យការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) អាចតាក់តែងយុទ្ធសាស្ត្រទប់ស្កាត់អំពើពុករលួយ និងជ្រើសរើសបេក្ខជនសម្រាប់តែងតាំងជាមន្ត្រីសាធារណ: ការតម្លើងឋានន្តរសក្តិ អាហារូបករណ៍ និងការហ្វឹកហ្វឺន។ អង្គភាពស្រាវជ្រាវនៅក្នុងសាខានេះ ពិនិត្យមើលនីតិវិធីបំពេញការងាររបស់នាយកដ្ឋាននានាដែលងាយរងអំពើពុករលួយ។ អង្គភាពស៊ើបការណ៍ផ្តល់ព័ត៌មាន ដែលតម្រូវឱ្យមានសម្រាប់បំពេញតាមតម្រូវការប្រតិបត្តិការនៃសាខាស៊ើបអង្កេត។
- **សាខារដ្ឋបាល** ដែលផ្តល់ការគាំទ្រផ្នែករដ្ឋបាលដល់សាខាពីរផ្សេងទៀត និងទទួលខុសត្រូវផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងបុគ្គលិករបស់ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) (Quah ២០០៣)។

ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) មានទំហំតូច ដែលមានបុគ្គលិកតែជាង ៨០ នាក់ប៉ុណ្ណោះ។ ឧទាហរណ៍ គណ:កម្មការឯករាជ្យប្រឆាំងនឹងអំពើពុករលួយនៅហុងកុង មានបុគ្គលិក ១៥ដងច្រើនជាងនេះ។ យ៉ាងណាក៏ដោយ ទីតាំងរបស់ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ដែលស្ថិតនៅក្នុងការិយាល័យនាយករដ្ឋមន្ត្រី ហើយនិងអំណាចផ្លូវច្បាប់របស់ការិយាល័យនេះក្នុងការទទួលបានសហប្រតិបត្តិការពីអង្គការសាធារណ: និងឯកជន អាចឱ្យការិយាល័យ (CPIB) នេះបំពេញការងាររបស់ខ្លួនបាន ដោយមិនបាច់តម្រូវឱ្យមានបុគ្គលិកបន្ថែម ទោះជាមានបន្ទុកការងារច្រើនលើសលុបក៏ដោយ (Quah ១៩៩៩:៨៤)។

តាមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) ការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) មានអំណាចទូលំទូលាយក្នុងការស៊ើបអង្កេតនិងចាប់ខ្លួន។ ផ្នែក ១៥ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) ចែងថា នាយក ឬអ្នកស៊ើបអង្កេតពិសេសនៃការិយាល័យនេះអាចចាប់ខ្លួន ក៏ដូចជាឆែកឆេរដោយមិនបាច់មានដីកា ចំពោះជនណាដែលសង្ស័យថាបានប្រព្រឹត្តអំពើពុករលួយក្រោមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA)។ ក្នុងករណីនៃបទល្មើសដែលស្ថិតនៅក្រោមផ្នែក ១៦៥ និងផ្នែក ២១៣-២១៥ នៃក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) ឬបទល្មើស ដែលអាចចាប់បានណាមួយ ដែលគេបានរកឃើញនៅពេលស៊ើបអង្កេតតាមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) នាយក ឬអ្នកស៊ើបអង្កេតពិសេស អាចប្រើអំណាចណាមួយ ឬអំណាចទាំងស្រុងរបស់ប៉ូលីសស៊ើបអង្កេត ដោយមិនបាច់មានបញ្ជាពីរដ្ឋអាជ្ញា (ផ្នែក ១៧/១ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA)។ នាយកការិយាល័យទប់ស្កាត់និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ឬចៅក្រម ដោយមានដីកា អាចបញ្ជាអ្នកស៊ើបអង្កេតពិសេស (ឬប៉ូលីស) ឱ្យចូលទៅក្នុងបរិវេណណាមួយដោយប្រើកម្លាំង ប្រសិនបើចាំបាច់ដើម្បីធ្វើការឆែកឆេរ។ ប្រសិនបើអ្នកស៊ើបអង្កេតមានហេតុផលអាចជឿថា ការស្វែងរកដីកាអាចបន្ទុចបង្អាក់ដល់ការឆែកឆេរ អ្នកស៊ើបអង្កេតអាចចូលទៅក្នុងបរិវេណនោះដោយមិនបាច់មានដីកា (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ/ផ្នែក ២២ (POCA))។ ដោយប្រើលិខិតបញ្ជា រដ្ឋអាជ្ញាអាចអនុញ្ញាតឱ្យការិយាល័យទប់ស្កាត់និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ប្រើអំណាចស៊ើបអង្កេតពិសេស (សូមមើលខាងក្រោមនៅផ្នែកការរៀបចំកិច្ចប្រតិបត្តិការ)។

ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) ចែងថែមទៀតថា ជនម្នាក់ៗមានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការផ្តល់ព័ត៌មានដល់នាយក ឬមន្ត្រីណាម្នាក់នៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) អំពីប្រធានបទណាមួយ ដែលនាយកឬមន្ត្រីនោះមានភារកិច្ចស៊ើបអង្កេតតាមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) (ផ្នែក ២៧)។ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ (POCA) ក៏មានចែងអំពីការការពារអ្នកផ្តល់ព័ត៌មានផងដែរ ដែលរាយការណ៍ពីអំពើពុករលួយដែលជាប់សង្ស័យ (ផ្នែក ៣៦)។

បន្ថែមទៅនឹងការពិនិត្យមើលឡើងវិញលើវិធីធ្វើការងារ និងផ្តល់យោបល់ដល់ផ្នែកសាធារណ: និងឯកជន អំពីរបៀបកាត់បន្ថយវិធីសាស្ត្រ និងនីតិវិធីដែលងាយរងអំពើពុករលួយឱ្យនៅតិចបំផុត ឧបករណ៍ទប់ស្កាត់បន្ថែមរួមមាន សេចក្តីតម្រូវដែលថាមន្ត្រីសាធារណ:គ្រប់រូបត្រូវធ្វើសេចក្តីប្រកាសនូវភាពមិនជំពាក់បំណុល និងសេចក្តីប្រកាសអំពីទ្រព្យ និងវិនិយោគ នៅពេលបានទទួលការតែងតាំង និងក្រោយមកត្រូវធ្វើមួយឆ្នាំម្តង។

ថ្វីបើការិយាល័យទប់ស្កាត់និងស៊ើបអង្កេតអំពើពុករលួយ (CPIB) មិនមានសាខាដែលធ្វើទំនាក់ទំនងជាមួយសាធារណជនដោយផ្ទាល់ក៏ដោយ ក៏ការិយាល័យនេះមើលឃើញការអប់រំសាធារណៈថាជាអង្គធាតុជាសារវន្តនៃយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពក្នុងការប្រយុទ្ធនឹងអំពើពុករលួយផងដែរ ។ ចំពោះគោលដៅនេះ ការិយាល័យបានធ្វើបាឋកថា និងសិក្ខាសាលាជាទៀងទាត់ សម្រាប់អប់រំមន្ត្រីសាធារណៈអំពីជម្ងឺនៃអំពើពុករលួយ ជាពិសេស មន្ត្រីដែលធ្វើការនៅក្នុងមុខងារទាំងឡាយណាដែលងាយប្រព្រឹត្តអំពើពុករលួយ ។

## ការរៀបចំកិច្ចប្រតិបត្តិការ

យ៉ាងណាក៏ដោយ ការទទួលខុសត្រូវក្នុងការប្រយុទ្ធនឹងអំពើពុករលួយមិនមែនស្ថិតនៅក្នុងការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) តែម្នាក់ឯងទេ ។ ថ្វីបើការិយាល័យ (CPIB) មានការទទួលខុសត្រូវចម្បងក្នុងការស៊ើបអង្កេតករណីពុករលួយក៏ដោយ ក៏ការទទួលខុសត្រូវចម្បងសម្រាប់ទប់ស្កាត់អំពើពុករលួយ ស្ថិតនៅក្នុងនាយកដ្ឋាននីមួយៗ ។ លេខាធិការអចិន្ត្រៃយ៍នៃក្រសួងនីមួយៗត្រូវទទួលខុសត្រូវក្នុងការធានាថានាយកដ្ឋាននីមួយៗមានគណៈកម្មាធិការមួយ ដែលមានភារកិច្ចពិនិត្យមើលឡើងវិញអំពីវិធានការប្រឆាំងនឹងអំពើពុករលួយ ។ វិធានការទាំងនេះរួមមាន ការធ្វើឱ្យមានភាពប្រសើរឡើងដល់វិធីបំពេញការងារនិងនីតិវិធី ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធតាមមើល រួមទាំងការឆែកមើលជាធម្មតានិងមិនឱ្យដឹងខ្លួនជាមុន ការផ្លាស់ប្តូរការងារជាទៀងទាត់របស់មន្ត្រីសាធារណៈ និងការដាក់ឱ្យអនុវត្តវិធានការម៉ឺងម៉ាត់សម្រាប់គ្រប់គ្រងទំនាស់ផលប្រយោជន៍ (Ali ២០០០:៨-៩) ។

**អគ្គមេធាវី** ដែលតែងតាំងដោយប្រធានាធិបតី តាមការជូនយោបល់របស់នាយករដ្ឋមន្ត្រី (មាត្រា ៣៥/១ នៃរដ្ឋធម្មនុញ្ញ) ក៏ជាអគ្គរដ្ឋអាជ្ញាផងដែរ ហើយក្នុងមុខនាទីនេះ មានអំណាចផ្តួចផ្តើមដឹកនាំ ឬបញ្ឈប់ ដំណើរការក្តីនៃបទល្មើសណាមួយ (មាត្រា ៣៥/៨ នៃរដ្ឋធម្មនុញ្ញ) ។ អគ្គមេធាវីមានឯករាជភាពនៅក្នុងតួនាទីនេះនឹងមិនស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលទេ ។ អគ្គមេធាវីជា**ប្រធានសភាអគ្គមេធាវី**នៃសិង្ហបូរី ដែលចែកជាប្រាំផ្នែក ។ ក្នុងចំណោមផ្នែកទាំងនេះ ផ្នែកយុត្តិធម៌ឧក្រិដ្ឋកម្មគឺជាការពង្រីកតួនាទីនៃអគ្គមេធាវីឱ្យទៅជាអគ្គរដ្ឋអាជ្ញា ហើយក្នុងតួនាទីនេះ ផ្តល់យោបល់លើករណីព្រហ្មទណ្ឌ និងធ្វើបណ្តឹងអាជ្ញាលើបទល្មើសព្រហ្មទណ្ឌ ព្រមទាំងបំពេញមុខងាររបស់អគ្គមេធាវីក្នុងការត្រួតពិនិត្យ និងដឹកនាំការប្តឹងចោទរឿងព្រហ្មទណ្ឌ ដោយបញ្ជាទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅក្នុងការស៊ើបអង្កេតរបស់ទីភ្នាក់ងារទាំងនោះ ។

ដើម្បីធ្វើបណ្តឹងអាជ្ញា (ប្តឹងចោទរឿងព្រហ្មទណ្ឌ) មួយបាន ដោយអាស្រ័យលើការស៊ើបអង្កេត ដែលធ្វើឡើងដោយការិយាល័យទប់ស្កាត់និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ត្រូវមានការយល់ព្រមពីអគ្គរដ្ឋអាជ្ញា (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយផ្នែក ៣៣) ។ បន្ថែមលើនេះ អគ្គរដ្ឋអាជ្ញាអាចផ្តល់ដល់នាយក និងអ្នកស៊ើបអង្កេតពិសេសនៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ឬដល់មន្ត្រីប៉ូលីសដែលមានឋានន្តរសក្តិស្មើនឹងអនុស្នងការ ឬឋានៈខ្ពស់ជាងនេះ នូវអំណាចស៊ើបអង្កេតពិសេសរួមទាំងការស៊ើបអង្កេតធនាគារ និងគណនីគ្រប់ប្រភេទផ្សេងទៀត (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ផ្នែក ១៨/១) ក៏ដូចជាអនុញ្ញាតដោយមានលិខិតបញ្ជាឱ្យការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ប្រើអំណាចស៊ើបអង្កេតរបស់ប៉ូលីសនៅក្នុងករណីនៃបទល្មើសប្រភេទណាមួយ (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ផ្នែក ១៩) ។ អគ្គរដ្ឋអាជ្ញាមានអំណាចផងដែរក្នុងការចេញបញ្ជាឱ្យការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) ធ្វើអធិការកិច្ចលើសៀវភៅគណនីរបស់ម្ចាស់ធនាគារ (ឬសហព័ទ្ធ និងកូន ឬអ្នកផ្សេងទៀតដែលអាចជាភ្នាក់ងាររបស់គាត់) (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ផ្នែក ២០/១) ។ ផ្នែក ២១ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA នេះ ផ្តល់អំណាចថែមទៀតដល់អគ្គរដ្ឋអាជ្ញាក្នុងការស្នើសុំព័ត៌មានអំពីធនធាន និងទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និងគ្រួសារ និងអ្នកចូលរួមជាមួយសាមីជន រួមទាំងបញ្ជាអ្នកកាន់កាប់ប្រាក់ចំណូលពន្ធដារឱ្យផ្តល់ព័ត៌មានណាមួយ ដែលមាននៅក្រោមការកាន់កាប់របស់ខ្លួន ទាក់ទិននឹងជនល្មើស (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ផ្នែក ២១) ។

បទល្មើសតាមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ស្ថិតនៅក្រោមយុត្តាធិការតុលាការថ្នាក់ស្រុក ដែលនឹងកាត់ក្តី ហើយនិងកំណត់ទណ្ឌកម្ម ក្រោយពីបានរកឃើញថាមានកំហុស (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ផ្នែក ៣៤) ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA ចែងបន្ថែមថា នៅពេលកាត់ក្តី ឬសាកសួរដេញដោលដោយតុលាការ អំពីបទល្មើសណាមួយ តាមច្បាប់ស្តីពីការទប់ស្កាត់អំពើ

ពុករលួយ POCA ការដែលជនជាប់ចោទមិនបានរាយការណ៍ អំពីការមានបានធនធាន ឬភោគទ្រព្យ ត្រូវតែឃើញថាជាការផ្តល់ភស្តុតាងគ្រប់គ្រាន់ ដែលថាជនជាប់ចោទនេះបានធនធាន និងភោគទ្រព្យទាំងនោះតាមរយៈការប្រព្រឹត្តពុករលួយ (អនុផ្នែក ២៤/ ១)។ ពេលណាចុងចោទត្រូវបានតុលាការរកឃើញកំហុសថាបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដោយមានការស្នើសុំជាផ្លូវការពីអគ្គរដ្ឋអាជ្ញា ចៅក្រមត្រូវចេញដីការឹបអូសយកនូវអ្វីៗទាំងអស់ ដែលគេគិតថាបានមកតាមរយៈសកម្មភាពឧក្រិដ្ឋកម្ម (ច្បាប់ស្តីពីអំពើពុករលួយ ចរាចរគ្រឿងញៀន និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ CBA អនុផ្នែក ៥/១)។

## មេរៀនដែលទទួលបាន

ហេតុផលចម្បងមួយក្នុងចំណោមមូលហេតុទាំងឡាយ ស្តីពីជោគជ័យរបស់សិង្ហបូរីក្នុងការប្រយុទ្ធនឹងអំពើពុករលួយ គឺកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការបំបាត់ឱកាសប្រព្រឹត្តអំពើពុករលួយ តាមរយៈការផ្តោតជានិច្ចនិរន្តទៅលើការធ្វើឱ្យស្ថាប័នមានប្រសិទ្ធភាព ដោយកាត់បន្ថយនីតិវិធីរដ្ឋបាលដែលយឺតយ៉ាវនិងមិនស័ក្តិសិទ្ធ កាត់បន្ថយការិយាធិបតេយ្យ និងតាមរយៈការផ្តាំផ្ញើជាញឹកញាប់ទៅកាន់អ្នកម៉ៅការរបស់រដ្ឋាភិបាលដែលថា បើមានការសូកសំណូកនិងអំពើពុករលួយ កិច្ចសន្យានឹងត្រូវបញ្ចប់ ហើយនិងត្រូវផាកពិន័យ និងវិធានការដាក់ទណ្ឌកម្មផ្សេងទៀត (ដូចជា ហាមមិនឱ្យចុះកិច្ចកិច្ចសន្យាជាមួយស្ថាប័នសាធារណៈក្នុងរយៈពេលប្រាំឆ្នាំ)។

នៅសិង្ហបូរី ទាំងអ្នកសូក និងអ្នកទទួលសំណូក ត្រូវមានទោសពីបទប្រព្រឹត្តអំពើពុករលួយ និងត្រូវមានទោសដូចគ្នា។ ក្រៅពីការផាកពិន័យ និងជាប់ពន្ធនាគារ បុគ្គលដែលត្រូវបានតុលាការរកឃើញថាមានកំហុសពីបទល្មើសប្រព្រឹត្តអំពើពុករលួយ ត្រូវបានតុលាការបញ្ជាឱ្យសងសំណូកមកវិញក្នុងចំនួនពេញលេញ។ តុលាការមានអំណាចផងដែរ ក្នុងការបញ្ជាឱ្យរឹបអូសទ្រព្យដែលបានមកដោយជនល្មើសពុករលួយ។ លទ្ធភាពនាំឱ្យបាត់បង់ការងារ សោធននិវត្តន៍ និងប្រយោជន៍ផ្សេងៗទៀត ក៏បានបណ្តាលឱ្យវិធានការទាប់ស្កាត់នេះមានប្រសិទ្ធភាពផងដែរ។ ក៏ប៉ុន្តែ ទំនងជាវិធានការដែលគួរឱ្យញញើតបំផុតសម្រាប់ប្រឆាំងនឹងអំពើពុករលួយនៅក្នុងសង្គមសិង្ហបូរី គឺមតិសាធារណៈដែលពិនិត្យមើលយ៉ាងលម្អិត និងផ្តន្ទាទោសជនពុករលួយ និងដែលធ្វើឱ្យការប្រព្រឹត្តិអំពើពុករលួយ មិនអាចទទួលយកបានជាដាច់ខាត ហើយដែលថាស្លាកស្នាមទុិយសនៃអំពើពុករលួយមិនអាចលាងជម្រះសោះឡើយ ដោយគ្រាន់តែជាប់ពន្ធនាគារនោះ (ការដកស្រង់ប្រសាសន៍របស់នាយករដ្ឋមន្ត្រី Lee Kuan Yew នៅក្នុង Quah ១៩៩៩:៧៦)។

ជោគជ័យរបស់សិង្ហបូរីនៅក្នុងការប្រយុទ្ធនឹងអំពើពុករលួយ គឺដោយសារតែភាពទូលំទូលាយនៃគោលការណ៍ច្បាប់របស់ប្រទេសនេះ ដែលត្រូវបានពិនិត្យមើលឡើងវិញទៀងទាត់តាមពេលកំណត់ ដើម្បីធ្វើវិសោធនកម្មសមស្របតាមត្រូវការ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ POCA បានផ្តល់ឱ្យការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) នូវអំណាចចាំបាច់ដើម្បីស៊ើបអង្កេត ព្រមទាំងទប់ស្កាត់អំពើពុករលួយប្រកបដោយប្រសិទ្ធភាព ក៏ដូចជាផ្តន្ទាទោសដែលមានប្រសិទ្ធភាពធ្វើឱ្យមន្ត្រីមានការខ្លាចរអាមិនហ៊ានពាក់ព័ន្ធទៅក្នុងសកម្មភាពពុករលួយ។

ប្រាក់ខែខ្ពស់នៅក្នុងសេវាសាធារណៈ ជាធម្មតា ត្រូវគេគិតថាជាកត្តាចម្បងមួយដែលធ្វើឱ្យមានអំពើពុករលួយក្នុងកម្រិតទាបនៅសិង្ហបូរី។ ក៏ប៉ុន្តែ ថ្វីបើបច្ចុប្បន្ននេះ ប្រាក់ឈ្នួលនៅក្នុងផ្នែកសាធារណៈនៅសិង្ហបូរី ស្ថិតនៅក្នុងចំណោមប្រទេសដែលមានកម្រិតប្រាក់ឈ្នួលខ្ពស់បំផុតក្នុងពិភាពលោក ហើយប្រាកដជាបានរួមចំណែកដល់ការពង្រឹងប្រព័ន្ធសុចរិតភាពក៏ដោយ ក៏ប្រទេសនេះត្រូវចងចាំថា កម្រិតប្រាក់បៀវត្សខ្ពស់ទាំងនេះ គឺជាលទ្ធផលចម្បងចេញមកពីគោលនយោបាយប្រឆាំងនឹងអំពើពុករលួយមិនមែនគ្រាន់តែជាកត្តាដែលពន្យល់ពីជោគជ័យរបស់គោលនយោបាយទាំងនេះនោះទេ។ នៅក្នុងឆ្នាំ ១៩៥៩ នៅពេលចាប់ផ្តើមយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ផលទុនជាតិសរុបសម្រាប់មនុស្សម្នាក់ៗនៅសិង្ហបូរី មានចំនួនត្រឹមតែ US$ ៤៤៣ ប៉ុណ្ណោះ។ សាមសិបប្រាំបីឆ្នាំក្រោយមក តួលេខនេះបានកើនឡើងក្នុងមួយឆ្នាំ ១១% ជាចម្បងដោយសារតែកំណើន ប្រាក់ចំណូលជាតិ និងផលិតភាព ដែលជាលទ្ធផលលេចចេញមកពីយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ និងពីគោលនយោបាយអភិវឌ្ឍគោលដៅកំណើនឆាប់រហ័ស រួមទាំងការវិនិយោគកម្រិតខ្ពស់នៅក្នុងការអភិវឌ្ឍធនធានមនុស្ស។ នៅក្នុងឆ្នាំ ១៩៩៤ ប្រាក់ឈ្នួលនៅក្នុងផ្នែកសាធារណៈស្ថិតនៅក្នុងចំណោមប្រទេសដែលមានកម្រិត ប្រាក់ឈ្នួលខ្ពស់បំផុតក្នុងពិភពលោក ដែលក្បែរគ្នាទៅនឹងកម្រិត

ប្រាក់ឈ្នួលនៅក្នុងផ្នែកឯកជនដែរ។ ហេតុដូច្នេះ ថ្វីបើការកាត់បន្ថយអំពើពុករលួយនៅសិង្ហបុរី ជាញឹកញាប់មានពាក់ព័ន្ធជាមួយនឹងកម្រិតខ្ពស់នៃប្រាក់បៀវត្សមន្ត្រីរដ្ឋការក៏ដោយ តាមពិតរដ្ឋាភិបាលទើបតែអាចបង្កើនប្រាក់បៀវត្សជូនមន្ត្រីរដ្ឋការបាន នៅឆ្នាំ ១៩៧២ ទេ។ នៅក្នុងពេលជាមួយគ្នានេះ មានការផ្តោតជាចម្បងទៅលើការកាត់បន្ថយការលើកទឹកចិត្ត និងកាត់បន្ថយឱកាសប្រព្រឹត្តអំពើពុករលួយ តាមរយៈកំណែទម្រង់សេដ្ឋកិច្ច ការអប់រំ និងកំណែទម្រង់ច្បាប់ និងការពង្រឹងស្ថាប័ន ហើយនិងការផ្តន្ទាទោសនិងការផាកពិន័យយ៉ាងធ្ងន់ធ្ងរ។ មេរៀនសំខាន់ៗ ដែលទទួលបានពីបទពិសោធនៅ សិង្ហបុរី គឺថាទីមួយ ការកាត់បន្ថយអំពើពុករលួយមានភាពស្មុគស្មាញជាងការបង្កើនប្រាក់ឈ្នួលជូនមន្ត្រីរដ្ឋការតែឯកឯង និងទីពីរ សូម្បីតែប្រទេសកំពុងជឿនលឿន ដែលធនធានមានកម្រិតក៏ដោយ ក៏អាចប្រយុទ្ធនឹងអំពើពុករលួយបានដែរ ប្រសិនបើមានឆន្ទៈនយោបាយ និងការគាំទ្រជាសាធារណៈគ្រប់គ្រាន់។

បទពិសោធរបស់សិង្ហបុរីមានសារៈសំខាន់ជាពិសេសរបស់វា ដោយហេតុថា វាតំណាងឱ្យករណីនៃទីភ្នាក់ងារឯករាជ្យប្រឆាំងនឹងអំពើពុករលួយមួយ ដែលស្ថិតនៅក្រោមការត្រួតមើលផ្ទាល់របស់នាយករដ្ឋមន្ត្រី។ សារៈសំខាន់ដ៏ចាំបាច់សម្រាប់ជោគជ័យនៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) នេះគឺការបំបែកការិយាល័យ CPIB នេះ ឱ្យដាច់ដោយឡែកពីប៉ូលីស ដោយហេតុថា គេគិតថាពួកប៉ូលីសទាំងនេះហើយដែលពុករលួយបំផុត។ អ្នកខ្លះលើកហេតុផលមកសំអាងថា ថ្វីបើឯករាជភាពរបស់ការិយាល័យនេះ មានកម្រិត ដោយហេតុថាទីតាំងរបស់ការិយាល័យនេះស្ថិតនៅក្នុងបរិវេណការិយាល័យរបស់នាយករដ្ឋមន្ត្រី នៅក្នុងទីក្រុងដ៏តូចមួយក៏ដោយ ក៏គឺដោយសារតែសម្ព័ន្ធភាពទៅនឹងផ្នែកប្រតិបត្តិថ្នាក់កំពូលនេះហើយដែលអនុញ្ញាតឱ្យការិយាល័យនេះ អាចកេណ្ឌប្រមូលការគាំទ្រគ្រប់បែបយ៉ាង ដែលត្រូវការសម្រាប់សកម្មភាពរបស់ខ្លួនពីស្ថាប័នរដ្ឋផ្សេងៗទៀត។ អ្នកខ្លះទៀតលើកហេតុផលមកសំអាងថា ទន្ទឹមនឹងនេះ សម្ព័ន្ធភាពនេះតំណាងឱ្យភាពងាយរងគ្រោះនៃប្រព័ន្ធ ដោយហេតុថា ជាសារវន្ត វាសំអាងលើភាពសុចរិតទៀងត្រង់ និងវិជ្ជាជីវៈនិយមនៃការដឹកនាំនយោបាយរបស់ប្រទេសសិង្ហបុរី។ ដូចគ្នានេះដែរ កម្លាំងរបស់រដ្ឋាភិបាលត្រូវបានគេមើលឃើញថា ជួយរួមចំណែកឆ្ពោះទៅរកការត្រួតពិនិត្យអំពើពុករលួយយ៉ាងមានប្រសិទ្ធភាព ថ្វីបើកម្លាំងនេះ បានមកពីការកម្រិតសេរីភាពនយោបាយ និងការកម្រិតសិទ្ធិប្រើប្រាស់ព័ត៌មានក៏ដោយ (អង្គការតម្លាភាពអន្តរជាតិ ២០០៣: ១៤០)។

ម្យ៉ាងទៀត យើងគប្បីទទួលស្គាល់ថា ជោគជ័យនៃការិយាល័យទប់ស្កាត់ និងស៊ើបអង្កេតអំពើពុករលួយ (CPIB) គឺបានមកពីអភិបាលកិច្ចល្អរបស់ប្រទេស រួមទាំងទីភ្នាក់ងារអយ្យការ និងអង្គតុលាការដែលមានប្រសិទ្ធភាព (អង្គការតម្លាភាពអន្តរជាតិ ២០០៣:១៤៥)។

## ប្រភព


- Ali, Muhammed, *ការបំបាត់អំពើពុករលួយ* - បទពិសោធរបស់សិង្ហបុរី ឯកសារបង្ហាញជូននៅ ក្នុងសិក្ខាសាលាស្តីពីបទពិសោធជាអន្តរជាតិអំពីអភិបាលកិច្ចល្អ និងការប្រយុទ្ធនឹងអំពើពុករលួយ បាងកក ខែកុម្ភៈ ឆ្នាំ ២០០០។
- ភាពសុចរិតទៀងត្រង់នៅក្នុងអភិបាលកិច្ចនៅតំបន់អាស៊ី កម្មវិធីអភិបាលកិច្ចប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក របាយការណ៍សិក្ខាសាលាក្រុងបាងកក ខែកក្កដា ឆ្នាំ ១៩៩៨។
- Quah, Jon S.T - ការប្រៀបធៀបវិធានការប្រឆាំងនឹងអំពើពុករលួយក្នុងប្រទេសក្នុងតំបន់អាស៊ីៈ មេរៀនដែលទទួលបានទស្សនាវដ្តីអាស៊ីអំពីរដ្ឋបាលសាធារណៈ លេខ ២ (កក្កដា-ធ្នូ ឆ្នាំ ១៩៩៩)។
- Quah, Jon S.T, ២០០៣ ការទប់ស្កាត់អំពើពុករលួយនៅតំបន់អាស៊ី ការសិក្សាប្រៀបធៀបនៅក្នុងប្រទេសប្រាំមួយ។
- អង្គការតម្លាភាពអន្តរជាតិ ២០០៣ របាយការណ៍សកលអំពីអំពើពុករលួយ ឆ្នាំ ២០០៣។
  *http://www.globalcorruptionreport.org/gcr2003.html*


ព័ត៌មានបន្ថែមប្រមូលផងដែរពីប្រព័ន្ធ website របស់ស្ថាប័នផ្សេងៗដែលបានរៀបរាប់ខាងលើ។



# ប្រទេសអាហ្វ្រិកខាងត្បូង

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- នាយកដ្ឋានសេវាសាធារណៈ និងរដ្ឋបាល (DPSA) *www.dpsa.govza*
- នាយកដ្ឋានបណ្តឹងតវ៉ាផ្ទៃក្នុង (ICD) *www.icd.gov.za*
- អាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) ជាពិសេសគឺ អង្គភាពរឹបអូសទ្រព្យ និងនាយកដ្ឋានប្រតិបត្តិការពិសេស *www.npa.gov.za*
- ការិយាល័យអគ្គសវនករ *www.agsa.co.za*
- ការិយាល័យការពារសាធារណៈ *www.polity.org.za/html/govt/pobprot/index.html?rebookmark=1*
- គណៈកម្មការសេវាសាធារណៈ (PSC) *www.psc.gov.za*
- សេវាប៉ូលីសអាហ្វ្រិកខាងត្បូង (SAPS) ជាពិសេស សេវាស៊ើបអង្កេតផ្នែកសាខាពាណិជ្ជកម្ម *www.saps.gov.za*
- សេវាចំណូលពន្ធដារអាហ្វ្រិកខាងត្បូង (SARS) *www.sars.gov.za*
- អង្គភាពស៊ើបអង្កេតពិសេស (SIU) *www.siu.org.za*

## បទបញ្ញត្តិចម្បង

- រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋអាហ្វ្រិកខាងត្បូង (ឆ្នាំ ១៩៩៦)
- ច្បាប់ស្តីពីទីភ្នាក់ងារអយ្យការជាតិ លេខ ៣២ ឆ្នាំ ១៩៩៨
- ច្បាប់ស្តីពីការទប់ស្កាត់និងប្រយុទ្ធនឹងសកម្មភាពពុករលួយ លេខ ១២ ឆ្នាំ ២០០៤
- ច្បាប់ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មអង្គការចាត់តាំង លេខ ១២១ ឆ្នាំ ១៩៩៨
- ច្បាប់ស្តីពីការលើកស្ទួយសិទ្ធិប្រើប្រាស់ព័ត៌មាន លេខ ២ ឆ្នាំ ២០០០
- ច្បាប់ស្តីពីការលើកស្ទួយរដ្ឋបាលតុលាការ លេខ ៣ ឆ្នាំ ២០០០
- ច្បាប់ស្តីពីការការពារការប្រកាសផ្សាយ លេខ ២៦ ឆ្នាំ ២០០០ (ច្បាប់លេខ ២៦)
- ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខ ១ ឆ្នាំ ១៩៩៩
- ច្បាប់ស្តីពីអង្គភាពស៊ើបអង្កេតពិសេសនិងសាលាក្តីពិសេស លេខ ៧៤ ឆ្នាំ ១៩៩៦ (ច្បាប់លេខ ៧៤)។

## សារវ័តា

ចាប់តាំងពីចប់របបអាប៉ាថេតមក អាហ្វ្រិកខាងត្បូងបានចេញពីរបបនយោបាយជារដ្ឋប្រកាន់ពូជសាសន៍ជិះជាន់ ពុករលួយ តាមបែបបរិបាលកិច្ចនយោបាយ ឆ្ពោះទៅរករបបប្រជាធិបតេយ្យទំនើបអាស្រ័យរដ្ឋធម្មនុញ្ញ។ យ៉ាងណាក៏ដោយ ការបញ្ចប់រដ្ឋអាប៉ាថេត មិនមែនជាការចាប់ផ្តើមនៃរដ្ឋាភិបាលប្រឆាំងនឹងអំពើពុករលួយដោយផ្ទាល់នោះទេ។ ផ្ទុយទៅវិញ ប្រទេសនេះបានឱ្យសញ្ញាបង្ហាញពីដំណើរការនៃការកែទម្រង់រដ្ឋយ៉ាងជ្រាលជ្រៅទៅវិញទេ (Van Vuuren ២០០៤:២)។ ដូច្នេះ កិច្ចការដំបូងមិនមែនជាការតាក់តែងផែនការសម្រាប់ប្រយុទ្ធនឹងអំពើ

ពុករលួយនោះទេ ក៏ប៉ុន្តែ ជាការកសាងស្ថាប័ន ដែលតម្រូវឱ្យមានសម្រាប់បំពេញកាតព្វកិច្ចរបស់រដ្ឋ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ថែមលើនេះទៀត កិច្ចការនេះត្រូវធ្វើជាមួយសមាសភាពពីរបបមុន ដែលកាន់កាប់មុខងារសំខាន់ៗនៅក្នុងសេវាសាធារណៈ ក្នុងបរិបទនៃសន្តិសុខ ព្រមទាំងសេដ្ឋកិច្ច ជាបន្តទៅក្នុងសម័យអន្តរកាល ដែលបានចរចាគ្នា។ ដូច្នេះ ផែនការពីដើមទី មិនមែនសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយទេ។ ការបង្កើតគម្រោងប្រយុទ្ធនឹងអំពើពុករលួយបានក្លាយទៅជាអាទិភាពទីមួយនៅក្រោមការគ្រប់គ្រងរបស់ប្រធានាធិបតី ណែលសុន ម៉ែនដឺឡា (Nelson Mandela) (១៩៩៤-១៩៩៩)។ នេះជាមធ្យោបាយចាំបាច់សម្រាប់ការពារសុវត្ថិភាពលើសមិទ្ធផល ដែលសម្រេចបាននៅក្នុងឆ្នាំដំបូងក្រោយពីការដួលរលំនៃប្រព័ន្ធអាប៉ាថេត និងមានការរីកចម្រើនថែមទៀតនៅក្រោមការគ្រប់គ្រងក្នុងអាណត្តិទីមួយរបស់ប្រធានាធិបតី ថាប៊ូ អឹមបេកគី (Thabo Mbeki) (១៩៩៩-២០០៤)។

អ្វីជាបន្តបន្ទាប់មកទៀតគឺ រដ្ឋសភាដែលត្រូវបានបោះឆ្នោតជ្រើសរើសតាមលទ្ធិប្រជាធិបតេយ្យ បានអនុម័តច្បាប់មួយចំនួនទាក់ទិនទៅនឹងការប្រយុទ្ធនឹងអំពើពុករលួយ ក៏ដូចជាការបង្កើតទីភ្នាក់ងារផ្សេងៗមួយចំនួន ដែលមានអាណត្តិការងារប្រឆាំងនឹងអំពើពុករលួយ គឺជាអាណត្តិការងាររំលែកបន្ទុកគ្នា ដែលផ្ទុយពីអាណត្តិការងារប្រឆាំងនឹងអំពើពុករលួយនៃទីភ្នាក់ងារតែមួយ។ បន្ថែមលើនេះទៀត សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបានដើរតួនាទីផងដែរ ក្នុងការរក្សាសន្ទុះនៃកំណែទម្រង់។ ថ្វីបើច្បាប់បញ្ញត្តិស្តីពីអំពើពុករលួយ ជាទូទៅ ត្រូវគេគិតថាគ្រប់គ្រាន់ក៏ដោយ ក៏មានករណីដែលបង្ហាញថា ការអនុវត្តច្បាប់ទាំងនេះនៅមានភាពមិនគ្រប់គ្រាន់នៅឡើយ។ ប្រការនេះមួយផ្នែកក៏ដោយសារខ្វះធនធាន (អង្គការតម្លាភាពអន្តរជាតិ ២០០៤:២៥៩-២៦០)។ លើសពីនេះទៀត មានការត្រួតគ្នារវាងអាណត្តិការងារនៃទីភ្នាក់ងារផ្សេងៗ និងកង្វះកិច្ចសម្របសម្រួលរវាងទីភ្នាក់ងារទាំងនោះ ដែលមានភារកិច្ចប្រយុទ្ធនឹងអំពើពុករលួយ (ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម UNODC ២០០៣)។

ថ្វីត្បិតតែមានការពិភាក្សាស្តីអំពីថា តើត្រូវបង្កើតទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយតែមួយឬយ៉ាងណា ក៏រដ្ឋាភិបាលបានសម្រេចរក្សាទុកនូវរចនាសម្ព័ន្ធស្ថាប័នដែលមានអាណត្តិការងាររំលែកបន្ទុកគ្នាសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយនេះដដែល ដោយជ្រើសយកការធ្វើឱ្យប្រសើរឡើងថែមទៀត ចំពោះទីភ្នាក់ងារដែលមានស្រាប់ ដូចដែលគេបានដាក់ស្នើឡើងនៅក្នុងយុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយឆ្នាំ ២០០២។ ស្របតាមអនុសាសន៍ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រនេះ គណៈកម្មាធិការសម្របសម្រួលប្រឆាំងនឹងអំពើពុករលួយមួយត្រូវបានបង្កើតឡើងសម្រាប់សម្របសម្រួលការងាររបស់ទីភ្នាក់ងារផ្សេងៗ (ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម UNODC ២០០៣)។ ការអនុម័តយុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ គឺជាការអភិវឌ្ឍជាវិជ្ជមានដោយផ្ទាល់ ដោយផ្តល់ឱ្យមានគម្រោងទូលំទូលាយក្នុងការទប់ស្កាត់ និងប្រយុទ្ធនឹងអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ (គឺក្រសួងមន្ទីនានារបស់រដ្ឋាភិបាល)។ ការអភិវឌ្ឍដែលជាកម្លាំងជំរុញបន្ថែមមួយទៀត គឺការដាក់ច្បាប់ស្តីពីការទប់ស្កាត់និងការប្រយុទ្ធនឹងសកម្មភាពពុករលួយ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៤ ជាជំនួសច្បាប់ស្តីពីអំពើពុករលួយឆ្នាំ ១៩៩២ ដែលជាទូទៅ ត្រូវបានមើលឃើញថាមានភាពមិនគ្រប់គ្រាន់។ ច្បាប់ថ្មីមានចែងអត្ថន័យច្បាស់លាស់ពីអំពើពុករលួយ ព្រមទាំងទទួលស្គាល់ទាំងផ្នែកសូកនិងផ្នែកទទួលសំណូក ថាជាបទល្មើស ពោលគឺចាត់ជាបទល្មើសព្រហ្មទណ្ឌទាំងការប៉ុនប៉ងសូក ឬការប៉ុនប៉ងពុករលួយ។

ប្រទេសអាហ្វ្រិកខាងត្បូងត្រូវបានចាត់ថ្នាក់ជាប្រទេសទី ៤៦ ក្នុងចំណោមប្រទេសទាំង ១៥៩ នៅក្នុងតារាងសន្ទស្សន៍ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិ ស្តីពីទស្សនៈអំពីអំពើពុករលួយ។ ប៉ុន្តែ ថ្វីបើអំពើពុករលួយមានកម្រិតទាបក៏ដោយ បើប្រៀបធៀបជាមួយនឹងប្រទេសជិតខាង ក៏របាយការណ៍ប្រទេសស្តីពីការប៉ាន់ប្រមាណអំពើពុករលួយ ដែលធ្វើឡើងដោយការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) រួមគ្នាជាមួយនឹងរដ្ឋាភិបាលអាហ្វ្រិកខាងត្បូង បង្ហាញឱ្យឃើញថា ទស្សនៈអំពីអំពើពុករលួយមានកម្រិតខ្ពស់ ថ្វីបើគេរាយការណ៍ថា អ្នកដែលប្រឈមមុខនឹងអំពើពុករលួយជាក់ស្តែងមានចំនួនតិចជាងក៏ដោយ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

នៅអាហ្វ្រិកខាងត្បូងមិនមានទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយតែមួយទេ។ ផ្ទុយទៅវិញ ភារកិច្ចប្រឆាំងនឹងអំពើពុករលួយត្រូវបាន

រំលែកបន្ទុកទៅឱ្យស្ថាប័នផ្សេងៗមួយចំនួន។ ការស៊ើបអង្កេត និងការដាក់បណ្តឹងអាជ្ញា (គឺប្តឹងចោទតាមនីតិវិធីតុលាការ) ពីអំពើពុករលួយស្ថិតនៅលើ**អាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) អង្គភាពស៊ើបអង្កេតពិសេស (SIU)** និង**សេវាប៉ូលីសអាហ្វ្រិកខាងត្បូង (SAPS)**។ ស្ថាប័ននានា ដូចជាការិយាល័យអគ្គសវនករ ការិយាល័យអ្នកការពារសាធារណៈ សេវាចំណូលពន្ធដារអាហ្វ្រិកខាងត្បូង និងគណៈកម្មការសេវាសាធារណៈ តាមមុខងារស្នូលរបស់ខ្លួន ត្រូវពង្រឹងសេចក្តីសុចរិតទៀងត្រង់របស់និយោជិត ការគ្រប់គ្រងហិរញ្ញវត្ថុ និងគុណភាពរដ្ឋបាលនៅក្នុងសេវាសាធារណៈ ដែលទាំងអស់នេះគឺជាកិច្ចការស្នូលក្នុងការទប់ស្កាត់និងការរំកែមុខអំពើពុករលួយ។

**អាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA)** ដែលដឹកនាំដោយនាយកជាតិនៃមហាអយ្យការ (គឺអគ្គរដ្ឋអាជ្ញា) (NDPD) និងតែងតាំងដោយប្រធានាធិបតី ត្រូវបានបង្កើតឡើងតាមបញ្ញត្តិមាត្រា ១៧៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងថា អាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) ត្រូវបំពេញមុខងាររបស់ខ្លួនដោយគ្មានការភ័យខ្លាច គ្មានការយោគយល់ ឬការរើសអើងណាមួយឡើយ។ នាយកជាតិនៃមហាអយ្យការ (NDPD) រាយការណ៍ជូនសភា និងត្រូវទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ មុខងារ និងភារកិច្ចនៃអាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីអាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) មានដូចតទៅនេះ

- ផ្តួចផ្តើម និងដឹកនាំដំណើរការរឿងក្តីព្រហ្មទណ្ឌ ក្នុងនាមរដ្ឋ
- បំពេញមុខងារចាំបាច់ណាមួយ ដែលត្រូវផ្តួចផ្តើមនិងដឹកនាំដំណើរការរឿងក្តីព្រហ្មទណ្ឌបែបហ្នឹង ហើយនិង
- បញ្ឈប់ដំណើរការក្តីព្រហ្មទណ្ឌ។

ក្នុងភារកិច្ចបែបនេះ អាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) គឺជាស្ថាប័នដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងកិច្ចប្រឹងប្រែងរបស់រដ្ឋ ក្នុងការប្រយុទ្ធនឹងអំពើពុករលួយ និងឧក្រិដ្ឋកម្មអង្គការចាត់តាំងនៅអាហ្វ្រិកខាងត្បូង។

អង្គភាពពីរនៃអាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) ដែលដើរតួនាទីផ្ទាល់បំផុតក្នុងការប្រយុទ្ធនឹងអំពើពុករលួយ គឺ**នាយកដ្ឋាន ប្រតិបត្តិការពិសេស (DSO)** ដែលគេហៅផងដែរថាខ្យាដំរី និង**អង្គភាពរឹបអូសទ្រព្យ (AFU)**។

គោលដៅចម្បងមួយនៃអាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) គឺត្រូវអនុវត្តបញ្ញត្តិស្តីពីការរឹបអូសទ្រព្យ ដែលមានចែងនៅជំពូក ៥ និងជំពូក ៦ នៃច្បាប់ស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្មអង្គការចាត់តាំង។ អង្គភាពរឹបអូសទ្រព្យ (AFU) ត្រូវបានបង្កើតឡើងសម្រាប់បំពេញគោលដៅនេះ។ ថ្វីបើអង្គភាពរឹបអូសទ្រព្យនេះ មិនមានភារកិច្ចដោយផ្ទាល់ក្នុងការប្រយុទ្ធនឹងអំពើពុករលួយក៏ដោយ ក៏ការងាររបស់អង្គភាពនេះមានសារៈសំខាន់ជាមូលដ្ឋានដែរ ចំពោះការទប់ស្កាត់តាមរយៈការទារយកប្រយោជន៍មកវិញ និងទ្រព្យដែលបានមក ដែលជាលទ្ធផលនៃការពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋកម្ម រួមទាំងអំពើពុករលួយផង។

**នាយកដ្ឋានប្រតិបត្តិការពិសេស (DSO)** ត្រូវបានដាក់ឱ្យដំណើរការក្នុងឆ្នាំ ១៩៩៩ ក្នុងលក្ខណៈជាផ្នែកមួយនៃការបង្កើនសមត្ថភាពរដ្ឋសម្រាប់ស៊ើបអង្កេតនិងដាក់បណ្តឹងអាជ្ញា ដោយមានប្រសិទ្ធភាពចំពោះឧក្រិដ្ឋកម្មដែលជាអាទិភាពជាតិ។ ក្នុងភារកិច្ចបែបនេះ នាយកដ្ឋានប្រតិបត្តិការពិសេស (DSO) គឺជាទីភ្នាក់ងារពហុផ្នែក ជាពិសេស មានអំណាចចាត់ការទល់នឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយមានអង្គការចាត់តាំង។ អំណាចនេះ រួមមាន ការស៊ើបអង្កេត និងការដាក់បណ្តឹងអាជ្ញាប្រឆាំងនឹងឧក្រិដ្ឋកម្មអង្គការចាត់តាំង និងអំពើពុករលួយ។

ជាចម្បង នាយកដ្ឋានប្រតិបត្តិការពិសេស (DSO) ផ្តោតទៅលើករណីអំពើពុករលួយថ្នាក់ខ្ពស់។ នាយកដ្ឋានប្រតិបត្តិការពិសេស (DSO) បានអនុម័តយកវិធីសាស្ត្រអនុវត្តន៍ច្បាប់ប្លែកគេមួយ ដែលរួមផ្សំការវិភាគឧក្រិដ្ឋកម្ម ការស៊ើបអង្កេត និងការដាក់បណ្តឹងអាជ្ញា តាមរបៀបបញ្ច្រាបចូលគ្នាដោយប្រើបច្ចេកវិទ្យាថ្មី។

**អង្គភាពស៊ើបអង្កេតពិសេស (SIU)** ត្រូវបានបង្កើតឡើងតាមច្បាប់លេខ ៧៤ និងត្រូវទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសភា។ អង្គភាពស៊ើបអង្កេតពិសេស (SIU) គឺជាស្ថាប័នពាក់កណ្តាលឯករាជ្យ ដែលមានចែងនៅក្នុងច្បាប់ ដោយត្រូវទទួលភារកិច្ចស៊ើបអង្កេតលើការលួចបន្លំ អំពើពុករលួយ និងការគ្រប់គ្រងមិនត្រឹមត្រូវលើទ្រព្យសម្បត្តិរដ្ឋ និងប្រាក់កាសសាធារណៈ។ ក្នុងស្ថានភាពបែបនេះ អង្គភាពស៊ើបអង្កេតពិសេស (SIU) គឺជាទីភ្នាក់ងារតែមួយគត់ដែលមានអាណត្តិការងារដាច់មុខ ក្នុងការប្រយុទ្ធនឹងអំពើពុករលួយ។ ក្រោយការស៊ើបអង្កេត ប្រសិនបើមានភស្តុតាងពីការលួចបន្លំ អំពើពុករលួយ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដោយមិនត្រឹមត្រូវ អង្គភាពស៊ើបអង្កេតពិសេស (SIU) មានអំណាចចាត់វិធានការបណ្តឹងរដ្ឋប្បវេណីនៅសាលាក្តីពិសេស ដើម្បីទាមទារយកមកវិញនូវទ្រព្យសម្បត្តិរដ្ឋ និងប្រាក់កាសសាធារណៈដែលត្រូវបានចំណាយ ឬប្រើប្រាស់ដោយមិនត្រឹមត្រូវ។ អង្គភាពស៊ើបអង្កេតពិសេសនេះ ផ្តោតលើករណីរដ្ឋប្បវេណី និងការទាមទារយកមកវិញ។ អង្គភាពស៊ើបអង្កេតពិសេស (SIU) មិនមានអំណាចចាត់វិធានការរឿងព្រហ្មទណ្ឌណាមួយទេ។ អង្គភាពស៊ើបអង្កេតពិសេស (SIU) ធ្វើការដោយមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិអយ្យការអាហ្វ្រិកខាងត្បូង (NPA) នាយកដ្ឋានប្រតិបត្តិការពិសេស (DSO) អង្គភាពរឹបអូសទ្រព្យ (AFU) និងសេវាប៉ូលីសអាហ្វ្រិកខាងត្បូង (SAPS)។ ពេលណាដែលអង្គភាពស៊ើបអង្កេតពិសេស (SIU) បានប្រទះឃើញសកម្មភាពឧក្រិដ្ឋ ឬរកឃើញឧក្រិដ្ឋកម្ម ដែលគេរាយការណ៍ព័ត៌មាននៃការរកឃើញនេះត្រូវបញ្ជូនទៅស្ថាប័នស៊ើបអង្កេតឧក្រិដ្ឋកម្មពាក់ព័ន្ធ ដើម្បីបន្តរឿងក្តីអំពើបទពុករលួយ ទាំងផ្នែករដ្ឋប្បវេណី ទាំងផ្នែកព្រហ្មទណ្ឌ។

នៅក្នុង**ស្ថាប័នសេវាប៉ូលីសអាហ្វ្រិកខាងត្បូង (SAPS)** គឺសាខាពាណិជ្ជកម្មនៃផ្នែកសេវាស៊ើបអង្កេត ដែលមានការទទួលខុសត្រូវចម្បងទាក់ទិននឹងអំពើពុករលួយ។ រឿងនេះបណ្តាលឱ្យមានការបញ្ចូលអង្គភាពប្រឆាំងនឹងអំពើពុករលួយនៃសេវាប៉ូលីសអាហ្វ្រិកខាងត្បូង (SAPS) ទៅក្នុងផ្នែកសេវាស៊ើបអង្កេត។

**នាយកដ្ឋានបណ្តឹងតវ៉ាផ្ទៃក្នុង (ICD)** ដែលត្រូវបានបង្កើតឡើងដោយបញ្ញត្តិនៃជំពូក ១០ ផ្នែក ៥០/១ នៃច្បាប់ស្តីពីសេវាប៉ូលីសអាហ្វ្រិកខាងត្បូង លេខ ៦៨/១៩៩៥ (ច្បាប់លេខ ៦៨) មានអំណាចស៊ើបអង្កេតលើការប្រព្រឹត្តិមិនត្រឹមត្រូវ ដែលប្រព្រឹត្តដោយសមាជិកសេវាប៉ូលីសអាហ្វ្រិកខាងត្បូង និងសមាជិកសេវាប៉ូលីសក្រុង (ផ្នែក ៥៣.២/ច្បាប់លេខ ៦៨) ក្នុងគោលបំណងលើកស្ទួយការប្រព្រឹត្តិល្អត្រឹមត្រូវរបស់ប៉ូលីស។ ភារកិច្ចនេះរួមបញ្ចូលផងដែរ ទាំងការស៊ើបអង្កេតលើបទចោទប្រកាន់ទៅលើសមាជិកសេវាប៉ូលីសអាហ្វ្រិកខាងត្បូង ដែលពាក់ព័ន្ធនៅក្នុងអំពើពុករលួយក្នុងទម្រង់ណាមួយ។ នាយកដ្ឋានបណ្តឹងតវ៉ាផ្ទៃក្នុង (ICD) គឺជានាយកដ្ឋានរបស់រដ្ឋាភិបាល ដែលដឹកនាំដោយនាយកប្រតិបត្តិម្នាក់ ដែលត្រូវបានស្នើឈ្មោះដោយរដ្ឋមន្ត្រី និងតែងតាំងដោយគណៈកម្មាធិការសភា ដែលប្រតិបត្តិការដោយឯករាជ្យពីសេវាប៉ូលីសអាហ្វ្រិកខាងត្បូង (ផ្នែក ៥១/ច្បាប់លេខ ៦៨)។

តាមគុណតម្លៃនៃជំពូក ៩ នៃរដ្ឋធម្មនុញ្ញ ដែលចែងអំពី**ស្ថាប័នរដ្ឋគាំទ្រលទ្ធិប្រជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ** ស្ថាប័នរដ្ឋឯករាជ្យមួយចំនួនត្រូវបានបង្កើតឡើង។ ក្នុងចំណោមនេះមានការិយាល័យអគ្គសវនករ និងការិយាល័យអគ្គរដ្ឋអាជ្ញា មានទំនាក់ទំនងពិសេសជាមួយនឹងប្រព័ន្ធសុចរិតភាពជាតិ។ ស្ថាប័នទាំងនេះត្រូវបានការពារទល់នឹងអន្តរាគមន៍ពីខាងក្រៅ និងត្រូវទទួលខុសត្រូវចំពោះរដ្ឋសភា ដែលស្ថាប័នទាំងនេះត្រូវបានតម្រូវឱ្យរាយការណ៍អំពីសកម្មភាព និងការបំពេញមុខងាររបស់ខ្លួនជាទៀងរាល់ឆ្នាំ (ផ្នែក ១៨១ នៃរដ្ឋធម្មនុញ្ញ)។

អគ្គសវនករ ដែលដឹកនាំ**ការិយាល័យអគ្គសវនករ** ដូចដែលមានចែងនៅក្នុងផ្នែក ១៨៨ នៃរដ្ឋធម្មនុញ្ញ ត្រូវធ្វើសវនកម្ម និងរាយការណ៍អំពីគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងការចាត់ចែងហិរញ្ញវត្ថុរបស់ស្ថាប័នខាងក្រោមនេះ:

- គ្រប់នាយកដ្ឋាននិងរដ្ឋបាល ថ្នាក់ជាតិនិងថ្នាក់ខេត្ត
- គ្រប់សាលាក្រុងទាំងអស់ និង
- ស្ថាប័ន ឬអង្គភាពគណនេយ្យណាមួយផ្សេងទៀតតាមតម្រូវការ។

ដូច្នេះ អគ្គសវនករមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យឧក្រិដ្ឋកម្មសេដ្ឋកិច្ចនៅអាហ្វ្រិកខាងត្បូង រួមទាំង រួមចំណែកក្នុងការទប់ស្កាត់អំពើពុករលួយផងដែរ ។

មុខងារនៃ**ការិយាល័យអគ្គរដ្ឋអាជ្ញា** ដែលដឹកនាំដោយអគ្គរដ្ឋអាជ្ញា មានចែងនៅក្នុងផ្នែក ១៨២ នៃរដ្ឋធម្មនុញ្ញ។ ដូចដែលមានចែងនៅក្នុងបទបញ្ញាជាតិ អគ្គរដ្ឋអាជ្ញាមានអំណាចដូចតទៅនេះ:

- ស៊ើបអង្កេតអំពីការបំពេញការងាររដ្ឋ ឬនៅក្នុងរបាលសាធារណៈនៅក្នុងវិស័យណាមួយនៃរដ្ឋាភិបាល ដែលត្រូវបានចោទ ឬមានការសង្ស័យថាមិនត្រឹមត្រូវ ឬដែលបង្កឱ្យមានភាពខុសឆ្គង ឬការខូចប្រយោជន៍ ។
- រាយការណ៍អំពីការបំពេញការងារនោះ និង
- ចាត់វិធានការកែលម្អសមស្រប ។

បន្ថែមទៅនឹងស្ថាប័នចម្បង៧ដែលបានរៀបរាប់ខាងលើមានទីភ្នាក់ងារបន្ថែមមួយចំនួនទៀត ដែលដើរតួនាទីនៅក្នុងការទប់ស្កាត់អំពើពុករលួយ ដូចជាគណៈកម្មការសេវាសាធារណៈ និងសេវាចំណូលពន្ធដារ អាហ្វ្រិកខាងត្បូង ក៏ដូចជាវេទិកាជាតិប្រឆាំងនឹងអំពើពុករលួយដែលជាស្ថាប័នមួយដែលមានអ្នកតំណាងពីផ្នែករដ្ឋាភិបាល ឯកជន និងសង្គមស៊ីវិល ។

## ការរៀបចំកិច្ចប្រតិបត្តិការ

ដោយសារតែមិនមានទីភ្នាក់ងារតែមួយប្រឆាំងនឹងអំពើពុករលួយ គណៈកម្មាធិការសម្របសម្រួលប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតឡើងតាមអនុសាសន៍ ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ ។ គណៈកម្មាធិការនេះ រួមមាន នាយកដ្ឋានជាតិ និងនាយកដ្ឋានខេត្ត ព្រមទាំងទីភ្នាក់ងារ និងស្ថាប័នជាតិផ្សេងទៀត ដែលមានមុខងារប្រឆាំងនឹងអំពើពុករលួយ ។ គណៈកម្មាធិការ មានភារកិច្ចធ្វើការសម្របសម្រួល និងធ្វើសមាហរណកម្មការងារប្រឆាំងនឹងអំពើពុករលួយ ។

នៅក្នុង**នាយកដ្ឋានសេវាសាធារណៈ និងរដ្ឋបាល** អង្គភាពសេវាសាធារណៈប្រឆាំងអំពើពុករលួយ មានតួនាទីសម្របសម្រួលផងដែរ និងត្រូវទទួលខុសត្រូវលើ:

- ការអភិវឌ្ឍនិងការអនុវត្តយុទ្ធសាស្ត្រស្តីពីសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ
- កិច្ចសម្របសម្រួល និងការធ្វើសមាហរណកម្មការងារប្រឆាំងនឹងអំពើពុករលួយរបស់រដ្ឋាភិបាលនៅកម្រិតគោលនយោបាយ និងកម្រិតយុទ្ធសាស្ត្រ
- គាំទ្រកម្មវិធីជាតិប្រឆាំងនឹងអំពើពុករលួយ
- គោលនយោបាយនិងសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិប្រឆាំងនឹងអំពើពុករលួយ
- ប្រមែប្រមូលនិងវិភាគព័ត៌មានអំពីអំពើពុករលួយ និងការប្រឆាំងនឹងអំពើពុករលួយ និង
- គាំទ្ររដ្ឋមន្ត្រីក្រសួងសេវាសាធារណៈ និងរដ្ឋបាលចំពោះការទទួលខុសត្រូវក្នុងការប្រយុទ្ធនឹងអំពើ ពុករលួយ ។

អង្គភាពសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ (PSAC) ផ្តល់ផងដែរ នូវសេវាផ្តល់យោបល់ និងសេវាគាំទ្រ ដល់ផ្នែកសាធារណៈស្តីពីការអនុវត្តគោលនយោបាយ និងនីតិកម្មប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងកោះប្រជុំគណៈកម្មាធិការសម្របសម្រួលប្រឆាំងនឹងអំពើពុករលួយ ។ យ៉ាងណាក៏ដោយ អង្គភាពសេវាសាធារណៈប្រឆាំងអំពើពុករលួយ មិនធ្វើការស៊ើបអង្កេតអំពើពុករលួយដោយខ្លួនឯងនោះទេ ។

យុទ្ធសាស្ត្រនៃសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ គឺជាគម្រោងដែលជាការផ្តើមគំនិតទូលំទូលាយសម្រាប់ប្រយុទ្ធ និងទប់ស្កាត់អំពើពុករលួយនៅក្នុងសេវាសាធារណៈ ដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ ២០០២ ផ្តល់ការណែនាំនៅក្នុងកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធអំពើពុករលួយ។ យុទ្ធសាស្ត្រស្នើថា ត្រូវតែបង្កើតឱ្យមានលំនាំដោះស្រាយតាមបែបប្រទាក់ក្រឡា និងរួមបញ្ចូលគ្នា សម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ ដែលតម្រូវឱ្យមានការរួមផ្សំយុទ្ធសាស្ត្រទប់ស្កាត់និងយុទ្ធសាស្ត្រប្រយុទ្ធ និងការពង្រឹងសមត្ថភាពស្ថាប័ន និងនីតិកម្មរបស់រដ្ឋាភិបាល[១]។ យុទ្ធសាស្ត្រនេះបង្កើតឱ្យមានការពិចារណាចំនួនប្រាំបួនចំណុចដូចតទៅនេះ:

- ការពិនិត្យមើលឡើងវិញនិងការពង្រឹងគោលការណ៍នីតិកម្ម
- បង្កើនសមត្ថភាពស្ថាប័នក្នុងការដោះស្រាយបញ្ហាអំពើពុករលួយ
- ធ្វើឱ្យប្រសើរឡើងដល់សិទ្ធិរាយការណ៍អំពីអំពើខុសឆ្គង និងការពារអ្នកបង្ហើបប្រាប់ពីអំពើពុករលួយ និងការពារសាក្សី
- ការហាមប្រាមមិនឱ្យមានបុគ្គលពុករលួយ និងអាជីវកម្មពុករលួយ
- ធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយគ្រប់គ្រង និងអនុវត្តការគ្រប់គ្រង
- ការគ្រប់គ្រងក្រមសីលធម៌វិជ្ជាជីវៈ
- បង្កើតភាពជាដៃគូជាមួយនឹងអ្នកពាក់ព័ន្ធផ្សេងទៀត
- វិភាគផ្នែកសង្គម ស្រាវជ្រាវ និងតស៊ូមតិស្តីពីគោលនយោបាយ និង
- លើកកម្ពស់ការយល់ដឹង ការហ្វឹកហ្វឺន និងការអប់រំ ដើម្បីគាំទ្រការអភិវឌ្ឍខាងលើ និងចាប់ធ្វើយុទ្ធនាការទំនាក់ទំនងសាធារណៈ។

ថ្វីបើជំពូក ២ នៃច្បាប់ដែលទើបនឹងអនុម័តថ្មី ស្តីពីការទប់ស្កាត់និងប្រយុទ្ធនឹងសកម្មភាពពុករលួយ (PCCAA) មានចែងពីបទល្មើសផ្សេងៗទាក់ទិននឹងសកម្មភាពពុករលួយក៏ដោយ ក៏ឧបករណ៍បន្ថែមមួយសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ មានចែងនៅក្នុងជំពូក ៣ ដែលចែងថា កម្មវិធីអភិវឌ្ឍន៍ជាតិនិងលទ្ធិប្រជាធិបតេយ្យ (NDDP) អាចស្នើសុំទៅចៅក្រមនៅក្នុងអង្គជំនុំជម្រះ ឱ្យស៊ើបអង្កេតបុគ្គលដែលមានទ្រព្យសម្បត្តិមិនសមាមាត្រទៅនឹងប្រភពចំណូល ឬទ្រព្យសម្បត្តិរបស់ខ្លួនបច្ចុប្បន្នដែលគេបានដឹងឮ។ បន្ថែមលើនេះ ផ្នែក ៣៤ នៃច្បាប់ស្តីពីការទប់ស្កាត់ និងប្រយុទ្ធនឹងសកម្មភាពពុករលួយ (PCCAA) តម្រូវថាជានណាម្នាក់ដែលកាន់កាប់តំណែងក្នុងអំណាច ហើយបានដឹង ឬមានហេតុផលនឹងដឹង និងសង្ស័យថា ជនណាម្នាក់ផ្សេងទៀតបានប្រព្រឹត្តបទល្មើសទាក់ទិននឹងអំពើពុករលួយ ដែលមានចំនួនទឹកប្រាក់ ១០០.000 Rand ឬតិចជាង US$ ២០.000) ត្រូវរាយការណ៍អំពីការដឹង ឬការសង្ស័យនោះ ឬធ្វើឱ្យការដឹង ឬការសង្ស័យនោះ ត្រូវបានរាយការណ៍ទៅកាន់មន្ត្រីប៉ូលីសណាម្នាក់។ ជនណាម្នាក់ដែយបានរាយការណ៍ពីសកម្មភាពដែលជាប់សង្ស័យថាជាអំពើពុករលួយ ត្រូវបានការពារតាមច្បាប់លេខ ២៦ ដែលចែងពីការការពារចំពោះអ្នកបង្ហើបប្រាប់ពីអំពើពុករលួយ តាមរយៈដំណើរការបង្ហាញនូវប្រព្រឹត្តកម្មពុករលួយ ឬការបំពានមុខតំណែងផ្សេងទៀតនៅក្នុងផ្នែកសាធារណៈ និងឯកជន។

នៅក្នុងកិច្ចប្រឹងប្រែងទប់ស្កាត់និងប្រយុទ្ធនឹងអំពើពុករលួយ រដ្ឋាភិបាលបានកំណត់ផងដែរថា គ្រប់នាយកដ្ឋាន និងស្ថាប័នទាំងអស់នៃសេវាសាធារណៈ ត្រូវបង្កើតឱ្យមានសមត្ថភាពអប្បបរមាសម្រាប់បំពេញមុខងារដូចតទៅនេះ:

- ធ្វើការប៉ាន់ប្រមាណអំពីហានិភ័យ
- អនុវត្តផែនការទប់ស្កាត់ការលួចបន្លំ យ៉ាងហោចណាស់ត្រូវមានគោលនយោបាយប្រឆាំងនឹងអំពើពុករលួយ និងផែនការអនុវត្តន៍ដោយអនុលោមតាមបញ្ញត្តិច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ស៊ើបអង្កេតបឋមលើការចោទប្រកាន់ពីអំពើពុករលួយ និងលើហានិភ័យដែលរកឃើញ
- ផ្តល់លទ្ធភាពដល់ដំណើរការនៃការស៊ើបអង្កេតថែមទៀត ការរើកមុខ និងការធ្វើបណ្តឹងអាជ្ញា ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន
- ទទួល និងដោះស្រាយការចោទប្រកាន់អំពីអំពើពុករលួយ តាមរយៈយន្តការនៃការបង្ហើបប្រាប់ឬយន្តការផ្សេងទៀត និង
- លើកស្ទួយក្រមសីលធម៌វិជ្ជាជីវៈក្នុងចំណោមនិយោជិត។

[១] ចូរមើលនាយកដ្ឋានសេវាសាធារណៈនិងរដ្ឋបាល យុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ Pretonia ខែមករា ឆ្នាំ ២០០២។

## មេរៀនដែលទទួលបាន

ភាពខ្លាំងមួយនៃប្រព័ន្ធសុចរិតភាពជាតិអាហ្វ្រិកខាងត្បូង គឺការដាក់ឱ្យប្រើនូវគោលការណ៍ច្បាប់ទូលំទូលាយពាក់ព័ន្ធនឹងការប្រឆាំងអំពើពុករលួយ។ គោលការណ៍ច្បាប់នេះ រួមមាន ច្បាប់ស្តីពីការលើកស្ទួយរដ្ឋបាលតុលាការ និងច្បាប់ស្តីពីការលើកស្ទួយសិទ្ធិប្រើប្រាស់ព័ត៌មាន ដែលផ្តល់អំណាចឱ្យសាធារណជនទូទៅអាចសុំឱ្យផ្នែកសាធារណៈ គឺក្រសួង មន្ទីក្នុងរដ្ឋាភិបាល ផ្តល់ព័ត៌មានដល់ពួកខ្លួន និងអាចសួរដេញដោលឬជំទាស់ទៅនឹងសេចក្តីសម្រេចរបស់រដ្ឋបាល។ នៅក្នុងរបាយការណ៍របស់ប្រទេសស្តីពីការប៉ាន់ប្រមាណអំពីអំពើពុករលួយ មានលើកឡើងថា ច្បាប់ទាំងនេះបានបង្កើនតម្លាភាពយ៉ាងធំធេង និងជួយឱ្យមានរដ្ឋាភិបាលស្អាតស្អំ។ កាអនុម័តច្បាប់ស្តីពីការទប់ស្កាត់និងប្រយុទ្ធនឹងសកម្មភាពពុករលួយគួរតែនាំទៅរកការបង្កលក្ខណៈងាយស្រួលដ៏មានប្រសិទ្ធភាពផងដែរក្នុងការប្រយុទ្ធនឹងអំពើពុករលួយ។ បន្ថែមលើនេះច្បាប់លេខ ២៦ បានផ្តល់ការការពារដល់អ្នកបង្ហើបឱ្យដឹងពីអំពើពុករលួយ និងសាក្សីនៅក្នុងករណីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងការគាំទ្រភារកិច្ចរបស់បុគ្គលក្នុងការរាយការណ៍ពីអំពើពុករលួយ ដូចដែលមានចែងបញ្ជាក់នៅក្នុងច្បាប់ស្តីពីការទប់ស្កាត់ និងប្រយុទ្ធនឹងសកម្មភាពពុករលួយ។ យ៉ាងណាក៏ដោយ កង្វល់បានកើនឡើងដោយសារតែរដ្ឋខ្វះសមត្ថភាពក្នុងការផ្តល់ឱ្យនូវការការពារជាក់ស្តែងដោយសារនាយកដ្ឋាន និងស្ថាប័នភាគច្រើនមិនបានផ្តល់ឱ្យមានគោលនយោបាយនិងនីតិវិធី ដែលចាំបាច់សម្រាប់ប្រតិបត្តិតាមច្បាប់លេខ ២៦ នោះទេ (ការិយាល័យ អ.ស.ប. ទប់ស្កាត់គ្រឿងញៀន និងឧក្រិដ្ឋកម្ម/២០០៣ និង Van Vuuren ២០០៤:៦)។

ប្រការនេះទាក់ទិនដល់ឧបសគ្គមួយថែមទៀត ពោលគឺកង្វះនៃការអនុវត្តច្បាប់ដែលមានជាធរមាន (តម្លាភាពអន្តរជាតិ ២០០៤:២៥៩) និងថា នៅក្នុងផ្នែកសាធារណៈ គ្មានសមត្ថភាពស្មើគ្នាក្នុងការអនុវត្ត និងប្រតិបត្តិតាមច្បាប់ (ការិយាល័យ អ.ស.ប.ស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម/២០០៣)។ ដូច្នេះ ធាតុផ្សំមួយដែលធានាជោគជ័យដល់យុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ គឺស្ថិតនៅក្នុងការអនុវត្តតាមច្បាប់ជាធរមាន ព្រមទាំងលើកកម្ពស់ការយល់ដឹងនៃអ្នកដែលមានភារកិច្ចអនុវត្តច្បាប់ ហើយនិងលើកកម្ពស់ការយល់ដឹងដល់សាធារណជនទូទៅស្តីអំពីសិទ្ធិនិងការទទួលខុសត្រូវ ដែលគោលការណ៍ច្បាប់បានផ្តល់ដល់អ្នកទាំងនោះ (ការិយាល័យអ.ស.ប. ស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម/២០០៣ និង Van Vuuren ២០០៤:៤-៥)។

ថ្វីបើអាហ្វ្រិកខាងត្បូងបានទទួលជោគជ័យក្នុងការបង្កើនសមត្ថភាពអនុវត្តច្បាប់ក៏ដោយ (មានន័យថា ការស៊ើបអង្កេត និងការដាក់បណ្តឹងអាជ្ញា) ក៏ប្រទេសនេះមិនបានទទួលជោគជ័យឱ្យបានដូចគ្នា នៅក្នុងការទប់ស្កាត់អំពើពុករលួយ និងការអប់រំសាធារណជនដែរ ដែលជាអង្គធាតុ ២ ទៀតនៃវិធីសាស្ត្រ ៣មុខព្រួញប្រឆាំងអំពើពុករលួយ។ នេះបង្កើតបានជាកំសោយចម្បងមួយក្នុងចំណោមកំសោយនានា ស្តីពីលំនាំដោះស្រាយបច្ចុប្បន្នរបស់អាហ្វ្រិកខាងត្បូងចំពោះអំពើពុករលួយ (ការិយាល័យ អ.ស.ប.ស្តីពីគ្រឿងញៀននិងឧក្រិដ្ឋកម្ម/២០០៣) ប្រហែលដោយសារតែមិនមានទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយតែមួយដែលមានអំណាចបែបនេះ។

យុទ្ធសាស្ត្រនេះចែងផងដែរពីបញ្ហាដែលត្រូវមានកិច្ចសម្របសម្រួលកាន់តែច្រើនឡើង រវាងស្ថាប័ននានា ដែលមានភារកិច្ចប្រឆាំងនឹងអំពើពុករលួយ។ កិច្ចសម្របសម្រួលរវាងស្ថាប័ននានាទើបតែនឹងផ្តួចផ្តើមធ្វើឡើងថ្មីៗនេះប៉ុណ្ណោះ។ ការបង្កើតទីភ្នាក់ងារសម្របសម្រួលប្រឆាំងនឹងអំពើពុករលួយ បានទទួលជោគជ័យខ្លះៗ ក្នុងការប្រមូលផ្តុំទីភ្នាក់ងារទាំងនេះ (Van Vuuren ២០០៤:៤)។ ក៏ប៉ុន្តែ ភារកិច្ចប្រឆាំងនឹងអំពើពុករលួយបែបរំលែកបន្ទុកគ្នា នៅតែត្រូវបានមើលឃើញថាជាកំសោយមួយប្រភេទ ដោយវាមានភារកិច្ចត្រួតគ្នានៅក្នុងច្បាប់ និងកង្វះកិច្ចសម្របសម្រួលរវាងស្ថាប័នទាំងនេះ។ ដូច្នេះ ត្រូវតែមានការបញ្ជាក់ឱ្យច្បាស់លាស់ នូវភារកិច្ចរបស់ទីភ្នាក់ងារនីមួយៗ ព្រមទាំងសម្របសម្រួលឱ្យបានប្រសើរឡើងនូវយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ហើយនិងសម្របសម្រួលឱ្យបានប្រសើរឡើងនូវការផ្តើមគំនិត និងការស៊ើបអង្កេត (ការិយាល័យ អ.ស.ប.ស្តីពីគ្រឿង ញៀននិងឧក្រិដ្ឋកម្ម/២០០៣)។ គេបានស្នើថា អាហ្វ្រិកខាងត្បូងគួរពិចារណាអំពីការបង្កើតទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយតែមួយ សម្រាប់ធ្វើជាមធ្យោបាយកែតម្រូវភាពមិនគ្រប់គ្រាន់ដែលមើលឃើញនេះ (Van Vuuren ២០០៤:៣-៤)។

ចំណុចខ្សោយមួយទៀត គឺកង្វះការគ្រប់គ្រងព័ត៌មានអំពីអំពើពុករលួយ ដែលទប់ស្កាត់រដ្ឋាភិបាល មិនឱ្យមានសមត្ថភាពអាចយល់ដឹងបានអំពីទ្រង់ទ្រាយនិងទំហំនៃអំពើពុករលួយ។ ប្រការនេះក៏បង្អាក់បន្ទុចផងដែរដល់ការវាស់វែងទៅលើប្រសិទ្ធភាពនៃយុទ្ធសាស្ត្រនិងសកម្មភាព

ប្រឆាំងនឹងអំពើពុករលួយ។ ដូច្នេះ ត្រូវតែបង្កើនសមត្ថភាពគ្រប់គ្រងចំណេះដឹងនៅក្នុងស្ថាប័ន ដែលមានភារកិច្ចប្រយុទ្ធនឹងអំពើពុករលួយ (ការិយាល័យ អ.ស.ប.ស្តីពីគ្រឿងញៀន និងឧក្រិដ្ឋកម្ម/២០០៣)។

តម្រូវការបង្កើនសមត្ថភាពស្ថាប័នដើម្បីទប់ទល់ជាមួយនឹងអំពើពុករលួយ ត្រូវបានដោះស្រាយផងដែរនៅក្នុងយុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយ។ នេះគឺ ការបង្កើនសមត្ថភាពតុលាការដែលបច្ចុប្បន្ននេះ មានបន្ទុកការងារច្រើនលើសលុបដែលបណ្តាលឱ្យមានកកស្ទះសំណុំរឿងជាច្រើន ការអូសបន្លាយ និងការដកថយរឿងក្តីទាក់ទិននឹងអំពើពុករលួយ ព្រមទាំងបង្កើនសមត្ថភាពនៃមន្ត្រីស៊ើបអង្កេត។ មានតម្រូវការបង្កើនសមត្ថភាពរបស់នាយកដ្ឋាន និងស្ថាប័ននានាផងដែរ ក្នុងការដោះស្រាយអំពើពុករលួយផ្ទៃក្នុង (ការិយាល័យ អ.ស.ប. ស្តីពីគ្រឿងញៀននិងឧក្រិដ្ឋកម្ម/២០០៣)។ ក៏ប៉ុន្តែ ស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ត្រូវប្រឈមមុខនឹងធនធានដែលកាន់តែតិចទៅៗ និងចំនួនរឿងក្តីដែលកាន់តែច្រើនឡើងៗ (តម្លាភាពអន្តរជាតិ ២០០៤:២៥៩)។ តាមពិតមានការអះអាងថា យុទ្ធសាស្ត្រសេវាសាធារណៈប្រឆាំងនឹងអំពើពុករលួយខ្លួនឯង ក៏មិនបានគ្រោងទុកនូវថវិកាបន្ថែម ដែលនឹងត្រូវការជាចាំបាច់ដែរ ហើយទុកឱ្យស្ថាប័ននិងនាយកដ្ឋាននានាផ្តល់ធនធានសម្រាប់សកម្មភាពបន្ថែម ដោយខ្លួនឯង ដោយដកចេញពីថវិការបស់ខ្លួនដែលមានបច្ចុប្បន្ន (តម្លាភាពអន្តរជាតិ ២០០៤: ២៦០)។ ប្រការនេះបណ្តាលឱ្យនាយកដ្ឋានមួយចំនួនមិនដាក់ប្រើប្រាស់នូវនីតិវិធី និងយន្តការសម្រាប់ប្រឆាំងនឹងអំពើពុករលួយ ដូចដែលច្បាប់បានតម្រូវនោះ។

## ប្រភព


- តម្លាភាពអន្តរជាតិ ២០០៤ របាយការណ៍សកលអំពីអំពើពុករលួយ ឆ្នាំ ២០០៤។
  *http://www.globalcorruptionreport.org/download.htm*
- UNODC (ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀននិងឧក្រិដ្ឋកម្ម) និងរដ្ឋាភិបាលអាហ្វ្រិកខាងត្បូង ឆ្នាំ ២០០៣ របាយការណ៍ប្រទេសស្តីពីការប៉ាន់ប្រមាណអំពើពុករលួយ។
  *http://www.unodc.org/southafrica_reports/*
- Van Vuuren, Hennie, ២០០៤ អាហ្វ្រិកខាងត្បូង ការសិក្សាករណីគំរូ (សេចក្តីសង្ខេប) ឯកសារសម្រាប់ការប្រជុំនៅកេនយ៉ា ស្តីពីរដ្ឋាភិបាលថ្មីប្រឆាំងនឹងអំពើពុករលួយ រៀបចំរួមដោយរដ្ឋាភិបាល កេនយ៉ា ទី-កេនយ៉ា និងតម្លាភាពអន្តរជាតិ ១១-១៣ តុលា ២០០៤។
  *http://www.kenyangm.co.ke/pdfs/south_africa.pdf*


ព័ត៌មានប្រមែប្រមូលផងដែរពីប្រព័ន្ធវេបសាយរបស់ស្ថាប័នផ្សេងៗដែលបានរៀបរាប់ខាងលើ។



# រាជាណាចក្រថៃ[១]

## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- តុលាការរដ្ឋបាល
- ការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO)
- តុលាការធម្មនុញ្ញ
- គណៈកម្មការបោះឆ្នោត
- ក្រសួងយុត្តិធម៌
- គណៈកម្មការជាតិសិទ្ធិមនុស្ស
- ការិយាល័យអគ្គសវនករថៃ (OAG)
- ការិយាល័យគណៈកម្មការសេវាកម្មស៊ីវិល (OCSC)
- ការិយាល័យគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ
- ការិយាល័យគណៈកម្មការព័ត៌មានផ្លូវការ (OIC)
- ការិយាល័យការពារពលរដ្ឋថៃ Ombudsman
- គណៈកម្មការអភិវឌ្ឍន៍សេវាសាធារណៈ ។

## បទបញ្ញត្តិចម្បង

- ច្បាប់ស្តីពីបទល្មើសទាក់ទិននឹងការដេញថ្លៃពុករលួយចំពោះទីភ្នាក់ងាររដ្ឋ ( ឆ្នាំ ១៩៩៩)
- ច្បាប់ស្តីពីការបង្កើតតុលាការរដ្ឋបាល ( ឆ្នាំ ១៩៩៩)
- ច្បាប់ប្រឆាំងនឹងការលាងលុយកខ្វក់ ( ឆ្នាំ ១៩៩៩)
- ច្បាប់ស្តីពីបទល្មើសក្នុងការដេញថ្លៃនៅទីភ្នាក់ងាររដ្ឋាភិបាល ( ឆ្នាំ ១៩៩៩)
- ច្បាប់ស្តីពីការិយាល័យតុលាការធម្មនុញ្ញ ( ឆ្នាំ ១៩៩៩)
- ច្បាប់ស្តីពីព័ត៌មានផ្លូវការ ( ឆ្នាំ ១៩៩៩)
- ច្បាប់បង្កើតអង្គការស្តីពីការប្រឆាំងអំពើពុករលួយ ( ឆ្នាំ ១៩៩៩)
- ច្បាប់បង្កើតអង្គការស្តីពីគណបក្សនយោបាយ ( ឆ្នាំ ១៩៩៨)
- ច្បាប់បង្កើតអង្គការស្តីពីសវនកម្មរដ្ឋ ( ឆ្នាំ ១៩៩៩)
- ច្បាប់បង្កើតអង្គការស្តីពីអ្នកការពារពលរដ្ឋ ( ឆ្នាំ ១៩៩៩)
- ច្បាប់ស្តីពីគ្រប់គ្រងក្រុមហ៊ុននិងភាគហ៊ុនដោយរដ្ឋមន្ត្រី ( ឆ្នាំ ២000) ។

---

[១] ព័ត៌មានចំពោះជំពូកនេះត្រូវបានផ្តល់ឱ្យដោយ Ryratana Suwanraks អ្នកគ្រប់គ្រងអង្គភាពអភិបាលកិច្ចនៃកម្មវិធីអភិវឌ្ឍន៍ អ.ស.ប ប្រចាំប្រទេសថៃ ។

## សាវតា

មុនឆ្នាំ ១៩៧៥ ការស៊ើបអង្កេត និងការប្រយុទ្ធនឹងអំពើពុករលួយ ត្រូវបានធ្វើឡើងដោយទីភ្នាក់ងាររដ្ឋាភិបាលធម្មតា (ជាពិសេសប៉ូលីស) ជាចម្បង ដោយអាស្រ័យលើច្បាប់ព្រហ្មទណ្ឌ និងបទបញ្ជាផ្សេងៗ ដែលអនុវត្តចំពោះមន្ត្រីសាធារណៈ។ មន្ត្រីរដ្ឋដែលគេរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ ត្រូវប្រឈមមុខនឹងការព្រមានជាបទវិន័យដោយទីភ្នាក់ងាររដ្ឋាភិបាលរបស់សាម៉ីជនរៀងៗខ្លួន។ ដូចគ្នានឹងករណីនៅក្នុងប្រទេសផ្សេងទៀតដែរ ការវិវត្តន៍នៃស្ថាប័នប្រឆាំងនឹងអំពើពុករលួយនៅប្រទេសថៃ បានកើតចេញពីវិបត្តិស្តីពីទំនុកចិត្តរបស់សាធារណជនទៅលើរដ្ឋាភិបាល។ ក្រោយពីការរំជើបរំជួលជាសាធារណៈប្រឆាំងនឹងរដ្ឋាភិបាលនៅ ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ១៩៧៣ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧៤ ចែងថា រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធរបស់រដ្ឋប្រកបដោយភាពស័ក្តិសិទ្ធ និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងសម្រាប់ទប់ស្កាត់ និងបំបាត់ការស្វែងរកផលប្រយោជន៍តាមរយៈមធ្យោបាយពុករលួយ។ ជាលទ្ធផល នៅក្នុងឆ្នាំ ១៩៧៥ ច្បាប់ប្រឆាំងនឹងអំពើពុករលួយត្រូវបានប្រកាសឱ្យប្រើ និងទីភ្នាក់ងារពិសេស គឺការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) ត្រូវបានបង្កើតឡើង។

ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩៩ ការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) ដំណើរការក្នុងស្ថានភាពជាអង្គភាពពិសេសរបស់រដ្ឋាភិបាលនៅក្នុងការិយាល័យរបស់នាយករដ្ឋមន្ត្រី។ ក៏ប៉ុន្តែ កម្រិតនៃអំពើពុករលួយនៅតែខ្ពស់នៅឡើយ ជាចម្បងគឺដោយសារតែមានក្រមសីលធម៌មិនគ្រប់គ្រាន់ មានបរិយាកាសមួយដែលនាំទៅរកអំពើពុករលួយ មានការអនុវត្តអន់ថយ ការសម្របសម្រួលកិច្ចប្រឹងប្រែងប្រឆាំងនឹងអំពើពុករលួយមិនគ្រប់គ្រាន់ និងកង្វះឯករាជភាពនៃការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) ដែលត្រូវរាយការណ៍ជូនអង្គនីតិប្រតិបត្តិតែប៉ុណ្ណោះ។ បន្ថែមលើនេះ មានការមិនទុកចិត្តពីសាធារណជនទូទៅ ទៅលើការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) និងទីភ្នាក់ងារសុចរិតភាពផ្សេងទៀត ជាពិសេស គឺប៉ូលីសនិងតុលាការ។

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ កើតចេញពីកិច្ចប្រឹងប្រែងកំណែទម្រង់នយោបាយ ដែលកើតចេញពីការរំជើបរំជួលរបស់ពលរដ្ឋក្នុងខែឧសភា ឆ្នាំ ១៩៩១[២]។ ដើម្បីធានាឱ្យមានតម្លាភាព និងគណនេយ្យភាព រដ្ឋធម្មនុញ្ញមានបំណងបង្កើតស្ថាប័នត្រួតពិនិត្យនានា ដែលឯករាជ្យ មានតម្លាភាព និងមិនស្ថិតនៅក្រោមអន្តរាគមន៍ពីអង្គនីតិប្រតិបត្តិ។ ស្ថាប័នដែលមានរួចមកហើយ ត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញដើម្បីធានាឱ្យមានឯករាជភាពធំធេង រីឯស្ថាប័នថ្មីជាច្រើនត្រូវបានបង្កើតឡើង (គណៈកម្មការបោះឆ្នោត ការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ ការិយាល័យអ្នកការពារពលរដ្ឋ តុលាការរដ្ឋបាល និងតុលាការធម្មនុញ្ញ)។ ដោយអនុលោមតាមបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់បង្កើតអង្គការស្តីពីការប្រឆាំងនឹងអំពើពុករលួយ ត្រូវបានប្រកាសឱ្យប្រើក្នុងឆ្នាំ ១៩៩៩។ ផ្ទុយនឹងការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ ដែលស្ថិតនៅក្រោមការិយាល័យនាយករដ្ឋមន្ត្រី គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) ត្រូវបានបង្កើតឡើងជាស្ថាប័នឯករាជ្យក្នុងឆ្នាំ ១៩៩៩ ជ្រើសរើសដោយព្រឹទ្ធសភា (ដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ដោយប្រជាពលរដ្ឋ)។

តម្រូវការលើកស្ទួយតម្លាភាព ការធ្វើឱ្យគុណភាពសេវាសាធារណៈមានភាពប្រសើរឡើង និងការពង្រឹងភាពសុចរិតទៀងត្រង់នៅក្នុងជីវភាពសាធារណៈ គឺជាកម្លាំងជំរុញមួយផងដែរ ដែលស្ថិតនៅពីក្រោយការប្រកាសឱ្យប្រើបទបញ្ជានៃការិយាល័យនាយករដ្ឋមន្ត្រី ស្តីពីអភិបាលកិច្ចល្អ (ឆ្នាំ ២០០១)។ សេចក្តីណែនាំនេះក្នុងចំណោមបំណងផ្សេងទៀត មានបំណងទប់ស្កាត់អំពើពុករលួយ ការប្រព្រឹត្តិខ្ពាំផ្គង និងការអនុវត្តមិនត្រឹមត្រូវដើម្បីប្រយោជន៍ផ្ទាល់ខ្លួន និងការមានបានរបស់បុគ្គលទាំងក្នុងផ្នែកសាធារណៈ និងផ្នែកឯកជន និងការបង្កើតស្មារតីទទួលខុសត្រូវរួមចំពោះសង្គម។ បទបញ្ជាមានចែងអំពីវិធាននៃសុចរិតភាព និងវិធាននៃគុណធម៌ចំពោះប្រាក់កាស ក្នុងចំណោមគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ។ ក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលបានចេញព្រះរាជក្រឹត្យ ស្តីពីវិធាននិងនីតិវិធីសម្រាប់រដ្ឋបាលសាធារណៈល្អ ដោយផ្តោតទៅលើការឆ្លើយតបទៅនឹងតម្រូវការនូវការគ្រប់គ្រងដែលមានមូលដ្ឋានលើលទ្ធផល ប្រសិទ្ធភាព និងគុណធម៌ ចំពោះប្រាក់កាស តម្លាភាព និងការកាត់បន្ថយការិយាធិបតេយ្យ។ ព្រះរាជក្រឹត្យតែងតាំងតួនាទីសំខាន់ៗដល់គណៈកម្មការអភិវឌ្ឍន៍ផ្នែកសាធារណៈ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០០២ សម្រាប់ដឹកនាំដំណើរការកំណែទម្រង់ផ្នែកសាធារណៈ។

[២] នៅក្នុងឆ្នាំ ១៩៩២ ឧត្តមសេនីយ៍ដែលដឹកនាំរដ្ឋប្រហារក្នុងឆ្នាំ ១៩៩១ ឡើងកាន់អំណាចជានាយករដ្ឋមន្ត្រី។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៧ បច្ចុប្បន្នចែងថា នាយករដ្ឋមន្ត្រីអាចមកពីមេដឹកនាំគណៈបក្សនយោបាយដែលមានឈ្មោះនៅក្នុងបញ្ជីបេក្ខជនសម្រាប់សមាជិកសភារបស់គណៈបក្សនយោបាយតែប៉ុណ្ណោះ។

រាជាណាចក្រថៃត្រូវបានចាត់ថ្នាក់ជាប្រទេសជាប់លំដាប់ថ្នាក់ទី ៥៩ ក្នុងចំណោមប្រទេសទាំង ១៥៩ ដែលមានឈ្មោះនៅក្នុងសន្ទស្សន៍ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិស្ដីពីទស្សនៈលើអំពើពុករលួយ។ អំពើពុករលួយនៅតែជាកង្វល់យ៉ាងធំធេងនៅឡើយ ជាពិសេសនៅក្នុងផ្នែកលទ្ធកម្ម ពន្ធដារ[៣] និងប្រតិបត្តិការអាជីកម្ម។ ជាច្រើនឆ្នាំមកហើយ អំពើពុករលួយមានភាពប្លែកៗគ្នា និងស្មុគស្មាញ ទាំងទំហំ និងទម្រង់ ដោយអនុលោមយ៉ាងជាក់លាក់ទៅនឹងការប្រែប្រួលភ្លាមៗនៃបរិយាកាសនយោបាយ សេដ្ឋកិច្ច និងសង្គម ការជឿនលឿនផ្នែកបច្ចេកវិទ្យា និងការប្រកួតប្រជែងអាជីវកម្មយ៉ាងសាហាវ។ ស្ដីពីអំពើពុករលួយផ្នែកនយោបាយ (នយោបាយដោយយកប្រាក់ជាមធ្យោបាយ) ព្រមទាំងអំពើពុករលួយដែលទាក់ទិននឹងឧក្រិដ្ឋកម្មអង្គការចាត់តាំង និងពេស្យាកម្មមានសភាពធំធេង។ សារព័ត៌មានបានដើរតួនាទីកាន់តែសំខាន់ឡើងនៅក្នុងការស៊ើបអង្កេត និងធ្វើឱ្យគេដឹងឮនូវឧទាហរណ៍អាក្រក់នៃអំពើពុករលួយ។ សភាបានបង្កើនតួនាទីរបស់ខ្លួនផងដែរ នៅក្នុងការពិនិត្យមើលការបំពានអំណាចដោយមន្ត្រី និងអ្នកនយោបាយ រីឯអង្គតុលាការក៏កំពុងបង្ហាញសញ្ញានៃគោលជំហរឯករាជ្យរបស់ខ្លួនកាន់តែច្រើនឡើងដែរ។ នៅទីបញ្ចប់ មានបណ្ដាញសង្គមស៊ីវិលប្រឆាំងនឹងអំពើពុករលួយយ៉ាងរស់រវើកផងដែរ ដោយមានអង្គការតម្លាភាពថៃ បណ្ដាញប្រឆាំងនឹងអំពើពុករលួយ និងមូលនិធិសម្រាប់ថៃដែលស្អាតស្អំ និងមានតម្លាភាពដែលដើរតួរនាទីចម្បង។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

គណៈកម្មការជាតិប្រឆាំងអំពើពុករលួយ (NCCC) គឺជាទីភ្នាក់ងារឯករាជ្យតាមរដ្ឋធម្មនុញ្ញ ដែលត្រូវទទួលខុសត្រូវចំពោះសភា។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមានសមាជិកប្រាំបួននាក់ (ប្រធានម្នាក់ និងសមាជិកប្រាំបីនាក់) ដែលមានអាណត្តិប្រាំបួនឆ្នាំ ដោយមិនអាចជ្រើសតាំងសាជាថ្មីបានទេ។ សមាជិកត្រូវបានជ្រើសតាំងដោយសភា ដោយជ្រើសរើសចេញពីបញ្ជីឈ្មោះដែលមានបេក្ខជន ១៨នាក់ ដែលត្រូវបានស្នើឈ្មោះដោយគណៈកម្មាធិការសម្រាំងបេក្ខជនដែលមានសមាជិក ១៥នាក់។[៤] បុគ្គលដែលត្រូវបានស្នើឈ្មោះជាបេក្ខជនសម្រាប់សមាជិកនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ គឺជារដ្ឋមន្ត្រី ចៅក្រមតុលាការធម្មនុញ្ញ សមាជិកឯករាជ្យនៃគណៈកម្មការអ្នកការពារពលរដ្ឋ សមាជិកនៃគណៈកម្មការជាតិសិទ្ធិមនុស្ស គណៈកម្មការសវនកម្មរដ្ឋ ដែលកំពុងបម្រើការ ឬបានបម្រើក្នុងមុខងារមិនទាបជាងអគ្គព្រះរាជអាជ្ញារង អគ្គនាយក ឬតំណែងសមមូល ឬជាសាស្ត្រាចារ្យសាកលវិទ្យាល័យ។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយត្រូវដាក់របាយការណ៍ប្រចាំឆ្នាំ ស្ដីពីលទ្ធផលការងាររបស់ខ្លួន ជូនព្រឹទ្ធសភា សភាតំណាងរាស្ត្រ និងគណៈរដ្ឋមន្ត្រី។

បន្ថែមទៅនឹងអង្គភាពរដ្ឋបាលនានា គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមាននាយកដ្ឋានចម្បងចំនួនប្រាំពីរៈ (១)នាយកដ្ឋានវិធានការទប់ស្កាត់អំពើពុករលួយ (២)នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ/ទំនាក់ទំនងសាធារណៈនិងសីលធម៌ (៣)នាយកដ្ឋានគោលនយោបាយនិងផែនការ (៤)នាយកដ្ឋានបំបាត់អំពើពុករលួយ/រដ្ឋបាលមូលដ្ឋាននិងផ្នែកសង្គម (៥)នាយកដ្ឋានបំបាត់អំពើពុករលួយ/ផ្នែកផ្សេងៗ ទៀត (៦) នាយកដ្ឋានអធិការកិច្ចទ្រព្យសកម្ម និង (៧)នាយកដ្ឋានកិច្ចការច្បាប់។

ការិយាល័យនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) គឺជាលេខាធិការដ្ឋាននៃគណៈកម្មការ។ លេខាធិការដ្ឋាននេះដឹកនាំដោយអគ្គលេខាធិការម្នាក់ ដែលត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធានគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ។

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយទទួលភារកិច្ចជាអ្នកសម្របសម្រួលចម្បងរវាងកិច្ចប្រឹងប្រែងគ្រប់បែបយ៉ាងប្រឆាំងនឹងអំពើពុករលួយនៅប្រទេសថៃ រួមទាំងការទប់ស្កាត់ និងការអនុវត្ត។ មុខងាររបស់គណៈកម្មការនេះមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់បង្កើតអង្គការស្ដីពីការប្រឆាំងនឹងអំពើពុករលួយ ឆ្នាំ ១៩៩៩ និងមានទាក់ទិន ជាពិសេស ទៅនឹងៈ

---

[៣] យោងតាមអគ្គនាយកនៃនាយកដ្ឋានពន្ធដារ (២០០២) យ៉ាងហោចណាស់ទឹកប្រាក់ចំនួន ២៥ លានបាត (ប្រហែល ៦១០.០០០ ដុល្លារសហរដ្ឋអាមេរិក) ត្រូវបានសូកដល់មន្ត្រីពន្ធដាររាល់ខែ។

[៤] សមាសភាពគណៈកម្មាធិការសម្រាំងបេក្ខជន រួមមានប្រធានតុលាការកំពូល ប្រធានតុលាការធម្មនុញ្ញ ប្រធានតុលាការរដ្ឋបាលកំពូល សាកលវិទ្យាធិការប្រាំពីរនាក់ ដែលតំណាងឱ្យស្ថាប័នអប់រំជាន់ខ្ពស់រដ្ឋ និងតំណាងគណៈបក្សនយោបាយ ប្រាំនាក់ ដែលមានអាសនៈនៅក្នុងសភាតំណាងរាស្ត្រ។

- ការប្រកាស និងអធិការកិច្ចលើទ្រព្យសកម្ម និងទ្រព្យអកម្មៈ គឺបុគ្គលដែលកាន់កាប់តំណែងនយោបាយ ក៏ដូចជាមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល (ថ្នាក់មជ្ឈិម និងថ្នាក់មូលដ្ឋាន) ត្រូវផ្តល់សម្រង់គណនេយ្យនៃទ្រព្យសកម្ម និងទ្រព្យអកម្មរបស់ខ្លួនជូនគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ក៏ដូចជាសម្រង់គណនេយ្យរបស់សហព័ទ្ធ និងកូនដែលនៅក្នុងបន្ទុក[៥] (រាល់បីឆ្នាំម្តង ក៏ដូចជានៅពេលចូលកាន់មុខងារ នៅពេលចាកចេញពីមុខងារ និងមួយឆ្នាំក្រោយពីចាកចេញពីមុខងារ)។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ទទួលខុសត្រូវក្នុងការកំណត់ប្រភេទតំណែងនានា ដែលត្រូវប្រឈមមុខនឹងអធិការកិច្ចលើទ្រព្យសកម្ម និងត្រូវថែងវិធាន និងនីតិវិធី។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយអាចធ្វើអធិការកិច្ចលើករណីណាមួយកាលបើមានការសង្ស័យយ៉ាងសមហេតុផលទៅលើមន្ត្រីណាម្នាក់ (សូម្បីតែសាម៉ីជនមិនមែនជាមន្ត្រីថ្នាក់ខ្ពស់ក៏ដោយ) និងបញ្ជាមន្ត្រីនោះឱ្យដាក់ជូនសេចក្តីប្រកាសទ្រព្យសម្បត្តិបែបនេះ។
- ការទប់ស្កាត់អំពើពុករលួយ រួមមានការអប់រំអំពីអំពើពុករលួយ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ គឺគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយទទួលខុសត្រូវក្នុងការកាត់បន្ថយឱកាសប្រព្រឹត្តអំពើពុករលួយ អប់រំពលរដ្ឋ លើកស្ទួយសីលធម៌ និងសីលធម៌ក្នុងការបំពេញការងារ និងពង្រឹងសម្ព័ន្ធភាពជាមួយនឹងសង្គមស៊ីវិល និងផ្នែកឯកជន។ គណៈកម្មការនេះផ្តល់វិធានការ និងអនុសាសន៍ (រួមទាំង កែលម្អផ្នែកនីតិកម្ម និងផ្នែកគ្រប់គ្រង) ដល់គណៈរដ្ឋមន្ត្រី និងអង្គការពាក់ព័ន្ធ ក្នុងគោលបំណងធ្វើឱ្យនីតិវិធីធ្វើការងារមានភាពប្រសើរឡើង និងកាត់បន្ថយឱកាស និងគ្រឿងលើកទឹកចិត្តឱ្យប្រព្រឹត្តអំពើពុករលួយនៅក្នុងផ្នែកសាធារណៈ។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយលើកស្ទួយតម្លាភាព និងគណនេយ្យភាពនៅក្នុងសង្គមផងដែរ។ គណៈកម្មការនេះសង្កេតមើលការអនុវត្តច្បាប់បង្កើតអង្គការ ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ដែលពាក់ព័ន្ធនឹងបញ្ហាទំនាស់ផលប្រយោជន៍។
- ការបំបាត់អំពើពុករលួយៈ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមានអំណាចធ្វើអធិការកិច្ច និងស៊ើបអង្កេត។

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ស៊ើបអង្កេតបទល្មើសដែលទាក់ទិននឹងការដេញថ្លៃ ដូចមានចែងនៅក្នុងច្បាប់ឆ្នាំ ១៩៩៩ ស្តីពីទីភ្នាក់ងារសាធារណៈផងដែរ។ ច្បាប់នេះដាក់ពិន័យយ៉ាងធ្ងន់ធ្ងរចំពោះអ្នកនយោបាយ និងមន្ត្រីរដ្ឋ ក៏ដូចជាអាជីវករឯកជនដែរ[៦]។ មន្ត្រីសាធារណៈដែលបានដឹងពីការអនុវត្តដំណើរការលទ្ធកម្ម ដែលមិនយុត្តិធម៌ ឬដោយមានអំពើពុករលួយ ក៏ប៉ុន្តែខកខានមិនបានចាត់ការទល់នឹងដំណើរការនេះ ក៏ត្រូវទទួលទោសធ្ងន់ធ្ងរដែរ។

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយអាចទាមទារឯកសារពាក់ព័ន្ធ ឬវត្ថុតាង ពីបុគ្គលណាម្នាក់ ឬកោះហៅបុគ្គលណាម្នាក់ឱ្យធ្វើជាកសិណសាក្សីនៅក្នុងករណីពុករលួយណាមួយ។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមិនអាចចេញដីកាឆែកឆេរ ឬដីកាចាប់ខ្លួន ឬឃុំខ្លួនបានទេ។ គណៈកម្មការនេះត្រូវដាក់ពាក្យសុំ ទៅតុលាការមានសមត្ថកិច្ចឱ្យចេញដីកាបែបនេះ។ ប្រសិនបើគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយយល់ថា ការបន្តបំពេញការងាររបស់ជនជាប់ចោទនឹងបង្កឱ្យមានការខូចខាតដល់ក្រសួងរដ្ឋាភិបាល ឬបណ្តាលឱ្យមានឧបសគ្គដល់ការស៊ើបអង្កេត គណៈកម្មការត្រូវបញ្ជូនរឿងនេះទៅចៅហ្វាយនាយរបស់សាម៉ីជន ដើម្បីចេញបញ្ជាឱ្យព្យួរមុខងារពីក្រសួងរដ្ឋាភិបាល ដោយរង់ចាំសេចក្តីសម្រេចរបស់គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ។ នៅពេលស៊ើបអង្កេតអំពីទ្រព្យធនមិនប្រក្រតីណាមួយ គណៈកម្មការជាតិប្រឆាំងអំពើពុករលួយមានអំណាចបញ្ជាឱ្យរឹបអូសយកទ្រព្យនោះជាបណ្តោះអាសន្នបាន។

---

[៥] យោងតាមផ្នែក ២៩១ នៃរដ្ឋធម្មនុញ្ញ បុគ្គលដែលកាន់កាប់តំណែងនយោបាយដូចតទៅនេះ ត្រូវដាក់ជូនគណៈនីៈ (១)នាយករដ្ឋមន្ត្រី (២)រដ្ឋមន្ត្រីសមាជិករដ្ឋាភិបាល (៣)សមាជិកសភាតំណាងរាស្ត្រ (៤)សមាជិកព្រឹទ្ធសភា (៥)មន្ត្រីនយោបាយផ្សេងទៀត (៦)មន្ត្រីរដ្ឋបាលមូលដ្ឋាន និងសមាជិកសភាមូលដ្ឋាន ដូចដែលមានចែងនៅក្នុងច្បាប់ (បញ្ជីនេះមានចែងបញ្ជាក់នៅមាត្រា ៣៩ នៃច្បាប់បង្កើតអង្គការស្តីពីការប្រឆាំងនឹងអំពើពុករលួយ)។ គណៈនីដែលត្រូវបានដាក់ជូនដោយនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីសមាជិករដ្ឋាភិបាល ត្រូវប្រកាសផ្សាយជាសាធារណៈ។

[៦] នៅក្នុងឆ្នាំ ២០០០ គេជឿថា អំពើពុករលួយនៅក្នុងលទ្ធកម្ម មានចំនួនប្រហែលពី ៥% ទៅ ១០%នៃថវិកា គម្រោងលទ្ធកម្ម និនមានប្រហែលពី ១០% ទៅ ២០%នៃថវិការគម្រោងដេញថ្លៃ (សិក្ខាសាលាអំពីផែនការយុទ្ធសាស្ត្រប្រឆាំងនឹងអំពើពុករលួយ ដែលធ្វើឡើងដោយគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយឆ្នាំ ២០០០)។

ការត្រួតពិនិត្យលើកិច្ចប្រតិបត្តិការរបស់គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ត្រូវបានធានាតាមរយៈការកំណត់កិច្ចសម្របសម្រួលប្រតិបត្តិការយ៉ាងច្បាស់លាស់ ដែលមានការពាក់ព័ន្ធជាមួយសេវាកម្មរបស់តុលាការ និងស្ថាប័នអយ្យការ។ ការស៊ើបអង្កេតលើករណីអំពើពុករលួយ ត្រូវបានសង្កេតមើលផងដែរ ដោយគណៈកម្មាធិការពិសេសនានា ដែលមានសមាសភាពរួមគ្នារវាងបុគ្គលជំនាញពីក្រៅ ដែលមានគុណវុឌ្ឍិខ្ពស់ និងមន្ត្រីនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ។

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ មិនគ្រាន់តែមានភារកិច្ចធានាការពារសាក្សីប៉ុណ្ណោះទេ ក៏ប៉ុន្តែ មានអំណាចផងដែរក្នុងការចេញបទបញ្ជា និងសម្រេចអំពីការផ្តល់រង្វាន់ចំពោះព័ត៌មានដែលនាំទៅរកការរើកមុខសកម្មភាពពុករលួយ។ គណៈកម្មការនេះជម្រុញឱ្យមានការស្រាវជ្រាវស្តីអំពីអំពើពុករលួយ តាមទស្សនៈយល់ឃើញក្នុងផ្នែកសង្គម ផ្នែកសេដ្ឋកិច្ច ផ្នែកនយោបាយ និងផ្នែកឧក្រិដ្ឋកម្មផងដែរ។ គណៈកម្មការនេះបានផ្តួចផ្តើមកម្មវិធីទប់ស្កាត់មួយចំនួន ក្នុងចំណោមយុវជន រដ្ឋបាលមូលដ្ឋាន និងពលរដ្ឋក្នុងសហគមន៍ទូទាំងប្រទេស។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ចាត់ឱ្យធ្វើការស្ទង់មតិអំពីបញ្ហាពុករលួយរនៅក្នុងផ្នែកអាជីវកម្ម និងនៅក្នុងរដ្ឋាភិបាល និងបានចេញគោលការណ៍ណែនាំសម្រាប់មន្ត្រីសាធារណៈ ដោយដាក់កម្រិតដល់ការទទួលអំណោយ។ លើសពីនេះ ជាផ្នែកមួយនៃភារកិច្ចទប់ស្កាត់របស់ខ្លួន គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយបានចាត់វិធានការមួយចំនួនសម្រាប់លើកកម្ពស់កម្រិតសីលធម៌ក្នុងចំណោមនិស្សិត។

## ការរៀបចំកិច្ចប្រតិបត្តិការ

នៅពេលដែលគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) រកឃើញភាពមិនប្រក្រតីនៅក្នុងសេចក្តីប្រកាសទ្រព្យនៃមន្ត្រីសាធារណៈ ក្រោយពីធ្វើការស៊ើបអង្កេតហើយ គណៈកម្មការនេះត្រូវបញ្ជូនរឿងនេះទៅតុលាការធម្មនុញ្ញដើម្បីធ្វើសេចក្តីសម្រេច។ នេះគឺនិយាយអំពីករណីដែលគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយរកឃើញថា អ្នកកាន់កាប់ការិយាល័យ (គឺមន្ត្រីរាជការ) បានលាក់ទុកព័ត៌មាន ឬបានដាក់ព័ត៌មានខុស នៅពេលដែលធ្វើសេចក្តីប្រកាសទ្រព្យសកម្ម និងទ្រព្យអកម្ម។[៧]

បន្ថែមលើនេះទៀត បុគ្គលដែលកាន់កាប់តំណែងនយោបាយ ឬតំណែងរដ្ឋាភិបាលជាន់ខ្ពស់[៨] អាចត្រូវបានដកហូតពីតំណែងដោយព្រឹទ្ធសភា ប្រសិនបើមានភស្តុតាងបង្ហាញពីការមានបានភោគទ្រព្យដោយអំពើពុករលួយ ការប្រព្រឹត្តអំពើពុករលួយនៅក្នុងតំណែងសាធារណៈ ឬការបំពានអំណាចដោយចេតនា។ នីតិវិធីចោទប្រកាន់ក្នុងប្រការនេះ អាចផ្តួចផ្តើមធ្វើតាមល័ក្ខខ័ណ្ឌពីរបែបៈ (១) យ៉ាងហោចណាស់ដោយសមាជិកមួយភាគបួននៃសភាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា និង (២) យ៉ាងហោចណាស់ដោយអ្នកបោះឆ្នោតចំនួន ៥០.០០០នាក់។ ក្នុងករណីនេះ ប្រធានព្រឹទ្ធសភាត្រូវបញ្ជូនសំណុំរឿងទៅគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ដើម្បីស៊ើបអង្កេត។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយត្រូវដាក់របាយការណ៍របស់ខ្លួនជូនព្រឹទ្ធសភា និងបន្ទាប់មក ព្រឹទ្ធសភាអាចដំណើរការបោះឆ្នោតដកហូតមន្ត្រីនោះចេញពីតំណែង។ ក៏ប៉ុន្តែ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយត្រូវដាក់របាយការណ៍ជូនអគ្គព្រះរាជអាជ្ញាផងដែរ ដើម្បីធ្វើការកាត់សេចក្តីនៅតុលាការកំពូលផ្នែកឧក្រិដ្ឋកម្ម សម្រាប់អ្នកកាន់កាប់ការិយាល័យនយោបាយ (តំណែងនយោបាយ) ឬនៅតុលាការមានសមត្ថកិច្ច (សម្រាប់មន្ត្រី

[៧] ច្បាប់ស្តីពីគ្រប់គ្រងក្រុមហ៊ុននិងភាគហ៊ុនដោយរដ្ឋមន្ត្រី ចែងថាសមាជិកគណៈរដ្ឋមន្ត្រីមិនអាចកាន់កាប់ភាគហ៊ុននៃក្រុមហ៊ុនសាធារណៈច្រើនជាង ៥ ភាគរយនោះទេ ល្គឹកណាតែសមាជិកនោះបង្កើតឱ្យមាន blind trust សម្រាប់គ្រប់គ្រងភាគហ៊ុនរបស់ខ្លួន ដោយខ្លួនគ្មានការពាក់ព័ន្ធប្រភេទណាមួយឡើយ។ នៅក្នុងឆ្នាំ ២០០០ រឿងក្តីដែលមានការពាក់ព័ន្ធដល់នាយករដ្ឋមន្ត្រីបច្ចុប្បន្ន ត្រូវបានប្តឹងទៅតុលាការធម្មនុញ្ញ។ តុលាការសម្រេចឱ្យនាយករដ្ឋមន្ត្រីឈ្នះក្តី។

[៨] បុគ្គលដែលកាន់កាប់តំណែងជានាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិកសភាតំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា ប្រធានតុលាការកំពូល ប្រធានតុលាការធម្មនុញ្ញ ប្រធានតុការកំពូលរដ្ឋបាល ឬអគ្គព្រះរាជអាជ្ញា ដែលស្ថិតនៅក្នុងកាលៈទេសៈនៃការមានបានភោគទ្រព្យមិនប្រក្រតី ដែលជាប់សង្ស័យពីអំពើពុករលួយ ការប្រព្រឹត្តិអំពើពុករលួយនៅក្នុងការិយាល័យ ការប្រព្រឹត្តអំពើពុករលួយនៅក្នុងកិរិយាល័យតុលាការ ឬមានចេតនាប្រើអំណាចដោយផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ អាចត្រូវបានដកចេញពីតំណែងដោយព្រឹទ្ធសភា (ផ្នែក ៣០៣ នៃរដ្ឋធម្មនុញ្ញ)។ បញ្ញត្តិនេះអនុវត្តផងដែរចំពោះសមាជិកគណៈកម្មការបោះឆ្នោត អ្នកការពារពលរដ្ឋ ចៅក្រមតុលាការធម្មនុញ្ញ សមាជិកនៃគណៈកម្មការសវនកម្មរដ្ឋ ចៅក្រមតុលាការស៊ីវិល ព្រះរាជអាជ្ញា និងមន្ត្រីជាន់ខ្ពស់ (ផ្នែក ៣០៣)។

ផ្សេងទៀត)។ ការដកហូតតំណែងដោយព្រឹទ្ធសភា មិនធ្វើឱ្យប៉ះពាល់ដល់ការកាត់សេចក្ដីរបស់តុលាការកំពូលនោះទេ (ដោយអនុលោមតាមច្បាប់បង្កើតអង្គការ ស្ដីពីដំណើរការក្ដីឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលកាន់កាប់តំណែងនយោបាយ) ឬនៅតុលាការផ្សេងទៀត (នៅក្នុងករណីនៃតំណែងមិនមែននយោបាយ)។

បុគ្គលណាក៏អាចដាក់បណ្ដឹងដោយផ្ទាល់ទៅកាន់គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយដែរ ដែលនៅក្នុងករណីនោះ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយនឹងធ្វើការស៊ើបអង្កេតអំពីអង្គហេតុ (ប៉ុន្តែគណៈកម្មការ ជាតិប្រឆាំងនឹងអំពើពុករលួយមិនពិចារណាលើបណ្ដឹងអនាមិកទេ)។ ប្រសិនបើរឿងក្ដីនោះទាក់ទិននឹងមន្ត្រីដែលកាន់កាប់តំណែងនយោបាយ ពេលនោះ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយនឹងរាយការណ៍ជូនព្រឹទ្ធសភា និងជូនអគ្គព្រះរាជអាជ្ញា។ នៅពេលដែលការស៊ើបអង្កេតទាក់ទិននឹងបុគ្គលដែលមិនកាន់កាប់តំណែងនយោបាយ រឿងក្ដីនោះត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញា (ប្រសិនបើមានការបំពានច្បាប់ព្រហ្មទណ្ឌ)។ ប្រសិនបើមានករណីដែលទាក់ទិននឹងវិធានការជាបទវិន័យ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ត្រូវបញ្ជូនរបាយការណ៍ជូនចៅហ្វាយនាយផ្ទាល់របស់សាម៉ីជនផងដែរដើម្បីចាត់វិធានការ។

ជាគោលការណ៍ គឺអគ្គព្រះរាជអាជ្ញា ដែលទទួលខុសត្រូវក្នុងការនាំរឿងពុករលួយទៅធ្វើការកាត់សេចក្ដី នៅតុលាការមានសមត្ថកិច្ច។ ប៉ុន្តែ គេក៏មានការលើកលែងខ្លះចំពោះវិធាននេះផងដែរ។ ទីមួយ កាលបើរឿងណាមួយត្រូវបានកាត់សេចក្ដីនៅតុលាការធម្មនុញ្ញ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ត្រូវដើរតួនាទីជាព្រះរាជអាជ្ញាដោយផ្ទាល់នៅក្នុងរឿងនេះ។ ទីពីរ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយត្រូវមានអំណាចបំពេញតួនាទីជាព្រះរាជអាជ្ញាផងដែរ តាមកាលៈទេសៈពីរដូចខាងក្រោមនេះ: (១)នៅពេលដែលជនជាប់ចោទ គឺជាអគ្គព្រះរាជអាជ្ញា (២) នៅពេលដែលអគ្គព្រះរាជអាជ្ញាយល់ឃើញថា របាយការណ៍របស់គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមិនពេញលេញគ្រប់គ្រាន់សម្រាប់ធ្វើបណ្ដឹងអាជ្ញា (ប្ដឹងចោទពីបទល្មើស) ព្រមទាំងមិនមានការព្រមព្រៀងគ្នាណាមួយនៅក្នុងគណៈកម្មាធិការការងារពិសេសដែលមានតំណាងមកពីគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ និងអគ្គព្រះរាជអាជ្ញា។[៩]

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ប្រតិបត្តិការនៅក្នុងបណ្ដាញទំនាក់ទំនងជាមួយនឹងស្ថាប័នផ្សេងទៀត ដែលមានការពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងកិច្ចប្រឹងប្រែងប្រយុទ្ធនឹងអំពើពុកលួយ។

**គណៈកម្មការបោះឆ្នោត**មានសមាជិកប្រាំនាក់ដែលត្រូវបានជ្រើសរើសដោយព្រឹទ្ធសភាតាមអនុសាសន៍របស់គណៈកម្មាធិការជ្រើសរើស។ គណៈកម្មការបោះឆ្នោតធានាឱ្យមានការបោះឆ្នោតសេរី និងយុត្តិធម៌។ ជាក់ស្ដែងជាងនេះទៀត គណៈកម្មការបោះឆ្នោតមានអំណាចធ្វើសេចក្ដីសម្រេចជំទាស់នឹងបេក្ខជន នៅក្នុងករណីទិញសន្លឹកឆ្នោត។ គណៈកម្មការបោះឆ្នោតមានអំណាចរៀបចំការបោះឆ្នោតសារជាថ្មី ឬអាចលុបឈ្មោះបេក្ខជនណាម្នាក់មិនឱ្យឈរឈ្មោះនៅក្នុងការបោះឆ្នោត ប្រសិនបើរកឃើញភស្ដុតាង ច្បាស់លាស់ថាបានពាក់ព័ន្ធនៅក្នុងការទិញសន្លឹកឆ្នោត។ បន្ថែមលើនេះទៀត គណៈកម្មការនេះត្រួតមើលការផ្ដល់ហិរញ្ញវត្ថុ និងវិភាគទានដល់គណៈបក្សនយោបាយផងដែរ។ ដើម្បីធានាឱ្យមានតម្លាភាពនៅក្នុងការផ្ដត់ផ្គង់ហិរញ្ញវត្ថុដល់គណៈបក្សនយោបាយ កំណត់ត្រាគណនេយ្យនៃគណៈបក្សនយោបាយ រួមទាំងចំណូល ចំណាយ និងវិភាគទានត្រូវបានតម្រូវឱ្យរាយការណ៍ជូនសាធារណជនលើរាល់ៗឆ្នាំ។

តួនាទីសំខាន់នៅក្នុងការប្រយុទ្ធនឹងអំពើពុករលួយ គឺស្ថិតនៅក្នុង**គណៈកម្មការក្រសួងស៊ីវិល (CSC)** និងទីភ្នាក់ងារប្រតិបត្តិរបស់គណៈកម្មការនេះ ព្រមទាំងស្ថិតនៅក្នុង**គណៈកម្មការអភិវឌ្ឍន៍ផ្នែកសាធារណៈ (PSDC)**។ គណៈកម្មការក្រសួងស៊ីវិល (CSC) កំណត់គោលនយោបាយ និងគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រង និងរដ្ឋបាលនៃក្រសួងស៊ីវិល និងត្រួតត្រា និងសង្កេតមើលលើកិច្ចប្រតិបត្តិការ។ គណៈកម្មការក្រសួងស៊ីវិល (CSC) មានសមាជិក ១៥-១៧ នាក់ ដែលសុទ្ធតែជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ និងបុគ្គលដែលមានគុណសម្បត្តិខ្ពស់ មក

---

[៩] គណៈកម្មាធិការការងារពិសេសនេះ គឺត្រូវប្រមែប្រមូលព័ត៌មានថែមទៀត សម្រាប់ដាក់ជូនអគ្គព្រះរាជអាជ្ញាធ្វើការកាត់សេចក្ដីបន្ត។ នៅពេលដែលគ្មានកិច្ចព្រមព្រៀង គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយដោយផ្ទាល់ត្រូវមានអំណាចកាត់សេចក្ដី ឬចាត់តាំងមេធាវីណាម្នាក់ឱ្យកាត់សេចក្ដីជួសគណៈកម្មការ។

ពីផ្នែកសាធារណៈ និងផ្នែកឯកជន[១០] ។ គណៈកម្មការក្រសួងស៊ីវិល (CSC) កំណត់ស្តង់ដារសីលធម៌សម្រាប់ឱ្យទីភ្នាក់ងាររដ្ឋាភិបាលប្រតិបត្តិតាម និងផ្តល់យោបល់ និងគាំទ្រក្រសួង នាយកដ្ឋាន និងខេត្ត ក្នុងការបង្កើតបច្ចេកទេសគ្រប់គ្រងដ៏មានប្រសិទ្ធិភាព និងស័ក្តិសិទ្ធិ (ចុះសោហ៊ុយតិច) ។ គណៈកម្មការក្រសួងស៊ីវិល១ជម្រុជចមានភារកិច្ចពង្រឹងការយល់ដឹងរបស់ពលរដ្ឋ អំពីតម្លៃនៃក្រសួងស៊ីវិល និងទំនុកចិត្តរបស់ពលរដ្ឋលើប្រព័ន្ធសេវាសាធារណៈ ។ ការិយាល័យនៃ**គណៈកម្មការក្រសួងស៊ីវិល (OCSC)** គឺជាទីភ្នាក់ងារមួយរបស់រដ្ឋាភិបាល ដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃការិយាល័យនាយករដ្ឋមន្ត្រី ។ ការិយាល័យនៃគណៈកម្មការក្រសួងស៊ីវិល (OCSC) ត្រូវបានដឹកនាំដោយអគ្គលេខាធិការម្នាក់ ដែលត្រូវទទួលខុសត្រូវផ្ទាល់ចំពោះនាយករដ្ឋមន្ត្រី ដែលជាប្រធាននៃគណៈកម្មការក្រសួងស៊ីវិល (CSC) ។ ភារកិច្ចចម្បងនៃគណៈកម្មការក្រសួងស៊ីវិល (CSC) គឺផ្តល់អនុសាសន៍ និងយោបល់ដល់គណៈរដ្ឋមន្ត្រី អំពីគោលនយោបាយគ្រប់គ្រងបុគ្គលិក សង្កេតមើលការគ្រប់គ្រងបុគ្គលិកផ្នែកសាធារណៈ បំពេញមុខងារជាទីភ្នាក់ងារកណ្តាលក្នុងការការពារប្រព័ន្ធតម្លើងឋានន្តរស័ក្តិដោយអាស្រ័យលើគុណសម្បត្តិ ព្រមទាំងលើកទឹកចិត្តដល់វិជ្ជាជីវៈនិយម ប្រសិទ្ធភាព លទ្ធផលដែលអាស្រ័យលើការបំពេញការងារ តម្លាភាព និងគណនេយ្យភាពនៅក្នុងផ្នែកសាធារណៈ ។ ក្រសួងមន្ត្រីប្រតិបត្តិជាន់ខ្ពស់ ដែលរៀបចំថ្មីនេះ មានគោលដៅបង្កើនតម្លាភាពនៅក្នុងការតែងតាំងមន្ត្រីសាធារណៈជាន់ខ្ពស់ ដោយអាស្រ័យលើគុណសម្បត្តិ ។ រដ្ឋធម្មនុញ្ញចែងផងដែរថា សមាជិកសភាមិនអាចប្រើតំណែងរបស់ខ្លួនសម្រាប់ធ្វើអន្តរាគមន៍នៅក្នុងការតែងតាំង ការជ្រើសរើស ការផ្ទេរ ឬការតម្លើងឋានន្តរសក្តិនៃមន្ត្រីរដ្ឋាភិបាលទេ ។

នៅក្នុងឆ្នាំ ២០០១ ការិយាល័យនៃគណៈកម្មការក្រសួងស៊ីវិល (OCSC) បានបង្កើតមូលនិធិថៃសម្រាប់តម្លាភាព និងភាពស្អាតស្អំ ។ មូលនិធិនេះ គឺជាកិច្ចប្រឹងប្រែងរួមរវាងការិយាល័យនៃគណៈកម្មការ ក្រសួងស៊ីវិល (OCSC) អង្គការសាធារណៈ និងអង្គការឯកជនពាក់ព័ន្ធ និងសាធារណជនទូទៅ ។ គោលដៅនៃមូលនិធិនេះ គឺលើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រប់ផ្នែកទាំងអស់នៃសង្គមថៃ រួមទាំងអ្នកនយោបាយ និយោជិករដ្ឋ អាជីវករ និងសាធារណជនទូទៅ ដើម្បីប្រកាន់ខ្ជាប់នូវស្តង់ដារសីលធម៌ និងការប្រព្រឹត្តិ ប្រកបដោយភាពសុចរិតទៀងត្រង់ ព្រមទាំងលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក និងភ្ជាប់បណ្តាញគ្នាក្នុងចំណោមអង្គការនិងបុគ្គល ដើម្បីធានាសុវត្ថិភាពប្រឆាំងនឹងអំពើពុករលួយ ។ យុទ្ធនាការដែលគេឱ្យឈ្មោះថា "មិនព្រមសូក និងមិនព្រមទទួលសំណូក" មានគោលដៅបង្កើតតម្លៃសីលធម៌ថ្មីសម្រាប់សង្គមថៃ ។

នៅក្នុងឆ្នាំ ២០០២ រដ្ឋាភិបាលបង្កើត**គណៈកម្មការអភិវឌ្ឍន៍ផ្នែកសាធារណៈ (PSDC)** ។ គណៈកម្មការ (PSDC) នេះ ដើរតួនាទីសំខាន់នៅក្នុងការសង្កេតមើលការអនុវត្តរាជក្រឹត្យស្តីពីវិធាន និងនីតិវិធីសម្រាប់រដ្ឋបាលសាធារណៈល្អ (ឆ្នាំ ២០០៣) ។ ដោយអនុលោមតាមរាជក្រឹត្យនេះ លេខាធិការអចិន្ត្រៃយ៍នៅក្នុងក្រសួងនីមួយៗត្រូវបង្កើតមណ្ឌលសេវាច្រកចេញចូលតែមួយ (OSSC) ដែលបំពេញតួនាទីជាអ្នកកណ្តាលរវាងពលរដ្ឋ និងទីភ្នាក់ងាររដ្ឋាភិបាល និងធ្វើឱ្យប្រសើឡើងនូវតម្លាភាព ភាពងាយស្រួលដល់សាធារណជនក្នុងការប្រើប្រាស់ព័ត៌មាន និងការផ្តល់សេវារហ័ស ។ មណ្ឌលសេវាច្រកចេញចូលតែមួយ (OSSC) ប្រហាក់ប្រហែលគ្នានេះដែរត្រូវបានបង្កើតឡើងនៅថ្នាក់ខេត្ត ស្រុក និងឃុំ ។

**ការិយាល័យគណៈកម្មការព័ត៌មានផ្លូវការ (OIC)** ទទួលបន្ទុកក្នុងការបង្កើតការយល់ដឹង និងការអនុវត្តច្បាប់ស្តីពីព័ត៌មានផ្លូវការ (ឆ្នាំ ១៩៩៧) ។ ជាសំខាន់ ទីភ្នាក់ងារសាធារណៈមានកាតព្វកិច្ចត្រូវផ្តល់ព័ត៌មានតាមការស្នើសុំពីសាធារណជន ដោយមានការលើកលែងតិចតួចប៉ុណ្ណោះ ។ ពលរដ្ឋអាចធ្វើបណ្តឹងទៅគណៈកម្មការព័ត៌មានផ្លូវការ (OIC) ក្នុងករណីដែលមានទីភ្នាក់ងារសាធារណៈណាមិនប្រតិបត្តិតាម ហើយគណៈកម្មការព័ត៌មានផ្លូវការ (OIC) មានអំណាចបង្គាប់ទៅទីភ្នាក់ងារនោះឱ្យប្រគល់នូវព័ត៌មានតាមការស្នើសុំ ។ រាជក្រឹត្យស្តីពីវិធាន និងនីតិវិធីសម្រាប់រដ្ឋបាលសាធារណៈល្អ (ឆ្នាំ ២០០៣) ក៏បានតម្រូវឱ្យប្រកាសផ្សាយនូវភារកិច្ចផ្លូវការផងដែរ[១១] ។ ការសម្ងាត់ជាផ្លូវការអាចមិនប្រកាសផ្សាយបានក្នុងគោលបំណងរក្សាសន្តិសុខជាតិ ស្ថេរភាពសេដ្ឋកិច្ចជាតិ សេចក្តីរៀបរយសាធារណៈ ឬដើម្បីការពារសិទ្ធិរបស់បុគ្គល ។

---

[១០] មានសមាជិកជាប់ឆ្នោតប្រាំនាក់ អ្នកឯកទេសបណ្ឌិតសភាពីប្រាំទៅប្រាំពីរនាក់ និងសមាជិកចាស់ប្រាំនាក់ (រួមមាន នាយករដ្ឋមន្ត្រី ឬឧបនាយករដ្ឋមន្ត្រី លេខាធិការអចិន្ត្រៃយ៍នៃក្រសួងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានថវិកា អគ្គលេខាធិការនៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សង្គម និងអគ្គលេខាធិការនៃគណៈកម្មការក្រសួងស៊ីវិល ។

[១១] ទីភ្នាក់ងាររដ្ឋាភិបាលនានាត្រូវបានតម្រូវឱ្យប្រកាសផ្សាយជាសាធរណៈនូវថវិកាប្រចាំឆ្នាំ លទ្ធកម្មប្រចាំឆ្នាំ ក៏ដូចជាកិច្ចសន្យាលទ្ធកម្មណាមួយរបស់ខ្លួន ដែលបានធ្វើរួចហើយ ។

**គណៈកម្មការសវនកម្មរដ្ឋ** ផ្ទៀងផ្ទាត់មើលភាពត្រឹមត្រូវនៃសេចក្ដីសម្រេចចំណូល ចំណាយ ការរក្សាទុក និងការចំណាយប្រាក់កាស និងការប្រើទ្រព្យផ្សេងទៀតរបស់ទីភ្នាក់ងារសាធារណៈនិងសហគ្រាសរដ្ឋ។ គណៈកម្មការសវនកម្មរដ្ឋ នឹងធ្វើសេចក្ដីបញ្ជាក់ផងដែរថា តើការចាត់ចែងចំណូលចំណាយត្រូវបានធ្វើឡើងតាមគោលដៅកំណត់ និងមានផលល្អគ្រប់គ្រាន់ឬយ៉ាងណា។ អគ្គសវនករត្រូវបានតែងតាំងដោយព្រះមហាក្សត្រក្រោយពីមានការយល់ព្រមពីរដ្ឋសភា។ អគ្គសវនករកាន់កាប់ការិយាល័យរហូតដល់ពេលចូលនិវត្តន៍នៅអាយុ ៦០ឆ្នាំ។

ច្បាប់បង្កើតអង្គការ ឆ្នាំ ១៩៩៩ ស្ដីពីការិយាល័យអ្នកការពារពលរដ្ឋ (Ombudsman) គិតទុកជាមុនថា ត្រូវមានអ្នកការពារពលរដ្ឋយ៉ាងច្រើនបំផុតបីនាក់។ អ្នកការពារពលរដ្ឋ (Ombudsman) មានអំណាចស្វែងរកអង្គហេតុនៃបណ្ដឹងតវ៉ាទល់នឹងមន្ត្រីសាធារណៈ ដែលមិនបំពេញការងារតាមច្បាប់ ខកខានមិនបានបំពេញភារកិច្ចរបស់ខ្លួនដែលច្បាប់បានតម្រូវ ឬប្រើអំណាចលើសពីសិទ្ធិអំណាចរបស់ខ្លួន។ ដូច្នេះ អ្នកការពារពលរដ្ឋ (Ombudsman) គឺជាបណ្ដាញមួយទៀត ដែលតាមរយៈបណ្ដាញនេះ គេអាចលើកករណីអំពើពុករលួយបានទៀត។ អ្នកការពារពលរដ្ឋមិនមានអំណាចស៊ើបអង្កេតទេ ហើយត្រូវប្ដឹងរឿងអំពើពុករលួយដែលត្រូវបានចោទប្រកាន់ ទៅគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ។ ការិយាល័យអ្នកការពារពលរដ្ឋ (Ombudsman) អាចបញ្ជូនសំណុំរឿងទៅតុលាការធម្មនុញ្ញ ឬទៅតុលាការរដ្ឋបាលបានផងដែរ ដើម្បីធ្វើសេចក្ដីសម្រេច។ ការិយាល័យ អ្នកការពារពលរដ្ឋ (Ombudsman) ត្រូវផ្ដល់របាយការណ៍ប្រចាំឆ្នាំដល់សភាផងដែរ ដែលជាបណ្ដាញមួយទៀត សម្រាប់បង្ហាញឱ្យដឹងពីស្ថានភាពអំពើពុករលួយនៅក្នុងប្រទេស។

**គណៈកម្មការជាតិសិទ្ធិមនុស្សថៃ (NHRC)** បង្កើតឡើងតាមរដ្ឋធម្មនុញ្ញ និងមានសមាសភាពការធ្វើការពេញពេល ១១នាក់ ដែលត្រូវបានបោះឆ្នោតជ្រើសតាំងសម្រាប់អាណត្តិប្រាំមួយឆ្នាំដោយព្រឹទ្ធសភា ដោយជ្រើសរើសចេញពីបញ្ជីសម្រាំងដែលមានបេក្ខជន ២២នាក់។ សមាជិកម្នាក់ៗអាចបម្រើបានតែមួយអាណត្តិប៉ុណ្ណោះ។ ភារកិច្ចរបស់គណៈកម្មការ (NHRC) គឺត្រូវ (១) លើកស្ទួយការគោរពសិទ្ធិមនុស្ស (២) ពិនិត្យមើល និងរាយការណ៍អំពីប្រព្រឹត្តិកម្មដែលរំលោភសិទ្ធិមនុស្ស ឬប្រព្រឹត្តិកម្មដែលមិនបំពេញតាមកាតព្វកិច្ចអន្តរជាតិ (៣) ដាក់ស្នើគោលនយោបាយ និងវិសោធនកម្មច្បាប់ វិធាន និងបទបញ្ជាសម្រាប់លើកស្ទួយនិងការពារសិទ្ធិមនុស្ស (៤) លើកស្ទួយការអប់រំសិទ្ធិមនុស្ស និងស្រាវជ្រាវអំពីសិទ្ធិមនុស្ស រួមទាំងការប្រកាសផ្សាយពត៌មានអំពីសិទ្ធិមនុស្ស (៥) លើកស្ទួយកិច្ចសម្របសម្រួល និងសហប្រតិបត្តិការជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀតនិង (៦) ផ្ដល់យោបល់នៅពេលដែលរដ្ឋាភិបាលពិចារណាលើការចូលជាភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្ស។ ការិយាល័យនៃគណៈកម្មការជាតិសិទ្ធិមនុស្សថៃស្ថិតនៅក្រោមការដឹកនាំរបស់អគ្គលេខាធិការម្នាក់។ គណៈកម្មការជាតិសិទ្ធិមនុស្សថៃ ដាក់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនជូនសភា និងគណៈរដ្ឋមន្ត្រី។

ទំនាក់ទំនងរវាងរដ្ឋ និងពលរដ្ឋរបស់ខ្លួន ត្រូវបានចាត់ចែងដោយសេចក្ដីសម្រេចរបស់**តុលាការរដ្ឋបាល**ផងដែរ។ យុត្តាធិការនៃតុលាការរដ្ឋបាលគ្របដណ្ដប់លើវិវាទរវាងពលរដ្ឋនិងរដ្ឋ រួមទាំងរឿងពុករលួយផងដែរ។ យុត្តាធិការនេះគ្របដណ្ដប់ផងដែរលើវិវាទអំពីករណី ដែលមន្ត្រីរាជការមានការធ្វេសប្រហែសក្នុងការបំពេញតួនាទីរបស់ខ្លួន ឬបំពេញតួនាទីរបស់ខ្លួនដោយមានការយឺតយ៉ាវមិនសមហេតុផល។ ជនណាដែលដឹងខ្លួនថា ខ្លួនបានទទួលការរើសអើងដោយមិនត្រឹមត្រូវពីទីភ្នាក់ងាររដ្ឋ អាចប្ដឹងទៅតុលាការរដ្ឋបាល ដែលជាហេតុធ្វើឱ្យតុលាការនេះក្លាយទៅជាកន្លែងសំខាន់ សម្រាប់សាធារណជនក្នុងការពិនិត្យមើលចំណាត់ការរបស់រដ្ឋ។

**ការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO)** បំពេញមុខងារជាអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុសម្រាប់ទីភ្នាក់ងារអនុវត្តន៍ច្បាប់នៅថៃ។ ក្នុងភារកិច្ចបែបនេះ មុខងារចម្បងនៃការិយាល័យនេះ គឺត្រូវប្រមែប្រមូល និងវិភាគរបាយការណ៍ផ្សេងៗ ដែលស្ថាប័នហិរញ្ញវត្ថុ និងប្រភពព័ត៌មានផ្សេងទៀតបានដាក់ជូនការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO) ដើម្បីកំណត់ប្រធានបទសម្រាប់ធ្វើការស៊ើបអង្កេត។ អំពើពុករលួយគឺជាបទុកមួយក្នុងចំណោមបទុកទាំងប្រាំពីរ ដែលច្បាប់ប្រឆាំងនឹងការលាងលុយកខ្វក់ ឆ្នាំ១៩៩៩ បានចែង។ ការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO) មានអំណាចបញ្ឈប់ប្រតិបត្តិការរបស់ធានាគារលើករណីដែលមានការសង្ស័យ ដោយអនុលោមតាមច្បាប់ប្រឆាំងនឹងការលាងលុយកខ្វក់។ ការិយាល័យនេះត្រូវទទួលខុសត្រូវចំពោះក្រុមប្រឹក្សាភិបាលមួយ ដែលគ្រប់គ្រងដោយនាយករដ្ឋមន្ត្រី។ ការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO) ទទួលខុសត្រូវធ្វើការស៊ើបអង្កេត ដែលអាចនាំទៅដល់ការឃាត់ទុក និងរឹបអូសទ្រព្យដែលបានមកដោយសារផលនៃការប្រព្រឹត្តិបទល្មើសដោយសន្មត់។ ការទទួលខុសត្រូវថែមទៀតនៃការិយាល័យប្រឆាំងនឹងការលាងលុយកខ្វក់ (AMLO) គឺការអប់រំសាធារណជន និងផ្នែកឯកជន អំពីច្បាប់ស្ដីពីការប្រឆាំងនឹងការលាងលុយកខ្វក់។

ព្រះរាជក្រឹត្យស្ដីពីអភិបាលកិច្ចល្អត្រូវបានចាត់តាំងការងារទៅឱ្យ**ក្រុមប្រឹក្សាផ្ដល់យោបល់កិច្ចការសង្គមកិច្ចនិងសេដ្ឋកិច្ច (NSEAB)** ផងដែរ ក្នុងការបង្កើត និងសម្រួលសហប្រតិបត្តិការរវាងរដ្ឋាភិបាល អាជីវកម្ម និងសាធារណជនទូទៅ ក្នុងការបង្កើតអភិបាលកិច្ចល្អសមស្រប។ ក្រុមប្រឹក្សាផ្ដល់យោបល់កិច្ចការសង្គមកិច្ចនិងសេដ្ឋកិច្ច (NSEAB) គឺជាអង្គដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ដែលមានសមាជិក ៩៩នាក់ ជ្រើសរើសចេញពីមុខអាជីពខុសៗគ្នា។ ក្រុមប្រឹក្សានេះ គឺជាបណ្ដាញជាផ្លូវការមួយរបស់ពលរដ្ឋក្នុងការបញ្ចេញសម្លេងទៅកាន់គណៈរដ្ឋមន្ត្រី។ ក្រុមប្រឹក្សានេះបានបង្កើតក្រុមការងារផ្ទៃក្នុងប្រឆាំងនឹងអំពើពុករលួយ។ គណៈរដ្ឋមន្ត្រីត្រូវបានតម្រូវឱ្យឆ្លើយតបទៅនឹងការសាកសួរដេញដោល ឬអនុសាសន៍របស់ក្រុមប្រឹក្សា ក៏ប៉ុន្តែមិនចាំបាច់ធ្វើតាមអនុសាសន៍ដែលបានផ្ដល់ជូននោះទេ។

## មេរៀនដែលទទួលបាន

ឯករាជភាពនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) ពីអង្គនីតិប្រតិបត្តិ បានធ្វើឱ្យមានភាពប្រសើរឡើងដល់ប្រតិបត្តិការរបស់គណៈកម្មការនេះ ជាពិសេស នៅពេលដែលគណៈកម្មការនេះត្រូវផ្ទៀងផ្ទាត់សេចក្ដីប្រកាសទ្រព្យសកម្ម និងទ្រព្យអកម្មរបស់បុគ្គលដែលកាន់កាប់តំណែងនយោបាយ។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) ក៏មានយុត្តាធិការធំទូលាយជាងយុត្តាធិការនៃអតីតការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) ផងដែរ ព្រោះ (OCCC) អាចធ្វើអន្តរាគមន៍បានក្រោយពេលដែលមានការចោទប្រកាន់ពីអំពើពុករលួយទៅលើមន្ត្រីរដ្ឋ។ ការបញ្ជូនទៅតុលាការធម្មនុញ្ញនូវរឿងដែលពាក់ព័ន្ធនឹងសេចក្ដីប្រកាសអំពីទ្រព្យសម្បត្តិរបស់អ្នកនយោបាយជាន់ខ្ពស់បានពង្រឹងទំនុកចិត្តរបស់ពលរដ្ឋទៅលើគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC)។

ជាក់ច្បាស់ណាស់ ថ្វីបើបំពេញតួនាទីមួយដ៏សំខាន់ក៏ដោយ ក៏គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមិនមែនជាស្ថាប័នតែមួយ ដែលប្រយុទ្ធនឹងអំពើពុករលួយនោះទេ។ ដូចគ្នានឹងករណីនៅក្នុងប្រទេសផ្សេងទៀតដែរ បទពិសោធរបស់ថៃបានបង្ហាញថា អង្គការតែមួយ ទោះបីជាមានឯករាជភាពនិងមានប្រសិទ្ធិភាពខ្ពស់ យ៉ាងណាក៏ដោយ ប្រហែលជាមិនបានទទួលជោគជ័យឡើយ ប្រសិនបើមិនមានការបំពេញបង្គ្រប់ដោយគោលការណ៍ច្បាប់ និងស្ថាប័នទូលំទូលាយទេនោះ។ ប្រទេសថៃបានតាក់តែងយន្តការស្ថាប័ន និងយន្តការច្បាប់ ដែលតាមរយៈយន្តការទាំងនេះ អំពើពុករលួយអាចត្រូវបានចាប់ផ្ដើមដោះស្រាយចេញពីទស្សនៈខុសៗគ្នា រួមទាំងកិច្ចប្រឹងប្រែងជាដុំកំភួននៅក្នុងកំណែទម្រង់ផ្នែកសាធារណៈ ព្រមទាំងតួនាទីសំខាន់ដែលត្រូវចាត់តាំងទៅឱ្យការិយាល័យគណៈកម្មការសេវាសាធារណៈផងដែរ។ ក៏ប៉ុន្តែ គោលការណ៍ដ៏ទូលំទូលាយនេះតម្រូវឱ្យមានយន្តការសម្របសម្រួលដែលមានប្រសិទ្ធភាពផងដែរ។ យ៉ាងណាក៏ដោយ ហាក់ដូចជាមានកង្វះនៃកិច្ចសម្របសម្រួលកាន់តែកើនឡើង ដោយហេតុថាបច្ចុប្បន្ននេះ ស្ថាប័នជាច្រើនបានប្រគល់ភារកិច្ចឱ្យសម្របសម្រួលសកម្មភាពប្រយុទ្ធនឹងអំពើពុករលួយដោយផ្ទាល់ឬដោយប្រយោល (គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) ការិយាល័យគណៈកម្មការក្រសួងស៊ីវិល (OCSC) ក្រុមប្រឹក្សាផ្ដល់យោបល់កិច្ចការសង្គមកិច្ចនិងសេដ្ឋកិច្ច (NSEAB))។

បន្ថែមទៅនឹងបណ្ដាញដ៏ទូលំទូលាយនៃស្ថាប័នរដ្ឋ បទពិសោធរបស់ថៃផ្ដោតទៅលើតម្រូវការឱ្យមានភាពជាដៃគូយ៉ាងមានប្រសិទ្ធភាពផងដែរ រវាងអាជ្ញាធរពាក់ព័ន្ធ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ពលរដ្ឋអាចធ្វើបណ្ដឹងតវ៉ា និងដាក់ពាក្យប្ដឹងពីការប្រព្រឹត្តិពុករលួយទៅគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ការិយាល័យអ្នកការពារពលរដ្ឋ ឬតុលាការរដ្ឋបាល ឬទៅព្រឹទ្ធសភា (ដោយប្រមូលផ្ដុំហត្ថលេខាឱ្យបានយ៉ាងតិច ៥០.០០០ ដើម្បីធ្វើញត្តិទៅប្រធានព្រឹទ្ធសភា ជំទាស់នឹងអ្នកនយោបាយ និងមន្ត្រីរដ្ឋជាន់ខ្ពស់[១២] ដែលអាកប្បកិរិយា និងទ្រព្យរបស់គាត់ ស្ដែងឱ្យឃើញពីការអនុវត្តអំពើពុករលួយ និង/ឬបំពានអំណាចសាធារណៈ)។ ការចាប់ខ្លួនថ្មីៗនេះនៅក្នុងក្រុងបាងកក កាលពីថ្ងៃទី ៣០ ខែតុលាឆ្នាំ ២០០៤ នៃអតីតរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលបានគេចខ្លួនពីសវនាការនៅតុលាការកំពូល (ក្នុងឆ្នាំ ២០០៣) គឺជាឧទាហរណ៍មួយ ដែលបង្ហាញពីកិច្ចសហការយ៉ាងជោគជ័យរវាងគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ និងសង្គមស៊ីវិល (នៅក្នុងករណីនេះគឺបណ្ដាញប្រឆាំងនឹងអំពើពុករលួយ)។

---

[១២] តំណែងទាំង ១៧ ដែលអាចប្ដឹងញត្តិជំទាស់បាន មានចែងនៅក្នុងច្បាប់អង្គការស្ដីពីការប្រឆាំងនឹងអំពើពុករលួយ។

ក៏ប៉ុន្តែ ថ្វីបើឯករាជភាពនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ បានបញ្ជាក់ថាបានជោគជ័យនៅក្នុងការចោទប្រកាន់ជាផ្លូវការនៅក្នុងរឿងក្តីអំពើពុករលួយដោយមន្ត្រីជាន់ខ្ពស់ ដែលមិនធ្លាប់មានពីមុននៅក្នុងប្រទេសក៏ដោយ ក៏កង្វះនៃការឃ្លាំមើលដោយតំណាងពីសង្គមស៊ីវិល គឺជាចំណុចនៃកង្វល់ផងដែរ។ ថ្វីបើសង្គមស៊ីវិលបានសហការយ៉ាងសកម្មជាមួយនឹងគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏យន្តការឃ្លាំមើល នៅតែខ្វះនៅឡើយ។ ទីមួយ តំណាងសង្គមស៊ីវិលមិនអាចដាក់ពាក្យសុំធ្វើជាសមាជិកនៃ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ។ ទីពីរ ច្បាប់ស្តីពីគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ អនុញ្ញាតឱ្យធ្វើបណ្តឹងចោទសមាជិកនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយទៅសភាតំណាងរាស្ត្រ ឬព្រឹទ្ធសភាប៉ុណ្ណោះ ក៏ប៉ុន្តែមិនមែនដោយអ្នកបោះឆ្នោតចំនួន ៥០.០០០ នាក់ដោយផ្ទាល់នោះទេ ដូចជាករណីនៃមន្ត្រីជាន់ខ្ពស់ផ្សេងទៀត។

គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) មានអំណាចផ្តួចផ្តើមដំណើរការដាក់បណ្តឹងអាជ្ញាបទព្រហ្មទណ្ឌអំពីអ្នកនយោបាយ ទីប្រឹក្សានៃអ្នកនយោបាយ និងមន្ត្រីជាន់ខ្ពស់ ក៏ប៉ុន្តែគណៈកម្មការនេះខ្វះបុគ្គលិក និងធនធានសម្រាប់បំពេញកិច្ចការនេះ។ សមត្ថភាពនៅតែជាបញ្ហាធ្ងន់ធ្ងរដែលជាកង្វល់នៅឡើយ ហើយគឺជាហេតុផលចម្បងមួយនៃការកកស្ទះសំណុំរឿងពុករលួយនៅពេលបច្ចុប្បន្ននេះ។ នៅពេលដែលការិយាល័យគណៈកម្មការប្រឆាំងនឹងអំពើពុករលួយ (OCCC) ត្រូវបានជំនួសដោយគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) រឿងដែលរង់ចាំការកាត់សេចក្តីមានប្រហែល ៣.០០០ រឿង។ បច្ចុប្បន្ននេះ រឿងដែលរង់ចាំការកាត់សេចក្តី បានកើនឡើងប្រហែលជិត ៥.០០០ រឿង។ អាណត្តិការងារនៃគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ គ្របដណ្តប់លើបុគ្គលកាន់តំណែងនយោបាយនៅគ្រប់កម្រិតទាំងអស់ រួមទាំងថ្នាក់មូលដ្ឋាន និងមន្ត្រីរាជការគ្រប់កម្រិតទាំងអស់។ ដោយមានបុគ្គលិកប្រហែល ៥០០នាក់ សម្រាប់បម្រើប្រជាពលរដ្ឋទាំងអស់ចំនួន ៦៥លាននាក់ វាស្ទើរតែមិនអាចឱ្យគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ (NCCC) បំពេញភារកិច្ចតាមអាណត្តិការងារទាំងស្រុងរបស់គណៈកម្មការនេះបាន[១៣]។ បច្ចុប្បន្ននេះ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយកំពុងតែរៀបចំបង្កើតឱ្យមានយន្តការសម្រាំងមួយនៅក្នុងក្រសួងនីមួយៗ មុននឹងរឿងពុករលួយណាមួយត្រូវបញ្ជូនទៅគណៈកម្មការ (NCCC)។

បញ្ហាសមត្ថភាពក៏កាន់តែធ្ងន់ធ្ងរឡើង ដោយសារហេតុថា សេចក្តីប្រកាសអំពីទ្រព្យសម្បត្តិរបស់មន្ត្រីដែលមិនមែនជាសមាជិកគណៈរដ្ឋមន្ត្រី ត្រូវបានច្បាប់ចាត់ថាជាការសម្ងាត់។ ដូច្នេះ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមិនអាចជួលបុគ្គលិក ឬស្ថាប័នពីក្រៅឱ្យជួយនៅក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃសេចក្តីប្រកាសទ្រព្យទាំងនោះឡើយ។

ដោយសារតែកង្វះសមត្ថភាព និងធនធានមនុស្សមិនគ្រប់គ្រាន់នេះហើយ ទើបគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយមិនអាចឈោងដល់ពលរដ្ឋដែលរាយការណ៍អំពីអំពើពុករលួយនោះ។ ភាពគ្មានប្រសិទ្ធភាពនៃកម្មវិធីអ្នកបង្ហើបប្រាប់ពីអំពើពុករលួយរបស់គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ បានកាត់បន្ថយការចូលរួមរបស់ពលរដ្ឋ។ គណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ ក៏ត្រូវលើកស្ទួយការកសាងសមត្ថភាពប្រយុទ្ធនឹងឧក្រិដ្ឋកម្មសេដ្ឋកិច្ចផងដែរ។ ក៏ប៉ុន្តែ ថ្វីបើគណៈកម្មការជាតិប្រឆាំងនឹងអំពើពុករលួយ បានផ្តល់អនុសាសន៍ដល់ទីភ្នាក់ងាររដ្ឋក៏ដោយ ដោយសារតែខ្វះបុគ្គលិកដែលបានហ្វឹកហ្វឺន ក៏គណៈកម្មការនេះមិនអាចធ្វើដូច្នេះបានទេ ចំពោះក្រុមហ៊ុនអាជីវកម្មឯកជន ដែលខុសគ្នាពីគណៈកម្មការឯករាជប្រឆាំងនឹងអំពើពុករលួយនៅហុងកុង ICAC។ ដោយទទួលស្គាល់ថា អំពើពុករលួយត្រូវបានគេមើលឃើញកាន់តែច្រើនឡើងថាជាឧក្រិដ្ឋកម្មឆ្លងកាត់ពីជាតិមួយទៅជាតិមួយ ដែលត្រូវតែចាប់ផ្តើមដោះស្រាយនៅកម្រិតតំបន់ និងនៅទូទាំងពិភពលោក កិច្ចព្រមព្រៀងអន្តរជាតិនានាត្រូវបានធ្វើឡើងដើម្បីរួមកម្លាំងគ្នា (ឧទាហរណ៍ ឆ្នាំមុននេះ ប្រទេសថៃ និងប្រទេសវៀតណាមបានចុះកតិកាសញ្ញាប្រឆាំងនឹងការលាងលុយកខ្វក់)។

---

[១៣] គណៈកម្មការឯករាជប្រឆាំងនឹងអំពើពុករលួយនៅហុងកុង មានបុគ្គលិកប្រហែល ១.៣០០នាក់ បើប្រៀបធៀបទៅនឹងចំនួនពលរដ្ឋ ដែលមានតែប្រាំមួយលានប្រាំបីសែននាក់ប៉ុណ្ណោះ។

## ប្រភព

- Phongpaichit និង Piriyarangsan S. អំពើពុករលួយនិងប្រជាធិបតេយ្យនៅថៃ សាកលវិទ្យាល័យជូឡាឡុងកន ឆ្នាំ ១៩៩៤ (បោះពុម្ពឡើងវិញ ឆ្នាំ ២០០១)។
- ការិយាល័យជាតិប្រឆាំងនឹងអំពើពុករលួយ  កូនសៀវភៅព័ត៌មាន។
- វិទ្យាស្ថានស្រាវជ្រាវការអភិវឌ្ឍថៃ ឆ្នាំ ២០០០ រដ្ឋធម្មនុញ្ញថៃ និងយន្តការថ្មីសម្រាប់សង្គម ដែលមានតម្លាភាព និងប្រឆាំងនឹងអំពើពុកករលួយ។
- តម្លាភាពអន្តរជាតិ ២០០៣ របាយការណ៍សកលអំពីអំពើពុករលួយ ឆ្នាំ ២០០៣។
  *http://www.globalcorruptionreport.org/gcr2003.htm*

ព័ត៌មានប្រមែប្រមូលផងដែរពីប្រព័ន្ធវេបសាយនៃ OECD និងតម្លាភាពអន្តរជាតិ ក៏ដូចជាពីប្រព័ន្ធវេបសាយរបស់ស្ថាប័នផ្សេងៗ ដែលបានរៀបរាប់ខាងលើ។

# សាធារណរដ្ឋរួមតង់ហ្សានី



## ស្ថាប័នសំខាន់ៗនៃប្រព័ន្ធសច្ចធម៌ថ្នាក់ជាតិ

- គណៈកម្មការសិទ្ធិមនុស្សនិងអភិបាលកិច្ចល្អ
- ការិយាល័យជាតិសវនកម្ម
- ការិយាល័យប្រធានាធិបតី *http://www.tanzania.go.tz/government*
- នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ (PCB) *http://www.tanzania.go.tz/pcb/*
- លេខាធិការដ្ឋានសីលធម៌សម្រាប់អ្នកដឹកនាំសាធារណៈ

## បទបញ្ញត្តិចម្បង

- ច្បាប់ស្តីពីការត្រួតពិនិត្យសេដ្ឋកិច្ចនិងឧក្រិដ្ឋកម្មអង្គការចាត់តាំង ឆ្នាំ ១៩៨៤
- ច្បាប់ស្តីពីការបង្កើត គណៈកម្មការសិទ្ធិមនុស្សនិងអភិបាលកិច្ចល្អ ឆ្នាំ ២០០២
- ច្បាប់វិសោធនកម្មស្តីពីការទប់ស្កាត់អំពើពុករលួយ លេខ ២ ឆ្នាំ ១៩៧៤
- ច្បាប់វិសោធនកម្មស្តីពីការទប់ស្កាត់អំពើពុករលួយ លេខ ២០ ឆ្នាំ ១៩៩០
- ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ លេខ ១៦ ឆ្នាំ ១៩៧១
- ច្បាប់ស្តីពីក្រមសីលធម៌សម្រាប់អ្នកដឹកនាំសាធារណៈ លេខ ១៣ ឆ្នាំ ១៩៩៥

## សាវតា

តង់ហ្សានី ធ្លាប់មានឈ្មោះល្បីថាជាប្រទេសក្រីក្រ ប៉ុន្តែ ជាប្រទេសដែលគ្មានអំពើពុករលួយ ។ ក្រោមរបបសង្គមនិយមក្រោយឆ្នាំ ១៩៦៧ មន្ត្រីសាធារណៈត្រូវបានអនុញ្ញាតឱ្យមានផ្ទះតែមួយ និងឱ្យប្រើប្រាស់រថយន្តសមល្មមតែប៉ុណ្ណោះ ។ ការងារប្រយុទ្ធនឹងអំពើពុករលួយត្រូវបានបំពេញដោយក្រសួងមហាផ្ទៃ ដោយនាយកដ្ឋានកម្លាំងប៉ូលីស ដែលមានភារកិច្ចធ្វើការស៊ើបអង្កេត និងដាក់បណ្តឹងអាជ្ញាប្រឆាំងនឹងបទល្មើសពុករលួយ ។ ក៏ប៉ុន្តែ ផលវិបាកនៃសេដ្ឋកិច្ចបង្គាប់បញ្ជា បានផ្តើមលេចចេញនូវសក្ខីភាពនៃឯកាធិភាពនៅក្នុងផ្នែកសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសធំធេងដល់ការកំហែងយកប្រាក់ ។ ដើម្បីប្រយុទ្ធនឹងកម្រិតនៃអំពើពុករលួយដែលកាន់តែកើនឡើង ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយត្រូវបានអនុម័តក្នុងឆ្នាំ១៩៧១ ។ បន្ទាប់មកមានការបង្កើត**ក្រុមប្រឆាំងនឹងអំពើពុករលួយ (ACS)** ក្នុងឆ្នាំ ១៩៧៥ ដោយប្រធានាធិបតី Julius Nyerere តាមច្បាប់វិសោធនកម្មស្តីពី ការទប់ស្កាត់អំពើពុករលួយ (ឆ្នាំ ១៩៩៤) ។ ដើមឡើយ ក្រុមប្រឆាំងនឹងអំពើពុករលួយ (ACS) ស្ថិតនៅក្រោមក្រសួងមហាផ្ទៃ ។ យ៉ាងណាក៏ដោយ ក្នុងកិច្ចប្រឹងប្រែងធ្វើឱ្យក្រុមប្រឆាំងនឹងអំពើពុករលួយមានឯករាជភាពពេញលេញក្នុងការបំពេញភារកិច្ចរបស់ខ្លួន ការត្រួតមើលក្រុមប្រឆាំងនឹងអំពើពុករលួយត្រូវបានផ្ទេរទៅឱ្យការិយាល័យនាយករដ្ឋមន្ត្រី និងបន្ទាប់មកផ្ទេរទៅឱ្យការិយាល័យប្រធានាធិបតី ។

នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ ថ្វីបើមានបង្កើតក្រុមប្រឆាំងនឹងអំពើពុករលួយ (ACS) ក៏ដោយ ក៏អំពើពុករលួយមានលក្ខណៈខ្លាំងក្លា ជាពិសេសនៅក្នុងក្រសួងប៉ូលីស ហើយការឆក់ប្លន់ទ្រព្យសម្បត្តិ និងការរត់ពន្ធមាននៅពាសវាលពាសកាល។ នៅក្នុងឆ្នាំ ១៩៨៤ រដ្ឋាភិបាលបាន អនុម័តច្បាប់ស្តីពីការត្រួតពិនិត្យសេដ្ឋកិច្ច និងឧក្រិដ្ឋកម្មអង្គការចាត់តាំង ដែលដាក់បទល្មើសក្រោមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ក្លាយទៅជាឧក្រិដ្ឋកម្មសេដ្ឋកិច្ច។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០ កម្រិតនៃអំពើពុករលួយនៅតែកើនឡើង ដោយមានអំពើពុករលួយតិចតួចនៅគ្រប់ ផ្នែកទាំងអស់នៃសេដ្ឋកិច្ច និងសេវាសង្គម។ កម្រិតខ្ពស់នៃរដ្ឋាភិបាល និងសេវាសាធារណៈត្រូវបានប៉ះពាល់ដោយអំពើពុករលួយផងដែរ (រដ្ឋាភិបាលតង់ហ្សានី ឆ្នាំ ១៩៩៦)។

នៅដើមទសវត្សរ៍ឆ្នាំ ១៩៩០ រដ្ឋាភិបាលបានចាប់ផ្តើមព្យាបាលជម្ងឺនៃអំពើពុករលួយជាបន្តបន្ទាប់ ដោយផ្តោតយ៉ាងខ្លាំងទៅលើការលើកស្ទួយការចូលរួមរបស់ពលរដ្ឋ ឧទាហរណ៍ រាយការណ៍ពីអ្នកប្រព្រឹត្តខុស ក៏ដូចជាយុទ្ធនាការធ្វើឱ្យមានភាពប្រសើរឡើងដល់ទំនាក់ទំនងរវាងប៉ូលីស និងសេវាសាធារណៈ។ នេះរួមមាន ផ្តល់ការលើកទឹកចិត្តដល់ការរាយការណ៍អំពីទំនិញរត់ពន្ធ ឬរបស់ចោរលួច/ប្លន់ និងមន្ត្រីប៉ូលីសត្រូវបានលើក ទឹកចិត្តមិនឱ្យទទួលយកសំណូកទាំងនោះ។ ថ្វីបើគេជឿថា យុទ្ធនាការទាំងនេះបានបណ្តាលឱ្យមានការកាត់បន្ថយអំពើពុករលួយខ្លះៗក៏ដោយ ក៏ការអនុវត្តយុទ្ធសាស្ត្រនេះបានជួបប្រទះឧបគ្គជាច្រើន។ អំពើពុករលួយនៅក្នុងលទ្ធកម្មនៅតែខ្ពស់នៅឡើយ មូលនិធិពីសប្បុរសជន និងពីអង្គការ មិនមែនរដ្ឋាភិបាល នៅតែបន្តផ្ទេរចូលទៅក្នុងគណនីឯកជន និងមានការគេចពន្ធដារក្នុងកម្រិតខ្ពស់។ បន្ថែមលើនេះ ចំណាត់ការរបស់តុលាការ មានភាពយឺតយ៉ាវនៅឡើយ និងមានការខកខានផ្តួនៗគ្នាក្នុងការដាក់ទណ្ឌកម្មជនដែលតុលាការរកឃើញថាមានកំហុស។ នៅក្នុងឆ្នាំ ១៩៩១ ក្រុមប្រឆាំងនឹងអំពើពុករលួយ ACS ត្រូវបានដូរឈ្មោះទៅជា **នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ (PCB)** ដោយមានបំណងបង្កើតឱ្យមានស្ថាប័ន ដែលអាចអនុវត្តលំនាំដោះស្រាយតាមបែបវិទ្យាសាស្ត្រចំពោះការប្រយុទ្ធនឹងអំពើពុករលួយ។

អំពើពុករលួយគឺជាបញ្ហាចម្បងមួយនៅក្នុងការបោះឆ្នោតឆ្នាំ ១៩៩៥ ដែលជាការបោះឆ្នោតពហុបក្សលើកទីមួយនៅតង់ហ្សានី ហើយ បេក្ខជនដែលឈ្នះឆ្នោត បានបង្ហាញឧទាហរណ៍ ដោយបានធ្វើសេចក្តីប្រកាសទ្រព្យសម្បត្តិរបស់ខ្លួន និងរបស់គ្រួសារខ្លួននៅក្នុងយុទ្ធនាការ បោះឆ្នោត[១]។ ប្រធានាធិបតីថ្មីសម្រេចបង្កើត**គណៈកម្មការប្រធានាធិបតីសម្រាប់ស៊ើបអង្កេតអំពើពុករលួយ** (ដែលជាសាមញ្ញគេហៅថា គណៈកម្មការ (Warioba) ហើយនឹងបង្កើត**លេខាធិការដ្ឋានសីលធម៌សម្រាប់អ្នកដឹកនាំសាធារណៈ**ដែរ។

គណៈកម្មការ Warioba ត្រូវបានតែងតាំងនៅដើមឆ្នាំ ១៩៩៦ ដើម្បីធ្វើការរិះរកយ៉ាងខ្លាំងក្លាអំពីបញ្ហាអំពើពុករលួយនៅក្នុងប្រទេស និងចែងជាអនុសាសន៍សម្រាប់ចាត់វិធានការ។ របាយការណ៍របស់គណៈកម្មការរៀបរាប់យ៉ាងលម្អិតថា អំពើពុករលួយទាំងតូចទាំងធំបាន ជ្រួតជ្រាបនៅគ្រប់កម្រិតនៃសង្គម ដែលបង្កើតបានជាស្លាកស្នាមទុយិសដល់ក្រសួង នាយកដ្ឋាន និងទីភ្នាក់ងារ ដែលពាក់ព័ន្ធនឹងការអនុវត្ត ពុករលួយ។ អំពើពុករលួយដ៏ធំធេងនេះត្រូវបានពន្យល់ថា មួយផ្នែកមកពីប្រាក់បៀវត្សទាបនៅក្នុងក្រសួងស៊ីវិល ក៏ប៉ុន្តែ របាយការណ៍សន្និដ្ឋានថា ជនល្មើសដែលអាក្រក់បំផុត ជាក់ស្តែងគឺជាមន្ត្រីជាន់ខ្ពស់នៅក្នុងរដ្ឋាភិបាល។ គណៈកម្មការកំណត់ថា គឺជាការខ្វះសីលធម៌សម្រាប់អ្នកដឹកនាំ និង ការខកខានមិនបានដកមន្ត្រីជាន់ខ្ពស់ពុករលួយចេញពីតំណែងឬមិនបានកាត់ទោសមន្ត្រីទាំងនេះ ដែលជាមូលហេតុចម្បងនៃអំពើពុករលួយ។ រឿងនេះរួមផ្សំជាមួយនឹងការដែលភាគីពាក់ព័ន្ធមិនអើពើនឹងរបាយការណ៍របស់ពលរដ្ឋ អំពីឧប្បត្តិហេតុនៃអំពើពុករលួយ គឺជាមូលហេតុបណ្តាល ឱ្យពលរដ្ឋខ្វះទំនុកចិត្តទៅលើស្ថាប័នរដ្ឋ ជាពិសេសគឺ អង្គតុលាការ និងប៉ូលីស។ ម្យ៉ាងទៀត គណៈកម្មការបានរកឃើញថា នាយកដ្ឋានទប់ស្កាត់ អំពើពុករលួយភជពបានផ្តោតទៅលើការស៊ើបអង្កេត ជាជាងទប់ស្កាត់អំពើពុករលួយ។ របាយការណ៍រកឃើញផងដែរថា នាយកដ្ឋានទប់ស្កាត់ អំពើពុករលួយ PCB មានធនធានមិនគ្រប់គាន់ ដើម្បីបំពេញអាណត្តិការងាររបស់ខ្លួន ដោយមានប្រសិទ្ធភាព (រដ្ឋាភិបាលតង់ហ្សានី ឆ្នាំ ១៩៩៦)។

បន្ទាប់ពីបានទទួលរបាយការណ៍របស់គណៈកម្មការមក រដ្ឋាភិបាលចាប់ផ្តើមបង្កើតយុទ្ធសាស្ត្រជាតិប្រឆាំងនឹងអំពើពុករលួយ។ ដំណើរការ នេះពាក់ព័ន្ធដល់ក្រសួងរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន សមាគមពលរដ្ឋ អ្នកផ្តល់អំណោយ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអង្គការសាសនា។ លទ្ធផលដែលកើតចេញពីដំណើរការតាមបែបចូលរួមបែបនេះ គឺយុទ្ធសាស្ត្រជាតិប្រឆាំងនឹងអំពើពុករលួយ និងផែនការ

[១] តាមច្បាប់ស្តីពីក្រមសីលធម៌សម្រាប់អ្នកដឹកនាំសាធារណៈ លេខ ១៣ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៥ គ្រប់អ្នកដឹកនាំទាំងអស់ត្រូវធ្វើសេចក្តី ប្រកាសអំពីទ្រព្យរបស់ខ្លួន។

សកម្មភាព ដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៩។ យុទ្ធសាស្ត្រនេះគ្របដណ្តប់គ្រប់ផ្នែកទាំងអស់ និងកំណត់គោលការណ៍បួនចំណុចសម្រាប់ប្រយុទ្ធនឹងអំពើពុករលួយ រួមមាន (១) ការទប់ស្កាត់ (២) ការអនុវត្ត (៣) ការយល់ដឹង និងការចូលរួមរបស់សាធារណជន និង (៤) ការកសាងសមត្ថភាពស្ថាប័ន។ យុទ្ធសាស្ត្របញ្ជាក់ផងដែរពីសារៈសំខាន់នៃឆន្ទៈនយោបាយសម្រាប់ជោគជ័យនៃវិធានការប្រឆាំងនឹងអំពើពុករលួយ។

តង់ហ្សានីត្រូវបានចាត់ថ្នាក់ជាប្រទេសទី ៨៨ ក្នុងចំណោមប្រទេសទាំង ១៥៩ នៅក្នុងសន្ទស្សន៍ឆ្នាំ ២០០៥ របស់អង្គការតម្លាភាពអន្តរជាតិ ស្តីពីទស្សនៈអំពីអំពើពុករលួយ។ ថ្វីបើប្រទេសនេះនៅតែប្រឈមមុខនឹងអំពើពុករលួយក្នុងកម្រិតខ្ពស់ ដែលជ្រួតជ្រាបចូលគ្រប់ផ្នែកនៃសង្គមក៏ដោយ ក៏តង់ហ្សានីបានបង្ហាញពីភាពប្រសើរឡើងចាប់ពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ ដែរ។

## អាណត្តិការងារ និងទំនាក់ទំនងការងារនៃស្ថាប័នប្រឆាំងអំពើពុករលួយសំខាន់ៗ

**នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ** (ជាឈ្មោះថ្មីនៃក្រុមប្រឆាំងនឹងអំពើពុករលួយ) ចាប់កំណើតនៅក្នុងឆ្នាំ ១៩៩១ តាមរយៈការជូនដំណឹងរបស់រដ្ឋាភិបាលលេខ ២៧/១៩៩១ ។ នាយកដ្ឋាននេះ ជាស្ថាប័នរដ្ឋាភិបាលពាក់កណ្តាលស្វយ័ត ដោយមានភារកិច្ចប្រយុទ្ធនឹងអំពើពុករលួយនៅលើទឹកដីតង់ហ្សានី ក្រោមការត្រួតមើលរបស់ការិយាល័យប្រធានាធិបតី។ នាយកដ្ឋាននេះត្រូវបានដឹកនាំដោយអគ្គនាយកម្នាក់ដែលទទួលខុសត្រូវផ្ទាល់ចំពោះប្រធានាធិបតី។ អគ្គនាយកមាននាយកបួននាក់ជាជំនួយការ (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PCA ផ្នែក ២/ក)។ ទាក់ទិននឹងកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCA អគ្គនាយកត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះលេខាធិការនាយកនៃការិយាល័យប្រធានាធិបតី។ អគ្គនាយកអនុញ្ញាតឱ្យមានការស៊ើបអង្កេតអំពីការអនុវត្តពុករលួយ ដែលពាក់ព័ន្ធដល់មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ គណៈបក្សនយោបាយ ស្ថាប័នសាធារណៈ និងផ្នែកឯកជន និងផ្តល់យោបល់ដល់ប្រធានាធិបតីអំពីវិធានការ ដែលត្រូវចាត់ក្រោយពីបានបញ្ចប់ការស៊ើបអង្កេតអំពីរឿងពុករលួយដែលត្រូវគេប្តឹង។

តាមច្បាប់វិសោធនកម្មស្តីពីការទប់ស្កាត់អំពើពុករលួយ PC[A]A/ផ្នែក ៣/ក(៣) មុខងារនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB មានដូចតទៅ:

- ចាត់វិធានការចាំបាច់ដើម្បី**ទប់ស្កាត់**អំពើពុករលួយនៅក្នុងផ្នែកសាធារណៈ រដ្ឋប្រតិព័ទ្ធ និងឯកជន។
- **ស៊ើបអង្កេត** ហើយនិងតាមការណែនាំរបស់នាយកមហាអយ្យការ ធ្វើបណ្តឹងអាជ្ញា (គឺប្តឹងចោទ) ចំពោះបទល្មើសដែលស្ថិតនៅក្រោមច្បាប់ស្តីពីការទប់ស្កាតអំពើពុករលួយ PCA និងបទល្មើសផ្សេងទៀត ដែលទាក់ទិននឹងប្រតិបត្តិការពុករលួយ។
- **ផ្តល់យោបល់**ដល់រដ្ឋាភិបាល អង្គការសាធារណៈ អង្គការសង្គមស៊ីវិល អង្គការរដ្ឋប្រតិព័ទ្ធ និងផ្នែកឯកជន អំពីវិធីនិងមធ្យោបាយទប់ស្កាត់អំពើពុករលួយ។

នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ចែកចេញជាបួនការិយាល័យ: (១) ការិយាល័យស៊ើបអង្កេត[២] (២) ការិយាល័យស្រាវជ្រាវ ត្រួតពិនិត្យ និងស្ថិតិ[៣] (៣) ការិយាល័យអប់រំសហគមន៍[៤] និង (៤) ការិយាល័យរដ្ឋបាល និងបុគ្គលិក[៥]។ ការិយាល័យនីមួយៗចែកចេញជាច្រើនផ្នែក។ មានអង្គភាពគណនី និង អង្គភាពសវនកម្មផ្ទៃក្នុង និងអង្គភាពបញ្ជីសម្ងាត់ផងដែរ។

---

[២] ការិយាល័យស៊ើបអង្កេតរួមមានផ្នែកស៊ើបអង្កេតផ្នែកសាធារណៈ ផ្នែកស៊ើបអង្កេតផ្នែកឯកជន ផ្នែកច្បាប់និងកាត់សេចក្តី និងផ្នែកសេវាទំនាក់ទំនងនិងបច្ចេកទេស។

[៣] ការិយាល័យស្រាវជ្រាវ ត្រួតពិនិត្យ និងស្ថិតិ រួមមានផ្នែកស្រាវជ្រាវ ផ្នែកត្រួតពិនិត្យ និងផ្នែកស្ថិតិ។

[៤] ការិយាល័យអប់រំសហគមន៍ រួមមានផ្នែកសម្ព័ន្ធការ/សម្របសម្រួល ផ្នែកអប់រំសាធារណៈ ផ្នែកបណ្ណាល័យ និងផ្នែក ផែនការ/ផ្គត់ផ្គង់ភស្តុភា។

[៥] ការិយាល័យរដ្ឋបាលនិងបុគ្គលិក រួមមានផ្នែករដ្ឋបាល ផ្នែកបុគ្គលិក និងផ្នែកហិរញ្ញវត្ថុ។

តាមច្បាប់ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB មានអំណាចស៊ើបអង្កេតអំពើពុករលួយគ្រប់ទម្រង់ទាំងអស់នៅក្នុងផ្នែកសាធារណៈ ផ្នែករដ្ឋប្រតិព័ទ្ធ ព្រមទាំងផ្នែកឯកជនផងដែរ។ អគ្គនាយកអាចយកមកកាន់កាប់ជំនួសប៉ូលីស នូវការស៊ើបអង្កេត ឬបណ្តឹងអាជ្ញាណាមួយ ដែលត្រូវបានចាប់ផ្តើមដោយប៉ូលីស ចំពោះបទល្មើសទាក់ទិននឹងអំពើពុករលួយ (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PCA ផ្នែក ២៤/៤)។ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ស្វាគមន៍ និងពិចារណាលើបណ្តឹងនានា រួមទាំងបណ្តឹងអនាមិកដែលបានដាក់ជូនផងដែរ។ ជាផ្នែកមួយនៃអំណាចស៊ើបអង្កេតរបស់ខ្លួន នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ផ្តួចផ្តើមការឃ្លាំមើលផងដែរ។ តាមការយល់ព្រមពីនាយកមហាអយ្យការ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB អាចធ្វើបណ្តឹងអាជ្ញា លើករណីពុករលួយផងដែរ។

មន្ត្រីនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ មានអំណាចក្នុងការបំពេញមុខងារ ដូចគ្នានឹងអំណាចរបស់មន្ត្រីប៉ូលីសដែរ[៦]។ អំណាចនេះ ជារួមមានអំណាចចាប់ខ្លួន អំណាចចូលទៅក្នុងបរិវេណ អំណាចឃុំឃ្លួនជនជាប់សង្ស័យ និងរឹបអូសយកទ្រព្យ កាលបើមានហេតុផលសង្ស័យថា បទល្មើសទាក់ទិននឹងអំពើពុករលួយ ត្រូវបានប្រព្រឹត្ត ឬប្រុងប្រៀបនឹងប្រព្រឹត្ត (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ផ្នែក ២៤/៤)។ បន្ថែមលើនេះ អគ្គនាយកអាចផ្តល់អំណាចស៊ើបអង្កេតពិសេស ដល់មន្ត្រីនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ ឧទាហរណ៍ ស៊ើបអង្កេតគណនីធនាគារ (ច្បាប់ស្តីពីការទប់ស្កាតអំពើពុករលួយ ផ្នែក ១២/១)។

នាយកដ្ឋានទប់ស្កាត់អំពើពុករលួយមានការិយាល័យប្រចាំតំបន់ផងដែរ ដែលដឹកនាំដោយនាយកនៃការិយាល័យតំបន់ ដែលត្រូវរាយការណ៍ផ្ទាល់ជូនអគ្គនាយក។ ការិយាល័យតំបន់មានភារកិច្ចទប់ស្កាត់ ស៊ើបអង្កេត និងអប់រំអំពីអំពើពុករលួយ។ យ៉ាងណាក៏ដោយ ការិយាល័យទាំងនេះមិនអាចផ្តើមចាត់ការ ឬលើកលែងចាត់ការរឿងអំពើពុករលួយណាមួយ ដោយគ្មានសេចក្តីណែនាំពីអគ្គនាយកបានឡើយ។ មានការិយាល័យប្រចាំស្រុកផងដែរ ។ ការិយាល័យទាំងនេះ ដឹកនាំដោយមន្ត្រីស៊ើបអង្កេតចំណាស់ៗ ហើយទទួលខុសត្រូវផ្ទាល់ចំពោះនាយកនៃការិយាល័យតំបន់។

## ការរៀបចំកិច្ចប្រតិបត្តិការ

ការបំពេញការងារនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ត្រូវស្ថិតនៅក្រោមការសង្កេតមើលរបស់**គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃ** និង**គណៈកម្មាធិការនាយក**។ គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃ ទទួលខុសត្រូវក្នុងការត្រួតមើលទូទៅលើការបំពេញការងារនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB។ គណៈកម្មាធិការនេះដឹកនាំដោយលេខាធិការនាយកនៃការិយាល័យប្រធានាធិបតី ជាមួយនឹងអគ្គនាយកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ អគ្គនាយកនៃប្រព័ន្ធស៊ើបការណ៍និងសន្តិសុខតង់ហ្សានី និងលេខាធិការផ្ទាល់របស់ប្រធានាធិបតីជាសមាជិកបន្ថែម។ នាយករដ្ឋបាលនិងបុគ្គលិកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ បំពេញមុខងារជាលេខាធិការ។ គណៈកម្មាធិការនាយកដឹកនាំដោយអគ្គនាយកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ដោយមាននាយកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយជាសមាជិក។ ប្រតិបត្តិការនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយត្រូវបានសង្កេតមើលដោយអគ្គសវនករផងដែរ។ របាយការណ៍របស់អគ្គសវនករត្រូវបានប្រកាសជាសាធារណៈ និងស្ថិតនៅក្រោមការវាយតម្លៃរបស់សាធារណជន។

ដូចបានលើកឡើងខាងលើ នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ អាចធ្វើបណ្តឹងអាជ្ញាចំពោះករណីពុករលួយ។ យ៉ាងណាក៏ដោយ ដើម្បីធ្វើដូច្នេះបាន នាយកដ្ឋានត្រូវស្វែងរកការយល់ព្រមពីនាយកមហាអយ្យការ (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ ផ្នែក ១៨)។ គឺផ្នែកច្បាប់ និងអយ្យការនៅក្នុងនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ ដែលមានភារកិច្ចធ្វើបណ្តឹងអាជ្ញាលើបទល្មើសពុករលួយ។ ក្នុងការធ្វើដូច្នេះ ផ្នែកនេះត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងប៉ូលីស ហើយនិងនាយកមហាអយ្យការ។ គ្មានបណ្តឹងអាជ្ញាណាមួយត្រូវបញ្ជូនទៅនាយកមហាអយ្យការ ដោយគ្មានការយល់ព្រមជាមុនពីគណៈកម្មាធិការនាយកនោះទេ។ បទល្មើសក្រោមច្បាប់ ស្តីពីការទប់ស្កាត់អំពើពុករលួយ ត្រូវកាត់ក្តីដោយតុលាការជាន់ខ្ពស់ (High Court) តុលាការជាន់ទាបបំផុត Court of Resident Magistrate ឬតុលាការថ្នាក់ស្រុក។

---

[៦] អំណាចដូចគ្នានឹងអំណាចដែលបានប្រគល់ឱ្យមន្ត្រីប៉ូលីសដែលមានឋានន្តរស័ក្តិស្មើនឹងអនុស្នងការប៉ូលីស ឬលើនេះ។

**ការិយាល័យអភិបាលកិច្ចល្អ** ដែលស្ថិតនៅក្នុង**ការិយាល័យប្រធានាធិបតី** មានភារកិច្ចៈ (១) អនុវត្ត និងសម្របសម្រួលយុទ្ធសាស្ត្រជាតិប្រឆាំងនឹងអំពើពុករលួយ និងផែនការសកម្មភាព (២) តាមសង្កេតមើលសីលធម៌នៃអ្នកដឹកនាំសាធារណៈ និងការបំពានអំណាច (៣) សម្របសម្រួលស្ថាប័នរដ្ឋ ដែលចូលរួមនៅក្នុងការប្រយុទ្ធនឹងអំពើពុករលួយ (៤) ពង្រឹងក្របខ័ណ្ឌច្បាប់ (គឺច្បាប់ប្រឆាំងនឹងអំពើពុករលួយ និងក្របខ័ណ្ឌសីលធម៌) និង (៥) ភ្ជាប់កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលជាមួយនឹងសង្គមស៊ីវិល (តាមរយៈការអប់រំកម្មវិធីទប់ស្កាត់អំពើពុករលួយ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានជាដើម)។ ក្នុងកិច្ចការបែបនេះ ការិយាល័យអភិបាលកិច្ចល្អមានការទទួលខុសត្រូវទូទៅក្នុងការសម្របសម្រួលការប្រយុទ្ធនឹងអំពើពុករលួយ។ យ៉ាងណាក៏ដោយ ការិយាល័យអភិបាលកិច្ចល្អ មានសមត្ថភាពតិចតួចក្នុងការបំពេញអាណត្តិការងារដ៏ធំធេងនេះ។

ច្បាប់ PLCE ឆ្នាំ ១៩៩៥ បានបង្កើតក្រមសីលធម៌សម្រាប់មន្ត្រីថ្នាក់ដឹកនាំសាធារណៈ (ដូចមានចែងនៅក្នុងច្បាប់) ព្រមទាំងតម្រូវឱ្យមន្ត្រីថ្នាក់ដឹកនាំសាធារណៈទាំងអស់រាយការណ៍អំពីទ្រព្យសម្បត្តិខ្លួន (រួមទាំងទ្រព្យសម្បត្តិសមាជិកគ្រួសារខ្លួនទាំងអស់)។ លេខាធិការដ្ឋានក្រមសីលធម៌សម្រាប់មន្ត្រីថ្នាក់ដឹកនាំសាធារណៈ មានភារកិច្ចទទួលរបាយការណ៍ទាំងនេះ ព្រមទាំងមានភារកិច្ចប្រាប់ឱ្យដឹងអំពីការរំលោភលើក្រមសីលធម៌ដែលប្រព្រឹត្តដោយមន្ត្រីទាំងនោះ និងសួរដេញដោលលើករណី ដែលគេចោទប្រកាន់ ឬដែលគេសង្ស័យអំពីការរំលោភបំពានលើក្រមសីលធម៌ ដូចមានចែងនៅក្នុងច្បាប់ PLCE ផ្នែក១៩ [២] ដែលប្រព្រឹត្តដោយមន្ត្រីទាំងនោះ។ លេខាធិការដ្ឋានក្រមសីលធម៌ត្រូវបានបង្កើតឡើងដោយអនុលោមតាមផ្នែក ១៣២ នៃរដ្ឋធម្មនុញ្ញ។ នៅក្នុងលេខាធិការដ្ឋាននេះ ការិយាល័យស្នងការសីលធម៌ ដែលបម្រើការជានាយកការិយាល័យត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ ដោយអនុលោមតាមផ្នែក២០ នៃច្បាប់ PLCE។ ស្នងការត្រូវរាយការណ៍ជូន និងបានតែងតាំងដោយប្រធានាធិបតី ។

ដូចដែលមានចែងនៅផ្នែក ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PCA ប្រសិនបើមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រធានាធិបតី ពីអគ្គមេធាវី ឬពីអគ្គនាយកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB មន្ត្រីសាធារណៈណាក៏ដោយ ក៏អាចត្រូវបានតម្រូវឱ្យផ្តល់របាយការណ៍អំពីទ្រព្យទាំងអស់ដែលខ្លួនកាន់កាប់ ព្រមទាំងទ្រព្យដែលគ្រួសារ ឬអ្នកសេពគប់ជាមួយខ្លួនបានកាន់កាប់។ ប្រសិនបើមន្ត្រីសាធារណៈនោះត្រូវបានគេរកឃើញថាមានកាន់កាប់ទ្រព្យសម្បត្តិ ដែលគេសង្ស័យថាបានមកដោយពុករលួយ សាម៉ីជនត្រូវពន្យល់អំពីរឿងនេះ។ ប្រសិនបើមន្ត្រីសាធារណៈនោះមិនអាចផ្តល់ចម្លើយឱ្យបានពេញចិត្តនោះទេ សាម៉ីជនត្រូវមានទោសថាបានប្រព្រឹត្តបទល្មើស តាមច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PCA ហើយតុលាការអាចបញ្ជាឱ្យដកហូតយកទ្រព្យដែលបានមកដោយមធ្យោបាយពុករលួយ (ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PCA ផ្នែក ៩)។

**គណៈកម្មការសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អ** ដែលបង្កើតឡើងក្នុងឆ្នាំ ២០០២ បំពេញមុខងារជាអ្នកការពារពលរដ្ឋ (ជាជំនួសគណៈកម្មការអចិន្ត្រៃយ៍ស៊ើបអង្កេតពីមុន)។ គណៈកម្មការមានភារកិច្ចពិចារណាលើបណ្តឹងតវ៉ាអំពីការបំពានអំណាច រួមទាំងការរំលោភសិទ្ធិមនុស្សផងដែរ។ ថ្មីៗនេះ គណៈកម្មការបានបញ្ជាក់ពីសមត្ថភាពរបស់ខ្លួន ដោយប្រឈមមុខជាមួយនឹងរដ្ឋាភិបាលនៅក្នុងរឿងក្តីមួយ ដែលប្តឹងដោយសមាជិកជាច្រើននៃភូមិមួយនៅ Serengeti ដែលត្រូវអាជ្ញាធរស្រុកដកចេញដោយបង្ខំ។ រឿងក្តីនេះមានមនុស្សតាមមើលច្រើនណាស់ ហើយគណៈកម្មការបានទទួលការគោរពពីសាធារណជន ដោយសារតែសេចក្តីសម្រេចរបស់គណៈកម្មការ ដែលមានភាពរសើបខាងផ្នែកនយោបាយ ប៉ុន្តែត្រូវបានមតិមហាជនយល់ថា សេចក្តីសម្រេចនេះត្រឹមត្រូវ និងយុត្តិធម៌។

**ការិយាល័យជាតិសវនកម្ម** គឺជាស្ថាប័នសវនកម្មកំពូលនៅក្នុងប្រទេស។ ការិយាល័យនេះ រួមជាមួយនឹងក្រុមប្រឹក្សាជាតិគណនេយ្យករ និងសវនករ បានចេញក្រមសីលធម៌សម្រាប់សមាជិករបស់ខ្លួន ដោយមានបំណងបង្កើតឱ្យមានការប្រព្រឹត្តិក្នុងមុខអាជីព ដែលនឹងនាំទៅដល់ការកាត់បន្ថយការអនុវត្តមិនត្រឹមត្រូវ រួមទាំងអំពើពុករលួយផង។ មុខអាជីពនេះ គឺស្ថិតនៅជួរមុខផងដែរ ស្តីពីការលើកស្ទួយការអនុវត្តយ៉ាងប្រសើរនៅក្នុងអភិបាលកិច្ចសម្រាប់ក្រុមអ្នកដឹកនាំនៅក្នុងប្រទេស។ ក្រុមប្រឹក្សាជាតិគណនេយ្យករ និងសវនករ គឺជាសមាជិកស្ថាបនិកមួយនៃវិទ្យាស្ថានអភិបាលកិច្ចសាជីវកម្មតង់ហ្សានី ដែលជាស្ថាប័នផ្នែកឯកជន ដែលថ្មីៗនេះបានចាប់ផ្តើមដឹកនាំផ្សព្វផ្សាយបញ្ហាអភិបាលកិច្ចសាជីវកម្មនេះនៅក្នុងប្រទេស។

## មេរៀនដែលទទួលបាន

មូលហេតុចម្បងមួយក្នុងចំណោមមូលហេតុចម្បងនានានៅតង់ហ្សានី ដូចដែលគណៈកម្មការ Warioba បានកត់សម្គាល់ គឺឧទាហរណ៍ស្តីអំពីអ្នកដឹកនាំដែលបានបង្ហាញឱ្យឃើញនៅភាពទន់ខ្សោយក្នុងការប្រយុទ្ធនឹងអំពើពុករលួយ។ ដូចដែលបានលើកឡើងពីខាងដើម អំពើពុករលួយធ្វើឱ្យប៉ះពាល់ដល់ប្រទេសនេះនៅគ្រប់កម្រិតទាំងអស់ ហើយថ្នាក់ដឹកនាំបានប្រឹងប្រែងដោះស្រាយបញ្ហាពុករលួយតិចតួចណាស់។ លើសពីនេះទៀត នៅពេលដែលសាធារណជនរាយការណ៍ពីមន្ត្រីពុករលួយថ្នាក់ទាបនៃរដ្ឋបាល ជាញឹកញយ រដ្ឋបាលមិនមានចាត់វិធានការអ្វីលើមន្ត្រីនោះទេ ដោយហេតុថា មន្ត្រីជាន់ខ្ពស់ដែលជាចៅហ្វាយនាយរបស់មន្ត្រីនោះមានការពាក់ព័ន្ធដោយផ្ទាល់នៅក្នុងអំពើពុករលួយ ឬចៅហ្វាយនាយនោះមិនចាត់ទុកអំពើពុករលួយនោះថាជាអាទិភាពឡើយ (រដ្ឋាភិបាលតង់ហ្សានី ឆ្នាំ ១៩៩៦)។

ដើម្បីលើកយកមកដោះស្រាយបញ្ហា ដែលសាធារណជនបានយល់ឃើញថាថ្នាក់ដឹកនាំខ្វះសីលធម៌ ច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយ PLCE ចែងអំពីការបង្កើតក្រមសីលធម៌សម្រាប់ថ្នាក់ដឹកនាំសាធារណៈ ហើយនឹងចែងអំពីការបង្កើតគណៈកម្មការសីលធម៌សម្រាប់ថ្នាក់ដឹកនាំសាធារណៈ និងការិយាល័យស្នងការសីលធម៌។ យ៉ាងណាក៏ដោយ ស្នងការនេះត្រូវបានកម្រិតឱ្យធ្វើការស៊ើបអង្កេតតែលើបណ្តឹងណាដែលបានទទួលពីបុគ្គលដែលស្គាល់អត្តសញ្ញាណ និងពីរបាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយពត៌មានតែប៉ុណ្ណោះ។ ស្នងការមិនអាចធ្វើការស៊ើបអង្កេតលើបណ្តឹងអនាមិកទេ។ ហើយក្នុងការស៊ើបអង្កេតនេះ លេខាធិការដ្ឋានត្រូវពឹងពាក់ផងដែរ លើប៉ូលីស និងនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB។ លើសពីនេះទៀត ដរាបណាមិនមានការកំណត់ស្តង់ដារច្បាស់លាស់ និងមិនមានចែងច្បាស់លាស់អំពីទណ្ឌកម្មចំពោះការរំលោភបំពានទេនោះ ភារកិច្ចរបស់ស្នងការត្រូវស្ថិតក្នុងកម្រិតមួយយ៉ាងចង្អៀត ។ ឧបសគ្គមួយថែមទៀតចំពោះដំណើរការដ៏មានប្រសិទ្ធិភាពនៃលេខាធិការដ្ឋាន គឺសេចក្តីថ្លែងការណ៍របស់អគ្គមេធាវី ដែលថាសេចក្តីប្រកាសជាសាធារណៈអំពីការមានបានភោគទ្រព្យ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គលក្នុងភាពជាឯកជន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ក្នុងការប្រតិបត្តិតាមសេចក្តីថ្លែងរបស់អគ្គមេធាវីនេះ ការប្រកាសទ្រព្យត្រូវដាក់ជូនដោយផ្ទាល់ទៅស្នងការសីលធម៌តែប៉ុណ្ណោះ។ ដើម្បីឱ្យបានសិទ្ធិប្រើប្រាស់សេចក្តីប្រកាសទាំងនោះ ត្រូវតែមានការអនុញ្ញាតពិសេស ហើយការអនុញ្ញាតពិសេសនេះកម្រនឹងផ្តល់ឱ្យណាស់។ ហើយសូម្បីតែបានទទួលការអនុញ្ញាតក៏ដោយ ក៏ព័ត៌មានដែលបានទទួលនោះមិនអាចយកទៅប្រកាសផ្សាយជាសាធារណៈបានទេ ព្រោះវាខុសច្បាប់។ រហូតមកដល់ពេលនេះ មិនមានអ្នកណាម្នាក់ត្រូវបានកាត់សេចក្តីឱ្យជាប់ទោសពីបទក្លែងបន្លំសេចក្តីប្រកាសទ្រព្យ ឬពីការមានភោគទ្រព្យយ៉ាងលើសលុបនោះទេ។

អំពើពុករលួយនៃមន្ត្រីថ្នាក់ទាបក៏គឺដោយសារប្រាក់ខែតិចពេក ហើយបញ្ហានេះគឺជារឿងមួយ ដែលគណៈកម្មការ Warioba បានទទួលស្គាល់ថាជាបញ្ហាមួយរបស់ខ្លួនផងដែរ។ ប៉ុន្តែ គណៈកម្មការសន្និដ្ឋានថា ប្រការនេះមិនត្រូវមើលឃើញថាជាកត្តាចម្បងចំពោះអំពើពុករលួយនោះទេ ដោយហេតុថា អ្នកដែលពុករលួយបំផុតនោះគឺជាមន្ត្រីថ្នាក់ខ្ពស់នៅក្នុងរដ្ឋាភិបាល និងដែលបានទទួលប្រាក់បៀវត្សច្រើនរួចទៅហើយ។ ដូច្នេះ ការតម្លើងប្រាក់បៀវត្ស គឺគ្រាន់តែជួយអ្នកទាំងនោះឱ្យលើកកម្ពស់តម្លៃអំពើពុករលួយតែប៉ុណ្ណោះ។ អំពើពុករលួយនេះ ដែលមានលក្ខណៈទូទៅក្នុងចំណោមមន្ត្រីថ្នាក់ខ្ពស់នៃសេវាសាធារណៈ ត្រូវបានលើកឡើងផងដែរនៅក្នុងយុទ្ធសាស្រ្តជាតិប្រឆាំងអំពើពុករលួយ និងផែនការសកម្មភាព។ យ៉ាងណាក៏ដោយ យុទ្ធសាស្ត្រនេះចែងថា ការតម្លើងប្រាក់បៀវត្ស និងការបង្កើនគ្រឿងលើកទឹកចិត្តសម្រាប់មន្ត្រីសធារណៈ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ ក៏ប៉ុន្តែ ជាទូទៅ គឺមិនបានដោះស្រាយបញ្ហាអំពើពុករលួយថ្នាក់លើទេ។

នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ខ្លួនឯងក៏មិនសូវមានប្រសិទ្ធភាពដែរ ដោយសារបានធ្វើបណ្តឹងអាជ្ញារឿងពុករលួយតែមួយចំនួនតូចប៉ុណ្ណោះ ហើយចំនួនរឿងដែលត្រូវបានកាត់ជាប់ទោសនោះរឹតតែតិចទៅទៀត។ បញ្ហាមួយ គឺបញ្ហារៀបចំរចនាសម្ព័ន្ធរបស់នាយកដ្ឋានពោលគឺដោយហេតុថានាយកដ្ឋានទប់ស្កាត់អំពើពុករលួយ គឺជាផ្នែកមួយនៃកិច្ចការរបស់ការិយាល័យប្រធានាធិបតី ដូច្នេះគឺវាខ្វះឯករាជភាពដោយហេតុថា នាយកដ្ឋាននេះស្ថិតនៅក្រោមសេចក្តីណែនាំនៃការិយាល័យប្រធានាធិបតី។ អគ្គនាយកនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយត្រូវបានតែងតាំងដោយប្រធានាធិបតី និងត្រូវទទួលខុសត្រូវចំពោះប្រធានាធិបតី។ ដោយមិនមានកំណត់រយៈពេលអាណត្តិច្បាស់លាស់អគ្គនាយកត្រូវបម្រើការតាមឆន្ទៈរបស់ប្រធានាធិបតី ដែលជាមនុស្សតែម្នាក់គត់ ដែលអាចដក ឬដាក់ទណ្ឌកម្មអគ្គនាយក។ របាយការណ៍សម្ងាត់ត្រូវបញ្ជូនទៅប្រធានាធិបតី។ ហេតុដូច្នេះហើយបានជា នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB មិនស្ថិតនៅក្នុងស្ថានភាពមួយ ដែលអាចធ្វើការ

ឱ្យបានម៉ឺងម៉ាត់ចំពោះអំពើពុករលួយ ដែលពាក់ព័ន្ធនឹងជនល្មើស ដែលជិតដឹតជាមួយប្រធានាធិបតី ។

លើសពីនេះទៀត គណៈកម្មាធិការត្រួតពិនិត្យនិងវាយតម្លៃ ដែលត្រួតមើលការបំពេញការងាររបស់នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ត្រូវបានដឹកនាំដោយលេខាធិការនាយកនៃការិយាល័យប្រធានាធិបតី។ ការរកឃើញរបស់គណៈកម្មាធិការនេះ មិនត្រូវបានប្រកាសផ្សាយទេ។ បន្ថែមលើនេះទៀត ទាំងសភា និងគណៈកម្មាធិការពលរដ្ឋ មិនមានអំណាចឃ្លាំមើលជាផ្លូវការលើនាយកដ្ឋានទប់ស្កាត់អំពើពុករលួយនោះទេ។ ទាំងនេះហើយគឺជាកត្តាដែលទំនងជាបណ្តាលឱ្យសាធារណជនមិនទុកចិត្តលើនាយកដ្ឋាននេះ។ អ្នកសង្កេតការណ៍ខ្លះបានលើកហេតុផលមកសំអាងថា នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB មិនបានទទួលការគាំទ្រ និងការជឿទុកចិត្តពីសាធារណជន ក្នុងការបំពេញការងារបានដោយឯករាជ្យនោះទេ ដោយសារតែការភ័យខ្លាច ភាពព្រងើយកន្តើយ និងការខ្វះការយល់ដឹងអំពីបេសកកម្មរបស់ PCB។ ថ្វីបើមានការកែប្រែក្នុងប៉ុន្មានឆ្នាំនេះ នៅក្នុងការបង្កើតរចនាសម្ព័ន្ធនៃក្រុមប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏មុខងារ និងការទទួលខុសត្រូវនៃនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ស្ថិតនៅតែដដែល ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើពុករលួយឆ្នាំ ១៩៧១។

ធាតុផ្សំសំខាន់មួយនៃទីភ្នាក់ងារប្រឆាំងនឹងអំពើពុករលួយ PCB គឺត្រូវមានសមត្ថភាពក្នុងការស្រាវជ្រាវអំពីកម្រិត និងមូលហេតុនៃអំពើពុករលួយ។ ផ្នែកស្រាវជ្រាវនៃការិយាល័យស្រាវជ្រាវ ត្រួតពិនិត្យ និងស្ថិតិនៅក្នុងនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ធ្វើការស្រាវជ្រាវអំពីគោលនយោបាយផ្សេងៗ ដើម្បីធានាមិនឱ្យមានចន្លោះសម្រាប់ប្រព្រឹត្តពុករលួយ និងស្រាវជ្រាវអំពីសេវាដែលស្ថាប័នផ្សេងៗបានផ្តល់ឱ្យដើម្បីរកឱ្យឃើញភាពចន្លោះប្រហោង ដែលបណ្តាលឱ្យមានអំពើពុករលួយ ស្រាវជ្រាវអំពីប្រាក់បៀវត្សរបស់មន្ត្រីសាធារណៈ និយោជិតនៃគណបក្សនយោបាយ ផ្នែករដ្ឋប្រតិព័ទ្ធ និងផ្នែកឯកជន ស្រាវជ្រាវអំពីច្បាប់ស្តីពីសេវាសាធារណៈ និងបទបញ្ជា ដើម្បីកំណត់ថាតើឧបករណ៍ច្បាប់បែបនេះសមរម្យ និងស្របតាមការប្រព្រឹត្តិរបស់និយោជិតដែរឬទេ និងស្រាវជ្រាវអំពីវិធីប្រយុទ្ធនឹងអំពើពុករលួយ ដែលប្រទេសផ្សេងទៀតបានអនុម័តប្រើ។

ការរំខានមួយថែមទៀតចំពោះប្រសិទ្ធភាពរបស់នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB គឺសម្ព័ន្ធភាពអន់ថយ ដែលនាយកដ្ឋាននេះមានជាមួយនឹងទីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ជាពិសេសគឺអង្គតុលាការ។ អង្គតុលាការខ្លួនឯងផ្ទាល់ក៏មានភាពទន់ខ្សោយ ដែលតម្រូវឱ្យមានធនធាន និងសមត្ថភាពច្រើនឡើងៗ។ ដើម្បីឱ្យការប្រយុទ្ធនឹងអំពើពុករលួយមានប្រសិទ្ធភាព និងដើម្បីអាចអនុវត្តយុទ្ធសាស្ត្រជាតិប្រឆាំងនឹងអំពើពុករលួយ និងផែនការសកម្មភាពបាន នាយកដ្ឋានទប់ស្កាត់អំពើពុករលួយ PCB ត្រូវតែមានសម្ព័ន្ធភាពឱ្យខ្លាំងថែមទៀតជាមួយរដ្ឋាភិបាលព្រមទាំងសង្គមស៊ីវិល និងផ្នែកឯកជន។ បើគ្រាន់តែពង្រឹងនាយកដ្ឋានទប់ស្កាត់អំពើពុករលួយ និងអនុវត្តយុទ្ធសាស្ត្រតែប៉ុណ្ណឹង មិនគ្រប់គ្រាន់ទេ។ ត្រូវមានកំណែទម្រង់ផ្សេងៗផងដែរ ដូចជា កំណែទម្រង់រដ្ឋបាលមូលដ្ឋាន កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ផ្នែកសាធារណៈ ដែលទាំងអស់នេះសុទ្ធតែដើរតួនាទីសំខាន់ក្នុងការប្រយុទ្ធនឹងអំពើពុករលួយ។ បន្ថែមលើនេះទៀត ត្រូវឱ្យមានការកែប្រែវប្បធម៌ និងឥរិយាបទនៅក្នុងការដឹកនាំ និងត្រូវតែមានឆន្ទៈនយោបាយពីថ្នាក់កំពូលផងដែរ ក្នុងការប្រយុទ្ធនឹងអំពើពុករលួយ។

## ប្រភព


- រដ្ឋាភិបាលតង់ហ្សានី ឆ្នាំ ១៩៩៦: របាយការណ៍របស់គណៈកម្មការអំពីស្ថានភាពនៃអំពើពុករលួយ នៅក្នុងប្រទេស។
- រដ្ឋាភិបាលតង់ហ្សានី ឆ្នាំ ១៩៩៩: យុទ្ធសាស្ត្រជាតិប្រឆាំងនឹងអំពើពុករលួយ និងផែនការសកម្មភាព សម្រាប់តង់ហ្សានី។
- Kpundeh, S. និង Levy, B.(eds) ២០០៤: ការកសាងសមត្ថភាពរដ្ឋនៅអាហ្វ្រិកៈលំនាំដោះស្រាយថ្មី មេរៀនដែលទើបនឹងលេចឡើង។


ព័ត៌មានបន្ថែមប្រមូលផងដែរពីប្រព័ន្ធ website របស់ស្ថាប័នផ្សេងៗដែលបានរៀបរាប់ខាងលើ។

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
ក្រុមអនុវត្តន៍អភិបាលកិច្ចបែបលទ្ធិប្រជាធិបតេយ្យ
មជ្ឈមណ្ឌលប្រចាំតំបន់របស់អង្គការយូអិនឌីភី នៅទីក្រុងបាងកក
http://regionalcentrebangkok.undp.or.th
UN Service Building
Rajdamnern Nok Avenue
ទីក្រុងបាងកក ១០២០០ ប្រទេសថៃ